

# ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង

## តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម

ប្រែសម្រួលជាភាសាខ្មែរដោយ ម៉ែន ពិចិត្រ

ឌី ខាំបូលី

គ្រីស្តូហ្វ័រ ឡៀរីង

មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយ

ក្រសួងទេសចរណ៍, ឆ្នាំ២០១៤

# ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង

## តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម

**ប្រែសម្រួលជាភាសាខ្មែរដោយ ម៉ែន ពិចិត្រ**

**ឌី ខាំបូលី**
**គ្រីស្តូហ្វ័រ ឌឿរីង**

មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយ
ក្រសួងទេសចរណ៍
ឆ្នាំ២០១៤

រក្សាសិទ្ធិគ្រប់បែបយ៉ាង ឆ្នាំ២០១៤ ដោយវិទ្យាស្ថានស្ទីករីត / មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងទេសចរណ៍

រក្សាសិទ្ធិគ្រប់បែបយ៉ាង មិនមានផ្នែកណាមួយនៃសៀវភៅនេះត្រូវបានយកទៅសរសេរ ឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ ឬមធ្យោបាយបែបណាក៏ដោយ ដែលរួមមានការថតចម្លង ការកត់ត្រា ឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកបោះពុម្ពផ្សាយបានឡើយ ។

វិទ្យាស្ថានស្ទីករីត / មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រអប់សំបុត្រលេខ ១១១០, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥
ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨
អ៊ីម៉ែល : dccam@online.com.kh
គេហទំព័រ : www.dccam.org, www.cambodiatribunal.org ឬ www.cambodiasri.org

គំនិតរចនាសៀវភៅ គំនិតសិល្បៈ ឆ្នាំ២០១៤ ដោយ ឆាំង យុ
ការជ្រើសរើសរូបថត និងចំណងជើងរូបថត ឆ្នាំ២០១៤
ដោយ គ្រីស្តូហ្វ័រ ឌៀរីង និង ឌី ខាំបូលី
រចនាក្រាហ្វិក ឆ្នាំ២០១៤ គ្របមុខសៀវភៅដោយ ក្រុមហ៊ុនឌីហ្សាញ អ៊ីវ៉ាន វ៉ុង និងអត្ថបទដោយ ដែម វ៉ែលសឺស្តី ក្រុមហ៊ុនឌីហ្សាញ Ludlow6

រចនាក្រាហ្វិកជាភាសាខ្មែរដោយ គឹម សុវណ្ណដានី
បកប្រែជាភាសាខ្មែរដោយ ម៉ែន ពិចិត្រ

កម្ពុជា : ការអប់រំពីអំពើប្រល័យពូជសាសន៍គឺជាការទប់ស្កាត់អំពើប្រល័យពូជសាសន៍
បោះពុម្ពផ្សាយនៅកម្ពុជា ឆ្នាំ២០១៤
អំណះអំណាង

ទស្សនៈនៅក្នុងសៀវភៅនេះគឺជារបស់អ្នកនិពន្ធផ្ទាល់ និងមិនបានបង្ហាញពីការយល់ឃើញរបស់ទីភ្នាក់ងារស៊ុីសដើម្បីសហប្រតិបត្តិការ និងអភិវឌ្ឍន៍ វិទ្យាស្ថានស្ទីករីត ឬមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។

ជំនួយទទ្រង់ផ្នែកហិរញ្ញវត្ថុសម្រាប់គម្រោងនេះត្រូវបានផ្តល់ ដោយសប្បុរសពីទីភ្នាក់ងារស៊ុីស ដើម្បីសហប្រតិបត្តិការ និងអភិវឌ្ឍន៍ ។

# មាតិកា


អារម្ភកថា ..... ១

សេចក្តីថ្លែងអំណរគុណ ..... ៣

សេចក្តីផ្តើម ..... ៩

ជំពូក១ ប្រវត្តិសាស្ត្រដំបូងនៃតំបន់អន្លង់វែង ..... ១៣

ជំពូក២ ការកកើតនៃចលនាកុម្មុយនីស្ត និងការមកដល់ជាលើកដំបូងរបស់ខ្មែរក្រហមនៅអន្លង់វែង ..... ២៧

ជំពូក៣ អន្លង់វែងនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ..... ៤១

ជំពូក៤ បរាជ័យ និងការរត់គេចខ្លួនរបស់ខ្មែរក្រហម ..... ៥១

ជំពូក៥ អន្លង់វែងនៅក្រោមការគ្រប់គ្រងរបស់វៀតណាម ..... ៦៣

ជំពូក៦ ការរៀបចំកងទ័ពឡើងវិញរបស់ខ្មែរក្រហម ..... ៦៩

ជំពូក៧ សង្គ្រាមឈ្លប និងសង្គ្រាមប្រជាជន ..... ៧៧

ជំពូក៨ ជីវិតនៅលើភ្នំដងរែក ..... ៨៩

ជំពូក៩ អន្លង់វែង : តំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម ..... ១០៨

ជំពូក១០ កេរដំណែលរបស់ តាម៉ុក ..... ១២៨

ជំពូក១១ ចំណុចចាប់ផ្តើមនៃទីបញ្ចប់ ..... ១៤៨

ជំពូក១២ ជម្លោះរវាង ប៉ុល ពត និង តាម៉ុក ..... ១៥២

ជំពូក១៣ ការចាប់ខ្លួន និងការកាត់ទោស ប៉ុល ពត ..... ១៦១

ជំពូក១៤ សមាហរណកម្មចូលទៅក្នុងរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៩៨ ..... ១៦៨

ជំពូក១៥ ពិនិត្យមើលតំបន់អន្លង់វែងឡើងវិញ ..... ១៨៩

ជំពូក១៦ រឿងរ៉ាវនៅអន្លង់វែង ..... ២០៨

អវសានកថា ..... ២១៨

*រូបភាពក្របមុខ ៖ ពិធីរៀបការនៅអន្លង់វែងកាលពីដើមទសវត្សរ៍ឆ្នាំ១៩៩០* ....២២០
*ជីវប្រវត្តិអ្នកនិពន្ធ* ....២២២
*បំណាងដើមរូបថត* ....២២៤
*កំណត់សម្គាល់* ....២៣១

# អារម្ភកថា

សៀវភៅប្រៀបបានទៅនឹងមនុស្ស នៅក្នុងន័យមួយដែលថា ដាញឹកញាប់ យើងតែងតែផ្សារភ្ជាប់សៀវភៅទៅនឹងកន្លែងដាក់លាក់មួយ ។ ឧទាហរណ៍ សៀវភៅសាសនាមានការពេញនិយមនៅកន្លែងគោរពប្រតិបត្តិសាសនា សៀវភៅសិក្សាក្រាស់ៗស្ថិតនៅក្នុងសាលារៀន និងបណ្ណាល័យ ហើយសៀវភៅប្រលោមលោកខ្លីៗ ជាទូទៅស្ថិតនៅជាមួយអ្នកធ្វើការក្នុងការិយាល័យ និងអ្នកធ្វើដំណើរសម្រាប់អានពេលទំនេរពីកិច្ចការ ឬពេលធ្វើដំណើរ ។ សៀវភៅផ្តល់ព័ត៌មានបណ្តុះគំនិត និងជំរុញលើកទឹកចិត្តអ្នកអាន ។ សៀវភៅគឺជាគ្រាប់ពូជនៃក្តីស្រមៃរបស់យើង ដែលជាមេរៀនមួយដែលយើងបានបំភ្លេច ខណៈពេលបច្ចេកវិទ្យាទំនើបៗកំពុងរីកដុះដាលគ្មានទីបញ្ចប់ ។ យល់ឃើញថាវាជារឿងល្អមួយដែល អ្នកនិពន្ធយកស្ថានភាពនៃទីកន្លែងមកពិចារណា ជាពិសេសនៅពេលដែលអ្នកនិពន្ធពិតជាចង់ផ្សារភ្ជាប់ការងាររបស់ខ្លួនទៅនឹងអ្នកអានគោលដៅ ។

ស្រមៃឃើញ មនុស្សកំពុងតែអានសៀវភៅនេះនៅជិតទីតាំងប្រវត្តិសាស្ត្រ ឬនៅក្នុងថ្នាក់រៀន មិនឆ្ងាយប៉ុន្មានពីតំបន់អន្លង់វែង និងប្រជាជនដែលរស់នៅក្នុងតំបន់នេះ ។ ទីតាំងនេះមានលក្ខណៈសមស្រប ពីព្រោះអ្នកនិពន្ធមានចេតនាផ្តោតទៅលើភាពជាមនុស្សរបស់ចលនាខ្មែរក្រហម ។

ការនិពន្ធដែលផ្តោតទៅលើមនុស្ស ជាជាងក្រុមនៃមនុស្ស ស្ថានភាព និងព្រឹត្តិការណ៍ មានគុណសម្បត្តិ និងគុណវិបត្តិ ។ គុណសម្បត្តិនៃការនិពន្ធបែបនេះ គឺថាវាបានបង្ហាញអំពីភាពស្មុគស្មាញនៃមនសិការរបស់មនុស្ស នៅក្នុងអំឡុងពេលនៃសង្គ្រាម អំពើឃោរឃៅ និងភាពចលាចលនៅក្នុងសង្គម ។ គុណវិបត្តិនៃវិធីសាស្ត្រនិពន្ធ បែបនេះគឺថាយើងត្រូវបានដាក់ឲ្យប្រឈមទៅនឹងការពិតដ៏លំបាកមួយ ដែលថាជនដៃដល់ក៏មានមុខមាត់ដូចយើងដែរ ហើយយើងត្រូវតែធ្វើការជ្រើសរើសយកជម្រើសមួយ ។

អំពើឧក្រិដ្ឋកម្មទាំងអស់ត្រូវបានប្រព្រឹត្តឡើងដោយមនុស្ស ហើយវាប្រហែលជាលំបាកសម្រាប់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មនេះ ពីព្រោះអំពើនេះហួសអំពីអ្វីដែលជនរងគ្រោះអាចស្រមៃឃើញ ។ ជាធម្មជាតិ ជនរងគ្រោះចង់កាត់ផ្តាច់ទំនាក់ទំនងពីជនដៃដល់ អ្នកសមគំនិត និងក្រុមគ្រួសាររបស់ជនដៃដល់ចេញពីសង្គមទាំងមូល ។ ការឆ្លើយ

តបបែបនេះ ហាក់ដូចជាការផ្ដល់តម្លៃដ៏អាក្រក់មួយ ដែលសង្គមត្រូវតែសងត្រឡប់មកវិញ នៅពេលធ្វើដំណើរទៅមុខ ។ ទោះជាយ៉ាងនេះក្ដី នៅក្នុងដំណើរវែងឆ្ងាយទៅមុខ ទង្វើបែបនេះមិនមែនជាចម្លើយសម្រាប់សង្គមកម្ពុជាទេ ។ ដើម្បីឲ្យប្រទេសកម្ពុជាធ្វើដំណើរទៅមុខយើងត្រូវប្រឈមមុខទៅនឹងការពិតដ៏លំបាកដែលថា ខ្មែរក្រហមក៏ជាមនុស្សដូចយើងគ្រប់គ្នាដែរ ។

ប្រសិនបើប្រវត្តិសាស្រ្ត នឹងត្រូវក្លាយទៅជាមគ្គុទេសក៍ប្រកបដោយប្រសិទ្ធភាព និងពិតប្រាកដមួយសម្រាប់អនាគត យើងត្រូវតែទទួលស្គាល់តម្រូវការដែលគ្មានទីបញ្ចប់នៅក្នុងការសិក្សាពីគ្រប់ទិដ្ឋភាពទាំងអស់ នៃអតីតកាលរបស់យើងរួមទាំងអតីតកាលប្រកបដោយភាពស្មុគស្មាញនិងពិបាកបកស្រាយផង ។ យុត្តិធម៌ នឹងមិនអាចកើតមានឡើងបានទេ នៅក្នុងស្ថានភាពដែលគ្មានការយល់ដឹង ហើយការអត់ឱន និងការផ្សះផ្សានឹងកើតមានពិតប្រាកដ ប្រសិនបើយើងសុខចិត្តទទួលស្គាល់គ្នាជាមនុស្សទៅវិញទៅមក ។

សៀវភៅ “ប្រវត្តិសាស្រ្តតំបន់អន្លង់វែង” នេះ នឹងចូលរួមចំណែកដើម្បីសម្រេចឲ្យបាននូវស្មារតីទាំងនេះ ។ ប៉ុន្តែសៀវភៅនេះគ្រាន់តែជាចំណែកតូចមួយ នៅក្នុងការតស៊ូស្វែងរកយុត្តិធម៌ទូលំទូលាយមួយនៅក្នុងប្រទេសកម្ពុជា ។ យើងត្រូវការការចាប់ផ្ដើមដើម្បីស្វែងរកទីបញ្ចប់មួយប្រសិនបើមាន ។ ទោះបីជាតំបន់អន្លង់វែងមានសន្តិភាពជាង ១៥ឆ្នាំហើយយ៉ាងណាក៏ដោយ ក៏យើងត្រូវចងចាំថា សន្តិភាព និងយុត្តិធម៌ត្រូវដើរទន្ទឹមគ្នាដើម្បីឲ្យសង្គមមួយធ្វើដំណើរទៅមុខ ។ ជោគវាសនារបស់ប្រទេសកម្ពុជាអាស្រ័យទៅលើការទទួលស្គាល់ និងការឲ្យតម្លៃទៅលើការពិតនេះ ក្នុងនាមជាបុគ្គល ជាសហគមន៍ និងជាប្រទេសមួយទាំងមូល ។

ឯកឧត្តម បណ្ឌិត ថោង ខុន
រដ្ឋមន្ត្រីក្រសួងទេសចរណ៍
ប្រធានគណៈកម្មការអន្តរក្រសួង
ដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្រ្តអន្លង់វែង

# សេចក្តីថ្លែងអំណរគុណ

ការស្រាវជ្រាវ ការសរសេរ និងការបោះពុម្ពសៀវភៅនេះនឹងមិនអាចសម្រេចបានទេ ប្រសិនបើគ្មានការជំរុញលើកទឹកចិត្ត ជំនួយ និងយោបល់ពីសំណាក់បុគ្គល និងអង្គភាពជាច្រើន ។ ជាបឋម យើង សូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការស៊ុីស ដែលបានផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ លើការស្រាវជ្រាវ និងការបោះពុម្ពសៀវភៅនេះ ។ យើងអាចធ្វើការសិក្សាស្រាវជ្រាវបានស៊ីជម្រៅទៅលើឯកសារបទសម្ភាសជាមួយប្រជាជន និងការធ្វើដំណើរទៅកាន់តំបន់នានានៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងប្រទេសថៃ ដោយសារតែជំនួយរបស់ភ្នាក់ងារសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការស៊ុីស ។

យើង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ លោក ឆាំង យុ ដែលជាស្ថាបនិកវិទ្យាស្ថាន ស្លឹករឹត និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានផ្តួចផ្តើមឲ្យមានការសិក្សាស្រាវជ្រាវ និងរៀបចំសៀវភៅនេះឡើង និងថែមទាំងបានផ្តល់នូវទិសដៅ និងអនុសាសន៍ដ៏មានតម្លៃជាច្រើននៅគ្រប់ដំណាក់កាលទាំងអស់នៃគម្រោងនេះ ។ លោក ឆាំង យុ បានចង្អុលបង្ហាញប្រាប់យើង អំពីប្រភពឯកសារដើមដែលត្រូវបានយកមកធ្វើជាឯកសារយោងនៅក្នុងសៀវភៅនេះ និងបានផ្តល់ដំបូន្មានល្អៗជាច្រើន ដែលធ្វើឲ្យមាតិកា និងការរចនាសម្ព័ន្ធនៅក្នុងសៀវភៅនេះកាន់តែមានភាពល្អប្រសើរឡើង ។ លោក គឺជាបុគ្គលដ៏សំខាន់នៃគម្រោងនេះតាំងពីការចាប់ផ្តើមរហូតដល់ចុងបញ្ចប់នៃការស្រាវជ្រាវ តែងនិពន្ធ និងបោះពុម្ព ។ យើង ក៏សូមថ្លែងអំណរគុណដល់ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសឯកឧត្តមរដ្ឋមន្ត្រី ថោង ខុន និងគណៈកម្មាការអន្តរក្រសួងសម្រាប់ការអភិវឌ្ឍតំបន់អន្លង់វែង ។

ទេសចរណ៍មិនមែនផ្តោតសំខាន់តែទៅលើការស្គាល់បុគ្គលតែម្នាក់នោះទេ ប៉ុន្តែថែមទាំងការស្វែងយល់ពីប្រជាជន ធនធាន និងបរិស្ថានដែលរំលេចនូវបទពិសោធនៃទេសចរណ៍ ។ ដោយហេតុនេះហើយក្រសួងទេសចរណ៍បានទទួលស្គាល់ថា ការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រ គឺជាជំហានមួយដ៏សំខាន់ក្នុងការជំរុញឲ្យមានការធ្វើដំណើរមកកាន់តំបន់នេះ និងទទួលស្គាល់ថា រឿងរ៉ាវដែលបានកើតឡើងនៅក្នុងតំបន់នេះ គឺជាផ្នែក

មួយនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ។ សៀវភៅមួយក្បាលនេះគ្រាន់តែជាចំណែកមួយ នៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការថែរក្សា និងឲ្យតម្លៃទៅលើប្រវត្តិសាស្ត្រដ៏ពិសេសនៃតំបន់នេះ ។ យើង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងទេសចរណ៍ ដែលបានគាំទ្រកិច្ចការនេះ ។

ទន្ទឹមនឹងនេះដែរ ការបោះពុម្ពផ្សាយសៀវភៅនេះ នឹងមិនអាចសម្រេចចេញជារូបរាងបានទេ ប្រសិនបើគ្មានការចូលរួមចែករំលែកព័ត៌មានប្រកបដោយភាពសប្បុរស និងស្មោះត្រង់ ពីសំណាក់ប្រជាជនដែលរស់នៅក្នុងតំបន់អន្លង់វែង ត្រពាំងប្រាសាទ និងអតីតតំបន់កាន់កាប់របស់ខ្មែរក្រហមដទៃទៀត ។ ប្រជាជនប្រមាណ៦០០នាក់ ដែលរស់នៅតំបន់អន្លង់វែង ត្រពាំងប្រាសាទ និងអតីតតំបន់កាន់កាប់ដទៃទៀត បានចំណាយពេលវេលាដ៏មានតម្លៃរបស់ខ្លួន ក្នុងការជួយផ្តល់ព័ត៌មានដល់ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈការផ្តល់បទសម្ភាសផ្ទាល់មាត់ និងការបញ្ជាក់បន្ថែមជាច្រើនលើកច្រើនសា ។ អ្នកផ្តល់បទសម្ភាសមួយចំនួនបានចំណាយពេលវេលាច្រើនជាង៥ម៉ោងរៀបរាប់រឿងរ៉ាវអតីតកាលរបស់ខ្លួន ។ អ្នកផ្តល់បទសម្ភាសទាំងនេះ បានរៀបរាប់រឿងរ៉ាវរបស់ខ្លួន តាំងពីពេលដែលខ្លួនចូលរួមបដិវត្តន៍ខ្មែរក្រហមនៅដើមឆ្នាំ ១៩៧០ រហូតដល់ការតស៊ូនៅលើភ្នំដងរែក និងការចូលសមាហរណកម្មនៅចុងឆ្នាំ ១៩៩៨ ក៏ដូចជាជីវិតរស់នៅនាពេលបច្ចុប្បន្ន ។ រឿងរ៉ាវរបស់ប្រជាជនទាំងនោះមានតម្លៃមិនអាចកាត់ថ្លៃបាន នៅក្នុងការសម្រេចបានជោគជ័យនៃការស្រាវជ្រាវសៀវភៅនេះ ។ ជាងនេះទៅទៀត យើង សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំនៅតំបន់អន្លង់វែង និងត្រពាំងប្រាសាទ ដែលរួមមានគណៈអភិបាលស្រុក ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ ដែលបានអនុញ្ញាតឲ្យក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការសម្ភាស និងបានជួយទ្រទ្រង់ផ្នែករដ្ឋបាល ដែលបានសម្រួលដល់ទំនាក់ទំនងគ្នារវាងក្រុមស្រាវជ្រាវ និងប្រជាជន ។យើង សូមថ្លែងអំណរគុណជាពិសេសដល់លោក យឹម ផាន់ណា អភិបាលនៃគណៈអភិបាលស្រុកអន្លង់វែង ដែលមិនត្រឹមតែបានអនុញ្ញាតឲ្យមានការស្រាវជ្រាវប៉ុណ្ណោះទេ ថែមទាំងបានចូលរួមផ្តល់បទសម្ភាសព្រមទាំងបានផ្តល់ដំបូន្មានជាច្រើនដល់ក្រុមស្រាវជ្រាវរបស់យើង ។

អត្ថបទនៅក្នុងសៀវភៅនេះត្រូវបានត្រួតពិនិត្យដោយ លោកសាស្ត្រាចារ្យ ដេវីដ

ឆេនដល័រ នៃសាកលវិទ្យាល័យម៉ូណាស ប្រទេសអូស្ត្រាលី និងជាប្រវត្តិវិទូឈានមុខគេមួយផ្នែកប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។

ការស្រាវជ្រាវរបស់យើងបានជំរុញឲ្យយើងពង្រីកការសិក្សាទៅដល់ប្រទេសថៃ ដោយយើង បានធ្វើសម្ភាសជាមួយប្រជាជនថៃមួយចំនួននៅក្នុងប្រទេសថៃ ។ យើងសូមថ្លែងអំណរគុណដល់ប្រជាជនដែលរស់នៅភូមិស្រែប្រៃ ដែលបានចំណាយពេលវេលាក្នុងការផ្តល់បទសម្ភាស ។ រឿងរ៉ាវមួយចំនួនរបស់ប្រជាជនទាំងនោះត្រូវបានបញ្ចូលទៅក្នុងសៀវភៅនេះ ដែលបានឆ្លុះបញ្ចាំងឲ្យឃើញអំពីទំនាក់ទំនងឆ្លងប្រទេសរវាងភូមិខ្មែរ និងភូមិថៃ ដែលបានកើតឡើងអស់រយៈពេលជាច្រើនជំនាន់ និងបន្តរហូតមកដល់សព្វថ្ងៃនេះ ។

សៀវភៅនេះក៏នឹងមិនអាចលេចចេញជារូបរាងបានទេ ប្រសិនបើគ្មានការជួយជ្រោមជ្រែងពីបណ្ឌិត ផាត កុសល និងលោក ឡុង ដានី ។ បណ្ឌិត ផាត កុសល គឺជាជំនួយការសាស្ត្រាចារ្យផ្នែក វិទ្យាសាស្ត្រនយោបាយ នៅមហាវិទ្យាល័យប្រ៊ុកលីន នៃសាកលវិទ្យាល័យក្រុងញ៉ូវយ៉ក ។ លោកបណ្ឌិតបានសម្ភាសប្រជាជនមួយចំនួននៅតំបន់នេះ និងបានផ្តល់រូបថតមួយចំនួនដល់យើង ដែលត្រូវបានបញ្ចូលទៅក្នុងសៀវភៅនេះ ។ លោក ឡុង ដានី គឺជាប្រធានក្រុមគម្រោងជំរុញឲ្យមានការទទួលខុសត្រូវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាប្រធានក្រុមដ៏ឆ្នើមមួយរូបនៅក្នុងគម្រោងចងក្រងសៀវភៅនេះ ។ ចំណេះដឹងរបស់លោកអំពីតំបន់នេះ និងចំណេះដឹងអំពីប្រជាជននៅក្នុងតំបន់អន្លង់វែង បានជួយសម្រួលដល់ការសម្ភាសរបស់ក្រុមការងារ ។ មិនតែប៉ុណ្ណោះ លោក ឡុង ដានី គឺជាធនធានដ៏សំខាន់សម្រាប់ព័ត៌មានស៊ីជម្រៅទាំងឡាយអំពីតំបន់អន្លង់វែង ។

ជាចុងបញ្ចប់ យើង សូមថ្លែងអំណរគុណចំពោះអ្នកបកប្រែ អូនរឿន អូនអន (ហៅតៃ) និង ស៊ីហ្សានី មី ក៏ដូចជាក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមមាន វ៉ាន់ថាន់ ពៅដារ៉ា, អេង កុកថាយ, សុខ វណ្ណៈ, ម៉ែន ពិចិត្រ, ម៉ម សុវណ្ណ, ហ៊ិន សុធានី, គីម ស្រួយ សុខវិសាល, និង រី លក្ខិណា ។ តៃ គឺជាអ្នកបកប្រែពីភាសាថៃទៅភាសាអង់គ្លេស និងបានជួយសម្រួលដល់ការសម្ភាសប្រជាជនថៃ ។ ស៊ីហ្សានី គឺជាអ្នកបកប្រែឯកសារពីភាសាបារាំងនៅដើមសតវត្សរ៍ទី២០ ។ យើង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានធ្វើដំណើរ

ជាច្រើនដងទៅកាន់តំបន់អន្លង់វែង និងត្រពាំងប្រាសាទ ដើម្បីធ្វើការសម្ភាស និងប្រមូលសម្ភារៈ និងឯកសារផ្សេងៗ ដែលផ្តល់ជាឯកសារយោងបន្ថែមដល់សៀវភៅនេះ ។

ជាចុងក្រោយ យើង សូមថ្លែងអំណរគុណចំពោះលោក ឡុង ដានី, អេង កុកថាយ, និង លី សុខឃាង ដែលបានផ្តល់មតិយោបល់កែលម្អទៅលើសេចក្តីព្រាងនៃសៀវភៅនេះ ។




| លេខកូដ | ផ្ទៃក្រឡា (ហិកតា) | ឈ្មោះទីតាំង |
|---|---|---|
| ក១ | ១.២០៧ | កន្លែងដុតខ្មោច ប៉ុល ពត |
| ក២ | ០.៥៥៥ | កន្លែងកាត់ទោស ប៉ុល ពត |
| ក៣ | ៣.០២៨ | ផ្ទះតាម៉ុក ផ្ទះកណ្តាលលើភ្នំដងរែក |
| ក៤ | ១.១៤២ | កន្លែងកែច្នៃគ្រាប់កាំភ្លើងលើភ្នំ២០០ |
| ក៥ | ១១៧.០៦១ | ផ្ទះប៉ុល ពត ខៀវ សំផន |
| ក៦ | ១.៧៨២ | ឃ្លាំងដាក់សំភារៈលើភ្នំ |
| ខ១ | ០.០៦២ | កន្លែងដុតខ្មោច សុន សេន |
| ខ២ | ៤.៤១២ | ស្រះស្រី |
| ខ៣ | ០.១២២ | ទីតាំងការដ្ឋានដឹកជញ្ជូន តាម៉ុក |
| ខ៤ | ៤១៧.០០០ | បឹងអន្លង់វែង |
| ខ៥ | ១.៦១៤ | ផ្ទះតាម៉ុក សារៈមន្ទីរតាម៉ុក |
| ខ៦ | ៣.៦៣២ | អតីតទីតាំងកន្លែងមន្ទីរពេទ្យតាម៉ុក |
| ខ៧ | ៤.៨៣០ | អតីតទីតាំងសាលារៀនតាម៉ុក |
| ខ៨ | ០.០៥៥ | ស្ពានតាម៉ុក |

# សេចក្តីផ្តើម

ប្រវត្តិសាស្ត្រពាក់ព័ន្ធនឹងការវិនិច្ឆ័យផ្នែកសីលធម៌ ។ ដូច្នេះ ការសិក្សាអំពីប្រជាជននៅតំបន់អន្លង់វែងពិបាកនឹងជៀសឲ្យផុតអំពីផ្នត់គំនិតមួយនៃការចោទប្រកាន់ ។ អន្លង់វែងគឺជាតំបន់ចុងក្រោយរបស់របបខ្មែរក្រហម ដែលជារបបមួយទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងសោកនាដកម្មទាំងឡាយ ដែលមិនអាចរៀបរាប់អស់នៅក្នុងសង្គមកម្ពុជា ។ ប្រជាជនកម្ពុជាប្រមាណជិតពីរលាននាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ហើយរហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅតែតស៊ូជាមួយនឹងលទ្ធផលនៃប្រវត្តិសាស្ត្រនេះ ។ ប្រជាជនដែលរស់នៅតំបន់អន្លង់វែងភាគច្រើន គឺជាអតីតកងទ័ព និងជាកម្មាភិបាលខ្មែរក្រហម ដែលអតីតកងទ័ពមួយចំនួនប្រហែលជាធ្លាប់ចូលរួមប្រព្រឹត្តអំពើឃោរឃៅ ។

យើងអាចនិយាយម្យ៉ាងទៀតថា ការសិក្សាអំពីប្រជាជននៅតំបន់អន្លង់វែងអាចងាយនឹងធ្វើឲ្យមនុស្សធ្លាក់ទៅក្នុងផ្នត់គំនិតនៃក្តីអាណិតអាសូរ នៅពេលដែលរឿងរ៉ាវនៃអំពើសោកនាដកម្មនៃរបប និងចលនានេះបានរសាត់បាត់ទៅវិញ នៅពេលដែលយើងបានស្តាប់ពុះរឿងរ៉ាវ និងការតស៊ូរបស់ប្រជាជនម្នាក់ៗ ។ កម្មាភិបាល និងសមាជិកគ្រួសាររាប់ពាន់នាក់ ព្រមទាំងមេដឹកនាំកុម្មុយនីស្តជាន់ខ្ពស់មួយចំនួនផង ត្រូវបានចាប់ខ្លួន និងសម្លាប់នៅទូទាំងប្រទេសកម្ពុជា ។ របបខ្មែរក្រហមបានចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់សមាជិករបស់ខ្លួនដែលចូលរួមចលនាតាំងពីថ្ងៃដំបូង ហើយឱកាសនៃការរួចខ្លួនមានតិចតួចបំផុត ប្រសិនបើបុគ្គលណាម្នាក់ត្រូវបានចោទប្រកាន់ពីបទមិនស្មោះត្រង់ ។ ជាក់ស្តែងភាពភ័យខ្លាចបានក្លាយទៅជាឧបករណ៍មួយ ដែលបានដាក់សង្គមកម្ពុជាទាំងមូលឲ្យទៅជាទាសករ ។

ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅហើយក្តី ក៏ប្រជាជនកម្ពុជានៅទូទាំងប្រទេសមិនថាអ្នកដែលរស់នៅក្នុងតំបន់ឬក្រៅតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហមនោះទេ ទទួលរងទុក្ខវេទនាយ៉ាងធំធេង ។ សង្គ្រាមរវាងកងទ័ពវៀតណាម និងខ្មែរក្រហមរយៈពេលជាង១០ឆ្នាំ បានបង្កឲ្យមានមនុស្សស្លាប់រាប់សែននាក់ដល់ភាគីទាំងសងខាង ។ អស់រយៈពេលជាច្រើនឆ្នាំ ការរស់នៅរបស់ប្រជាជនកម្ពុជាត្រូវពឹងផ្អែកទៅលើជំនួយ

មនុស្សធម៌ ខណៈពេលដែលគ្រោះទុរ្ភិក្ស និងជំងឺនៅតែបន្តញាំញី ។

ទោះជាយ៉ាងនេះក្តី នៅពេលដែលប្រជាជនក្នុងតំបន់អន្លង់វែង អាចទទួលស្គាល់នូវផលវិបាកដ៏អាក្រក់នៃចលនាខ្មែរក្រហមដែលខ្លួនបានចូលរួម និងទ្រទ្រង់នៅក្នុងកាលៈទេសៈជាច្រើន ឥរិយាបថរបស់ប្រជាជនទាំងនោះចំពោះរបបខ្មែរក្រហម គឺមិនសមាមាត្រទៅនឹងទំហំនៃអំពើឃោរឃៅ ដែលខ្លួនបានដឹងថា បានកើតមានឡើងនោះទេ ។ ទោះបីជាមនុស្សគ្រប់រូបយល់ស្របថា ឧក្រិដ្ឋកម្មដ៏អាក្រក់បានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងបន្តកើតមានក្រោយមកទៀតក្តី ក៏បុគ្គលមួយចំនួននៅតែមានមនោសញ្ចេតនាស្រលាញ់ចំពោះអតីតកាលបែបនេះ ហើយមួយចំនួនទៀតនៅតែជឿជាក់ថា លទ្ធិកុម្មុយនីស្តនៅតែអាចអនុវត្តបាន ប្រសិនបើមានមេដឹកនាំល្អជាងនេះ ។ ដូចគ្នានេះ នៅពេលដែលប្រជាជនជាច្រើនទទួលស្គាល់ថា មេដឹកនាំខ្មែរក្រហមមួយចំនួន ដូចជា តាម៉ុក ជាមនុស្សសាហាវឃោរឃៅ ក៏មនុស្សមួយចំនួននៅតែមានការគោរពចំពោះ តាម៉ុក ដែលអ្នកទាំងអស់នោះ មិនអាចបំភ្លេចបាន ។

គោលបំណងនៃការនិពន្ធសៀវភៅនេះ គឺមិនមែនដើម្បីផ្តន្ទាទោស ឬលើកសរសើរប្រជាជនដែលរស់នៅតំបន់អន្លង់វែងនោះទេ ។ ផ្ទុយទៅវិញ យើងសង្ឃឹមថានឹងអាចផ្តល់ទស្សនៈមួយអំពីសហគមន៍មួយ ដែលមិនទាន់ត្រូវបានសិក្សាឲ្យស៊ីជម្រៅ និងផ្តល់ជាសំឡេងមួយទៅឲ្យប្រជាជនមួយក្រុម ដែលសំឡេងរបស់គាត់មិនត្រូវបានដឹងឮគ្រប់គ្រាន់ពីមុនមក ។ វាគឺជាច្បាប់ជាសាកលដែលថា សន្តិភាពត្រូវបានកសាងឡើង និងថែរក្សាតាមរយៈការពិភាក្សាដោយបើកទូលាយ អំពីរឿងរ៉ាវដែលបានកើតឡើងពីអតីតកាល ។ យើងសង្ឃឹមថា សៀវភៅនេះនឹងចូលរួមចំណែកក្នុងការសម្រេចឲ្យបានគោលដៅនេះ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែធ្វើក្នុងការផ្តោះទៅបង្កើតមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។

សៀវភៅនេះចាប់ផ្តើមដោយការលើកឡើងអំពីការកកើតតំបន់អន្លង់វែង មុនខ្មែរក្រហមចូលមកដល់ ។ ជំពូក១ ពិភាក្សាអំពីប្រវត្តិសាស្ត្រតំបន់អន្លង់វែង និងប្រទេសកម្ពុជា នៅអំឡុងពាក់កណ្តាលទីមួយនៃសតវត្សរ៍ទី២០ ។ ជំពូក២ បង្ហាញអំពីការកកើតឡើងនៃចលនាកុម្មុយនីស្តនៅតណ្ហូចិន ដែលគ្រប់គ្រងដោយអាណានិគមបារាំង និងការមកដល់តំបន់អន្លង់វែងដំបូងរបស់ខ្មែរក្រហម ។ ជំពូក៣ ពិភាក្សាអំពីជីវិតរបស់ប្រជាជន

នៅក្រោមរបបខ្មែរក្រហម ដែលដំបូងឡើយជាសហគមន៍រួមមួយ ហើយក្រោយមកក្លាយទៅជាសហករណ៍ ។ ជំពូក៤ និយាយអំពីព័ត៌មានលម្អិតអំពីបរាជ័យរបស់ខ្មែរក្រហមដោយសារកងទ័ពវៀតណាម ។ ជំពូកនេះពិភាក្សាអំពីការរត់បែកខ្ចាត់ខ្ចាយរបស់ប្រជាជនកម្ពុជា និងបទពិសោធរបស់កងទ័ព ជនស៊ីវិល និងសមាជិកក្រុមគ្រួសាររបស់ប្រជាជនទាំងអស់នោះ ។ ជំពូក៥ និងជំពូក៦ ឆ្លុះបញ្ចាំងអំពីតំបន់អន្លង់វែងនៅក្រោមការគ្រប់គ្រងរបស់វៀតណាម និងការរៀបចំរចនាសម្ព័ន្ធឡើងវិញរបស់ខ្មែរក្រហមនៅលើភ្នំដងរែក ។ ទោះបីជារបបខ្មែរក្រហមត្រូវបានផ្តួលរំលំចេញពីអំណាច និងទទួលបរាជ័យនៅសមរភូមិក៏ដោយ ក៏របបនេះអាចរៀបចំកម្លាំងរបស់ខ្លួនឡើងវិញឲ្យទៅជាកម្លាំងទ័ពព្រៃតាមរយៈជំនួយបរទេស ។ ជំពូក៧និងជំពូក៨សិក្សាអំពីជីវិតជាកងទ័ពឈ្លប ។ ជំពូក៧ ផ្តោតសំខាន់ទៅលើយុទ្ធវិធី និងយុទ្ធសាស្ត្រកងទ័ពរបស់ខ្មែរក្រហម ។ ជំពូក៨ ប្រមើលមើលអំពីការតស៊ូរបស់ប្រជាជនសាមញ្ញដែលធំដឹងក្តីនៅក្នុងជំរំកងទ័ព និងជំរំជនភៀសខ្លួន ។ ជំពូក៩ បង្ហាញទិដ្ឋភាពផ្សេងៗជុំវិញ កម្លាំងនយោបាយអន្តរជាតិ ដែលបានជួយឲ្យខ្មែរក្រហមរក្សាបាននូវចលនាតស៊ូបែបកងទ័ពព្រៃរបស់ខ្លួន ។ ជំពូកនេះស្តែងឲ្យឃើញអំពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនៃចលនាខ្មែរក្រហមនៅថ្នាក់ខ្ពស់ និងបង្ហាញអំពីទំព័រថ្មីនៃការដឹកនាំរបស់តាម៉ុក ។ ជំពូក១០ រៀបរាប់អំពីបុគ្គលិកលក្ខណៈរបស់ តាម៉ុក ជាមួយនឹងគម្រោងសាងសង់ជាច្រើន និងទំនាក់ទំនងរវាង តាម៉ុក និងប្រជាជននៅក្នុងតំបន់អន្លង់វែង ។ ជំពូក ១១ ដល់ជំពូក១៣ ពិភាក្សាអំពីថ្ងៃចុងក្រោយនៃថ្នាក់ដឹកនាំរបស់ចលនាខ្មែរក្រហម ។ ជំពូកទាំងនេះគ្របដណ្តប់ទំនាស់ផ្ទៃក្នុងរវាង ប៉ុល ពត និង តាម៉ុក ព្រមទាំងការចាប់ខ្លួន និងការកាត់ទោស ប៉ុល ពត ។ ជំពូក១៤ ពិពណ៌នាអំពីព្រឹត្តិការណ៍ផ្សេងៗ ដែលនាំទៅដល់ការប្រយុទ្ធគ្នាចុងក្រោយនៅក្នុងតំបន់អន្លង់វែង និងការដួលរលំចុងក្រោយ ។ ជំពូក១៥ និងជំពូក១៦ សង្ខេបប្រវត្តិសាស្ត្រសហគមន៍តំបន់អន្លង់វែងឡើងវិញ ដោយដំបូងឡើយពិភាក្សាអំពីប្រវត្តិសាស្ត្រនេះពីទស្សនៈរបស់អ្នកខាងក្រៅ និងបន្ទាប់មកទស្សនៈរបស់ប្រជាជនដែលរស់នៅក្នុងតំបន់អន្លង់វែងនេះ ។

ជំពូក ១

# ប្រវត្តិសាស្ត្រដំបូងនៃតំបន់អន្លង់វែង

តំបន់អន្លង់វែងត្រូវបានបង្កើតឡើងតាំងពីយូរអង្វែងណាស់មកហើយ មុនពេលដែលតំបន់ នេះក្លាយទៅជាតំបន់កាន់កាប់ចុងក្រោយដ៏ល្បីល្បាញរបស់ចលនាកុម្មុយនីស្ត ខ្មែរក្រហម ។ នៅឆ្នាំ១៩០៥ តំបន់អន្លង់វែង ត្រូវបានទទួលស្គាល់ដោយអ្នកគូរផែនទីជនជាតិបារាំង នៅពេលដែលអ្នកគូរផែនទីទាំងនេះកំពុងបង្កើតខ្សែបន្ទាត់ព្រំដែនកម្ពុជាជាមួយនឹងប្រទេសជិតខាងភាគខាងជើង ។ ដូចសហគមន៍ផ្សេងៗទៀត ដែលត្រូវបានបង្កើតឡើងនៅតាមបណ្តោយព្រំដែនខាងទឹកដីថៃដែរ តំបន់ អន្លង់វែងត្រូវបានតាំងទីលំនៅដោយជនជាតិខ្មែរ ដែលបានធ្វើចំណាកស្រុកមកពីភាគខាងត្បូងនៃទឹកដីសៀម ដែលបច្ចុប្បន្នស្ថិតនៅក្នុង ខេត្តស៊ីសាកេតប្រទេសថៃ ។[១]



## រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល

តំបន់អន្លង់វែងមានប្រវត្តិផ្លាស់ប្តូរច្រើនដងរវាងការគ្រប់គ្រងដោយកម្ពុជា និងការគ្រប់គ្រងដោយថៃ ។ មុនឆ្នាំ១៨៦៧ អន្លង់វែងស្ថិតនៅក្នុងទឹកដីកម្ពុជា ។ រវាងឆ្នាំ១៨៦៧ និងឆ្នាំ១៩០៧ អន្លង់វែងស្ថិត នៅក្នុងអតីតខេត្តថៃមួយ ដែលមានឈ្មោះ សៀមណាខន ។ នៅឆ្នាំ១៨៦៣ ប្រទេសកម្ពុជាស្ថិត នៅក្រោមអាណាព្យាបាលបារាំង ។ ដោយមានការដាក់សម្ពាធពីបារាំង សៀមបានប្រគល់ខេត្តបាត់ដំបង និងសៀមរាបមកឲ្យកម្ពុជាវិញនៅឆ្នាំ១៩០៧ ។

នៅឆ្នាំ១៩៤១ តំបន់អន្លង់វែងនេះបានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ថៃ ជាថ្មីម្តងទៀត បន្ទាប់ពី មានជម្លោះមួយរយៈពេលខ្លីរវាងថៃ និងបារាំង ។ នៅចន្លោះឆ្នាំ១៩៤១ និងឆ្នាំ១៩៤៦ អន្លង់វែងត្រូវបានបញ្ចូលទៅក្នុងខេត្តរបស់ថៃ ដែលមានឈ្មោះថា ប៉ែ្វកភីប៊ុនសង់ក្រាម ដែលជាឈ្មោះរបស់អតីតនាយករដ្ឋមន្ត្រីថៃនាពេលនោះ ។ នៅក្នុងដំណាក់កាលនេះ ថៃបានគ្រប់គ្រងខេត្តសៀមរាប និងខេត្ត បាត់ដំបងរបស់ខ្មែររហូតដល់ឆ្នាំ១៩៤៦ នៅពេលដែលបារាំង និងថៃចុះកិច្ចព្រមព្រៀងលើសន្ធិសញ្ញាព្រំដែន ដែលបានប្រគល់ខេត្តទាំងពីរមកឲ្យកម្ពុជាវិញ ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ខេត្តឧត្តរមានជ័យត្រូវបានបង្កើតឡើង ដោយកាត់ចេញពីខេត្តសៀមរាប ។ ទោះជាយ៉ាងនេះក្តី ក្រោយឆ្នាំ១៩៧០ តំបន់អន្លង់វែងក្លាយទៅជា«ដែនដីមួយ ដែលមិនមានរដ្ឋបាលគ្រប់គ្រងដែលនៅឆ្លាស់គ្នាក្រោមខេត្ត ឬជាស្រុកទៅតាមរបបដឹកនាំក្រោយៗមកទៀត ។»[២] នៅឆ្នាំ១៩៩៩ ខេត្តឧត្តរមានជ័យ ត្រូវបានបង្កើតឡើងវិញ ហើយតំបន់អន្លង់វែងដែលធ្លាប់ជាភូមិមួយ បានក្លាយទៅជាស្រុកមួយដែលស្ថិតនៅក្នុងខេត្តឧត្តរមានជ័យរហូតដល់សព្វថ្ងៃ ។

## តំបន់អន្លង់វែង និងតំបន់ជុំវិញនៅមុនឆ្នាំ១៩០៨

ស្ថិតនៅចម្ងាយប្រមាណ១២៥គីឡូម៉ែត្រ ពីទីរួមខេត្តសៀមរាប និងចម្ងាយប្រហែល១២គីឡូម៉ែត្រពីជួរភ្នំដងរែក អន្លង់វែងមានប្រវត្តិជាតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ។ នៅក្នុងរជ្ជកាលព្រះបាទ សម្តេចព្រះ នរោត្តម (១៨៦០-១៩០៤) និងនៅក្នុងស្ទើរមួយរយៈកាលនៃរបបអាណានិគមនិយមបារាំង (១៨៦៣-១៩៥៣)

រដ្ឋបាលរបស់ប្រទេសកម្ពុជាមិនសូវមានការយកចិត្តទុកដាក់ ទៅលើតំបន់ជនបទ ហើយរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនេះ ស្ទើរតែគ្មានវត្តមាននៅតាមតំបន់ដាច់ស្រយាលទាំងឡាយនៃព្រះរាជាណាចក្រ ។

ដោយសារតែមានការខ្វះខាតផ្លូវថ្នល់ ប្រព័ន្ធទំនាក់ទំនង និងហេដ្ឋារចនាសម្ព័ន្ធ តំបន់អន្លង់វែងមិនទទួលឥទ្ធិពលពីរដ្ឋាភិបាលសៀម និងរដ្ឋាភិបាលកម្ពុជាទេ ។ ជាងនេះទៅទៀត ស្ថានភាពនៅតំបន់អន្លង់វែង ហាក់មិនមានការប្រែប្រួលទេ ទោះបីជាបារាំងបានចូលមកគ្រប់គ្រងប្រទេសកម្ពុជាក៏ដោយ ។[៣]

នៅក្នុងរយៈកាលដ៏រុងរឿងនៃអារ្យធម៌អង្គរ អាណាចក្រខ្មែរលាតសន្ធឹងទៅភាគខាងជើងរហូតដល់ប្រទេសចិន ដែលរាប់បញ្ចូលស្ទើរតែទាំងអស់នៃទឹកដីថៃនាពេលបច្ចុប្បន្ននេះ ។[៤] ប៉ុន្តែ ដោយសារមូលហេតុមួយចំនួន ដែលនៅតែជាប្រធានបទនៃការជជែកដេញដោលគ្នារហូតមកដល់សព្វថ្ងៃនេះ អាណាចក្រអង្គរ បានធ្លាក់ចុះយ៉ាងលឿននៅសតវត្សរ៍ទី១៤នៅពេលដែលប្រទេសជិតខាងកម្ពុជា បានបង្កើនអំណាចរបស់ខ្លួនឡើងជាលំដាប់ ។ រហូតមកដល់សតវត្សរ៍ទី១៨ ដោយ សារតែសង្គ្រាម ភាពចលាចលនៅក្នុងសង្គម និងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចកម្ពុជាធ្លាក់ចូលទៅក្នុងភាពទន់ខ្សោយ ដែលងាយនឹងទទួលរងការឆក់ប្លន់ និងការបាត់បង់ទឹកដី ទៅអ្នកជិតខាងដ៏មានអំណាចរបស់ខ្លួន គឺប្រទេសអាណាម និងសៀម (ដែលជាប្រទេសវៀតណាម និងប្រទេសថៃនាពេលបច្ចុប្បន្ន) ។ ដោយបាត់បង់អធិបតេយ្យភាពទៅប្រទេសជិតខាងព្រះបាទ សម្តេចព្រះអង្គឌួង (១៨៤១-១៨៦០) បានស្វែងរកការការពារពីបារាំង ដែលនៅទីបំផុតបង្កើតបាននូវសន្ធិសញ្ញា ឆ្នាំ ១៨៦៣ រវាងព្រះរាជបុត្ររបស់ព្រះអង្គ គឺព្រះបាទ នរោត្តម និងបារាំង ។

សន្ធិសញ្ញាឆ្នាំ១៨៦៣ បានបង្កើតអាណាព្យាបាលបារាំងមកលើប្រទេសកម្ពុជា ដែលសន្ធិសញ្ញានេះ បានផ្តល់សិទ្ធិដល់បារាំងក្នុងការគ្រប់គ្រងទៅលើផ្នែក ពាណិជ្ជកម្មដែនដី និងសាសនា ។ ចំណែកឯ ព្រះបាទ នរោត្តម នៅបន្តដឹកនាំកិច្ចការនយោបាយ និងរដ្ឋបាលផ្ទៃក្នុង ។[៥] ក្រោយៗមកទៀត ជាពិសេស បន្ទាប់ពីឆ្នាំ១៨៨៤ កិច្ចការទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរបារាំង ។

ស្ថាប័នសង្គម និងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចរបស់កម្ពុជា ហាក់មានការផ្លាស់ប្តូរ

តិចតួចណាស់ នៅចន្លោះឆ្នាំ១៨៦៣ដល់ចុងសតវត្សរ៍ទី១៩ ។ ដោយផ្ទុយគ្នាទៅនឹងបែបផែនជីវិតរបស់រាជវង្សានុវង្ស និងក្រុមគ្រួសារអភិជន ប្រជាជនកម្ពុជាភាគច្រើនមានកម្មសិទ្ធិតិចតួចណាស់ ក្រៅពីសម្លៀកបំពាក់ សម្ភារៈផ្ទះបាយ និងសម្ភារៈធ្វើស្រែចម្ការ ។[៦] «ប្រជាជនទាំងនោះរស់នៅតាមទម្លាប់ដែលដូនតារបស់ខ្លួន បានអនុវត្តអស់រយៈពេលជាច្រើនពាន់ឆ្នាំ នៅក្នុងផ្ទះខ្ទមប្រក់ស្លឹកត្នោតសង់ខ្ពស់ផុតពីដី ដើម្បីឲ្យមានខ្យល់ចេញចូល និងការពារពីទឹកជំនន់ សត្វពស់ និងសត្វល្អិតផ្សេងៗ ។»[៧] ព្រះពុទ្ធសាសនាគឺជាមូលដ្ឋានគ្រឹះនៃជីវិតរបស់អ្នកភូមិ ដែលបានផ្សារភ្ជាប់ទំនាក់ទំនងក្នុងចំណោមអ្នករស់នៅក្បែរខាងគ្នា ក៏ដូចជាសហគមន៍ទាំងមូល ។ ការដោះដូរផ្នែកសេដ្ឋកិច្ច និងសង្គមត្រូវបានកំណត់ដោយលក្ខខណ្ឌភូមិសាស្ត្រមិនអំណោយផល ហើយនៅតំបន់ដាច់ស្រយាលដូចជាតំបន់អន្លង់វែង ភូមិទាំងឡាយហាក់ដូចជាកោះនៅក្នុងសមុទ្រព្រៃដ៏ក្រាស់ ។[៨] យើងអាចស្រមៃឃើញថា មន្ត្រីបារាំងដែលបានធ្វើដំណើរស្វែងយល់តាមបណ្ដោយព្រំដែនកម្ពុជា-សៀម នៅឆ្នាំ១៩០៥ ប្រហែលជាបានប្រទះឃើញស្ថានភាពប្រហាក់ប្រហែលគ្នានេះ ។ ដូចដែលប្រវត្តិវិទូមួយរូបបានលើកឡើង «ទោះបីជាពីរជ្ជកាលមួយទៅរជ្ជកាលមួយមានការធ្លាក់ចុះ ស្ថានភាពនៅតាមភូមិស្រុកនៅតែដដែល ។»[៩]

តំបន់អន្លង់វែងហាក់ដូចជាមិនមានការប្រែប្រួលច្រើនទេទោះបីជាតំបន់នេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរ ឬសៀម[១០] ។[១១] សៀមហាក់ដូចជាមិនជំទាស់ក្នុងការអនុញ្ញាតឲ្យប្រជាជនខ្មែរបន្តប្រតិបត្តិទំនៀមទម្លាប់ចាស់របស់ខ្លួន នៅក្នុងខេត្តទាំងឡាយដែលសៀមបានកាត់យក ។[១២] សម្រាប់តំបន់ដាច់ស្រយាល ដូចជាអន្លង់វែង និងតំបន់ដែលស្ថិតនៅភាគខាងជើងជួរភ្នំដងរែកក្នុងទឹកដីសៀម ប្រជាជនខ្មែរនៅតែបន្តអនុវត្តរបស់ខ្លួន ដូចដែលខ្លួនធ្លាប់បានអនុវត្តអស់ជាច្រើនសតវត្សរ៍កន្លងមក ។ ជនជាតិថៃម្នាក់ដែលធ្លាប់រស់នៅអន្លង់វែងក្នុងទសវត្សរ៍ឆ្នាំ១៩៥០ បានរៀបរាប់ថា ភាសាខ្មែរគឺជាភាសាដែលប្រជាជនភាគច្រើននិយាយទាំងនៅលើទឹកដីថៃ និងទឹកដីខ្មែររហូតដល់ពាក់កណ្ដាលសតវត្សរ៍ទី២០ ។ «ប្រជាជនស្ទើរតែមួយរយភាគរយនិយាយភាសាខ្មែរនៅទីនោះ ។ ប៉ុន្តែ បច្ចុប្បន្នប្រជាជន នៅទីនេះ (សំដៅទៅលើប្រជាជន ដែលរស់នៅក្នុងខេត្តស៊ីសាកេត ប្រទេសថៃ) ស្ទើរតែមួយរយភាគរយនិយាយភាសាថៃ ។»[១៣]

## រឿងរ៉ាវរបស់ចោរប្លន់ម្នាក់

នៅខែវិច្ឆិកា ឆ្នាំ១៩០៧ អាជ្ញាធរកម្ពុជាបានចាប់ខ្លួនចោរប្លន់ម្នាក់ ដែលមានឈ្មោះថា អាឃួន ដែលបានចូលរួមប្រព្រឹត្តអំពើឆក់ប្លន់នៅក្នុងតំបន់ ។ អាឃួន បានរត់គេចខ្លួនពីរបីថ្ងៃបន្ទាប់ពីជាប់ឃុំឃាំង ។ ប៉ុន្តែ មុនពេលគេចខ្លួន អាឃួន បានប្រាប់រឿងមួយចំនួនទាក់ទងទៅនឹងក្រុមចោរប្លន់ ដែលធ្វើឲ្យអាជ្ញាធរបារាំងដឹងកាន់តែច្បាស់អំពីការសង្ស័យរបស់ខ្លួន អំពីអំពើសមគំនិតរបស់មន្ត្រីរាជការស៊ីវិលសៀម នៅក្នុងអំពីឆក់ប្លន់នោះ ។ អាឃួន គឺជាជនជាតិខ្មែរម្នាក់ ដែលរស់នៅក្នុងភូមិធ្នង់ ខេត្តចុងកាល់ (ស្រុកចុងកាល់ ខេត្តឧត្តរមាន-ជ័យបច្ចុប្បន្ន) ។ នៅដើមខែតុលា ឆ្នាំ១៩០៨ ក្រុមចោរដែលមានគ្នាប្រហែល៦០នាក់ ប្រដាប់ដោយកាំភ្លើង និងដាវ បានចូលមកក្នុងភូមិរបស់ អាឃួន ។ មេចោរបានចាត់គ្នារបស់ខ្លួនប្រហែល៣០នាក់ ឲ្យដើរប្រមូលអ្នកភូមិ និងចាប់បញ្ជូនអ្នកភូមិទាំងនោះទៅឃុំគោល ខេត្តសង់កៀក ប្រទេសសៀម ។ អាឃួន ស្ថិតនៅក្នុងអ្នកភូមិដែលក្រុមចោរបានកៀរយកទៅ ។ ក្រុមចោរបានប្រមូលប័ណ្ណបង់ពន្ធទាំងអស់របស់អ្នកភូមិ ហើយកម្ទេចចោលដោយបាននិយាយថា ខ្លួននឹងមិនអនុញ្ញាតឲ្យអ្នកភូមិទាំងអស់ជាប់ពាក់ព័ន្ធជាមួយនឹងបារាំងទៀតទេ ។ មិនតែប៉ុណ្ណោះ ក្រុមចោរទាំងនោះបានដើរប្រមូលសត្វគោ និងសត្វចិញ្ចឹមផ្សេងៗទៅជាមួយ ប៉ុន្តែបានបោះបង់ចោលទៅវិញ ដើម្បីកុំឲ្យយឺតដំណើររបស់ខ្លួន ។ ក្រុមចោរបានបង្ខំ អាឃួន ឲ្យធ្វើជាអ្នកនាំផ្លូវនៅក្នុងការចូលទៅឆក់ប្លន់ភូមិផ្សេងៗទៀតនៅក្នុងទឹកដីខ្មែរ ។ ក្រុមចោរបានបញ្ជាឲ្យ អាឃួន នាំពួកខ្លួនទៅភូមិដូនលក ភូមិទង ក្នុងខេត្តចុងកាល់ ។ នៅក្នុងភូមិទាំងពីរ ក្រុមចោរបានចាត់ឲ្យកម្លាំងរបស់ខ្លួនដើរប្រមូលអ្នកភូមិ ហើយនាំយកទៅប្រទេសសៀម ។ សមាជិកក្រុម ដែលនៅសេសសល់បានបន្តទៅប្លន់នៅអន្លង់វែង ។ ប៉ុន្តែ ដោយសារតែភ្លៀងធ្លាក់ខ្លាំងក្រុមចោរទាំងអស់នោះមិនអាចធ្វើដំណើរទៅដល់តំបន់អន្លង់វែងនោះបានទេ ។ ដោយសារសមាជិកភាគច្រើនមិនចេះហែលទឹក ក្រុមចោរទាំងអស់នោះ បានសម្រេចចិត្តវិលត្រឡប់ទៅប្រទេសសៀមវិញ ។

## អំពើឆក់ប្លន់

យើងអាចធ្វើការប៉ាន់ស្មានបានថា ដោយសារតំបន់អន្លង់វែងស្ថិតនៅឆ្ងាយពីការគ្រប់គ្រងរបស់រដ្ឋាភិបាល យើងមិនអាចដឹងអំពីប្រវត្តិដើមរបស់ប្រជាជន ដែលបានមកតាំងទីនៅក្នុងតំបន់នេះដំបូងបង្អស់បានទេ ។ នៅក្រោមការជិះជាន់របស់ក្រុមអភិជន




និងមន្ត្រីរាជការក្នុងតំបន់ប្រជាជនសាមញ្ញជាញឹកញយ ទទួលរងការចាប់កំណែនកងទ័ព ការបង្ខំឲ្យធ្វើការងារធ្ងន់ និងការបង់ពន្ធ ។ ដោយពុំមានមធ្យោបាយក្នុងការការពារខ្លួន ប្រជាជនភាគច្រើនយល់ឃើញថា មានតែតំបន់ព្រៃភ្នំ និងតំបន់តាមព្រំដែនទេជាតំបន់មានសេរីភាពផុតពីកណ្តាប់ដៃរបស់អាជ្ញាធរ ។[១៤] ប៉ុន្តែ នេះមិនមែនមានន័យថា ប្រជាជនទាំងនេះសុទ្ធតែភៀសខ្លួនចេញពីការធ្វើទុក្ខបុកម្នេញនោះទេ ។ ការឆក់ប្លន់នៅតាមភូមិកើតមានឡើងនៅក្នុងប្រទេសកម្ពុជាជាច្រើនសតវត្សរ៍មកហើយ ហើយអំពើនេះភាគច្រើនកើតឡើងនៅ«ទីតាំងដែលមានលក្ខខណ្ឌភូមិសាស្ត្រអំណោយផល ដែលអាចឲ្យក្រុមចោរប្លន់រត់គេចខ្លួនចូលទៅក្នុងព្រៃភ្នំ ឬរត់ឆ្លងព្រំដែន ។»[១៥]

ប៉ុក គៀក អ្នកភូមិម្នាក់នៅអន្លង់វែង បានរំឭករឿងរ៉ាវដែលចាស់ៗ នៅក្នុងភូមិធ្លាប់តំណាលប្រាប់គាត់អំពីតំបន់អន្លង់វែងក្នុងសតវត្សរ៍ទី២០ ។ “អន្លង់វែងត្រូវបានហៅថា

ជាភូមិចោរ ពីព្រោះប្រជាជននៅក្នុងតំបន់នេះ បានចូលលួចគោពីខេត្តសៀមរាបទៅលក់នៅប្រទេសថៃ ។ នៅពេលនោះ ប្រជាជននៅអន្លង់វែងពុំមាន ការងារឬអាជីវកម្មពិតប្រាកដទេ ។»[១៦] ទោះបីជាតាមការពិត អន្លង់វែងប្រហែលជាមិនមែនជា«ភូមិចោរ»ក្ដី ក៏យើងអាចសន្និដ្ឋានបានថា លក្ខខណ្ឌភូមិសាស្ត្រ តំបន់អន្លង់វែង បានអូសទាញក្រុមចោរជាច្រើនឲ្យមកតាំងទីលំនៅជាមួយនឹងប្រជាជនទូទៅដែរ ។[១៧]

មកត្រឹមឆ្នាំ១៨៩២ រដ្ឋាភិបាលអាណានិគមបារាំងបានគ្រប់គ្រងលើការប្រមូលយកពន្ធដារស្ទើរតែទាំងអស់ ហើយក្រោយមក បារាំងបានគ្រប់គ្រងមកលើរដ្ឋបាលខ្មែរស្ទើរតែគ្រប់ផ្នែក ។[១៨] ការយាងសោយព្រះទិវង្គតរបស់ព្រះបាទ នរោត្តម និងការឡើងគ្រងរាជ្យរបស់ព្រះអនុជរបស់ព្រះអង្គគឺ ព្រះបាទ ស៊ីសុវត្ថិ នៅឆ្នាំ១៩០៤ បង្កើតបាននូវរដ្ឋកាលថ្មីមួយនៃការប្រមូលផ្ដុំអំណាចរដ្ឋបាល កាន់តែខ្លាំងជាងមុន និងការប្រមូលពន្ធដារកាន់តែច្រើនឡើងពីសំណាក់បារាំង ដែលប្រការទាំងនេះបានបង្កឲ្យមានវិបត្តិសង្គមកាន់តែខ្លាំងឡើង ។[១៩] ខណៈពេលដែលបារាំងបង្កើនការគ្រប់គ្រងទៅលើរដ្ឋបាល ការប្រមូលពន្ធនិងកាតព្វកិច្ចផ្សេងៗ ទៀតកាន់តែខ្លាំងឡើង ប្រជាជនបានរត់ចូលកាន់តែជ្រៅទៅរស់នៅក្នុងព្រៃ និងតាមតំបន់ព្រំដែន ។[២០] នៅពេលដែលតំបន់ព្រៃទាំងនោះក៏ត្រូវបានគ្រប់គ្រងកាន់តែខ្លាំងឡើងប្រជាជនមួយចំនួនបានចាប់ផ្ដើមផ្លាស់ទីលំនៅទៅកាន់ប្រទេសសៀម ឬប្រទេសលាវក្នុងអំឡុងពេលនៃការប្រមូលពន្ធ និងវិលត្រឡប់មកវិញ នៅពេលដែលអាជ្ញាធរចាកចេញទៅវិញ ។[២១]

តំបន់ព្រំដែនបានក្លាយទៅជាផ្លូវសម្រាប់ជនដែលរត់គេចចេញពីការបង់ពន្ធ និងជាតំបន់ជម្លោះ ។ នៅឆ្នាំ១៩០៧ បារាំងបានចរចាឲ្យថៃប្រគល់ខេត្តបាត់ដំបង និងខេត្តសៀមរាប មកឲ្យកម្ពុជាវិញ ។ ទោះបីជាសៀមត្រូវបានបង្ខំយ៉ាងណា ក៏ដោយ ក៏សៀមមិនសុខចិត្តប្រគល់ខេត្តទាំងពីរនេះ មកឲ្យកម្ពុជាវិញដោយសន្តិវិធីដែរ ។

នៅក្នុងឆ្នាំដដែលនោះដែរ នៅពេលដែលកម្ពុជាទាមទារមកវិញនូវទឹកដីភាគខាងជើង និងភាគខាងលិចពីសៀម កម្ពុជាក៏ទទួលរងការវាយប្រហារយ៉ាងខ្លាំងជាបន្តបន្ទាប់ពីសំណាក់ក្រុមចោរប្លន់ នៅក្នុងខេត្តបាត់ដំបង និងតំបន់អន្លង់វែង ។

នៅឆ្នាំ១៩០៧ របាយការណ៍សំខាន់ៗជាច្រើនបានរៀបរាប់អំពីក្រុមចោរប្លន់ដែលបានធ្វើប្រតិបត្តិការនៅលើទឹកដីភាគខាងជើង និងខាងលិចនៃប្រទេសកម្ពុជា ។ ប្រជាជន

នៅក្នុងភូមិបានរាយការណ៍ទៅមន្ត្រីបារាំងថា ក្រុមចោរប្លន់ប្រហែលពី៦០ទៅ៩០នាក់ មកពីសៀមបានចូលមកក្នុងភូមិជាច្រើននៅអន្លង់វែង និងតំបន់មួយចំនួននៅក្នុងខេត្តបាត់ដំបង ដោយបានបង្ខំប្រជាជនឲ្យទៅប្រទេសសៀមជាមួយខ្លួន ដោយបានគំរាមសម្លាប់ ។ អ្នកភូមិជាច្រើនមានការភ័យខ្លាច ហើយបានរត់ភៀសខ្លួនទៅកាន់ភូមិមួយចំនួនរបស់សៀម ដូចជាភូមិសង់គា បាសាន ឬចូលជ្រៅទៅក្នុងប្រទេសថៃនាពេលបច្ចុប្បន្ន ។[២២] បន្ទាប់ពីក្រុមចោរប្លន់បានចាកចេញ អាជ្ញាធរបារាំងបានធ្វើដំណើរទៅកាន់តំបន់ទាំងនោះ ដើម្បីធ្វើការស៊ើបអង្កេត គឺគ្រាន់តែទៅមើលគ្រួសារសេសសល់មួយចំនួនតូចប៉ុណ្ណោះ ។[២៣]

ដោយទទួលស្គាល់ពីការគំរាមកំហែងក្នុងទ្រង់ទ្រាយធំបែបនេះ អាជ្ញាធរបារាំង បានចាត់តាំងកម្លាំង ឈ្លបប្រហែល១៥នាក់ឲ្យធ្វើដំណើរទៅកាន់ព្រំដែនក្នុងតំបន់ អន្លង់វែង ដើម្បីសង្កេតមើល ។[២៤]

ជីវិតនៅអន្លង់វែង នៅក្នុងរយៈកាលនោះ មានភាពឯកោ និងលំបាក ។ មានទំនាក់ទំនងតិចតួច ណាស់ទៅកាន់ពិភពខាងក្រៅ ។ ដូច្នេះ កម្លាំងប៉ូលីសណាដែលត្រូវបានចាត់តាំងឲ្យទៅប្រចាំការនៅតំបន់ទាំងនោះត្រូវពឹងផ្អែកទាំងស្រុងទៅលើធនធាននៅក្នុងតំបន់ទាំងនោះ ។ ដោយយល់ឃើញពីស្ថានភាពលំបាកនៅតំបន់ទាំងនោះ អាជ្ញាធរបារាំងបានសម្រេចផ្លាស់ប្តូរកម្លាំងនគរបាលរបស់ខ្លួនរៀងរាល់៣ខែម្តង ។[២៥]

ទោះបីជាអាជ្ញាធរបារាំងមិនអាចរកភ័ស្តុតាងបញ្ជាក់បានថា រដ្ឋាភិបាលសៀមមានការសមគំនិត ជាមួយនឹងសកម្មភាពឆក់ប្លន់ខាងលើក៏ដោយ ក៏បារាំងបានសន្និដ្ឋានថាសកម្មភាពឆក់ប្លន់នោះទទួលបានការជំរុញលើកទឹកចិត្តពីអាជ្ញាធរសៀម ។ ភ័ស្តុតាងនៃសម្ព័ន្ធភាពនេះ យោងទៅលើយុទ្ធសាស្ត្រជាបន្តរបស់ក្រុមចោរប្លន់ ក្នុងការបោសសម្អាតភូមិមិនឲ្យមានមនុស្សរស់នៅ ដែលផ្ទុយនឹងផលប្រយោជន៍នៃអំពើឆក់ប្លន់ ។[២៦] អាជ្ញាធរបារាំងសង្ស័យថា មន្ត្រីសៀមបានប្រាប់ក្រុមចោរទាំងអស់នោះឲ្យធ្វើការឆក់ប្លន់ភូមិរបស់ខ្មែរតាមតែអាចធ្វើបាន និងប្រមូលប្រជាជនខ្មែរមកប្រទេសសៀម បើមិនដូច្នោះទេ ក្រុមចោរទាំងនោះនឹងត្រូវអាជ្ញាធរសៀមដាក់ទោស ។ អាជ្ញាធរបារាំងសង្ស័យថា សមាជិកមួយចំនួនរបស់ក្រុមចោរ គឺជាជនជាតិខ្មែរ ដែលត្រូវបានកៀរ និងបង្ខំឲ្យចូលរួមនៅក្នុងសកម្មភាពឆក់ប្លន់ទាំងនោះ ។[២៧]

## ជីវិតរស់នៅក្នុងតំបន់អន្លង់វែង ៖ ១៩០៨-១៩៧០

មិនខុសពីប្រទេសអាណានិគមដទៃទៀតទេអាណានិគមបារាំងក៏ត្រូវបានជំរុញឲ្យកេងប្រវ័ញ្ចទៅលើប្រភពធនធានរបស់កម្ពុជា និងបង្កើនពាណិជ្ជកម្ម ដើម្បីផលប្រយោជន៍របស់ខ្លួន ។ ទន្ទឹមនឹងផលប្រយោជន៍សេដ្ឋកិច្ច និងផលប្រយោជន៍ផ្នែកភូមិសាស្ត្រជាយុទ្ធសាស្ត្រ ប្រទេសអាណានិគមក៏បានស្វែងរកការផ្សព្វផ្សាយវប្បធម៌របស់ខ្លួន និងនៅក្នុងកម្រិតកំណត់ណាមួយ ដើម្បីធ្វើឲ្យប្រសើរឡើងដល់ជីវិត និងសហគមន៍របស់ប្រទេសដែលស្ថិតនៅក្រោមអាណានិគម ។ ការចាប់អារម្មណ៍របស់បារាំងនៅក្នុងការអភិវឌ្ឍវិស័យវប្បធម៌ និងសេដ្ឋកិច្ចសង្គម ដែលត្រូវបានស្គាល់ថា «បេសកកម្មពង្រីកអារ្យធម៌ខ្ពង់ខ្ពស់» គឺជាផ្នែកមួយដ៏សំខាន់របស់អាណានិគមនិយមបារាំងនៅក្នុងប្រទេសកម្ពុជា ។

បារាំងបានធ្វើកំណាយ សិក្សា និងជួសជុលប្រាសាទ ដែលកសាងឡើងនៅសម័យអង្គរ និងរូបចម្លាក់ជាច្រើន ដែលភ្ញៀវទេសចរបានឃើញនាពេលបច្ចុប្បន្ន ។ បារាំងក៏បានសាងសង់ផ្លូវថ្នល់ ផ្លូវរថភ្លើង និងខ្សែកាបទូរសារ ។ ជាងនេះទៅទៀត បារាំងបានរៀបចំ និងធ្វើមជ្ឈការឡើងវិញនូវការប្រមូលពន្ធដារ និងរចនាសម្ព័ន្ធ គ្រប់គ្រងរដ្ឋបាលព្រមទាំងបានបង្កើតកម្មវិធីកិច្ចការសាធារណៈក្នុងទ្រង់ទ្រាយធំ ។

ប៉ុន្តែ នៅពេលដែលបារាំងបានចំណាយពេលវេលា និងធនធានយ៉ាងច្រើនទៅលើការពង្រឹង ការអភិវឌ្ឍរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល និងសេដ្ឋកិច្ចសង្គមរបស់កម្ពុជាទាំងមូល ការពង្រីកវិស័យអប់រំ សុខាភិបាល និងជីវភាពរស់នៅជាទូទៅរបស់ប្រជាជននៅតាមទីជនបទនៅមានភាពខ្វះខាត ។ មិនខុសពីតំបន់ដាច់ស្រយាល ដទៃទៀតនៅក្នុងប្រទេសកម្ពុជា នៅដើមសតវត្សរ៍ទី២០ តំបន់អន្លង់វែងមានការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធគ្រឿងបរិក្ខារពេទ្យ បុគ្គលិកពេទ្យដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងថ្នាំសង្កូវ ។ ហេតុដូច្នេះ ជំងឺនៅតែបន្តជាបញ្ហាគ្រោះថ្នាក់ដល់ប្រជាជននៅក្នុងតំបន់ជាពិសេស គឺជំងឺឆ្លង ។

ជាក់ស្តែង មិនថាប្រជាជនកើតនៅក្នុងសតវត្សរ៍ណាទេ ភាពលំបាកវេទនា នៅក្នុងជីវភាពរស់នៅ និងភាពមិនទៀងទាត់ក្នុងការរស់រានមានជីវិតជាមនុស្ស បានក្លាយទៅជាផ្នែកមួយនៃជីវិតរបស់ប្រជាជន ដែលរស់នៅតាមតំបន់ជនបទដាច់ស្រយាល និងតាមបណ្តោយព្រំដែន ។

ភូមិសាង៉ុំ (បារាំង ហៅភូមិនេះថា ភូមិស្រង៉ុំ) ស្ថិតនៅចម្ងាយប្រហែល១២គីឡូ

ម៉ែត្រពីតំបន់អន្លង់វែង ដែលជាចំណុចប្រសព្វរវាងព្រំដែនកម្ពុជា និងថៃ បច្ចុប្បន្ន ។ យោងតាមចាស់ទុំជនជាតិថៃ ភូមិនេះស្ថិតនៅលើទីតាំងនៃច្រកព្រំដែនជាំសាង៉ាំ សព្វថ្ងៃ ។ ដូចគ្នាទៅនឹងតំបន់អន្លង់វែងដែរ ភូមិនេះត្រូវបានអ្នកគូរផែនទី បារាំងទទួលស្គាល់នៅពេលធ្វើគំនូសបែងចែកព្រំដែនកម្ពុជា-សៀម នៅចន្លោះ ឆ្នាំ១៩០៧-១៩០៩ ។

ភូមិសាង៉ាំ ត្រូវបានដាក់ឈ្មោះតាមដើមឈើធំមួយប្រភេទ ដែលដុះនៅក្នុងភូមិ ។ ចាស់ៗជនជាតិថៃបានពិពណ៌នាថា ភូមិនេះគឺជាភូមិ ដែលជនជាតិសៀម និងខ្មែរបានមកតាំងទីរស់នៅជាមួយគ្នា ។[២៨] ដូចគ្នាជាមួយនឹងភូមិផ្សេងៗទៀតនៅក្នុងតំបន់នេះ ប្រជាជនភាគច្រើននៅក្នុងភូមិនិយាយភាសាខ្មែរ ។

នៅឆ្នាំ១៩៤៨ ប្រជាជននៅក្នុងភូមិនេះបានទទួលរងគ្រោះពីជំងឺរាតត្បាត ។ ប៉ុន្តែរឿងរ៉ាវលម្អិត អំពីជំងឺនេះ ហាក់នៅមានភាពស្រពេចស្រពិលនៅឡើយ ។ បើយោងតាមចាស់ៗជនជាតិថៃមួយចំនួន ភូមិសាង៉ាំ ត្រូវបានបំផ្លាញដោយសារជំងឺអាសន្នរោគ ។[២៩] ភូមិសាង៉ាំ នៅតែជាតំបន់ពាណិជ្ជកម្មក្នុងតំបន់ មួយនាពេលបច្ចុប្បន្ននេះ ។

ការផ្ទុះឡើងនៃជំងឺអាសន្នរោគនៅទសវត្សរ៍ឆ្នាំ១៩៤០ បានបណ្តាលឲ្យប្រជាជនជាច្រើនភូមិបាត់បង់ជីវិត ។ ទោះបីជាពុំមានទិន្នន័យច្បាស់លាស់ដើម្បីបញ្ជាក់អំពីរឿងនេះក្តី ក៏ជំងឺនេះត្រូវបានជឿជាក់ថា មានប្រភពចេញមកពីភូមិរៀនជី ប្រទេសសៀម ដែលស្ថិតនៅចម្ងាយប្រមាណ១០គីឡូម៉ែត្រពីភូមិសាង៉ាំ ។ ជំងឺនេះបានរាលដាលដល់ភូមិសាង៉ាំ ដែលបានបណ្តាលឲ្យប្រជាជនស្ទើរគ្រប់គ្នាឆ្លងជំងឺនេះ ។ អ្នកដែលអាចគេចផុតពីជំងឺនេះបានចាកចេញពីភូមិ ហើយភូមិទាំងមូលត្រូវបានបោះបង់ចោល ។

នៅក្នុងប្រទេសថៃសព្វថ្ងៃនេះមានតែចាស់ៗជនជាតិថៃម្នាក់ ឬពីរនាក់ប៉ុណ្ណោះដែលរួចរស់ជីវិត នៅពេលជំងឺអាសន្នរោគបានរាតត្បាត ។ ប៉ុន្តែ រឿងរ៉ាវអំពីជំងឺអាសន្នរោគដែលបានបង្កជាគ្រោះមហន្តរាយដ៏ធ្ងន់នេះ ត្រូវបានជនជាតិថៃនៅតាមតំបន់ព្រំដែននិយាយប្រាប់តគ្នាពីជំនាន់មួយទៅជំនាន់មួយរហូតដល់សព្វថ្ងៃ ។

យើងមិនបានដឹងច្បាស់ទេថា តើតំបន់អន្លង់វែង ឬភូមិខ្មែរនៅក្បែរនោះទទួលរងគ្រោះពីជំងឺអាសន្នរោគនោះដែរឬយ៉ាងណានោះទេ ។ ទោះជាយ៉ាងនេះក្តី បើពិនិត្យទៅតាមទីតាំងភូមិសាស្ត្រនៃភូមិសាង៉ាំ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីភូមិថៃ ដែលអាចដើរដល់ក្នុងរយៈពេលមួយថ្ងៃ យើងអាចសន្និដ្ឋានបានថា ជំងឺអាសន្នរោគ ដែលមាន

ប្រភពចេញពីប្រទេសថៃ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ អាចរាលដាលដល់ភូមិមួយចំនួននៅជុំវិញតំបន់អន្លង់វែង។ សេចក្តីសន្និដ្ឋាននេះត្រូវបានធ្វើឡើង ដោយសារតែតំបន់នេះជាតំបន់ដែលមានប្រជាជនធ្វើដំណើរចេញចូលរវាងប្រទេសកម្ពុជា និងថៃ ព្រមទាំងភាពប្រហាក់ប្រហែលគ្នានៃស្ថានភាពសេដ្ឋកិច្ច និងសង្គម នៅតាមតំបន់ដែលស្ថិតនៅតាមបណ្តោយព្រំដែន។[៣០]

រហូតមកដល់ទសវត្សរ៍ឆ្នាំ១៩៩០ សេវាសុខាភិបាលសាធារណៈ ផ្លូវគមនាគមន៍ និងប្រព័ន្ធអប់រំ នៅមានកម្រិតទាបខ្លាំងនៅឡើយ (ឬស្ទើរតែមិនមានទាល់តែសោះ) នៅក្នុងតំបន់អន្លង់វែង។

មី ឆេង បានរំឭកថា នៅទសវត្សរ៍ឆ្នាំ១៩៥០ តំបន់អន្លង់វែងមានសាលារៀនតែមួយប៉ុណ្ណោះ។ ភូមិរំចេក ដែលជាភូមិចាស់នៅតំបន់អន្លង់វែង មានប្រជាជនជាង ៥០គ្រួសារ ពុំមានសាលារៀនទេ។ ដូចគ្នាដែរ ភូមិតាវេវ និងភូមិខ្ទុរ ក៏មិនមានសាលារៀនដែរ។ ដូចដែល ធីន ប៊ិន បានលើកឡើង«កុមារតូចៗមិនបានទៅសាលារៀនទេ។ ពួកគេធំដឹងក្តីដោយមិនចេះអក្សរ។»[៣១] ឈិត ធី យល់ស្រប ដោយ បាននិយាយថា « មិនបានទៅសាលារៀននោះទេ ដោយសារតែ ត្រូវជួយក្រុមគ្រួសាររបស់ ក្នុងការរកស៊ីចិញ្ចឹមជីវិត។»[៣២]

ចាន់ បៃ ដែលជាអ្នកភូមិមួយរូបនៅតំបន់អន្លង់វែង បានរៀបរាប់អំពីជីវិតរស់នៅក្នុងភូមិខ្ទុរ កាលពីមុនឆ្នាំ១៩៧៥ថា ៖

> នៅពេលនោះ នៅក្នុងភូមិនេះមានប្រជាជនរស់នៅតែ ៦គ្រួសារប៉ុណ្ណោះ។ កុមារតូចៗ មិនបានទៅសាលារៀននោះទេ។ ប្រជាជនជីកក្ដួច និងដំឡូងព្រៃសម្រាប់បរិភោគ ហើយមិនដែលពាក់អាវ ឬសម្លៀកបំពាក់ស្អាតៗដូចសព្វថ្ងៃនេះទេ។ ជាទូទៅ យើងស្លៀកសម្លៀកបំពាក់ប្រឡាក់។ យើងមិនមានលុយទិញប៊ីចេងទេ។ យើងបរិភោគតែបាយជាមួយអំបិល ដែលទិញមកពីភូមិខ្នារ ប្រទេសថៃ។ នៅទីនេះពុំមានផ្សារ ឬផ្លូវថ្នល់នៅឡើយទេ។ យើង ត្រូវចំណាយពេល១០ថ្ងៃធ្វើដំណើរដោយថ្មើរជើងឆ្លងកាត់ភ្នំ ដើម្បីទៅដល់តំបន់ប្រជុំជននៅក្នុងទឹកដីកម្ពុជា។ ប៉ុន្តែ ប្រសិនបើយើងចង់ទិញ

> អំបិល យើងគ្រាន់តែធ្វើដំណើរទៅថៃ ស្នាក់នៅទីនោះមួយយប់ ហើយត្រឡប់មកភូមិវិញនៅថ្ងៃបន្ទាប់ ។[៣៣]

ការកំណត់អាយុចូលរៀនក៏ត្រូវបានគណនាខុសពីបច្ចុប្បន្នដែរ ។ ដោយសារតែថ្ងៃខែឆ្នាំកំណើត និងអាយុ មិនត្រូវបានប្រជាជនចងចាំ ឬកត់ត្រាទុក ប្រជាជនបានប្រើប្រាស់វិធីប្រកបដោយភាពច្នៃប្រឌិតនៅពេលកុមារធំដឹងក្តីល្មមអាចចូលសាលារៀនបាន ។

> នៅពេលខ្ញុំចូលរៀននៅខេត្តតាកែវ នៅដើមទសវត្សរ៍ឆ្នាំ១៩៦០ អាយុចូលរៀននៅពេលនោះ មានភាពខុសគ្នាពីអាយុចូលរៀនបច្ចុប្បន្នច្រើនណាស់ ។ នៅពេលដែលខ្ញុំនៅជាកុមារ យើងត្រូវយកដៃរបស់យើងដាក់លើក្បាល ហើយព្យាយាមប៉ះត្រចៀកម្ខាងទៀត ។ ប្រសិនបើដៃរបស់យើងមិនអាចប៉ះត្រចៀកម្ខាងទៀតបានទេ យើងនឹងមិនត្រូវបានអនុញ្ញាតឲ្យចុះឈ្មោះចូលរៀនទេ ។ ជាទូទៅ កុមារភាគច្រើនមានអាយុ១០ឆ្នាំទើបបានចូលរៀន ។[៣៤]

សេដ្ឋកិច្ចតំបន់អន្លង់វែង ពឹងផ្អែកទាំងស្រុងទៅលើការដាំដុះ និងភោគផលផ្សេងៗដែលអាចប្រមូលបាននៅលើដី ។ ដោយសារតែពុំមានរូបិយប័ណ្ណ ប្រជាជនប្រើមធ្យោបាយដោះដូរដើម្បីទិញទំនិញ ។ «យើងពុំមានក្រដាសប្រាក់ ឬប្រាក់កាក់នោះទេ ។ ដូច្នេះយើងបានយកកន្ទេល និងផ្តៅ ទៅដូរអំបិលជាមួយថៃ ។»[៣៥] ប្រជាជននៅក្នុងតំបន់ក៏ធ្វើស្រែ និងដាំផ្លែឈើដូចជា ស្វាយ និងដើមឈើហូបផ្លែដទៃទៀតអាស្រ័យទៅនឹងលក្ខខណ្ឌដី ។[៣៦]

មធ្យោបាយដឹកជញ្ជូនមានចំនួនតិចតួចណាស់ ដោយសារតែពុំមានផ្លូវសម្រាប់ធ្វើដំណើរ ។ មិនមានប្រជាជនណាម្នាក់មានរថយន្ត ឬម៉ូតូនោះទេ ។ តាមពិតទៅ ស្ទើរតែគ្មានប្រជាជនណាម្នាក់មានកង់ជិះនោះទេ ។[៣៧]

> មនុស្សគ្រប់គ្នាធ្វើដំណើរដោយថ្មើរជើង ។ យើងចំណាយពេលមួយ ថ្ងៃដើម្បីធ្វើដំណើរពីអន្លង់វែងទៅរំចេក ។ យើងទៅដល់រំចេក នៅពេល

ថ្ងៃត្រង់ ។ ប្រជាជនមួយចំនួនជិះរទេះ ។ ប៉ុន្តែ ដោយសារគ្រួសាររបស់មិនមានរទេះទេ យើងត្រូវដើរ និងឈប់សម្រាកតាមផ្លូវ ប្រសិនបើយើងចង់ធ្វើដំណើរទៅតំបន់ឆ្ងាយ ដូចជា ស្រែណោយ ។[៣៨]

ដោយសារតែកង្វះមធ្យោបាយធ្វើដំណើរ និងផ្លូវថ្នល់ វាមិនមែនជារឿង ដែលគួរឲ្យភ្ញាក់ផ្អើលទេដែលប្រជាជនកម្រនឹងចាកចេញពីភូមិណាស់ ។ ឈិត ធី បានរៀបរាប់អំពីជីវិតរបស់គាត់ នៅក្នុងរជ្ជកាលព្រះបាទ នរោត្តម សីហនុ (១៩៤១ - ១៩៥៥) ថា "ប្រជាជនកម្រមានទំនាក់ទំនងជាមួយគ្នាណាស់ ។ អ្នកភូមិរស់នៅ ធ្វើការងារ និងប្រកបរបររកស៊ីតែនៅក្នុងភូមិរៀងៗខ្លួន ។"[៣៩] ចាន់ បៃ បានលើកឡើងថា " ខ្ញុំមិនដែលបានចាកចេញពីភូមិរបស់ខ្ញុំនោះឡើយ ក្នុងមួយយុវវ័យរបស់ខ្ញុំ ។"[៤០]

ដោយសារតែខ្វះការផ្លាស់ប្តូរ និងភាពក្រីក្រនៅក្នុងតំបន់ ការផ្គត់ផ្គង់សម្លៀកបំពាក់នៅមានកម្រិតតិចតួចណាស់ ។

> ប្រជាជននៅភូមិរំចេកភាគច្រើនជាអ្នកក្រ ។ ជាទូទៅ គាត់គ្រាន់តែរុំក្រណាត់ ដើម្បីគ្រាន់តែបិទបាំងរាងកាយតែប៉ុណ្ណោះ ។ បុរសភាគច្រើនមិនមានអាវពាក់ទេ ហើយបុរសមួយចំនួនទៀត មិនមានខោស្លៀកទេ ។ មិនមានកន្លែងលក់សម្លៀកបំពាក់ច្រើនទេ ។ ជនជាតិថៃធ្វើដំណើរមកដល់ទីនេះរៀងរាល់១០ខែម្តង ដើម្បីធ្វើជំនួញ ។[៤១]

ទំនៀមទម្លាប់ និងពិធីបុណ្យនៅក្នុងភូមិ ក៏មានលក្ខណៈខុសពីពិធីនាពេលបច្ចុប្បន្នដែរ ។ បើយោងតាម ចាន់ បៃ "នៅក្នុងពិធីរៀបមង្គលការ ពុំមានការលេងភ្លេង ឬគោះស្គរទេ ។ ប្រជាជនគ្រាន់តែសម្លាប់ជ្រូកមួយ ហើយចាស់ៗនៅក្នុងភូមិបីបួននាក់ ធ្វើជាអធិបតីនៅក្នុងពិធី ដើម្បីជាការគោរពទៅដល់ព្រលឹងដូនតាតែប៉ុណ្ណោះ ។"[៤២]

រហូតដល់ទសវត្សរ៍ឆ្នាំ១៩៨០ តំបន់អន្លង់វែងនៅតែសំបូរទៅដោយសត្វព្រៃជាច្រើន ។ "ដំរីតែងតែចូលមកក្នុងភូមិតាដេវ ។"[៤៣] តំបន់នេះក៏មានសត្វគោព្រៃ ក្របីព្រៃ និងសត្វខ្លា ។ ជារឿយៗ អ្នកគ្រប់គ្រងបារាំងប្រចាំខេត្តស្ទឹងត្រែង (មានឋានៈស្មើអភិបាល

ខេត្ត) បានមកកត់ត្រាតារាងតម្លៃនៅលើទីផ្សារ ចំពោះស្បែក សត្វដំរី ស្បែកសត្វមាស ថ្គាមខ្លា ភ្លុក និងស្រកាពង្រួល ។[៤៤]

សត្វព្រៃត្រូវបានមើលឃើញថាជាប្រភពចំណូលផង និងជាគ្រោះថ្នាក់ផង ។ ដូចដែល មី ឆេង បានលើកឡើង «យើងប្រើប្រាស់កាំភ្លើង ដើម្បីការពារភូមិរបស់យើងពីការទន្ទ្រានរបស់សត្វដំរី ដែលបានចូលមកស៊ីស្រូវរបស់យើង ។»[៤៥] ធីន ប៊ិន ក៏បានរំឭកដែរថា សត្វខ្លា គឺជាការព្រួយបារម្ភរបស់ប្រជាជននៅក្នុងភូមិ ដោយសារតែសត្វខ្លាបានចូលមកក្នុងភូមិនៅពេលយប់ និងបានសម្លាប់សត្វឆ្កែ ។ ធីន ប៊ិន បានបន្ថែមថា «កាលពីដើម យើងហូបសាច់សត្វក្តាន់ ទន្សាយ ឈ្លូស អណ្តើក តឹកកែ បង្កួយ និងសត្វ ព្រៃផ្សេងៗទៀត ។ ប៉ុន្តែ សត្វទាំងអស់នោះ បានបាត់បង់អស់ហើយសព្វថ្ងៃនេះ ។»[៤៦]

ជំពូក២

# ការកកើតនៃចលនាកុម្មុយនីស្ត និងការមកដល់ជាលើកដំបូងរបស់ខ្មែរក្រហមនៅអន្លង់វែង

## សេចក្តីផ្តើម

អន្លង់វែងគឺជាស្រុកដាច់ស្រយាលមួយរបស់កម្ពុជា ដែលស្ថិតនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ។ ជាប្រវត្តិសាស្ត្រតំបន់អន្លង់វែងនេះ មិនត្រូវបានរដ្ឋាភិបាលកណ្តាលយកចិត្តទុកដាក់ ហើយប្រជាជននៅតំបន់នេះហាក់នៅដាច់ឆ្ងាយពីពិភពខាងក្រៅ ។ ស្ថានភាពឯកោរបស់តំបន់នេះ បានបង្កភាពងាយស្រួលដល់ខ្មែរក្រហម ក្នុងការបង្កិតបង្កំ និងបញ្ចុះបញ្ចូលប្រជាជននៅតំបន់នេះឲ្យចូលរួមជាមួយចលនារបស់ខ្លួន ។

"ខ្មែរក្រហម" គឺជាឈ្មោះដែលសម្តេចព្រះ នរោត្តម សីហនុ មានបន្ទូលសំដៅទៅក្រុមកុម្មុយនីស្តមួយក្រុម ដែលប្រឆាំងនឹងព្រះអង្គនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ ឈ្មោះផ្លូវការរបស់ក្រុមនេះ គឺបក្សកុម្មុយនីស្តកម្ពុជា ដែលបានគ្រប់គ្រងប្រទេសកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ទោះជាយ៉ាងនេះក្តី តំបន់ជនបទភាគច្រើននៃប្រទេសកម្ពុជាបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម មុនជ័យជម្នះ ខែមេសា ឆ្នាំ១៩៧៥ទៅទៀត ។ ដោយសារតំបន់អន្លង់វែង ជាតំបន់ដាច់ស្រយាល តំបន់នេះស្ថិតនៅក្នុងចំណោមតំបន់ដំបូងបង្អស់ ដែលបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។

តំបន់អន្លង់វែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម នៅដើមឆ្នាំ១៩៧០ បន្ទាប់ពីការកាន់កាប់រយៈពេលខ្លីរបស់កងទ័ព លន់ នល់ ។ នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ជីវិតរបស់ប្រជាជននៅតំបន់អន្លង់វែង មានការផ្លាស់ប្តូរយ៉ាងខ្លាំង ។ មិនតែប៉ុណ្ណោះ មនោគមន៍វិជ្ជាបដិវត្តន៍របស់ខ្មែរក្រហមតម្រូវឲ្យប្រជាជននៅអន្លង់វែងបោះបង់ចោលនូវប្រពៃណី និងការអនុវត្តទាំងឡាយរបស់ខ្លួន ។ នៅទីបំផុត ប្រជាជនត្រូវបានតម្រូវឲ្យបោះបង់ចោលផ្ទះសម្បែងរបស់ខ្លួនថែមទៀត ។

បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥ ប្រជាជននៅអន្លង់វែង បន្តរស់នៅក្នុងផ្ទះរបស់ខ្លួន ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ទោះជាយ៉ាងនេះក្តី ប្រជា

ជនទាំងអស់ត្រូវបានរៀបចំ ទៅតាមក្រុមផ្សេងៗ ដើម្បីធ្វើស្រែចម្ការ និងកាប់ឆ្ការព្រៃ ឬបំពេញការងារពលកម្មផ្សេងៗទៀត ។[៤៧] ខ្មែរក្រហមបានកាន់កាប់ និងរៀបចំតំបន់នេះ ទៅតាមរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួន ។[៤៨]

នៅឆ្នាំ១៩៧៧ ប្រជាជនទាំងអស់នៅអន្លង់វែងត្រូវបានបង្ខំឲ្យចាកចេញពីអន្លង់វែង ទៅរស់នៅតាមសហករណ៍ ដែលត្រូវបានបង្កើតឡើងនៅតំបន់ផ្សេង ។ នៅពេលដែលរបបខ្មែរក្រហមត្រូវបានផ្តួលរំលំនៅដើមឆ្នាំ១៩៧៩ ប្រជាជនដែលធ្លាប់រស់នៅតំបន់អន្លង់វែងបានធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ ។ នៅពេលនោះ ប្រជាជនបានប្រឈមនឹងបញ្ហាលំបាកសាជាថ្មីរវាងកងទ័ពខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាល ដែលប្រណាំងប្រជែងដណ្តើមការគាំទ្រពីប្រជាជន ។ កងទ័ពរបស់ខ្មែរក្រហមដែលនៅសេសសល់ បានរត់ភៀសខ្លួនទៅរស់នៅលើភ្នំដងរែក នៅពេលដែលកងទ័ពវៀតណាម និងកងទ័ពរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា កាន់កាប់តំបន់អន្លង់វែង ។ ប្រជាជនដែលមិនធ្លាប់មានទំនាក់ទំនងជាមួយនឹងកងទ័ពខ្មែរក្រហម ត្រូវបានបង្ខំឲ្យធ្វើការសម្រេចចិត្តរវាងការបន្តរស់នៅក្នុងភូមិកំណើតរបស់ខ្លួនក្រោមការគ្រប់គ្រងរបស់កងទ័ពវៀតណាម និងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា ឬភៀសខ្លួនទៅតាមខ្មែរក្រហមទៅភ្នំដងរែក និងប្រទេសថៃ ។

## ការកកើតឡើងនៃចលនាកុម្មុយនីស្តនៅកម្ពុជា

ទោះបីជាអន្លង់វែងគឺជាជំពូកចុងក្រោយនៃមេរៀនស្តីអំពីប្រវត្តិចលនាកុម្មុយនីស្តនៅកម្ពុជាក្តី ក៏ចលនានេះមិនបានចាប់ផ្តើមនៅទីនោះទេ ។ ដើម្បីយល់ឲ្យបានច្បាស់នូវប្រវត្តិសាស្ត្រចុងក្រោយរបស់ចលនាកុម្មុយនីស្តនៅកម្ពុជា និងថាតើចលនានេះមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយតំបន់អន្លង់វែង យើងត្រូវក្រឡេកទៅមើលប្រវត្តិដំបូងនៃចលនាកុម្មុយនីស្តនៅតំបន់អាស៊ីអាគ្នេយ៍ (ឬរឿងរ៉ាវដែលបានកើតឡើងនៅក្នុងសហព័ន្ធឥណ្ឌូចិន នៅទសវត្សរ៍ឆ្នាំ១៩៤០) ។

ប្រវត្តិដំបូងនៃចលនាកុម្មុយនីស្តនៅកម្ពុជា មានទំនាក់ទំនងជិតស្និទ្ធទៅនឹងចលនាតស៊ូប្រឆាំងនឹងអាជ្ញាធរអាណានិគមបារាំង ដែលនៅពេលនោះចលនានេះ មិនទាន់ត្រូវបានបង្កើតឲ្យទៅជាកម្លាំងរឹងមាំមួយនៅឡើយទេ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៤០ ។ នៅឆ្នាំ

១៩៣៩ បារាំងត្រូវបានកងទ័ពរបស់របបណាហ្ស៊ីអាល្លឺម៉ង់ផ្តួលរំលំ ។ របបណាហ្ស៊ីបានបង្កើតរបបអាយ៉ងមួយ ដើម្បីគ្រប់គ្រងផ្នែកខ្លះនៃប្រទេសបារាំង និងផលប្រយោជន៍ទាំងឡាយរបស់អាណានិគមបារាំង ។ អាល្លឺម៉ង់បានបញ្ជារដ្ឋាភិបាលវីជីរបស់បារាំងឲ្យធ្វើការណែនាំដល់រដ្ឋបាលអាណានិគមនៅឥណ្ឌូចិនទាំងអស់ ឲ្យសហការជាមួយប្រទេសជប៉ុន ដែលជាសម្ព័ន្ធមិត្ររបស់អាល្លឺម៉ង់ ។

ស្ទើរតែពេញមួយរយៈពេលនៃសង្គ្រាមលោកលើកទីពីរ ជប៉ុនផ្តោតការយកចិត្តទុកដាក់ទៅលើតំបន់ប៉ាស៊ីហ្វិក និងដាក់វត្តមានរបស់ខ្លួនកម្រិតតូចមួយនៅតំបន់ឥណ្ឌូចិន ។ ជាក់ស្តែង នៅប្រទេសកម្ពុជា ជប៉ុនបានបង្កើតទីតាំងកងទ័ពរបស់ខ្លួនមួយនៅទីក្រុងភ្នំពេញ និងបានអនុញ្ញាតឲ្យអាជ្ញាធរអាណានិគមបារាំងបន្តការគ្រប់គ្រង រដ្ឋបាលរបស់ខ្លួននៅកម្ពុជា ដូចដែលបារាំងធ្លាប់បានធ្វើតាំងពីឆ្នាំ១៨៦៣មក ។

ដោយមើលឃើញបារាំងត្រូវបានអាល្លឺម៉ង់ផ្តួលរំលំនៅឆ្នាំ១៩៣៩ ប្រទេសជិតខាងរបស់កម្ពុជា ពោលគឺ ប្រទេសថៃ បានឆ្លៀតឱកាសដណ្តើមយកខេត្តបាត់ដំបង និងសៀមរាប ព្រមទាំងតំបន់មួយចំនួនទៀតរបស់ប្រទេសឡាវ ។ នៅឆ្នាំ១៩៤០ ដោយបានដឹងអំពីការចុះខ្សោយរបស់បារាំង ថៃបានវាយប្រហារមកលើភាគឦសាននៃប្រទេសកម្ពុជា ។

សង្គ្រាមបារាំង-ថៃ (១៩៤០-១៩៤១) គឺជាការវាយប្រយុទ្ធគ្នាក្នុងទ្រង់ទ្រាយតូចប៉ុណ្ណោះ ។ ប៉ុន្តែ សង្គ្រាមនេះបានបញ្ចប់ទៅដោយការបន្សល់នូវលក្ខខណ្ឌអាក្រក់សម្រាប់បារាំង និងប្រទេសក្រោមអាណានិគមរបស់ខ្លួន ។ នៅក្រោមកិច្ចព្រមព្រៀងសន្តិភាព ដែលសម្រុះសម្រួលដោយជប៉ុន បារាំងបានប្រគល់ខេត្តបាត់ដំបង និងសៀមរាបរបស់កម្ពុជាទៅឲ្យថៃ ។[៤៩] ជប៉ុនបានអនុញ្ញាតឲ្យបារាំងបន្តគ្រប់គ្រងផ្នែកសេសសល់របស់កម្ពុជារហូតដល់ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ ដែលបន្ទាប់ពីពេលនោះមក ជប៉ុនបានអនុវត្តការគ្រប់គ្រងរបស់ខ្លួន មកលើប្រទេសកម្ពុជាដោយផ្ទាល់រហូតដល់ថ្ងៃដែលជប៉ុនចាញ់សង្គ្រាមលោកលើកទីពីរ ។ ខណៈពេលដែលជប៉ុននិងអាល្លឺម៉ង់បានចាញ់សង្គ្រាមលោកលើកទីពីរបារាំង បានចាប់ផ្តើមអាណានិគមរបស់ខ្លួនឡើងវិញនៅឥណ្ឌូចិន ។ ប៉ុន្តែ រដ្ឋបាលអាណានិគមបារាំងនៅលើទឹកដីនេះបានផ្លាស់ប្តូរទំព័រថ្មីមួយបាត់ទៅហើយ ។

បរាជ័យរបស់បារាំងនៅក្នុងសង្គ្រាមលោកលើកទីពីរ និងអសមត្ថភាពរបស់បារាំង

ក្នុងការការពារផលប្រយោជន៍របស់ខ្លួននៅលើទឹកដីឥណ្ឌូចិន បានឆ្លុះបញ្ចាំងអំពីភាពអន់ខ្សោយរបស់បារាំង ។ ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ធ្លាប់មានប្រវត្តិជាមួយនឹងការបះបោរ ការតស៊ូប្រឆាំង ចលនាទ័ពព្រៃ មនោគមន៍វិជ្ជាបដិវត្តន៍ ទស្សនជាតិនិយម និងជំនួយពីបរទេស ។ កត្តាទាំងអស់នេះបានជំរុញឲ្យមានការងើបឡើង តស៊ូពីសំណាក់អ្នកប្រយុទ្ធដើម្បីសេរីភាពជំនាន់ក្រោយ ដែលមិនដូចជា ក្រុមផ្សេងៗទៀតនោះទេ ។

ខ្មែរឥស្សរៈ គឺជាចលនាជាតិនិយម ដែលប្រឆាំងនឹងអាណានិគមបារាំង ។ ចលនានេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៥ ដោយមានជំនួយពីប្រទេសថៃ ។ ចលនានេះមានដើមកំណើតនៅទីក្រុងបាងកក ដែលនៅទីនោះប្រាពិសិទ្ធ ដានិត (ប៉ុក ឃុន) ដោយមានជំនួយពីប្រទេសថៃ បានបង្កើតគណបក្សខ្មែរឥស្សរៈ ។ ថៃមានការអាក់អន់ចិត្តចំពោះការប្រគល់ខេត្តបាត់ដំបង និងសៀមរាប មកឲ្យកម្ពុជាវិញ ។ ដោយមានបំណងចង់បង្កឲ្យមានការបះបោរ ថៃបានគាំទ្រដល់ការបង្កើតចលនាខ្មែរឥស្សរៈ (ដែលមានច្រើនក្រុមផ្សេងៗគ្នាដែលត្រូវបានបង្កើតឡើងដោយឯករាជ្យ នៅតាមតំបន់ជាច្រើននៅទូទាំងប្រទេសកម្ពុជា) ។[៥០] ចលនាទាំងនេះត្រូវបានបង្កើតឡើងជាចម្បងដើម្បីផ្តួលរំលំអាជ្ញាធរអាណានិគមបារាំង ។ ទោះជាបែបនេះក្តី ចលនាទាំងនេះក្រោយមកបានក្លាយទៅជាការជំរុញលើកទឹកចិត្តក្រុមមេដឹកនាំកម្ពុជាជំនាន់ថ្មីឲ្យប្រឆាំងទៅនឹងរដ្ឋកម្ពុជាឯករាជ្យទៅវិញ ។

នៅពេលដែលចលនាខ្មែរឥស្សរៈនៅភាគបស្ចិមស្វែងរកការគាំទ្រពីប្រទេសថៃ ក្រុមចលនាខ្មែរឥស្សរៈនៅភាគបូព៌ា បានសហការជាមួយក្រុមកុម្មុយនីស្តវៀតមិញ ។

វៀតមិញ គឺជាក្រុមនៃបក្សសម្ព័ន្ធកុម្មុយនីស្តវៀតណាម ដែលប្រឆាំងនឹងការគ្រប់គ្រងលើប្រទេស វៀតណាមឡើងវិញពីសំណាក់បារាំង ។ នៅឆ្នាំ១៩៤៩ ក្រុមវៀតមិញទទួលបានការគាំទ្រពីចិនកុម្មុយនីស្ត ដែលបានអនុញ្ញាតឲ្យក្រុមនេះ ពង្រីកការតស៊ូប្រឆាំងនឹងបារាំង ពីសង្គ្រាមឈ្លបទៅជាសង្គ្រាមរវាងកងទ័ពនៃប្រទេសទាំងពីរ ។ នៅឆ្នាំ១៩៥០ ប្រទេសក្នុងតំបន់ឥណ្ឌូចិនបានចាប់ផ្តើមងើបបះបោរ ។

សង្គ្រាមឥណ្ឌូចិនលើកទីមួយគឺជាការបះបោរប្រឆាំងនឹងអាណានិគម ។ ស្មារតីជាតិនិយមបានផុសឡើងទៅជាកម្លាំងដ៏ខ្លាំងក្លាមួយ នៅក្នុងអំឡុងពេលនៃសង្គ្រាមលោកលើកទីពីរ ហើយការតស៊ូប្រឆាំងនឹងអាណានិគមបានផ្ទុះឡើងនៅទូទាំងអាស៊ីអាគ្នេយ៍ ។ ទោះជាយ៉ាងនេះក្តី ការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លានៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទីមួយ កើត

ឡើងនៅប្រទេសវៀតណាម ។ ស្របពេលជាមួយគ្នានេះដែរអ្នកជាតិនិយមខ្មែរក៏បានចាប់ផ្តើមធ្វើការតស៊ូប្រហាក់ប្រហែលគ្នាដើម្បីឯករាជ្យរបស់ខ្លួនដែរ ។

នៅពេលដែលវៀតមិញកំពុងតស៊ូប្រឆាំងនឹងបារាំងនៅក្នុងប្រទេសវៀតណាម ក្រុមខ្មែរឥស្សរៈបានចាប់ផ្តើមសង្គ្រាមក្នុងទ្រង់ទ្រាយតូច ប៉ុន្តែសំខាន់នៅក្នុងប្រទេសកម្ពុជា ។ ក្រុមឥស្សរៈមួយចំនួន គឺជាក្រុមចោរព្រៃខណៈមួយចំនួនទៀត គឺជាអ្នកប្រយុទ្ធដើម្បីសេរីភាព ។ ក្រុមទាំងពីរនេះគឺជាការគំរាមកំហែងជាប្រចាំដល់អាជ្ញាធរបារាំង និងកងយោធពលខេមរភូមិន្ទ ដែលមានទីតាំងនៅតាមទីជនបទ ។ ទោះបីជាក្រុមឥស្សរៈហាក់មានគោលដៅនយោបាយរួម ក្នុងការទាមទារឯករាជ្យជូនប្រទេសកម្ពុជា ក្រុមនេះមិនដែលរួបរួមគ្នាជាធ្លុងមួយ និងស្មើភាពគ្នា ដូចក្រុមវៀតមិញទេ ។ ក្រុមឥស្សរៈជាច្រើនបានប្រព្រឹត្តអំពើឆក់ប្លន់ និងមិនមានទិសដៅនយោបាយច្បាស់លាស់ទេ ។ នៅពេលដែលក្រុមមួយចំនួនស្វែងរកជំនួយពីប្រទេសថៃ ក្រុមមួយចំនួនទៀតស្វែងរកជំនួយពីវៀតមិញនៅក្រោមស្លាកកុម្មុយនីស្តនិយម ។[៥១]

នៅខែមេសា ឆ្នាំ១៩៥០ សមាជិកឆ្វេងនិយមជាង២០០នាក់នៃចលនាខ្មែរឥស្សរៈបានជួបប្រជុំគ្នានៅខេត្តកំពត និងបានបង្កើត «រណសិរ្សរួបរួមខ្មែរឥស្សរៈ» ដោយឈរលើគោលការណ៍កុម្មុយនីស្ត ។ ចលនានេះតំណាងឲ្យសម្ព័ន្ធភាពរវាងប្រជាជនដែលរស់នៅតាមទីក្រុង បញ្ញវន្ត ប្រជាកសិករ និងពុទ្ធសាសនិកអ្នកជាតិនិយម ។ រណសិរ្សនេះដឹកនាំដោយ សឺង ង៉ុកមិញ (អាចារ្យបង្រៀន ដែលជាអាចារ្យពុទ្ធសាសនា) និងបានសហការជាមួយវៀតណាមក្នុងការប្រយុទ្ធប្រឆាំងនឹងបារាំង ។ រណសិរ្សនេះក៏តំណាងឲ្យការចាប់ផ្តើមសម្រាប់សមាជិកនាពេលអនាគតជាច្រើនរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលជាបក្សមួយ ដែលនៅទីបញ្ចប់បានដណ្តើមកាន់កាប់ប្រទេសកម្ពុជា និងបង្កើតរបប«កម្ពុជាប្រជាធិបតេយ្យ» ។[៥២]

ឧទាហរណ៍ តាម៉ុក, ជា ស៊ីម និង ហេង សំរិន គឺជាជនបដិវត្តន៍នៅក្នុងចលនាខ្មែរឥស្សរៈ ។[៥៣] ទោះជាយ៉ាងនេះក្តី មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ដូចជា សាឡុត ស (ប៉ុល ពត) , សុន សេន, ខៀវ សំផន និង អៀង សារី បានក្លាយទៅជាជនកុម្មុយនីស្តនៅពេលដែលខ្លួនកំពុងសិក្សារៀនសូត្រនៅក្រៅប្រទេស ។

នៅឆ្នាំ១៩៥១ កុម្មុយនីស្តវៀតណាមបានជួយណែនាំឲ្យមានការបង្កើតបក្សប្រជា

ជនបដិវត្តន៍ខ្មែរដែលជាប្រភពដើមនៃបក្សកុម្មុយនីស្តកម្ពុជា ។ សមាជិកគណៈកម្មាធិការនៃបក្សនេះរួមមាន សឺង ង៉ុកមិញ (តំណែងកំពូល) , ស៊ីវ ហេង (កិច្ចការកងទ័ព) , ទូ សាមុត (អប់រំមនោគមន៍វិជ្ជា) និង ចាន់ សម័យ (កិច្ចការសេដ្ឋកិច្ច) ។ ដូចរណសិរ្សរួបរួមឥស្សរៈដែរ បក្សប្រជាជនបដិវត្តន៍ខ្មែរស្វែងរកការណែនាំពីកុម្មុយនីស្តវៀតណាម ។[៥៤]

អនុលោមតាមសន្និសីទសន្តិភាពទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ (ដែលនៅពេលនោះសង្គ្រាមឥណ្ឌូចិន លើកទីមួយត្រូវបានបញ្ចប់ជាផ្លូវការ) រដ្ឋបាលអាណានិគម បារាំងត្រូវបានដកចេញពីប្រទេសវៀតណាម ។ នៅពេលនោះ វៀតណាមត្រូវបានបែងចែកជាពីរគឺ វៀតណាមខាងជើងដែលមានទំនោរទៅរកលទ្ធិកុម្មុយនីស្ត និងវៀតណាមខាងត្បូងដែលមានទំនោរទៅរកបស្ចិមប្រទេស ។ ជាផ្នែកមួយនៃសន្និសីទ សន្តិភាពទីក្រុងហ្សឺណែវ កងកម្លាំងវៀតមិញទាំងអស់ ត្រូវបានតម្រូវឲ្យដកចេញពីកម្ពុជា ។

ទោះជាយ៉ាងនេះក្តី កងទ័ព និងទីប្រឹក្សាវៀតណាមមួយចំនួន បន្តស្នាក់នៅកម្ពុជាបន្តទៀត ។ ដោយមានការព្រួយបារម្ភអំពីសុវត្ថិភាពបដិវត្តន៍ នៅពេលដែលប្រព័ន្ធនយោបាយមានការផ្លាស់ប្តូរ ស៊ីវ ហេង, ចាន់ សម័យ និងកម្មាភិបាល បក្សប្រជាជនបដិវត្តន៍ខ្មែរជាងមួយពាន់នាក់ផ្សេងទៀត បានរត់ភៀសខ្លួន ទៅប្រទេសវៀតណាមដែលនៅទីនោះក្រុមនេះបានចូលរួមជាមួយ សឺង ង៉ុកមិញ និងសមាជិកបក្សផ្សេងទៀត ដែលបានភៀសខ្លួនទៅវៀតណាមមុននេះបន្តិច ។

រយៈពេលប៉ុន្មានឆ្នាំបន្ទាប់ពីសន្និសីទសន្តិភាពទីក្រុងហ្សឺណែវ (១៩៥៥-១៩៥៩) គឺជាពេលវេលាដែលចលនាកុម្មុយនីស្តនៅកម្ពុជាមានដំណើរវិវត្តយឺត ។ នៅមុនសន្និសីទសន្តិភាពទីក្រុងហ្សឺណែវ សម្តេចព្រះ នរោត្តម សីហនុ បានបញ្ចុះបញ្ចូលរដ្ឋាភិបាលបារាំងថា មធ្យោបាយតែមួយគត់ដែលអាចទប់ស្កាត់បដិវត្តន៍កុម្មុយនីស្តបាន គឺការប្រគល់ឯករាជ្យមកឲ្យកម្ពុជា ។ ដោយបន្តស្ថិតនៅក្នុងស្ថានភាពចលាចលនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទីមួយ បារាំងបានបន្ទន់ឥរិយាបថហើយ កម្ពុជាទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ ។ ទោះបីជាកម្ពុជាប្រហែលជាមានផលប្រយោជន៍ច្រើនសម្រាប់អាណានិគមបារាំងក៏ដោយក៏បារាំងផ្តោតការយកចិត្តទុកដាក់របស់ខ្លួនជាចម្បងទៅលើការគ្រប់គ្រងនៅវៀតណាម ។

ក្រោយពីកម្ពុជាទទួលបានឯករាជ្យពីបារាំង និងបន្ទាប់ពីសន្និសីទសន្តិភាព ទីក្រុងហ្សឺណែវមក ក្រុមខ្មែរឥស្សរៈជាច្រើនបានបោះបង់ចោលការតស៊ូរបស់ខ្លួន ហើយកុម្មុយ

និស្តវៀតណាមបានដកខ្លួនចេញពីប្រទេសកម្ពុជាស្ទើរតែទាំងស្រុង ។ ព្រឹត្តិការណ៍ទាំងអស់នេះបានធ្វើឲ្យចលនាកុម្មុយនិស្តនៅកម្ពុជាចុះខ្សោយ ហើយដោយមានការធ្វើទុក្ខបុកម្នេញពីសំណាក់កងទ័ពរបស់សម្តេចព្រះ នរោត្តម សីហនុ មេដឹកនាំកុម្មុយនិស្តកម្ពុជាជាច្រើនបានរត់ចូលព្រៃ ។

នៅក្រោយឆ្នាំ១៩៥៤ ក្រុមកុម្មុយនិស្តសេសសល់នៅក្នុងប្រទេសកម្ពុជា បានប្រឹងប្រែងតស៊ូ ដើម្បីបានរស់រានមានជីវិត ។ នៅក្រោមការដឹកនាំរបស់លោក លន់ នល់ ដែលជាអគ្គមេបញ្ជាការកងទ័ពរបស់សម្តេចព្រះ នរោត្តម សីហនុ រដ្ឋាភិបាលបានតាមចាប់ខ្លួនមេដឹកនាំកុម្មុយនិស្តជាច្រើន ដែលបានបង្ខំឲ្យក្រុមនេះរត់ចូលព្រៃ ។

ពីថ្ងៃទី២៨ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ សមាជសម្ងាត់មួយរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរត្រូវបានរៀបចំឡើងនៅស្ថានីយរថភ្លើងមួយនៅទីក្រុងភ្នំពេញ ដោយមានការចូលរួមពីសំណាក់សមាជិក៧នាក់មកពីសាខានៅទីក្រុង និង១៤នាក់ផ្សេងទៀតមកពីសាខានៅតាមជនបទ ។ សមាជនេះបានរៀបចំបក្សសាជាថ្មីឡើងវិញ កំណត់គោលនយោបាយថ្មី និងផ្លាស់ប្តូរឈ្មោះបក្ស ទៅជាបក្សពលករកម្ពុជា ដែលមាន ទូ សាមុត ជាលេខាបក្ស និង នួន ជា ជាអនុលេខា ។ ប៉ុល ពត មានតំណែងលំដាប់ទីបីនៅក្នុងបក្ស ហើយបានក្លាយជាអនុលេខាបក្សទីពីរ នៅឆ្នាំ១៩៦១ ។[៥៥]

នៅខែកុម្ភៈ ឆ្នាំ១៩៦៣ បក្សពលករកម្ពុជាបានបើកសមាជបន្ទាន់មួយ បន្ទាប់ពី ទូ សាមុត បានបាត់ខ្លួននៅឆ្នាំ១៩៦២ ។ សមាជនេះបានជ្រើសរើស ប៉ុល ពត ជាលេខាបក្ស និង នួន ជា ជាអនុ លេខាដដែល ។ ភ្លាមៗបន្ទាប់ពីត្រូវបានជ្រើសតាំងជាលេខាបក្ស ប៉ុល ពត បានភៀសខ្លួនទៅជិរកងទ័ពវៀតណាម “មន្ទីរ១០០” នៅជាប់ព្រំដែនស្រុកមេមត់ ភាគឦសាននៃប្រទេសកម្ពុជា ។ នៅឆ្នាំ១៩៦៥ ប៉ុល ពត បានធ្វើដំណើរដោយថ្មើរជើងតាមផ្លូវលំហូជីមិញ ឆ្ពោះទៅកាន់ទីក្រុងហាណូយ ដើម្បីពិភាក្សាជាមួយវៀតណាមខាងជើង ។ ប៉ុល ពត ក៏មានគម្រោងទៅធ្វើទស្សនកិច្ចនៅប្រទេសចិន និងកូរ៉េខាងជើងដែរ ។

នៅឆ្នាំ១៩៦៦ បន្ទាប់ពីមកដល់កម្ពុជាវិញ ប៉ុល ពត បានប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនិស្តកម្ពុជា ។ គណៈកម្មាធិការមជ្ឈិមបក្សនៅពេលនោះរួមមាន ប៉ុល ពត, នួន ជា, អៀង សារី, វ៉ន វ៉េត និង សុន សេន ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ បក្សកុម្មុយនិស្តកម្ពុជាទទួលបានសមាជិកថ្មីជាច្រើន ដែលភាគច្រើនរស់នៅតំបន់ដាច់ស្រយាលតាមបណ្តោយ

ព្រំដែនវៀតណាម ដែលនៅឆ្ងាយពីកងទ័ពរបស់សម្ដេចព្រះ នរោត្តម សីហនុ ។

ដោយនៅឆ្ងាយពីការគ្រប់គ្រងរបស់រដ្ឋាភិបាល កងកម្លាំងកុម្មុយនីស្ដកម្ពុជា បានប្រមូលផ្ដុំអំណាចរបស់ខ្លួន និងរៀបចំកម្លាំងឡើងវិញ ដើម្បីត្រៀមសម្រាប់ស្ថានភាពអំណោយផលណាមួយ ដែលអាចអនុញ្ញាតឲ្យខ្លួនដណ្ដើមអំណាចបាន ។ នៅទីបំផុត ស្ថានភាពអំណោយផលនោះបានមកដល់នៅឆ្នាំ១៩៧០ នៅពេលដែល សម្ដេចព្រះ នរោត្តម សីហនុ ត្រូវបានផ្ដួលរំលំចេញពីអំណាច និងនៅពេលដែលរបប លន់ នល់ ត្រូវបានបង្កើតឡើង ។

ការទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ និងការបង្កើតរបប លន់ នល់ គឺជាលទ្ធផលនៃសម្ពាធជា ច្រើនដែលចេះតែកើនឡើងជាលំដាប់ទាំងពីខាងក្នុង និងពីខាងក្រៅទៅលើការគ្រប់គ្រងរបស់សម្ដេចព្រះ នរោត្តម សីហនុ ដែលជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់សម្ដេចព្រះ នរោត្តម សីហនុ ក្នុងការរក្សាអព្យាក្រឹតភាពរបស់កម្ពុជា ក្នុងអំឡុងពេលនៃសង្គ្រាមវៀតណាម ។

សង្គ្រាមវៀតណាម គឺជាពាក្យដែលប្រើសំដៅទៅលើការប្រយុទ្ធគ្នារវាងភាគីសហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង ក្នុងនាមជាភាគីមួយជាមួយនឹងភាគីវៀតណាមកុម្មុយនីស្ដ ដែលគាំទ្រដោយវៀតណាមខាងជើង ក្នុងនាមជាភាគីម្ខាងទៀត ។ ទោះបីជាការគាំទ្រពីដំបូងរបស់សហរដ្ឋអាមេរិក ផ្ដោតសំខាន់តែទៅលើជំនួយសេដ្ឋកិច្ច និងការផ្ដល់ប្រឹក្សាផ្នែកយោធាដល់វៀតណាមខាងត្បូងយ៉ាងណាក៏ដោយក្ដី ក៏ជំនួយនេះបានកើនឡើងជាលំដាប់រហូតទៅជាការទប់ទល់ទៅនឹងការគំរាមកំហែងរបស់កុម្មុយនីស្ដ ។ មកដល់ឆ្នាំ១៩៦៥ សហរដ្ឋអាមេរិកបានផ្ដល់ថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅឲ្យវៀតណាមខាងត្បូង ហើយជំនួយរបស់សហរដ្ឋអាមេរិកបានកើនឡើងយ៉ាងលឿន ពីជំនួយផ្នែកសេដ្ឋកិច្ច និងការប្រឹក្សាយោធាទៅជាជំនួយផ្នែកកម្លាំងទ័ព និងបុគ្គលិកយោធាយ៉ាងច្រើន ។ ខណៈពេលដែលសង្គ្រាមរវាងសហរដ្ឋអាមេរិក និងវៀតណាមខាងជើង កាន់តែមានភាពតានតឹងឡើង សហរដ្ឋអាមេរិកបានបង្កើន និងពង្រីកការទម្លាក់គ្រាប់បែករបស់ខ្លួនកាន់តែធំឡើង ។ ដូចការប៉ាន់ស្មាន កងទ័ពរបស់វៀតណាមកុម្មុយនីស្ដបានប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីគេចចេញពីគ្រាប់បែករបស់សហរដ្ឋអាមេរិក ។

សម្ដេចព្រះ នរោត្តម សីហនុ មិនមានជម្រើសច្រើនទេ ក្នុងការទប់ស្កាត់មិនឲ្យ

វៀតណាមកុម្មុយនីស្ត ប្រើប្រាស់ទឹកដីរបស់កម្ពុជា ។ កងយោធពលខេមរភូមិន្ទ មិនមានកម្លាំងគ្រប់គ្រាន់ ដើម្បីទប់ទល់ជាមួយនឹងកុម្មុយនីស្ត ហើយស្របពេលជាមួយគ្នានោះ សម្តេចព្រះ នរោត្តម សីហនុ ក៏កំពុងតែប្រឈមជាមួយនឹងជនកុម្មុយនីស្តកម្ពុជា ជាច្រើននៅតាមទីជនបទក្នុងប្រទេសកម្ពុជា ។

សម្តេចព្រះ នរោត្តម សីហនុ បានសម្លឹងមើលទៅក្រុមអភិរក្សនិយមនៅក្នុងជួររដ្ឋាភិបាល (ដែលរួមមានកងកម្លាំងប៉ូលីស និងយោធា) ដើម្បីវាយប្រហារជនកុម្មុយនីស្តដែលប្រឆាំងនឹងព្រះអង្គខណៈពេលដែលព្រះអង្គបន្តរក្សាទំនាក់ទំនងមិត្តភាពជាមួយវៀតណាមកុម្មុយនីស្ត ព្រមទាំងបន្តជំរុញកម្មវិធីកំណែទម្រង់នយោបាយ តាមបែបសង្គមនិយមព្រះពុទ្ធសាសនារបស់ព្រះអង្គ ។ កម្មវិធីនយោបាយនេះទទួលបានជោគជ័យ ដែលស្របពេលជាមួយគ្នានោះ សម្តេចព្រះ នរោត្តម សីហនុទទួលជំនួយយោធាពីសហរដ្ឋអាមេរិក ។ ប៉ុន្តែ នៅខែវិច្ឆិកា ឆ្នាំ១៩៦៣ បន្ទាប់ពីបដិសេធជំនួយរបស់សហរដ្ឋអាមេរិក សម្តេចព្រះ នរោត្តម សីហនុ មិនអាចរក្សាបាននូវកម្មវិធីសុខុមាលភាពសង្គម ដែលប្រកបដោយការចំណាយយ៉ាងច្រើនតទៅទៀតបានទេ ។ ដើម្បីទប់ទល់ទៅនឹងការខ្វះខាតនេះ សម្តេចព្រះ នរោត្តម សីហនុ បានធ្វើជាតូបនីយកម្មទៅលើការនាំចេញ និងនាំចូលរបស់កម្ពុជា ដែលនយោបាយនេះមានប្រសិទ្ធភាពរយៈពេលខ្លី ក្នុងការទ្រទ្រង់កម្មវិធីសង្គមរបស់ព្រះអង្គ ។ ប៉ុន្តែ សម្រាប់លទ្ធផលរយៈពេលវែង កម្មវិធីនយោបាយបែបនេះបានជំរុញឲ្យមានការដោះដូរនៅក្នុងទីផ្សារងងឹត ដែលបានបណ្តាលឲ្យរដ្ឋាភិបាលបាត់បង់ចំណូលពន្ធអស់ជាច្រើន ។

ក្រុមស្តាំនិយម (ដែលរួមមាន ប៉ូលីសទាហាន និងក្រុមអភិជន) ចាប់ផ្តើមខឹងសម្បារជាមួយនឹងការកើនឡើងនូវអស្ថេរភាពផ្នែកសេដ្ឋកិច្ច និងការកើនឡើងនៃក្រុមកុម្មុយនីស្ត ។ កម្លាំងកុម្មុយនីស្តកាន់តែមានភាពក្លៀវក្លាឡើង នៅក្នុងប្រតិបត្តិការយោធារបស់ខ្លួន ។ ដោយខ្វះជំនួយរបស់សហរដ្ឋអាមេរិក ការគំរាមកំហែងនៃការដណ្តើមអំណាចពីសំណាក់ក្រុមកុម្មុយនីស្តកាន់តែកើនឡើង ។

មកត្រឹមឆ្នាំ១៩៦៩ សម្តេចព្រះ នរោត្តម សីហនុមិនអាចបញ្ចៀសប្រទេសកម្ពុជាឲ្យចេញផុតពីសង្គ្រាមវៀតណាមបានតទៅទៀតទេ ។ដោយមានការអាក់អន់ចិត្តជាមួយភាពព្រងើយកន្តើយរបស់សម្តេចព្រះ នរោត្តម សីហនុ និងដោយមើលឃើញពីសកម្មភាព

របស់វៀតណាមកុម្មុយនីស្តនៅក្នុងទឹកដីកម្ពុជា សហរដ្ឋអាមេរិកបានចាប់ផ្តើមទម្លាក់គ្រាប់បែកក្នុងទ្រង់ទ្រាយធំ និងជាយុទ្ធសាស្ត្រ មកលើប្រទេសកម្ពុជា នៅឆ្នាំ១៩៦៩ ។[៥៦] ភាពខ្វះចន្លោះរបស់សម្តេចព្រះ នរោត្តម សីហនុ នៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ចជាតិ និងការពាររដ្ឋាភិបាលកម្ពុជាពីសត្រូវរបស់ខ្លួនទាំងខាងក្នុង និងខាងក្រៅ បានជំរុញឲ្យក្រុមដែលរិះគន់ព្រះអង្គចាប់ផ្តើមធ្វើសកម្មភាព ។

នៅឆ្នាំ១៩៧០ នៅពេលដែលសម្តេចព្រះ នរោត្តម សីហនុ យាងចេញពីប្រទេសកម្ពុជា ក្រុមស្តាំនិយមបានទម្លាក់ព្រះអង្គចេញពីអំណាច ។

## របប លន់ នល់ ៖ ១៩៧០-១៩៧៥

នៅខែមីនា ឆ្នាំ១៩៧០ រដ្ឋសភាជាតិបានបោះឆ្នោតទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងជាព្រះប្រមុខរដ្ឋ និងបានបង្កើតរបបថ្មីមួយ ។ របបថ្មីដែលដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ មានគោលបំណងប្រយុទ្ធប្រឆាំងនឹងការគំរាមកំហែងរបស់ក្រុមកុម្មុយនីស្ត ទាំងកុម្មុយនីស្តកម្ពុជា និងកុម្មុយនីស្តវៀតណាម ។ ទោះបីជាលោកសេនាប្រមុខ លន់ នល់ ទទួលបានការគាំទ្រ ពីសហរដ្ឋអាមេរិកក៏ដោយ ក៏ប្រជាជននៅតាមទីជនបទមិនទទួលស្គាល់របបថ្មីនេះឡើយ ។

ទោះបីជាសម្តេចព្រះ នរោត្តម សីហនុ ត្រូវបានបណ្តេញចេញពីអំណាច ក៏ដោយ ក៏ព្រះអង្គនៅតែទទួលបានការគោរពស្រលាញ់ពីប្រជាជននៅតាមទីជនបទ ។ ព្រះអង្គទ្រង់យល់ឃើញថា ការជួយជ្រោមជ្រែងពីសំណាក់ខ្មែរក្រហមអាចជួយឲ្យព្រះអង្គទទួលបានអំណាចត្រឡប់មកវិញ ។ ព្រះអង្គបានចងសម្ព័ន្ធភាព ជាមួយនឹងខ្មែរក្រហម ដែលជាអតីតគូសត្រូវកុម្មុយនីស្តរបស់ព្រះអង្គ និងបានបង្កើត«រណសិរ្សរួបរួមជាតិកម្ពុជា» និងរដ្ឋាភិបាលនិរទេសមួយ ដែលមានឈ្មោះថា «រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» ។ ទោះជាយ៉ាងនេះក្តី នៅទីបញ្ចប់ខ្មែរក្រហម គ្រាន់តែប្រើប្រាស់ព្រះអង្គ ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួនតែប៉ុណ្ណោះ ។

ស្របពេលជាមួយគ្នានេះដែរ កងទ័ពវៀតណាមកុម្មុយនីស្តបានចូលកាន់តែជ្រៅមកក្នុងប្រទេសកម្ពុជា និងបានធ្វើការជាមួយខ្មែរក្រហម ក្នុងការជ្រើសរើស និងហ្វឹកហ្វឺនកងទ័ពបដិវត្តន៍ ដែលបានកើនឡើងពីចំនួនប្រមាណបីពាន់នាក់នៅឆ្នាំ១៩៧០ ទៅជាងបួនម៉ឺននាក់

នៅឆ្នាំ១៩៧៣ ។ ដោយមានជំនួយពីវៀតណាម កងទ័ពខ្មែរក្រហមបានចាប់ផ្តើមផ្តួលរំលំកងទ័ពរបស់លោកសេនាប្រមុខ លន់ នល់ នៅលើសមរភូមិ ។ ទោះជាយ៉ាងនេះក្តី កិច្ចសហប្រតិបត្តិការរវាងវៀតណាម និងខ្មែរក្រហម គ្រាន់តែជាកិច្ចសហប្រតិបត្តិការបណ្តោះអាសន្នតែប៉ុណ្ណោះ ។ នៅពេលដែលកងទ័ពខ្មែរក្រហមមានកម្លាំងកាន់តែខ្លាំងឡើង ខ្មែរក្រហមបានទាមទារឲ្យវៀតណាមដកកម្លាំងរបស់ខ្លួនចេញពីប្រទេសកម្ពុជា ។[៥៧] មកដល់ចុងឆ្នាំ១៩៧៣ កងកម្លាំងវៀតណាមភាគច្រើនត្រូវបានដកចេញពីកម្ពុជា ហើយខ្មែរក្រហមបានទទួលខុសត្រូវទាំងស្រុងនៅក្នុងសង្គ្រាមប្រឆាំងនឹងរបប លន់ នល់ ។

ពីខែមករា ដល់ខែសីហា ឆ្នាំ១៩៧៣ សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកប្រមាណកន្លះលានតោនមកលើប្រទេសកម្ពុជា ដែលបានសម្លាប់ប្រជាជនប្រមាណបីសែននាក់ ។[៥៨] ការទម្លាក់គ្រាប់បែកបានពន្យារជ័យជម្នះរបស់ខ្មែរក្រហម ប៉ុន្តែ បានបង្កការខឹងសម្បារពីសំណាក់ប្រជាជននៅតាមទីជនបទ ដែលប្រការនេះបានជួយសម្រួលដល់ការជ្រើសរើសកងទ័ពរបស់ខ្មែរក្រហម ។

មកត្រឹមដើមឆ្នាំ១៩៧៣ ៨៥ភាគរយនៃប្រទេសកម្ពុជា បានធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ហើយកងទ័ពរបស់លោកសេនាប្រមុខ លន់ នល់ ស្ទើរតែពុំអាចបន្តការប្រយុទ្ធតទៅមុខទៀតបាន ។ ប៉ុន្តែ ដោយសារជំនួយរបស់សហរដ្ឋអាមេរិក កងទ័ព លន់ នល់ អាចបន្តការប្រយុទ្ធជាមួយខ្មែរក្រហមបានពីរឆ្នាំទៀត ។

## ការមកដល់ដំបូងរបស់ខ្មែរក្រហមនៅតំបន់អន្លង់វែង

ភ្លាមៗបន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ ដែលបានទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីអំណាច កងទ័ពរបស់ លន់ នល់ បានគ្រប់គ្រងតំបន់អន្លង់វែងបានមួយរយៈពេលខ្លី ។ នៅក្នុងរយៈពេលនោះ កងទ័ព លន់ នល់ បានប្រយុទ្ធជាមួយកងកម្លាំងកុម្មុយនីស្តវៀតណាមខាងជើង (ឬហៅថាវៀតកុង) ជាញឹកញាប់ ។ កងកម្លាំងវៀតកុងទាំងនេះបានចូលមកប្រទេសកម្ពុជា ដើម្បីជួយដល់ខ្មែរក្រហម ។ ការតស៊ូដើម្បីទម្លាក់រដ្ឋាភិបាល លន់ នល់ នៅពេលនោះ ត្រូវបានខ្មែរក្រហមពណ៌នាថា ជាសង្គ្រាមប្រឆាំងទៅនឹង«ចក្រពត្តិអាមេរិក» និងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ។

ស្ថានភាព និងពេលវេលាជាក់លាក់អំពីការមកដល់ដំបូងរបស់ខ្មែរក្រហមនៅតំបន់

អន្លង់វែងមិនត្រូវបានដឹងឲ្យបានច្បាស់លាស់ទេ ។ យោងតាមសំដីរបស់ប្រជាជនដែលរស់នៅទីនោះ កងកម្លាំងខ្មែរក្រហមបានមកតាំងទីនៅតំបន់ក្បែរអន្លង់វែង តាំងពីមុនឆ្នាំ ១៩៧០ ។ ពីរបីខែបន្ទាប់ពីកងទ័ព លន់ នល់ ដកចេញពីតំបន់អន្លង់វែង ខ្មែរក្រហមបានបង្កើតមូលដ្ឋានមួយនៅព្រៃស្អាក ដែលត្រូវបានស្គាល់ថា កងកេង ជាកន្លែងដែលខ្មែរក្រហមធ្វើការឃោសនា និងជ្រើសរើសប្រជាជនអន្លង់វែងជាច្រើនឲ្យចូលរួមចលនាតស៊ូបដិវត្តន៍របស់ខ្លួន ។ ខ្មែរក្រហមទទួលបានជោគជ័យនៅក្នុងការងារនេះ ដោយបានបែងចែកប្រជាជនឲ្យទៅជាកងផ្សេងៗ ដើម្បីកាប់ឆ្ការដីសម្រាប់ដាំដំណាំនិងធ្វើស្រែ ដែលជាកិច្ចការដ៏សំខាន់ សម្រាប់គោលដៅជាយុទ្ធសាស្ត្ររបស់ខ្មែរក្រហម ។ មិនយូរប៉ុន្មានបន្ទាប់ពីការបង្កើតមូលដ្ឋានកងកេង កងទ័ពខ្មែរក្រហម និងកងទ័ពវៀតកុងបានផ្តួលរំលំកងទ័ព លន់ នល់ និងដណ្តើមកាន់កាប់តំបន់អន្លង់វែងទាំងស្រុង ។ ប្រជាជនដែលត្រូវបានកៀរឲ្យទៅរស់នៅកងកេង បានវិលត្រឡប់ទៅរស់នៅតាមភូមិរៀងៗខ្លួនវិញ និងបានកសាងជីវិតសាជាថ្មីឡើងវិញ ។ ទោះជាយ៉ាងនេះក្តី ការប្រយុទ្ធគ្នាក្នុងទ្រង់ទ្រាយតូចរវាងកងទ័ព លន់ នល់ និងកងទ័ពខ្មែរក្រហម នៅតែបន្តកើតមានមួយរយៈពេលកាលពីឆ្នាំ ១៩៧០ ដល់ឆ្នាំ១៩៧៥ ដែលមិនអនុញ្ញាតឲ្យប្រជាជនមានពេលសម្រាកនៅក្នុងជីវិត ។[៥៩]

ការចូលកាន់កាប់តំបន់អន្លង់វែងរបស់ខ្មែរក្រហមកើតឡើងនៅក្នុងពេលដែលប្រទេសជាតិកំពុងជួបប្រទះនូវចលាចល ជម្លោះ និងអស្ថេរភាពសង្គម ជាពិសេស នៅតាមទីជនបទ ។[៦០] ជីវិតនៅតាមសហគមន៍ត្រូវបានផ្លាស់ប្តូរខណៈពេលដែលជម្លោះបានកើតមានឡើងនៅគ្រប់ទីជនបទ ដែលបានផ្តល់លទ្ធភាពដ៏ល្អដល់ខ្មែរក្រហមក្នុងការជ្រើសរើសប្រជាជនក្នុងទ្រង់ទ្រាយធំឲ្យចូលរួមជាមួយបដិវត្តន៍របស់ខ្លួន ។[៦១] ប្រជាជនទាំងឡាយណាដែលស្ម័គ្រចិត្តចូលរួមជាមួយខ្មែរក្រហមត្រូវបានតម្រូវឲ្យស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ និងត្រូវទៅរស់នៅក្នុងមន្ទីររបស់ខ្មែរក្រហម ។ ភាសានិយាយ និងទំនាក់ទំនងនៅក្នុងសហគមន៍អន្លង់វែងបានផ្លាស់ប្តូរ ។ ដើម្បីបង្ហាញអំពីការលះបង់របស់ខ្លួនចំពោះខ្មែរក្រហម សមាជិកថ្មីទាំងអស់បានប្រើប្រាស់ភាសាផ្សេង ដើម្បីពណ៌នាអំពីទំនាក់ទំនងសង្គម ។ សមាជិកថ្មីទាំងនេះបានប្រើពាក្យ“សមមិត្ត” សម្រាប់ហៅគ្នាទៅវិញទៅមក ។ មិនយូរប៉ុន្មាន ភាសាជា ប្រពៃណីរបស់ខ្មែរសម្រាប់ប្រើប្រាស់ក្នុងទំនាក់ទំនងគ្រួសារ ដូចជាពាក្យ

“ពូ មីង បងប្រុស បងស្រី” បានរលាយបាត់ ។ រោហារសព្ទ នយោបាយត្រូវបានបញ្ចូលទៅក្នុងការប្រាស្រ័យទាក់ទងគ្នាប្រចាំថ្ងៃ ។

បទពិសោធដែលតំបន់អន្លង់វែងជួបប្រទះនៅក្រោមមនោគមន៍វិជ្ជា និងការគ្រប់គ្រងរបស់ខ្មែរក្រហម គឺគ្រាន់តែជាផ្នែកមួយនៃទស្សនវិស័យដ៏ធំរបស់ខ្មែរក្រហម នៅក្នុងការកែប្រែប្រទេសជាតិ ។ នៅពេលដែលទីក្រុងភ្នំពេញធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ ប្រជាជនរាប់សែននាក់ត្រូវ បានខ្មែរក្រហមជម្លៀសដោយបង្ខំចេញពីទីក្រុងទៅកាន់ទីជនបទ ។ គោលនយោបាយនៃការជម្លៀសប្រជាជនចេញពីទីក្រុងទៅកាន់ទីជនបទ មិនមែនអនុវត្ត តែនៅទីក្រុងភ្នំពេញនោះទេ ។ នៅទូទាំងប្រទេសកម្ពុជា ប្រជាជនត្រូវបានជម្លៀសចេញពីទីប្រជុំជនដែលនៅសេសសល់ទៅកាន់ទីជនបទ ដែលនៅទីនោះប្រជាជនត្រូវបានបង្ខំឲ្យធ្វើការដោយកម្លាំងនៅតាមការដ្ឋាននានា ។

បន្ថែមទៅលើការជម្លៀសដោយបង្ខំ មនោគមន៍វិជ្ជារបស់ខ្មែរក្រហមបានគ្របដណ្តប់ទៅលើវប្បធម៌ និងសេដ្ឋកិច្ចជាតិទាំងមូល ។ មនោគមន៍វិជ្ជារបស់ខ្មែរក្រហមមានប្រភពចេញមកពីទ្រឹស្តីម៉ៅនិយម និងទ្រឹស្តីម៉ាក្សលេនីន ។[៦២] មេដឹកនាំខ្មែរក្រហមមានបំណងកែប្រែប្រទេសកម្ពុជាឲ្យទៅជាសង្គមជនបទមួយដែលគ្មានវណ្ណៈ គ្មានអ្នកមានគ្មានអ្នកក្រ និងគ្មានការជិះជាន់ ។ ដើម្បីសម្រេចឲ្យបាននូវផែនការនេះ ខ្មែរក្រហមបានលុបបំបាត់រូបិយវត្ថុ ទីផ្សារសេរី សាលារៀន កម្មសិទ្ធិឯកជន សម្លៀកបំពាក់បែបបស្ចិមប្រទេស ការប្រតិបត្តិសាសនា និងវប្បធម៌ខ្មែរ ។ ខ្មែរក្រហមបានប្រែក្លាយសាលារៀន វត្តអារាម វិហារសាសនាអ៊ីស្លាម វិហារសាសនាគ្រិស្ត សាកលវិទ្យាល័យ ហាងទំនិញ និងអគាររដ្ឋាភិបាល ទៅជាមន្ទីរ សន្តិសុខ ឃ្លាំងផ្ទុកសម្ភារៈ ជំរំអប់រំកែប្រែ និងជង្រុកស្រូវ ។[៦៣]

កើត ព្រះ បានរៀបរាប់អំពីបទពិសោធរបស់គាត់ ក្នុងនាមជាយុវជនម្នាក់ដែលធ្វើស្រែនៅក្នុងកងចល័ត ។ ព្រះ បានរៀបរាប់ថា ៖

> យើងចាប់ផ្តើមទៅធ្វើស្រែនៅម៉ោង៥ទៀបភ្លឺ ហើយយើងត្រូវបានអនុញ្ញាតឲ្យសម្រាកហូបអាហារថ្ងៃត្រង់នៅម៉ោង១១ ។ យើងត្រូវចាប់ផ្តើម ធ្វើការបន្តទៀតនៅម៉ោង១រសៀល និងសម្រាក នៅម៉ោង៥ល្ងាច

ដើម្បីហូបអាហារជាលើកទីពីរ ។ បន្ទាប់មក ខ្មែរក្រហមបានបញ្ជាឲ្យយើងទៅធ្វើការបន្តទៀតនៅម៉ោង៦រហូតដល់ម៉ោង១០យប់ ។ ខ្មែរក្រហមប្រើចង្កៀងប្រេងកាត ដើម្បីបំភ្លឺវាលស្រែឲ្យកងចល័តធ្វើការ ។ គោលដៅរបស់ខ្មែរក្រហម គឺធ្វើយ៉ាងណាសម្រេចឲ្យ បានទិន្នផលបីតោនក្នុងមួយហិចតា ។ នៅក្នុងរដូវប្រូតកាត់ យើងប្រមូលផលស្រូវ ហើយដាក់នៅក្នុងឃ្លាំង ប្រមាណបីទៅបួនឃ្លាំង ។ ប៉ុន្តែ ខ្ញុំមិនបានដឹងថា តើខ្មែរក្រហមយកស្រូវទាំងអស់នោះ ទៅទីណានោះទេ ។

ជំពូក៣

# អន្លង់វែងនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម

## *មេដឹកនាំខ្មែរក្រហមនៅតំបន់អន្លង់វែង*

*នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) អន្លង់វែង ស្ថិតនៅក្រោមរបបគ្រប់គ្រងមួយប្រកបដោយភាពច្របូកច្របល់ ដោយសារតែការធ្វើបន្សុទ្ធកម្ម ការចាប់ខ្លួន និងភាពចលាចលផ្នែកនយោបាយ ដែលបានគ្របដណ្តប់លើតំបន់នេះ ។ នៅក្នុងអំឡុងពេលនៃសង្រ្គាមស៊ីវិល (១៩៧០-១៩៧៥) អន្លង់វែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់តំបន់សៀមរាប-ឧត្តរមានជ័យ ដែលត្រូវបានស្គាល់ថាជាតំបន់៣៥របស់ខ្មែរក្រហម ។[៦៤] ស្រុកអន្លង់វែង ត្រូវបានបែងចែកជា៤ឃុំ ដែលរួមមានឃុំអន្លង់វែង លំទង ត្រពាំងតាវ និងថ្នល់ ។ ឃុំទាំងបួននេះ ត្រូវបានបែងចែកបន្តទៀតទៅជាសហករណ៍ដែលប្រជាជននៅអន្លង់វែងត្រូវរស់នៅ និងបំពេញការងារ ។*

*ដូចតំបន់ដទៃទៀតនៅទូទាំងប្រទេសកម្ពុជាដែរ ការចាប់ខ្លួន បន្សុទ្ធកម្ម និងការសម្លាប់តែងតែកើតឡើងជាញឹកញាប់នៅអន្លង់វែង ។ ទោះបីជាថ្នាក់ដឹកនាំខ្មែរក្រហមភាគច្រើននៅអន្លង់វែងគឺជាគោលដៅនៃបន្សុទ្ធកម្មនិងការសម្លាប់ក៏ដោយ ក៏មេដឹកនាំទាំងនេះ បានអនុវត្តទង្វើដូចគ្នានេះទៅលើប្រជាជនរបស់ខ្លួន ។ ទីស្នាក់ការធំរបស់ខ្មែរក្រហមនៅអន្លង់វែង មានទីតាំងស្ថិតនៅភូមិរំចេក ឃុំលំទង ។ សមមិត្ត រ៉ុង ដែលជាកម្មាភិបាលមកពីខេត្តកំពង់ចាម គឺជាលេខាស្រុកអន្លង់វែងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៧ ។[៦៥] រ៉ុង ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅឃុំឃាំងនៅស្រុកសំរោង ខេត្តឧត្តរមានជ័យ ។[៦៦] សមមិត្ត ទុយ បានឡើងជាលេខាស្រុកអន្លង់វែងជំនួស រ៉ុង ។ ប៉ុន្តែ បន្ទាប់ពីឡើងជាលេខាបានរយៈពេលបីខែ ទុយ បានបាត់ខ្លួន ។ វ៉ន ដែលជាកម្មាភិបាលមកពីភូមិភាគនិរតី បានក្លាយជាមេដឹកនាំទីបីនៅអន្លង់វែង ។ ប្រជាជននៅអន្លង់វែងនិយាយថា វ៉ន និងអនុលេខារបស់ខ្លួនឈ្មោះ តោ បានចាប់ខ្លួន និងសម្លាប់ប្រធានសហករណ៍អស់ជាច្រើនរូប ។[៦៧]*

*ដើម្បីការពារព្រំដែន ខ្មែរក្រហមបានដាក់កងវរសេនាតូចមួយកងឲ្យប្រចាំការនៅស្រុកអន្លង់វែង ដែលទទួលខុសត្រូវយាមកាម និងការពារព្រំដែនជាមួយប្រទេសថៃ ។*

កងវរសេនាតូចនេះដឹកនាំដោយ សមមិត្ត កៃ ជាប្រធាន, សមមិត្ត ថេន ជាអនុប្រធាន និង សមមិត្ត ជុំ ជាសមាជិកទីបី ។ កងទ័ពនៅក្នុងកងវរសេនាតូចនេះ បានទទួលការហ្វឹកហាត់ចំនួនបីខែមុននឹងត្រូវបានបញ្ជូនឲ្យទៅឈរជើងនៅតាមព្រំដែន ដែលនៅទីនោះជម្លោះជាមួយថៃបានកើតឡើងជារឿយៗ ។ កងទ័ពត្រូវបានបញ្ជាឲ្យយាមព្រំដែន ជីកដីដាំចម្រូង និងការពារលទ្ធភាពនៃការវាយប្រហារពីសំណាក់ក្រុមខ្មែរស (ខ្មែរសសំដៅទៅលើកងទ័ពដែលនៅសេសសល់របស់ លន់ នល់) ។[៦៨]

ជីវិតជាកងទ័ពជួបការលំបាក ប៉ុន្តែ នៅតែស្ថិតនៅក្នុងជីវភាពល្អប្រសើរជាងប្រជាជនភាគច្រើន ។ កងទ័ពដែលប្រចាំការនៅតាមបណ្តោយព្រំដែន មិនមានអាហារហូបចុកគ្រប់គ្រាន់ទេ ។ កងទ័ពទាំងអស់នោះត្រូវជីកដំឡូងព្រៃ និងក្តួចយកមកបរិភោគបន្ថែម ទោះបីជាមេដឹកនាំផ្គត់ផ្គង់ស្រូវរៀងរាល់ពីរសប្តាហ៍ម្តងក៏ដោយ ។ ជាទូទៅអង្គភាពនីមួយៗត្រូវតែពឹងផ្អែកលើខ្លួនឯងដើម្បីរស់ ហើយកងទ័ពត្រូវបានលើកទឹកចិត្តឲ្យទៅបរបាញ់សត្វព្រៃ និងស្វែងរកអាហារដោយខ្លួនឯង ។ ដោយសារអន្លង់វែងគ្របដណ្តប់ទៅដោយព្រៃ តំបន់នេះសំបូរសត្វព្រៃណាស់ (ដូចជាសត្វខ្លា) កងទ័ពខ្មែរក្រហមមួយចំនួនបានក្លាយទៅជាអ្នកប្រមាញ់សត្វព្រៃយ៉ាងស្ទាត់ជំនាញ ។

## ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅតំបន់អន្លង់វែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ប្រជាជនត្រូវបានអនុញ្ញាតឲ្យរស់នៅ និងហូប អាហារនៅតាមផ្ទះរៀងៗខ្លួន ។ ប៉ុន្តែ នៅពេលដែលខ្មែរក្រហមទទួលបានអំណាចកាន់តែច្រើន ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនបានផ្លាស់ប្តូរបន្តិចម្តងៗពីជីវិត គ្រួសារ ការធ្វើស្រែចម្ការ និងការរស់នៅក្នុងសហគមន៍ ទៅជាជីវិតដែលគ្របដណ្តប់ដោយការរស់នៅជាលក្ខណៈសមូហភាពនៅក្នុងសហករណ៍ ។ បន្ទាប់ពីឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមបានឲ្យប្រជាជនប្រគល់សម្ភារៈផ្ទះបាយរបស់ខ្លួន ទៅឲ្យសហករណ៍សម្រាប់ការប្រើប្រាស់រួម ។ ជីវិតរស់នៅរបស់ប្រជាជនចាប់ផ្តើមជួបការលំបាកកាន់តែធ្ងន់ទៅៗ នៅពេលដែលប្រជាជនត្រូវបានតម្រូវឲ្យហូបរួម ហើយពេលវេលាសម្រាប់គ្រួសារត្រូវបានចំណាយទៅលើការងារពលកម្មតាមវាលស្រែ ។ នៅក្នុងការរស់នៅជាសហករណ៍ ប្រជាជនត្រូវធ្វើការច្រើនម៉ោង និងទទួលរងការធ្វើទុក្ខបុកម្នេញ ។ ប្រជាជនត្រូវធ្វើការពីព្រលឹម

ទល់ព្រលប់ហើយ ពេលខ្លះត្រូវធ្វើការរហូតដល់ពាក់កណ្ដាលយប់ ។ អ្វីៗទាំងអស់ រួមទាំងទម្លាប់ការងារស្រែចម្ការប្រចាំថ្ងៃផង ត្រូវបានកំណត់ដោយខ្មែរក្រហម ។

ជីវិតមានការលំបាកហើយប្រជាជនមិនមានពេលវេលាផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារនោះទេ ។ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការពីម៉ោង៦ដល់ម៉ោង១១ព្រឹក បន្ទាប់មកត្រូវបានអនុញ្ញាតឲ្យសម្រាកមួយភ្លែត ។ នៅម៉ោង១រសៀល ប្រជាជនទាំងអស់ត្រូវត្រឡប់ទៅកាន់ការដ្ឋានការងារវិញរហូតដល់ម៉ោង ៥ល្ងាច ។ មនុស្សគ្រប់រូបមានការនឿយហត់យ៉ាងខ្លាំង ហើយទន្ទឹងរង់ចាំស្នូរគោះជួង ដែលជាសញ្ញាប្រកាសថា ការងារនៅថ្ងៃនោះបានបញ្ចប់ហើយ ។ ទោះបីជាធ្វើការច្រើនម៉ោងក្នុងមួយថ្ងៃយ៉ាងណាក៏ដោយ ក៏នៅពេលខ្លះ ខ្មែរក្រហមបង្ខំឲ្យប្រជាជនធ្វើការរហូតដល់យប់ជ្រៅបន្ថែមទៀត ដែលជួនកាលរហូតដល់ម៉ោង១០យប់ ។

ក្នុងគោលបំណងពង្រីងខ្សែសង្វាក់ការងារ ខ្មែរក្រហមបានបែងចែកប្រជាជនឲ្យទៅជាកងផ្សេងៗគ្នាទៅតាមវ័យ និងភេទ ។ កងទាំងនោះរួមមាន កងចល័ត កងកុមារ កងស្ត្រី និងកងដឹកជញ្ជូន ។ ប្រជាជននៅក្នុងកងទាំងនោះត្រូវប្រឹងប្រែង ធ្វើការងារ មិនថាឈឺ ឬអស់កម្លាំងនោះទេ ។ ប្រជាជនទាំងឡាយណាដែលបដិសេធ ឬមិនអាចបំពេញការងារបាននឹងត្រូវទទួលទារុណកម្ម ឬបាត់ខ្លួននៅក្នុងករណីមួយចំនួន ។

## ជីវិតរស់នៅក្នុងសហករណ៍

មិនខុសពីតំបន់ដទៃទៀតនៃប្រទេសកម្ពុជា ភូមិជាច្រើននៅតំបន់អន្លង់វែងត្រូវបានប្រែក្លាយឲ្យទៅជាសហករណ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាយើងអាចសន្និតថា ជីវិតរបស់ប្រជាជន ប្រហែលជាមិនខុសគ្នាខ្លាំងពេកទេ យ៉ាងណាក៏ដោយក៏ពីសហករណ៍មួយទៅសហករណ៍មួយទៀតនៅក្នុងតំបន់នេះ យើងអាចនឹងមានការភាន់ច្រឡំដោយសារតែស្ថានភាពនៅក្នុងសហករណ៍នីមួយៗអាចមានស្ថានភាពខុសគ្នាខ្លាំងអាស្រ័យទៅលើប្រធានសហករណ៍នីមួយៗ និងការងាររដ្ឋបាលរបស់កម្មាភិបាលខ្មែរក្រហមនៅតំបន់នោះ ។ ការសិក្សាស្រាវជ្រាវរបស់យើងមិនបានពិនិត្យមើលឲ្យស៊ីជម្រៅទៅលើស្ថានភាពជាក់ស្ដែងនៅក្នុងសហករណ៍នីមួយៗទេ ។ ទោះជាយ៉ាងនេះក្ដី ក្នុងគោលបំណងផ្ដល់ឲ្យអ្នកអានអំពីទិដ្ឋភាពទូទៅមួយនៃជីវិតរស់នៅក្នុងសហករណ៍ យើងបានសង្ខេប

អំពីជីវិតរស់នៅក្នុងសហករណ៍មួយ ដែលមានឈ្មោះថា សហករណ៍តាដេវ ។

តាដេវ គឺជាឈ្មោះភូមិមួយនៅក្នុងឃុំត្រពាំងតាវ ដែលជាភូមិចាស់មួយរបស់ឃុំរនាម នៃស្រុកប្រាសាទរវៀង ។ ភូមិនេះមានប្រជាជនរស់នៅប្រហែល២៥ គ្រួសារនៅក្នុងរបបរបស់សម្ដេចព្រះ នរោត្ដម សីហនុ ។ ភូមិនេះមិនមានរចនាសម្ព័ន្ធសង្គមនោះទេ ហើយមន្ត្រីរដ្ឋាភិបាលកម្រចុះមកត្រួតពិនិត្យភូមិដាច់ស្រយាលមួយនេះណាស់ ។

របាយការណ៍មួយចំនួនបានលើកឡើងថា ប្រជាជនជាច្រើនមកពីភូមិត្រពាំងតាវ គោកក្ដាន់ និងភូមិផ្កាំរមាស ត្រូវបានប្រមូលឲ្យមករស់នៅក្នុងសហករណ៍តាដេវ ដែលមានសមមិត្ត ម៉ុល ជាប្រធានសហករណ៍ និងសមាជិកមួយចំនួនទៀត ដែលរួមមាន សាក់, ជឿម និង ឯក ។ កម្មាភិបាលទាំងអស់នេះត្រូវបានស្គាល់ថាជាមេដឹកនាំកាចសាហាវ ដែលឲ្យប្រជាជនហូបតែបបររាវ ។ ទោះជាយ៉ាងនេះក្ដី ក្រុមគ្រួសាររបស់កម្មាភិបាលខ្មែរក្រហមភាគច្រើនមានបាយហូប ។ ស៊ីន ហួង បានរំឭកអំពីជីវិត របស់គាត់នៅក្នុងសហករណ៍ តាដេវ ដូចតទៅ ៖

> *យើងត្រូវបានបំបែកឲ្យធ្វើការងារផ្សេងគ្នា ។ ឪពុករបស់ខ្ញុំធ្វើការនៅក្នុងរោងម៉ាស៊ីនកិនស្រូវ ។ ខ្ញុំទៅឃ្វាលគោ ។ ម្ដាយរបស់ខ្ញុំ ទៅធ្វើការងារស្រែចម្ការ ។ ប្អូនប្រុសរបស់ខ្ញុំដើរកាត់ស្មៅសម្រាប់ធ្វើជី ។ បងប្រុសរបស់ខ្ញុំទៅធ្វើការនៅរោងម៉ាស៊ីនកិនស្រូវសហករណ៍ជាមួយឪពុករបស់ខ្ញុំ ។ យើងធ្វើការពីព្រលឹមទល់ព្រលប់ និងសម្រាកនៅពេលហូបអាហារថ្ងៃត្រង់ ។ យើងទទួលបានបបរមួយចានតូចពីរពេលក្នុងមួយថ្ងៃ ។ ដើម្បីបំពេញក្រពះ យើងបានដើរបេះត្រកួនមកហូបជាមួយអំបិល ។*[៦៩]

ដូចភូមិផ្សេងៗទៀតនៅក្នុងតំបន់នេះដែរ ការរស់នៅក្នុងភូមិតាដេវ ត្រូវបានបង្កើតឡើងជារបៀបសហករណ៍ ។ ទោះជាយ៉ាងនេះក្ដី គ្រួសារជាច្រើនបន្តរស់នៅក្នុងភូមិរៀងៗខ្លួន (ឬយ៉ាងហោចណាស់ រស់នៅក្នុងរង្វង់នៃបរិវេណភូមិរបស់ខ្លួន) រហូតដល់ឆ្នាំ១៩៧៧ ។ នៅឆ្នាំ១៩៧៧ ភូមិទាំងអស់នៅក្នុងតំបន់អន្លង់វែង គ្មានមនុស្សរស់នៅ ។ អ្នកភូមិត្រូវបានជម្លៀសទៅកាន់ស្រុកក្រឡាញ់ ក្នុងខេត្តសៀមរាប ។

## កុមារ

យោងតាមបទសម្ភាសជាមួយប្រជាជនដែលរស់នៅតំបន់អន្លង់វែង កុមារដែលរស់នៅតំបន់នេះក្នុងរយៈកាលនៃរបបខ្មែរក្រហម ត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ខ្លួនអស់រយៈពេលយ៉ាងយូរ ។ ក្មេងប្រុសស្រីត្រូវបានដាក់ឲ្យរស់នៅដាច់ដោយឡែកពីគ្នា ។ មុត សៅ ដែលជាអតីតគ្រូបង្រៀន គឺជាប្រធានកងកុមារ ។ កុមារត្រូវបានបញ្ជាឲ្យដើរកាត់ស្មៅ និងចិញ្ច្រាំផ្ញើជី ។ ជាទូទៅ កុមារទាំងនោះត្រូវបានតម្រូវឲ្យធ្វើការងារធ្ងន់ ដូចជា ជីកដី និងលើកភ្លឺស្រែ ។ កុមារជាច្រើនស្ទើរតែពុំមានកម្លាំងគ្រប់គ្រាន់ដើម្បីលើកចបកាប់ដីនោះទេ ។

ដូចប្រជាជនកម្ពុជាភាគច្រើន ដែលរស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ជីវិតរបស់កុមារហាក់ដូចជាកំពុងស្ថិតនៅក្នុងល្បោនដ៏ចម្លែកមួយ ។ កុមារត្រូវបានប្រើដូចជាគោក្របី ឲ្យធ្វើស្រែ ជីកដី និងធ្វើការងារផ្សេងៗទៀត ដូចជាឪពុកម្តាយរបស់ខ្លួនដែរ ។ ភាពសប្បាយរីករាយបែបយុវវ័យបានក្លាយទៅជាការចងចាំមួយ ដែលស្ថិតនៅសែនឆ្ងាយ ។ ចំណែកឯកុមារភាពដែលគ្មានទោសពៃរ៍ បែរជាទទួលរងនូវសោកនាដកម្មដែលគួរឲ្យខ្លាច និងរួមរឹតទៅដោយជំងឺ និងការស្លាប់ ។ អគ្គភាពកុមាររួមមានកុមារពី ៣០០ ទៅ៤០០នាក់ ។ កុមារទាំងនេះរស់នៅ និងហូបចុករួមគ្នា ។ បន្ថែមពីលើការងារដែលប្រើប្រាស់កម្លាំងពលកម្ម ជារៀងរាល់ថ្ងៃកុមារទាំងនោះត្រូវបានតម្រូវឲ្យរៀនសូត្រមនោគមន៍វិជ្ជា និងអក្សរបន្តិចបន្តួច ។ កុមារទទួលបានអាហារពីរពេលក្នុងមួយថ្ងៃ នៅម៉ោង១១ព្រឹក និងម៉ោង៥ល្ងាច ។ កុមារម្នាក់ៗទទួលបានបបរមួយកូនចានតូចក្នុងមួយពេល ។[៧០]

## ការចាប់ខ្លួន និងការសម្លាប់

ការចាប់ខ្លួន និងការសម្លាប់គឺជាដំណើរការជាទូទៅ ហើយជីវិតរស់នៅប្រចាំថ្ងៃផ្សារភ្ជាប់នឹងការឃ្លាំមើលទៅលើទម្លាប់ និងការនិយាយស្តី ។ កាយវិការសាមញ្ញ ពាក្យសម្តី ឬទម្លាប់របស់បុគ្គលម្នាក់ អាចបង្ហាញអំពីការខ្វះការគោរពស្រលាញ់ ចំពោះរបបខ្មែរក្រហម ហើយគ្រាន់តែការសង្ស័យ ក៏គ្រប់គ្រាន់សម្រាប់ចាប់ខ្លួនអ្នកណាម្នាក់បានដែរ ។

កែ ជាប្រធានកងវរសេនាតូច និងជាប្រធានមន្ទីរសន្តិសុខនៅអន្លង់វែង ។ មន្ទីរ

សន្តិសុខនេះក្រោយមក បានក្លាយជាកន្លែងដ៏គួរឲ្យភ័យខ្លាចមួយសម្រាប់ចាប់ខ្លួនមនុស្សទាំងឡាយណាដែលទទួលការសង្ស័យ ។ ខ្មែរក្រហមបានស្វែងរកជនទាំងឡាយណា ដែលជាប់ទាក់ទងជាមួយរបបរបស់សម្តេចព្រះ នរោត្តម សីហនុ និងរបប លន់ នល់ ។ ប្រសិនបើជនណាម្នាក់ត្រូវបានរកឃើញថា មានជាប់ពាក់ព័ន្ធនឹងរបបមុន ជននោះនឹងត្រូវបញ្ជូនទៅកាន់ភូមិរំចេក ដើម្បីធ្វើការតាមដាន និងសម្លាប់ ។ ជាងនេះទៅទៀត ខ្មែរក្រហមបានចាប់និងសម្លាប់ចោលជនទាំងឡាយណា ដែលរត់គេចខ្លួនទៅប្រទេសថៃ ។

សាក្សីមួយរូបបានរំឭកថា គាត់បានឃើញ កៃ ចាប់ខ្លួនមនុស្ស៥នាក់ ដែលបានព្យាយាមរត់គេចទៅប្រទេសថៃ ។ គាត់បានរៀបរាប់ថា ៖

> *ខ្ញុំបានឃើញកងទ័ពចាប់មនុស្ស៥នាក់ដែលបានព្យាយាមរត់ ទៅប្រទេសថៃ ។ តា កៃ បានមកដល់ជាមួយអង្គរក្សរបស់គាត់ចំនួន៤ ឬ ៥នាក់ ។ គាត់បានវាយមនុស្សដែលរត់គេចខ្លួនទាំង៥នាក់នោះ ។ មនុស្សម្នាក់ៗទទួលរងយ៉ាងហោចណាស់ម្នាក់៣០រំពាត់ ។ តា កៃ បានសួរអ្នកទាំងនោះថា មកពីណា និងចង់ទៅណា ។ ពួកគេបាននិយាយថា ពួកគេមកពីខេត្តកំពង់ធំ និងសៀមរាប និងមានបំណងទៅប្រទេសថៃ ។ តា កៃ បានវាយប្រជាជនទាំងនោះរហូតដល់បែកខ្នងហូរឈាម ។ បន្ទាប់មក អ្នកទាំង៥នាក់នោះត្រូវបានខ្មែរក្រហមនាំយកទៅបាត់ ។ ខ្ញុំមិនជឿថា អ្នកទាំង៥នាក់នោះអាចនៅមានជីវិតនោះទេ ។*[៧១]

ប្រជាជនជាច្រើនមកពីខេត្តផ្សេងៗទៀត ក៏ត្រូវបានជម្លៀសទៅអន្លង់វែងដែរ ប៉ុន្តែប្រជាជនទាំងនេះមិនត្រូវបានកម្មាភិបាលខ្មែរក្រហមជឿទុកចិត្តនោះទេ ។ ប្រជាជនទាំងនេះក៏មិនមានសាច់ញាតិ ឬមិត្តភក្តិ សម្រាប់ពឹងអាស្រ័យបានដែរ ហើយជាញឹកញយត្រូវបានខ្មែរក្រហមសម្លាប់ដោយសារការសង្ស័យ ។[៧២] មន្ទីរសន្តិសុខរបស់ខ្មែរក្រហមត្រូវបានបង្កើតឡើងនៅចំទីតាំង ដែលជាអនុវិទ្យាល័យហ៊ុនសែននាពេលបច្ចុប្បន្ន ។ គុកនោះត្រូវបានសង់អំពីឈើដំបូលប្រក់ស្បូវ ដែលមានទទឹង៥ម៉ែត្រ និងបណ្តោយ៧ម៉ែត្រ ។ អ្នកទោសត្រូវបានបង្ខំឲ្យដេកជាជួរ ដោយជើងរបស់អ្នកទោសទាំងនោះត្រូវបាន

ដាក់ខ្នោះជើងដែលធ្វើអំពីឈើ ។ របៀបឃុំឃាំងអ្នកទោសនៅទីនោះ ស្រដៀងនឹងរបៀបឃុំឃាំងអ្នកទោសនៅមន្ទីរស-២១នៅភ្នំពេញ ។ ជាទូទៅអ្នកទោសត្រូវបានឃុំខ្លួនរយៈពេលមួយសប្តាហ៍មុននឹងត្រូវបានយកទៅសម្លាប់ នៅក្នុងទីតាំងសម្លាប់ជាច្រើនកន្លែងដែលទីតាំងមួយស្ថិតនៅក្បែរវត្តអន្លង់វែងបច្ចុប្បន្ន ។[៧៣] ការសម្លាប់អ្នកទោសភាគច្រើនត្រូវបានធ្វើឡើងនៅពេលយប់ ។

## ការជម្លៀសប្រជាជនដោយបង្ខំទៅស្រុកក្រឡាញ់នៅឆ្នាំ១៩៧៧

នៅចុងឆ្នាំ១៩៧៧ រ៉ន ដែលជាប្រធានថ្មីនៃស្រុកអន្លង់វែង បានបញ្ជាឲ្យជម្លៀសប្រជាជននៅអន្លង់វែងទាំងអស់ឲ្យទៅរស់នៅតាមសហករណ៍ នៅក្នុងឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ ប្រជាជនអន្លង់វែងមួយចំនួនត្រូវបានបញ្ជូនទៅស្រុកវ៉ារិន្ទ ស្រីស្នំ សំរោង និងចុងកាល់ ។ ចាប់ពីចុងឆ្នាំ១៩៧៧ដល់ដើមឆ្នាំ១៩៧៩ តំបន់អន្លង់វែងបានក្លាយទៅជាមូលដ្ឋានកងទ័ពរបស់ខ្មែរក្រហម ។

យឹម ឡាហឿ ដែលជាអតីតកងទ័ពការពារព្រំដែននៅអន្លង់វែង ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានរៀបរាប់អំពីបទពិសោធដ៏គួរឲ្យរន្ធត់របស់ខ្លួននៅពេលដែល គាត់ទៅសួរសុខទុក្ខគ្រួសាររបស់គាត់បន្ទាប់ពីការជម្លៀស ។ ឡាហឿ បាននិយាយថា ៖

> *នៅពេលដែលខ្ញុំទៅដល់ផ្ទះ ខ្ញុំបានឃើញឆ្នាំងដាំបាយរបស់ជីដូនខ្ញុំត្រូវបានព្យួរទុកចោលដោយគ្មានអ្នកណាប្រើ ។ នៅក្នុងភូមិពោរពេញទៅដោយភាពស្ងាត់ជ្រងំ ។ ប្រជាជនទាំងអស់ត្រូវបានជម្លៀសទៅស្រុកក្រឡាញ់ ។ នៅពេលបានឃើញទិដ្ឋភាពបែបនេះ ខ្ញុំមានអារម្មណ៍អស់សង្ឃឹម ។ ខ្ញុំបានលះបង់គ្រប់បែបយ៉ាង ដើម្បីបម្រើប្រទេសជាតិ ប៉ុន្តែ លះបង់ដើម្បីអ្វី? ខ្ញុំបាត់បង់អ្វីៗគ្រប់យ៉ាង ។ ខ្ញុំបាត់បង់អស់នូវភាពជឿជាក់ ។ ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងម៉េចនោះទេ មានតែទទួលយកស្ថានភាពនេះ ហើយបន្តរស់នៅតទៅទៀត ។[៧៤]*

ប្រជាជនធ្វើដំណើរទៅស្រុកក្រឡាញ់ដោយមធ្យោបាយផ្សេងៗគ្នា តាមរយៈរទេះគោ ដោយថ្មើរជើង និងតាមរយៈរថយន្តរបស់ខ្មែរក្រហម ។ នៅពេលទៅដល់ស្រុកក្រឡាញ់ ប្រជាជនមកពីតំបន់អន្លង់វែង ត្រូវបានបែងចែកឲ្យរស់នៅតាមសហករណ៍នានា និងត្រូវបានចាត់តាំងទៅតាមកងផ្សេងៗជាមួយប្រជាជន ដែលមកពីតំបន់ផ្សេង ។ មានតែកុមារតូចៗតែប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យស្នាក់នៅជាមួយម្តាយនៅពេលយប់ ។ នៅពេលថ្ងៃកុមារត្រូវបានតម្រូវឲ្យទៅរៀន និងកាត់ស្មៅយកទៅធ្វើជីសម្រាប់ដាក់ក្នុងស្រែ ។ កុមារក៏ត្រូវបានតម្រូវឲ្យដើរប្រមូលកណ្តាប់ស្រូវ ឬដើរដេញចាបកុំឲ្យស៊ីស្រូវ ។ ប្រជាជនត្រូវធ្វើការទាំងរដូវប្រាំង និងរដូវវស្សា និងត្រូវទៅលើកទំនប់ និងជីកប្រឡាយ ។ នៅក្បែរទំនប់ស្ពានស្រែងមានវាលពិឃាតមួយកន្លែងនៅស្រុកក្រឡាញ់ដែលមានឈ្មោះថា "ឡ ពិឃាតភ្នំទ្រង់បាត" ។[៧៥]

ជីវិតរស់នៅរបស់ប្រជាជនមានការលំបាក ។ នៅទីនោះ ប្រជាជនពុំមានអាហារបរិភោគគ្រប់គ្រាន់ និងត្រូវរស់នៅក្នុងភាពសង្ស័យគ្នាទៅវិញទៅមក ។ សូម្បីតែទង្វើប្រចាំថ្ងៃជាធម្មតារបស់មនុស្ស ក៏អាចបង្កទៅជាការសង្ស័យបានដែរ ។ ជាក់ស្តែងអ្នកនៅរស់រានមានជីវិតម្នាក់បាននិយាយថា គាត់ធ្លាប់បានឃើញខ្មែរក្រហមដឹកមនុស្សយកទៅសម្លាប់ចោល ដោយសារតែបុគ្គលនោះចំណាយពេលវេលាយូរពេកក្នុងការបន្ទោបង់ ។ ទីតាំងពិឃាតនៅស្រុកក្រឡាញ់ត្រូវបានស្គាល់ថា នៅក្បែរឡពិឃាដភ្នំទ្រង់បាត ដែលមនុស្សរាប់រយពាន់នាក់ត្រូវបានសម្លាប់ ។[៧៦]

## សេចក្តីបញ្ចប់

មុនឆ្នាំ១៩៧០ អន្លង់វែងគឺជាតំបន់ដាច់ស្រយាលមួយនៅក្នុងប្រទេសកម្ពុជា និងជាតំបន់មួយ នៅក្រៅការគ្រប់គ្រងរបស់រដ្ឋ ទាំងផ្នែកសេដ្ឋកិច្ច និងកិច្ចការរដ្ឋបាល ។ រដ្ឋាភិបាលកណ្តាលកម្រធ្វើដំណើរ ទៅកាន់តំបន់នេះណាស់ហើយប្រជាជនរស់នៅតាមទម្លាប់ដែលធ្លាប់រស់នៅរាប់ជំនាន់មកហើយ ដោយពឹងផ្អែកលើការធ្វើស្រែចម្ការ ការដួញដូរ និងដំណាំដាំដុះនៅក្នុងភូមិ ។ នៅពេលដែលខ្មែរក្រហម ចូលមកដល់តំបន់នេះនៅដើមឆ្នាំ១៩៧០ វប្បធម៌នៅតំបន់អន្លង់វែងចាប់ផ្តើមប្រែប្រួល ។ ប្រជាជនត្រូវបានបង្ខំឲ្យទទួលយកមនោគមន៍វិជ្ជាបដិវត្តន៍បែបថ្មីរបស់ខ្មែរក្រហម ដែលមានបំណងលុប

បំបាត់ចោលនូវការអនុវត្តបែបប្រពៃណី ជំនឿ និងឥរិយាបថ។ ប្រជាជនជួបប្រទះនូវការលំបាកយ៉ាងខ្លាំង ដូចជាការរស់នៅបែបសហករណ៍ ការបង្ខំឲ្យធ្វើការងារជាទម្ងន់ ការខ្វះខាតអាហារ និងការបំបិទសិទ្ធិសេរីភាព ដែលបានបង្កជាផលលំបាកដល់បុគ្គល និងសហគមន៍ទាំងមូល ។ ការសម្លាប់ដោយគ្មានការកាត់ទោស ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងការបន្តការគំរាមកំហែងដោយជម្លោះ បានបង្កនូវភាពភ័យខ្លាច និងភាពមិនប្រាកដប្រជាដល់ប្រជាជន ។ នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានបង្ខំប្រជាជនទាំងអស់ឲ្យផ្លាស់ទៅធ្វើការនៅស្រុកក្រឡាញ់ ដោយធ្វើឲ្យតំបន់អន្លង់វែង ក្លាយទៅជាមូលដ្ឋានកងទ័ពរបស់ខ្មែរក្រហម ។ ទោះបីជាការផ្លាស់ប្តូរនេះ ប្រហែលជាត្រូវបានរៀបចំឡើងជាយុទ្ធសាស្ត្រមួយដើម្បីប្រមូលកម្លាំងធ្វើការនៅស្រុកក្រឡាញ់ វាក៏អាចជាយុទ្ធសាស្ត្រមួយសម្រាប់ទប់ស្កាត់ប្រជាជនកុំឲ្យរត់ទៅប្រទេសថៃ ។ យោងតាមបទសម្ភាសប្រជាជនមានបំណងរត់ឆ្លងព្រំដែនទៅប្រទេសថៃ ដោយឆ្លងកាត់តាមអន្លង់វែង ប៉ុន្តែត្រូវបានខ្មែរក្រហមចាប់ខ្លួន ។ មិនមានព័ត៌មានណាមួយបង្ហាញថា មានប្រជាជនប៉ុន្មាននាក់អាចរត់គេចខ្លួនរួចនោះទេ ។

ជំពូក ៤

# បរាជ័យ និងការរត់គេចខ្លួនរបស់ខ្មែរក្រហម

## ជម្លោះជាមួយវៀតណាម

ចាប់តាំងពីដំណាក់កាលដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ កងទ័ពខ្មែរក្រហមបានចាប់ផ្តើមប៉ះទង្គិចជាមួយកងទ័ពវៀតណាមកុម្មុយនីស្ត ។[៧៧] ការប្រទាញប្រទង់គ្នានៅតាមព្រំដែនបានបន្តទៅជាការប៉ះទង្គិចគ្នាកាន់តែញឹកញាប់ឡើងៗ រវាងរដ្ឋកុម្មុយនីស្តទាំងពីរ ។ នៅចុងឆ្នាំ១៩៧៧ កម្ពុជាប្រជាធិបតេយ្យបានធ្វើសង្គ្រាម ក្នុងទ្រង់ទ្រាយធំជាមួយនឹងប្រទេសវៀតណាម ។

ការកើនឡើងនូវការប៉ះទង្គិចគ្នាមិនបានកើតឡើងក្នុងពេលតែមួយយប់នោះទេ ។ ជម្លោះរ៉ាំរ៉ៃរវាង ប្រទេសទាំងពីរបានកើតឡើងតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០មកម៉្លេះ ហើយការប្រយុទ្ធគ្នាក្នុងទ្រង់ទ្រាយធំ អាចពិនិត្យមើលបកក្រោយអំពីព្រឹត្តិការណ៍ទាំងឡាយ ដែលបានកើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៧ នៅពេលដែលខ្មែរក្រហមធ្វើការវាយប្រហារទៅលើខេត្តមួយចំនួនរបស់វៀតណាម ។ កងទ័ពខ្មែរក្រហមបានធ្វើការវាយប្រហារខេត្តគៀនយ៉ាង និងខេត្តអានយ៉ាង នៅចុងឆ្នាំ១៩៧៧ និងបានបាញ់ផ្លោងចូលទីរួមខេត្តចូវដុក (ខេត្តមាត់ជ្រូកជាភាសាខ្មែរ) នៅខែឧសភា ។[៧៨] ជាងនេះទៅទៀត នៅខែកញ្ញា ក្រោមបញ្ជារបស់ សុន សេន ខ្មែរក្រហមបានសម្លាប់រង្គាលប្រជាជនស៊ីវិលវៀតណាមប្រមាណជាបីរយនាក់ នៅក្នុងខេត្តតាយនិញ ។[៧៩]

ដោយប្រឈមមុខនឹងការវាយប្រហារនៅតាមបណ្តោយព្រំដែនវៀតណាម បានសម្រេចចិត្តធ្វើការវាយបកវិញ ។ ការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងខ្មែរក្រហមបានរីករាលដាលធំឡើងនៅខែតុលា ឆ្នាំ១៩៧៧ នៅពេលកងទ័ពវៀតណាមបានវាយលុកចូលផ្នែកជាច្រើនក្នុងទឹកដីកម្ពុជា ។ ទោះជាយ៉ាងនេះក្តី មកត្រឹមខែមករា ឆ្នាំ១៩៧៨[៨០] វៀតណាមបានដកកងទ័ពរបស់ខ្លួនចេញទៅវិញ ។[៨១]

ឆ្លើយតបទៅនឹងការលុកលុយរបស់វៀតណាម និងដោយមានការភ័យខ្លាចចំពោះអំពើក្បត់ខាងក្នុង រដ្ឋាភិបាលរបស់ ប៉ុល ពត បានធ្វើសង្គ្រាមជាមួយកម្មាភិបាលក្នុង

ភូមិភាគបូព៌ា ដែលស្ថិតនៅជាប់ព្រំដែនវៀតណាមដែលជា«កន្លែងដែលកងទ័ពវៀតណាមបានលុកលុយចូលយ៉ាងជ្រៅ» ។[៨២] កម្មាភិបាលភូមិភាគបូព៌ាជាច្រើនបានរត់ភៀសខ្លួនទៅវៀតណាម ដែលនៅទីនោះកម្មាភិបាលទាំងនេះ ទទួលបានការគាំទ្រពីវៀតណាម ហើយនៅទីបំផុតវៀតណាមបានជួយផ្ដួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិ កម្ពុជាត្រូវបានបង្កើតឡើង ដែលនឹងជំនួសកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីរបបនេះត្រូវបានផ្ដួលរំលំ ។ នៅខែមិថុនា ឆ្នាំ១៩៧៨ វៀតណាមចាប់ផ្ដើមទម្លាក់គ្រាប់បែកមកលើកម្ពុជា ហើយនៅខែតុលា វៀតណាមចាប់ផ្ដើមរៀបចំសម្រាប់ការវាយប្រហារក្នុងទ្រង់ទ្រាយធំ ។[៨៣] ជាចុងក្រោយ នៅចុងខែធ្នូ ឆ្នាំ១៩៧៨ វៀតណាម បានបើកការវាយប្រហារក្នុងទ្រង់ទ្រាយធំមកលើកម្ពុជាប្រជាធិបតេយ្យ ។





## បរាជ័យរបស់ខ្មែរក្រហម

របបកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ចប់ ដូចគ្នាទៅនឹងការចាប់ផ្តើមនៃរបបនេះដែរ គឺស្ថិតនៅក្នុងស្ថានភាពសង្គ្រាម និងភាពចលាចលនៅក្នុងសង្គម ។ កម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលរំលំដោយកងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។

កងទ័ពវៀតណាមបានវាយសន្ទាប់យ៉ាងខ្លាំងក្លាចូលក្នុងប្រទេសកម្ពុជាជាមួយនឹងចំនួនកងទ័ពដ៏ច្រើនក្នុងល្បឿនលឿន និងកាំភ្លើងធំធុនធ្ងន់ ជាមួយនឹងការវាយប្រហារជាច្រើនដំណាក់កាល ។ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ កងវរសេនាតូចរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចំនួន៩កង និងកងទ័ពប្រជាជនវៀតណាមចំនួន១២កងពលបានធ្វើការវាយប្រហារយ៉ាងខ្លាំង និងព្រមៗគ្នា មកលើកម្ពុជាប្រជាធិបតេយ្យ ។ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយលុកចូលកម្ពុជាប្រជាធិបតេយ្យនៅទីតាំងបីផ្សេងៗគ្នា ។ បីកងវរសេនាតូចបានវាយលុកចូល ខេត្តស្វាយរៀង តាមបណ្តោយផ្លូវជាតិលេខ១ ៣កងវរសេនាតូចទៀតវាយលុកចូលតាមខេត្តកំពង់ចាម និង៣កងវរសេនាតូចចុងក្រោយវាយលុកចូលតាមស្រុកស្នួល ខេត្តក្រចេះ ។

កងទ័ពប្រជាជនវៀតណាមបានប្រើប្រាស់កម្លាំងរបស់ខ្លួនចំនួន១២កងពល (ដែលមានចំនួនប្រហែល ១សែន ២ម៉ឺននាក់) ដោយមានការគាំទ្រពីកងទ័ពជើងទឹក កងរថក្រោះ កងកាំភ្លើងធំ និងកងទ័ពជើងអាកាស ។ កងទ័ពវៀតណាម និងកងទ័ពរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដណ្តើមកាន់កាប់ បានទីក្រុងភ្នំពេញតែក្នុងរយៈពេលបីសប្តាហ៍ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ នៅក្នុងអំឡុងពេលដប់ថ្ងៃបន្ទាប់មកទៀត កងទ័ពទាំងពីរដណ្តើមកាន់កាប់បានប្រទេសកម្ពុជាស្ទើរតែទាំងស្រុង ។ វៀតណាមបានជួយបង្កើតរបបថ្មីមួយ ដែលមានឈ្មោះថា សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៩ ដែលមានសមមិត្ត ហេង សំរិន ជាប្រធាន និងសមមិត្ត ប៉ែន សុវណ្ណ ជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី (នាយករដ្ឋមន្ត្រី) និងជារដ្ឋមន្ត្រីការពារជាតិ ។[៨៤]

## ការរត់គេចខ្លួនទៅភ្នំដងរែក

ជាមួយនឹងការវាយប្រហារពីសំណាក់កងទ័ពវៀតណាម និងកងទ័ពរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមកកម្ពុជា កងទ័ព និងកម្មាភិបាលខ្មែរក្រហម ព្រមទាំងប្រជាជនដែលកំពុងតែភ័យញាប់ញ័រ បានចាប់ផ្តើមរត់បែកខ្ញែកគ្នា និងបានភៀសខ្លួនទៅពួនសម្ងំនៅក្នុងព្រៃ និងបានរត់ទៅព្រំដែនថៃ ។ ជាទូទៅ អង្គភាពរបស់ខ្មែរក្រហមទាំងអស់ បានបាត់បង់ទំនាក់ទំនងជាមួយមេបញ្ជាការរបស់ខ្លួន និងបានបោះបង់ចោលប្រតិបត្តិការសឹក ដើម្បីស្វែងរកកន្លែងលាក់ខ្លួនរៀងៗខ្លួន ។ នៅក្នុងអំឡុងពេលរត់ភៀសខ្លួន ខ្មែរក្រហមបានកេណ្ឌប្រជាជនរាប់ម៉ឺននាក់ទៅជាមួយខ្លួន ក្នុងគោលបំណងរៀបចំចលនាតស៊ូបដិវត្តន៍សាជាថ្មីម្តងទៀត ។ ប្រជាជនក្នុងភូមិភាគឦសាន ភូមិភាគឧត្តរ និងភូមិភាគកណ្តាល ត្រូវបានជម្លៀសទៅកាន់ព្រំដែនភាគខាងជើង ហើយត្រូវបានប្រមូលផ្តុំឡើងវិញ នៅលើជួរភ្នំដងរែក(ដែលស្ថិតនៅក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ) ។ ប្រជាជនដែលរស់នៅភូមិភាគបូព៌ា ភូមិភាគបស្ចិម ភូមិភាគនិរតី និងភូមិភាគពាយ័ព្យត្រូវដើរដោយថ្មើរជើង ឬត្រូវបានដឹកជញ្ជូនទៅភាគខាងលិចនិងពាយ័ព្យនៃព្រំដែនប្រទេសកម្ពុជា ដែលស្ថិតនៅក្នុងខេត្តកោះកុង ពោធិ៍សាត់ និងបាត់ដំបង ។ ចំណែកឯប្រជាជននៅក្នុងទីក្រុងភ្នំពេញត្រូវបានបញ្ជូនតាមរថភ្លើងទៅកាន់ខេត្តពោធិ៍សាត់ និង

បាត់ដំបង ។ បន្ទាប់ពីធ្វើដំណើរដល់ខេត្តទាំងពីរនេះ ប្រជាជនត្រូវបានគម្រូវឲ្យធ្វើដំណើរបន្តដោយថ្មើរជើង ដែលជាដំណើរដ៏វែងឆ្ងាយទៅកាន់ព្រំដែនថៃ ។

នៅតាមផ្លូវដ៏វែង និងប្រកបដោយគ្រោះថ្នាក់ឆ្ពោះទៅព្រំដែនថៃ ប្រជាជន និងកងទ័ពភៀសខ្លួនមានស្បៀងអាហារតិចតួចណាស់ ។ ដូច្នេះប្រជាជនភៀសខ្លួនទាំងអស់នោះត្រូវដើរបេះស្លឹកឈើព្រៃ មើមឈើព្រៃ និងចាប់សត្វព្រៃទាំងឡាយ ដែលអាចរកបាននៅតាមផ្លូវមកធ្វើជាអាហារ ។ ប្រជាជនភៀសខ្លួនមួយចំនួនទទួល បានស្បៀងអាហារពីអ្នកភូមិ ។ ប៉ុន្តែ ជាទូទៅប្រជាជនភៀសខ្លួនត្រូវបង្ខំចិត្តធ្វើដំណើរដោយអត់បាយ និងទឹកបរិភោគអស់រយៈពេលជាច្រើនថ្ងៃ ។ នៅក្នុងករណីមួយចំនួនប្រជាជនភៀសខ្លួនបាននិយាយថា ខ្លួនបានផឹកទឹកនោមខ្លួនឯង ដោយសារតែមិនអាចទៅរកទឹកមកហូបបានពីព្រោះ តំបន់ដែលមានទឹកត្រូវបានកងទ័ពវៀតណាមយាមល្បាត ។ កងទ័ព និងប្រជាជនភៀសខ្លួនមួយចំនួនបាន និយាយថា ខ្លួនបានផឹកទឹកដែលមានជាតិពុល ដែលបានបណ្តាលឲ្យស្លាប់បន្ទាប់ពីបរិភោគរួច ។ ការពិតអំពីការរាយការណ៍ទាំងនេះមិនត្រូវបានដឹងទេ ហើយការស្លាប់ក៏អាចបណ្តាលមកពីការហូបទឹកកខ្វក់ ដែលមានសារធាតុគីមី ឬមានមេរោគបង្កជំងឺ ។[៨៥]

ប្រជាជនដែលរត់ទៅកាន់ព្រំដែនថៃ ជួបប្រទះបញ្ហាលំបាកជាច្រើន ដូចជា កង្វះខាតស្បៀងអាហារ និងជម្រក ។ ជាងនេះទៅទៀត ប្រជាជនភៀសខ្លួនទាំងនោះ មិនហ៊ានចូលទៅក្នុងភូមិដ្ឋានរបស់អ្នកភូមិទេ ដោយសារតែខ្លាចកងទ័ពវៀតណាមចាប់ខ្លួន ។

ប្រជាជននៅភូមិភាគឦសាន ដែលរួមមានខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី និងក្រចេះ ត្រូវឆ្លងទន្លេមេគង្គទៅកាន់ខេត្តព្រះវិហារ ដើម្បីធ្វើដំណើរទៅកាន់ព្រំដែនថៃ ។[៨៦] ប្រជាជនទាំងអស់នោះភាគច្រើនជាសមាជិកកងពល៨០១ និងកងពល៩២០ ដែលជាកងពលមជ្ឈិមរបស់ខ្មែរក្រហម ក្រោមការគ្រប់គ្រងរបស់ សូ សារឿន (ហៅ តា០៥) និង មៀច សាន (ហៅ តា០៦) ។ ទោះបីជាប្រជាជនមួយចំនួនឆ្លងទន្លេមេគង្គនៅខេត្តក្រចេះ និងស្ទឹងត្រែងក្តី ប្រជាជនមួយចំនួនទៀត ត្រូវឆ្លងទន្លេមេគង្គនៅក្នុងទឹកដីឡាវ ដោយសារតែការវាយប្រហាររបស់កងទ័ពវៀតណាមនៅក្នុងទឹកដីកម្ពុជា ។ ខណៈពេលដែលប្រជាជនមួយចំនួនឆ្លងទន្លេដោយទូក ប្រជាជនមួយចំនួនទៀតឆ្លងទន្លេដោយប្រើដើមឫស្សីពីរបីដើមចងផ្អោបគ្នាតែប៉ុណ្ណោះ ។ ប្រជាជនត្រូវធ្វើដំណើរនៅពេល

ថ្ងៃ និងសម្រាកនៅពេលយប់ ។ ប្រជាជនមួយចំនួនបានស្លាប់នៅតាមផ្លូវដោយសារតែដាច់បាយ ។ មិនមានអ្នកណាគិតអំពីអ្នកណានោះទេ ។ ម្នាក់ៗប្រឹងធ្វើយ៉ាងណាឲ្យតែខ្លួនបានរួចរស់ជីវិត ។ ដូចដែលអ្នករស់រានមានជីវិតម្នាក់បានលើកឡើងថា ដើម្បីរស់ម្នាក់ៗក្លាយទៅជាមនុស្សអាត្មានិយម ។[៨៧]

សាំង ថាញ់ អតីតនីរសារកងពល២៨០របស់ខ្មែរក្រហមដែលមានទីតាំងនៅភូមិភាគបូព៌ាបានរៀបរាប់អំពីបទពិសោធរបស់ខ្លួននៅពេលរត់ទៅភ្នំ១០០១ថា ៖

> *នៅឆ្នាំ១៩៨០ ខ្ញុំបានដឹកនាំកងទ័ព៧នាក់រត់ទៅមុំបី ។ នៅតាមផ្លូវ ខ្ញុំបានជួបកងទ័ពខ្មែរក្រហម និងប្រជាជនជាច្រើនក្រុម ដែលកំពុងធ្វើដំណើរទៅមុំបីដែរ ។ ទោះជាយ៉ាងនេះក្តី ក្រុមនីមួយត្រូវមានភាពឯករាជ្យ ពោលគឺ ធ្វើយ៉ាងណាឲ្យទៅដល់មុំបី ដើម្បីជួបជុំជាមួយអង្គការ ។ ខ្ញុំបានយកមាសទៅដូរយកអង្ករនឹងអំបិលពីអ្នកភូមិ ។ យើងបានរំលែកអំបិលដាក់ទៅក្នុងកូនថង់តូចៗហើយទុកនៅក្នុងកាបូបរៀងៗខ្លួន ។ ខ្ញុំបានឃើញមនុស្សជាច្រើនបានស្លាប់ ហើយសាកសពហើមស្អុយនៅតាមផ្លូវ ។ ស្ត្រីមួយចំនួនបានដេកស្លាប់នៅក្នុងអង្រឹង ។ ស្ត្រីមួយចំនួនបានស្រែកហៅឲ្យខ្ញុំជួយ «សមមិត្ត! សូមជួយផង! សូមយកខ្ញុំទៅជាមួយផង!» ខ្ញុំបានសួរខ្លួនឯងថា «តើខ្ញុំអាចជួយពួកគាត់យ៉ាងម៉េច បើខ្ញុំជួយខ្លួនឯងមិនទាំងបានផង?» ជាងនេះទៅទៀត កងទ័ពវៀតណាមបានដេញតាមយើងពីក្រោយជាប់រហូត ។ កងទ័ពបានសម្លាប់មនុស្សដែលជិតស្លាប់ ។ ពេលមកដល់ស្រុកឆែប យើងបានកាប់ដើមចេក ហើយបេះផ្លែចេកខ្ចីយកមកហូបដូចដំរី ។ យើងបានចំណាយពេលមួយខែកន្លះទើបធ្វើដំណើរមកដល់មុំបី ។ ពេលទៅដល់មុំបី យើងរកបានអង្ករយ៉ាងច្រើន ហើយម្នាក់ៗកំពុងតែឃ្លានខ្លាំង ។ ម្នាក់ៗហូបច្រើនហួសហេតុ ។ ប្រជាជនមួយចំនួនបានស្លាប់ដោយសារតែហូបអង្ករឆៅច្រើនជ្រុល ។ ដូច្នេះ មេៗបានឲ្យយើងហូបបាយដំណើបជំនួសវិញ ។[៨៨]*

កងទ័ពខ្មែរក្រហម និងសមាជិកក្រុមគ្រួសារបានចំណាយពេលជាច្រើនថ្ងៃ (ហើយ

សម្រាប់ប្រជាជនជាច្រើនផ្សេងទៀត ត្រូវចំណាយពេលជាច្រើនខែ) ដើម្បីដើរទៅព្រំដែនថៃ ។ ឈឿន ដែលជាកងទ័ព ម្នាក់នៅក្នុងកងពល៩២០ បានធ្វើដំណើរដោយថ្មើរជើងជាមួយកងទ័ពខ្មែរក្រហមចំនួន១.៥០០នាក់ ផ្សេងទៀតអស់រយៈពេល២ខែ និង ១០ថ្ងៃដើម្បីទៅដល់ខេត្តបាត់ដំបង ដែលនៅទីនោះ មេបញ្ជាការកងពល មៀច សាន បានមកទទួលហើយនាំផ្លូវឆ្ពោះទៅកាន់ ភ្នំដងរែក ។[៨៩] យឹម ផាន់ណា ដែលជាអតីតកងទ័ពនៅក្នុងកងពល៨០១ បានរត់ភៀសខ្លួនទៅកាន់ព្រំដែនថៃជាមួយនឹងកងទ័ព និងកម្មាភិបាលខ្មែរក្រហមដទៃ ទៀត ។ ផាន់ណា បានរំឭកអំពីដំណើរដ៏វែង និងលំបាកថា ៖

> យើងចាប់ផ្តើមធ្វើដំណើរខែមីនា ឆ្នាំ១៩៧៩ ។ អាកាសធាតុនៅពេលនោះក្តៅខ្លាំងណាស់ ។ តំបន់ដែលមានទឹកត្រូវបានកងទ័ពវៀតណាមគ្រប់គ្រង ។ ជារឿយៗ ការប្រយុទ្ធគ្នាតែងតែកើតឡើង នៅតាមតំបន់ទាំងនោះ ។ មនុស្សជាច្រើនបានស្លាប់ និងរបួស ។ ដៃជើងរបស់ខ្ញុំចាប់ផ្តើមហើម ដែលធ្វើឲ្យខ្ញុំមិនអាចដើរទៅមុខបាន ។ ខ្ញុំបានវង្វេងពីក្រុមរបស់ខ្ញុំ នៅពេលរត់គេចពីកងទ័ពវៀតណាម ។ នៅទីបំផុត ខ្ញុំត្រូវផឹកទឹកនោមខ្លួនឯងដើម្បីរស់ ។ជួនកាល កងទ័ពវៀតណាមវាយប្រហារយើងនៅពេលដែលយើងកំពុងដាំបាយ ។ យើងត្រូវរត់បែកផ្លូវគ្នា ដោយទុកបាយចោល ។ ពីមួយពេលទៅមួយពេលក្រុមរបស់យើងកាន់តែតូចទៅៗ ។ ឌី ធិន គឺជាមេក្រុមរបស់យើងនៅពេលនោះ ។ នៅពេលយើងធ្វើដំណើរមកដល់ស្រុកឆែប ខ្ញុំត្រូវបានបង្ខំឲ្យចូលទៅក្នុងភូមិដើម្បីទទួលការព្យាបាល ព្រោះដៃជើងរបស់ខ្ញុំកាន់តែហើមខ្លាំងឡើង ។ ថែមទាំងគ្រុនក្តៅទៀត ។ ប្រសិនបើខ្ញុំបន្តនៅជាមួយក្រុម ដំណើរទៅមុខរបស់យើងនឹងត្រូវយឺតដោយសារតែជំងឺរបស់ខ្ញុំ ។ ដូច្នេះ ក្រុមរបស់ខ្ញុំបានដកហូតកាំភ្លើងរបស់ខ្ញុំ និងបង្ខំឲ្យខ្ញុំចូលសារភាពជាមួយសត្រូវ ។ មិនចង់ទៅទេ ប៉ុន្តែគ្មានជម្រើស ។ ពេលមកដល់ក្នុងភូមិ ខ្ញុំត្រូវបានកងទ័ពវៀតណាមចាប់ខ្លួន ហើយបញ្ជូនទៅក្នុងគុក ។ នៅទីនោះបានជួបមិត្តភក្តិរបស់ខ្ញុំជាច្រើន ។[៩០]

គីម ណន ដែលជាអតីតកងទ័ពខ្មែរក្រហមប្រចាំនៅតំបន់សៀមរាប-ឧត្តរមានជ័យ (តំបន់១០៦) ស្ថិតនៅក្នុងកងកាំភ្លើងធំនៃតំបន់នេះ ។ នៅឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមវាយចូលកម្ពុជា ណន និងកងរបស់ខ្លួន ត្រូវបានបញ្ជូនទៅស្រុកថាឡាបរិវ៉ាត់ (ខេត្តស្ទឹងត្រែង) ដើម្បីជួយវាយសមរភូមិនៅទីនោះ ។ ណន បានរៀបរាប់អំពីដំណើរភៀសខ្លួនដ៏លំបាកទៅកាន់ព្រំដែនថៃថា ៖

> *ពេលមកដល់ស្រុកថាឡាបរិវ៉ាត់ ខ្ញុំមិនអាចបែងចែកបានអ្នកណាជាខ្មែរ អ្នកណាជាយួនបានទេ ។ ព្រឹកឡើង ខ្ញុំបានឃើញកងទ័ពវៀតណាមជាច្រើន ដូចផ្សិតដែលដុសចេញពីដី ។ ការប្រយុទ្ធគ្នាបានកើតឡើងជាច្រើនថ្ងៃ ។ យើងចាញ់កងទ័ពវៀតណាម ហើយបានដកថយចូលទៅក្នុងព្រៃ ដែលនៅទីនោះមានសត្វព្រៃជាច្រើន ដូចជា ដំរី និងខ្លា ។ ខ្ញុំគិតថា ខ្ញុំប្រាកដជាស្លាប់មិនខាន ។ នៅពេលយប់ ខ្ញុំមិនហ៊ានដេកនៅលើដីទេ ។ ខ្ញុំដេកនៅលើដើមឈើ ។ លុះដល់ព្រឹកឡើង ខ្ញុំបានវង្វេងទិស ។ ខ្ញុំបានឮសំឡេងបាញ់កាំភ្លើង ហើយក៏សម្រេចដើរតាមទិសដៅសំឡេងនោះ ។ ពេលដើរទៅដល់ទីវាលមួយ ខ្ញុំបានឃើញមនុស្សមួយក្រុមអត់ពាក់អាវ ប៉ុន្តែ មិនអាចមើលស្គាល់ថាជាអ្នកណា ។ ខ្ញុំបានស្រែកហៅពួកគេ ប៉ុន្តែ ដោយសារពួកគេជាកងទ័ពវៀតណាម ដូច្នេះ ពួកគេមិនអាចស្តាប់ ខ្ញុំយល់ទេ ។ កងទ័ពទាំងនោះបានបក់ដៃឲ្យខ្ញុំដើរទៅរកគេ ។ ខ្ញុំបានដើរទៅរកពួកគេ ប៉ុន្តែនៅពេលដែលមើលឃើញថាជាពួកកងទ័ពវៀតណាម ខ្ញុំបានរត់គេចចេញ ។ ខ្ញុំបានវង្វេងនៅក្នុងព្រៃអស់រយៈពេលពីរថ្ងៃទៀត ដោយគ្មានអាហារ ។ ពេលដើរតាមផ្លូវ ខ្ញុំបានឮសំឡេងឡានមួយ ។ ខ្ញុំបានដឹងថា វាជាឡានរបស់ខ្មែរក្រហម ដូច្នេះ ខ្ញុំបានរត់សំដៅទៅរកឡាននោះ ហើយសុំជិះទៅជាមួយ ។ កងទ័ពខ្មែរក្រហមទាំងនោះ យល់ព្រមឲ្យខ្ញុំជិះជាមួយ ។ កងទ័ពវៀតណាមនៅតែបន្តដេញយើង ពីក្រោយរហូតដល់ស្រុកជាំក្សាន្តខេត្តព្រះវិហារ ។*[៩១]

ប្រជាជនជ្រើសរើសការរត់ភៀសខ្លួនទៅកាន់ព្រំដែនកម្ពុជា-ថៃ ដោយសារហេតុ

ផលជាច្រើន ។ ប្រជាជននៅតែមានជំនឿលើការឃោសនារបស់ខ្មែរក្រហមដែលថា វៀតណាមគឺជាសត្វចម្លែក ។ ខ្មែរក្រហមបានឃោសនាប្រាប់ប្រជាជនថា កងទ័ពវៀតណាមនឹងអារកមនុស្ស ឬដាក់ចូលទៅក្នុងទឹកក្តៅ ។ ខ្មែរក្រហមក៏បានប្រាប់ប្រជាជនដែរថា វៀតណាមចូលចិត្តវះពោះមនុស្ស ហើយញាត់ស្មៅចូល ។ ប្រជាជនជាច្រើនយល់ឃើញថា ជីវិតនឹងវេទនាជាងស្លាប់ទៅទៀត ប្រសិនបើកងទ័ពវៀតណាមចាប់បាន ។ ដូច្នេះ ប្រជាជនសុខចិត្តប្រើមធ្យោបាយគ្រប់បែបយ៉ាងដើម្បីរត់គេចខ្លួន ។ ប្រជាជនមួយចំនួនទៀតយល់ ឃើញថាប្រទេសកម្ពុជា បានធ្លាក់ក្រោមការគ្រប់គ្រងរបស់វៀតណាម ហើយជម្រើសតែមួយគត់គឺការកសាងជីវិតសាជាថ្មីនៅក្នុងប្រទេសមួយទៀត ។ ប្រជាជនមួយចំនួនទៀតបានដឹងថា អង្គការសហប្រជាជាតិកំពុងផ្តល់អាហារដល់ជនភៀសខ្លួន នៅជំរំជនភៀសខ្លួន នៅភ្នំឆត្រ និងជំរំជនភៀសខ្លួនដទៃទៀតនៅក្នុងប្រទេសថៃ ។ ទោះជាយ៉ាងនេះក្តី ប្រជាជនមួយចំនួនគឺជាសមាជិករបស់របបកម្ពុជាប្រជាធិបតេយ្យ ។

ឡុង ដេង ដែលជាអតីតកងទ័ពនៅក្នុងកងពល៨០១ បានរំឭកពីការគេចខ្លួនរបស់គាត់ពីខេត្តរតនគិរី ទៅកាន់ទន្លេរពៅថា ៖

> នៅពេលដែលវៀតណាមចូលមកដល់កម្ពុជានៅឆ្នាំ១៩៧៩ ខ្ញុំបានរត់ចូលនិងរស់នៅក្នុងព្រៃខេត្តរតនគិរី ។ បន្ទាប់មក នៅឆ្នាំ១៩៨១ ខ្ញុំបានរត់ទៅភ្នំដងរែក ដោយសារតែមានការលំបាកផ្នែកសេដ្ឋកិច្ច ។ យើងបានធ្វើដំណើរចេញពីខេត្តរតនគិរី ឆ្លងកាត់តាមប្រទេសឡាវ ពីព្រោះកងទ័ពវៀតណាមបានឈរជើងនៅតាមព្រំដែនក្នុងទឹកដីកម្ពុជា ។ ពេលមកដល់ខេត្តស្ទឹងត្រែង យើងបានធ្វើក្បូនឫស្សី ដើម្បីឆ្លងទន្លេមេគង្គទៅខេត្តព្រះវិហារ ។ នៅពេលដែលខ្ញុំកំពុងហែលឆ្លងទន្លេ ជើងរបស់ខ្ញុំបានរមួលក្រពើ ។ ខ្ញុំក៏អង្គុយសម្រាកនៅច្រាំងទន្លេ ដោយសារតែខ្ញុំមិនអាចដើរទៅមុខបាន ។ សមាជិកផ្សេងទៀតនៅក្នុងអង្គភាពរបស់ខ្ញុំបានឆ្លងទន្លេ និងបានបន្តដំណើរទៅមុំបីមុនខ្ញុំ ។ ខ្ញុំបានចំណាយពេលអស់៩ថ្ងៃ មុននឹងធ្វើដំណើរទៅដល់ទន្លេរពៅ ឬមុំបី ។ ចំណែកឯមិត្តភក្តិរបស់ខ្ញុំចំណាយពេលតែ៣ថ្ងៃប៉ុណ្ណោះ ។[៩៧]

ឯម សារិន ដែលជាសមាជិកគណៈតំបន់ក្រចេះចុងក្រោយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានគ្រប់គ្រងការរត់គេចខ្លួនរបស់កម្មាភិបាលកងទ័ព និងប្រជាជនស៊ីវិលពីខេត្តក្រចេះទៅកាន់ព្រំដែនថៃ ។ សារិន បានដឹកនាំប្រជាជន និងកងទ័ពឆ្លងទន្លេមេគង្គនៅស្រុកព្រែកប្រសព្វ ហើយបន្តដំណើរទៅខេត្តកំពង់ធំ និងធ្វើដំណើរបន្តទៀតទៅកាន់ខេត្តព្រះវិហារ ។ ប្រជាជនជាច្រើនផ្សេងទៀត បានធ្វើដំណើរតាមឡានទៅខេត្តស្ទឹងត្រែង និងបានឆ្លងទន្លេមេគង្គទៅស្រុកថាឡាបរិវ៉ាត់ ហើយបន្តដំណើរឆ្ពោះទៅខេត្តព្រះវិហារ ។ សម្រាប់ដំណើរដ៏វែងឆ្ងាយនេះ សារិន បានត្រៀមឡាន ចំនួន៤៧គ្រឿង ដោយមានសាំងពេញ ព្រមទាំងស្បៀងអាហារ និងសម្ភារៈសំខាន់ៗផ្សេងទៀត ។ ដោយសារតែប្រជាជននៅភូមិភាគឦសាន មានចំនួនច្រើនលើសលប់ សារិន មិនអាចដឹកជញ្ជូនប្រជាជន និងឡានទាំងអស់ឆ្លងទន្លេបានទេ ។ ដោយមានជំនួយពី ខេង ដែលជាលេខាតំបន់ស្ទឹងត្រែង សារិន អាចចម្លងបានតែឡានចំនួន ១៧គ្រឿង និងសម្ភារៈសំខាន់ៗមួយចំនួនតែប៉ុណ្ណោះ ដែលមានដូចជា សាំង អង្ករ និងសម្លៀកបំពាក់ ។ សារិន បានបញ្ជាឲ្យដុតឡានដែលនៅសេសសល់ចោលទាំងអស់ ដើម្បីកុំឲ្យកងទ័ពវៀតណាមប្រើប្រាស់បាន ។ ប្រជាជនដែលឆ្លងស្រឡាងមិនទាន់ ត្រូវហែលឆ្លងទន្លេមេគង្គ ឬរត់ចូលព្រៃ ។[៩៣] ស្ថានភាពនៅពេលនោះមានសភាពតានតឹង និងជ្រួលច្របល់យ៉ាងខ្លាំងដោយសារកងទ័ពវៀតណាម បានវាយចូលកាន់តែជិតដល់តំបន់នេះ ហើយប្រជាជនបាននាំគ្នារត់គេចខ្លួនទៅតាមទិសដៅផ្សេងៗគ្នា ។

ដោយបែកពីប្រពន្ធ សារិន បានសម្រេចចិត្តមិនធ្វើដំណើរទៅព្រំដែនថៃ ភ្លាមៗទេ ។ សារិន បានសម្រេចចិត្តដើរបកក្រោយវិញ ដើម្បីស្វែងរកប្រពន្ធរបស់គាត់ ។ បន្ទាប់ពីបានជួបប្រពន្ធរបស់គាត់នៅខេត្តកំពង់ចាម សារិន បានទៅរស់នៅក្នុងព្រៃជាមួយកងទ័ពខ្មែរក្រហមមួយក្រុមទៀតរហូតដល់ឆ្នាំ១៩៨៣ ។ ក្រោយមក សារិន បានធ្វើដំណើរមកចូលរួមជាមួយចលនាខ្មែរក្រហមនៅលើភ្នំដងរែក ។ សារិន បានរៀបរាប់អំពីជីវិតរបស់គាត់នៅក្នុងព្រៃថា ៖

> ខ្ញុំបានបរទេះគោទៅភ្នំដី ។ ក្រុមរបស់ខ្ញុំមានគ្នាចំនួន១៥នាក់ ដែលក្នុងនោះមានស្ត្រី ២នាក់ ។ យើងបានលាក់ខ្លួននៅក្នុងព្រៃ កាប់ឆ្ការព្រៃយកដី និងធ្វើស្រែចម្ការសម្រាប់ចិញ្ចឹមជីវិត ។ កងទ័ពខ្មែរក្រហមជាច្រើនអន្តភាព

> ផ្សេងទៀត កំពុងធ្វើប្រតិបត្តិការនៅខាងមុខ ។ អង្គភាពមួយចំនួនខ្វះខាតអំបិលនិងស្បៀងអាហារ ។ ជាសំណាងល្អ ក្រុមរបស់ខ្ញុំបានរកឃើញអំបិលមួយពាង និងស្ករមួយពាង ដែលត្រូវបានកប់លាក់ទុកនៅក្នុងដីដែលជាអតីតទីតាំងមួយរបស់កងទ័ពខ្មែរក្រហម ។ យើងបានដាំ និងសម្ងួតអំបិលហើយលាក់ទុកសម្រាប់ប្រើឲ្យបានយូរ ។ យើងមានអំបិល ពូថៅ និងកាំបិតជាច្រើន ដែលអាចឲ្យយើងធ្វើស្រែចម្ការបានល្អ ។ យើងដាំស្រូវ និងបន្លែជាច្រើន ដែលរួមមានពោត ឪឡឹក ត្រកួន ត្រសក់ ល្ពៅ និងត្រសក់ស្រូវ ។ បន្ទាប់ពីរស់នៅទីនេះអស់រយៈពេលពីរបីឆ្នាំ យើងបានសម្រេចចិត្តធ្វើដំណើរឡើងភ្នំដងរែកនៅឆ្នាំ១៩៨៣ ។[៩៤]

ដើម្បីសម្រួលដល់ការរត់ភៀសខ្លួនរបស់កងទ័ព និងប្រជាជនស៊ីវិល ទៅកាន់ព្រំដែនថៃ និងតំបន់ផ្សេងៗទៀតនៅតាមព្រំដែនដែលគ្រប់គ្រងដោយខ្មែរក្រហម ខ្មែរក្រហមបានដាក់អង្គភាពកងទ័ពតូចៗជាច្រើននៅតាមផ្លូវ ។ អង្គភាពទាំងនេះ ទទួលខុសត្រូវយាមល្បាតតាមផ្លូវ និងចង្អុលបង្ហាញទិសដៅដល់ប្រជាជនភៀសខ្លួន ។ នៅក្នុងករណីខ្លះ អង្គភាពទាំងនេះដឹកនាំប្រជាជនទៅកាន់ជំរំកងទ័ពនៅលើភ្នំដងរែក ។ ប្រសិនបើពុំមានជំនួយពីអង្គភាពទាំងអស់នេះទេ កងទ័ពខ្មែរក្រហម និងប្រជាជនភៀសខ្លួន ប្រាកដជាមានការលំបាកក្នុងការរត់គេចពីកងទ័ពវៀតណាម ដែលបានគ្រប់គ្រងស្ទើរគ្រប់ឃុំស្រុកទាំងអស់នៅទូទាំងប្រទេស ។

ប្រជាជនដែលធ្វើដំណើរចាកចេញពីប្រទេសកម្ពុជា មានការហត់នឿយយ៉ាងខ្លាំង និងទទួលរងគ្រោះពីការខ្វះជីវជាតិយ៉ាងធ្ងន់ធ្ងរ ។ ប្រជាជនជាច្រើនបានធ្វើដំណើរច្រើនជាងមួយខែដោយគ្មានអាហារ ។ មេដឹកនាំខ្មែរក្រហមបានអនុញ្ញាតឲ្យប្រជាជនទាំងនោះសម្រាករយៈពេលមួយឬពីរខែ ដោយបានផ្គត់ផ្គង់សម្ភារៈជាច្រើនដូចជាថ្នាំសង្កូវ សម្លៀកបំពាក់អាហារ និងសម្ភារៈចាំបាច់ផ្សេងៗទៀតសម្រាប់ការរស់នៅ ។ បន្ទាប់មក មេដឹកនាំខ្មែរក្រហមបានរៀបចំចាត់តាំងកម្លាំងប្រយុទ្ធ ឡើងវិញដោយបែងចែកប្រជាជនទៅតាមអតីតតំបន់ និងអង្គភាពរៀងៗខ្លួនឡើងវិញ ។[៩៥]

ជំពូក៥

# អន្លង់វែងនៅក្រោមការគ្រប់គ្រងរបស់វៀតណាម

## ការមកដល់របស់កងទ័ពវៀតណាម

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យចេញពីអំណាច ។ ភ្លាមៗនោះកងទ័ពវៀតណាម និងរណសិរ្សសាមគ្គី សង្គ្រោះជាតិកម្ពុជាបានបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ ដែលមានឈ្មោះថា សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ប្រជាជនអន្លង់វែង ដែលត្រូវបានជម្លៀសដោយបង្ខំឲ្យទៅធ្វើការនៅតាមសហករណ៍ផ្សេងៗ បានវិលត្រឡប់មកផ្ទះរបស់ខ្លួនវិញ ។ ទោះបីជាបានវិលត្រឡប់មកដល់ផ្ទះវិញក្តី ក៏ប្រជាជនទាំងនោះនៅតែព្រួយបារម្ភ ប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជាជាមួយនឹងកងទ័ពខ្មែរក្រហម ។

នៅពេលដែលប្រជាជនត្រឡប់មកតំបន់អន្លង់វែងដំបូង ប្រជាជនទាំងអស់នោះប្រមូលផ្តុំគ្នានៅតំបន់មួយ ដែលបច្ចុប្បន្នបានក្លាយទៅជាផ្សារអន្លង់វែង ។ ប្រជាជនបានឃើញអង្ករ និងសម្ភារៈប្រើប្រាស់ជាច្រើនដូចជា កង់ ម៉ូតូ និងម៉ាស៊ីនដេរ ដែលកម្មាភិបាល និងកងទ័ពខ្មែរក្រហមបានបោះបង់ចោលនៅពេលខ្មែរក្រហមរត់ចេញ ពីតំបន់នេះ ។ ប្រជាជនបាននាំគ្នាប្រមូលយកអង្ករ និងសម្ភារៈទាំងអស់នោះ ហើយត្រឡប់ទៅផ្ទះរៀងៗខ្លួន ។

មួយសប្តាហ៍ក្រោយមក កងទ័ពវៀតណាមបានមកដល់ និងបានគ្រប់គ្រងតំបន់អន្លង់វែង ។ កងទ័ពវៀតណាមបានហៅប្រជាជនមកប្រជុំ ។ នៅពេលកំពុងប្រជុំ កងទ័ពខ្មែរក្រហមបានចូលមកវាយប្រហារ កន្លែងប្រជុំដែលបានរំសាយការប្រជុំនោះ ។ ការប្រយុទ្ធគ្នាបានបន្តពេញមួយថ្ងៃ មុនពេលកងទ័ពវៀតណាមអាចវាយរុញច្រានកងទ័ពខ្មែរក្រហមឲ្យចូលព្រៃវិញ ។ នៅព្រឹកថ្ងៃបន្ទាប់ កងទ័ពវៀតណាម និងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាបានរៀបចំការប្រជុំមួយទៀតជាមួយប្រជាជននៅអន្លង់វែង ។ កងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាបានប្រកាសថា ខ្លួនចូលមកដើម្បីរំដោះប្រជាជន

មិនមែនមកសម្លាប់ប្រជាជននោះទេ និងបានប្រកាសប្រាប់ប្រជាជនឲ្យរៀបចំខ្លួនសម្រាប់ការជម្លៀសជាលើកទីពីរ ។ កងទ័ពវៀតណាមបានសម្រេចចិត្តថា ប្រជាជននៅអន្លង់វែងត្រូវតែផ្លាស់ទៅនៅភូមិផ្សេង ពីព្រោះអន្លង់វែងនៅដាច់ស្រយាលពេក ហើយមានការពិបាកក្នុងការការពារ ។ ម្យ៉ាងវិញទៀត ដោយសារតែមានការវាយប្រហារឥតឈប់ឈរពីសំណាក់ខ្មែរក្រហម ប្រជាជនត្រូវតែទៅរស់នៅតំបន់ផ្សេងដែលមានសុវត្ថិភាពជាងអន្លង់វែង ។[៩៦] យោងតាមបទសម្ភាសជាមួយប្រជាជន តំបន់អន្លង់វែងមានប្រជាជនរស់នៅប្រហែល១០០គ្រួសារ ដែលមានចំនួនប្រជាជនសរុបពី៤០០ទៅ៥០០នាក់ ។ កងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាម បានប្រើប្រាស់រថយន្តចំនួន៣០គ្រឿង ដើម្បីដឹកជញ្ជូនប្រជាជនទាំងអស់ទៅកាន់ឃុំកន្ទួត ក្នុងស្រុកជាំក្សាន្ត ។ ការជម្លៀសនេះត្រូវបានធ្វើឡើងនៅខែមីនា ឆ្នាំ១៩៧៩ ។ ប្រជាជនមួយចំនួននៅតែបន្តភ័យខ្លាចចំពោះខ្មែរក្រហម និងជឿជាក់ថាវៀតណាមចូលមករំដោះខ្លួន ។ ប្រជាជនទាំងនោះបានសម្រេចចិត្តទៅរស់នៅឃុំស្រែណយ ក្នុងស្រុកវ៉ារិន្ទ ដែលជាកន្លែងប្រជាជនទាំងនោះកសាងជីវិតថ្មីដោយប្រកបរបរកសិកម្ម ។[៩៧]

មកដល់ស្រុកជាំក្សាន្ត មេឃុំរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចេញមកទទួលស្វាគមន៍ប្រជាជនជម្លៀសមកពីអន្លង់វែង ។ ប្រជាជនអន្លង់វែង ត្រូវបានដាក់ឲ្យនៅមួយកន្លែង ហើយឃុំថ្មីមួយត្រូវបានបង្កើតឡើង សម្រាប់ ប្រជាជនដែលមកពីអន្លង់វែង ។ ជាសំណាងល្អ ដោយសារតែផ្ទះជាច្រើនខ្នងត្រូវបានបោះបង់ចោលប្រជាជនអន្លង់វែងមិនចាំបាច់សាងសង់ផ្ទះថ្មីនោះទេ ។[៩៨]

ទោះបីជាស្រុកជាំក្សាន្តមានសុវត្ថិភាពជាងអន្លង់វែងយ៉ាងណាក្តី ក៏តំបន់នេះនៅតែទទួលរងការវាយប្រហារពីសំណាក់ខ្មែរក្រហមជាញឹកញាប់ ។ នៅទីបញ្ចប់ស្រុកជាំក្សាន្តក៏ត្រូវបានបោះបង់ចោល ហើយប្រជាជនត្រូវបានផ្លាស់ប្តូរទីលំនៅទៅកាន់ស្រុករវៀងដែលនៅពេលនោះគឺជាទីរួមខេត្តព្រះវិហារ ។ បន្ទាប់ពីសមាហរណកម្មឆ្នាំ១៩៩៨ ប្រជាជនមួយចំនួនដែលនឹកស្រុកកំណើត បានត្រឡប់ទៅរស់នៅស្រុកអន្លង់វែងវិញ ហើយប្រជាជនមួយចំនួនទៀតបានបន្តរស់នៅក្នុងស្រុករវៀង ។

កងទ័ពខ្មែរក្រហម និងប្រជាជនមួយចំនួនតូច ដែលកើតនៅអន្លង់វែង បានបដិសេធមិនគោរពតាមផែនការជម្លៀសរបស់កងទ័ពវៀតណាម និងកងទ័ពសាធារណរដ្ឋប្រជា

មានិតកម្ពុជា ហើយបានសម្រេចចិត្តបន្តរស់នៅអន្លង់វែងតទៅទៀត ។ ជាលទ្ធផល ប្រជាជន និងកងទ័ពទាំងនេះជួបប្រទះនឹងឧបសគ្គ និងគ្រោះថ្នាក់ជាច្រើន ។ កងទ័ពវៀតណាមមិនទុកចិត្តប្រជាជននេះទេ ដោយសារប្រជាជនទាំងនេះហាក់នៅមានភក្តីភាពជាមួយខ្មែរក្រហម ។ ទោះបីជាគ្មានភស្តុតាងច្បាស់លាស់ក៏ដោយ ប្រជាជនដែលរស់នៅតំបន់នេះ មួយចំនួនបាននិយាយថា ប្រជាជនមួយចំនួនត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។[99] កងទ័ពវៀតណាមបានចោទប្រកាន់ប្រជាជនទាំងនោះថាជា «កងទ័ព ប៉ុល ពត ដែលមានបាតដៃប្រឡាក់ឈាម ។»[100] យឹម ឡាហឿ បាននិយាយថា គាត់ និងប្រជាជនប្រមាណ៧០នាក់ទៀត បានវិលត្រឡប់ទៅអន្លង់វែងដើម្បីស្វែងរកសាច់ញាតិ ប៉ុន្តែត្រូវបានកងទ័ពវៀតណាមចាប់ខ្លួននៅភូមិលំទង ។ ប្រជាជនដែលត្រូវបានចាប់ខ្លួនបានទទួលទារុណកម្ម និងសួរចម្លើយ ។ ឡាហឿ បានរំឭកថា ៖

> *ខ្ញុំបានរត់ត្រឡប់មកផ្ទះ ហើយត្រូវកងទ័ពវៀតណាមចាប់ខ្លួន បាននៅភូមិលំទង ។ កងទ័ពវៀតណាមបានឆែកឆេរខ្លួនខ្ញុំ និងបានសម្លឹងមើលសម្លៀកបំពាក់ មុខ និងភ្នែករបស់ខ្ញុំ ។ បន្ទាប់មក កងទ័ពវៀតណាមបានជ្រើសរើសគ្នារបស់ខ្ញុំចំនួន៥នាក់ហើយបានសួរយើងថា ធ្វើអ្វីកាលពីជំនាន់សម្តេចព្រះនរោត្តម សីហនុ ។ ខ្ញុំបានឆ្លើយថា ខ្ញុំមិនមានធ្វើអ្វីទេ គ្រាន់តែបានរៀនសូត្របន្តិចបន្តួច ។ «តើអ្នកធ្វើអ្វីនៅក្នុងរបប លន់ នល់?» ខ្ញុំបានឆ្លើយថា ឃ្វាលគោ ។ «តើអ្នកធ្វើអ្វីនៅក្រោយឆ្នាំ១៩៧០?» ខ្ញុំឆ្លើយថា ខ្ញុំមិនបានធ្វើអ្វីទេ ព្រោះខ្ញុំនៅតូច ។ ខ្ញុំត្រូវបានខ្មែរក្រហមឲ្យរៀនរាំ ។ នៅពេលដែលកងទ័ពវៀតណាមសួរខ្ញុំថា ធ្វើអ្វីនៅជំនាន់ ប៉ុល ពត? ខ្ញុំបានឆ្លើយតាមត្រង់ថា ខ្ញុំជាកងទ័ពរបស់ ប៉ុល ពត ។ «តើអ្នកការពារនៅព្រំដែនណា?» ខ្ញុំឆ្លើយថា ខ្ញុំឈរជើងនៅព្រំដែនថៃ ។ «តើអ្នកធ្លាប់ប្រយុទ្ធនៅតាមព្រំដែនវៀតណាមដែរឬទេ?» ខ្ញុំបានឆ្លើយថា «ខ្ញុំមិនដែលដឹងអំពីព្រំដែននោះទេ ។ ខ្ញុំមិនទាំងដឹងថាវៀតណាមមានរូបរាងយ៉ាងម៉េចផង ។» បន្ទាប់ពីសួរសំណួរទាំងអស់នេះរួច កងទ័ពវៀតណាមបាននិយាយថា ពួកគេ«នឹងសម្លាប់យើងទាំងអស់គ្នានៅពេលក្រោយ ។» បន្ទាប់ពីសួរចម្លើយរួចកងទ័ពវៀតណាម*

*បានអនុញ្ញាតឲ្យយើងត្រឡប់ទៅភូមិវិញ ។ ខ្ញុំបានធ្វើដំណើរទៅភូមិតាដេវ ដែលនៅទីនោះ ខ្ញុំបានជួបឪពុកម្ដាយរបស់ខ្ញុំ និងអ្នកភូមិផ្សេងទៀត ទើបតែត្រឡប់មកពីស្រុក ក្រឡាញ់វិញ ។*[១០១]

ប្រជាជនដែលត្រូវបានចាត់ទុកថាជា“កងទ័ពរបស់ ប៉ុល ពត” និងដែលបានប្រយុទ្ធប្រឆាំងជាមួយវៀតណាម មិនមានវាសនាល្អនោះទេ ។ ធីន ប៊ិន បានរៀបរាប់អំពីព្រឹត្តិការណ៍ដែលគាត់បាន ឃើញនៅអន្លង់វែងថា ៖

*កងទ័ពវៀតណាមបានចាប់មនុស្ស៦នាក់ និងបានបណ្ដើរអ្នកទាំងអស់នោះ ទៅកាន់កន្លែងមួយនៅក្បែរអូរជីក ។ កងទ័ពវៀតណាមបានបញ្ជាឲ្យប្រជាជនទាំង៦នាក់នោះឈរតម្រង់ជួរបែរមុខទៅរកខ្លួន ។ បន្ទាប់មក កងទ័ពវៀតណាមបានបាញ់អ្នកទាំង៦នាក់នោះ ដែលបានដួលទៅលើដីទាំងអស់គ្នា ។ កងទ័ពវៀតណាមបានពិនិត្យមើលសាកសពប្រជាជនទាំង៦នាក់ ហើយជឿជាក់ថា ពួកគេបានស្លាប់អស់ហើយ ។ ក្រោយមកកងទ័ពវៀតណាមបានដើរទៅក្នុងព្រៃ ដើម្បីរកខសមកដុតសាកសព ។ រំពេចនោះ អ្នកដែលមិនទាន់ស្លាប់ បានប្រវេប្រវាក្រោកឡើង ហើយរត់យកអាយុជីវិត ។ ប្អូនប្រុសរបស់ខ្ញុំ គឺជាជនរងគ្រោះម្នាក់ក្នុងចំណោមប្រជាជនដែលត្រូវបាញ់សម្លាប់ ។ យើងមានបំណងធ្វើដំណើរទៅស្រុកសំរោងនៅក្នុងថ្ងៃកើតហេតុនោះ ។ ប៉ុន្តែនៅពេលដែលខ្ញុំបានឃើញព្រឹត្តិការណ៍នោះ និងការសម្លាប់ប្អូនប្រុសរបស់ខ្ញុំ ខ្ញុំបានសម្រេចចិត្តត្រឡប់មកភូមិកំណើតរបស់ខ្ញុំវិញ ។ មិនយូរប៉ុន្មាន កងទ័ពខ្មែរក្រហមបានចុះពីលើភ្នំ និងបានជម្លៀសយើងឲ្យទៅរស់នៅជំរំរបស់ពួកគេនៅលើភ្នំ ។ នៅទីនោះ ខ្មែរក្រហមបានដាក់ផែនការឲ្យយើងផលិតចម្រូង ។*[១០២]

នៅចុងឆ្នាំ១៩៧៩ កងទ័ពខ្មែរក្រហមបានបន្តជម្លៀសប្រជាជនដែលសេសសល់ នៅតំបន់អន្លង់វែងឡើងភ្នំដងរែក ។ នៅពេលនោះ មិនទាន់មានផ្លូវសម្រាប់ធ្វើដំណើរពី

អន្លង់វែងទៅលើភ្នំដងរែកទេ ។ ដូច្នេះ ប្រជាជនត្រូវតែដើរកាត់ព្រៃក្រាស់ៗហើយ នៅពេលខ្លះត្រូវតោងវល្លិ៍ឈើ ដើម្បីឡើងលើចំណោតថ្មភ្នំខ្ពស់ៗ ។[១០៣] អ្នកដែលបានឡើងទៅដល់លើភ្នំមុន ត្រូវជួយយោងអ្នកដែលនៅខាងក្រោមដោយប្រើខ្សែវល្លិ៍ព្រៃ ។ ដោយសារតែការធ្វើដំណើរមានការលំបាកខ្លាំង ប្រជាជនបានបោះសម្ភាយរបស់ខ្លួនចោលតាមផ្លូវ ដោយទុកតែរបស់របរណាដែលចាំបាច់ដូចជា ឆ្នាំង អង្ករ និងស្បៀងអាហារ ។

ក្រៅពីនេះប្រជាជនមួយចំនួនផ្សេងទៀតបានសម្រេចចិត្តមិនទៅតាមក្រុមណាទាំងអស់ មិនថាក្រុមខ្មែរក្រហម ឬកងទ័ពវៀតណាម ។ ប្រជាជនទាំងនេះ បានរត់ទៅលាក់ខ្លួននៅក្នុងព្រៃនៅជុំវិញតំបន់អន្លង់វែង ដោយរស់នៅផ្តុំគ្នាជាក្រុមតូចៗ ដើម្បីសុវត្ថិភាព និងបានជាគ្នា ។[១០៤] ជារឿយៗប្រជាជនទាំងនេះ ត្រូវបង្ខំចិត្តរត់ពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីគេចពីការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម ។[១០៥] ប្រជាជនទាំងនេះរស់នៅដោយបរិភោគផ្លែឈើព្រៃ និងបរបាញ់សត្វព្រៃ ។ យ៉ាងហោចណាស់ នៅក្នុងដើមទសវត្សរ៍ឆ្នាំ១៩៨០ ប្រជាជនដែលបន្តរស់នៅតំបន់អន្លង់វែងភាគច្រើនបានក្លាយទៅជាជនដែលពុំមានទីលំនៅច្បាស់លាស់ ។ ស៊ីន ហ្វួង បានរៀបរាប់អំពីជីវិតរសាត់អណ្តែតនៅអន្លង់វែង បន្ទាប់ពីត្រឡប់មកពីស្រុកក្រឡាញ់វិញថា ៖

> ជាទូទៅ យើងស្នាក់នៅកន្លែងមួយបានតែមួយ ឬពីរយប់តែប៉ុណ្ណោះ មុននឹងផ្លាស់ទៅកាន់កន្លែងថ្មី ។ យើងត្រូវរត់ និងដេកនៅកន្លែងផ្សេងៗគ្នាជាច្រើននៅក្នុងព្រៃ នៅពេលដែលកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាមប្រយុទ្ធគ្នាម្តងៗ ។ យើងបានរកឃើញដំឡូងព្រៃដែលចាស់ជ្រុល ហើយរឹងដូចឈើពិបាកហូប ។ ប៉ុន្តែវា គឺជាម្ហូបតែមួយគត់ដែលយើងអាចរកមកហូបបាន ។ ជួនកាលយើងហូបដំឡូងព្រៃជាមួយត្រី ឬសាច់សត្វព្រៃដូចជាជីងចក់ ឬអណ្តើក ដើម្បីចម្អែតក្រពះរបស់យើង ។[១០៦]

## ការកាន់កាប់របស់វៀតណាមនៅតំបន់អន្លង់វែង

របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាមបានបង្កើតបន្ទាយកងទ័ពជាច្រើននៅអន្លង់វែង ដើម្បីធ្វើជាមូលដ្ឋានយុទ្ធសាស្ត្រយោធា ។ ទីបញ្ចាការ

ធំរបស់កងទ័ពវៀតណាមមានឈ្មោះថា កុងប៊ិញ ។ វៀតណាមក៏បានបង្កើតអង្គភាពកងទ័ពពិសេសមួយ ដែលស្ថិតនៅក្បែរច្រកព្រំដែនជាំសាង៉ាំនាពេលបច្ចុប្បន្ន ដើម្បីទប់ស្កាត់ការវាយលុកពីសំណាក់ខ្មែរក្រហមចូលមកអន្លង់វែង ។ ជាទូទៅអន្លង់វែង នៅចន្លោះពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩ត្រូវបានប្រជាជនស៊ីវិលបោះបង់ចោល ហើយក្លាយទៅជាតំបន់គ្រប់គ្រងដោយយោធា ដោយសារតែផលលំបាកសម្រាប់ប្រជាជនស៊ីវិលក្នុងការតាំងទីលំនៅ ។ លក្ខណៈភូមិសាស្ត្ររបស់តំបន់អន្លង់វែង បានផ្តល់ទីតាំងឈរជើងដ៏រឹងមាំមួយ ដល់កងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាម ។ ខ្មែរក្រហមបានចំណាយពេលពេញមួយទសវត្សរ៍ដើម្បីដណ្តើមកាន់កាប់តំបន់នេះ ដោយមិនទទួលបានជោគជ័យ ។

ដើម្បីការពារពីការវាយលុក និងការជ្រៀតចូលរបស់ខ្មែរក្រហមកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាម បានដឹកត្រង់សេជាច្រើនកន្លែង នៅតំបន់អន្លង់វែង ។ នៅក្រោមផែនការ ក-៥[107] វិធានការជាច្រើនត្រូវបានផ្តួចផ្តើម ដើម្បីពង្រឹងការការពារតំបន់នេះ និងកាត់បន្ថយការជ្រៀតចូលរបស់ខ្មែរក្រហម ។ វិធានការទាំងនោះរួមមាន ការកាប់ឆ្ការព្រៃ ការដាក់ពង្រាយគ្រាប់មីន ការដាំចម្រូង និងការសាងសង់របងធ្វើអំពីឫស្សីជាមួយនឹងបន្លាលួស ។

នៅចន្លោះពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩ កងទ័ពខ្មែរក្រហម និងប្រជាជនដែលនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម រស់នៅតាមមូលដ្ឋានកងទ័ពតាមបណ្តោយព្រំដែនខ្មែរ-ថៃ ឬនៅតាមជំរំជនភៀសខ្លួន ជាច្រើននៅក្នុងទឹកដីថៃ ។ ភ្នំ១០០១ និងភ្នំ១០០៣ គឺជាមូលដ្ឋានកងទ័ពដ៏ចម្បងពីររបស់ខ្មែរក្រហម ដែលមានទំនាក់ទំនងជាមួយនឹងតំបន់អន្លង់វែង ។ មូលដ្ឋានទាំងពីរនេះស្ថិតនៅលើជួរភ្នំដងរែក ភាគខាងជើង និងភាគពាយ័ព្យនៃព្រំដែនខ្មែរ-ថៃ ។ មូលដ្ឋានទាំងពីរនេះ គឺជាទីតាំងអំណោយផលសម្រាប់ខ្មែរក្រហមក្នុងការអនុវត្តយុទ្ធសាស្ត្រការពារខ្លួនផង និងក្នុងការកសាងកម្លាំងទ័ពឡើងវិញផង ។ មូលដ្ឋានទាំងពីរនេះ ស្ថិតនៅប្រហែលជាពីរទៅបីគីឡូម៉ែត្រពីព្រំដែនថៃ និងហ៊ុមព័ទ្ធដោយព្រៃឈើយ៉ាងក្រាស់ៗ និងភ្នំដែលមិនអាចចូលទៅដល់ ។

ជំពូក ៦

# ការរៀបចំកងទ័ពឡើងវិញរបស់ខ្មែរក្រហម

## *ភ្នំ១០០១ ៖ ដំណាក់កាលដំបូងនៃការរៀបចំរចនាសម្ព័ន្ធរបស់ខ្មែរក្រហមឡើងវិញ*

ភ្នំ១០០១គឺជាឈ្មោះ ដែលខ្មែរក្រហមហៅសំដៅទៅលើមូលដ្ឋានកងទ័ពមួយ ដែលស្ថិតនៅត្រង់ចំណុចប្រសព្វគ្នានៃព្រំដែនរបស់ប្រទេសទាំងបី ដែលរួមមានខេត្តព្រះវិហារនៃប្រទេសកម្ពុជា ខេត្តខុប៊ុនរាជធានីនៃប្រទេសថៃ និងខេត្តចំប៉ាសាក់ នៃប្រទេសឡាវ ។ ចំណុចប្រសព្វនេះត្រូវបានស្គាល់ថា មុំបី ឬទន្សោរពៅ ។[១០៨] ភ្នំ១០០១ បានក្លាយទៅជាតំបន់សុវត្ថិភាពដំបូងបង្អស់មួយរបស់ខ្មែរក្រហមដែលនៅទីនោះ មេដឹកនាំខ្មែរក្រហមបានជួបជុំជាមួយកងទ័ពរបស់ខ្លួន និងប្រជាជនភៀសខ្លួនរាប់ម៉ឺននាក់ ។ ភ្នំ១០០១ត្រូវបានបង្កើតឡើងភ្លាមៗ បន្ទាប់ពីការដួលរលំរបស់ខ្មែរក្រហមហើយបានក្លាយទៅជាមូលដ្ឋានយោធា និងស៊ីវិល សម្រាប់ការរៀបចំរចនាសម្ព័ន្ធយោធា និងរដ្ឋបាលឡើងវិញដើម្បីធ្វើការតស៊ូដណ្តើមអំណាចមកវិញ ។

ភ្នំ១០០១ត្រូវបានជ្រើសរើស ដោយសារតែភ្នំនេះស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា ឆ្ងាយពីព្រំដែនវៀតណាមប៉ុន្តែនៅជិតព្រំដែនថៃ ។ ប្រទេសថៃ គឺជាច្រកចេញចូលតែមួយគត់ ដែលខ្មែរក្រហមអាចទទួលបានស្បៀងអាហារសម្ភារៈចាំបាច់ផ្សេងៗទៀត និងគ្រឿងសព្វាវុធ ។ ជាងនេះទៅទៀត ប្រទេសថៃគឺជាទីតាំងជាយុទ្ធសាស្ត្រសម្រាប់ខ្មែរក្រហមធ្វើទំនាក់ទំនង និងតភ្ជាប់ទៅពិភពខាងក្រៅ ។ ជាលក្ខណៈភូមិសាស្ត្រភ្នំ១០០១ស្ថិតនៅលើទីតាំងអំណោយផល ដែលខ្មែរក្រហមអាចធ្វើការប្រមូលផ្តុំកងទ័ពរបស់ខ្លួនបានយ៉ាងឆាប់រហ័ស ។ ទីតាំងនេះត្រូវបានការពារពីធម្មជាតិដោយព្រៃឈើក្រាស់ៗ និងជួរភ្នំជាច្រើន ដែលកងទ័ពវៀតណាម និងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចំណាយពេលអស់៦ឆ្នាំ ទម្រាំអាចវាយដណ្តើមយកបាននៅចុងឆ្នាំ១៩៨៤ ។

ទោះបីជាខ្មែរក្រហមទទួលជំនួយពីប្រភពជំនួយបរទេសជាច្រើនក៏ដោយ ក៏ប្រទេសចិនគឺជាអ្នកគាំទ្រចម្បងរបស់ខ្មែរក្រហម ។ ប្រសិនបើគ្មានជំនួយពីប្រទេស ចិនលើផ្នែកកងទ័ព ហិរញ្ញវត្ថុ សម្ភារៈ និងនយោបាយទេ ខ្មែរក្រហមប្រហែលជាមានការលំបាក នៅក្នុង

ការធ្វើសង្គ្រាមប្រឆាំងទៅនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលគាំទ្រដោយវៀតណាម នៅក្នុងពេញមួយទសវត្សន៍ឆ្នាំ១៩៨០ ។ ប្រទេសថៃក៏ជាប្រទេសផ្តល់ជំនួយសំខាន់មួយទៀតរបស់ខ្មែរក្រហម ។ ប្រទេសថៃបានផ្តល់ជម្រកដល់កងទ័ពខ្មែរក្រហម និងបានជួយសម្រួលដល់ការដឹកជញ្ជូនសម្ភារៈជាច្រើន ដែលរួមមានទាំងគ្រឿងសព្វាវុធ ដែលត្រូវបានដឹកមកពីប្រទេសចិន ។[១០៩]

សុន សេន ដែលជាឧបនាយករដ្ឋមន្ត្រីទីបី និងរដ្ឋមន្ត្រីការពារជាតិនៃកម្ពុជាប្រជាធិបតេយ្យ គឺជាមេដឹកនាំខ្មែរក្រហមនៅលើភ្នំ១០០១ ។ មេដឹកនាំជាន់ខ្ពស់ ខ្មែរក្រហមដទៃទៀត ដូចជា ប៉ុល ពត, អៀង សារី, នួន ជា និង ខៀវ សំផន រស់នៅក្នុងទីបញ្ជាការរបស់ខ្លួននៅក្នុងទឹកដីថៃ ឬបោះទីតាំងនៅតាមតំបន់ព្រំដែន ដែលស្ថិតនៅក្នុងខេត្តកោះកុង ពោធិ៍សាត់ និងបាត់ដំបង ។ មេដឹកនាំខ្មែរក្រហមទាំងនេះ បានដឹកនាំអនុវត្តការងារជាច្រើន ដូចជា សេដ្ឋកិច្ច កិច្ចការបរទេស ការបណ្តុះបណ្តាល ផ្នែកនយោបាយ គោលនយោបាយ និងការឃោសនា ។ នៅឯក្នុងប្រទេស សុន សេន ទទួលជំនួយពីមេបញ្ជាការទ័ពជាន់ខ្ពស់ជាច្រើន ដែលរួមមាន តា ម៉ុក, កែ ពក, មាស មុត, ស៊ូ ម៉េត, សូ ហុង, នី កន, សូ សារឿន, និង មៀច សាន ។ មេបញ្ជាការទ័ពទាំងនេះ ក្រោយមកបានក្លាយទៅជាមេដឹកនាំសមរភូមិទិសសំខាន់ៗ របស់ខ្មែរក្រហមក្នុងការដឹកនាំការតស៊ូប្រយុទ្ធប្រឆាំងទៅនឹងកងទ័ពវៀតណាម និងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។[១១០] ជាទូទៅ មេដឹកនាំខ្មែរក្រហមថ្នាក់កណ្តាលផ្តោតការយក ចិត្តទុកដាក់ទៅលើការពង្រឹង និងការដឹកនាំសកម្មភាពនានា នៅខាងក្នុងប្រទេស ដូចជា ការរៀបចំបង្កើតជាភូមិ និងការបង្កើតសាលារៀន និងប្រព័ន្ធសុខាភិបាល ។[១១១] ផ្ទុយទៅវិញ ប្រតិបត្តិការយោធារបស់វៀតណាមផ្តោតទៅលើការប្រមូលផ្តុំគ្រប់គ្រងទៅលើទឹកដីកម្ពុជាទាំងមូល ។ នៅក្នុងរយៈពេលប៉ុន្មានខែនៃភាពស្ងប់ស្ងាត់ ក្រោយការដួលរលំ មេដឹកនាំខ្មែរក្រហមបានចាប់ផ្តើមរៀបចំកម្លាំងកងទ័ព ដែលនៅសេសសល់របស់ខ្លួន និងរៀបចំគ្រប់គ្រងទឹកដីកម្ពុជាដែលនៅសេសសល់ឡើងវិញ ។

ជាផ្នែកមួយនៃផែនការដណ្តើមកាន់កាប់ទឹកដីបន្ថែមទៀត និងដើម្បីកេណ្ឌប្រជាជនឲ្យចូលមកខាងខ្លួន កាន់តែច្រើនថែមទៀត មេដឹកនាំខ្មែរក្រហមនៅភ្នំ១០០១បានរៀបចំបញ្ជូនកងទ័ពរបស់ខ្លួនជាច្រើនចូល មកខាងក្នុងនៃប្រទេសកម្ពុជា ។ កងពលរបស់ខ្មែរក្រហមទាំងនេះ បានបែកគ្នាបោះទីតាំង និងធ្វើការនៅក្នុង ខេត្តមួយចំនួនដូចជា រតនគិរី

មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ ព្រះវិហារ កំពង់ធំ កំពង់ចាម កំពង់ឆ្នាំង ព្រៃវែង ស្វាយរៀង និងតំបន់មួយចំនួនក្នុងខេត្តកណ្តាល ។

ជាទូទៅ ខ្មែរក្រហមបានអនុវត្តនូវអ្វីដែលត្រូវបានហៅថា "សង្គ្រាមឈ្លប" ឬ "សង្គ្រាមប្រជាជន" ។ សមាជិកគ្រួសារកងទ័ព និងប្រជាជនស៊ីវិលដែលនៅមូលដ្ឋានខាងក្រោយ ត្រូវដឹកជញ្ជូនសម្ភារៈផ្គត់ផ្គង់ គ្រឿងសព្វាវុធ និងគ្រាប់កាំភ្លើងទៅឲ្យកងទ័ពនៅសមរភូមិមុខ ។ ការងារដ៏គ្រោះថ្នាក់នេះតម្រូវឲ្យមានកម្លាំងទ័ព ការពារច្រើន រហូតទៅដល់ប្រមាណ២០០នាក់ ។ ក្រុមដឹកជញ្ជូនសម្ភារៈទាំងនេះ ត្រូវធ្វើដំណើរដោយថ្មើរជើងឆ្លងកាត់ព្រៃ ដែលមានចម្ងាយពី៥ទៅ១០គីឡូម៉ែត្រក្នុងមួយថ្ងៃ ។ កងដឹកជញ្ជូនម្នាក់ៗត្រូវស្ពាយគ្រឿងសព្វាវុធ និងសម្ភារៈធ្ងន់ៗ ដែលធ្វើឲ្យការធ្វើដំណើរមានល្បឿនយឺត និងប្រកបដោយភាពហត់នឿយ ។ ការដឹកជញ្ជូនមួយលើកៗត្រូវចំណាយពេលប្រហែលមួយខែ ។ ប្រជាជនធ្វើដំណើរនៅពេលថ្ងៃ និងសម្រាកនៅលើកម្រាលកៅស៊ូ ឬអង្រឹងនៅពេលយប់ ។

ធៀប ថេន អតីតកងទ័ពនៅក្នុងកងពល៩២០ បានរៀបរាប់អំពីបទពិសោធរបស់គាត់នៅក្នុងការដឹកជញ្ជូនអាវុធពីភ្នំ១០០១ ទៅឲ្យកងទ័ពខ្មែរក្រហមដែលមានទីតាំងនៅខេត្តក្រចេះថា ៖

> ខ្ញុំបានដឹកនាំកងទ័ពមួយក្រុម ដែលមានសមាជិក៧០នាក់ ដើម្បីដឹកជញ្ជូនអាវុធទៅកាន់សមរភូមិនៅខេត្តក្រចេះ ។ យើងបានដើរចុះពីលើភ្នំដងរែកទៅកាន់ឃុំស្រអែម ហើយធ្វើដំណើរបន្តទៅខេត្តកំពង់ធំ ។ នៅពេលរសៀលថ្ងៃមួយ យើងបានឈប់សម្រាកនៅតាមផ្លូវ ដើម្បីដាំបាយហូបថ្ងៃត្រង់ ។ បន្ទាប់ពីបាយថ្ងៃត្រង់រួច ពេលយើងបន្តដំណើរបានប្រហែលមួយគីឡូម៉ែត្រ កងទ័ពខ្មែរវៀតណាមបានកន្ទ្រាក់គ្រាប់បែកចង្កោម ។ កងទ័ពម្នាក់នៅខាងមុខបានដួល ។ ពេលខ្ញុំក្រឡេកមកក្រោយកងទ័ព២នាក់ទៀតបានដួលទៅលើដី ។ ខ្ញុំបានបោះគ្រាប់បែកដៃបួន-ប្រាំគ្រាប់ ដែលប្រហែលជាបានសម្លាប់កងទ័ពវៀតណាមមួយចំនួន ។ យើងប្រមូលបានមួករបស់កងទ័ពវៀតណាមចំនួន១០ បន្ទាប់ពីការប៉ះទង្គិចនោះរួចមក ។ ខ្ញុំក៏ទទួលរង

របួស និងត្រូវបានសែងត្រឡប់មកក្រោមវិញដើម្បីព្យាបាល ។[១១២]

នៅចុងឆ្នាំ១៩៨៤ កងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាម បានបើកការវាយប្រហារ និងដណ្តើមកាន់កាប់បានភ្នំ១០០១ ។ ប្រជាជនស៊ីវិលទាំងអស់ត្រូវបានជម្លៀសទៅក្នុងទឹកដីថៃ និងរស់នៅក្បែរមន្ទីររបស់ សុន សេន ។ ក្រោយមក ប្រជាជន និងកងទ័ពខ្មែរក្រហមគ្រប់កងពលទាំងអស់ត្រូវបានបញ្ជូនឲ្យទៅរស់នៅតំបន់មួយទៀត ដែលមានឈ្មោះថាភ្នំ១០០៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ។ ចាប់តាំងពីពេលនោះមក សុន សេន ចាប់ផ្តើមបាត់បង់ឥទ្ធិពលយោធា ទោះបីជា សុន សេន នៅតែបន្តដឹកនាំកងទ័ព និងប្រជាជនមកពីភ្នំ១០០១យ៉ាងណាក៏ដោយ ។ មួយរយៈពេលកន្លងមកទៀត មេដឹកនាំខ្មែរក្រហមវ័យក្មេងថ្មីៗ ចាប់ផ្តើមទទួលបានអំណាចកាន់តែច្រើននៅក្នុងរង្វង់មេដឹកនាំខ្មែរក្រហម ដែលបានបង្កឲ្យមានភាពតានតឹង និងការប្រកួតប្រជែងផ្ទៃក្នុង ។

## ភ្នំ១០០៣ ៖ មូលដ្ឋានយោធាជាយុទ្ធសាស្ត្ររបស់ តាម៉ុក

ខ្មែរក្រហមបានប្រឹងប្រែងដណ្តើមយកមកវិញ នូវតំបន់តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដែលមានប្រវែងប្រមាណ៨៣០គីឡូម៉ែត្រ និងលាតសន្ធឹងពីខេត្តព្រះវិហារនៅភាគខាងជើងទៅខេត្តឧត្តរមានជ័យ, បន្ទាយមានជ័យ, បាត់ដំបង, ប៉ៃលិន, ពោធិ៍សាត់ និងខេត្តកោះកុង នៅភាគខាងលិច ។[១១៣] តាម៉ុក គឺជាមេបញ្ជាការកងទ័ពដ៏សកម្មមួយរូបនៅក្នុងប្រតិបត្តិការនេះ ដោយសារ តាម៉ុក គ្រប់គ្រងព្រំដែនភាគខាងជើងនៃខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ ។

មិនមានរបាយការណ៍ច្បាស់លាស់ណាមួយ ដែលបង្ហាញថា តើមូលដ្ឋានទីមួយៗ ត្រូវបានបង្កើតឡើងនៅពេលណាឲ្យពិតប្រាកដនោះទេ ។ ប៉ុន្តែ ជាទូទៅ ភ្នំ១០០៣ ត្រូវបានជឿជាក់ថា ត្រូវបានបង្កើតឡើងក្រោយការបង្កើតមូលដ្ឋាន នៅភ្នំ១០០១បន្តិច ។ បន្ទាប់ពី តាម៉ុក បានជួយ សុន សេន បង្កើតមូលដ្ឋាននៅលើភ្នំ១០០១រួចមក តាម៉ុក បានកាន់កាប់ទីតាំងសំខាន់មួយទៀតនៅភ្នំ១០០៣ នៅចុងឆ្នាំ១៩៧៩ ។

ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៤ ភ្នំ១០០៣បានក្លាយទៅជាតំបន់កាន់កាប់ដ៏សំខាន់

មួយរបស់ចលនាខ្មែរក្រហម ។ ដោយសារតែការប្រមូលផ្តុំកងកម្លាំងរបស់ខ្មែរក្រហមនៅក្នុងតំបន់នេះ ភ្នំ១០០៣អាចត្រូវបានចាត់ទុកថា ជាមូលដ្ឋានគោលរបស់ចលនាខ្មែរក្រហមទាំងមូល ។ ប្រសិនបើធ្វើការប្រៀបធៀបមូលដ្ឋាននៅម៉ាឡៃ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អៀង សារី ផ្តោតជាចម្បងទៅលើកិច្ចការសេដ្ឋកិច្ចហើយមន្ទីរក-១៨ ដែលស្ថិតនៅក្នុងខេត្តត្រាត នៃប្រទេសថៃ និងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត និងបញ្ញវន្តមួយចំនួនទៀត ហាក់ផ្តោតជាចម្បងទៅលើការងារនយោបាយ និងដំណើរការជាទូទៅរបស់ចលនាខ្មែរក្រហម ។[១១៤]

បើពិនិត្យមើលអំពីទីតាំងភូមិសាស្ត្រ ភ្នំ១០០៣ លាតសន្ធឹងពីប្រាសាទព្រះវិហារទៅស្រុកអន្លង់វែង ក្នុងខេត្តឧត្តរមានជ័យ ។ ស្រុកត្រពាំងប្រាសាទមានទីតាំងនៅក្បែរច្រកព្រំដែន ជប់រុន ដែលខ្មែរក្រហមប្រើប្រាស់សម្រាប់ដឹកជញ្ជូនគ្រឿងសព្វាវុធ និងស្បៀងពីប្រទេសថៃ ឬពីមូលដ្ឋានរបស់ខ្លួននៅលើភ្នំដងរែក ទៅឲ្យកងទ័ពនៅខាងក្នុងប្រទេសកម្ពុជា ។[១១៥]

ប្រជាជនដែលរស់នៅលើភ្នំ១០០៣ ត្រូវបានជ្រើសរើសចេញពីតំបន់ខ្មែរក្រហមជាច្រើនដែល រួមមានតំបន់សំឡូត ម៉ាឡៃ ភ្នំ១០០១ និងពីជំរំជនភៀសខ្លួន មួយចំនួនផ្សេងទៀត ។ ប្រជាជនមករស់នៅភ្នំ១០០៣ គឺខ្លះមកដោយចៃដន្យ ខ្លះមកដោយការបង្ខិតបង្ខំ ឬខ្លះទៀតមក ដោយសារតែការឃោសនារបស់ខ្មែរក្រហម ។ ស្ត្រីមួយចំនួនមិនមានជម្រើស និងត្រូវធ្វើដំណើរទៅតាមប្តី ដែលបម្រើការជាកងទ័ពខ្មែរក្រហមនៅលើភ្នំ១០០៣ ។ ប្រជាជនភាគច្រើនគឺជាអតីតកម្មាភិបាលខ្មែរក្រហម និងប្រជាជនដែលមកពីភូមិភាគនិរតីនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាអតីតតំបន់គ្រប់គ្រងរបស់ តាម៉ុក ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។[១១៦] ប្រជាជនដែលធ្វើដំណើរទៅកាន់ភ្នំ១០០៣ ត្រូវធ្វើដំណើរតាមទឹកដីថៃ ដើម្បីជៀសវាងការប្រឈមមុខ ដោយប្រការណាមួយជាមួយកងទ័ពវៀតណាម និងកងទ័ពរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រចាំការនៅតាមបណ្តោយព្រំដែនខាងទឹកដីកម្ពុជា ។ ចំនួនប្រជាជននៅភ្នំ១០០៣ បានកើនឡើងជាលំដាប់ ដែលការកើនឡើងនេះ ត្រូវបានប្រជាជនអះអាងថា ដោយសារតែលក្ខខណ្ឌអំណោយផលរបស់តំបន់នេះ និងដោយសារតែការគ្រប់គ្រងល្អរបស់ តាម៉ុក ដែលបានផ្តល់ការផ្គត់ផ្គង់គ្រប់បែបយ៉ាង ដែលចាំបាច់សម្រាប់ការរស់នៅប្រចាំថ្ងៃ ។

ដោយមានការគាំទ្រពេញទំហឹងពីកងទ័ព និងប្រជាជន តាម៉ុក បានក្លាយទៅជាមេបញ្ជាការកងទ័ពដ៏មានអំណាចនៅលើភ្នំ១០០៣ ដែលមិនមានអ្នកណាអាចប្រជែងបាន ។

នៅក្នុងគោលនយោបាយការបរទេស ប្រទេសចិន និងប្រទេសថៃ គឺជាអ្នកគាំទ្រដ៏សំខាន់សម្រាប់ការបន្តការតស៊ូរបស់ខ្មែរក្រហម ។ ដោយសារឥទ្ធិពល និងសង្គ្រាមត្រជាក់បានបង្ខំសហរដ្ឋអាមេរិកឲ្យគាំទ្រ ចលនាត្រីភាគី ដែលកម្ពុជាប្រជាធិបតេយ្យជាផ្នែក មួយនៃចលនានេះ ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងកងទ័ពវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគាំទ្រដោយមានចិនជាប្រភពធនធានដ៏សំខាន់សម្រាប់ផ្គត់ផ្គង់សម្ភារៈ និងដោយមានថៃជាប្រភពធនធានដ៏សំខាន់សម្រាប់ការផ្តល់ទីតាំងកងកម្លាំងខ្មែរក្រហមមានលទ្ធភាព រៀបចំចលនាតស៊ូរបស់ខ្លួនឡើងវិញ ដែលអាចប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាម ។

## ការបង្កើតភូមិ និងជំរំជនភៀសខ្លួន

ដើម្បីសម្រួលដល់ការគ្រប់គ្រងរដ្ឋបាល តំបន់នៅលើភ្នំ១០០៣ត្រូវបានរៀបចំឲ្យទៅជាភូមិហើយ បែបផែននៃការរស់នៅរបស់ប្រជាជន ស្រដៀងគ្នាទៅនឹងការរស់នៅបែបសហករណ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះជាយ៉ាងនេះក្តី អ្វីដែលខុសប្លែកគ្នាចម្បងមួយ រវាងជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជីវិតក្រោយរបបនេះគឺប្រជាជនទទួលបានអាហារ និងសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ ។[១១៧] នៅពេលដែលរបបខ្មែរក្រហមត្រូវបានកំណត់ដោយគ្រោះអត់ឃ្លាន រដ្ឋបាលរបស់ចលនាខ្មែរក្រហមក្រោយឆ្នាំ១៩៧៩ បានប្រើប្រាស់ការផ្តល់ម្ហូបអាហារ និងសម្ភារៈ ដែលបានមកពីម្ចាស់ជំនួយបរទេសជាមធ្យោបាយដើម្បីទទួលបានភាពស្មោះត្រង់ពីប្រជាជន ។

ប្រជាជនទាំងអស់ត្រូវបានចាត់តាំងឲ្យរស់នៅតាមអង្គភាពកងទ័ពរបស់ខ្លួន ។ ប្រជាជនត្រូវបាន រំពឹងថានឹងចែករំលែកការងារ ការហូបចុក និងការកំសាន្តជាមួយគ្នា ។ ភូមិនីមួយៗដែលមានចម្ងាយពីគ្នា ប្រហែលកន្លះគីឡូម៉ែត្រទៅមួយគីឡូម៉ែត្រ ត្រូវបានដាក់ឈ្មោះទៅតាមលេខកងពល ឬទៅតាមឈ្មោះមេភូមិនៅក្នុងករណីមួយចំនួន ។[១១៨] ភូមិនីមួយៗមានប្រជាជនពី៣០ទៅ៤០គ្រួសារ ហើយជាទូទៅ ប្រជាជនរស់នៅក្នុងខ្ទមធ្វើអំពីឈើ ឬស្សី និងស្បូវ ។[១១៩] ដោយសារតែការគំរាមកំហែងពីការវាយប្រហារ ដែល

អាចកើតមានការសាងសង់ផ្ទះជាមួយនឹងសម្ភារៈបែបនេះមានភាពងាយស្រួលក្នុងការផ្លាស់ប្តូរទីលំនៅ និងការរត់គេចខ្លួន បានភ្លាមៗជាមួយនឹងការផ្តល់សញ្ញាបន្តិចបន្តួច ។

ការគ្រប់គ្រងរដ្ឋបាលនៅអន្លង់វែង មិនដូចការគ្រប់គ្រងរដ្ឋបាលនាពេលបច្ចុប្បន្នទេ ។ ជាទូទៅ តាម៉ុក ធ្វើជាអធិបតីទាំងលើការងាររដ្ឋបាល និងកិច្ចការកងទ័ព ។[១២០]

កងទ័ពខ្មែរក្រហម និងសមាជិកគ្រួសារ រស់នៅ និងផ្លាស់ទីកន្លែងពីជំរំមួយទៅជំរំមួយទៀត នៅក្នុងទឹកដីថៃ ដូចជា ជំរំអូរត្រាវ ស៊ីងចាន់ ជប់ម្ចូ ដងទង់ ខែជន និង ណាងស៊ុង ។ ទោះបីជាប្រជាជននៅអន្លង់វែងអះអាងថា ជំរំជនភៀសខ្លួនទាំងអស់នេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅភ្នំ១០០៣ក្តី ក៏យើងមានការលំបាកក្នុងការកំណត់អត្តសញ្ញាណពិតប្រាកដរបស់ជំរំនីមួយៗ ហើយអត្តសញ្ញាណនេះអាចមានការប្រែប្រួលដោយសារតែលំហូររបស់ប្រជាជនស៊ីវិល និងកងទ័ព នៅក្នុងអំឡុងពេលជម្លោះ ។[១២១]

ជំរំអូរត្រាវ គឺជាមូលដ្ឋានទ្រទ្រង់ដ៏សំខាន់មួយរបស់ខ្មែរក្រហម នៅភ្នំ១០០៣ ។ ជំរំនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ដែលបានបង្កើតទីបញ្ជាការមួយនៅក្នុងជំរំនេះ ។ អង្គការជំនួយព្រំដែនរបស់អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិមួយចំនួនផ្សេងទៀតបានផ្តល់ជំនួយមនុស្សធម៌ ដូចជា ស្បៀងអាហារ ទឹកស្អាត ការថែទាំសុខភាព និងសម្ភារៈចាំបាច់ផ្សេងៗទៀត ព្រមទាំងការអប់រំកម្រិតបឋមសិក្សា ។[១២២] ប៉ុន្តែជំនួយនេះត្រូវបានកម្រិតផ្តល់ឲ្យតែស្ត្រី និងកុមារប៉ុណ្ណោះ ដោយសារតែកងទ័ពត្រូវបានចាត់ទុកថាជាក្រុមចម្បាំង ។ ជនភៀសខ្លួនសរុបនៅជំរំអូរត្រាវមានចំនួន១៥.០០០នាក់ មកត្រឹមឆ្នាំ១៩៩១ ។ ជំរំនេះត្រូវបានបិទជាស្ថាពរនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩២ ។

ប្រជាជនមួយចំនួននៅក្នុងជំរំអូរត្រាវបានលួចឆ្លងដែនចូលប្រទេសថៃ ដើម្បីស្វែងរកការងារ និងប្រាក់ចំណូល ។ ប្រជាជនទាំងនោះនឹងធ្វើការងារគ្រប់បែបយ៉ាង ដូចជាបេះផ្លែឪឡឹក ជីកដំឡូង និងច្រូតស្រូវ ។ ការងារទាំងនោះត្រូវបានសម្របសម្រួលដោយថៅកែជនជាតិថៃ ដែលបានកេងចំណេញពីជនភៀសខ្លួនខ្មែរ ដែលខំស្វែងរកឱកាសដើម្បីទទួលបានជីវិតល្អប្រសើរជាងមុន ។ រថយន្តរបស់ថៃ ជាច្រើនគ្រឿងបានមកចតចាំនៅមុខជំរំជនភៀសខ្លួននៅពេលព្រឹក ហើយដឹកជញ្ជូនជនភៀសខ្លួនមកជំរំវិញនៅពេលល្ងាច ។[១២៣] ក្រៅពីការងារលក់កម្លាំងពលកម្ម ជនភៀសខ្លួនមួយចំនួនបានលក់ស្បៀវទៅឲ្យថៃ ។ ជនភៀសខ្លួនទាំងនោះ ទទួលបានតម្លៃ៥បាត (ប្រហែល៦២០រៀល)

សម្រាប់ស្បូវមួយកណ្ដាប់ ។[១២៤]

នៅចុងឆ្នាំ១៩៨៤ កងទ័ពវៀតណាម និងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជារាប់ម៉ឺននាក់បានវាយប្រហារច្រកចេញចូលធំរបស់ភ្នំ១០០៣ ដែលស្ថិតនៅក្នុងឃុំព្រះប្រឡាយ ។ កងទ័ពវៀតណាម និងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រមាណជាង៣០.០០០នាក់ បានកម្ទេចជំរំជនភៀសខ្លួនខ្មែរក្រហម មូលដ្ឋានផ្គត់ផ្គង់សម្ភារៈ និងប្រព័ន្ធការពាររបស់ខ្មែរក្រហមនៅក្នុងទឹកដីកម្ពុជា ។[១២៥] នៅត្រឹមដំណាក់កាលនេះ កងទ័ពវៀតណាម និងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា គ្រប់គ្រងបានតំបន់កាន់កាប់ទាំងអស់របស់ខ្មែរក្រហម និងថែមទាំងវាយកាន់កាប់ មូលដ្ឋានរបស់រណសិរ្សហ៊្វុនស៊ិនប៉ិច និងរណសិរ្សរំដោះ ប្រជាពលរដ្ឋខ្មែរថែមទៀត ។ ទាំងជនភៀសខ្លួននៅក្នុងតំបន់ទាំងអស់នោះ និងកម្លាំងតស៊ូទាំងអស់ត្រូវរត់ទៅរស់នៅក្នុងជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃ ។

សាធារណរដ្ឋប្រជាមានិតកម្ពុជាបានប្រៀបប្រដូចការវាយប្រហាររបស់ខ្លួន នៅឆ្នាំ១៩៨៤-១៩៨៥ ថាជា“ការចងមុងវាយមូស” ។ ទោះជាយ៉ាងនេះក្តី ខ្មែរក្រហមបានប្រៀបប្រដូចបរាជ័យរបស់ខ្លួនទៅនឹង“ការចាក់ទម្លាយសម្បុកអង្ក្រង” ដែលមានន័យថា កងទ័ពបរាជ័យរបស់ខ្មែរក្រហមប្រៀបបានទៅនឹងអង្ក្រងដែលចេញពីសម្បុកហើយជ្រៀតចូលកាន់តែជ្រៅទៅផ្ទៃខាងក្នុងនៃប្រទេសកម្ពុជា ។[១២៦] ទោះបីជាលទ្ធផលជាក់ស្តែងនៃការវាយប្រហារមានការលំបាកក្នុងការវាស់ស្ទង់ក្តី គេសង្កេតឃើញថា កងទ័ពខ្មែរក្រហមមួយចំនួនបានជ្រៀតចូលកាន់តែជ្រៅជាងមុន ទៅខាងក្នុងប្រទេសដើម្បីធ្វើវិទ្ធង្សនា និងសាបព្រួសការឃោសនារបស់ខ្លួន ។ ម្យ៉ាងវិញទៀត កងទ័ពខ្មែរក្រហមជាច្រើន ត្រូវបានកោះហៅឲ្យវិលត្រឡប់មកមូលដ្ឋានវិញ ដើម្បីពង្រឹងកម្លាំងនៅតាមព្រំដែន ។ ដោយសារតែការខ្វះខាតម្ហូបអាហារនៅក្នុងអំឡុងពេលនោះ កងទ័ពខ្មែរក្រហមដែលនៅខាងក្នុងប្រទេសបានធ្វើការឆក់ប្លន់ប្រជាជននៅតាមភូមិ ដើម្បីរស់រានមានជីវិត ។

មេដឹកនាំខ្មែរក្រហមបានជម្លៀសប្រជាជនពីភ្នំ១០០៣ ទៅជំរំអូរត្រាវ និង ស៊ីងចាន់ ។ ចាប់តាំងពីពេលនោះមក ដោយសារតែការគំរាមកំហែងពីកងទ័ពវៀតណាម ខ្មែរក្រហមបានចាប់ផ្តើមជ្រើសរើស ប្រជាជនសាមញ្ញនៅក្នុងជំរំឲ្យចូលបម្រើកងទ័ព ។ ជីវិតកាន់តែលំបាក ហើយមេដឹកនាំ និងកម្មាភិបាលខ្មែរក្រហម កាន់តែជិះជាន់ និងបង្ខិតបង្ខំប្រជាជន ។

ជំពូក៧

# សង្គ្រាមឈ្លប និងសង្គ្រាមប្រជាជន

## សមរភូមិមុខនៅភ្នំ១០០៣

នៅខែធ្នូ ឆ្នាំ១៩៧៩ កម្លាំងសេសសល់របស់ខ្មែរក្រហម បានប្រកាសបង្កើតកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ ។ ចំនួនកងទ័ពបានកើនឡើងជាលំដាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៥ ប៉ុន្តែ បន្ទាប់មក ទំហំកងទ័ពបានថយចុះទៅវិញ ។ នៅត្រឹមខែសីហា ឆ្នាំ១៩៨០ ចំនួនកងទ័ពខ្មែរក្រហមកើនឡើងពី២ម៉ឺននាក់ ទៅ៤ម៉ឺននាក់ ។ សុន សេន ធ្លាប់បានប្រកាសថាខ្មែរក្រហមមានកងទ័ពចំនួន៦ម៉ឺននាក់ ដែលត្រូវបានចែកចេញជា៥ពាន់កងឈ្លប ដែលបានធ្វើសង្គ្រាមឈ្លបនៅទូទាំងប្រទេស ។[127] បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ១៩៩១ កងទ័ពខ្មែរក្រហមបានថយចុះនៅត្រឹមចំនួន៧ម៉ឺននាក់ ដោយសារតែការធ្វើមាតុភូមិនិវត្តន៍របស់ប្រជាជនពីជំរំជនភៀសខ្លួនត្រឡប់ទៅស្រុកកំណើតវិញ និងដោយសារការផ្តាច់ខ្លួនក្នុងទ្រង់ទ្រាយតូច ។[128] មកត្រឹមពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ កងទ័ពខ្មែរក្រហមនៅសល់ប្រហែលចំនួន១ម៉ឺននាក់ ហើយនៅឆ្នាំ១៩៩៨ ខ្មែរក្រហមនៅសល់កងទ័ពប៉ុន្មានពាន់នាក់តែប៉ុណ្ណោះ ។

ទោះបីជាកងទ័ពខ្មែរក្រហមត្រូវបានបែងចែកទៅជាអង្គភាពតូចៗក៏ដោយ ក៏ខ្មែរក្រហមនៅតែបន្ត រៀបចំកងទ័ពរបស់ខ្លួនទៅជាកងពល កងវរសេនាធំ កងវរសេនាតូច កងអនុសេនាធំ និងកងអនុសេនាតូច ដែលរចនាសម្ព័ន្ធយោធា ដែលត្រូវបានបង្កើតឡើងតាំងពីរយៈកាលបដិវត្តន៍ (១៩៧០ - ១៩៧៥) ។ កងពលនីមួយៗមានកម្លាំងទ័ពប្រហែលពី២ពាន់ទៅ៣ពាន់នាក់ ទោះបីជាតួលេខនេះបានធ្លាក់ចុះ យ៉ាងខ្លាំង ។ នៅទីបំផុតកងពលមួយចំនួនមានកងទ័ពមិនដល់ពីរបីរយនាក់ផង ។[129]

អតីតកងពលខ្មែរក្រហមមួយចំនួន ដែលត្រូវបានបង្កើតឡើងតាំងពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) នៅតែរក្សាវត្តមានរបស់ខ្លួនដដែល ខណៈពេលដែលកងពលថ្មីៗជាច្រើនត្រូវបានបង្កើតឡើងដោយការដាក់បញ្ចូលគ្នានូវកងទ័ពដែលរត់ខ្ចាត់ខ្ចាយ ។ ខ្មែរក្រហមក៏បានធ្វើការជ្រើសរើសកងទ័ពបន្ថែមពីក្នុងចំណោម

ប្រជាជនដែលរស់នៅក្នុងជំរំជនភៀសខ្លួន ឬពីក្នុងតំបន់កាន់កាប់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។[១៣០] កងទ័ពដែលត្រូវបានជ្រើសរើសថ្មីនោះ រួមមានទាំងអ្នកស្ម័គ្រចិត្ត និងអ្នកដែលត្រូវខ្មែរក្រហមបានកេណ្ឌយកមក ។ មនុស្សមួយចំនួនត្រូវបានចាប់មក ពីខាងក្នុងប្រទេសកម្ពុជា និងបញ្ជូនមកអន្តភាពកងទ័ពនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ។

ជាផ្នែកមួយនៃរចនាសម្ព័ន្ធយោធានៅភ្នំ១០០៣ តាម៉ុក បានបង្កើតមូលដ្ឋានសមរភូមិមុខជាច្រើន កន្លែងនៅតាមព្រំដែន ដែលបច្ចុប្បន្នស្ថិតនៅក្នុងស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ដែលនៅជាប់គ្នាជាមួយនឹងខេត្តស៊ីសាកេត ប្រទេសថៃ ។

Khmer Rouge Strongholds and Military Operations Between 1979 and 1989




មូលដ្ឋានសមរភូមិទាំងនេះរួមមាន ភ្នំ៨០៨, ភ្នំ៨០០, ភ្នំ៤០, ភ្នំ១០០២ និងភ្នំ៥០ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភ្នំ១០០៣ ។ មូលដ្ឋានសមរភូមិមុខទាំងនេះមានទីតាំងនៅលើភ្នំដងរែក នៅចំណុចព្រំដែនជាយុទ្ធសាស្ត្រ ដែលនៅទីនោះ ខ្មែរក្រហមអាចបញ្ជូនកងទ័ពរបស់ខ្លួន ចូលមកវាយកាន់កាប់ទីតាំងផ្សេងៗនៅក្នុងប្រទេស ដើម្បីធ្វើប្រតិបត្តិការយោធា ។[១៣១] ជាពិសេសសមរភូមិមុខទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីបណ្តេញកងទ័ពវៀតណាមចេញពីតំបន់អន្លង់វែង ។ ទោះជាយ៉ាងនេះក្តី ខ្មែរក្រហមមិន

អាចសម្រេចគោលបំណងនេះបានទេ រហូតដល់ចុងឆ្នាំ១៩៨៩ នៅពេលដែលកងទ័ពវៀតណាមទាំងអស់ ត្រូវបានដកចេញពីប្រទេសកម្ពុជា ។ នៅតំបន់ព្រំដែនខាងទឹកដីកម្ពុជា ដោយអនុលោមទៅតាម ផែនការការពារជាតិ ដែលត្រូវបានស្គាល់ថា ជាផែនការ«ក-៥» កងទ័ពវៀតណាម និងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបង្កើតបន្ទាយយោធាជាយុទ្ធសាស្ត្រជាច្រើន ដើម្បីទប់ស្កាត់ការជ្រៀតចូលរបស់កងទ័ពខ្មែរក្រហម ។

មូលដ្ឋានសមរភូមិមុខភ្នំ៨០៨ មានទីតាំងស្ថិតនៅអតីតភូមិថ្កាមរមាស ដែលបច្ចុប្បន្នគឺជាច្រកព្រំដែនជាំសាង៉ាំ ។ ខ្មែរក្រហមបានសាងសង់ឃ្លាំងសម្ភារៈមួយនៅទីនោះ ដើម្បីផ្គត់ផ្គង់សម្ភារៈដល់សមរភូមិ ។ សឿន ដែលជាអតីតមេបញ្ជាការកងពល៧៧៥ ដែលមានមូលដ្ឋាននៅភូមិភាគឧត្តររបស់កម្ពុជាប្រជាធិបតេយ្យ គឺជាប្រធានភ្នំ៨០៨ ដែលជាច្រកព្រំដែនដ៏សំខាន់មួយរវាងកម្ពុជា និងថៃ ។[១៣២] មូលដ្ឋាននេះមានទីតាំងជិតជាងគេ ទៅនឹងបន្ទាយរបស់កងទ័ពវៀតណាម ។ នៅខាងកើត គឺជាទីតាំងរបស់មូលដ្ឋានសមរភូមិមុខភ្នំ៨០០ ដែលមានទីតាំងនៅជិតទំនប់លើក្នុងឃុំត្រពាំងប្រិយ៍ (ស្រុកអន្លង់វែង) ។ ភ្នំ៨០០ យកឈ្មោះតាមកងពល៨០០ ដែលមាន ឌី ធិន ជាមេបញ្ជាការ ។ ទៅខាងកើតបន្តិចទៀត គឺជាមូលដ្ឋានសមរភូមិមុខភ្នំ៤០ ដែលស្ថិតនៅតំបន់មួយ ដែលត្រូវបានគេស្គាល់ថា អូរធំ និង ប្រោក (បច្ចុប្បន្ននៅ ក្នុងឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ) ។ មូលដ្ឋានសមរភូមិបន្ទាប់ គឺភ្នំ១០០២ ដែលមានទីតាំងនៅត្រង់ច្រកព្រំដែនជប់រុន (បច្ចុប្បន្ននៅក្នុងឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ) ។ កងពល៦១២ត្រូវបានបង្កើតឡើង និងត្រូវបានចាត់តាំងឲ្យការពារ និងធ្វើប្រតិបត្តិការនៅលើភ្នំ១០០២ ។ ហឿន គឺជាប្រធានកងពល៦១២ ហើយ ឈាន គឺជាអនុប្រធាន ។[១៣៣] កងទ័ពនៅលើភ្នំ១០០២ ធ្វើប្រតិបត្តិការចាប់ពីច្រកព្រំដែនជប់រុនទៅដល់ប្រាសាទព្រះវិហារ និងតំបន់មួយចំនួនផ្សេងទៀតនៅក្នុងខេត្តព្រះវិហារ ជាពិសេសនៅតាមបណ្តោយផ្លូវជាតិលេខ១២ ពីឃុំស្រអែមទៅស្រុកជាំក្សាន្ត ។ សមរភូមិមុខ ភ្នំ៥០ មានទីតាំងនៅខាងកើតច្រកព្រំដែនជប់រុន ។

នៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៥ មូលដ្ឋានភ្នំ១០០២ និងភ្នំ៥០ គឺជាមូលដ្ឋានសមរភូមិដ៏សំខាន់ពីរ នៅក្នុងប្រតិបត្តិការសង្គ្រាមប្រឆាំងនឹងវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ មូលដ្ឋានទាំងពីរនេះ ស្ថិតនៅក្នុងទឹកដីខ្មែរ ។ នៅឆ្នាំ១៩៨០ ដើម្បីបម្រើដល់យុទ្ធសាស្ត្រកងទ័ព តាម៉ុក បានដឹកនាំការសាងសង់ផ្លូវមួយខ្សែដោយផ្ទាល់

ចេញពីមូលដ្ឋានរបស់គាត់នៅក្នុងទឹកដីថៃ ទៅកាន់ឃុំព្រះប្រឡាយក្នុងទឹកដីខ្មែរ ដោយឆ្លងកាត់ច្រកព្រំដែនជប់រុន ។ ផ្លូវនេះត្រូវបានប្រើប្រាស់ជាច្រកដ៏សំខាន់សម្រាប់បញ្ជូនកម្លាំងទៅខាងក្នុងប្រទេសកម្ពុជា និងសម្រាប់ដឹកជញ្ជូនសម្ភារៈ និងគ្រឿងសព្វាវុធទៅឲ្យកងទ័ពនៅសមរភូមិមុខ ។ តាម៉ុក បានបាត់បង់ជើងស្តាំរបស់គាត់នៅក្នុងអំឡុងពេលសាងសង់នោះ ដោយសារតែគ្រាក់ទ័រឈូសផ្លូវជាន់លើមីនគោន នៅតំបន់មួយដែលត្រូវបានហៅថា ចម្ការម្ទេស (ចម្ការមួយដែលស្ថិតនៅក្នុងទឹកដីថៃ ទល់មុខនឹងឃុំព្រះប្រឡាយក្នុងស្រុកត្រពាំងប្រាសាទ) ។ ប៊ិល សារ៉ាត់ បានរៀបរាប់អំពីការសាងសង់ផ្លូវនេះ និងព្រឹត្តិការណ៍ដែលធ្វើឲ្យ តាម៉ុក ក្លាយទៅជាមនុស្សពិការថា ៖

> តាម៉ុក បានឈរមើល និងបញ្ជាគ្រឿងចក្រដោយខ្លួនឯង ។ គេបានប្រាប់គាត់ថា កុំឲ្យឈរក្បែរគ្រឿងចក្រពេក ពីព្រោះមីនប្រឆាំងរថក្រោះមួយគ្រាប់នៅមិនទាន់ត្រូវបានរកឃើញនៅឡើយ ។ នៅពេលដែលគាត់កំពុងឈរបញ្ជាការសាងសង់គ្រឿងចក្របានបើកកិនលើមីនប្រឆាំងនឹងរថក្រោះនោះ ។ ប្រវ៉ាក់គ្រឿងចក្រនោះបានដាច់ ហើយវ៉ាត់មកត្រូវជើងស្តាំរបស់គាត់យ៉ាងខ្លាំង ។ អំបែងមីនក៏ បានខ្ទាតមកត្រូវដើមទ្រូងរបស់គាត់ ។ កងទ័ពបានប្រញាប់ប្រញាល់ លើកគាត់ដាក់លើគ្រែ និងសែងគាត់ទៅប្រទេសថៃ ។ វេជ្ជបណ្ឌិត ជួន ជឿន និងគ្រូពេទ្យថៃមួយចំនួនទៀត បានធ្វើការព្យាបាលគាត់នៅតាមផ្លូវ ។ កងទ័ពបានសែងគាត់ឆ្លងកាត់ព្រំដែនទៅដល់ជំរំជប់ម្លូ និងដឹកគាត់តាមឡានទៅកាន់ប្រទេសថៃ ។ កងទ័ពត្រូវចំណាយពេលពេញមួយយប់ ទើបធ្វើដំណើរទៅដល់ជំរំជប់ម្លូ ដោយប្តូរវេនគ្នាសែង ។ កងទ័ពទាំងនោះមិនបានដេកឬឈប់សម្រាកនៅតាមផ្លូវឡើយ ។ មុនពេលសន្លប់បាត់ស្មារតីតាម៉ុក បានផ្តាំផ្ញើកងទ័ព និងប្រជាជនដែលនៅជុំវិញគាត់ថា “អញប្រហែលជាមិនរស់ទេ ។ ជួយថែរក្សាប្រជាជន និងបន្តចលនាតស៊ូតទៅទៀត ។” មនុស្សគ្រប់គ្នា នាំគ្នាស្រែកយំនៅពេលបានឮគាត់និយាយដូច្នេះ ។[១៣៤]

## រចនាសម្ព័ន្ធយោធារបស់ខ្មែរក្រហម (១៩៧៩-១៩៩៦)



## ប្រតិបត្តិការនៅខាងក្នុង ៖ សង្គ្រាមឈ្លប និងសង្គ្រាមប្រជាជន

កងទ័ពនៅភ្នំ១០០៣ ត្រូវបានបញ្ជូនឲ្យទៅធ្វើប្រតិបត្តិការនៅក្នុងប្រទេសជារៀងរាល់ឆ្នាំ ។ កងទ័ពទាំងនោះត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅជុំវិញបឹងទន្លេសាប ក្នុងខេត្តសៀមរាប កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង ព្រមទាំងតំបន់មួយចំនួននៅតាមបណ្តោយព្រំដែន ក្នុងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ។ កងទ័ពនីមួយៗត្រូវបានអនុញ្ញាតឲ្យមកសួរសុខទុក្ខគ្រួសារនៅលើភ្នំដងរែកម្តងរយៈពេលមួយឬពីរអាទិត្យ ។ បន្ទាប់មក កងទ័ពទាំងនោះនឹងត្រូវបានបញ្ជូនឲ្យត្រឡប់ទៅកាន់ទីតាំង ដែលខ្លួនត្រូវបានចាត់តាំងឲ្យទៅ ។ម្តងម្កាល កងទ័ពខ្មែរក្រហមដែលធ្វើប្រតិបត្តិការនៅជួរមុខអាចទំនាក់ទំនងមកប្រពន្ធ និងក្រុមគ្រួសាររបស់ខ្លួនតាមរយៈសារទូរលេខ និងសំបុត្រ ។[១៣៥] មុនពេលចេញទៅបំពេញបេសកកម្ម កងទ័ពខ្មែរក្រហម ត្រូវចូលរួមវគ្គបណ្តុះបណ្តាលជាមួយមេដឹកនាំរបស់ខ្លួន ។ ឯក សុផល ដែលជាអតីតលេខាតំបន់៣៧ និងជាមេបញ្ជាការកងទ័ពក្នុងភូមិភាគបស្ចិម នៃរបបកម្ពុជាប្រជាធិបតេយ្យ បានរំឭកអំពីការងាររបស់គាត់នៅខាងក្នុងប្រទេសថា ៖

> នៅពេលដែលកងទ័ពវៀតណាមបានវាយចូលប្រទេសកម្ពុជា ខ្ញុំនិងអនុប្រធានរបស់ខ្ញុំឈ្មោះ ប៉ា ដឹម បានដឹកនាំកងទ័ពចំនួន១ពាន់នាក់ ពីខេត្តកោះកុង ទៅខេត្តកំពង់ឆ្នាំង ។ កងទ័ពរបស់យើងធ្វើប្រតិបត្តិការនៅជុំវិញបឹងទន្លេសាប ដោយមានស្បៀងអាហារតិចតួចណាស់ ។ នៅឆ្នាំ១៩៨២ តាម៉ុក បានហៅខ្ញុំឲ្យត្រឡប់ទៅអន្លង់វែងវិញ ដែលនៅទីនោះ ខ្ញុំបានរៀបការប្រពន្ធទីពីរ ។ បន្ទាប់ពីរៀបការរួច តាម៉ុក បានបញ្ជាឲ្យខ្ញុំទៅធ្វើការនៅតំបន់ជាច្រើន នៅក្នុងខេត្តព្រះវិហារ និងខេត្តកំពង់ធំ ជាមួយកងទ័ពរបស់ កែ ពក និង ស្រី សុបិន្ត ។ ខ្ញុំក៏ធ្លាប់បានទៅធ្វើការនៅស្រុកពួក ក្រឡាញ់ និងវ៉ារិន្ទ ។ ខ្ញុំអាចត្រឡប់មកផ្ទះមកជួបប្រពន្ធរបស់ខ្ញុំរៀងរាល់កន្លះឆ្នាំឬមួយឆ្នាំម្តង ។ នៅឆ្នាំ១៩៨៦ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅខេត្តកំពង់ឆ្នាំង ។ ខ្ញុំបានដឹកនាំកម្លាំងប្រហែលមួយរយនាក់ហែលឆ្លងទន្លេសាប ដោយសារតែយើងពុំមានទូកគ្រប់គ្រាន់ ។ កម្លាំងរបស់យើងធ្វើការ

> នៅស្រុកបរិបូណ៌ ដែលនៅទីនោះ យើងបានពើបប្រយុទ្ធជាមួយកងទ័ពវៀតណាម និងកងទ័ពរដ្ឋាភិបាលជាញឹកញាប់ ។ ជួនកាលយើងស្នាក់នៅក្នុងភូមិ ។ ប៉ុន្តែ ភាគច្រើន យើងនៅក្នុងព្រៃ ដើម្បីជៀសពីការប្រយុទ្ធគ្នា ។ កងទ័ពរបស់ខ្ញុំទាំងអស់ ទុកប្រពន្ធចោលនៅអន្លង់វែង ។ នៅឆ្នាំ១៩៩៦ ខ្ញុំបានធ្វើដំណើរតាមរថភ្លើង ពីខេត្តកំពង់ឆ្នាំងទៅខេត្តពោធិ៍សាត់ ហើយរស់នៅទីនោះរហូតដល់សមាហរណកម្ម ។[១៣៦]

ជាទូទៅ កងទ័ពខ្មែរក្រហមត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅតំបន់ជុំវិញភូមិកំណើតរបស់ខ្លួន ដោយសារខ្មែរក្រហមមើលឃើញអំពីអត្ថប្រយោជន៍ជាច្រើនក្នុងការធ្វើដូច្នេះ ។



កងទ័ពដែលធ្វើការនៅក្បែរភូមិកំណើតរបស់ខ្លួន ស្គាល់ច្បាស់អំពីទីតាំងភូមិសាស្ត្រក្នុងតំបន់ និងអាចធ្វើការយ៉ាងមានប្រសិទ្ធភាពជាមួយប្រជាជននៅក្នុងតំបន់នោះ ។ ជាងនេះទៅទៀត កងទ័ពទាំងនោះអាចទទួលបានការទំនុកបម្រុងពីអ្នកភូមិ ដូចជាចំណីអាហារ និងការស្នាក់នៅ នៅពេលដែលកងទ័ពទាំងអស់នោះអស់ស្បៀងអាហារម្តងៗ ។ ខ្មែរក្រហមក៏អាចទទួលបានការសហការពីអ្នកភូមិ ក្នុងការទទួលបានព័ត៌មានពីអាជ្ញាធរមូលដ្ឋានរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ បណ្តាញចារកម្មរបស់ខ្មែរក្រហមអាចអនុញ្ញាតឲ្យខ្មែរក្រហមរៀបចំខ្លួនដើម្បីធ្វើការវាយប្រហារ និងប្រតិបត្តិការឈ្លបផ្សេងៗទៀតប្រឆាំងនឹងរដ្ឋាភិបាល បន្ទាយកងទ័ពវៀតណាម និងការិយាល័យរដ្ឋបាល ។

សង្គ្រាមឈ្លប និងសង្គ្រាមប្រជាជន គឺជាយុទ្ធសាស្ត្រយោធាចម្បងរបស់ខ្មែរក្រហមនៅក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអ្វី ដែលខ្មែរក្រហមហៅថា "អាខ្មាំងយួនឈ្លានពាន" ។ យុទ្ធសាស្ត្រទាំងពីរនេះត្រូវបានខ្មែរក្រហមអនុវត្តតាំងពីឆ្នាំ១៩៦៨ នៅពេលដែលខ្មែរក្រហមចាប់ផ្តើមការតស៊ូប្រដាប់អាវុធប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជា ។ យុទ្ធសាស្ត្រសង្គ្រាមឈ្លបអាចត្រូវបានពណ៌នាថា ចល័តហើយរស់រវើកចំពោះអង្គការចាត់តាំង និងយុទ្ធសាស្ត្ររបស់សត្រូវ ។ ក្រុមឈ្លបនីមួយៗ មានគ្នាពី១០ទៅ១២នាក់ ។

> *ដែលហៅថាសង្គ្រាមឈ្លប ន័យរបស់វា គឺលបវាយខ្មាំងដោយក្រុមតូចៗ ស្រាល ស្វាត់ ចល័ត រស់រវើក ។ ន័យជាក់ស្តែង គឺក្រុមឈ្លបតូចៗ ទៅធ្វើសកម្មភាពវាយខ្មាំងដោយអាវុធ ចម្រូង មីន លបបាញ់ស៊ុប លបចាំកន្ទ្រាក់ មីន ពង្រិចពង្រិលកម្លាំងខ្មាំង មួយថ្ងៃមួយក្បាល ពីរក្បាលជាប្រចាំ ។ ក្រុមឈ្លបអត់នៅស្ងៀមទេ គឺចល័តវាយខ្មាំងជាប់ មានគំនិតផ្តើមរកវាយខ្មាំងជាប់ ឃ្លាំលខ្មាំងជាប់ ខ្មាំងចេញមិនបាន ។ ក្រុមឈ្លបផ្តាច់ផ្លូវតូចធំរបស់ខ្មាំង ។ ផ្តាច់ផ្លូវដោយកាប់ឈើបិទ រាំងសម្រាស់ ចាក់ចម្រូង ដាក់មីន មីនថ្មើមីនថ្មើរជើង មីនសម្រាប់ឡាន មីនសម្រាប់រថក្រោះលើផ្លូវសងខាងផ្លូវ ហើយនៅឃ្លាំចាំ មើលខ្មាំងនៅនឹងកន្លែងជាប់ បណ្តាក់វេនគ្នាយប់ថ្ងៃមិនឲ្យចន្លោះឡើយ ។[១៣៧]*

ការវាយប្រហារត្រូវបានធ្វើឡើងដោយស្ងៀមស្ងាត់បំផុត ដោយមិនឲ្យ«សត្រូវ» ដឹងខ្លួនជាមុន។ ការវាយឆ្មក់ និងរត់បែបសង្គ្រាមឈ្លបនេះតម្រូវឲ្យមានការផ្លាស់ទីជាប្រចាំ ដើម្បីសម្របខ្លួនទៅតាមស្ថានភាពនៅក្នុងសមរភូមិ ដែលមានការផ្លាស់ប្តូរជានិច្ច។[១៣៨]

ជាមួយនឹងយុទ្ធវិធីសង្គ្រាមឈ្លប កងទ័ពខ្មែរក្រហមបានវាយប្រហារទៅលើមន្ទីរឃុំ និងមន្ទីរស្រុក ព្រមទាំងអគាររបស់រដ្ឋាភិបាលផ្សេងៗទៀត។ មធ្យោបាយទំនាក់ទំនងផ្លូវថ្នល់ និងផ្លូវរថភ្លើងនៅទូទាំងប្រទេសគឺជាមុខសញ្ញានៃការវាយប្រហារ។ ការវាយប្រហាររបស់ខ្មែរក្រហមបានបង្កជាឧបសគ្គ និងសោកនាដកម្មជាច្រើនដល់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា កងទ័ពវៀតណាម និងប្រជាជនទូទៅ។ ឧទាហរណ៍ នៅខែមិថុនា ឆ្នាំ១៩៨០ ខ្មែរក្រហមបានបាញ់គ្រាប់ផ្លោងទៅលើស្ថានីយរថភ្លើង នៅស្តុកអាចម៍រមាស ក្នុងខេត្តកំពង់ឆ្នាំង ដែលបានសម្លាប់មនុស្សអស់ជាច្រើន។[១៣៩]

មេដឹកនាំខ្មែរក្រហមជឿជាក់ថា ការវាយប្រហារ និងការសម្លាប់កងទ័ពវៀតណាមនៅទូទាំងប្រទេស ជារៀងរាល់ថ្ងៃនឹងធ្វើឲ្យកម្លាំងរបស់វៀតណាមចុះខ្សោយ ហើយនៅទីបញ្ចប់ វៀតណាមនឹងដកទ័ពចេញពីប្រទេសកម្ពុជា។ ប៉ុល ពត ធ្លាប់បានអួតអាងថា ប្រសិនបើកងទ័ពវៀតណាមត្រូវបានដកចេញពីប្រទេសកម្ពុជា ខ្លួននឹងវាយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា«ឲ្យបើុងដូចក្រដាស» ហើយនឹងដណ្តើមយកអំណាចមកគ្រប់គ្រងសាជាថ្មីម្តងទៀត។[១៤០]

ជាផ្នែកមួយនៃសង្គ្រាមប្រជាជនកងទ័ពខ្មែរក្រហមនីមួយៗ ត្រូវបានចាត់តាំងឲ្យធ្វើការអូសទាញប្រជាជន ដោយការធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រជាជន។ ជាជាងផ្តោតទៅលើគោលដៅយោធា សង្គ្រាមប្រជាជនផ្តោតទៅលើប្រជាជនស៊ីវិល ដែលអាចផ្តល់ព័ត៌មានដ៏មានតម្លៃ និងជាធនធានដែលមិនចេះរីងស្ងួត សម្រាប់ការផ្គត់ផ្គង់ប្រតិបត្តិការនៅខាងក្នុង។ ការរំដោះប្រទេសជាតិចេញពី «ការឈ្លានពានរបស់វៀតណាម និងអាយ៉ងរបស់វា» គឺជាសារមួយដ៏សំខាន់នៃសង្គ្រាមប្រជាជន។ ជាងនេះទៅទៀត សង្គ្រាមប្រជាជនមានន័យថា ប្រជាជនទាំងក្មេងទាំងចាស់ ទាំងប្រុសទាំងស្រី អាចចូលរួមនៅក្នុងសង្គ្រាមនេះបាន។

ប្រជាជនត្រូវបានលើកទឹកចិត្តឲ្យធ្វើការរួមគ្នា នៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើសង្គ្រាម ។ ប្រជាជនអាចចូលរួមផលិតចម្រូង និងវាយអន្ទាក់ ដើម្បីការពារភូមិរបស់ខ្លួន ។ ប្រជាជនអាចផ្តល់ព័ត៌មាន ទៅដល់កងឈ្លប និងធ្វើជាចារកិច្ចរបស់កងឈ្លប នៅក្នុងការកំណត់គោលដៅវាយប្រហារទៅលើមន្ត្រី រដ្ឋាភិបាល និងការិយាល័យរដ្ឋបាល ។ ប្រជាជនក៏ត្រូវបានលើកទឹកចិត្តឲ្យធ្វើការបំផ្លិចបំផ្លាញផ្លូវសាធារណៈ ព្រមទាំងបដិសេធមិនលក់សម្ភារៈ និងផលិតផលផ្សេងៗទៅឲ្យសត្រូវ ។ ប្រជាជនក៏ត្រូវបានលើកទឹកចិត្ត ឲ្យធ្វើការរារាំងដល់ផែនការរបស់រដ្ឋាភិបាល ក្នុងការប្រមូលផ្តុំ ឬជ្រើសរើសកងទ័ព ។[១៤១]

ព្រាំ យឹម ដែលជាអតីតកងទ័ពនៅក្នុងកងពល៨០១ បានរៀបរាប់អំពីពិសោធន៍ដែលគាត់បានរៀនពីមេបញ្ជាការរបស់គាត់ នៅក្នុងការធ្វើសង្គ្រាមប្រជាជនថា ៖

> ដំបូង យើងកសាងបុគ្គលហើយបន្ទាប់មក យើងកសាងគ្រួសារមួយ ទាំងមូល ។ ដំបូង យើងកសាងប្តីដែលអាចទៅកសាងប្រពន្ធរបស់គាត់បន្ត ។ នៅពេលដែលប្តី និងប្រពន្ធមានគោលជំហរស្នេហាជាតិដូចគ្នា អ្នកទាំងពីរនឹងបន្តកសាងកូនៗរបស់ខ្លួនហើយកូនៗ នឹងកសាងមិត្តភក្តិរបស់គេបន្តទៀត ។ ដំណើរការនៃការកសាងកម្លាំង ប្រៀបបានទៅនឹងសត្វកណ្តៀរដែលស៊ីឈើ ។ បន្តិចម្តងៗ សត្វកណ្តៀរនឹងបំផ្លាញឈើពីខាងក្នុង ។ សំបកក្រៅរបស់ឈើមើលទៅ ហាក់ដូចជានៅល្អ ។ ប្រតិបត្តិការខាងក្នុងនេះត្រូវសម្ងាត់ បើមិនដូច្នោះ យើងត្រូវរត់ចូលព្រៃ ដើម្បីគេចចេញពីការចាប់ខ្លួន និងការធ្វើទុក្ខបុកម្នេញ ។[១៤២]

កងទ័ពខ្មែរក្រហមដែលធ្វើការនៅខាងក្នុងបានបង្កើតទាំងភាពភ័យខ្លាច និងទាំងមិត្តភាពជាមួយប្រជាជន ។ ម្យ៉ាង កងទ័ពខ្មែរក្រហមលួចប្លន់ទ្រព្យសម្បត្តិ និងដុតបំផ្លាញផ្ទះសម្បែងរបស់ប្រជាជនដើម្បីធ្វើឲ្យកម្លាំងរបស់អាជ្ញាធរមូលដ្ឋាន និងកម្លាំងរបស់វៀតណាមចុះខ្សោយ ។ ម្យ៉ាងវិញទៀត កងទ័ពខ្មែរក្រហមបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកភូមិ ដែលបានផ្តល់ស្បៀងអាហារ និងសម្ភារៈចាំបាច់ផ្សេងៗ សម្រាប់ការរស់នៅ

ប្រចាំថ្ងៃ ។ ប៉ាន ប៉ាត់ ដែលជាអតីតកងទ័ពនៅក្នុង កងពល៥១៩ បាននិយាយថា «ការធ្វើទំនាក់ទំនងជាមួយប្រជាជនមិនមែនជារឿងលំបាកទេ ។ យើងបង្កើតទំនាក់ទំនងជាមួយអ្នកភូមិណា ដែលមានកូនធ្វើជាទាហាន របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ មិនយូរប៉ុន្មាន យើងបានក្លាយទៅជាមិត្តភក្តិ ។ យើងមិនវាយគ្នាទេ ។ ការប្រយុទ្ធគ្នាប្រៀបបានទៅនឹងការបំផ្លាញឆ្នាំងបាយខ្លួនឯង ។ យើងអាចចេញចូលក្នុងភូមិបានយ៉ាងងាយ ។»[១៨៣] អ្នកភូមិមួយចំនួនថែមទាំងធ្វើជានីរសារឲ្យខ្មែរក្រហមទៀតផង ។ មាស អេន ដែលជាអ្នកភូមិម្នាក់នៅស្រុកអន្លង់វែង បានរំឭកថា ៖

*ខ្ញុំបានចូលរួមជាមួយខ្មែរក្រហមនៅឆ្នាំ១៩៨៥ ដោយសារតែខ្ញុំមានបញ្ហានៅក្នុងគ្រួសារ ។ ខ្មែរក្រហមមានទំនាក់ទំនងល្អជាមួយប្រជាជននៅក្នុងភូមិ (ភូមិរូង ឃុំល្វែងឫស្សី ស្រុកជីក្រែង ខេត្តសៀមរាប) ។ អ្នកភូមិបានជួយរៀបចំដំណើររបស់ខ្ញុំទៅកាន់ភ្នំដងរែក ។ ខ្មែរក្រហមមានក្រុមចារកិច្ចរបស់ខ្លួននៅក្នុងភូមិ ។ ប្រសិនបើកងទ័ពវៀតណាមចុះមកត្រួតពិនិត្យនៅក្នុងភូមិនៅម៉ោង១រសៀល អ្នកភូមិនឹងឲ្យការទៅខ្មែរក្រហមដែលនឹងចាកចេញពីភូមិនៅម៉ោង ១២ថ្ងៃត្រង់ ដើម្បីជៀសវាងពីការប្រឈមមុខដាក់គ្នាជាមួយកងទ័ពវៀតណាម ។ ប្រសិនបើកងទ័ពខ្មែរក្រហមមិនអាចចាកចេញពីភូមិទាន់ពេលទេ នោះការប្រយុទ្ធជាមួយកងទ័ពវៀតណាមនឹងកើតមានឡើង ។ ខ្ញុំបានធ្វើដំណើរ និងដេកជាមួយកងទ័ពខ្មែរក្រហមអស់រយៈពេលកន្លះខែមុននឹងទៅដល់មូលដ្ឋានរបស់ខ្មែរក្រហមនៅលើភ្នំដងរែក ។ យើងបានធ្វើដំណើរឆ្លងកាត់តំបន់ដែលក្រាលទៅដោយគ្រាប់មីន ។ ខ្ញុំត្រូវគោងវល្លិឡើងចំណោតថ្មភ្នំ ។ ក្រោយមក ខ្ញុំបានក្លាយទៅជាកងទ័ពខ្មែរក្រហមនៅក្នុងកងពល៧៨៥ និងក្រោយមកទៀតនៅក្នុងកងពល៩៨០ ។*[១៨៤]

ទោះជាយ៉ាងនេះក្តី យុទ្ធសាស្ត្រសង្គ្រាមប្រជាជនរបស់ខ្មែរក្រហម មិនមានប្រសិទ្ធភាព ដោយសារតែប្រជាជនមិនមានជំនឿទៅលើយុទ្ធសាស្ត្រ ដែលគ្មានភាពប្រាកដប្រជារបស់ខ្មែរក្រហម ។ ជាងនេះទៅទៀត ប្រជាជនមានការនឿយណាយ និងនៅតែឈឺចាប់

ចំពោះរឿងរ៉ាវដែលបានកើតឡើង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ ទោះជានៅក្នុងកាលៈទេសៈណាក៏ដោយ ប្រជាជនជាច្រើននឹងមិនប្រថុយប្រថានសហការជាមួយខ្មែរក្រហមនោះទេ ។ ប្រសិនបើប្រជាជនសម្រេចចិត្តរត់ចូលព្រៃដើម្បីគេច ចេញពីការលំបាកទាំងឡាយ ដែលបង្កឡើងដោយអាជ្ញាធររដ្ឋាភិបាល ប្រជាជនទាំងនោះ សុខចិត្តទៅចុះចូលជាមួយរណសិរ្សហ៊ុនស៊ិនប៉ិចដែលដឹកនាំដោយអតីតព្រះមហាក្សត្រព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ឬចូលរួមជាមួយរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរដែលដឹកនាំដោយសម្តេច សឺន សាន ។ ជាទូទៅ កងទ័ពខ្មែរក្រហមប្រើការគំរាមកំហែង ។ ប្រជាជនម្នាក់បានរៀបរាប់អំពីពាក្យសម្តី ដែលខ្មែរក្រហមធ្លាប់និយាយទៅកាន់គាត់ថា «មូលដ្ឋានសេដ្ឋកិច្ចរបស់យើង គឺនៅក្នុងព្រៃ ។ ប្រសិនបើហ៊ានរាយការណ៍ពីយើងទៅប្រាប់សត្រូវ ខ្លួននឹងបាត់បង់មូលដ្ឋានសេដ្ឋកិច្ច ហើយប្រឈមមុខនឹងសេចក្តីស្លាប់ ។»[១៨៥] នៅក្នុងស្ថានភាពបែបនេះ ប្រជាជនជាច្រើនដែលនៅក្នុងតំបន់ប្រទាញប្រទង់គ្នា បានជ្រើសរើសយកផ្លូវកណ្តាល ដោយមិនចូលរួម ហើយក៏មិនប្រឆាំងនឹងខ្មែរក្រហមដែរ ។ ដើម្បីរស់រានផ្នែកសេដ្ឋកិច្ច ប្រជាជនបានសហការជាមួយភាគីជម្លោះទាំងពីរ ។

ជំពូក៨

# ជីវិតនៅលើភ្នំដងរែក

## ជីវិតរបស់ប្រជាជននៅភ្នំ១០០៣

ប្រជាជនដែលធ្លាប់រស់នៅលើភ្នំ១០០៣ បានរៀបរាប់អំពីជីវិតលំបាកវេទនា និងភាពមិនមានទីលំនៅច្បាស់លាស់ ដែលស្រមោលនៃសង្គ្រាមទាំងនេះបន្ត គ្របដណ្តប់មកលើគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួន ។ សំឡេងគ្រាប់ផ្លោង និងសំឡេងផ្ទុះពីចម្ងាយ គឺជាសញ្ញានៃការវាយប្រហារ ដែលមានន័យថាក្រុមគ្រួសារទាំងឡាយ ត្រូវប្រញាប់ប្រញាល់ប្រមូលផ្តុំសម្ភារៈចាំបាច់ និងរៀបចំរត់គេចខ្លួន ។ ឪពុកម្តាយជាច្រើនតែងតែព្រួយបារម្ភជារៀងរាល់ថ្ងៃ ។ សកម្មភាពសាមញ្ញ ដូចជា ការអនុញ្ញាតឲ្យកូនរត់លេងខាងក្រៅអាចនាំមកនូវគ្រោះថ្នាក់ ដែលបណ្តាលមកពីការវាយប្រហារ ដែលអាចកើតមាននៅថ្ងៃនោះ ។ ប្រពន្ធតែងតែលើកដៃលាប្តីដោយក្តីកង្វល់ នៅពេលប្តីធ្វើដំណើរទៅសមរភូមិមុខ ដោយបានដឹងយ៉ាងច្បាស់ថាការធ្វើដំណើរទៅសមរភូមិម្តងៗអាចជាការជួបគ្នាជាចុងក្រោយ ។ ជីវិតហាក់ដូចជាដំណើរផ្សងព្រេងនៅក្នុងចន្លោះនៃការរស់នៅប្រចាំ និងសង្គ្រាម ។

ការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនៅលើភ្នំ១០០៣ ជាមួយនឹងកងទ័ពវៀតណាម កើតមានឡើងជាញឹកញាប់ ។ ស្ថានភាពបែបនេះបានបង្ខំប្រជាជនឲ្យរត់ភៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីគេចពីគ្រាប់កាំភ្លើង និងគ្រាប់ផ្លោង ។ ប្រជាជនបានពណ៌នាជីវិតចល័តបែបនេះ ដែលប្រកបដោយភាពលំបាកវេទនា ដោយសារតែប្រជាជនត្រូវសាងសង់លំនៅឋានថ្មី នៅរៀងរាល់ពេលរត់គេចខ្លួនម្តងៗ ។ ជាងនេះទៅទៀត ប្រជាជនត្រូវយកសម្ភារៈជាច្រើនទៅតាមខ្លួន នៅពេលមានការប្រយុទ្ធគ្នាម្តងៗ ។ ប្រជាជនបានឃើញកងទ័ពរងរបួស និងស្លាប់ ដែលត្រូវបានសែងកាត់តាមភូមិជារៀងរាល់ថ្ងៃ ។ជួនកាលកងទ័ពដើរជាន់មីនដែលខ្លួនឯងបានកប់ ។ កងទ័ពវៀតណាមបានបាញ់គ្រាប់ផ្លោងចូលទៅក្នុងភូមិនៅលើភ្នំ ដែលបានបង្កឲ្យមានការស្លាប់យ៉ាងច្រើន ។[១៨៦] សំភីន អតីតអ្នកកាន់ឃ្លាំង តាម៉ុក និងជាជនពិការដោយគ្រាប់មីនម្នាក់ ដែលធ្លាប់រស់នៅ

លើឆ្នាំ១០០៣ បានរៀបរាប់អំពីជីវិតចល័តរបស់គាត់ថា ៈ

> កងទ័ពវៀតណាមវាយប្រហារយើង នៅពេលពួកគេស៊ើបដឹងពីទីតាំងរបស់យើង ។ អ្នកដែលស្លាប់ត្រូវបានទុកចោល ហើយអ្នកដែលនៅរស់បន្តធ្វើដំណើរទៅមុខទៅរកទីតាំងថ្មី ។ យើងតែងតែទុកចានឆ្នាំងនៅក្នុងបង្វេចរបស់យើងជាប្រចាំ ហើយយើងតែងតែប្រុងប្រយ័ត្នជាប់ជានិច្ច ។ យើងមិនបណ្តោយឲ្យកូនចៅទៅណាឆ្ងាយពីយើងទេ ដោយខ្លាចបែកគ្នានៅពេលការប្រយុទ្ធគ្នាកើតឡើង ។ វាក្លាយជាទម្លាប់របស់យើងទៅហើយ ដែលបន្ទាប់ពីហូបអាហាររួច យើងតែងតែរៀបចំសម្ភារៈផ្ទះបាយរបស់យើងដាក់ទៅក្នុងបង្វេច ។ ជាទូទៅការវាយប្រហារកើតឡើងស្ទើររៀងរាល់ថ្ងៃ ។[១៨៧]

ទោះជាយ៉ាងណាក្តី ប្រជាជនរស់នៅក្រោមការឧបត្ថម្ភគាំទ្រទាំងស្រុងពីសំណាក់តាម៉ុក ដែលបានបែងចែកស្បៀងអាហារ និងសម្ភារៈផ្សេងៗទៀត ទៅឲ្យប្រជាជនយ៉ាងទៀងទាត់ ។ ប្រជាជនមិនត្រូវបានតម្រូវឲ្យទៅធ្វើការស្រែចម្ការ លើកទំនប់ និងជីកប្រឡាយ ដូចដែលខ្លួនធ្លាប់ធ្វើកាលពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) នោះទេ ។ ប្រជាជនម្នាក់ៗទទួលបានសម្លៀកបំពាក់មួយកំផ្លេរក្នុងមួយឆ្នាំ និងអង្ករពីរកំប៉ុងក្នុងមួយថ្ងៃ ។ នៅរៀងរាល់មួយសប្តាហ៍ ឬពីរសប្តាហ៍ម្តង ប្រជាជនបានទៅបើកស្បៀងអាហារ សម្ភារៈផ្ទះបាយ និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀតពីឃ្លាំងរបស់ តាម៉ុក ។ ស្បៀងអាហារទាំង នោះរួមមាន ៈ ទឹកត្រី អំបិល ស្ករស មី ត្រីខកំប៉ុង ប្រហុក ប្រេងឆាទឹកដោះគោ សាប៊ូ ប៊ីចេង ក្រណាត់ ក្រមា និងសារុង ជាដើម ។ តាម៉ុក បានដឹកសម្ភារៈ និងស្បៀងអាហារទាំងអស់នោះពីប្រទេសថៃជារៀងរាល់ខែ ។ លទ្ធភាពបែបនេះអាចធ្វើទៅបានដោយសារទទួលបានជំនួយពីប្រទេសចិន សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តលោកខាងលិចប្រទេស សមាជិកអាស៊ាន និងអង្គការមនុស្សធម៌អន្តរជាតិ ។[១៨៨]

## **កងដឹកជញ្ជូននារី**

នៅពេលដែលបុរសត្រូវបានជ្រើសរើសឲ្យទៅធ្វើកងទ័ព និងត្រូវបានបញ្ជូនឲ្យទៅសមរភូមិមុខ និងទៅខាងក្នុងប្រទេស ស្ត្រីដើរតួនាទីយ៉ាងសំខាន់ ជាអ្នកជំនួយនៅសមរភូមិក្រោយ ។ តាម៉ុក បានបង្កើតកងដឹកជញ្ជូននារីជាច្រើនក្រុម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។ កងនីមួយៗមាននារីពី២០ទៅ៣០នាក់ ហើយនារី ទាំងអស់សុទ្ធតែនៅលីវ ។ ស្ត្រីដែលរៀបការរួចត្រូវបានអនុញ្ញាតឲ្យចេញពីកង ហើយទៅរស់នៅជាមួយប្តីនៅតាមអង្គភាពកងពលរៀងៗខ្លួន ។

កងដឹកជញ្ជូននារីបានចូលរួមយ៉ាងច្រើន ទៅក្នុងកិច្ចខិតខំប្រឹងប្រែងផ្នែកយោធារបស់ខ្មែរក្រហម ។ កងនារីទាំងនេះត្រូវបានបញ្ជូនទៅកាន់តំបន់ផ្សេងៗ នៅតាមព្រំដែនដើម្បីគ្រប់គ្រងការដឹកជញ្ជូនស្បៀងអាហារ គ្រាប់មីន និងគ្រឿង សព្វាវុធ ទៅឲ្យកងទ័ពនៅសមរភូមិមុខ ។ ជាងនេះទៅទៀត កងនារីបានជួយផលិត និងដឹកជញ្ជូនចម្រូង ដែលត្រូវបានប្រើប្រាស់ធ្វើជាឧបករណ៍ការពារ ដើម្បីកាត់បន្ថយការវាយប្រហាររបស់សត្រូវ ។ កងនារីក៏ត្រូវបានដាក់ឲ្យទទួលខុសត្រូវ នៅក្នុងការដឹកជញ្ជូនកងទ័ពដែលរងរបួសត្រឡប់មកមូលដ្ឋាននៅលើភ្នំវិញ ។

ឡាច ថៃ ដែលជាអតីតនារីមួយរូបនៅក្នុងកងដឹកជញ្ជូននារី បានរំឭកអំពីបទពិសោធរបស់ខ្លួន នៅក្នុងការដឹកជញ្ជូនគ្រឿងសព្វាវុធទៅឲ្យកងទ័ពនៅសមរភូមិមុខថា ៖

> *កម្លាំងរបស់យើងរស់នៅមូលដ្ឋានជាំស្មា នៅក្នុងទឹកដីថៃ ។ នៅរៀងរាល់ពេលដែលគេត្រូវការយើង យើងនឹងធ្វើដំណើរទៅព្រំដែន ។ ក្រុមរបស់ខ្ញុំមានគ្នាពី៥០ទៅ១០០នាក់ ដើម្បីដឹកជញ្ជូនគ្រឿងសព្វាវុធទៅឲ្យកងទ័ពនៅសមរភូមិមុខ ។ មេកងរបស់ខ្ញុំឈ្មោះ ភួន និង ផាត ។ នៅក្នុងអំឡុងពេលនៃការដឹកជញ្ជូនគ្រឿងសព្វាវុធ យើងតែងតែជួបប្រទះជាមួយកងទ័ពវៀតណាមដែលដើរយាមល្បាតតាមព្រំដែន ។ នៅពេលជួបប្រទះនឹងកងទ័ពវៀតណាម យើងបានរត់គេចខ្លួន ដើម្បីកុំឲ្យកងទ័ពវៀតណាមឃើញ ។ យើងអាចដើរបានជាធម្មតាវិញ នៅពេលឃ្លាតឆ្ងាយពីកងយាមល្បាតរបស់វៀតណាម ។ នេះគឺជាការងារដ៏លំបាក ។ នៅពេលមួយនោះ កងទ័ព*

វៀតណាមបានបំផ្ទុះមីនខ្មែរដែលបានសម្លាប់នារីដឹកជញ្ជូនអស់១២នាក់ ។ យើងបានរត់បែកផ្លូវគ្នាទៅគ្រប់ទិសទី ។ យើងបានចំណាយពេលពីរអាទិត្យទម្រាំប្រមូលគ្នាបានមកវិញ ។ នារីមួយចំនួនបានស្លាប់ដោយសាររបួស និងដាច់បាយ ដោយសារតែគេមិនអាចរកអាហារហូប បាននៅក្នុងពេលនោះ ។ ជីវិតគឺពោរពេញទៅដោយភាពលំបាកវេទនា ។[១៨៩]

## កងពិការ

ទោះបីជាប្រជាជនទូទៅប្រឈមមុខនឹងគ្រោះថ្នាក់ ដោយសារគ្រាប់មីន និងគ្រាប់ផ្ទុះផ្សេងទៀតក៏ដោយ ក៏កងទ័ព និងប្រជាជននៅក្នុងកងដឹកជញ្ជូន ងាយនឹងទទួលរងគ្រោះខ្លាំងជាងគេ ។ រហូតមកត្រឹមឆ្នាំ១៩៨៦ ប្រជាជនយ៉ាងហោចពីរទៅបីរយនាក់នៅលើភ្នំ១០០៣ បានក្លាយទៅជាជនពិការ ។ ហេតុដូច្នេះ តាម៉ុក បានបង្កើតកងពិការ និងបានជួយទំនុកបម្រុងតម្រូវការសព្វបែបយ៉ាងរបស់ជនពិការទាំងអស់ ។ តាម៉ុក និយាយថា "ទោះជាជនពិការក៏អាចជួយបង្កើតកូនបានដែរ" ។ នៅក្នុងន័យនេះ តាម៉ុក បានរៀបចំគូស្រករឲ្យជនពិការទាំងអស់នោះ ។ លន់ សេង ដែលជាអតីតប្រធានកងវរសេនាធំ៩១ នៅក្នុងកងពល៩៨០ និងដែលបានពិការជើងម្ខាងដោយសារគ្រាប់មីន គឺជាប្រធានកងពិការ ។ ក្រោយមក ប្រជាជនពិការទាំងអស់ត្រូវបានដាក់ឲ្យរស់នៅក្នុងភូមិមួយ នៅពេលខ្មែរក្រហមបានចុះមករស់នៅអន្លង់វែង នៅដើមឆ្នាំ១៩៩០ ។

## ការផលិតចម្រូង

ការងារដ៏សំខាន់មួយរបស់ប្រជាជន ដែលភាគច្រើនគឺជាសមាជិកគ្រួសាររបស់កងទ័ព គឺការផលិតចម្រូងធ្វើអំពីឫស្សី ។ ប្រជាជនត្រូវបានបែងចែកជាក្រុមដែលចែកវេនគ្នាទៅកាប់ឫស្សីនៅក្នុងព្រៃ ដើម្បីបិតចម្រូងឲ្យកងទ័ព ដើម្បីយកទៅដាំនៅតាមផ្លូវធ្វើដំណើររបស់កងទ័ពវៀតណាម ។ ចម្រូងក៏ត្រូវបានដាំនៅជុំវិញភូមិ ដើម្បីទប់ស្កាត់ការលបចូលរបស់ចារកិច្ចកងទ័ពវៀតណាម និងចារកិច្ចរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។[១៩០]

ប្រជាជនម្នាក់ៗត្រូវបានតម្រូវឲ្យផលិតចម្រូងពី២០០ទៅ៥០០ចម្រូងក្នុងមួយថ្ងៃ ។

ជូនកាលប្រជាជនត្រូវធ្វើការទាំងយប់ ដើម្បីសម្រេចតាមចំនួនដែលបានកំណត់ ។ បន្ទាប់ពីផលិតចម្រូងរួចរាល់ហើយ ប្រជាជនមួយក្រុមទៀត ត្រូវបានចាត់តាំងឲ្យដឹកជញ្ជូនចម្រូងទៅឲ្យកងទ័ពខ្មែរក្រហមនៅសមរភូមិមុខ ។[១៥១] ស្ត្រីមួយចំនួនដឹកជញ្ជូនចម្រូងដោយទូលនៅលើក្បាល ហើយអ្នកខ្លះទៀតដឹកជញ្ជូនតាមរទេះគោ ។ ការងារនេះមានសារៈសំខាន់ណាស់ សម្រាប់ប្រជាជន និងកងទ័ពនៅសមរភូមិមុខ ។ ជាការដឹងគុណដល់ការចូលរួមចំណែកនេះ រូបសំណាកស្ត្រីទូលចម្រូង នៅលើក្បាលត្រូវបានកសាងឡើងនៅ


៣១

# ប្រជាជនភូមិខ្ញុំ

ចាប់តាំងពីអាមេរិកាំងយួនចូលឈ្លានពានទន្ទ្រានកាន់កាប់ទឹកដីកម្ពុជាយើងមក ប្រជាជនភូមិខ្ញុំបានភៀសខ្លួនមករស់នៅលើព្រៃភ្នំ។ ជីវភាពពេលនោះក្រខ្សត់ ហើយលំបាកវេទនាណាស់។ តែប្រជាជនភូមិខ្ញុំដាច់ខាតមិនចុះចាញ់មេអាមេរិកាំងយួនឡើយ។ ក្នុងការរស់នៅប្រចាំថ្ងៃ ប្រជាជនភូមិខ្ញុំចេះសាមគ្គីជួយគ្នាទៅវិញទៅមក។

មួយថ្ងៃៗ ប្រជាជនភូមិខ្ញុំចេញទៅរកជីកមើមក្ដួច ជីកដំឡូងព្រៃ ទំពាំងឫស្សី និងបេះស្លឹកល្ពៅ ស្លឹកពួចជាដើម មកស្ងោរធ្វើជាម្ហូបអាហារ។ ជួនពេលខ្លះរកបាន ជួនពេលខ្លះរកមិនបាន តែបងប្អូនចេះចែករំលែកគ្នាហូបយ៉ាង[illegible]។ បើមានបងប្អូនណា[illegible] គេទាំងឡាយជួយឈឺឆ្អាល ជួយរត់រកថ្នាំឫសឈើព្រៃ។

លើផ្លូវទៅកាន់ច្រកព្រំដែនជាំសាង៉ាំ ។

ប្រជាជនត្រូវបានបង្រៀនឲ្យចេះផលិតចម្រូងជ័រឆក់ ដែលមានជាតិពុល ។ សារធាតុពុលដែលប្រើសម្រាប់លាបនៅចុងចម្រូង ត្រូវបានចម្រាញ់ចេញមកពីការលាយបញ្ចូលគ្នារវាងជ័រឈើ និងពិសពស់ ព្រមទាំងសារធាតុពុលដទៃទៀតដែលអាចរកបាន ។ ជ័រឈើ និងសារធាតុពុលទាំងនេះត្រូវបានរំងាស់បញ្ចូលគ្នារហូតក្លាយទៅជាជ័រកាវ ដែលត្រូវយកទៅលាបនៅលើចុងចម្រូង ។ រូបមន្តសម្រាប់ផលិតចម្រូងជ័រឆក់នេះបានមកពីជនជាតិភាគតិចតំបន់ភ្នំ ដែលមកពីភូមិភាគឦសាន ។ ដោយសារតែសារធាតុផ្សំមានចំហាយខ្លាំង អ្នកដែលផលិតជ័រឆក់នេះ ជួបប្រទះបញ្ហាសុខភាព ។ ជាក់ស្តែង ប្រជាជនដែលរម្ងាស់សារធាតុពុលនេះតែងតែហើមមុខ និងឈឺចុកចាប់ ។[១៥២] ខ្មែរក្រហមចាត់ទុកចម្រូងជ័រឆក់របស់ខ្លួនថាជា«អាវុធស័ក្តិសិទ្ធិ ។» ខ្មែរក្រហមបានអះអាងថា ចម្រូងជ័រឆក់មួយដើមខ្លាំងជាងគ្រាប់បេ៤០ចំនួនដប់គ្រាប់ ដោយសារ«ចម្រូងជ័រឆក់មួយដើមសម្លាប់ខ្មាំងបានមួយក្បាល ហើយធ្វើឲ្យបាក់ស្មារតីច្រើនសិបក្បាលទៀត ។»[១៥៣]

ប៊ិល សារ៉ាត់ ដែលជាអតីតកម្មាភិបាលខ្មែរក្រហមនៅភ្នំ១០០៣ បានរំឭកអំពីបទពិសោធរបស់គាត់ នៅពេលធ្វើការក្រោមការគ្រប់គ្រងផ្ទាល់ពី តាម៉ុក ដើម្បីផលិតចម្រូង និងដាក់មីន ។

*ខ្ញុំធ្វើការនៅក្នុងកងនារី ។ សមមិត្តនារី ស៊ុប ជាប្រធានកង ។ ក្រុមរបស់ខ្ញុំដែលត្រូវបានស្គាល់ថាជាកងយាយតុង ត្រូវបានបញ្ជូនឲ្យទៅច្រកជប់រុន ។ ក្រុមរបស់ខ្ញុំ មានគ្នាចំនួន៣០នាក់ ដែលសុទ្ធតែនៅលីវ ។ បន្ទាប់ពីខ្ញុំរៀបការហើយ នៅឆ្នាំ១៩៨៦ ខ្ញុំបានចេញពីកង និងទៅរស់នៅជាមួយប្តីរបស់ខ្ញុំនៅក្នុងកងពល៧៨៥ ។ ប្រពន្ធរបស់កងទ័ពធ្វើការងារបិតចម្រូង និងដឹកជញ្ជូនចម្រូងដោយរទេះទៅកាន់សមរភូមិមុខ ។ ចម្រូងមួយដើមមានប្រវែងប្រហែលមួយហត្ថ ។ ខ្ញុំក៏ធ្លាប់បានលាបថ្នាំពុលទៅលើចុងចម្រូងសារធាតុពុលទាំងនោះ ត្រូវបានផ្តល់ឲ្យដោយកងទ័ព ។ ខ្ញុំពិតជាពេញចិត្តខ្លាំងណាស់នៅក្នុងការធ្វើជាយុទ្ធនារី ។ ខ្ញុំពិតជាពេញចិត្តនឹងការងារដឹកជញ្ជូនមីន ។ ខ្ញុំមិនខ្លាចមីនទេ ។ យើងបានរាយមីននៅតាមតំបន់ដែលយើងបានឃើញចារកិច្ចយួនឆ្លងកាត់ ។[១៥៤]*

ចម្រូងគឺជាអាវុធសំខាន់ទីពីររបស់ខ្មែរក្រហម បន្ទាប់ពីគ្រឿងសព្វាវុធ ។ ខ្មែរក្រហមដាំចម្រូងពីររបៀបផ្សេងគ្នា ។ ខ្មែរក្រហមអាចដាំចម្រូង ដោយបង្កប់ជាមួយនឹងស្មៅ ឬដាំចម្រូងនៅក្នុងរណ្ដៅ ។ ចម្រូងទាំងនោះមើលទៅស្មើរតែប្រហាក់ប្រហែលទៅនឹងស្មៅ ហើយពិបាកនឹងសម្គាល់ឃើញណាស់ នៅពេលដែលមនុស្សម្នាក់កំពុងរត់គេចចេញពីការប្រយុទ្ធ ។ ប្រសិនបើជនណាម្នាក់ដួលទៅលើចម្រូង ចម្រូងនោះនឹងបែកទៅជាបំណែក តូចៗ ហើយចាក់ចូលទៅក្នុងសាច់ ។ បំណែកចម្រូងតូចៗ នេះពិបាកនឹងដកចេញពីសាច់ណាស់ ។ កងទ័ព

២៥



# កងដឹកជញ្ជូន

ក្រុមខ្ញុំមានភារកិច្ចដឹកជញ្ជូនគ្រាប់ទៅសមរភូមិមុខ ។

យើងរៀបចំគ្រាប់ និងសម្ភារៈស្ពាយខ្លួនតាំងពីព្រលប់ ។ ភ្លឺស្អះៗ យើងចេញដំណើរ ។ យើងគិតថា ទំរាំថ្ងៃរះក្ដៅ យើងនឹងធ្វើដំណើរបានឆ្ងាយហើយ យើងគិតទៅសំរាកនៅអូរខាងមុខ ។ យើងធ្វើដំណើរអស់រយៈពេលពីរម៉ោង ឆ្លងកាត់ភ្នំពីរ ទាំងឡើង ទាំងចុះ ឆ្លងអូរប្អូន-ប្រាំ ទាំងអូរមានទឹក ទាំងអូរស្ងួត ។ ឥឡូវយើងបានធ្វើដំណើរមកដល់ទិសដៅកំណត់សំរាកហើយ ។ យើងឈប់សំរាកនៅក្រោមម្លប់ឈើ ក្បែរមាត់អូរ ។ យើងដាក់កម្លាំងខ្លះឱ្យយាម ។ អ្នកឯទៀតចុះក្នុងអូរ លាងដៃ លាងជើង និងលុបមុខ ។ ទឹកអូរថ្លាឈ្វង់ ហើយត្រជាក់ស្រួល មើលទៅឃើញបាតដី ។ យើងអង្គុយសំណេះសំណាលគ្នា នៅលើថ្មធំៗរាបស្មើ នៅក្បែរមាត់អូរ ។ ម្លប់ឈើត្រជាក់ និងខ្យល់រំភើយៗ ដែលបក់តាមបណ្ដោយជ្រលងភ្នំ មកប៉ះខ្លួនយើង ធ្វើឱ្យយើងមានកម្លាំងព្រើសមួយរំពេច ។

យើងចែកកម្លាំងគ្នាដាំបាយ ដាំទឹក ។ អ្នកខ្លះដាំបាយ អ្នកខ្លះបេះស្លឹកឈើព្រៃមកធ្វើបន្លែ ដូចជាស្លឹកព្រេច ស្លឹកក្របួងជាដើម ។ អ្នកខ្លះទៀតស្ទូចត្រី ចាប់ក្ដាម ក្ដាវ ខ្យងក្នុងអូរយកមកឱ្យស្ងោរធ្វើម្ហូប ។ បាយឆ្អិន

ដែលគេចផុតពីការស្លាប់ដោយចម្រូងតែងតែឈឺចាប់រយៈពេលវែង ពីព្រោះមុខរបួសមិនងាយនឹងជាសះស្បើយឡើយ ។[១៥៥] ជួនកាលអន្ទាក់ចម្រូងអាចឲ្យខ្មែរក្រហមចាប់ខ្លួនកងទ័ពវៀតណាមបានដែលជាទូទៅត្រូវបានបញ្ជូនទៅប្រទេសថៃ ។ មានការអះអាងថាថៃបានដោះដូរកងទ័ពវៀតណាម ជាមួយរដ្ឋាភិបាលវៀតណាមជាថ្នូរនឹងលុយកាក់ ។

## ការដឹកជញ្ជូនគ្រឿងសព្វាវុធ និងសម្ភារ

ដូចកងដឹកជញ្ជូននារីដែរ ការដឹកជញ្ជូនគ្រាប់ និងសម្ភារៈ គឺជាការងារដ៏សំខាន់របស់ប្រជាជនទូទៅនៅលើភ្នំ១០០៣ ។ ប្រជាជនមានមោទកភាពចំពោះការងារនេះ ដោយសារតែប្រជាជនទាំងនោះយល់ឃើញថា ការតស៊ូរបស់ខ្លួន គឺជាផ្នែកមួយនៃការតស៊ូរួមរបស់ប្រទេសជាតិ ដើម្បីការពារប្រទេសរបស់ខ្លួន ប្រយុទ្ធប្រឆាំងទៅនឹងអ្វី ដែលប្រជាជនទាំងនោះជឿជាក់ថា «ការឈ្លានពានរបស់យួនមកលើកម្ពុជា ។»

សមរភូមិចម្បងមួយដែលតម្រូវឲ្យមានការដឹកជញ្ជូនសម្ភារៈប្រកបដោយប្រសិទ្ធភាព គឺសមរភូមិនៅព្រៃស្អាក ។[១៥៦] ជាទូទៅ ក្រុមដឹកជញ្ជូនត្រូវចំណាយពេលពី៣ទៅ៤ថ្ងៃ ដើម្បីធ្វើដំណើរពីភ្នំដងរែកទៅកាន់ព្រៃស្អាក ។ ជាញឹកញាប់ក្រុមដឹកជញ្ជូនជួបប្រទះនឹងកងទ័ពវៀតណាម ដែលតម្រូវឲ្យក្រុមនេះត្រូវលាក់ខ្លួន និងស្វែងរកផ្លូវផ្សេងទៀតដើម្បីធ្វើដំណើរទៅសមរភូមិមុខ ។ នៅក្នុងករណីនេះ ក្រុមដឹកជញ្ជូនត្រូវចំណាយពេលយ៉ាងតិច២សប្តាហ៍ដើម្បីធ្វើដំណើរទៅដល់គោលដៅរបស់ខ្លួន ។ ជាទូទៅ ក្រុមដឹកជញ្ជូនត្រូវធ្វើដំណើរទាំងយប់ទាំងថ្ងៃ ។[១៥៧]

សកម្មភាពដឹកជញ្ជូនសំខាន់កើតឡើងនៅក្នុងឆ្នាំ១៩៨៧-១៩៨៩ នៅពេលដែលខ្មែរក្រហមតស៊ូ ដើម្បីដណ្តើមយកនូវទឹកដីដែលបាត់បង់មកវិញ ។ កងទ័ពវៀតណាមបានវាយប្រហារបកវិញដោយ រុញច្រានខ្មែរក្រហមឲ្យថយក្រោយ នៅក្នុងការវាយប្រយុទ្ធគ្នាជាច្រើនលើក រហូតដល់ខ្មែរក្រហមត្រូវបង្ខំចិត្តស្វែងរកការជ្រកកោននៅក្នុងទឹកដីថៃ ។ ក្រុមដឹកជញ្ជូនបានជួបប្រទះនូវគ្រោះថ្នាក់ជាច្រើន នៅតាមផ្លូវទៅកាន់សមរភូមិ ។ ក្រុមដឹកជញ្ជូនទទួលរងគ្រោះពីការវាយប្រហារពីសំណាក់កងទ័ពវៀតណាម និងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ក្រុមដឹកជញ្ជូនត្រូវធ្វើដំណើរដោយប្រុងប្រយ័ត្នដោយសារតែមីនជាច្រើននៅក្នុងដី ។ ជាញឹកញាប់ ក្រុមដឹកជញ្ជូនបានរងគ្រោះ

ដោយសារការដើរជាន់មីនដែលខ្លួនឯងជាអ្នកកប់ ។ សមាជិកក្រុមដឹកជញ្ជូនណាដែលស្លាប់នៅតាមផ្លូវនឹងត្រូវកប់នៅកន្លែងនោះ ហើយអ្នកដែលរងរបួសនឹងត្រូវបញ្ជូនមកមន្ទីរពេទ្យនៅលើភ្នំ ។ ជាទូទៅ ក្នុងរយៈពេលមួយខែម្តង ប្រជាជនម្នាក់ៗត្រូវបានជ្រើសរើសឬស្ម័គ្រចិត្តចូលរួមដឹកជញ្ជូនគ្រាប់ និងសម្ភារៈទៅសមរភូមិមុខ ។

ឱ សាវ៉ាត បានដើរជាន់មីន និងបានបាត់បង់ជើងម្ខាងនៅពេលគាត់ដឹកជញ្ជូនគ្រាប់ទៅឲ្យកងទ័ពនៅសមរភូមិមុខនៅឆ្នាំ១៩៨៧ ។ សាវ៉ាត បានរំឭកអំពីបទពិសោធរបស់គាត់ថា ៖

> *ផ្លូវធ្វើដំណើរនៅលើភ្នំដើម្បីដឹកជញ្ជូនគ្រាប់ទៅសមរភូមិមុខតូចចង្អៀតណាស់ ។ ផ្លូវនេះមានទទឹងប្រហែលកន្លះម៉ែត្រតែប៉ុណ្ណោះ និងជាផ្លូវតែមួយគត់ទៅកាន់សមរភូមិមុខ ។ នៅពេលខ្ញុំទៅដល់សមរភូមិ ហើយប្រគល់គ្រាប់ទៅឲ្យកងទ័ព ខ្ញុំបានធ្វើដំណើរត្រឡប់មកវិញ ។ នៅតាមផ្លូវត្រឡប់មកវិញ ខ្ញុំបានឃើញស្ត្រីចំណាស់ៗ ស្ពាយគ្រាប់ធំៗហើយធ្ងន់នៅលើខ្នង ។ ខ្ញុំបានជៀសទៅម្ខាង ដើម្បីទុកផ្លូវឲ្យស្ត្រីចំណាស់ទាំងនោះដើរ ។ ជាអកុសល មួយជំហានរបស់ខ្ញុំ បេញពីផ្លូវជាន់ចំគ្រាប់មីន ។ នៅពេលដែលមីននោះផ្ទុះមិនត្រឹមតែខ្ញុំដាច់ជើងម្ខាងទេ ក្ដួយប្រុសរបស់ខ្ញុំក៏ត្រូវរបួសដោយសារអំបែងតូចៗដែលខ្ទាតត្រូវ ។ ខ្ញុំចាំថា ខ្ញុំបានប្រាប់ស្ត្រីចំណាស់ទាំងនោះកុំឲ្យដើរទៅក្នុងព្រៃប្រយ័ត្នជាន់ត្រូវមីន ។ ប៉ុន្តែ ខ្ញុំមិននឹកស្មានមីនត្រូវបានកប់នៅក្បែរផ្លូវដើរដ៏តូចនេះសោះ ។ មិនតែប៉ុណ្ណោះ មីននេះគឺត្រូវបានខ្មែរក្រហមគ្នាឯងដែលជាអ្នកដាក់ ។ នៅពេលដែលខ្ញុំដួលទៅលើដី ខ្ញុំបានក្រឡេកមើលជុំវិញខ្លួនខ្ញុំ ហើយបានឃើញមីនជាច្រើនគ្រាប់ផ្សេងទៀត ។ ជាសំណាងល្អខ្ញុំបានដួលទៅលើផ្លូវដើរ ។ បើមិនដូច្នោះទេខ្លួនរបស់ខ្ញុំទាំងមូល ប្រហែលជាខ្ទេចអស់ទៅហើយ ។ ខ្ញុំត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យនៅលើភ្នំដងរែក ។*[១៥៨]




## ការអប់រំ

នៅលើឆ្នាំ១០០៣ មានតែសាលាបឋមសិក្សាមួយប៉ុណ្ណោះ ដែលត្រូវបានបង្កើតឡើងសម្រាប់តែកុមារ ។ ប្រព័ន្ធអប់រំដ៏អន់ខ្សោយនេះ អនុញ្ញាតឲ្យសិស្សរៀនបានត្រឹមតែសរសេរ អាន និងគណិតវិទ្យាជាមូលដ្ឋានតែប៉ុណ្ណោះ ។ តាម៉ុក បានបញ្ជាឲ្យកុមារទាំងអស់ចូលរៀននៅក្នុងសាលា ប៉ុន្តែសាលារៀនមានត្រឹមតែថ្នាក់ទី៤ ។ ការអប់រំអាចដំណើរការទៅបានដោយសារកម្មាភិបាលខ្មែរក្រហមមួយចំនួនតូច បានបម្រើការធ្វើជាគ្រូបង្រៀន ។ ខៀវ នៅ (ក្មួយប្រុសរបស់ តាម៉ុក) , យក់ ហម, លាវ, អឿន, វ៉ុន, ផង់ គឹមឆន និង ញឿន

គឺជាគ្រូបង្រៀននៅពេលនោះ ។ ទោះបីជាកម្មាភិបាលខ្មែរក្រហមទាំងអស់នេះពុំមានចំណេះដឹងផ្នែកគរុកោសល្យគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏អ្នកទាំងនេះបានបង្កើតគណៈកម្មាធិការមួយដើម្បីរៀបរៀងជាសៀវភៅសិក្សាដែលសរសេរដោយដៃ ។ ខ្លឹមសារនៅក្នុងសៀវភៅទាំងនោះ ចេញមកពីចំណេះដឹងរបស់កម្មាភិបាលទាំងនេះ ដែលធ្លាប់បានរៀនសូត្រកាលពីខ្លួននៅសាលា ។ ដោយសារតែកង្វះខាតឯកសារយោងជាច្រើនកម្មាភិបាលខ្មែរក្រហមទាំងនោះបានបកប្រែមេរៀនមួយចំនួនចេញពីសៀវភៅពុម្ពរបស់ថៃ ។ ការអប់រំក៏ទទួលបានការគាំទ្រពីកម្មវិធីជំនួយអន្តរជាតិ ជាពិសេសពីប្រតិបត្តិការជំនួយព្រំដែនរបស់អង្គការសហប្រជាជាតិ ដែលបានបោះពុម្ព និងឧបត្ថម្ភសៀវភៅសិក្សា និងសម្ភារៈសិក្សាផ្សេងទៀតទៅដល់សាលារៀន ។

ពីដំបូង សាលារៀននេះបានបើកថ្នាក់បង្រៀនពីរពេលក្នុងមួយថ្ងៃ ។ ប៉ុន្តែ ដោយសារតែពុំមានថ្នាក់រៀនគ្រប់គ្រាន់ សិស្សអាចរៀនបានតែមួយពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ។ ម៉ោងសិក្សាពេលព្រឹកគឺចាប់ពីម៉ោង៧ដល់ម៉ោង១១ និងពេលថ្ងៃចាប់ពីម៉ោង១ ដល់ម៉ោង៤ ។ កុមារត្រូវរៀន៦ថ្ងៃក្នុងមួយសប្តាហ៍ ពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍ ។ ចំនួនសិស្សក្នុងមួយថ្នាក់ អាចទាបបំផុតគឺពី៥ទៅ៦នាក់ ទៅតាមកម្រិតសិក្សា ។ តាម៉ុក ក៏បានឧបត្ថម្ភសម្លៀកបំពាក់ និងសម្ភារៈផ្សេងៗទៀតទៅដល់សាលារៀននេះ ។

គោលដៅនៃការអប់រំ ត្រូវបានផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងការតស៊ូនយោបាយ និងយោធារបស់ខ្មែរក្រហម ។ ក្រៅអំពីការអប់រំកុមារឲ្យមានជំនាញផ្នែកភាសា និងគណិតវិទ្យាជាមូលដ្ឋាន ការអប់រំក៏ផ្តោតជា ចម្បងទៅលើការឃោសនានយោបាយ ។ កម្មវិធីសិក្សានៅពេលនោះបានបណ្តុះគំនិតកុមារឲ្យស្អប់ខ្ពើម ខឹងសម្បារ និងចង់សងសឹកចំពោះអ្វីដែលខ្មែរក្រហមហៅថា“អាខ្មាំងយួនឈ្លានពាន” ។ កុមារត្រូវបានអប់រំឲ្យយល់ថា វៀតណាម គឺជាអ្នកដែលបានធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសកម្ពុជា ។ ជាងនេះទៅទៀត បញ្ហាដែលទាក់ទងទៅនឹងការស្លាប់រស់របស់ប្រទេសកម្ពុជា ចេញមកតែអំពីការប៉ុនប៉ងរបស់វៀតណាមក្នុងការលេបយកទឹកដីកម្ពុជា ។ នៅក្នុងអំឡុងពេលនោះ កុមារត្រូវបានបង្រៀនឲ្យមើលឃើញកុមារផ្សេង ទៀតទៅតាមនិន្នាការនយោបាយ ដូចជា កូនយួន (សំដៅទៅលើកុមារដែលរស់នៅក្នុងតំបន់ដែលគ្រប់គ្រង ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា) កូនវ៉ា (កុមារដែលរស់នៅក្រោមការគ្រប់គ្រងរបស់រណសិរ្សហ៊្វុនស៊ិនប៉ិច) និងកូនជាតិ

(កុមារដែលនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម) ។

សៀវភៅរៀនអក្សរ ដែលត្រូវបានបោះពុម្ពដោយរបបកម្ពុជាប្រជាធិបតេយ្យ និរទេស សម្រាប់សិស្សថ្នាក់ទី២ (បោះពុម្ពនៅឆ្នាំ១៩៨៧) បានបញ្ចូលមេរៀនជាច្រើន ដែលនិយាយអំពីការឃោសនានយោបាយ និងមនោគមន៍វិជ្ជា ។ ខ្មែរក្រហមបានបំពាក់បំប៉នកុមារឲ្យមាន“មនសិការតស៊ូ” និងស្មារតីជាតិនិយមជ្រុលហួសហេតុ ។ មេរៀនមួយ ដែលមានចំណងជើងថា “ប្រជាជនភូមិខ្ញុំ” មានអត្ថន័យថា ៖

> ចាប់តាំងពីអាខ្មាំងយួនឈ្លានពានទន្ទ្រានកាន់កាប់ទឹកដីកម្ពុជាយើងមក ប្រជាជនភូមិខ្ញុំបានភៀសខ្លួនមករស់នៅឯព្រៃភ្នំ ។ ជីវភាពពេលនោះក្រខ្សត់ ហើយលំបាកវេទនាណាស់ ។ តែប្រជាជនភូមិខ្ញុំ ដាច់ខាតមិនចុះញ៉មអាខ្មាំងយួនឡើយ ។ ក្នុងការរស់នៅប្រចាំថ្ងៃ ប្រជាជនភូមិខ្ញុំចេះសាមគ្គីជួយគ្នាទៅវិញទៅមក ។
>
> មួយថ្ងៃៗ ប្រជាជនភូមិខ្ញុំចេញទៅរកដីកមើមក្តួច ដំឡូងព្រៃ ទំពាំងឬស្សី និងបេះស្លឹកល្ពៅង ស្លឹកច្រេសជាដើម មកផ្សំធ្វើជាម្ហូបអាហារ ។ ជួនពេលខ្លះរកបានពេលខ្លះរកមិនបាន តែបងប្អូនចេះចែករំលែកគ្នាហូបយ៉ាងល្អកល្អឺន ។ បើមានបងប្អូនណាម្នាក់ឈឺថ្កាត់ គេទាំងឡាយជួយឈឺឆ្អាល ជួយរត់រកថ្នាំឫសឈើព្រៃ ។ អ្នកខ្លះជួយថែទាំ ខ្លះជួយជាស្បៀងអាហារខ្លះជួយជាកម្លាំងកាយកម្លាំងចិត្ត ។
>
> ក្រោយមក យើងមានជីវភាពគួរសមហើយ ។ ប្រជាជនភូមិខ្ញុំមានសុខភាពល្អបន្តរឡើងវិញ ។ បងប្អូនបានរួមចំណែកវាយអាខ្មាំងយួនឈ្លានពានជាមួយពួៗកងទ័ពជាតិ យ៉ាងសកម្ម និងក្លៀវក្លា ។ បងប្អូនខ្លះជួយដឹកជញ្ជូនគ្រាប់រំសេវ ស្បៀងអាហារជូនពួៗកងទ័ព ។ បងប្អូនខ្លះទៀតជួយធ្វើចម្រូងខ្នារ សង់មន្ទីរពេទ្យ សង់ឃ្លាំងគ្រាប់ និងសង់សាលាឲ្យកុមាររៀនសូត្រ ។

ទំនៀមទម្លាប់ដ៏ល្អប្រសើរនេះ ធ្វើឲ្យប្រជាជនភូមិខ្ញុំរស់នៅសុខដុមរមនាគ្រប់ពេលវេលា ក្នុងកិត្តិយសថ្លៃថ្នូរ ទោះបីស្ថិតនៅក្នុងសម័យតស៊ូវាយអាខ្មាំងយួនឈ្លានពានវាតទីលេបទឹកដីប្រល័យពូជសាសន៍នេះក៏ដោយ ។[១៥៩]

មេរៀនមួយទៀតមានចំណងជើងថា «បងប្រុសខ្ញុំ» ៖

កាលពីឆ្នាំ១៩៨០ បងប្រុសខ្ញុំមានអាយុ១៥ឆ្នាំ ។ កាលនោះ គាត់រស់នៅជាមួយពុកម៉ែខ្ញុំនៅឯភ្នំក្រវាញ ។ បងប្រុសខ្ញុំជាមនុស្សខ្សស្រាហ៍ព្យាយាម ហើយស្លូតបូត និងសុភាពរាបសារ ។

ព្រលឹមស្រាងៗឡើង បងប្រុសខ្ញុំក្រោកអុជចង្កៀង មើលមេរៀនសាឡើងវិញ ។ មុនទៅសាលារៀន គាត់បោសសម្អាតទីធ្លាជុំវិញផ្ទះ ហើយជួយដងទឹកដាក់ពាងទុកជូនម៉ែប្រើប្រាស់ ។ ល្ងាចពេលត្រឡប់មកពីសាលារៀនវិញ គាត់ជួយស្រោចដំណាំក្បែរៗផ្ទះ ។ ឯថ្ងៃឈប់សម្រាករៀន បងតែងជួយធ្វើការពុកម៉ែ ដូចជាដាំ បន្លែ ស្រោចបន្លែ រកខស ដងទឹក ថែទាំសត្វមាន់ទា ឬជួយមើលថែទាំប្អូនៗជាដើម ។ ពេលយប់មុនសម្រាន្ត គាត់មើលមេរៀន ឬធ្វើកិច្ចការ ដែលលោកគ្រូដាក់ឲ្យធ្វើ ។ ជូនកាលគាត់ជួយបង្រៀនអក្សរខ្ញុំ ។ ខ្ញុំបងប្រុសខ្ញុំចូលចិត្តអានរឿង ដែលនិយាយពីវីរភាពរបស់ប្រជាជនកម្ពុជារបស់ពូៗកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ ក្នុងការតស៊ូវាយអាខ្មាំងយួនឈ្លានពានឲ្យខ្ញុំស្តាប់ ។

លុះដល់ឆ្នាំ១៩៨៣ បងប្រុសខ្ញុំចូលធ្វើកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ ។ ឆ្នាំ១៩៨៦ បងមានភារកិច្ចទៅធ្វើការងារជាមួយប្រជាជននៅក្នុងឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ ដើម្បីប្រមូលកម្លាំងវាយអាខ្មាំងយួនឈ្លានពាន រំដោះភូមិ ឃុំ ស្រុក និងរំដោះប្រទេសកម្ពុជាទាំងមូល ។

*ខ្ញុំស្រលាញ់ និងគោរពបងប្រុសខ្ញុំណាស់*[160]

## ការព្យាបាលជំងឺ

ការព្យាបាលជំងឺនៅភ្នំ១០០៣ មានលក្ខណៈជាការព្យាបាលបឋម ហើយផ្ដល់ការព្យាបាលសម្រាប់តែរបួស និងជំងឺធម្មតាតែប៉ុណ្ណោះ ។ ជាលទ្ធផល ប្រជាជន និងកងទ័ពស្ថិតនៅក្នុងស្ថានភាព ដែលងាយនឹងរងគ្រោះពីគ្រោះថ្នាក់ និងជំងឺណាស់ ។ ប្រជាជនពុំទទួលបានការព្យាបាលជំងឺត្រឹមត្រូវទេ ។ បុគ្គលិកពេទ្យត្រូវបានជ្រើសរើសចេញពីប្រជាជននៅលើភ្នំ ។ បុគ្គលិកពេទ្យមួយចំនួនទទួលបានការបណ្ដុះបណ្ដាលនៅលើភ្នំ១០០៣ ។ បុគ្គលិកពេទ្យមួយចំនួនទៀត ត្រូវបានបញ្ជូនឲ្យទៅទទួលការបណ្ដុះបណ្ដាលនៅប្រទេសថៃ ជាមួយវេជ្ជបណ្ឌិតថៃ និងចិន ដោយមានជំនួយពីអ្នកបកប្រែភាសាខ្មែរ ។[161] ការបណ្ដុះបណ្ដាលប្រព្រឹត្តទៅដោយការអនុវត្តជាក់ស្ដែង ។ បុគ្គលិកពេទ្យត្រូវបានបណ្ដុះបណ្ដាលជំនាញព្យាបាលបឋមដូចជាការលាងរបួស និងការព្យាបាលជំងឺគ្រុនចាញ់ ។[162] បុគ្គលិកពេទ្យស្រីមួយចំនួនត្រូវបានបណ្ដុះបណ្ដាលឲ្យទៅជាឆ្មប ។

បន្ទាប់ពីបញ្ចប់វគ្គបណ្ដុះបណ្ដាល បុគ្គលិកពេទ្យភេទប្រុសត្រូវបានបញ្ជូនឲ្យទៅជាមួយកងទ័ព ដើម្បីច្បាំងជាមួយវៀតណាមនៅតាមសមរភូមិមុខ ។ មន្ទីរពេទ្យទទួលព្យាបាលកងទ័ពរងរបួសពី៥ ទៅ៦នាក់ជារៀងរាល់ថ្ងៃ ។[163] ដើម្បីសម្រួលដល់ការព្យាបាលជំងឺ និងសង្គ្រោះកងទ័ពរបួស ដែលកាន់តែកើនឡើងជារៀងរាល់ថ្ងៃ ខ្មែរក្រហមនៅភ្នំ១០០៣ បាន

ណុប សុភា ដែលជាអតីតសិស្សពេទ្យមួយរូបនៅភ្នំ១០០៣ បានរំឭកអំពីការសិក្សាវិជ្ជាពេទ្យរបស់គាត់នៅប្រទេសថៃថា ៖

*ការសិក្សាមិនមានរយៈពេលរហូតដល់ទៅមួយឆ្នាំទេ ។ ឧទាហរណ៍ មួយខែមាន៣០ថ្ងៃ ។ យើងសិក្សាទ្រឹស្ដី១០ថ្ងៃ អនុវត្តជាក់ស្ដែង១០ថ្ងៃ ហើយ១០ថ្ងៃទៀតរៀនភាសា ។ ដូចគ្នាដែរ ក្រុមនីមួយៗមានសមាជិក៣០នាក់ ។ យើងបានចែកវេនគ្នាចម្អិនម្ហូប ។ យើងបានប្រើបច្ចេកទេសពេទ្យ ដើម្បីព្យាបាលទាំងប្រជាជន និងកងទ័ព ។*

បង្កើតមន្ទីរពេទ្យជាច្រើនកន្លែងដែល រួមមានពេទ្យ១០០៣ ពេទ្យ៧២ និងពេទ្យ ១៣ ។ ខឿន និង ខាល គឺជាប្រធានមន្ទីរ ពេទ្យ១៣ ។ ខន និងក្រោយមក លន គឺ ជាប្រធានមន្ទីរពេទ្យ៧២ ។ មន្ទីរពេទ្យត្រូវ បានប្តូរទីតាំងពីកន្លែងមួយទៅកន្លែងមួយទៀត អាស្រ័យទៅលើស្ថានភាពនៅសមរភូមិមុខ ។

## ការរៀបមង្គលការ

ខ្មែរក្រហមមានគោលនយោបាយជំរុញឲ្យមានការរៀបការ ដែលជាមធ្យោបាយមួយក្នុងការបង្កើនកងទ័ពនៅក្នុំ១០០៣ តាមរយៈចំណងគ្រួសារ ដែលអាចទប់ស្កាត់កុំឲ្យមានការផ្តាច់ខ្លួនចូលទៅរដ្ឋាភិបាល ។ ការរៀបការមិនត្រូវបានបង្ខំនោះទេ ប៉ុន្តែប្រជាជនក៏ពុំមានឱកាសច្រើននៅក្នុងការជ្រើសគូស្រករ ឬស្វែងរកជម្រើសដែលប្រសើរជាងបានដែរ ។ បញ្ហាគ្រប់យ៉ាង ដែលរួមទាំងការរៀបការផង ស្ថិតនៅក្នុងការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំ ។ កងទ័ពអាចស្នើសុំរៀបការជាមួយនារីនៅក្នុងជំរំបាន ។ ប៉ុន្តែ នារីមួយចំនួនមិនពេញចិត្តចំពោះគូស្រកររបស់ខ្លួននោះឡើយ ។ ជាទូទៅនារីយល់ឃើញថា ការមានស្វាមី ដែលមិនអាចផ្តល់ភាពកក់ក្តៅក្នុងគ្រួសារ ប្រសើរជាងការរស់នៅតែឯង ។[១៦៤] នារីមួយចំនួនមិនពេញចិត្តចំពោះការបញ្ជាឲ្យរៀបការជាមួយជនពិការ ប៉ុន្តែនារីទាំងនោះមិនហ៊ានបដិសេធ ។[១៦៥] បន្ទាប់ពីរៀបការរួចគូស្វាមីភរិយាទាំងពីរសង់ផ្ទះខ្ទមមួយ ដែលមានទំហំ៣ម៉ែត្របួនជ្រុងធ្វើអំពីឬស្សី និងដំបូលប្រក់ស្បូវ ។

ពីដំបូង ពិធីរៀបមង្គលការត្រូវបានធ្វើឡើងជាក្រុមដូចគ្នាទៅនឹងពិធីរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ទោះបីជាចំនួនគូមានតិចជាងក៏ដោយ ។ ក្រោយមកពិធីរៀបមង្គលការតាមបែបប្រពៃណីខ្មែរត្រូវបានអនុញ្ញាត ។

ចាន់ នឿន ធ្វើការនៅក្នុងកងដឹកជញ្ជូន ហើយបានរៀបការនៅឆ្នាំ១៩៨០ ។ ពិធីរៀបមង្គលការរបស់គាត់មាន៨គូ ។ កងទ័ព និងកម្មាភិបាលនៅក្នុងកងរបស់គាត់បានមកចូលរួមពិធីរៀបមង្គលការនោះ ។[១៦៦] ហាប់ ហេន ដែលជាស្ត្រីម្នាក់ទៀត ដែលបានរៀបការនៅលើភ្នំ១០០៣ បាននិយាយថា “នៅពេលនោះ យើងមិនដឹងថា ស្នេហាមានន័យថាម៉េចនោះទេ ។ យើងមិនដែលចាប់អារម្មណ៍ទៅលើមនុស្សប្រុសផង ។”[១៦៧] ហាប់ ហេន បានរំឭកអំពីថ្ងៃរៀបមង្គលការរបស់គាត់ថា ៖

> *តា ញឹម គឺជាចាស់ទុំដែលបានរៀបចំមង្គលការឲ្យយើង ។ ពិធីរៀបមង្គលការត្រូវបានធ្វើឡើងនៅប្រហែលម៉ោងពារសៀល ។ នៅថ្ងៃខ្ញុំរៀបការមាន១១គូ ។ នៅពេលនោះយើងពុំមានតុប្កៅអីទេ ។ ទាំងប្រុសទាំងស្រីនាំគ្នាអង្គុយនៅលើអង្កត់ឈើ ដែលអាចរកបាននៅក្បែរនោះ ។ នៅក្នុងពិធីរៀបមង្គលការ ប្រធានកងបានប្រកាសថា យើងទាំងពីរនាក់បានក្លាយទៅជាប្ដីប្រពន្ធ និងបានណែនាំ យើងឲ្យប្រឹងប្រែងធ្វើការងារ និងមិនត្រូវរត់ចោលចលនាខ្មែរក្រហម ។ យើងបានទះដៃអបអរសាទរ ហើយបន្ទាប់មក ពិធីជប់លៀងតូចមួយត្រូវបានរៀបចំឡើង ដែលមានម្ហូបអាហារដូចជា គុយទាវ ត្រីខកំប៉ុង ទឹកដោះគោ និងនំឈូប ។ នេះគឺជាពិធីរៀបមង្គលការរបស់យើងនាពេលនោះ ។*[168]

ចាប់ពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៨០មក ពិធីរៀបមង្គលការនៅភ្នំ១០០៣ ត្រូវបានរៀបចំឡើងប្រសើរជាងមុន ។ ទោះបីជាពុំមានសម្លៀកបំពាក់ប្រពៃណី ព្រះសង្ឃ ឬចម្រៀងប្រពៃណីក៏ដោយ ក៏អាចារ្យ[169] ត្រូវបានអនុញ្ញាតឲ្យរៀបចំពិធី ហើយពិធីតាមប្រពៃណីមួយចំនួន ដូចជាពិធីបង្វិលពពិលក៏ត្រូវបានអនុញ្ញាតដែរ ។[170] កម្មវិធីរាំជាមួយនឹងចម្រៀងរបស់ ស៊ិន ស៊ីសាមុត[171] ត្រូវបានរៀបចំឡើងសម្រាប់ពិធីជប់លៀងជាមួយនឹងអាហារពីរបីមុខ និងបង្អែម ។[172] សាច់ញាតិ និងមិត្តភក្តិរបស់កូនកម្លោះក្រមុំក៏ចូលរួមនៅក្នុងពិធីមង្គលការនេះដែរ ។ ចំណងដៃចាប់ពី១០ទៅ១០០បាត (រូបិយប័ណ្ណថៃ) ។ ទោះបីជា តាម៉ុក មិនបានចូលរួមនៅក្នុងពិធីរៀបមង្គលការក៏ដោយ ក៏ តាម៉ុក តែងតែឧបត្ថម្ភអង្ករ និងសម្ភារៈផ្ទះបាយមួយចំនួនដល់គូស្រករថ្មី ។[173]

## សេចក្ដីបញ្ចប់

ភ្នំ១០០១ និងភ្នំ១០០៣ ដែលស្ថិតនៅលើភ្នំដងរែក គឺជាតំបន់កាន់កាប់ ដ៏សំខាន់របស់ខ្មែរក្រហម និងត្រូវបានប្រើប្រាស់ជាទីបញ្ជាការយោធាជាយុទ្ធសាស្ត្រ សម្រាប់ប្រតិបត្តិការយោធានៅទូទាំងប្រទេស ។ មូលដ្ឋានយោធាទាំងពីរនេះ អនុញ្ញាតឲ្យកម្លាំង

បរាជ័យសេសសល់របស់ខ្មែរក្រហមរៀបចំឡើងវិញនូវយុទ្ធសាស្ត្រ និងរចនាសម្ព័ន្ធយោធារបស់ខ្លួន ។ មូលដ្ឋានទាំងនេះ គឺជាទីតាំងជាយុទ្ធសាស្ត្រសម្រាប់ការរស់រានរបស់ខ្មែរក្រហម និងសម្រាប់ការតស៊ូឡើងវិញ ។ មូលដ្ឋានទាំងនេះ ក៏ជាសមរភូមិប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ជាងនេះទៅទៀតមូលដ្ឋានទាំងនេះ ក៏ត្រូវបានប្រើប្រាស់ជាទីតាំងដ៏សំខាន់សម្រាប់ទទួលជនភៀសខ្លួនខ្មែរ ។

ជីវិតរស់នៅលើភ្នំដងរែកមានការលំបាកទាំងផ្លូវកាយ និងស្មារតី ។ កងទ័ពត្រូវបានបញ្ជូនទៅកាន់សមរភូមិ ចំណែកប្រជាជនសាមញ្ញ ជួយកងទ័ពតាមរយៈការដឹកជញ្ជូនស្បៀងអាហារ គ្រឿងសព្វាវុធ និងចម្រូងទៅសមរភូមិមុខ ។

ដោយសារតែមានការគំរាមកំហែងពីសង្គ្រាមជាប្រចាំ ប្រជាជនមិនដែលស្គាល់ជីវិតរស់នៅសាមញ្ញទេ ។ ផ្ទុយទៅវិញ គ្រប់ក្រុមគ្រួសារទាំងអស់ត្រូវបង្ខំចិត្តរស់នៅដោយស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ចចំពោះសង្គ្រាម និងការតស៊ូដើម្បីជាតិ ។ នៅក្នុងស្ថានភាពសឹកបែបនេះ កុមារមិនមានឱកាសទទួលបានការអប់រំត្រឹមត្រូវទេ ។ ដូចគ្នាដែរ ប្រជាជនក៏មិនទទួលបានការថែទាំសុខភាពឲ្យបានត្រឹមត្រូវដែរ ។ មេដឹកនាំខ្មែរក្រហមព្យាយាមខបត្តម្ភប្រជាជន ដើម្បីកុំឲ្យកងទ័ពព្រួយបារម្ភអំពីសមាជិកគ្រួសាររបស់ខ្លួនដែលនៅខាងក្រោយ ។ ទោះជាយ៉ាងនេះក្តី ភាពភ័យខ្លាច ជាប្រចាំ និងជីវិតរស់នៅប្រកបដោយភាពវឹកវរ នៅតែតាមញាំញីប្រជាជន និងកងទ័ពជាប់ជានិច្ច ។ រឿងរ៉ាវអំពីមនុស្សដើរជាន់មីន និងកងទ័ពទទួលរងរបួសបានក្លាយទៅជាព័ត៌មានប្រចាំថ្ងៃ ដែលមនុស្សគ្រប់រូបបានដឹងជាមុនថានឹងកើតឡើង ។ មិនមាននរណាម្នាក់ដឹងច្បាស់ថា ថ្ងៃអនាគតរបស់ខ្លួននឹងក្លាយទៅជាយ៉ាងណានោះទេ ។

ជីវិតក៏ជួបការលំបាកដែរ ដោយសារតែតម្រូវការជាប្រចាំ ក្នុងការបញ្ជូនកងទ័ពឲ្យទៅធ្វើការនៅខាងក្នុងប្រទេស ។ កងទ័ពទាំងនេះត្រូវបានបញ្ជូនទៅស្ទើរតែគ្រប់ខេត្តទាំងអស់ នៅក្នុងប្រទេសកម្ពុជាដើម្បីធ្វើការឃោសនា និងធ្វើវិទ្ធង្សនានៅតាមតំបន់ដាច់ស្រយាល ។ កងទ័ពត្រូវរស់នៅឆ្ងាយពីប្រពន្ធ និងកូនរបស់ខ្លួនក្នុងរយៈពេលយូរ ។ ដោយសារតែត្រូវរស់នៅឆ្ងាយពីមូលដ្ឋាន កងទ័ពទាំងនោះត្រូវពឹងផ្អែកលើខ្លួនឯងដើម្បីរស់ ។ ស្ថានភាពលំបាកបែបនេះ បានបង្ខំឲ្យកងទ័ពមួយចំនួនប្រព្រឹត្តអំពើឆក់ប្លន់ និងសម្លាប់

មនុស្ស ជាពិសេសនៅតាមភូមិដាច់ស្រយាលរបស់កម្ពុជា ។ ជាទូទៅ កងទ័ពអាចត្រឡប់មកកងពលរបស់ខ្លួនវិញនៅលើភ្នំ នៅក្នុងរយៈពេល១ ឬ២ឆ្នាំ បន្ទាប់ពីក្រុមថ្មីត្រូវបានបញ្ជូនទៅជំនួស ។

ជំពូក៩

# អន្លង់វែង ៖ តំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម

## សេចក្តីផ្តើម

បន្ទាប់ពីរស់នៅលើភ្នំដងរែកអស់រយៈពេល១០ឆ្នាំ កងទ័ពខ្មែរក្រហមដែលនៅសេសសល់ក្រោមការដឹកនាំរបស់ តាម៉ុក នៅភ្នំ១០០៣ ដណ្តើមកាន់កាប់តំបន់អន្លង់វែងបាន នៅចុងឆ្នាំ១៩៨៩ ។ នៅដើមឆ្នាំ១៩៩០ តាម៉ុក បានសម្រេចចិត្តបញ្ជូនប្រជាជនទាំងអស់ នៅក្នុងជំរំជនភៀសខ្លួនក្នុងទឹកដីថៃ និងនៅមូលដ្ឋានយោធា លើភ្នំដងរែកមកកាន់តំបន់អន្លង់វែង ។ មកដល់អន្លង់វែង ប្រជាជនចាប់ផ្តើមសាងសង់ផ្ទះ និងធ្វើស្រែចម្ការ ហើយមេដឹកនាំខ្មែរក្រហមផ្តោតការយកចិត្តទុកដាក់ទៅលើការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់នោះ ។ នៅក្នុងរយៈពេលពីរបីឆ្នាំដំបូងនៃការកាន់កាប់តំបន់អន្លង់វែង តាម៉ុក បានផ្តួចផ្តើមគម្រោងសាងសង់ជាច្រើននៅក្នុងតំបន់ដែលរួមមានការសាងសង់ អាងស្តុកទឹកនៅបឹងអន្លង់វែង និងការសាងសង់ផ្លូវថ្នល់ស្ពាន ឃ្លាំងផ្ទុកសម្ភារៈ ឃ្លាំងផ្ទុកគ្រឿងសព្វាវុធ សាលារៀន មន្ទីរពេទ្យ និងទីបញ្ជាការកងទ័ពជាច្រើនទៀត ។ ដោយសារតែកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍតំបន់នេះ តាម៉ុក ទទួលបានប្រជាប្រិយភាពយ៉ាងខ្លាំង នៅក្នុងចំណោមប្រជាជនដែលរស់នៅអន្លង់វែង ។

ទោះបីជាសហគមន៍ខ្មែរក្រហមមួយនេះ ហាក់ទទួលបានលក្ខខណ្ឌរស់នៅប្រសើរជាងមុន ចលនាខ្មែរក្រហមទាំងមូលបានប្រឈមមុខនឹងការផ្តាច់ជំនួយពីបរទេសយ៉ាងធ្ងន់ដែលបានជះឥទ្ធិពលយ៉ាងខ្លាំង ដល់លទ្ធភាពរបស់តំបន់អន្លង់វែង នៅក្នុងការទ្រទ្រង់ការរស់រានរបស់សហគមន៍ និងយុទ្ធសាស្ត្រការពារខ្លួន ។ ដោយត្រូវបានចងដោយសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស ខ្មែរក្រហមត្រូវបានតម្រូវឲ្យចូលរួមនៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ អនុញ្ញាតឲ្យកងកម្លាំងថែរក្សា សន្តិភាពរបស់អង្គការសហប្រជាជាតិ គ្រប់គ្រងទៅលើតំបន់កាន់កាប់របស់ខ្លួន និងទម្លាក់អាវុធ ។ ទោះជាយ៉ាងនេះក្តី ខ្មែរក្រហមមិនដែលបំពេញតាមកាតព្វកិច្ចទាំងអស់នេះទេ ។ មិនយូរប៉ុន្មាន ខ្មែរក្រហមហាក់ដូចជាស្ថិតនៅក្នុងភាពឯកោកាន់តែខ្លាំងឡើង ។

មេដឹកនាំខ្មែរក្រហមជឿជាក់ថា ខ្លួនមានហេតុផលនៅក្នុងការធ្វើពហិការមិនចូលរួមការបោះឆ្នោត ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ។ ជាពិសេសដោយឈរទៅលើគោលដៅស្ម័យការពារ ខ្មែរក្រហមមានការរំពឹងទុកមួយដែលគ្មានភាពប្រាកដនិយម ដែលថាសង្គ្រាមនឹងធានាបាននូវភាពស្មើគ្នាផ្នែកនយោបាយជាមួយរាជរដ្ឋាភិបាលកម្ពុជាដែលទើបតែជាប់ឆ្នោតថ្មី ។

ប្រទេសចិន ថៃ និងសហរដ្ឋអាមេរិកបានផ្តាច់ជំនួយជាផ្លូវការពីក្រុមខ្មែរក្រហម ។ វៀតណាមបានដកកងទ័ពចេញពីទឹកដីកម្ពុជា ។ ប្រទេសកម្ពុជាសម្រេចបាននូវការបោះឆ្នោតប្រកបដោយប្រជាធិបតេយ្យលើកដំបូង នៅក្នុងអំឡុងពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ។ នៅខាងក្រៅប្រទេសកម្ពុជា សង្គ្រាមត្រជាក់រវាងសហរដ្ឋអាមេរិក និងសហភាពសូវៀតបានបញ្ចប់ ។ ការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយចាស់ រវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត រវាងចិន និងវៀតណាម និងរវាងសហរដ្ឋអាមេរិក និងវៀតណាមក៏បានបញ្ចប់ដែរ ។ ជារួមបរិយាកាសភូមិសាស្ត្រនយោបាយដែលបានទ្រទ្រង់ ចលនាខ្មែរក្រហមអស់រយៈពេលជាច្រើនឆ្នាំបានផ្លាស់ប្តូរនៅទីបញ្ចប់ ។ ទោះជាយ៉ាងនេះក្តី មេដឹកនាំខ្មែរក្រហមនៅមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការបោះបង់ចោលសង្គ្រាមនៅឡើយ ។

ទោះបីជាមានការផ្លាស់ប្តូរបរិយាកាសនយោបាយអន្តរជាតិក៏ដោយ ក៏តំបន់អន្លង់វែងនៅតែអាចទ្រទ្រង់ខ្លួនឯងបានដដែល ។ មន្ត្រីរដ្ឋាភិបាល និងអ្នកជំនួញថៃ ទទួលបានផលប្រយោជន៍យ៉ាងច្រើនពីការធ្វើជំនួញឆ្លងដែនជាមួយអន្លង់វែង ជាពិសេសទៅលើជំនួញឈើ ។ ដោយសារហេតុនេះ រដ្ឋាភិបាលថៃបានបន្តជួយសម្រួល និងធ្វើជំនួញដោយសម្ងាត់ជាមួយខ្មែរក្រហម ។ ខ្មែរក្រហមមានលទ្ធភាពអាចរក្សាបាននូវលំហូរសាច់ប្រាក់ និងប្រភពធនធានទាំងឡាយ ដើម្បីការពារតំបន់អន្លង់វែងរហូតដល់ដង្ហើមចុងក្រោយ ។

ប្រជាជននៅតំបន់អន្លង់វែងហាក់ដូចជាចង់បានការផ្សះផ្សាជាតិ ជាងការបន្តធ្វើសង្គ្រាម ។ សង្គ្រាម និងការរស់នៅក្នុងព្រៃអស់ជាច្រើនទសវត្សរ៍បានសម្លាប់ជីវិតប្រជាជនអស់ជាច្រើន ។ ទោះបីជាប្រជាជននៅអន្លង់វែងមានបំណងប្រាថ្នារួម នៅក្នុងការបញ្ចប់សង្គ្រាមក៏ដោយ ក៏ប្រជាជនទាំងអស់នោះពុំមានឥទ្ធិពលទៅលើយុទ្ធសាស្ត្ររួមរបស់ខ្មែរក្រហមនោះទេ ។ ប្តីត្រូវបានបញ្ជូនឲ្យទៅធ្វើសង្គ្រាមឈ្លបនៅខាងក្នុងប្រទេស

នៅពេលដែលប្រពន្ធ និងសមាជិកគ្រួសារដទៃទៀត ត្រូវគាំទ្រសមរភូមិមុខ តាមរយៈការដឹកជញ្ជូនស្បៀងអាហារ និងគ្រឿងសព្វាវុធទៅកាន់សមរភូមិ ។

ទោះបីជាមេដឹកនាំខ្មែរក្រហមនៅតែរឹងរូសចង់បន្តសង្គ្រាមក៏ដោយ ក៏ប្រជាជនគ្រប់រូបបានមើលឃើញពីស្ថានភាពអន់ថយរបស់ចលនាខ្មែរក្រហម ។ នៅទីបញ្ចប់ ជម្លោះផ្ទៃក្នុងការបាត់បង់តំបន់គ្រប់គ្រងជាបន្តបន្ទាប់ និងការបាត់បង់ធនធាន និងការគាំទ្រ បានធ្វើឲ្យមេដឹកនាំខ្មែរក្រហមចុះខ្សោយ ។ ដោយទទួលរងឥទ្ធិពលពីការផ្តាច់ខ្លួនរបស់ខ្មែរក្រហមនៅតំបន់ប៉ៃលិន និងម៉ាឡៃ ក៏ដូចជាតំបន់កាន់កាប់ជាច្រើនផ្សេងទៀតការបែកបាក់គ្នានៅក្នុងជួរមេដឹកនាំខ្មែរក្រហមនៅអន្លង់វែង កាន់តែរង្គោះរង្គើខ្លាំងឡើង ។ ជាងនេះទៅទៀត តំបន់អន្លង់វែងត្រូវឯកោទាំងស្រុង និងបានទទួលឋានៈជាតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហមដែលពុំមានក្តីសង្ឃឹម ។

ជម្លោះផ្ទៃក្នុងបានឈានដល់កម្រិតកំពូល នៅពេលដែល ប៉ុល ពត បញ្ជាឲ្យសម្លាប់ សុន សេន ដែលបន្ទាប់មក មានការប្រយុទ្ធគ្នារយៈពេល៩ថ្ងៃ រវាងកម្លាំង ដែលស្មោះនឹង ប៉ុល ពត និងកម្លាំងរបស់ តាម៉ុក ។ ជម្លោះនេះបានបញ្ចប់ នៅពេលដែល តាម៉ុក បានទទួលជ័យជម្នះ ចាប់ខ្លួន និងកាត់ទោស ប៉ុល ពត ។ នៅទីបំផុត ប៉ុល ពត បានស្លាប់នៅពេលរត់គេចខ្លួនពីការវាយប្រហាររបស់កងយោធពលខេមរភូមិន្ទ ។

បន្ទាប់ពី ប៉ុល ពត ស្លាប់ទៅ ការដឹកនាំចលនាខ្មែរក្រហមរបស់ តាម៉ុក មានអាយុបានតែ១ឆ្នាំប៉ុណ្ណោះ បន្ទាប់ពីមេទ័ពរបស់គាត់បានបះបោរប្រឆាំងនឹងគាត់ ហើយបានផ្តាច់ខ្លួនចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ នៅទីបញ្ចប់ អន្លង់វែងត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងរាជរដ្ឋាភិបាលកម្ពុជា នៅចុងឆ្នាំ១៩៩៨ ដែលសមាហរណកម្មនេះទទួលបានការស្វាគមន៍ពីគ្រប់ភាគីទាំងអស់ ។

## ចុងបញ្ចប់នៃសង្គ្រាមត្រជាក់

ការឡើងកាន់អំណាច និងដួលរលំនៃចលនាខ្មែរក្រហមមានទំនាក់ទំនងយ៉ាងស្មុគស្មាញជាមួយនឹងបញ្ហាពិភពលោក ។ ដូច្នេះ ដើម្បីសិក្សាអំពីថ្ងៃចុងក្រោយនៃចលនាខ្មែរក្រហមនៅក្នុងបរិបទនេះ វាមានសារៈសំខាន់ក្នុងការពិនិត្យមើលទៅលើឥទ្ធិពលក្នុងតំបន់ និងពិភពលោក និងថាតើឥទ្ធិពលទាំងនេះដើរតួដូចម្តេចខ្លះមកលើ ដំណាក់ចុងក្រោយនៃ

ចលនាខ្មែរក្រហម ។

នៅក្នុងអំឡុងពេលនៃសង្គ្រាមលោកលើកទីពីរ ការប្រកួតប្រជែងនៅក្នុងតំបន់ និងនៅលើពិភពលោករវាងសហរដ្ឋអាមេរិក សហភាពសូវៀត ចិន និងវៀតណាម មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ជាមួយនឹងបញ្ហាកម្ពុជា ។ ដោយជាប់នៅក្នុងការប្រកួតប្រជែងអំណាចជាសាកលជាមួយសហភាពសូវៀត សហរដ្ឋអាមេរិកបានចំណាយធនធានសេដ្ឋកិច្ច និងយោធា ដើម្បីចូលរួមប្រយុទ្ធនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទីពីរ (ឬសង្គ្រាមវៀតណាម) ។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងនេះ ត្រូវបានធ្វើឡើងក្នុងគោលដៅជាយុទ្ធសាស្ត្រក្នុងការទប់ស្កាត់ការរីករាលដាលនៃលទ្ធិកុម្មុយនីស្តក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងនេះទទួលបានលទ្ធផលផ្ទុយទៅវិញនៅទីបញ្ចប់ ។ សង្គ្រាមនេះគ្រាន់តែអាចបង្អាក់ការរួបរួមគ្នាឡើងវិញរបស់វៀតណាម និងបានសម្រួលដល់ការឡើងកាន់អំណាចរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ ។

នៅក្នុងអំឡុងពេលនៃសង្គ្រាមឥណ្ឌូចិនលើកទីពីរ លទ្ធិកុម្មុយនីស្តបានគ្របដណ្តប់មកលើស្ទើរតែឥណ្ឌូចិនទាំងមូល ។ ប្រទេសវៀតណាម ឡាវ និងកម្ពុជាត្រូវបានគ្របដណ្តប់ដោយឥទ្ធិពលកុម្មុយនីស្ត ដែលបានទាញយកប្រយោជន៍ និងទទួលឥទ្ធិពលពីការប្រកួតប្រជែងជាសាកល រវាងសហរដ្ឋអាមេរិក សហភាពសូវៀត និងចិន ។ ទោះបីជាសហភាពសូវៀត និងចិន ប្រកាន់យកលទ្ធិកុម្មុយនីស្តដូចគ្នា ក៏ដោយ ក៏ភាពមិនចុះសម្រុងគ្នាផ្នែកមនោគមន៍វិជ្ជា បូរណភាពទឹកដី និងសេដ្ឋកិច្ច បានធ្វើឲ្យទំនាក់ទំនងរវាងប្រទេសទាំងពីរធ្លាក់ទៅក្នុងស្ថានភាពធ្ងន់ក្នុងរយៈពេលយូរ ។

ការបែកបាក់គ្នារវាងចិន និងសូវៀត គឺជាផ្នែកមួយយ៉ាងសំខាន់ ដែលបានជះឥទ្ធិពលទៅលើភូមិសាស្ត្រនយោបាយនៅអាស៊ីអាគ្នេយ៍ ។ ខ្មែរក្រហមដែលខ្លាចឥទ្ធិពលរបស់វៀតណាមបានចងសម្ព័ន្ធភាពជាមួយចិន ។ វៀតណាមដែលតែងតែសង្ស័យអំពីការជ្រៀតជ្រែករបស់ចិន បានចងសម្ព័ន្ធភាពជាមួយសហភាពសូវៀត ។ នៅពេលដែលកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលគាំទ្រដោយវៀតណាម បានវាយផ្តួលរំលំកម្លាំងខ្មែរក្រហមនៅឆ្នាំ១៩៧៩ ចិនបានឆ្លើយតបទៅវិញ ដោយការវាយកាន់កាប់ផ្នែកមួយនៃប្រទេសវៀតណាមក្នុងរយៈពេលមួយខ្លី ។

ការតស៊ូរវាងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងវៀតណាម ដែល

គាំទ្រដោយសហភាពសូវៀត ជាមួយនឹងកងទ័ពខ្មែរក្រហមដែលគាំទ្រដោយចិន ត្រូវបានស្គាល់ថាជាសង្គ្រាមឥណ្ឌូចិនលើកទីបី (ឬសង្គ្រាមរវាងកម្ពុជា និងវៀតណាម) ។[១៧៤]

នៅពេលត្រូវបានបណ្តេញចេញពីអំណាច ខ្មែរក្រហមនៅតែបន្តស្វែងរកជំនួយពីប្រទេសចិន ។ ចំណែកឯវៀតណាម និងរដ្ឋាភិបាលកម្ពុជាដែលទើបតែត្រូវបានបង្កើតថ្មីសាធារណរដ្ឋប្រជាមានិតកម្ពុជា បានស្វែងរកជំនួយពីសហភាពសូវៀត ។ សហរដ្ឋអាមេរិក និងបស្ចិមប្រទេសយល់ឃើញថា ការវាយចូលរបស់វៀតណាមមកក្នុងប្រទេសកម្ពុជា គឺជាការឈ្លានពានដែលមិនធ្លាប់កើតមានពីមុនមកទៅលើរដ្ឋអធិបតេយ្យមួយ ។ សហរដ្ឋអាមេរិកបានគាំទ្រនៅក្នុងកម្រិតមួយ ទៅលើការតស៊ូរបស់ខ្មែរក្រហម ដើម្បីគ្រប់គ្រងប្រទេសកម្ពុជាឡើងវិញ ។

នៅក្នុងពេលជាមួយគ្នានោះ សហរដ្ឋអាមេរិកក៏បានមើលឃើញឱកាសមួយនៅក្នុងការធ្វើឲ្យវៀតណាម ដែលជាអតីតសត្រូវរបស់ខ្លួន និងសហភាពសូវៀត ដែលជាអ្នកឧបត្ថម្ភគាំទ្រវៀតណាមចុះខ្សោយ ។ នៅក្នុងអំឡុងពេលនៃសង្គ្រាមឥណ្ឌូចិនលើកទីបី សហរដ្ឋអាមេរិកភាគច្រើន មិនមានវត្តមានកងទ័ពនៅអាស៊ីអាគ្នេយ៍ទេ ។ ទោះបីជាឥទ្ធិពលរបស់សហរដ្ឋអាមេរិកបានចុះខ្សោយនៅតំបន់នេះក្តី ក៏សហរដ្ឋអាមេរិកនៅតែបន្តស្វែងរកមធ្យោបាយ ដើម្បីប្រឈមទៅនឹងការពង្រីកឥទ្ធិពលរបស់សហភាពសូវៀតនៅក្នុងតំបន់នេះ ។ បន្ទាប់ពីទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងចិនត្រឡប់ទៅរកភាពប្រក្រតីឡើងវិញ សហរដ្ឋអាមេរិកបានសហការជាមួយចិន នៅក្នុងការផ្តល់ការគាំទ្រដោយសម្ងាត់ដល់កម្លាំងរបស់ខ្មែរក្រហម និងកម្លាំងទាំងឡាយណាដែលប្រឆាំងទៅនឹងវៀតណាម និងរដ្ឋាភិបាលកម្ពុជាដែលទើបតែបង្កើតថ្មី ។ ដូច្នេះចាប់ពីឆ្នាំ១៩៧៩ រហូតមកពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ខ្មែរក្រហមទទួលបានការឧបត្ថម្ភគាំទ្រពីបស្ចិមប្រទេស ចិន និងថៃ ។

នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ស្ថានភាពនយោបាយក្នុងតំបន់ និងពិភពលោកបាននាំទៅដល់ការកាត់បន្ថយជំនួយផ្នែកធនធាន និងការទូតយ៉ាងគំហុកពីចលនាខ្មែរក្រហម ។

ចាប់តាំងពីឆ្នាំ១៩៨០មក មហាសន្និបាតអង្គការសហប្រជាជាតិ បានបោះឆ្នោតជាច្រើនដងដែលតម្រូវឲ្យដកកម្លាំងបរទេសទាំងអស់ចេញពីប្រទេសកម្ពុជា ។[១៧៥] ទោះជាយ៉ាងនេះក្តី ការគំរាមកំហែងជាបន្តអំពីលទ្ធភាពដែលខ្មែរក្រហមអាចវិលត្រឡប់មកវិញបានបង្ហាញអំពីតម្រូវការនៃវត្តមានកងទ័ពវៀតណាមនៅកម្ពុជា ។ ដោយមានវត្តមាន

កងទ័ពវៀតណាមនៅក្នុងប្រទេសកម្ពុជា ខ្មែរក្រហមមិនអាចប្រយុទ្ធដោយបើកចំហជាមួយកងទ័ពវៀតណាម និងកងទ័ពរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានទេ ។ ម្យ៉ាងវិញទៀត ដោយសារតែកងកម្លាំងខ្មែរក្រហម និងកម្លាំងប្រឆាំងផ្សេងទៀតមានទីតាំងនៅក្នុងព្រៃលើភ្នំ និងនៅតាមបណ្តោយព្រំដែន ការប៉ុនប៉ងកម្ទេចចលនាតស៊ូទាំងនេះ និងការបញ្ចប់សង្គ្រាមទ័ពឈ្លបជួបការលំបាក ។

វត្តមានរបស់កងទ័ពវៀតណាមនៅលើទឹកដីកម្ពុជា បានបង្កការលំបាកយ៉ាងខ្លាំងដល់វៀតណាម និងកម្ពុជា ។ សហរដ្ឋអាមេរិក ចិន និងបស្ចិមប្រទេសបានដាក់ទណ្ឌកម្មសេដ្ឋកិច្ចទៅលើវៀតណាម និងរដ្ឋាភិបាលកម្ពុជា ដែលបានជះឥទ្ធិពលធ្ងន់ដល់ប្រទេសទាំងពីរ ។ ទោះបីជាវៀតណាម និងកម្ពុជាទទួលបានជំនួយពីសហភាពសូវៀត និងប្រទេសមួយចំនួននៅក្នុងប្លុកសូវៀតក៏ដោយ ក៏ក្រោយមកជំនួយនេះត្រូវបានកាត់បន្ថយ ។ ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ សហភាពសូវៀតចាប់ផ្តើមកាត់បន្ថយជំនួយសេដ្ឋកិច្ចរបស់ខ្លួនពីប្រទេស និងចលនាកុម្មុយនីស្តនៅជុំវិញពិភពលោក ។ ជាលទ្ធផលវៀតណាមត្រូវបង្ខំចិត្តកាត់បន្ថយជំនួយមកឲ្យកម្ពុជា ។ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៧ វៀតណាមបានដកកងទ័ពរបស់ខ្លួនចេញពីកម្ពុជាចំនួន២ម៉ឺននាក់ ។[១៧៦] នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៨៨ រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម លោក ង្វៀន កូថាច់ បានប្រកាសអំពីការដកទ័ពចំនួន៥ម៉ឺននាក់បន្ថែមទៀត នៅត្រឹមខែធ្នូ ឆ្នាំ១៩៨៨ ។[១៧៧] មកត្រឹមខែកញ្ញា ឆ្នាំ១៩៨៩ វៀតណាមបានបញ្ចប់ការដកកងទ័ពរបស់ខ្លួនទាំងអស់ ដែលមានចំនួនប្រមាណ២សែននាក់ចេញពីប្រទេសកម្ពុជា ។[១៧៨]

ការដកទ័ពរបស់វៀតណាមប្រៀបដូចជាកាំបិតមុខពីរ ។ ម្យ៉ាង ការដកកងទ័ពនេះបានដកឧបសគ្គដ៏ធំមួយ ចេញពីដំណើរឆ្ពោះទៅរកការទទួលបានដំណោះស្រាយនយោបាយមួយសម្រាប់បញ្ហាកម្ពុជា ។ ម្យ៉ាងវិញទៀត ការដកទ័ពចេញនេះ យ៉ាងហោចបានផ្តល់ឱកាសដល់ខ្មែរក្រហម នៅក្នុងការបន្តការវាយប្រហារ ។

## ការកាន់កាប់ និងការតាំងទីលំនៅរបស់ខ្មែរក្រហមនៅអន្លង់វែង នៅឆ្នាំ១៩៨៩

នៅពេលដែលវៀតណាមចាប់ផ្តើមដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជា កម្លាំងខ្មែរក្រហមនៅលើភ្នំ១០០៣ និងខ្មែរក្រហមដែលនៅតំបន់កាន់កាប់តាមបណ្តោយព្រំដែន

ដទៃទៀតបានបើកយុទ្ធនាការក្នុងទ្រង់ទ្រាយធំ ដើម្បីដណ្តើមយកតំបន់នៅខាងក្នុងប្រទេសកម្ពុជាមកវិញ ។ ខ្មែរក្រហមបានចាប់ផ្តើមកេណ្ឌជនភៀសខ្លួនប្រមាណ៦ពាន់នាក់ ដើម្បីជួយដឹកជញ្ជូនគ្រឿងសព្វាវុធ និងស្បៀងអាហារទៅឲ្យកងទ័ពនៅសមរភូមិមុខ ។[១៧៩] ដោយមានគ្រឿងសព្វាវុធនៅក្នុងឃ្លាំងគ្រប់គ្រាន់ កងទ័ពខ្មែរក្រហមនៅលើភ្នំ១០០៣ ក្រោមការដឹកនាំរបស់ តាម៉ុក បានបើកការវាយប្រហារផ្តាច់ព្រ័ត្រ នៅចុងឆ្នាំ១៩៨៩ ដើម្បីកាន់កាប់តំបន់អន្លង់វែង ។ ការវាយប្រហារនេះត្រូវបានធ្វើឡើងនៅចំថ្ងៃបុណ្យភ្ជុំបិណ្ឌ ។

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៨៩ ខ្មែរក្រហមដណ្តើមបានតំបន់អន្លង់វែងដោយជោគជ័យ ដែលមានរយៈពេលពីរខែក្រោយការដណ្តើមកាន់កាប់បានតំបន់ប៉ៃលិន ដែលសំបូរទៅដោយត្បូង ដែលត្រូវខ្មែរក្រហមវាយយកបាននៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨៩ ។ ក្រោយមកទៀត ខ្មែរក្រហមដណ្តើមកាន់កាប់បានតំបន់មួយចំនួនទៀត ដូចជា ប៉ោយប៉ែត និងម៉ាឡៃ នៃខេត្តបន្ទាយមានជ័យ សំពៅលូន ភ្នំព្រឹក្ស កំរៀង និង សំឡូត នៅខេត្តបាត់ដំបង វាលវែងនៅខេត្តពោធិ៍សាត់ កោះស្លា និងភ្នំវល្លិ៍ នៅខេត្តកំពត ឱរ៉ាល់ និងភ្នំស្រួច នៅខេត្តកំពង់ស្ពឺ និងតំបន់តូចៗជាច្រើនផ្សេងទៀត នៅតាមព្រំដែនដែលរួមទាំងតំបន់នៅជុំវិញប្រាសាទព្រះវិហារ ។

ស្របពេលជាមួយគ្នានេះដែរ កងកម្លាំងរបស់រណសិរ្សរួបរួមជាតិដើម្បីកម្ពុជាមួយឯករាជ្យ សន្តិ និងសហប្រតិបត្តិការ ដែលហៅកាត់ថា ហ៊្វុនស៊ិនប៉ិច និងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ក៏បានធ្វើការវាយប្រហារក្នុងទ្រង់ទ្រាយធំ និងដណ្តើមកាន់កាប់បានតំបន់មួយចំនួននៅតាមព្រំដែននៃខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ ។ ទោះបីជាបាត់បង់តំបន់ជាច្រើននៅក្នុងប្រទេសក៏ដោយ ក៏រដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅតែគ្រប់គ្រងទឹកដីភាគច្រើននៃប្រទេសកម្ពុជា ។ ដូចគ្នានេះដែរ ប្រជាជនកម្ពុជាភាគច្រើនរស់នៅក្នុងតំបន់គ្រប់គ្រងរបស់សាធារណរដ្ឋប្រជាមានិត ។

ខ្មែរក្រហមនៅភ្នំ១០០៣ បានប្រើប្រាស់កម្លាំងចំនួន១២កងពល ដើម្បីវាយដណ្តើមកាន់កាប់តំបន់អន្លង់វែង ។ ឌុច សារិត ដែលជាអតីតកងទ័ពនៅក្នុងកងពល៦១២ បានរំឭកអំពីជ័យជម្នះរបស់ខ្មែរក្រហម ទៅលើកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជានៅតំបន់អន្លង់វែងដូចតទៅ[១៨០] ៖

## Khmer Rouge Strongholds and Military Operations Between 1990 and 1998




KHÔNG CÓ GÌ QUÝ HƠN ĐỘC LẬP TỰ DO



> នៅឆ្នាំ១៩៨៥ កងទ័ពវៀតណាមបានវាយកាន់កាប់មូលដ្ឋានរបស់ខ្មែរក្រហមទាំងអស់នៅលើភ្នំដងរែក ។ ខ្មែរក្រហមបានចល័ត ប្រជាជន និងកងទ័ពទាំងអស់ពីមូលដ្ឋានរបស់ខ្លួននៅក្នុងទឹកដីថៃ ទៅកាន់តំបន់ក្បែរសមរភូមិ ។ ខ្មែរក្រហមមានបំណងវាយរុញច្រានកងទ័ពវៀតណាម ឲ្យចេញពីតំបន់ព្រំដែន ។ ការប្រយុទ្ធបានកើតឡើងអស់រយៈពេលជាង ៤ឆ្នាំ ពីឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៨៩ ។ នៅចុងឆ្នាំ១៩៨៨ យើងបានវាយរុញច្រានកងទ័ពវៀតណាមឲ្យចុះពីភ្នំដងរែក ។ បន្ទាប់ពីគ្រប់គ្រងបានភ្នំដងរែក យើងចាប់ផ្តើមធ្វើប្រតិបត្តិការនៅតាមបណ្តោយផ្លូវបារាំង [ផ្លូវពីតំបន់អន្លង់វែងទៅកាន់ខេត្តព្រះវិហារ] ។ យើងបានធ្វើការវាយប្រហារជាប់ជានិច្ច ពីឆ្នាំ១៩៨៨ទៅឆ្នាំ១៩៨៩ ។ នៅទីបញ្ចប់ [នៅឆ្នាំ១៩៨៩] យើងវាយកាន់កាប់បានតំបន់អន្លង់វែង និងបានបញ្ជូនប្រជាជនមកតាំងទីលំនៅនៅក្នុងតំបន់នេះ ។[១៨១]

នៅពេលគ្រប់គ្រងបានអន្លង់វែង តំបន់នេះបានក្លាយទៅជារដ្ឋធានីរបស់ចលនាខ្មែរក្រហម ដែលអនុញ្ញាតឲ្យខ្មែរក្រហមអាចរៀបចំយុទ្ធសាស្ត្រកងទ័ព នយោបាយ និងសេដ្ឋកិច្ច ។

## ការតាំងទីលំនៅដំបូងនៅអន្លង់វែង

ពីរបីថ្ងៃបន្ទាប់ពីទទួលបានជ័យជម្នះ តាម៉ុក បានរៀបចំកិច្ចប្រជុំមហាជននៅជាំជប់ម្លូ ដោយបានប្រកាសអំពីការវិលត្រឡប់របស់ខ្មែរក្រហម មករស់នៅលើទឹកដីកម្ពុជាវិញ ។ តាម៉ុក បានប្រកាសថា «យើងនឹងឈប់រស់នៅលើទឹកដីថៃទៀតហើយ ។»[១៨២] ដើម្បីសម្រួលដល់ការដឹកជញ្ជូនប្រជាជន និងសម្ភារៈជាច្រើន តាម៉ុក បានដឹកនាំការកសាងផ្លូវធំមួយទៀតឆ្លងកាត់តាមច្រកព្រំដែនជាំសាង៉ាំ ។[១៨៣] តាម៉ុក បានប្រើគ្រឿងចក្រឈូសដី ប្រកបដោយគុណភាពខ្ពស់ ដែលគាត់បានទិញពីប្រទេសថៃ ដើម្បីឈូសផ្លូវពីជាំជប់ម្លូមកកាន់ទីប្រជុំជនអន្លង់វែង ។ តាម៉ុក បានចំណាយពេលប្រហែល២ខែ ដើម្បីបញ្ចប់ការកសាងផ្លូវនេះ ។ នៅខែកុម្ភៈ ឆ្នាំ១៩៩០ ខ្មែរក្រហមបានដឹកជញ្ជូនប្រជាជន

ចុះពីលើភ្នំដងរែកមកកាន់តំបន់អន្លង់វែង ។ ប្រជាជនចាប់ផ្តើមកសាងលំនៅឋានអចិន្ត្រៃយ៍ ដោយបានបញ្ចប់ចល័តក្នុងព្រៃអស់រយៈពេលជាង១០ឆ្នាំ ។

តាម៉ុក បានហៅអន្លង់វែងថា ជាប្រទេសមួយ ។ តាម៉ុក បានរើយ្វាំងរបស់គាត់មកកាន់តំបន់អន្លង់វែង ។ តាម៉ុក បានបញ្ជាឲ្យកងទ័ពដាក់មីន និងដាំចម្រូង នៅតាមផ្លូវយុទ្ធសាស្ត្រទាំងអស់ឆ្ពោះមកកាន់តំបន់នេះ ដើម្បីការពារការប៉ុនប៉ងការវាយប្រហារណាមួយពីកងកម្លាំងរបស់រដ្ឋាភិបាលរដ្ឋកម្ពុជា ។[១៨៤]

ប្រជាជនដែលធ្វើដំណើរចុះពីលើភ្នំនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ បានរៀបរាប់ថា ខ្លួនបានឃើញផ្ទះ ធ្វើអំពីដីឥដ្ឋ ខ្ទមតូចៗ និងរោងឈើជាច្រើន ដែលជាអតីតបន្ទាយរបស់កងទ័ពវៀតណាម ។ តំបន់នេះសំបូរទៅដោយគ្រាប់មីន ។ ជីវិតរស់នៅជួបប្រទះនឹងឧបសគ្គជាច្រើន ដោយសារតែប្រជាជន ក៏ដូចជាកងទ័ពត្រូវចាប់ផ្តើមជីវិតពីបាតដៃទទេ ។ ទោះបីជាជីវិតប្រឈមនឹងការលំបាកជាច្រើនយ៉ាងណា ក៏ដោយ ក៏ប្រជាជនទទួលបានភាពរីករាយ និងសេចក្តីសង្ឃឹមក្នុងការកសាងផ្ទះថ្មីនៅលើទឹកដីកម្ពុជា ។

ដោយមិនទាន់មានការរៀបចំរចនាសម្ព័ន្ធភូមិឃុំនៅឡើយ ប្រជាជនរស់នៅតាមបន្ទាយកងពលរៀងៗខ្លួន ។ បន្ទាយកងពលទាំងនោះ មានទីតាំងនៅលើតំបន់ដែលជាអតីតភូមិចាស់ ដែលភាគច្រើននៅតាមតំបន់ក្បែរប្រភពទឹក និងដើមឈើធំៗ ។

ការធ្វើដំណើររបស់ប្រជាជន ត្រូវបានដាក់កំហិតយ៉ាងតឹងរ៉ឹង ។ ស្ត្រី និងកុមារ ត្រូវរស់នៅក្នុងរោងជាបណ្តោះអាសន្ននៅពេលដែលបុរសនាំគ្នាកាប់ឆ្ការព្រៃ និងដោះមីន ដើម្បីសាងសង់ផ្ទះ ។ បុរសៗអាចឆ្ការដីបានប្រហែល១០ម៉ែត្រក្នុងមួយថ្ងៃ ។ គ្រួសារនីមួយៗត្រូវទទួលខុសត្រូវនៅក្នុងការដោះមីន នៅលើដីដែលខ្លួនរស់នៅដោយខ្លួនឯង ដែលការងារនេះមិនមែនជាបញ្ហាលំបាកខ្លាំងទេសម្រាប់ប្រជាជនភាគច្រើន ដោយសារបុរសភាគច្រើនគឺជាកងទ័ពដែលមានបទពិសោធជាច្រើននៅក្នុងប្រតិបត្តិការដោះមីន ។[១៨៥]

កែវ ភ័ក្រ បានរំឭកអំពីបទពិសោធរបស់គាត់នៅអន្លង់វែង បន្ទាប់ពីគាត់ចុះពីជំរំដប់មួយដំបូងនៅដើមឆ្នាំ១៩៩០ថា ៖

> ខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំងចំពោះគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ដោយសារតែអន្លង់វែងគឺ ជាអតីតបន្ទាយកងទ័ពវៀតណាម ។ ខ្ញុំបានឃើញការ



> *ផ្ទុះគ្រាប់ ដែលបានសម្លាប់មនុស្សអស់ជាច្រើននាក់ ។ ខ្ញុំមិនហ៊ានធ្វើដំណើរចេញក្រៅភូមិដែលខ្ញុំរស់នៅនោះទេ ។ ប្រជាជនមួយចំនួនបានជីកដីដាំចេកដោយជីកប៉ះចំមីន ដែលបានផ្ទុះស្លាប់ចោលកូនតូចៗ ។ នៅក្នុងអំឡុងពេលនោះ យើងមិនហ៊ានភ្ជួររដីធ្វើស្រែនោះទេ ។ ការធ្វើស្រែត្រូវបានធ្វើឡើងទាល់តែប៉ុន្មានឆ្នាំក្រោយមកទៀត ។*

នៅពេលដែលមីនត្រូវបានដោះអស់ ប្រជាជនចាប់ផ្ដើមកាប់ដើមឈើដើម្បីសង់ផ្ទះ ។ នៅក្នុងរយៈពេល៥ ទៅ៦ ខែដំបូង បន្ទាប់ពីកាន់កាប់បានអន្លង់វែង ព្រៃឈើដ៏ក្រាស់ស្ទើរតែក្លាយទៅជាវាលរាបស្មើ ។ សូម្បីតែកូនឈើតូចៗក៏ត្រូវបានកាប់ដែរ ។ ភូមិទាំងឡាយត្រូវបានដាក់ឈ្មោះជាបណ្ដោះអាសន្នទៅតាមឈ្មោះ កងពល ឬឈ្មោះប្រធានកងពល ដូចគ្នាទៅនឹងការរៀបចំភូមិនៅលើភ្នំ១០០៣ដែរ ។ កងពល៩៨០មានទីតាំងនៅក្បែរសាលាស្រុកអន្លង់វែងបច្ចុប្បន្ន ដែលមានដើមស្វាយធំៗ ។ ដោយសារតែតំបន់នេះ មានទំនាក់ទំនងជាមួយនឹងសមាជិករបស់កងពល៩៨០ តំបន់នោះត្រូវបានដាក់ឈ្មោះថា “ភូមិ៩៨០” ។[១៨៦]

នៅចុងឆ្នាំ១៩៩០ និងដើមឆ្នាំ១៩៩១ តាម៉ុក និងមេដឹកនាំខ្មែរក្រហមនៅអន្លង់វែង







ចាប់ផ្ដើមរៀបចំជាភូមិ ។ ឈ្មោះភូមិត្រូវបានដាក់ទៅតាមទីតាំងធនធានធម្មជាតិដែលមាននៅក្បែរនោះ ។ ឧទាហរណ៍ ភូមិទំនប់លើយកតាមឈ្មោះទំនប់ទឹកដែល តាម៉ុក បានសង់នៅជិតនោះ ។ ភូមិទួលត្បែង ត្រូវបានហៅតាមឈ្មោះដើមត្បែងជាច្រើនដែលដុះនៅទីនោះ ។ ភូមិស្រះឈូក យកឈ្មោះតាមស្រះមួយដែលមានដើមឈូកដុះពាសពេញ ។ ភូមិត្រពាំងប្រីយ៍ យកតាមឈ្មោះដើមប្រីយ៍ដ៏ច្រើននៅក្បែរត្រពាំងមួយនៅក្នុងភូមិនោះ ទោះបីជាក្រោយ មក ភូមិនេះបានរើចេញឆ្ងាយពីត្រពាំង មកនៅក្បែរផ្លូវជាតិក៏ដោយ ។ ភូមិទឹកជុំ យកឈ្មោះតាមសណ្ឋានដីរបស់ភូមិនេះ ដែលមើលទៅហាក់ដូចជាកូនកោះមួយដែលហ៊ុមព័ទ្ធដោយទឹក ។ ភូមិឃ្លាំងកណ្ដាល យកតាមឈ្មោះឃ្លាំងរបស់ តាម៉ុក ដែលនៅក្បែរនោះ ត្រូវបានប្រើប្រាស់សម្រាប់ផ្ទុកស្បៀងអាហារ និងសម្ភារៈផ្សេងៗ ដើម្បីផ្គត់ផ្គង់ដល់ប្រជាជន ។ ភូមិបឹងត្រូវបានដាក់ឈ្មោះ ដោយសារតែភូមិនេះមានបឹងមួយនៅពីមុខ ។ ភូមិទួលសាលា ត្រូវបានដាក់ឈ្មោះ ដោយសារតែមានសាលាទ្រុឌទ្រោមមួយ ដែលត្រូវបានសង់នៅលើទួលមួយ ។ ភូមិអូរក្រញូង យកតាមឈ្មោះដើមក្រញូងដ៏សំបូរនៅទីនោះ ទោះបីជាដើម ក្រញូងត្រូវកាប់អស់ក្រោយមយ៉ាងណាក៏ដោយ ។ ភូមិអូរស្វាយ យកឈ្មោះតាមដើមស្វាយ ដែលដុះនៅក្បែរអូរ ។ ភូមិយាងជើង និងភូមិយាងត្បូង យកឈ្មោះតាមដើមយាង ។ ភូមិព្រលាន យកឈ្មោះតាមអតីតព្រលានយន្តហោះមួយ ដែលត្រូវបានសាងសង់ឡើងតាំងពីជំនាន់ សម្ដេចព្រះ នរោត្ដម សីហនុ ។[១៨៧]

ភូមិមួយចំនួនទៀតត្រូវបានដាក់ឈ្មោះតាមគម្រោងសាងសង់នានានៅក្នុងតំបន់ ។ ឧទាហរណ៍ មានដូចជាភូមិត្រាក់ទ័រ ភូមិឡាន និងភូមិដឹកជញ្ជូន ។ ភូមិកម្មករ យកឈ្មោះតាមកម្មករមួយក្រុមដែលរស់នៅក្បែរនោះ ដើម្បីសាងសង់ស្ពាន ។

តាម៉ុក ក៏បានបង្កើតភូមិដាច់ដោយឡែកមួយសម្រាប់ជនពិការដោយសារសង្គ្រាម ដោយសារប្រជាជនពិការទាំងនោះ មិនអាចរស់នៅដោយខ្លួនឯងបាន ។ ភូមិនោះមានឈ្មោះថា ភូមិជើងភ្នំ ។ ស្បៀងអាហារ និងសម្ភារៈផ្សេងៗទៀត ត្រូវបានដឹកយកទៅផ្គត់ផ្គង់ប្រជាជននៅក្នុងភូមិនោះជាប្រចាំ ។ ប្រជាជនអន្លង់វែងភាគច្រើន បានហៅភូមិនោះថា "ភូមិជនពិការ" ដោយសារអ្នកភូមិភាគច្រើនជាជនពិការ ។ តាម៉ុក បានរៀបចំរៀបការឲ្យកងទ័ពពិការទាំងអស់ ។ ប្រធានភូមិទីមួយ ក៏ជាមនុស្សពិការដែរ ។ នៅក្នុងភូមិនេះមានគ្រួសារជនពិការប្រហែលពី៣០ទៅ៤០ គ្រួសារដោយសារតែជនពិការភាគច្រើន

ចង់រស់នៅក្បែរសាច់ញាតិរបស់ខ្លួននៅក្នុងភូមិផ្សេងទៀត ។[១៨៩]

## ការធ្លាក់ចុះជំនួយបរទេស

ទោះបីជាខ្មែរក្រហមទទួលបានប្រយោជន៍ជាច្រើន ពីការដកទ័ពវៀតណាមចេញពីកម្ពុជា បរិយាកាសភូមិសាស្ត្រនយោបាយ ដែលបានទ្រទ្រង់ចលនាខ្មែរក្រហមអស់ជាច្រើនឆ្នាំ ក៏មានការផ្លាស់ប្តូរដែរ ។ សង្គ្រាមត្រជាក់ជិតដល់ទីបញ្ចប់ ហើយសហរដ្ឋអាមេរិក សហភាពសូវៀត ចិន និងប្រទេសនៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន បានបោះជំហានដ៏សំខាន់ស្វែងរកដំណោះស្រាយផ្នែកការទូត ដើម្បីបញ្ចប់ជម្លោះរ៉ាំរ៉ៃនៅកម្ពុជា ។ នៅឆ្នាំ១៩៩១ ភាគីកម្ពុជាទាំងអស់ ដែលរួមទាំងខ្មែរក្រហមផងបានយល់ព្រមចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ។ មកត្រឹមឆ្នាំ១៩៩៣ ប្រទេសចិន ថៃ និងបស្ចិមប្រទេសបានផ្តាច់ជំនួយជាផ្លូវការពីខ្មែរក្រហម ។

ដោយសារជំនួយបរទេសកាន់តែរួញតូច តាម៉ុក បានបង្វែរការទទួលខុសត្រូវទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ពីក្រោមការគ្រប់គ្រងរបស់ខ្លួន ទៅឲ្យគ្រួសារឯកជនវិញ ។ ប្រជាជនចាប់ផ្តើមកាប់ឆ្ការដីដាំដំណាំ និងចិញ្ចឹមសត្វ ដើម្បីបំពេញការខ្វះខាតដែលប្រជាជនទទួលបានពីរដ្ឋបាលរបស់ តាម៉ុក ។[១៩០] តាម៉ុក ក៏បានចែកឈើដល់កងទ័ពដើម្បីសង់ផ្ទះ ។ តាម៉ុក បានជំរុញឲ្យប្រជាជន និងកងទ័ពជួយគ្នាទៅវិញទៅមក នៅក្នុងការកសាងភូមិ និងសាងសង់ផ្ទះ នៅក្នុងទម្រង់ជាក្រុមប្រវាស់ដៃ ឬក្រុមសាមគ្គី ។ ក្រុមនេះខុសពីសហករណ៍កុម្មុយនីស្តដែលត្រូវបានបង្កើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយសារខ្មែរក្រហមនៅអន្លង់វែង ទទួលស្គាល់កម្មសិទ្ធិឯកជន ហើយគ្រួសារនីមួយៗរស់នៅ និងហូបចុកនៅតាមផ្ទះរៀងៗខ្លួន ។

## ការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល

នៅឆ្នាំ១៩៩៥ ខ្មែរក្រហមបានរៀបចំតំបន់អន្លង់វែងឲ្យទៅជាស្រុកមួយ ដែលរួមមាន១១ឃុំ និង ៥០ភូមិ ។ បើយោងតាមកំណត់ត្រារដ្ឋបាលស្រុកអន្លង់វែងរបស់ខ្មែរក្រហម ស្រុកនេះមានប្រជាជនចំនួន ៣.២៥៧គ្រួសារ ស្មើនឹង ១៦.០៨៧នាក់ ។[១៩១] ប្រជាជនទាំងអស់ត្រូវបានចាត់ទុកជាសហគមន៍យោធាមួយ ដែលត្រូវបែងចែកជាពីរ

ក្រុមកម្លាំងជួរមុខ និងជួរក្រោយ ។ ដើម្បីពង្រឹងសន្តិសុខនៅអន្លង់វែង កងសន្តិសុខជាច្រើនត្រូវបានបង្កើតឡើង ។ កងទាំងនេះ រួមមានកងជីវពលភូមិចំនួន១០៨នាក់ កងជីវពលឃុំ៥៩នាក់ ប៉ុស្តិ៍យាមចំនួន១៥ដែលមានអ្នកយាមចំនួន៨៧នាក់ ត្រង់សេចំនួន២.២១៤កន្លែង កម្លាំងផលិតចម្រូងចំនួន១.២៦១នាក់ កម្លាំងកាប់ឫស្សីចំនួន៨០៧នាក់ និងរទេះគោចំនួន១៣៣រទេះ ។

នៅក្បែរស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទក៏ត្រូវបានបង្កើតឡើងដែរ ដែលរួមមានឃុំចំនួន៦ : ឃុំបាក់អន្លង់ផ្អាវ ត្រពាំងប្រាសាទ អូរស្មាយ ទំនប់ដាច់ និងព្រះប្រឡាយ ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺថា ស្រុកអន្លង់វែង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ចំណែកឯស្រុកត្រពាំងប្រាសាទ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត ។

ដំណាំបឋមរបស់ស្រុកអន្លង់វែងគឺស្រូវ ។ ទោះជាយ៉ាងនេះក្តី ប្រជាជនក៏ធ្វើការដាំដុះដំណាំរដូវប្រាំងផ្សេងៗទៀតដែរ ដែលរួមមាន ពោត ស្រូវស្រាល ដំឡូងជ្វា ដំឡូងមី ល្ពៅ ឪឡឹក ឃ្លោក ស្ពៃក្តោប ត្រសក់ ត្រប់ ម្ទេស ប៉េងប៉ោះ ល្ហុង ចេក អំពៅ ដូង ស្វាយ ខ្នុរ ក្រូច ទៀប និងត្របែក ។ ប្រជាជនក៏ប្រកបរបរចិញ្ចឹមសត្វដែរ ដូចជា គោ ក្របី មាន់ ទា និងជ្រូក ។

ឧស្សាហកម្មសិប្បកម្ម ក៏មានទំហំធំដែរ ដែលរួមមានទាំងសិប្បកម្ម និងរោងតម្បាញចាស់ និងថ្មី ។ សិប្បកម្ម និងរោងតម្បាញទាំងនេះ ផលិតនូវផលិតផលប្រើប្រាស់ក្រណាត់ និងសម្ភារៈផ្សេងៗសម្រាប់បម្រើដល់សេដ្ឋកិច្ចក្នុងតំបន់ និងអគ្គការយោធារបស់ខ្មែរក្រហម ។ ឧស្សាហកម្មផលិតរបស់ជាច្រើនដូចជា កាំបិត ពូថៅ ចប កណ្តៀវ នង្គ័ល រនាស់ រទេះគោ ត្បាល់បុកដោយដៃ ត្បាល់បុកដោយជើង អង្រែ ត្បាល់កិន កញ្ជ្រែង ល្អី កាបូប គ្រួស កន្ទេល ក្រមា និងសំពត់ ។[១៩៧]

## របនាសម្ព័ន្ធដឹកនាំរដ្ឋបាលរបស់ខ្មែរក្រហមនៅអន្លង់វែង

នៅខែតុលា ឆ្នាំ១៩៩៣ ប៉ុល ពត, ខៀវ សំផន និង ចាន់ យូរ៉ាន់ បានរត់មកអន្លង់វែង នៅពេលដែលកងយោធពលខេមរភូមិន្ទបានវាយកាន់កាប់ទីបញ្ជាការរបស់ខ្មែរក្រហម នៅភ្នំឆត្រ ។ តាម៉ុក បានសាងសង់ផ្ទះនៅក្បាលអន្សោង សម្រាប់មេដឹកនាំទាំងអស់នោះ ដែលមានចម្ងាយប្រហែល២៥គីឡូម៉ែត្រពីទីប្រជុំជនអន្លង់វែង និងប្រហែល១គីឡូម៉ែត្រ

ពីដីថៃ ។[១៩៣]

ផ្ទះនៅក្បាលអន្លង់បានក្លាយទៅជាទីបញ្ជាការរបស់ ប៉ុល ពត និងត្រូវបានចាត់ទុកថា ជាតំបន់ ហាមឃាត់របស់ចលនាខ្មែរក្រហម ។ មិនមាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យចេញចូលផ្ទះនោះបានទេ ក្រៅពីទីប្រឹក្សាជំនិតរបស់ ប៉ុល ពត ក្រុមវិទ្យុ និងអង្គរក្សរបស់ខ្លួន ។ ជាញឹកញយ មេបញ្ជាការកងទ័ពខ្មែរក្រហមតែងតែជួបប្រជុំគ្នានៅផ្ទះរបស់ ប៉ុល ពត នៅក្បាលអន្លង់ ។[១៩៤] ប៉ុល ពត បានរៀបចំស្ថានីយវិទ្យុផ្សាយសំឡេងមួយ

រដ្ឋាភិបាលបណ្តោះអាសន្នកម្ពុជាប្រជាធិបតេយ្យ (១៩៩៤-១៩៩៨)




នៅក្បែរផ្ទះរបស់គាត់ ។ ប្រជាជនដែលរស់នៅអន្លង់វែងភាគច្រើនស្គាល់ និងធ្លាប់បានឃើញ តាម៉ុក ប៉ុន្តែ ប្រជាជនតិចតួចណាស់ ដែលធ្លាប់បានឃើញ ប៉ុល ពត ។[១៩៥] ផ្ទុយទៅវិញ ប៉ុល ពល មានភាពជិតស្និទ្ធជាមួយកងទ័ព និងប្រជាជននៅស្រុកត្រពាំងប្រាសាទ ។ ប៉ុល ពត ធ្លាប់ជួយធ្វើស្រែ និងចុះទៅសួរសុខទុក្ខប្រជាជន ។

នួន ជា និង សុន សេន បានផ្លាស់មករស់នៅអន្លង់វែងនៅខែតុលា ឆ្នាំ១៩៩៦ បន្ទាប់ពីខ្មែរក្រហមនៅម៉ាឡៃ ប៉ៃលិន និងសមរភូមិទិស២៥០ (ដែលរួមមានស្រុកសំពៅលូន ភ្នំព្រឹក្ស និងកំរៀង) បានផ្តាច់ខ្លួនចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។[១៩៦] តាម៉ុក បានសង់ផ្ទះឲ្យមេដឹកនាំទាំងអស់នេះនៅលើទីតាំងមួយ ដែលត្រូវបានស្គាល់ថា ពើយតារួន ដែលស្ថិតនៅក្បែរច្រកព្រំដែនជាំសាង៉ាំ ។ តាម៉ុក បានសង់ផ្ទះធំមួយនៅអូរជីក ក្បែរទីប្រជុំជនអន្លង់វែង ដែលជាទីបញ្ជាការយោធារបស់គាត់ ។ អៀង សារី គឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមតែមួយគត់ ដែលរស់នៅក្រៅរដ្ឋបាលគ្រប់គ្រងរបស់អន្លង់វែង ។ អៀង សារី មានមូលដ្ឋាននៅម៉ាឡៃ ដោយទទួលបានការគាំទ្រពីកងពលធំពីរ ៖ កងពល

៤៥០ ដែលដឹកនាំដោយ សុខ ភាព មាន ទីបញ្ជាការនៅម៉ាឡៃ និងកងពល៤១៥ ដែលដឹកនាំដោយ អ៊ី ឈាន មានទីបញ្ជាការនៅប៉ៃលិន ។ តំបន់កាន់កាប់របស់ខ្មែរក្រហមដទៃទៀត ទោះជាមានមូលដ្ឋាននៅតាមព្រំដែន ឬនៅខាងក្នុងប្រទេសក្តី គឺជាក្រុមតូចៗ ដែលទទួលបញ្ជាផ្ទាល់ពីអន្លង់វែង ។

នៅខែកក្កដា ឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតច្បាប់ដាក់ឲ្យក្រុមខ្មែរក្រហមនៅក្រៅច្បាប់ ។ ជាការឆ្លើយតបទៅនឹងច្បាប់ស្តីពី«ការដាក់ក្រុមខ្មែរក្រហមឲ្យនៅក្រៅច្បាប់» ខ្មែរក្រហមបានប្រកាសបង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិ និងសាមគ្គីជាតិកម្ពុជា ដែលមានទីស្នាក់ការនៅអន្លង់វែង ។ សមាជិករដ្ឋាភិបាលបណ្តោះអាសន្ននេះរួមមាន ខៀវ សំផន (នាយករដ្ឋមន្ត្រី) ចាន់ យូរ៉ាន់ (ឧបនាយក រដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស) កែវ យ៉ាន (រដ្ឋមន្ត្រីការពារជាតិ) ម៉ក់ បេន (រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ជួន ជឿន (ទីប្រឹក្សាពិសេស) ទេព ឃុនណាល់ (រដ្ឋមន្ត្រីទទួលបន្ទុកបូរណភាពទឹកដី) យឹម ផន (រដ្ឋមន្ត្រីមហាផ្ទៃ) កោរ ប៊ុនហេង (រដ្ឋមន្ត្រីកិច្ចការសាធារណៈ) និង តាម៉ុក (អគ្គមេបញ្ជាការកងទ័ព) ។

ប៉ុល ពត, នួន ជា, អៀង សារី, សុន សេន និង កែ ពក មិនមានឈ្មោះ នៅក្នុងបញ្ជីមេដឹកនាំ រដ្ឋាភិបាលបណ្តោះអាសន្នរបស់ខ្មែរក្រហមនោះទេ ។ ទោះជាយ៉ាងនេះក្តី ប៉ុល ពត នៅតែជាមេដឹកនាំដ៏មានអំណាច និងមានឥទ្ធិពលមួយរូប នៅក្នុងរដ្ឋាភិបាលថ្មីនេះ ។ នួន ជា ដើរតួនាទីជាអ្នកអប់រំ ប៉ុន្តែគាត់មិនមានឥទ្ធិពលផ្នែកយោធាឡើយ ។ នួន ជា បានផ្តល់ការអប់រំនយោបាយដល់កងទ័ព និងកម្មាភិបាលជាប្រចាំ ។ នួន ជា ក៏បានអប់រំណែនាំដល់ប្រជាជនអំពីប្រធានបទស្តីពីជីវិតរស់នៅប្រចាំថ្ងៃ ដូចជាការថែរក្សាអនាម័យ និងការចិញ្ចឹមសត្វជាដើម ។[197] នួន ជា បានណែនាំប្រជាជនឲ្យប្រុងប្រយ័ត្នចំពោះជំងឺគ្រុនចាញ់ ។ ចំពោះមនោគមន៍វិជ្ជានយោបាយវិញ នួន ជា បានណែនាំប្រជាជនកុំឲ្យបោះបង់ចោលការលះបង់ដើម្បីបុព្វហេតុជាតិនិយម ។ នួន ជា បានអប់រំប្រជាជនថា «កុំបោះបង់ចោលប្រទេសជាតិរបស់អ្នក និងមិនត្រូវចាញ់ឧបាយកលរបស់យួន ។»[198]

នៅអន្លង់វែង សុន សេន ត្រូវបានដកហូតសិទ្ធិផ្នែករដ្ឋបាល និងយោធា ។ ដូច នួន ជា ដែរ សុន សេន ដើរតួនាទីនៅក្នុងការអប់រំប្រជាជន និងកម្មាភិបាល ។ សុន សេន បាន

បង្រៀនប្រជាជនថា «អ្នកទាំងអស់គ្នាត្រូវតែស្វាហាប់ក្នុងការបង្កបង្កើនផលស្រូវ ។ អ្នកត្រូវនាំគ្នាដាំចេក ដំឡូង និងត្រកួន ឲ្យបានច្រើន ដើម្បីជៀសវាងការចំណាយលុយទៅទិញនៅផ្សារ ។»[១៩៩]

តាមពិតទៅ ដោយសារ តាម៉ុក គ្រប់គ្រងកងពលខ្លាំងៗនៅអន្លង់វែង ហើយគាត់ដើរតួជា អ្នកគ្រប់គ្រងរដ្ឋបាលចម្បងនៅតំបន់នេះ តាម៉ុក ត្រូវបានចាត់ទុកថា ជាមេដឹកនាំកំពូលនៅអន្លង់វែង ។ ជាទូទៅជីវិតរបស់ តាម៉ុក មានលក្ខណៈចល័ត ដោយផ្លាស់ប្តូរចុះឡើងរវាងផ្ទះនៅលើភ្នំដងរែក និងផ្ទះធំនៅអូរដឹក ។

ជំពូក១០

# កេរដំណែលរបស់ តាម៉ុក

## តាម៉ុក : មេទ័ពអន្លង់វែង

អ៊ុង ជឿន ឬ ឈិត ជឿន ហៅ តាម៉ុក កើតនៅឆ្នាំ១៩២៦ នៅខេត្តតាកែវ ។ តាម៉ុក ឆ្លងកាត់បទពិសោធជីវិតជាច្រើនមុនពេលមកដល់អន្លង់វែង ។ កាលពីកុមារភាព តាម៉ុក ធ្លាប់បួសជាសង្ឃ និងក្រោយមកបានក្លាយជាប្រធានខ្មែរឥស្សរៈប្រចាំខេត្តតាកែវ ។ នៅឆ្នាំ១៩៦៣ តាម៉ុក បានក្លាយជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា ។ ពីឆ្នាំ១៩៦៨ដល់ឆ្នាំ១៩៧៨ តាម៉ុក បានក្លាយជាអនុលេខា និងក្រោយមកលេខាភូមិភាគនិរតីនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅចុងឆ្នាំ១៩៧៨ តាម៉ុក គ្រប់គ្រងភូមិភាគពាយ័ព្យនៃកម្ពុជាប្រជាធិបតេយ្យ ។ ដោយមានឈ្មោះបដិវត្តន៍ ង៉ួន កង, តាម៉ុក បានក្លាយជាអនុប្រធានទីមួយនៃសភាប្រជាជនបដិវត្តន៍ និងជាអនុប្រធានទីពីរនៃបក្សកុម្មុយនីស្តកម្ពុជា ។

យោងតាមព័ត៌មានដែលប្រមូលបានមុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ តាម៉ុក ត្រូវបានពណ៌នាថា ជាមេដឹកនាំឃោរឃៅ និងគ្មានចិត្តករុណា ។[២០០] នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក កងកម្លាំងខ្មែរក្រហម បានធ្វើបន្សុទ្ធកម្មទៅលើភូមិភាគបូព៌ា ដោយធ្វើការសម្លាប់រង្គាលទៅលើប្រជាជនសាមញ្ញ និងកម្មាភិបាលខ្មែរក្រហម ក្នុងភូមិភាគនោះ ។ ទង្វើទាំងអស់នេះបានធ្វើឲ្យ តាម៉ុក ទទួលបានងារជា «ពេជ្ឈឃាត» ។[២០១]

ទោះជាយ៉ាងនេះក្តី តាម៉ុក មានមុខមាត់ថ្មីទាំងស្រុងនៅអន្លង់វែង ។ ប្រជាជនអន្លង់វែងចាត់ទុក តាម៉ុក ជាមេដឹកនាំសាមញ្ញ ចិត្តល្អ និងមិនចេះរើសអើង ហើយប្រការដែលថា គាត់មានកំហុសដ៏ធំធេងនោះ គឺគ្រាន់តែជានិយាយអាក្រក់ពីគាត់តែប៉ុណ្ណោះ ។ តាម៉ុក អាចផ្តល់ការឧបត្ថម្ភគាំទ្រដល់ប្រជាជន និងកងទ័ពជាង១ម៉ឺន៦ពាន់នាក់ ដែលរស់នៅក្រោមការគ្រប់គ្រងរបស់ខ្លួននៅអន្លង់វែង ។ សម្រាប់ប្រជាជននៅអន្លង់វែងជាច្រើន តាម៉ុក គឺជាមេដឹកនាំបែបប្រពៃណី ដែលដឹកនាំប្រទេសប្រៀបដូចជាឪពុកដែលថែរក្សាគ្រួសាររបស់ខ្លួន ។

ជាទូទៅ ប្រជាជនទទួលបានសម្ភារៈឧបត្ថម្ភរៀងរាល់ពីរសប្តាហ៍ម្តង ឬមួយខែម្តង ។ ក្មេងចាប់ពីអាយុ៥ឆ្នាំឡើងទៅនឹងទទួលបានរបបអង្ករមួយធុងប្រេងកាតក្នុងមួយខែ (អង្ករមួយធុងប្រេងកាតមានទម្ងន់ប្រហែល២០គីឡូក្រាម ហើយប្រាំពីរធុងស្មើនឹងអង្ករមួយបាវ) ។[២០២] ក្មេងដែលមានអាយុចាប់ពី៥ឆ្នាំ ចុះមកដល់ទារកដែលទើបនឹងកើតទទួលបានរបបអង្ករកន្លះធុងប្រេងកាតក្នុងមួយខែ ។

តាម៉ុក ទំនុកបម្រុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនគ្រប់បែបយ៉ាង ។ ប្រជាជននឹងមករកពឹងពាក់គាត់ សូម្បីតែរឿងតូចតាច ដូចជា ស្ករស ឬអំបិលសម្រាប់ចម្អិនម្ហូប ។ តាម៉ុក បានចំណាយពេលច្រើនជាមួយប្រជាជន និងត្រួតពិនិត្យមើលគម្រោងសាងសង់ជាច្រើន ដែលបម្រើដល់ផលប្រយោជន៍សហគមន៍ ។ ឥរិយាបថរបស់ តាម៉ុក និងគម្រោងសាងសង់ក្នុងតំបន់ទាំងនេះធ្វើឲ្យ តាម៉ុក ទទួលបានកេរ្តិ៍ឈ្មោះជាមេដឹកនាំប្រកបដោយការលះបង់ និងជាមេដឹកនាំជាទីគោរពស្រលាញ់របស់ប្រជាជននៅអន្លង់វែង ។ នៅក្នុងបរិបទនេះ តាម៉ុក បានបន្តដើរតាមគន្លងប្រពៃណីរបស់ខ្មែរក្រហម ដោយគ្រប់គ្រងលើគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់ប្រជាជន ។

ភាពខុសគ្នាដ៏គួរឲ្យកត់សម្គាល់រវាង តាម៉ុក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង តាម៉ុក ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ (ក្រោយឆ្នាំ ១៩៧៩) គឺកេរ្តិ៍ឈ្មោះរបស់គាត់ ក្នុងនាមជាមេដឹកនាំព្រៃផ្សៃ ឬជាឃាតករ ។ ជាទូទៅប្រជាជនដែលស្គាល់ តាម៉ុក នៅអន្លង់វែង មានការងឿងឆ្ងល់ថាតើ តាម៉ុក អាចក្លាយទៅជាមេដឹកនាំឃោរឃៅ ឬ«ពេជ្ឈឃាត» ដោយរបៀបណា?

យោងតាមបទសម្ភាសជាមួយប្រជាជន តាម៉ុក មិនចូលចិត្តភាពហ៊ឺហាទេ ។ ឈួន ឈុន ដែលជាអតីតអ្នកបើកបរឲ្យ តាម៉ុក បាននិយាយថា តាម៉ុក ហូបអាហារ ដូចជាប្រជាកសិករក្រីក្រដែរ ។ តាម៉ុក មិនចូលចិត្តហូបអាហារល្អៗ ឬប្រើប្រាស់សម្ភារៈទំនើបៗ ដូចមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដទៃទៀតទេ ។ គាត់ស្តីបន្ទោសប្រជាជន ដូចជាឪពុកស្តីបន្ទោសកូន ប៉ុន្តែ គាត់មិនដែលគុំគួនអ្នកណាទេ ។ ក្រោយពីដេរស្តីរួចមក តាម៉ុក នឹងនិយាយទៅកាន់អ្នកទាំងនោះធម្មតា ព្រមទាំងជួយរកដំណោះស្រាយ ដោយមិនប្រកាន់ពីប្រវត្តិអតីតកាល ឬឋានៈអ្វីឡើយ ។ ប្រជាជនស្គាល់មេដឹកនាំខ្មែរក្រហមដទៃទៀត ដូចជា ខៀវ សំផន, ប៉ុល ពត, និង នួន ជា តាមរយៈរូបថតតែប៉ុណ្ណោះ ។[២០៣]

គីម ណាន ដែលជាអតីតកងទ័ពនៅក្នុងកងពល៧៨៥ យល់ថា តាម៉ុក គឺជាមនុស្ស ដែលពិបាកនឹងពណ៌នា ។

> វាគឺជារឿងមួយស្មុគស្មាញក្នុងការបរិយាយអំពីចរិតលក្ខណៈរបស់ តាម៉ុក ។ តាម៉ុក មិនដែលបែងចែកខ្លួនគាត់ឲ្យខុសពីប្រជាជនសាមញ្ញទេ ។ នៅពេលគាត់ជួបនរណាម្នាក់ គាត់តែងតែជេរស្តីយ៉ាងខ្លាំង ។ ប៉ុន្តែ គាត់នឹងឲ្យអ្វីដែលគាត់មានទៅឲ្យបុគ្គលនោះ ។ ថ្ងៃមួយ ខ្ញុំនិងមិត្តភក្តិរបស់ខ្ញុំ បានទៅបើកអង្ករ និងអាហារនៅឃ្លាំង ។ យើងបានយកកាំភ្លើងទៅជាមួយ ។ នៅពេលយើងកំពុងបើករបបអាហារ ឡានហ្ស៊ីបរបស់ តាម៉ុក បានមកដល់ ។ តាម៉ុក បានសួរយើងថា "សុខសប្បាយទេពួកអាក្មេងៗ ? ពួកហ្អែងទៅណា ?" ខ្ញុំបានឆ្លើយថា "បាទតា! ពួកខ្ញុំមកបើកអង្ករ និងអាហារ ។" គាត់ បានសួរថា "យ៉ាងម៉េចហើយនៅសមរភូមិ? ប្រសិនបើខ្មាំងចូលមកបាន អញនឹងសម្លាប់ពួកហ្អែងចោល ។ ពួកហ្អែងនេះដូចអាចម៍អ៊ីចឹង ។" បន្ទាប់មកគាត់បានយកឈើច្រត់របស់គាត់មកវាយក្បាលខ្ញុំ ។ គាត់បានដើរចូលទៅក្នុងឃ្លាំង និងបានស្តីឲ្យអ្នកយាមឃ្លាំង ។ គាត់បានបញ្ជាអ្នកយាមឃ្លាំងឲ្យបន្ថែមរបបអាហារពួកយើងថែមទៀត ដោយបាននិយាយថាពួកយើងហូបមិនឆ្អែតទេជាមួយនឹងរបបអាហារដូចរាល់ដង ។[២០៤]

តាម៉ុក មានឈ្មោះល្បីល្បាញជាមួយនឹងទេពកោសល្យផ្នែកយុទ្ធសាស្ត្រយោធា និងសមត្ថភាពរបស់គាត់នៅក្នុងការធ្វើការងារនៅក្រោមស្ថានភាពដ៏លំបាកបំផុតនៅក្នុងព្រៃ ។ ប្រជាជននៅអន្លង់វែងចាត់ទុកគាត់ថា ជាមេដឹកនាំដែលមិនចេះខ្លាច ។ គាត់ដើរពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីពិនិត្យស្ថានភាពរស់នៅរបស់ប្រជាជន ។ ឯម អឿន ដែលជាប្រជាជនមួយរូបនៅអន្លង់វែងបានពណ៌នាពីចរិតលក្ខណៈរបស់ តាម៉ុក ថា ៖

> តាម៉ុក គឺជាមនុស្សល្អ ពីព្រោះគាត់មិនមានកម្មសិទ្ធិផ្ទាល់ខ្លួនទេ ។ គាត់មិនដែលអនុញ្ញាតឲ្យសាច់ញាតិ ឬកូនចៅរបស់គាត់ យកទ្រព្យសម្បត្តិរបស់

> សហគមន៍ទេ ។ គាត់រស់នៅសាមញ្ញដូចប្រជាជនដែរ ។ តាម៉ុក ជាមនុស្សនិយាយត្រង់ ស្មោះត្រង់ និងស្រឡាញ់ប្រជាជនណាស់ ។ គាត់បែងចែករបបអង្ករដល់ប្រជាជនស្មើៗគ្នា ដោយមិនប្រកាន់ឋានៈ និងតួនាទីឡើយ ។ ប្រសិនបើគ្មាន តាម៉ុក ប្រជាជនទាំងអស់ប្រហែលជាស្លាប់ និងគ្មានអាហារហូបនោះទេ ។ មេដឹកនាំខ្មែរក្រហមដទៃមិនអនុញ្ញាតឲ្យយើងដឹងសូម្បីតែដំណើរ និងទីតាំងដែលគេរស់នៅផង ។[២០៥]

ប្រជាជនដែលមិនសូវជិតស្និទ្ធនឹង តាម៉ុក ក៏មានទស្សនៈស្រដៀងគ្នាដែរ ។ គឹម លី បានរត់ភៀសខ្លួនទៅរស់នៅក្នុងជំរំបុទ្ធិសែន ក្រោមការគ្រប់គ្រងរបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ ក្រោយមកនៅពេលវៀតណាមវាយកាន់កាប់បានជំរំនេះ លី បានរត់ទៅរស់នៅជំរំជនភៀសខ្លួនដែលគ្រប់គ្រងដោយរណសិរ្សហ៊ុនស៊ិនប៉ិចនៅអូរស្មាច់ ។ នៅឆ្នាំ១៩៩៣ លី មករស់នៅអន្លង់វែង ។ លី បានរៀបរាប់អំពីបទពិសោធរបស់គាត់ដែលធ្លាប់រស់នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ថា ៖

> ខ្ញុំមិនកាន់ជើងខាងណាទេ ខ្ញុំនិយាយតាមតែអ្វីដែលខ្ញុំបានមើលឃើញ ។ រាល់ពេលដែលយើងខ្វះអង្ករ លុយ ឬថ្នាំសង្កូវ តាម៉ុក បានជួយយើង ។ ខ្ញុំមិនដឹងជាត្រូវខឹងនឹងមនុស្សដូច តាម៉ុក យ៉ាងម៉េចនឹងកើតទេ ពីព្រោះគាត់មិនដែលធ្វើបាបខ្ញុំផង ។ គាត់ថែមទាំងបានឲ្យលុយខ្ញុំពីរពាន់បាត (រូបិយបណ្ណថៃ) ដើម្បីទិញជ្រូក និងមាន់យកមកចិញ្ចឹមទៀតផង ។[២០៦]

តា ម៉ុក រៀបការប្រពន្ធទីពីរឈ្មោះ ណេន នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ នៅពេលដែលប្រពន្ធទី មួយរបស់គាត់ ង៉ែត ឃឹម បានស្លាប់ដោយសារជំងឺ ។[២០៧] ប្រពន្ធទីពីររបស់តាម៉ុក គឺជាស្ត្រីមេម៉ាយ ដែលមានកូនពីរនាក់ជាមួយប្តីមុន ដែលជាអតីតមេបញ្ជាការកងទ័ពរបស់ តាម៉ុក ។ ប្តីមុនរបស់គាត់ស្លាប់ នៅក្នុងអំឡុងពេលប្រយុទ្ធគ្នានៅអន្លង់វែង ។ ណេន បានផ្លាស់ទៅរស់នៅប៉ៃលិន និងរៀបការប្តីទីបី បន្ទាប់ពី តាម៉ុក ស្លាប់នៅឆ្នាំ ២០០៦ ។[២០៨]

## គម្រោងសាងសង់របស់ តាម៉ុក

តាម៉ុក បានផ្តួចផ្តើមគំនិតសាងសង់ផ្លូវ ទំនប់ទឹក សាលារៀន មន្ទីរពេទ្យ ស្ពាន និងគម្រោងជាច្រើនផ្សេងទៀតនៅអន្លង់វែង ។ គម្រោងសាងសង់ទាំងអស់នោះបានផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងការបកស្រាយរបស់ខ្មែរក្រហមទៅលើសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស ។ ជាផ្នែកមួយនៃសន្ធិសញ្ញាសន្តិភាពនេះ ខ្មែរក្រហមត្រូវបានលើកទឹកចិត្តឲ្យកសាងហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស ដើម្បីត្រៀមធ្វើសមាហរណកម្មចូលរដ្ឋាភិបាល ។ ជាលទ្ធផល តាម៉ុក បានជួលជំនាញការជនជាតិថៃ ដែលមានជំនាញផ្នែកសាងសង់ឲ្យមកសាងសង់សាលារៀន មន្ទីរពេទ្យ និងស្ពានអូរជីក ។ តាម៉ុក ចំណាយប្រាក់តែសម្រាប់ជួលជំនាញការថៃតែប៉ុណ្ណោះ ប៉ុន្តែមិនបានចំណាយទៅលើកម្មករខ្មែរនោះទេ ។ តាម៉ុក បានអំពាវនាវប្រជាជននៅអន្លង់វែងឲ្យចូលរួមជួយនៅក្នុងគម្រោងសាងសង់នេះ ។ ប្រជាជនទាំងឡាយដែលមានកូនចៅត្រូវចូលរៀនក្នុងសាលា ឬត្រូវធ្វើដំណើរឆ្លងកាត់ស្ពានមានកាតព្វកិច្ចចូលរួមជួយក្នុងគម្រោងសាងសង់នោះ ។[២០៩]

សមិទ្ធផលទាំងនេះបានធ្វើឲ្យ តាម៉ុក អាចឈរជើងកាន់តែរឹងមាំនៅអន្លង់វែង



ពីព្រោះគម្រោងទាំងនេះបានផ្សារភ្ជាប់កេរ្តិ៍ឈ្មោះរបស់គាត់ទៅនឹងផលប្រយោជន៍របស់ប្រជាជន ។ ក្រៅអំពីគម្រោងសាងសង់ផ្លូវនៅអន្លង់វែង តាម៉ុក ក៏បានសាងសង់ផ្លូវដែលបម្រើដល់យុទ្ធសាស្ត្រយោធាដែរ ។ ផ្លូវទាំងនោះ រួមមានផ្លូវពីច្រកព្រំដែនជាំសាង៉ាំទៅកាន់ទីរួមស្រុកអន្លង់វែង ផ្លូវលេខ៦៧ទៅកាន់ខេត្តសៀមរាប ផ្លូវលេខ៦៨ទៅកាន់ស្រុកសំរោង ខេត្តឧត្តរមានជ័យ និងការជួសជុលផ្លូវចាស់ ដែលកសាងតាំងពីជំនាន់អាណានិគមបារាំងទៅកាន់ប្រាសាទព្រះវិហារ ។[២១០] មុនពេលកសាងផ្លូវទាំងអស់នោះ គឺជាផ្លូវដីដែលមិនអាចបើកឡានបាន ។

## ឃ្លាំងកណ្តាល

ដោយសារជំនួយរបស់ចិនត្រូវបានកាត់ផ្តាច់ក្រោយសន្និសីទសន្តិភាពទីក្រុងប៉ារីស នៅឆ្នាំ១៩៩១ តាម៉ុក បានចាប់ផ្តើមទិញស្បៀងអាហារពីប្រទេសថៃ ។ ខ្មែរក្រហមត្រូវទិញអង្កររាប់ម៉ឺនបាវក្នុងមួយខែ ដើម្បីផ្គត់ផ្គង់ទាំងប្រជាជន និងកងទ័ព ។ តាម៉ុក បានសាងសង់ឃ្លាំងធំៗចំនួន៦ ដើម្បីរក្សាស្បៀងទាំងនេះ ។ គម្រោងសាងសង់នេះ ត្រូវបានបញ្ចប់នៅខែឧសភា ឆ្នាំ១៩៩២ ។ ឃ្លាំងទាំងនោះ មានទីតាំងនៅក្នុងភូមិឃ្លាំងកណ្តាល ឃុំត្រពាំង



ប្រើយ៍ ដែលមានចម្ងាយប្រហែល៤គីឡូម៉ែត្រពីទីរួមស្រុកអន្លង់វែង ។ ឃ្លាំងទាំងនោះត្រូវបានសាងសង់ឡើងពីឥដ្ឋ ដែលមានដំបូលប្រក់ស័ង្កសី ។ ឃ្លាំងទាំងអស់នេះ គឺជាប្រភពផ្គត់ផ្គង់ដ៏សំខាន់សម្រាប់ប្រជាជននៅអន្លង់វែង និងកងទ័ពនៅសមរភូមិមុខ ។ ជាទូទៅប្រជាជនបានហៅឃ្លាំងនោះថា "ឃ្លាំងតាភិន" ពីព្រោះ តាភិន គឺជាអ្នកគ្រប់គ្រងឃ្លាំងទាំងអស់នោះ ។ កម្មាភិបាលផ្សេងទៀតដែលធ្វើការនៅឃ្លាំងកណ្តាលរួមមាន ហឿង លីណេត និង វ៉ែត ។ ឃ្លាំងកណ្តាលក៏ត្រូវបានប្រើប្រាស់ ដើម្បីរក្សាគ្រាប់កាំភ្លើង និងគ្រឿងសព្វាវុធសេសសល់ផ្សេងទៀតដែលចិនផ្តល់ឲ្យដែរ ។

## សាលារៀន

គម្រោងសាងសង់សាលារៀនត្រូវបានបញ្ចប់នៅខែមេសា ឆ្នាំ១៩៩៣ ។ សាលារៀននោះមានកម្ពស់បីជាន់ និង១២បន្ទប់ ដែលអាចដាក់សិស្សបានពីបីរយទៅបួនរយនាក់ ។ ជាងនេះទៅទៀត ឃុំនីមួយៗមានសាលារៀនតូចៗពីមួយទៅបួន ដែលត្រូវបានសាងសង់ឡើងពីឈើ និងមានដំបូលប្រក់ស្បូវ ។ គ្រូបង្រៀនបានធ្វើការដើម្បីភាពល្អប្រសើរនៅក្នុងសហគមន៍ ពីព្រោះគ្រូបង្រៀនទាំងនោះមិនទទួលបានប្រាក់បៀវត្សទៀងទាត់នោះទេ ។ សាលារៀនធំនោះបានក្លាយទៅជាវិទ្យាល័យអន្លង់វែង បន្ទាប់ពីសមាហរណកម្មឆ្នាំ១៩៩៨មក ។

សាលារៀនរបស់ តា ម៉ុក ផ្តល់ការអប់រំកម្រិតបឋមសិក្សាពីថ្នាក់ទី១ ដល់ថ្នាក់ទី៥ ។ សៀវភៅសិក្សាសរសេរដោយដៃរួមមាន មេរៀនអំពីវេយ្យាករណ៍ខ្មែរ រឿងព្រេង កំណាព្យ កសិកម្ម ភូមិវិទ្យា ធនធានធម្មជាតិ អាហារបំប៉ន អនាម័យ និងវត្ថុធាតុដើម ។ ប៉ុន្តែសៀវភៅសិក្សាទាំងនោះ ភាគច្រើនផ្តោតទៅលើការឃោសនា ដែលជំរុញឲ្យសិស្សមានគំនុំប្រឆាំងនឹងអ្វី ដែលខ្មែរក្រហមហៅថា "ឧក្រិដ្ឋកម្មរបស់យួន" និងរាជរដ្ឋាភិបាលកម្ពុជា ។ សៀវភៅសិក្សាបានបង្រៀនសិស្សអំពីវីរភាពរបស់កងទ័ពខ្មែរក្រហម នៅក្នុងការធ្វើប្រតិបត្តិការវិទ្ធង្សនានិងមានមេរៀនអំពីវិធីសាស្ត្រសង្គ្រាមឈ្លប សង្គ្រាមប្រជាជនរបៀបផលិតចម្រូង និងការធ្វើខ្លួនឲ្យទៅជាកម្មាភិបាលល្អ ។ សៀវភៅរៀនអក្សរសម្រាប់ថ្នាក់ទីបួន ដែលត្រូវបានបោះពុម្ព នៅឆ្នាំ១៩៩៥ មានមេរៀនមួយអំពីសមាសធាតុទាំងប្រាំនៃ"កម្មាភិបាលល្អ" ៖

> *កម្មាភិបាលល្អ គឺជាកម្មាភិបាលដែលជាប់មហាជន ទាំងមហាជនក្នុងជួរ ទាំងមហាជនក្នុងប្រជាជន ដូចទឹក និងត្រី ។ កម្មាភិបាលល្អជាបុគ្គលដែលយល់ច្បាស់ និងអនុវត្តតាមគោលការណ៍របស់បក្សប្រកាន់គោលជំហររឹងប៉ឹងនៅមូលដ្ឋាន និងសមរភូមិយល់ដឹងពីស្ថានភាពសត្រូវនិងខ្លួនឯង ព្រមទាំងអាចដឹកនាំការប្រយុទ្ធប្រឆាំងសត្រូវ ព្រមទាំងមិនមានទំនាក់ទំនង ឬជួញដូរជាមួយសត្រូវក្នុងរូបភាពណាក៏ដោយ ។ កម្មាភិបាលល្អដឹកនាំប្រជាជនដោះស្រាយបញ្ហាសេដ្ឋកិច្ច ។ កម្មាភិបាលល្អរស់នៅតាមគោលការណ៍សេដ្ឋកិច្ចរបស់បក្ស ។ កម្មាភិបាលល្អត្រូវតែរាបសារ និងស្មោះត្រង់ចំពោះប្រជាជន ព្រមទាំងមិនប្រើអំណាចរបស់ខ្លួនគំរាមកំហែងប្រជាជនដទៃ ។*[២១១]

សិស្សត្រូវបានតម្រូវឲ្យទន្ទេញចាំមាត់ នូវពាក្យពីរឃ្លាក្នុងគោលបំណងឲ្យសិស្សរក្សាការខឹងសម្បារ និងស្អប់ខ្ពើមចំពោះរាជរដ្ឋាភិបាលកម្ពុជា ។ ពាក្យទាំងពីរនោះគឺ «អាយ៉ង» និង «យួន» ។

## មន្ទីរពេទ្យ

គម្រោងសាងសង់មន្ទីរពេទ្យត្រូវបានបញ្ចប់នៅខែតុលា ឆ្នាំ១៩៩៣ ។ មន្ទីរពេទ្យនេះគឺជាសំណង់អគារថ្មកម្ពស់បីជាន់ ។ ឡុន ដែលជាកម្មាភិបាលខ្មែរក្រហម និងដែលធ្លាប់ទៅរៀននៅប្រទេសចិន និងលាវ ដែលជាជំនាញការសាងសង់ និងជនជាតិថៃម្នាក់ជាអ្នកទទួលខុសត្រូវចំពោះការសាងសង់មន្ទីរពេទ្យនេះ ។ មន្ទីរពេទ្យនេះទទួលព្យាបាលប្រជាជន និងទាហានដែលមានជំងឺ និងរបួសស្រាលៗតែប៉ុណ្ណោះ ។ អ្នកជំងឺនិងរបួសធ្ងន់ត្រូវបានបញ្ជូនទៅព្យាបាលនៅប្រទេសថៃ ។ មន្ទីរពេទ្យរបស់ តាម៉ុក បានក្លាយទៅជាមន្ទីរពេទ្យស្រុកអន្លង់វែង បន្ទាប់ពីសមាហរណកម្មឆ្នាំ១៩៩៨ ។

## ស្ពានអូរជីក

កាលពីដំបូង ស្ពានអូរជីកត្រូវបានសាងសង់ជាបណ្តោះអាសន្នពីឈើ និងដើមឫស្សីដើម្បីដឹកជញ្ជូនប្រជាជនចុះពីជំរំ និងពីលើភ្នំ ។ នៅរៀងរាល់រដូវវស្សា ការធ្វើដំណើរប្រចាំ



ថ្ងៃរបស់ប្រជាជនជួបប្រទះនឹងបញ្ហាលំបាក ដោយសារតែទឹកអូរជីកកើនឡើងយ៉ាងខ្លាំង ។ ប្រជាជនត្រូវចំណាយពេលជាច្រើនម៉ោង ដើម្បីធ្វើដំណើរឆ្លងកាត់អូរជីកទៅកាន់ទីប្រជុំជនអន្លង់វែង ហើយការធ្វើដំណើរម្តងៗ គឺប្រកបដោយគ្រោះថ្នាក់ ។ ប្រជាជនមួយចំនួនបានលង់ទឹកស្លាប់ពេលព្យាយាមឆ្លងអូរជីកនៅរដូវវស្សា ។ ហេតុដូច្នេះ តាម៉ុក បានសម្រេចចិត្តសាងសង់ស្ពានអូរជីក បន្ទាប់ពីបញ្ចប់ការសាងសង់ទំនប់អូរជីករួចមក ។ សំណង់ស្ពានអូរជីកបានចាប់ផ្តើមនៅឆ្នាំ១៩៩៤ និងបានបញ្ចប់នៅខែមករា ឆ្នាំ១៩៩៦ ។[២១៧]

ស្ពានអូរជីកនេះមិនមានគ្រឹះក្រោមទេ ។ តាម៉ុក មិនអនុញ្ញាតឲ្យជំនាញការថៃសាងសង់សសរស្ពានទេ ។ តាម៉ុក បានអះអាងថា គាត់បានប្រើកូនភ្នំពីរ (អតីតកូនភ្នំនៅក្បែរផ្ទះរបស់គាត់នៅមាត់ទឹក) មកធ្វើជាគ្រឹះរបស់ស្ពាន ។ បើយោងតាមការរៀបរាប់របស់ប្រជាជននៅក្នុងស្រុក តាម៉ុក បានពន្យល់ហេតុផលថា "គ្រឹះរបស់អញមាំជាងគ្រឹះរបស់ឯង ។" ប្រជាជនបានចូលរួមនៅក្នុងការសាងសង់ស្ពាន ដោយការជួយជញ្ជូនដី ដុំថ្ម និងស៊ីម៉ង់ត៍ ឲ្យកម្មករសំណង់ ។ ព្រះ យ៉ង់ ដែលជាអតីតកងទ័ពបានរំឭកពាក្យសម្តីរបស់ តាម៉ុក ថា ៖



ស្ពាននេះគឺជាប្រយោជន៍របស់ប្រជាជនគ្រប់រូប ។ ទោះបីជា អ្នកណាប្រញាប់ទៅណាក៏ដោយ អ្នកនោះត្រូវតែឈប់ ហើយជួយធ្វើសិន ។ អ្នកណាក៏ដោយឲ្យតែធ្វើដំណើរឆ្លងកាត់ការដ្ឋានស្ពាននេះ ត្រូវតែចែករំលែកកម្លាំងពលកម្ម ។ មិនមានអ្នកណាម្នាក់ហ៊ានប្រកែកទេពីព្រោះ តាម៉ុក អង្គុយនៅក្បាលស្ពានស្ទើររៀងរាល់ថ្ងៃ ។ តាម៉ុក នឹងហៅប្រជាជនណាដែលធ្វើដំណើរឆ្លងកាត់ការដ្ឋានសាងសង់ស្ពាននេះឲ្យជួយធ្វើសិន ។[២១៣]

## ផ្ទះក្បែរមាត់បឹង

ផ្ទះក្បែរមាត់ទឹករបស់ តាម៉ុក ត្រូវបានសាងសង់ឡើងនៅលើអតីតកូនភ្នំមួយ ដែលត្រូវបានគាស់ រំលើង ដើម្បីយកថ្មមកសាងសង់ស្ពាន និងទំនប់អូរជីក ។ នៅក្នុងបរិវេណនោះមានផ្ទះ៤ខ្នង ។ ផ្ទះទីមួយ ដែលត្រូវបានកសាងឡើងនៅឆ្នាំ១៩៩៣ មានជញ្ជាំងឈើ និងដំបូលធ្វើពីស៊ីប្រូស៊ីម៉ង់ត៍ ។ ផ្ទះទីពីរដែលមានទំហំធំជាងគេត្រូវចំណាយពេល២ឆ្នាំ ទើបអាចបញ្ចប់ការសាងសង់រួចរាល់នៅឆ្នាំ១៩៩៦ ។ ផ្ទះនេះ មានកម្ពស់បីជាន់ ដែលជាន់









ទីមួយគឺជាបន្ទប់សម្ងាត់ និងមានតែ តាម៉ុក ម្នាក់តែប៉ុណ្ណោះដែលអាចចេញចូលបាន ។ ជាន់ទីពីរត្រូវបានប្រើប្រាស់ជាបន្ទប់ប្រជុំ ហើយជាន់ទីបីគឺជាបន្ទប់សម្រាករបស់ តាម៉ុក ។ ផ្ទះទីបី ត្រូវបានប្រើប្រាស់សម្រាប់ជាកន្លែងស្នាក់នៅសាច់ញាតិរបស់ តាម៉ុក និងអ្នកដែលមកពឹងពាក់ តាម៉ុក ។ ផ្ទះទីបួន ដែលត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៩៣ គឺសម្រាប់បុគ្គលិក និងចុងភៅរបស់ តាម៉ុក ស្នាក់នៅ ។

សម្រាប់ផ្ទះទីពីរដែលធំបង្អស់ តាម៉ុក បានបញ្ជាឲ្យកម្មករទៅកាប់ដើមទ្រាស ទាំងមូលមកធ្វើជាសសរផ្ទះ ។ តាម៉ុក បានហាមមិនឲ្យកម្មករកាត់ចោលសូម្បីតែសំបកឈើ ។ ពីដំបូង ដំបូលផ្ទះនោះត្រូវបានសាងសង់ឡើងអំពីឈើ ។ ប៉ុន្តែ ដោយសារតែកត្តាអាកាសធាតុ និងកម្ដៅ ឈើបានរីក និងរួមមាឌ ។ បីខែក្រោយមកទឹកភ្លៀងបានជ្រាបចូលតាមដំបូល ដូច្នេះហើយ តាម៉ុក បានបញ្ជាឲ្យប្ដូរដំបូលក្បឿងវិញ ។ នៅខាងក្នុងផ្ទះមានលម្អទៅដោយរូបគំនូរប្រាសាទព្រះវិហារ និងប្រាសាទអង្គរវត្តអមដោយរូបគំនូរដែនទីប្រទេសកម្ពុជាមួយយ៉ាងធំនៅលើជញ្ជាំង ។ វត្ថុបុរាណជាច្រើនត្រូវបានដាក់លម្អនៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងបរិវេណផ្ទះ ។



កម្មករប្រហែលជា៣០នាក់បានចូលរួមនៅក្នុងការសាងសង់ផ្ទះ តាម៉ុក ។ អ្នកទាំងនោះរួមមាន ហែម មាន, ឌុល និង មឿន ។ សុខ ស្ថិតនៅក្នុងកងអារឈើ ដែលទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ឈើសម្រាប់សង់ផ្ទះ ។ អេង គឺជាជាងគំនូរនៃរូបប្រាសាទទាំងអស់ និងផែនទី ។[២១៨] តាន់ ដែលជាជនជាតិភាគតិចមកពីតំបន់ភ្នំ គឺជាជាងចម្លាក់ ។[២១៩] តាម៉ុក បានគូរប្លង់ផ្ទះ និងធ្វើការផ្ទាល់ជាមួយនឹងកម្មករទាំងអស់ ។ ប្រសិនបើកម្មករណាមិនធ្វើតាមការណែនាំរបស់គាត់បាន គាត់នឹងហៅអ្នកនោះឲ្យចុះមកជួប និយាយទល់មុខជាមួយគាត់ ដែលនៅពេលនោះ គាត់នឹងវាយក្បាលអ្នកនោះជាច្រើនដងជាមួយនឹងឈើច្រត់របស់គាត់ ។ ក្បាលរបស់ មាន ទទួលរងជាច្រើនដំបង នៅក្នុងអំឡុងពេលនៃការសាងសង់ ។ មាន បានរំឭកពាក្យពេចន៍របស់ តាម៉ុក បន្ទាប់ពីទទួលរងមួយឈើច្រត់ថា «បន្ទាប់ពីវាយនឹងឈើច្រត់របស់គាត់រួចហើយ គាត់បាននិយាយថា ទៅ! ទៅយកក្បាលគោមួយឲ្យប្រពន្ធហ្អែង ។»[២១៦] តាម៉ុក អនុញ្ញាតឲ្យកម្មករទាំងអស់របស់គាត់ហូបគោមួយក្បាលក្នុងមួយថ្ងៃ ។[២១៧]

ផ្ទះក្បែរមាត់បឹង គឺជាទីស្នាក់ការធំរបស់ តាម៉ុក សម្រាប់បម្រើទាំងការងារយោធា





និងរដ្ឋបាលនៅស្រុកអន្លង់វែងពីឆ្នាំ១៩៩៣ រហូតដល់ការដួលរលំចលនាខ្មែរក្រហមនៅចុងឆ្នាំ១៩៩៨ ។ តាម៉ុក តែងតែរៀបចំកិច្ចប្រជុំជាមួយមេបញ្ជាការកងទ័ពរបស់គាត់នៅផ្ទះនោះ ដែលក៏ជាកន្លែងស្នាក់នៅមួយរបស់ក្រុមគ្រួសារគាត់ដែរ ។

## រោងចក្រអារឈើ

នៅឆ្នាំ១៩៩១ តាម៉ុក បានបង្កើតរោងចក្រអារឈើមួយ ដើម្បីផ្គត់ផ្គង់ឈើឲ្យកងទ័ពធ្វើផ្ទះ និងដើម្បីធ្វើជំនួញជាមួយថៃ ។ រោងអារឈើនេះ មានទីតាំងនៅក្នុងវត្តស្រះឈូកបច្ចុប្បន្ន ដែលក៏ជាកន្លែងសាងសង់ចេតិយរបស់ តាម៉ុក ដែរ ។ រោងចក្រដ៏តូចនេះ មិនអាចផ្គត់ផ្គង់ឈើគ្រប់គ្រាន់ទៅឲ្យប្រជាជនរាប់ម៉ឺននាក់ដើម្បីសាងសង់ផ្ទះ បន្ទាប់ពីបានចុះពីជំរំ និងពីលើភ្នំមក ។ ដូច្នេះ ប្រជាជនជាច្រើនបាននាំគ្នាកាប់ឈើដោយខ្លួនឯង ។[២១៨]

កម្មាភិបាលដែលធ្វើការនៅរោងចក្រអារឈើរួមមាន ហែម មាន, រ៉ែន, ទៀ, សុខ, និង មឿន ។ មាន គឺជាប្រធានរោងចក្រ ហើយ រ៉ែន គឺជាអនុប្រធាន ។ រោងចក្រនេះមានម៉ាស៊ីនអារឈើ ចំនួន២៤គ្រឿង ហើយឈើត្រូវបានកាប់មកពីព្រៃស្អែក ។ សុខ គឺជាប្រធានកងកាប់ឈើ ហើយ មឿន គឺជាសមាជិកម្នាក់នៅក្នុងកង ។ រោងចក្រអារឈើនេះដំណើរការរហូតដល់ថ្ងៃប្រយុទ្ធគ្នានៅដើមឆ្នាំ១៩៩៨ ហើយក្រោយមកទៀត ម៉ាស៊ីន និងសម្ភារៈផ្សេងៗនៅក្នុងរោងចក្រត្រូវបានកងទ័ពយកទៅលក់អស់ ។[២១៩]

## ទំនប់អូរដឹក

ទំនប់អូរដឹក គឺជាអតីតបឹងដ៏ធំមួយដែលឈ្មោះស្រុកអន្លង់វែងគឺយកតាម ឈ្មោះបឹងនេះ ។ តាម៉ុក សាងសង់ទំនប់ទឹកនេះដើម្បីធ្វើជាអាងស្តុកទឹក និងជាប្រភពផ្គត់ផ្គង់ត្រីសម្រាប់ការបរិភោគប្រចាំថ្ងៃរបស់ប្រជាជន ។ ការសាងសង់ទំនប់ទឹកនេះ ត្រូវបានធ្វើឡើងជាបីដំណាក់កាល នៅឆ្នាំ១៩៩១ ឆ្នាំ១៩៩២ និងឆ្នាំ១៩៩៤ ។ តាមរបៀបណាក៏ដោយ ប្រជាជនគ្រប់រូបនៅអន្លង់វែងបានចូលរួមនៅក្នុងការសាងសង់ទំនប់ទឹកនេះ ។ ប្រជាជននៅក្នុងភូមិត្រូវបានបែងចែកទៅជាក្រុមតូចៗ ដែលក្នុងមួយក្រុមមានសមាជិក ១២នាក់ ។ ក្រុមទាំងអស់ដាក់វេនគ្នា ដើម្បីសាងសង់ទំនប់ទឹកនេះ ។ ជាងនេះទៅទៀត

តាម៉ុក តែងតែហៅប្រជាជនណា ដែលគាត់ជួបដោយមិនរើសមុខឲ្យជួយសាងសង់ទំនប់ទឹក នៅពេលគាត់មកពិនិត្យការដ្ឋានម្តងៗ ។

ជាងនេះទៅទៀត តាម៉ុក ក៏បានសាងសង់ទំនប់ទឹកថ្មីមួយដែលមានឈ្មោះថា «ទំនប់ថ្មី» ដែលស្ថិតនៅចម្ងាយប្រហែល២០គីឡូម៉ែត្រពីទីរួមស្រុកអន្លង់វែង ។ តាម៉ុក មានគម្រោងជីកប្រឡាយទឹកដ៏វែងមួយ ដែលហូរព័ទ្ធជុំវិញស្រុកអន្លង់វែងទាំងមូល និងប្រឡាយទឹកតូចៗជាច្រើនផ្សេងទៀត ដើម្បីផ្គត់ផ្គង់ទឹកទៅកាន់ភូមិទាំងអស់សម្រាប់ធ្វើស្រែចម្ការ ។[២២០]

## ជម្លោះខាងក្រៅ : ការប្រយុទ្ធគ្នាជាមួយនឹងកងកម្លាំងរបស់រដ្ឋាភិបាល

រដ្ឋកម្ពុជា និងក្រោយមករាជរដ្ឋាភិបាលកម្ពុជា បានប៉ុនប៉ងជាច្រើនដង ដើម្បីវាយដណ្តើមកាន់កាប់អន្លង់វែង ប៉ុន្តែមិនទទួលបានជោគជ័យ ។ នៅដើមឆ្នាំ១៩៩៣ កងកម្លាំងរបស់រដ្ឋាភិបាលនៃរដ្ឋកម្ពុជាបានវាយចូល និងកាន់កាប់បានអន្លង់វែង ដើម្បីទប់ស្កាត់ការលុកលុយរបស់ខ្មែរក្រហមចូលទៅក្នុងប្រទេសកម្ពុជា ។

ទោះជាយ៉ាងនេះក្តី ជ័យជម្នះរបស់កងកម្លាំងរដ្ឋកម្ពុជាគ្រាន់តែជាជ័យជម្នះបណ្តោះអាសន្នមួយតែប៉ុណ្ណោះ ។ ដោយប្រឈមមុខនឹងការបាត់បង់តំបន់អន្លង់វែង តាម៉ុក បានបញ្ជាឲ្យប្រជាជនដុតផ្ទះសម្បែងខ្លួនឯងចោល ។ តាម៉ុក ក៏បានបញ្ជាឲ្យដុតឈើដែលបានកាប់រួចចោលដែរ ដោយសារតែគាត់មិនអាចដឹកជញ្ជូនឈើទាំងអស់នោះទៅកាន់ប្រទេសថៃទាន់ពេលវេលា ។ ការដុតបំផ្លាញឈើនេះ បានបង្កើតឲ្យមានវាលធំល្វឹងល្វើយ ដែលគ្របដណ្តប់ទៅដោយផេះពណ៌ស ។ ណាន ដែលជាអ្នកភូមិមួយរូបបាននិយាយថា «ឈើជាច្រើនម៉ឺនម៉ែត្រគូបនៅលើដីទំហំមួយគីឡូម៉ែត្រការ៉េនៅភូមិស្រះឈូក ត្រូវបានដុតកម្ទេច ។ ទីនោះបានក្លាយទៅជាវាលផេះពណ៌ស ។ ឈើដែលបានឆេះគឺជាឈើប្រណិត ។»[២២១] តាម៉ុក បានដឹកនាំប្រជាជនឡើងភ្នំដងរែក និងឆ្លងដែនទៅប្រទេសថៃ ។ កម្លាំងរបស់រដ្ឋាភិបាលបាន កាន់កាប់ទីតាំងនៅតាមជើងភ្នំក្បែរច្រកព្រំដែនជាំសាង៉ាំ និងតំបន់អន្លង់វែងប្រហែលមួយខែកន្លះ ។

ជីវ ចាន់ ដែលជាអតីតនីសាររបស់ វន វើត (ឧបនាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច) បាននិយាយថា ជីវិតគឺពោរពេញទៅដោយការលំបាកវេទនានៅក្នុងជម្លោះឆ្នាំ១៩៩៣-១៩៩៤ :

> *ខ្ញុំបានស្គាល់ពីក្រោយខ្នង ហើយរត់ឡើងភ្នំដងរែក ។ ផ្ទះដែលទើបតែសង់ថ្មីរបស់ខ្ញុំ ត្រូវបានដុតបំផ្លាញចោលរាបដល់ដី នៅសល់តែសំបកខ្មៅខ្យង ។ យើងបានរត់ភៀសខ្លួនទៅប្រទេសថៃ ។ ដោយសារតែគ្មានមធ្យោបាយដឹកជញ្ជូនប្រពន្ធខ្ញុំ និងខ្ញុំបានដឹកគោ ជញ្ជូនកូន និងសម្ភារផ្សេងៗឡើងលើភ្នំ ។*[២២២]

បន្ទាប់ពីការកាន់កាប់មួយរយៈពេលខ្លី ពីកម្លាំងរបស់រដ្ឋាភិបាលខ្មែរក្រហម បានវាយបកមកវិញ និងបានកាន់កាប់អន្លង់វែងសាជាថ្មី ។ នៅពេលធ្វើដំណើរត្រឡប់មកវិញ ខ្មែរក្រហមបានឃើញសាកសពស្អុយរលួយជាច្រើននៅកណ្តាលវាល ។ ប្រជាជននាំគ្នាដើរប្រមូលសាកសពទាំងអស់នោះមកដុតចោល ។[២២៣] ក្រោយពីសម្អាតសាកសព និងឈរជើងបានរឹងមាំឡើងវិញហើយ ប្រជាជនចាប់ផ្តើមសង់ផ្ទះសាជាថ្មី ។

នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ កងយោធពលខេមរភូមិន្ទ ដែលជាកងកម្លាំងរដ្ឋាភិបាលចម្រុះរវាងគណបក្សប្រជាជនកម្ពុជា[២២៤] និងគណបក្សហ៊្វុនស៊ិនប៉ិចបានបើកការវាយប្រហារក្នុងទ្រង់ទ្រាយធំម្តងទៀត និងបានកាន់កាប់តំបន់អន្លង់វែងរយៈពេលខ្លី ។ ជាថ្មីម្តងទៀតកម្លាំងរបស់ខ្មែរក្រហម និងប្រជាជននៅអន្លង់វែង ត្រូវបានបង្ខំឲ្យរត់ភៀសខ្លួនទៅប្រទេសថៃ ។[២២៥] ទោះជាយ៉ាងនេះក្តីម្តងនេះ ខ្មែរក្រហមអាចវាយដណ្តើមយកតំបន់អន្លង់វែងវិញនៅក្នុងរយៈពេលពីរសប្តាហ៍ ។[២២៦] កងយោធពលខេមរភូមិន្ទជួបប្រទះនឹងការលំបាកជាខ្លាំង ដោយសារតែតំបន់នោះនៅឆ្ងាយដាច់ស្រយាល និងគ្របដណ្តប់ទៅដោយព្រៃឈើក្រាស់ៗ និងគ្រាប់មីន ។ កងយោធពលខេមរភូមិន្ទទទួលរងគ្រោះពីការវាយប្រហាររបស់ខ្មែរក្រហម គ្រាប់មីន និងការផ្គត់ផ្គង់ស្បៀងអាហារមិនគ្រប់គ្រាន់ ។ ការវាយប្រហារគ្នាទៅវិញទៅមករវាងកម្លាំងរដ្ឋាភិបាល និងខ្មែរក្រហមបានកើតឡើងជាប់ជានិច្ចនៅក្នុងរយៈពេលជាង៨ឆ្នាំ ដែលធ្វើឲ្យបទពិសោធនៃការចូលកាន់កាប់តំបន់ ការរត់ភៀសខ្លួន និងការដណ្តើមកាន់កាប់សាជាថ្មីក្លាយទៅជាផ្នែកមួយនៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅតំបន់អន្លង់វែង ។[២២៧]

ដោយសារខ្វះខាតអាវុធដើម្បីការពារតំបន់កាន់កាប់របស់ខ្លួន មកដល់ដំណាក់កាលនេះ ខ្មែរក្រហមបានចាប់ផ្តើមច្នៃគ្រឿងសព្វាវុធ និងគ្រាប់មីនដោយខ្លួនឯង ដោយធ្វើពី

សំបកដប និងកំប៉ុង ។ សូម្បីតែសំបកដកទឹកក្រូចធម្មតា ក៏អាចក្លាយទៅជាអាវុធដ៏គ្រោះថ្នាក់មួយបានដែរ ។[២២៨] ខ្មែរក្រហមក៏បានពឹងផ្អែកយ៉ាងខ្លាំង ទៅលើចម្រូងធ្វើពីឫស្សីដែរ ។ វិធីសាស្ត្រទាំងអស់នេះបានជួយឲ្យខ្មែរក្រហមនៅតំបន់អន្លង់វែង អាចបន្តការប្រយុទ្ធជាមួយកងយោធពលខេមរភូមិន្ទរហូតដល់ចុងឆ្នាំ១៩៩៨ ។

## បន្សុទ្ធកម្មផ្ទៃក្នុង ៖ សាច់ហើមសាច់ស្អុយ

នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ វាជារឿងធម្មតាដែលកម្មាភិបាលខ្មែរក្រហម ក៏ដូចជាប្រជាជនសាមញ្ញត្រូវបានចាប់ខ្លួននិងដាក់ឃុំឃាំងនៅក្នុងគុក ។ របបនេះបានដាក់ចេញនូវផែន ការសេដ្ឋកិច្ចមួយដែលមិនអាចសម្រេចបាន ហើយនៅពេលដែលផែនការមិនទទួលបានលទ្ធផលតាមការកំណត់មនុស្សម្នាក់នឹងត្រូវបានដាក់ឲ្យទទួលខុសត្រូវ ។ នៅក្នុងកាលៈទេសៈបែបនេះកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម និងថ្នាក់កណ្តាលបានចោទប្រកាន់គ្នាទៅវិញទៅមក និងបានចោទប្រជាជនសាមញ្ញ ដើម្បីបំពេញតាមការទាមទាររបស់អង្គការក្នុងការស្វែងរកសត្រូវខាងក្នុងភ្នាក់ងារស៊ើបការសម្ងាត់ និងជនដែលធ្វើវិទ្ធង្សនា ។ ទោះបីជារបបកម្ពុជាប្រជាធិបតេយ្យ ដែលដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជាបានដួលរលំនៅឆ្នាំ១៩៧៩ ហើយយ៉ាងណាក៏ដោយ ក៏ការអនុវត្តបែបកុម្មុយនីស្ត ដូចជា ការធ្វើបន្សុទ្ធកម្មទៅលើកម្មាភិបាលគ្រប់លំដាប់ថ្នាក់នៅតែត្រូវបានបន្តអនុវត្តរហូតដល់ថ្ងៃចុងក្រោយនៃចលនាខ្មែរក្រហមនៅក្នុងតំបន់អន្លង់វែង ។

ប្រជាជន និងកងទ័ពដែលត្រូវបានចាប់ឃុំឃាំង ឬយកទៅសម្លាប់ចោលត្រូវបានហៅថា "សាច់ហើមសាច់ស្អុយ" ដែលសំដៅទៅលើជនទាំងឡាយណា ដែលមាននិន្នាការប្រឆាំងទៅនឹងថ្នាក់ដឹកនាំខ្មែរក្រហម ឬជនដែលមានបំណងចង់ផ្តាច់ខ្លួន ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ពាក្យនេះក៏សំដៅទៅលើជនទាំងឡាយណាដែលត្រូវបានចាត់ទុកថា ជាភ្នាក់ងារស៊ើបការសម្ងាត់របស់វៀតណាម ឬភ្នាក់ងាររបស់បរទេស ។ ការឃោសនានយោបាយបានធ្វើឲ្យមានការជឿជាក់ថា មានភ្នាក់ងារស៊ើបការសម្ងាត់ ដែលបង្កប់ខ្លួននៅក្នុងជួរចលនាខ្មែរក្រហម និងដែលមានបំណងចង់បំផ្លិចបំផ្លាញចលនាខ្មែរក្រហមនៅអន្លង់វែង ។

ពាក្យ "សាច់ហើមសាច់ស្អុយ" នេះក៏ត្រូវបានប្រើសម្រាប់ដើម្បីកំណត់អត្តសញ្ញាណ

សត្រូវផ្សេងៗគ្នាជាច្រើនទៀតដែរ ។ កងទ័ព និងប្រជាជនដែលផ្តាច់ខ្លួនចេញពីក្រុមនយោបាយផ្សេង ដែលត្រូវបានបង្កើតឡើងបន្ទាប់ពីឆ្នាំ១៩៧៩ ដូចជារណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងក្រុមរាជានិយមហ៊្វុនស៊ិនប៉ិច ក៏ត្រូវបានចាត់បញ្ចូលទៅក្នុងប្រភេទ «សាច់ហើមសាច់ស្អុយ» ។ ជាងនេះទៅទៀត ប្រជាជនដែលប្រព្រឹត្តខុសសីលធម៌ ឬអំពើទាំងឡាយដែលប្រឆាំងនឹងមេដឹកនាំ ឬពាក់ព័ន្ធនឹងជំនួញដែលត្រូវបានហាមឃាត់ ក៏ត្រូវបានចាត់ទុកថា ជាប្រភេទ«សាច់ហើមសាច់ស្អុយ» ។

ភូមិទួលគ្រួស គឺជាភូមិមួយដែលត្រូវបានស្គាល់ថាជាកន្លែងសម្រាប់ប្រមូលផ្តុំ«សាច់ហើមសាច់ស្អុយ» ដែលត្រូវបានចាប់យកមកពីគ្រប់អគ្គការនយោបាយទាំងអស់នៅអន្លង់វែង ។ ភូមិនេះគឺជាភូមិដាច់ស្រយាលនៅក្នុងព្រៃដែលមានចម្ងាយប្រហែល១០គីឡូម៉ែត្រពីទីរួមស្រុកអន្លង់វែង ។ ភូមិនេះត្រូវបានរៀបចំឡើងជាជំរំប្រមូលផ្តុំ និងជាជំរំសម្រាប់សម្លាប់ប្រជាជនទាំងឡាយណាដែលត្រូវបានចាត់ទុកថា ជា«សាច់ហើមសាច់ស្អុយ» ឬនិយាយម្យ៉ាងទៀត សម្រាប់ប្រជាជនដែលបានប្រព្រឹត្តកំហុសធ្ងន់ និងត្រូវទទួលទោស ។ សាត គឺជាប្រធានភូមិទួលគ្រួស ហើយ លន់ សេង គឺជាអនុប្រធាន ។ សាត ទទួលបញ្ជាពី តាម៉ុក ក្នុងការចាប់ខ្លួនជនទាំងឡាយណា ដែលត្រូវបានចាត់ទុកថាជាជំពូក «សាច់ហើមសាច់ស្អុយ» ។ នៅភូមិទួលគ្រួស មានគុកក្រោមដីមួយដែលគ្រប់គ្រងដោយ ម៉េន ។

ភូមិទួលគ្រួស ក៏ត្រូវបានស្គាល់ថា ជា«ភូមិចិនយំ» ។ ជនជាតិចិនដែលរស់នៅប្រទេសកម្ពុជាអស់ជាច្រើនជំនាន់មកហើយនោះ តែងតែប្រកបអាជីវកម្មសហគ្រាស ឬអាជីវកម្មឯកជន ដែលប្រជាជនកម្ពុជាទូទៅមិនសូវប្រកបរបរបែបនេះទេ ។ ដោយសារអាជីវកម្មឯកជនត្រូវបានហាមប្រាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅអន្លង់វែង ជនទាំងឡាយណាដែលត្រូវបានចាប់បានពីបទប្រកបអាជីវកម្មទាំងនេះត្រូវបានចាត់ទុកថា ជាអ្នកជំនួញជនជាតិចិន ហើយជាលទ្ធផលជននោះនឹងត្រូវទទួលទណ្ឌកម្ម ។ នៅអន្លង់វែងប្រជាជនណាដែលប្រកបរបររកស៊ីរបៀបជនជាតិចិន នឹងត្រូវចាប់ខ្លួន ហើយបញ្ជូនទៅភូមិទួលគ្រួស ។ ប្រជាជននៅក្នុងភូមិនេះ តែងតែស្រែកយំខ្លាំងៗ ហើយសំឡេង និងការរើសអើងទៅលើ«អ្នកជំនួញជនជាតិចិន» បានក្លាយទៅជាផ្នែកមួយនៃឈ្មោះរបស់ភូមិនេះ ។

មឹប មុំ បានរំឭកអំពីរឿងរ៉ាវរបស់គាត់ ដែលត្រូវចោទប្រកាន់ថាជា«សាច់ហើម

សាច់ស្អុយ»ថា ៖

> ប្ដីរបស់ខ្ញុំត្រូវបានបញ្ជូនទៅសមរភូមិមុខ ។ នៅខាងក្រោយធ្វើស្រែចម្ការ និងជួយផលិតចម្រូង ។ គេមិនឲ្យយើងរកស៊ីជួញដូរទេ ។ ប៉ុន្តែ ខ្ញុំបានធ្វើនំបញ្ចុកលក់ ។ ប្ដី និងបងប្រុសរបស់ខ្ញុំចេះនិយាយភាសាថៃ ។ មេបញ្ជាការរបស់ពួកគាត់បានអនុញ្ញាតឲ្យពួកគាត់ឆ្លងដែនទៅក្នុងទឹកដីថៃដើម្បីទិញសម្លៀកបំពាក់ផ្ញើប្រពន្ធ នៅពេលពួកគាត់ជិតត្រឡប់មកផ្ទះវិញ ។ បន្ទាប់ពីទទួលបានសម្លៀកបំពាក់ និងសម្ភារៈផ្សេងៗទៀត ខ្ញុំបានដើរកាត់ព្រៃដើម្បីយកវាទៅលក់នៅភូមិផ្សេងទៀត ។ ខ្ញុំត្រូវបានចាប់ខ្លួន និងត្រូវបានចាត់ទុកថា ជា«សាច់ហើមសាច់ស្អុយ» ។ ប្រសិនបើយើងមិនបានផ្ដាច់ខ្លួនឲ្យបានឆាប់ទេ ម្ល៉េះខ្ញុំត្រូវបានយកទៅសម្លាប់ចោលបាត់ទៅហើយ ។[២២៩]

ដូចប៉ុន្មានឆ្នាំមុនៗដែរ បន្សុទ្ធកម្មនិងការចាប់ខ្លួន ហាក់ដូចជាកើតឡើងជាបន្តបន្ទាប់ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលជម្លោះតាមព្រំដែនរវាងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យកាន់តែមានភាពតានតឹងឡើង ចំនួនមនុស្សដែលត្រូវបានចាប់ខ្លួនបានកើនឡើងយ៉ាងខ្លាំង ។ ដូចគ្នាដែរ នៅពេលដែលចំនួនប្រជាជនផ្ដាច់ខ្លួន បានកើនឡើងការបែកបាក់នៅក្នុងជួរមេដឹកនាំខ្មែរក្រហម ក៏កាន់តែតានតឹងឡើងដែរ ដែលនាំទៅដល់យុទ្ធនាការនៃការចាប់ខ្លួន និងសម្លាប់ ។

តាម៉ុក បានហៅកងទ័ពដែលរត់ចេញពីកងពល៥១៩ មកតំបន់អន្លង់វែងថាជា«ពួកប៉ារ៉ាទីពីរ» ដែលសំដៅទៅលើកងទ័ពរបស់ហ៊ុនស៊ិនប៉ិច និងឯកសណ្ឋានយោធាប៉ារ៉ា ។ កងទ័ពភាគច្រើននៅក្នុងកងពលនេះបានផ្ដាច់ខ្លួនចុះចូលជាមួយរាជរដ្ឋាភិបាលនៅឆ្នាំ ១៩៩៦ ជាមួយ អៀង សារី ។[២៣០] មេបញ្ជាការមួយចំនួន និងកងទ័ពប្រហែលមួយរយនាក់នៅក្នុងកងពល៩៨០ ក៏ត្រូវបានចាត់ទុកថាជាជំពូក«សាច់ហើមសាច់ស្អុយ» ។ អ្នកទាំងអស់នោះរួមមាន យឹម ដាន់ណា, យឹម សាន, នួន ជឿន, លី ស៊ុន និង ពើយ សារឿន ។ ទោះជាយ៉ាងនេះក្ដី តាម៉ុក មិនបានបញ្ជូនជនទាំងអស់នោះទៅកាន់ភូមិទួលគ្រួសទេ ដោយសារតែអ្នកទាំងនោះនៅមានការគោរព និងការស្មោះស្ម័គ្រពីសំណាក់កងទ័ពនៅ

ក្នុងកងពលរបស់ខ្លួនៗ ផ្ទុយទៅវិញ តាម៉ុក បានបញ្ជូនអ្នកទាំងនេះ ទៅកាន់សមរភូមិគ្រោះថ្នាក់បំផុតនៅក្នុងខេត្តព្រះវិហារ ដែលនៅទីនោះមេបញ្ជាការទាំងនេះបានជួបប្រយុទ្ធគ្នាយ៉ាងញឹកញាប់ជាមួយកងកម្លាំងរបស់រាជរដ្ឋាភិបាលកម្ពុជា ។[២៣១]

ជំពូក ១១
# ចំណុចចាប់ផ្តើមនៃទីបញ្ចប់

## *ជម្លោះផ្ទៃក្នុងនៅក្នុងជួរមេដឹកនាំខ្មែរក្រហម*

មានហេតុផលជាច្រើន ចំពោះការបែកបាក់ និងឈានទៅរកជម្លោះផ្ទៃក្នុងដែលកើតឡើងនៅក្នុងថ្ងៃចុងក្រោយនៃចលនាខ្មែរក្រហម ។ ការសម្រេចចិត្តថា តើគួរចូលរួមនៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ ឬយ៉ាងណា បានបង្កភាពតានតឹងនៅក្នុងចំណោមមេដឹកនាំខ្មែរក្រហម ។ ប៉ុល ពត ប្រកាន់ខ្ជាប់នូវគំនិត ដែលថា កងកម្លាំង និងចារកិច្ចរបស់វៀតណាមបានជ្រាបចូលទៅក្នុងប្រព័ន្ធរដ្ឋបាលទាំងអស់របស់រដ្ឋកម្ពុជា ។ ជាងនេះទៅទៀត ប៉ុល ពត នៅតែជឿជាក់ថា ខ្មែរក្រហមអាចដណ្តើមយកកម្ពុជាម្តងទៀតបាន ។ ទស្សនៈរបស់ ប៉ុល ពត ហាក់មិននៅឆ្ងាយប៉ុន្មានពីការពិតទេ ។

ស្ទើរតែភ្លាមៗ បន្ទាប់ពីវៀតណាមបានដកកងទ័ពជាចុងក្រោយ ចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ សមរភូមិជាយុទ្ធសាស្ត្រសម្រាប់ដោតវាសនាប្រទេសកម្ពុជាបានផ្លាស់ប្តូរពីដំណាក់កាលយោធាមកដំណាក់កាលនយោបាយវិញ ។ ជាការពិតណាស់ កម្លាំងកងទ័ពរបស់ភាគីទាំងអស់ មានឥទ្ធិពលទៅលើវិជ្ជាភាពនយោបាយ ។ និយាយម្យ៉ាងទៀត អំណាចនយោបាយរបស់ភាគីមួយត្រូវបានបង្ហាញតាមរយៈការគ្រប់គ្រងទៅលើប្រជាជន ក៏ដូចជាអង្គការយោធារបស់ខ្លួន ។ ប៉ុន្តែ ទោះបីជាកម្លាំងទ័ព ពិតជាមានឥទ្ធិពលទៅលើការទទួលបានការគាំទ្រនៅក្នុងការបោះឆ្នោត ដែលត្រូវបានរៀបចំឡើងដោយអង្គការសហប្រជាជាតិយ៉ាងណាក៏ដោយ ក៏ជ័យជម្នះជាយុទ្ធសាស្ត្រ មិនមែនស្ថិតនៅលើការប្រយុទ្ធនៅតាមសមរភូមិនោះទេ ប៉ុន្តែស្ថិតនៅក្នុងទឹកចិត្តរបស់ប្រជាជនកម្ពុជា ។

ភាគីចម្បងៗនៅក្នុងការតស៊ូអំណាចនេះ ដែលរួមមានភាគីគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរបានមើលឃើញការពិតនេះ និងបានត្រៀមខ្លួនប្រកួតប្រជែង ដើម្បីទទួលបានអំណាចនយោបាយនេះទាំងមុន និងក្រោយការបោះឆ្នោត ។ ផ្ទុយទៅវិញ ថ្នាក់ដឹកនាំខ្មែរក្រហមមើលឃើញថា សម្ព័ន្ធភាពរបស់គណបក្សទាំងបីខាងលើគ្រាន់តែជាការសមគំនិតមួយរបស់អន្តរជាតិតែប៉ុណ្ណោះ ។

សម្រាប់ ប៉ុល ពត ការចូលរួមនៅក្នុងការបោះឆ្នោត ប្រៀបដូចជាការយកក្បាលខ្លួនឯងទៅដាក់ក្នុងមាត់ខ្លា ។ ថ្នាក់ដឹកនាំខ្មែរក្រហមបានធ្វើពហិការមិនចូលរួម នៅក្នុងការបោះឆ្នោត ។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៩៣ គឺ៦សប្តាហ៍មុនការបោះឆ្នោត ខ្មែរក្រហមបានបិទការិយាល័យរបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញ និងបានដកកម្មាភិបាលរបស់ខ្លួនត្រឡប់មកតំបន់ដែលខ្លួនគ្រប់គ្រងវិញ ។ ខ្មែរក្រហមបានបិទច្រកចេញចូលទៅកាន់តំបន់កាន់កាប់របស់ខ្លួនទាំងអស់ និងបានបដិសេធមិនទម្លាក់អាវុធ ។

មេដឹកនាំខ្មែរក្រហមក៏បានហាមប្រជាជន និងកងទ័ពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនមិនឲ្យទៅបោះឆ្នោត ។ មេដឹកនាំខ្មែរក្រហមបានណែនាំប្រជាជនរបស់ខ្លួនថា «បើចូលរួមយើងស្លាប់លឿន បើមិនចូលរួមយើងស្លាប់យឺត ។»[២៣២] ដោយសារហេតុផលនេះ ខ្មែរក្រហមបានសម្រេចចិត្តបន្តការតស៊ូរបស់ខ្លួនប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជាដែលទើបជាប់ឆ្នោតថ្មីបន្តទៀត ។[២៣៣]

បន្ទាប់ពីជោគជ័យនៅក្នុងការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣ រដ្ឋាភិបាលកម្ពុជា ដែលកើតឡើងដោយការបោះឆ្នោតប្រកបដោយប្រជាធិបតេយ្យ ត្រូវបានបង្កើតឡើងដោយមិនបានផ្តល់គុណសម្បត្តិអ្វីទាំងអស់ដល់ចលនាខ្មែរក្រហម ។ ម្យ៉ាងខ្មែរក្រហមមានឱកាសតិចតួចណាស់ ក្នុងការទទួលបានការគាំទ្រផ្នែកនយោបាយបើប្រៀបធៀបទៅនឹងការគាំទ្រផ្នែកយោធា ។ ម្យ៉ាងទៀត លទ្ធភាពដែលខ្មែរក្រហមអាចគ្រប់គ្រងអំណាចបានវិញ គឺស្ទើរគ្មានទាល់តែសោះ ។

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៤ រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់ស្តីពី«ការដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់» ដែលបានចូលជាធរមាននៅថ្ងៃទី១៥ ខែកក្កដា ។[២៣៤] ច្បាប់នេះផ្តោតទៅលើតែមេដឹកនាំខ្មែរក្រហម និងកងទ័ពខ្មែរក្រហមតែប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលប្រជាជនសាមញ្ញដែលរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមទេ ។ នៅក្រោមច្បាប់នេះ អង្គការខ្មែរក្រហមត្រូវបានចាត់ទុកថាជា អង្គការខុសច្បាប់ ហើយមេដឹកនាំខ្មែរក្រហមអាចប្រឈមមុខនឹងការកាត់ទោសឲ្យជាប់គុកពី១០ឆ្នាំទៅមួយជីវិត ។[២៣៥] ប៉ុល ពត ជឿជាក់ថា មិនមានសង្ឃឹមសម្រាប់ដំណោះស្រាយសន្តិភាព និងការផ្សះផ្សាទៅថ្ងៃអនាគតទេ ។ ដូច្នេះ មេដឹកនាំខ្មែរក្រហមបានសម្រេចថា ជម្រើសតែមួយគត់គឺបន្តការធ្វើសង្គ្រាម ។

នៅក្នុងដំណាក់កាលនេះ ខ្មែរក្រហមបន្តរស់នៅដោយភាពភ័យខ្លាច ហើយក៏មិនស្ថិតនៅក្នុងស្ថានភាពមួយរឹងមាំនោះដែរ ។ អតីតសម្ព័ន្ធមិត្តនយោបាយពីររបស់ខ្មែរក្រហមគឺ ហ៊ុនសិនប៉ិច និងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ[២៣៦] ត្រូវអនុវត្តតាមកាតព្វកិច្ចដែលមានចែងនៅក្នុងសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស និងមិនអាចបន្តសហការជាមួយខ្មែរក្រហមបានទៀតទេ ។

ការផ្តាច់ជំនួយអន្តរជាតិបន្ទាប់ពីឆ្នាំ១៩៩៣ បានជំរុញឲ្យមេដឹកនាំខ្មែរក្រហមធ្វើវិមជ្ឈការកម្លាំងរបស់ខ្លួន ។ ដូចដែលបានលើកឡើងខ្មែរក្រហមបានបាត់បង់ជំនួយបរទេសស្ទើរតែទាំងអស់ បន្ទាប់ពីឆ្នាំ១៩៩១ ។ ក្រៅពីអាជីវកម្មក្រៅផ្លូវការជាមួយថៃ ខ្មែរក្រហមរស់នៅដោយពឹងផ្អែកទាំងស្រុងទៅលើធនធានដែលខ្លួនមាន ។[២៣៧] នៅពេលកម្លាំងខ្មែរក្រហមទទួលបន្ទុកកាន់តែធ្ងន់ជាងមុនសម្រាប់ជីវភាពរស់នៅរបស់ខ្លួន ជម្លោះផ្នែកសេដ្ឋកិច្ច និងក្រោយមកជម្លោះនយោបាយបានកើតឡើងនៅក្នុងចលនានេះ ។ ដោយត្រូវរស់នៅដោយខ្លួនឯង ចលនាខ្មែរក្រហមបានបែកបាក់ទៅជាក្រុមតូចៗនៅតាមតំបន់ផ្សេងៗ ដែលបានបង្កើតជាបក្ខពួកនិយម ។ បន្ថែមពីលើនេះ រាជរដ្ឋាភិបាលកម្ពុជាបានឆ្លៀតឱកាសទាញយកប្រយោជន៍ពីការបែកបាក់នេះ ដោយជំរុញឲ្យមានការផ្តាច់ខ្លួន ។ នៅពេលដែលការផ្តាច់ខ្លួនកាន់តែកើនឡើងមេដឹកនាំខ្មែរក្រហមកាន់តែធ្លាក់ចូលទៅក្នុងភាពឯកោ និងចាប់ផ្តើមសង្ស័យគ្នាទៅវិញទៅមក ។ ជាលទ្ធផលមេដឹកនាំខ្មែរក្រហមចាប់ផ្តើមវាយប្រហារគ្នា ។

ក្នុងចំណោមក្រុមខ្មែរក្រហមទាំងអស់ តាម៉ុក គឺជាមេដឹកនាំដែលជោគជ័យជាងគេនៅក្នុងការរៀបចំសេដ្ឋកិច្ចអន្លង់វែងឡើងវិញ ដែលអាចរស់រានបានដោយមិនពឹងផ្អែកទៅលើជំនួយបរទេស ។ តាម៉ុក មិនចង់ពឹងផ្អែកទៅលើមេដឹកនាំខ្មែរក្រហមផ្សេងទៀតសម្រាប់ការរស់នៅរបស់ខ្លួនឡើយ ។ គីម ណាន បានរំឭកសម្តីរបស់ តាម៉ុក ថា « នឹងមិនសុំលុយពីអ្នកណាម្នាក់ទេ ។ មានលុយជាច្រើននៅភាគខាងលិច ។ ប៉ុល ពត មានលុយច្រើនណាស់ ។ ប៉ុន្តែ នឹងមិនសុំជំនួយពីគាត់ទេ ។»[២៣៨]

ទោះជាយ៉ាងនេះក្តីការសម្រេចចិត្តនេះមិនមែនជាបំណងប្រាថ្នារបស់ប្រជាជននៅអន្លង់វែងទេ ។ ប្រជាជនភាគច្រើនដែលរស់នៅតំបន់អន្លង់វែងបានលះបង់ ពេលវេលាស្ទើរពេញមួយជីវិតរបស់ខ្លួនចូលរួមក្នុងចលនាតស៊ូកុម្មុយនីស្ត ។ ប្រជាជនមួយចំនួនបាន

ចូលរួមជាមួយខ្មែរក្រហមតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០ ។ ដូច្នេះ ប្រជាជនទាំងនោះបានចូលបម្រើខ្មែរក្រហមអស់រយៈពេលជាង២០ឆ្នាំ ។ បន្ទាប់ពីរយៈពេលជាង២០ឆ្នាំនៃការធ្វើសង្គ្រាម សូម្បីតែកម្មាភិបាលខ្មែរក្រហមដែលរឹងរូសបំផុតក៏បានចោទសួរអំពីលទ្ធផលនៃការបន្តធ្វើសង្គ្រាមដែរ ។

កត្តាធំបំផុតនៃជម្លោះផ្ទៃក្នុងរបស់ខ្មែរក្រហម គឺការផ្តាច់ខ្លួនក្នុងទ្រង់ទ្រាយធំរបស់កម្លាំងខ្មែរក្រហមសេសសល់នៅតំបន់ម៉ាឡៃ និងប៉ៃលិន ។ នៅខែតុលា ឆ្នាំ១៩៩៦ អៀង សារី បានដឹកនាំកងទ័ពជាង៣ពាន់នាក់នៅតំបន់ប៉ៃលិន និងម៉ាឡៃ ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។[២៣៩] ពិធីផ្តាច់ខ្លួនជាផ្លូវការត្រូវបានប្រារព្ធធ្វើឡើងនៅប៉ៃលិន នៅថ្ងៃទី៦ និងនៅម៉ាឡៃ នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ។ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ទៀ បាញ់ និង ទៀ ចំរ៉ាត់ ដែលតំណាងឲ្យរាជរដ្ឋាភិបាលកម្ពុជា និង អៀង សារី, អ៊ី ឈាន និង សុខ ភាព ដែលតំណាងឲ្យភាគីខ្មែរក្រហមបានចូលរួមធ្វើជាអធិបតីនៅក្នុងពិធីនេះ ។ ក្រោយមកទៀត ការផ្តាច់ខ្លួនក្នុងទ្រង់ទ្រាយតូចផ្សេងៗទៀតបានចាប់ផ្តើមកើតឡើងជាបន្តបន្ទាប់ ។ ការផ្តាច់ខ្លួនទាំងនោះរួមមានការផ្តាច់ខ្លួនរបស់ក្រុមខ្មែរក្រហមនៅសំឡូត[២៤០] កងពល៥១៩ នៅខេត្តបន្ទាយមានជ័យដឹកនាំដោយ សូ ហុង និង ឌុល សារឿន[២៤១] និងក្រុមខ្មែរក្រហម នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ។[២៤២] កែវ សាន មេបញ្ជាការខ្មែរក្រហមនៅភ្នំស្រួច និង កែវ ពង្ស មេបញ្ជាការខ្មែរក្រហមនៅភ្នំឱរ៉ាល់ បានចុះចូលជាមួយរាជរដ្ឋាភិបាលតាំងពីដើមឆ្នាំ១៩៩៦ ។[២៤៣] នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៦ នី កន, សុន ឈុំ និង មាស មុត បានដឹកនាំការផ្តាច់ខ្លួនរបស់កម្លាំងខ្មែរក្រហមនៅស្រុកកំរៀង ភ្នំព្រឹក្ស និងសំពៅលូន ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

ការផ្តាច់ខ្លួនទាំងអស់នេះគឺជាកត្តាចម្បងមួយ ដែលបានបង្ហាញឲ្យឃើញពីការធ្លាក់ចុះនៃចលនាខ្មែរក្រហម ។ ការផ្តាច់ខ្លួនគឺជាការវាយបំបាក់ផ្នែកស្មារតី និងក៏ដូចជាការផ្តួលរំលំផ្នែកយោធា ។ នៅទីបំផុត ការផ្តាច់ខ្លួននេះបានបង្កឲ្យមានការបែកបាក់ផ្ទៃក្នុងនៅក្នុងរង្វង់មេដឹកនាំខ្មែរក្រហម ដែលនឹងនាំទៅដល់ការដួលរលំរបស់ចលនាខ្មែរក្រហម ។

ជំពូក១៧

# ជម្លោះរវាង ប៉ុល ពត និង តាម៉ុក

ជម្លោះរវាង ប៉ុល ពត និង តា ម៉ុក ចាប់ផ្តើមនៅពេលមានការផ្តាច់ខ្លួននៅប៉ៃលិន និង ម៉ាឡៃ ។ ប៉ុល ពត ជឿជាក់ថា អៀង សារី, អ៊ី ឈាន និង សុខ ភាព អាចនឹងវិលត្រឡប់មក ចូលរួមជាមួយចលនារបស់ខ្លួនវិញ ។ នៅដើមខែតុលា ឆ្នាំ១៩៩៦ ប៉ុល ពត បានបញ្ជាឲ្យ តាម៉ុក និង នួន ជា ទៅដោះស្រាយបញ្ហាផ្តាច់ខ្លួននៅប៉ៃលិន និងម៉ាឡៃ ។

ទទួលបានបញ្ជារបស់ ប៉ុល ពត តាម៉ុក និង នួន ជា បានធ្វើដំណើរទៅប៉ៃលិន ដោយ ពុំមានកងទ័ពទៅជាមួយទេ ។ មានតែអង្គរក្សពីរបីនាក់ប៉ុណ្ណោះ ដែលបានអមដំណើរ តាម៉ុក និង នួន ជា ។ ប៉ុល ពត បានដឹងថា មេបញ្ជាការកងទ័ពរបស់ អៀង សារី បានកាន់កាប់សិទ្ធិ កងទ័ពទាំងស្រុងនៅប៉ៃលិន ។ ដូច្នេះ ប្រសិនបើជម្លោះកើតឡើង តាម៉ុក និង នួន ជា នឹង ពិបាកក្នុងការវិលត្រឡប់មកវិញ ។[៧៤៤]

តាម៉ុក និង នួន ជា មិនសម្រេចបានលទ្ធផលនៅក្នុងបេសកកម្មនេះទេ ដែលបានធ្វើឲ្យ ប៉ុល ពត ខឹងសម្បារទៅវិញ ។ តាម៉ុក និង នួន ជា មិនត្រឹមតែមិនអាចបញ្ចុះបញ្ចូលកម្លាំង ខ្មែរក្រហមនៅប៉ៃលិន និងម៉ាឡៃឲ្យវិលត្រឡប់មកវិញបាននោះទេ ថែមទាំងត្រូវបាន បណ្តេញចេញពីតំបន់នោះថែមទៀតផង ។ អ្នកទាំងពីរបានរត់មកសំឡូត ហើយបានជួប ជាមួយ សុន សេន ។ មេដឹកនាំទាំង៣រូបបានធ្វើដំណើរត្រឡប់មកអន្លង់វែងជាមួយគ្នាតាម ប្រទេសថៃ ។ ម៉ៅ ដែលជាអង្គរក្សជំនិតរបស់ តាម៉ុក បានអៀវ តាម៉ុក ដោយសារ តាម៉ុក ពិការជើងម្ខាង និងមិនអាចដើរដោយខ្លួនឯងបាន ។ ជាការតបស្នងនូវភាពស្មោះត្រង់របស់ កងទ័ព សុន សេន បានប្រគល់លុយមួយបង្វេចឲ្យទៅកងទ័ពទាំងនោះ ដែលបានជួយជូនពួក ខ្លួនទៅដល់ប្រទេសថៃ ដោយសុវត្ថិភាព ។ សហនាយករដ្ឋមន្ត្រី សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន បានស្នើសុំទៅអាជ្ញាធរថៃ ឲ្យចាប់ខ្លួន តាម៉ុក, នួន ជា និង សុន សេន ។ ប៉ុន្តែអាជ្ញាធរថៃមិនបានធ្វើតាមសំណើនេះទេហើយ តាម៉ុក, នួន ជា និង សុន សេន បានធ្វើដំណើរត្រឡប់មកអន្លង់វែងវិញដោយគ្មានឧបសគ្គអ្វីទាំងអស់ ។

ពេលធ្វើដំណើរមកដល់ព្រំដែនថៃ ម៉ៅ (អង្គរក្សរបស់ តាម៉ុក) បានទូរស័ព្ទមកអន្លង់វែង ដោយបានស្នើសុំឡានមួយគ្រឿងមកទទួល តាម៉ុក, នួន ជា និង សុន សេន ត្រឡប់មកតំបន់កាន់កាប់វិញ ។ ជាជាងទទួលបានជំនួយ ម៉ៅ ត្រូវបាន ប៉ុល ពត បញ្ជាឲ្យទិញសាំងដើម្បីដុតសម្លាប់មេដឹកនាំ ដែលជិះនៅក្នុងឡាននោះ ។ ម៉ៅ ស្គាល់ តាម៉ុក តាំងពីនៅក្មេង និងបានបម្រើ តាម៉ុក ស្ទើរពេញមួយជីវិតយុវវ័យរបស់គាត់ ។ ម៉ៅ បានបដិសេធមិនធ្វើតាមបញ្ជានេះទេ ។ ផ្ទុយទៅវិញ ម៉ៅ បានជួលរថយន្តមួយគ្រឿងពីថៃ ដើម្បីជូនមេដឹកនាំទាំងបីត្រឡប់មកអន្លង់វែងវិញ ។[២៨៥]

ប៉ុល ពត បានធ្វើដំណើរមកជួប តាម៉ុក នៅពេលដែល តាម៉ុក មកផ្ទះរបស់គាត់នៅពើយតារូន ។ មេដឹកនាំទាំងពីរបានជួបគ្នាអស់រយៈពេលដ៏យូរ និងបានឈ្លោះប្រកែកគ្នាខ្លាំងៗ ។ ប៉ុល ពត បានចាប់ខ្លួន និងឃុំឃាំង តាម៉ុក, នួន ជា និង សុន សេន អស់រយៈពេល៦ខែចាប់ ពីខែតុលា ឆ្នាំ១៩៩៦ ដល់ ខែកុម្ភៈ ឆ្នាំ១៩៩៧ ។ តាម៉ុក បានរំឭកថា « ត្រូវបានឃុំខ្លួន អស់រយៈពេល៦ខែជាមួយ នួន ជា និង សុន សេន ។ យើងស្ថិតនៅក្នុងបន្ទប់ងងឹត និង មិនត្រូវបានអនុញ្ញាតឲ្យដើរទៅណាទេ ។ គិតថា ប្រហែលជាគាត់ខ្លាចធ្លាយព័ត៌មានចេញទៅក្រៅ ។ មិននឹកស្មានថា គេចង់សម្លាប់យើងសោះ ។»[២៨៦]

## គណៈកម្មាធិការ១៩ ៖ មេដឹកនាំខ្មែរក្រហមជំនាន់ថ្មី

ទោះបីជា ប៉ុល ពត ឃុំឃាំងមេដឹកនាំជាន់ខ្ពស់ទាំងបីយ៉ាងស្ងៀមស្ងាត់ នៅក្នុងអំឡុងពេលនោះ ប៉ុល ពត មិនបានសម្លាប់មេដឹកនាំទាំងនោះទេ ដែលអាចនឹងបង្កឲ្យមានជម្លោះ ។ ផ្ទុយទៅវិញ ប៉ុល ពត បានជ្រើសរើសការដកហូតការគាំទ្រ (ជាពិសេសពី តាម៉ុក) ដោយបានស្នើឲ្យមានការផ្លាស់ប្តូរថ្នាក់ដឹកនាំនៅអន្លង់វែង ។ ប៉ុល ពត បានស្នើថា គ្រប់មេដឹកនាំខ្មែរក្រហមដែលមានវ័យចំណាស់ទាំងអស់ ដែលរួមទាំង តាម៉ុក និងខ្លួនគាត់ផងត្រូវចូលនិវត្តន៍ និងទុកឱកាសឲ្យអ្នកដឹកនាំជំនាន់ក្រោយបន្តការតស៊ូ ។ មេដឹកនាំចាស់ទាំងអស់នឹងធ្វើជាទីប្រឹក្សារបស់ចលនានេះ ។ នៅខែកុម្ភៈ ឆ្នាំ១៩៩៧ ប៉ុល ពត បានរៀបចំមហាសន្និបាតមួយ ដែលមានអ្នកចូលរួមប្រមាណ៤រយនាក់ ដែលភាគច្រើនគឺជាមេបញ្ជាការកងទ័ព ។ គោលបំណងនៃមហាសន្និបាតនេះ គឺការពិភាក្សាអំពីការផ្ទេរអំណាចពីមេដឹកនាំចាស់ៗទៅឲ្យអ្នកជំនាន់ថ្មី ។ ការផ្ទេរអំណាចនឹងត្រូវធ្វើឡើងតាមរយៈការបោះឆ្នោត ។

បេក្ខជនចំនួន១០រូបបានឈរឈ្មោះសម្រាប់ការបោះឆ្នោតផ្ទេរអំណាចនេះ ដែលរួមមាន សូ សារឿន, មៀច សាន, ឌឹម ផុន, ញាន, ហឿន និង ខន ។ មៀច សាន ដែលជាមេបញ្ជាការស្និទ្ធនឹង ប៉ុល ពត ទទួលបានសំឡេងគាំទ្រច្រើនជាងគេ ។ ទោះជាយ៉ាងនេះក្តី សាន បានសម្រេចចិត្តមិនប្រកួតប្រជែងជាមួយ សារឿន ដែលជាអតីតមេបញ្ជាការរបស់គាត់ និងដែលបានចូលបម្រើបដិវត្តន៍មុនគាត់ ។ មេដឹកនាំជាន់ខ្ពស់ ខ្មែរក្រហមបានពិភាក្សាគ្នា និងបានសម្រេចថា សូ សារឿន គឺជាមេដឹកនាំជំនាន់ថ្មីរបស់ចលនាខ្មែរក្រហម ។ ប៉ុន្តែ តាម៉ុក ចង់ឲ្យ ឌឹម ផុន (បុរសមមិត្ត៤២) ដែលជាមេបញ្ជាការស្និទ្ធនឹងគាត់ធ្វើជាមេដឹកនាំវិញ ។

បន្ទាប់ពីការបោះឆ្នោតនៅក្នុងមហាសន្និបាតរួចមក ប៉ុល ពត បានបង្កើតគណៈកម្មាធិការមួយ ដែលមានសមាជិក១០នាក់ ។ គណៈកម្មាធិការនោះមានឈ្មោះថា «គណៈកម្មាធិការ១៩» ដែលដឹកនាំដោយ សូ សារឿន ដែលបានក្លាយទៅជាអគ្គមេបញ្ជាការកងទ័ពនៅតំបន់អន្លង់វែង ។ ទីបញ្ជាការរបស់ សារឿន មានទីតាំងនៅឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ។ សារឿន និង ឌឹម ផុន មិនចុះសម្រុងនឹងគ្នាទេ ។ សារឿន មានបំណងចង់ប្រមូលផ្តុំអំណាច ដោយកម្ចាត់មេទ័ពខ្លាំងៗដែលស្និទ្ធនឹង តាម៉ុក ។ មេទ័ពល្បីៗ



របស់ តាម៉ុក (ដូចជា ខឹម នុន, ឡុង ទេម និង យឹម ផាន់ណា) នឹងត្រូវបានដកហូតសិទ្ធិកងទ័ព និងត្រូវបានតែងតាំងឲ្យកាន់ការងាររដ្ឋបាលជំនួសវិញ ។

តាម៉ុក បានប្រឆាំងទៅនឹងគំនិតផ្តួចផ្តើមនេះ ។ តាម៉ុក យល់ឃើញថាកិច្ចការទាំងអស់នេះគឺជាយុទ្ធសាស្ត្ររបស់ ប៉ុល ពត ក្នុងការប្រមូលផ្តុំអំណាចនៅអន្លង់វែង ។[២៤៧] នៅពេលកម្លាំងរបស់ ប៉ុល ពត ត្រូវបានបញ្ជូនទៅក្នុងប្រទេសទៅធ្វើការតាមតំបន់ឆ្ងាយៗ កម្លាំងរបស់ តាម៉ុក ភាគច្រើនឈរជើងនៅក្បែរតំបន់អន្លង់វែង ។ ស្ថានភាពបែបនេះអនុញ្ញាតឲ្យតាម៉ុក អាចរារាំងដំណើរការរបស់គណៈកម្មាធិការ១៩ និងបន្តគ្រប់គ្រងអំណាចនៅអន្លង់វែង ។ បន្ទាប់ពីមហាសន្និបាតនៅខែកុម្ភៈនោះមក តាម៉ុក បានចាប់ផ្តើមធ្វើការចរចាសាជាថ្មីជាមួយរាជរដ្ឋាភិបាលតាមរយៈគណបក្សហ៊្វុនស៊ិនប៉ិច ។ នៅក្នុងការចរចានេះ តាម៉ុក បានយល់ព្រមជាគោលការណ៍ថា ប៉ុល ពត នឹងមិនមានសំឡេងអ្វីទាំងអស់ នៅក្នុងកិច្ចចរចាសម្បទាននយោបាយជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

## ការសម្លាប់ សុន សេន

នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៧ សុន សេន ដែលជាជនបដិវត្តន៍ដ៏យូរឆ្នាំមួយរូបរបស់ ប៉ុល ពត ត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃ ។[២៤៨] ជាងនេះទៅទៀត សមាជិកគ្រួសារចំនួន១០នាក់ទៀត ដែលរួមមាន យ៉ុន យ៉ាត (ប្រពន្ធរបស់ សុន សេន និងជារដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំ និងសិក្សាជាតិ) កូនស្រីពីរនាក់ ចៅប្រុសអាយុ៥ឆ្នាំម្នាក់ អ្នកបើករថយន្តម្នាក់ និងនីរសារម្នាក់ត្រូវបានសម្លាប់ទាំងអស់ ។ ការសម្លាប់ សុន សេន គឺជាព្រឹត្តិការណ៍ចុងក្រោយមួយនៃថ្ងៃចុងក្រោយនៃចលនាខ្មែរក្រហមនៅអន្លង់វែង ។

នៅយប់នៃការសម្លាប់ សុន សេន គឺ ប៉ុល ពត បានសុំឲ្យមានការប្រជុំមួយជាមួយ សុន សេន ។ ប៉ុន្តែ សុន សេន បានបដិសេធការប្រជុំនោះ ។ យ៉ុន យ៉ាត បានប្រាប់ទៅនីរសារថា វាយប់ជ្រៅពេក ហើយសុំពន្យារពេលប្រជុំទៅព្រឹកនៃថ្ងៃបន្ទាប់វិញ ។[២៤៩] ប៉ុល ពត បានបញ្ជាឲ្យមេទ័ពរបស់គាត់ សូ សារឿន សម្លាប់ សុន សេន និងប្រពន្ធ ដែលកំពុងស្នាក់នៅក្នុងផ្ទះដែល តាម៉ុក សង់ឲ្យនៅក្បែរពើយតារូន ។ សារឿន បានដឹកនាំកម្លាំងប្រមាណពី២០ទៅ៣០នាក់ទៅផ្ទះ សុន សេន នៅវេលាម៉ោងប្រហែល១១យប់ ។ កងទ័ពបានស្រែកហៅ

សុន សេន និងប្រពន្ធឲ្យចេញមកខាងក្រៅផ្ទះ ហើយបានបាញ់សម្លាប់អ្នកទាំងពីរ ។[២៥០] សារឿន បានអនុវត្តលើសពីបញ្ជារបស់ ប៉ុល ពត ដោយបានសម្លាប់សាច់ញាតិរបស់ សុន សេន ចោលទាំងអស់ ។[២៥១] មានការជឿជាក់ថាកូនស្រីទាំងពីររបស់ សុន សេន ត្រូវបានរំលោភមុននឹងសម្លាប់ ។ ឡិ រិន អតីតកងទ័ពនៅក្នុងកងពល៩១២ បានឃើញសាកសពរបស់ស្ត្រីទាំងពីរ ដែលត្រូវបានទុកចោលអាក្រាតកាយនៅលើផ្ទាំងថ្ម ដោយនៅខ្លួនមានតែខោក្នុងប៉ុណ្ណោះ ។[២៥២] អាក្រក់ជាងនេះទៅទៀតកងទ័ពបានបើកឡានកិនពីលើសាកសពទាំងនោះ ដែលបណ្ដាលឲ្យសាកសពប្រេះលលាដ៏ក្បាល និងបាក់ដៃជើងជាបំណែក ។

សាកសពរបស់ សុន សេន និងសាកសពក្រុមគ្រួសារទាំងអស់ ត្រូវបានយកទៅបូជាជាមួយគ្នា នៅទីតាំងមួយ ដែលបច្ចុប្បន្នក្លាយទៅជាវត្តស្រះឈូក ។ ប្រជាជនរាប់រយនាក់ដែលរស់នៅក្បែរនោះ បានមកមើលការបូជាសពនេះ ។ បន្ទាប់ពីបូជារួច ឆ្អឹង និងផេះត្រូវបានកប់នៅក្បែរនោះ ។ កន្លែងបូជាសពនៅមិនឆ្ងាយប៉ុន្មានពីចេតិយរបស់ តាម៉ុក ទេ ។ ដោយសារតែមិនមានសញ្ញាសម្គាល់ច្បាស់លាស់កន្លែងបូជានេះអាចត្រូវបានសម្គាល់តាមរយៈដំបូកដីតូចៗពីរបីនៅទីនេះ ។[២៥៣]

បន្ទាប់ពីទទួលបានដំណឹងអំពីការស្លាប់របស់ សុន សេន តាម៉ុក បានធ្វើការសន្និដ្ឋានថា ប៉ុល ពត មានបំណងចង់សម្លាប់គាត់នៅក្នុងការធ្វើបន្សុទ្ធកម្មរួម ។ តាម៉ុក ខឹងនឹង ប៉ុល ពត និង សូ សារឿន យ៉ាងខ្លាំង និងបានកោះប្រជុំជាបន្ទាន់មួយជាមួយមេបញ្ជាការកងទ័ព នៅផ្ទះរបស់គាត់ក្បែរមាត់ទឹក ។ តាម៉ុក បានប្រាប់ទៅមេទ័ពទាំងអស់ថា ប៉ុល ពត និង សូ សារឿន មានបំណងចង់សម្លាប់គាត់ និងចង់ធ្វើជាស្ដេចនៅអន្លង់វែង ។ តាម៉ុក បានប្រាប់មេទ័ពរបស់គាត់ឲ្យត្រៀមខ្លួនធ្វើសង្គ្រាមជាមួយ ប៉ុល ពត ។

## ការប្រយុទ្ធរវាង ប៉ុល ពត និង តាម៉ុក

ការស្លាប់របស់ សុន សេន បានបង្កឲ្យមានការប៉ះទង្គិចគ្នាចំនួន៥ថ្ងៃនៅអន្លង់វែង ។ នៅចន្លោះពីថ្ងៃទី១០ ទៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៩៧ កងទ័ពដែលស្មោះត្រង់នឹង តាម៉ុក បានប៉ះទង្គិចគ្នាជាមួយកងទ័ពដែលស្មោះត្រង់នឹង ប៉ុល ពត ។

នៅយប់ថ្ងៃទី៩ ខែមិថុនា តាម៉ុក បានបញ្ជាឲ្យប្រមូលផ្ដុំកម្លាំងទាំងអស់របស់គាត់ ដើម្បីវាយដណ្ដើមយកសាកសពរបស់ សុន សេន និងក្រុមគ្រួសារ ដែលក្រោយមករូបថត

របស់សាកសពទាំងនោះត្រូវបានប្រើប្រាស់សម្រាប់ធ្វើការឃោសនា ។ នៅថ្ងៃទី១០ ខែមិថុនា ប្រហែលម៉ោង៧ព្រឹក តាម៉ុក និងកងកម្លាំងរបស់គាត់បានផ្សព្វផ្សាយការសម្លាប់ សុន សេន ជាសាធារណៈ ដើម្បីប្រមូលការគាំទ្រពីកងទ័ព និងប្រជាជន ។ តាម៉ុក បានប្រកាសប្រាប់ប្រជាជនថា សុន សេន និងក្រុមគ្រួសារទាំងអស់ត្រូវបានសម្លាប់ ។ ជាមួយនឹងរូបថតសាកសពរបស់ សុន សេន ជាភ័ស្តុតាង តាម៉ុក បានអំពាវនាវដល់ប្រជាជនឲ្យចូលរួមជាមួយគាត់ ដើម្បីធ្វើការតស៊ូប្រឆាំងនឹង ប៉ុល ពត ។

តា ម៉ុក បានបញ្ជាឲ្យកងពល៩៨០ និងកងពល៩១២ ចាប់ខ្លួន ប៉ុល ពត និងបក្ខពួក ។[២៥៤] ឡុង ទេម, សាន់ គង់, យឹម ផាន់ណា, យឹម ពែម និង ម៉ុន ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវក្នុងការដឹកនាំកម្លាំងរបស់ តាម៉ុក ប្រយុទ្ធជាមួយនឹងកម្លាំងរបស់ ប៉ុល ពត ដែលរួមមានកងពល៨០១របស់ សូ សារឿន និងកងពល៩២០ របស់ មៀច សាន ។ តាម៉ុក ក៏បានសុំជំនួយពី ញឹក ប៊ុនឆៃ (ដែលជាមេបញ្ជាការកងទ័ពរបស់ហ៊ុនស៊ិនប៉ិច) ដែលបានដឹកជញ្ជូនគ្រឿងសព្វាវុធតាមខ្ទម្ពាគបក្រពីទីតាំងយោធានៅអូរស្មាច់មកឲ្យកម្លាំងរបស់ តាម៉ុក នៅអន្លង់វែង ។ កងទ័ព១៥នាក់ត្រូវបានចាត់តាំងឲ្យការពារឃ្លាំងកណ្តាលដែលជាឃ្លាំងផ្គត់ផ្គង់សម្ភារៈសំខាន់ៗរបស់តំបន់អន្លង់វែង ។ ការងាររបស់កងទ័ពទាំងអស់នេះ គឺត្រូវប្តូរផ្តាច់ការពារកុំឲ្យឃ្លាំងនេះ ធ្លាក់ទៅក្នុងដៃរបស់កងកម្លាំងរបស់ ប៉ុល ពត ។

ឆ្លើយតបទៅនឹងការឃោសនារបស់ តាម៉ុក គឺ ប៉ុល ពត បានវាយប្រហារ តាម៉ុក តាមវិទ្យុ ។ ប៉ុល ពត បានចោទប្រកាន់កងកម្លាំងរបស់ តាម៉ុក ថា ក្បត់ជាតិ ។ ខៀវ សំផន ក៏បានចូលរួមនៅក្នុងជម្លោះនោះដែរ ។ នៅថ្ងៃទី១១ ខែមិថុនា ខៀវ សំផន បានអានសេចក្តីប្រកាសរបស់ ប៉ុល ពត តាមវិទ្យុដោយបានចោទប្រកាន់ សុន សេន ថាបានក្បត់នឹងចលនា និងជាភ្នាក់ងារស៊ើបការសម្ងាត់របស់«រដ្ឋាភិបាលអាយ៉ងយួន» នៅទីក្រុងភ្នំពេញ ។

នៅក្នុងអំឡុងពេលនៃជម្លោះ ប្រជាជនមិនត្រូវបានអនុញ្ញាតឲ្យដើរ ហើរដោយសេរីនៅពេលយប់ទេ ។ ផ្លូវត្រូវបានបិទនៅម៉ោង៥ឬ៦ល្ងាច ។ ប្រជាជនបានឃើញ កងទ័ពចល័តទៅមកនៅអន្លង់វែងនៅរៀងរាល់ល្ងាច ដែលធ្វើឲ្យប្រជាជនមានការភ័យខ្លាច ។ ការប្រយុទ្ធគ្នានេះ គឺជាការវាយប្រហារយ៉ាងដំណំទៅលើទស្សនៈរបស់ប្រជាជន ។ នៅក្នុងន័យមួយ ភាពតានតឹងតែងតែកើតមានរវាងក្រុមផ្សេងៗគ្នា ។ ប៉ុន្តែ ការប្រយុទ្ធគ្នាជាចំហបែបនេះ បានបញ្ជាក់អំពីការខ្វះសាមគ្គីភាពនៅក្នុងចលនាខ្មែរក្រហម និងបានបំផ្លាញ

សេចក្តីទុកចិត្តរបស់ប្រជាជន ទៅលើមេដឹកនាំរបស់ខ្លួន ។ យ៉ក់ ហម ដែលជាកម្មករនៅរោងចក្រអារឈើរបស់ តាម៉ុក បានបង្ហាញអំពីអារម្មណ៍របស់គាត់ បន្ទាប់ពីបានដឹងអំពីការសម្លាប់ សុន សេន ។

> *នៅពេលដែលខ្ញុំឃើញមេដឹកនាំខ្មែរក្រហមប្រយុទ្ធគ្នាដោយ បើកចំហបែបនេះ ខ្ញុំបានបាត់បង់ការជឿជាក់ទាំងអស់ទៅលើពួកគាត់ ។ ខ្ញុំមិនដឹងថាតើខ្ញុំអាចបន្តធ្វើការនិងរស់នៅជាមួយគាត់បានដោយរបៀបណានោះទេ ។ ខ្ញុំយល់ឃើញថា មធ្យោបាយតែមួយគត់ ដែលអាចទទួលបានសុភមង្គល និងសុវត្ថិភាពគឺការចុះចូលជាមួយរដ្ឋាភិបាល ។ ការប្រយុទ្ធ ការបាញ់ និងការសម្លាប់គ្នាបង្កតែភាពតានតឹងតែប៉ុណ្ណោះ ។ ជឿជាក់ថា ជីវិតបែបនេះគឺគ្មានអនាគតទេ ។ យើងរស់នៅក្នុងអគ្គភាព និងកងខុសៗគ្នា ដែលកងនីមួយៗមានមេដឹកនាំម្នាក់ ។ ប៉ុន្តែ មេដឹកនាំរបស់យើងមិនចុះសម្រុងនឹងគ្នានោះទេ ។ ដូច្នេះ យើងមិនអាចរស់នៅជាមួយគ្នាដោយសន្តិភាពបានទេ ។ រៀងរាល់ឆ្នាំ យើងតស៊ូ ជាមួយនឹងសង្គ្រាម និងបញ្ហាជាប់ជានិច្ច ។ យើងប្រយុទ្ធជាមួយរដ្ឋាភិបាល និងទទួលបញ្ជាឲ្យដុតផ្ទះរបស់ខ្លួនឯងចោល ។ ប៉ុន្តែ អ្វីដែលយើងចង់បាន គឺការវិលត្រឡប់ទៅភូមិរបស់យើងវិញ ។ យើងមានការធុញទ្រាន់នឹងសង្គ្រាមខ្លាំងណាស់ ។ ដោយសារតែកត្តាទាំងអស់នេះហើយ បានជាខ្ញុំយល់ឃើញថា សុភមង្គលអាចសម្រេចបានលុះត្រាតែយើងចុះចូលជាមួយរដ្ឋាភិបាល ។*[៧៥៥]

បន្ទាប់ពីប្រយុទ្ធគ្នាអស់រយៈពេល៥ថ្ងៃ ប៉ុល ពត បានបញ្ជាឲ្យ ស៊ូ សារឿន, មៀច សាន និងមេបញ្ជាការដែលស្មោះត្រង់នឹងខ្លួនដទៃទៀតម្នាក់អារុំង ហើយចរចាជាមួយ តាម៉ុក ។ ប៉ុល ពត មានបំណងបញ្ចុះបញ្ចូល តាម៉ុក ឲ្យបញ្ចប់ការប្រយុទ្ធគ្នា ដោយសារតែ ប៉ុល ពត យល់ឃើញថា បើនៅបន្តប្រយុទ្ធតទៅទៀត «សត្រូវនឹងទទួលបានផលប្រយោជន៍កាន់តែច្រើន» ។ ជាងនេះទៅទៀត មានហេតុផលជាក់ស្តែងក្នុងការបញ្ចប់សង្គ្រាមនេះ ។ ទោះបីជា ប៉ុល ពត ទទួលបានភក្តីភាពពីមេទ័ពរបស់ខ្លួនក៏ដោយ ក៏ ប៉ុល ពត ពុំមានធនធានសេដ្ឋកិច្ច

គ្រប់គ្រាន់ក្នុងការបន្តការប្រយុទ្ធតទៅទៀតបានទេ ។ សរុបមកដោយសារ តាម៉ុក គ្រប់គ្រងលើដង្ហើមសេដ្ឋកិច្ចទាំងអស់នៅតំបន់អន្លង់វែង ប៉ុល ពត មានឱកាសតិចតួចណាស់ក្នុងការទទួលបានជ័យជម្នះពីការប្រយុទ្ធនេះ ។

តា ម៉ុក បានចាប់ខ្លួន សូ សារឿន និងប្រពន្ធ, មៀច សាន និងកូនប្រុស មៀច សារ៉ាវុធ, ព្រមទាំងមេបញ្ជាការកងទ័ពមួយចំនួនទៀតដូចជា ឃន, ធួន, សែន, និង ខេមរា ដែលសុទ្ធតែជាអ្នកស្មោះត្រង់នឹង ប៉ុល ពត ។ អ្នកទាំងនេះត្រូវបានឃុំឃាំង នៅក្នុងទ្រុងដែកដែលមានកម្ពស់ប្រហែលមួយម៉ែត្រកន្លះ ។[២៥៦] សមាជិកគ្រួសារដទៃទៀតរបស់ សារឿន និង សាន ត្រូវបានឃុំខ្លួននៅក្នុងផ្ទះ ។[២៥៧] ពីរខែក្រោយមក សូ សារឿន និងប្រពន្ធ និងមៀច សាន ត្រូវបានកាត់ទោសប្រហារជីវិត ។ អ្នកទាំងបីត្រូវបានកប់ទាំងរស់នៅក្នុងរណ្តៅសាកសពរួម ។[២៥៨]


កន្លែងកាត់ទោសប៉ុលពត
POLPOT'S WAS SENTENCED HERE

ជំពូក ១៣

# ការចាប់ខ្លួន និងការកាត់ទោស ប៉ុល ពត

## ការចាប់ខ្លួន ប៉ុល ពត

ប៉ុល ពត, ខៀវ សំផន, នួន ជា, ដួន ជឿន, ចាន់ យូរ៉ាន់, ទេព ឃុនណាល់ ព្រមទាំងទីប្រឹក្សា និងអ្នកនៅក្រោមបង្គាប់មួយចំនួនបានរត់គេចពីកងកម្លាំងរបស់ តាម៉ុក ទៅលាក់ខ្លួននៅក្នុងរូងភ្នំមួយនៅឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ។ កងទ័ពមួយចំនួនដែលបានរត់ភៀសខ្លួន និងតាមការពារ ប៉ុល ពត គឺជាអតីតកងទ័ពរបស់ តាម៉ុក ។ ដោយសារតែអស់សង្ឃឹម កងទ័ពទាំងនោះចាប់ផ្តើមរត់ចោល ប៉ុល ពត ម្តងម្នាក់ៗ ។ ក្រោយមក កងទ័ពរបស់ តាម៉ុក បានរកឃើញកន្លែងលាក់ខ្លួនរបស់ ប៉ុល ពត ។ កងទ័ពម្នាក់របស់ តាម៉ុក ដែលបានចូលទៅក្នុងរូងភ្នំដើម្បីចាប់ ប៉ុល ពត បានឃើញ ខៀវ សំផន កំពុងចម្អិនអាហារឲ្យ ប៉ុល ពត ។ នៅពេលដែលកងទ័ពរូបនោះដើរសំដៅទៅរកអ្នកទាំងពីរ ប៉ុល ពត និង ខៀវ សំផន បានភ្ជង់កាំភ្លើងខ្លីដាក់ ប៉ុន្តែមិនបានបាញ់ទេ ។[២៥៩] ខៀវ សំផន បម្រុងនឹងបាញ់សម្លាប់ខ្លួនឯង ប៉ុន្តែត្រូវបានដន្លងរបស់គាត់ ដែលជាមេបញ្ជាការរបស់ តាម៉ុក ឃាត់ទាន់ ។

ពេលចូលទៅដល់ក្នុងរូងភ្នំ កងទ័ពបាននិយាយទៅកាន់ ប៉ុល ពត ដោយសម្តីសុភាពរាបសារថា "យើង សុំអញ្ជើញអ៊ំត្រឡប់ទៅវិញ ។ តា ចង់ជួបអ៊ំ ។" នៅទីបញ្ចប់ ប៉ុល ពត ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៧ ។ កងទ័ព បានសែង ប៉ុល ពត នៅលើអង្រឹង ។[២៦០] អ្នកដទៃទៀតដើរ ដោយជើងត្រឡប់មកវិញ ។ ខៀវ សំផន និង នួន ជា បានយំនៅពេលដើរតាមផ្លូវត្រឡប់មកវិញ ដោយសារតែអ្នកទាំងពីរខ្លាច តាម៉ុក សម្លាប់ចោល ។ កងទ័ពបានឃុំឃាំងមេដឹកនាំជាន់ខ្ពស់ទាំងនោះនៅឃ្លាំងកណ្តាល ។ ក្រោយមក ប៉ុល ពត និងមេបញ្ជាការកងទ័ពមួយចំនួនត្រូវបានបញ្ជូនទៅឃុំឃាំងនៅក្បែរច្រកព្រំដែនជាំសាងាំសព្វថ្ងៃ ។ ខៀវ សំផន, នួន ជា, ចាន់ យូរ៉ាន់, ដួន ជឿន, និងមេដឹកនាំផ្សេងទៀតត្រូវបានដោះលែង ។ ដោយគ្មានកន្លែងត្រូវទៅ ឬគេចខ្លួនបានមេដឹកនាំទាំងនេះបានបន្តរស់នៅជាមួយ តាម៉ុក រហូតដល់សមាហរណកម្មនៅឆ្នាំ១៩៩៨ ។

## តុលាការប្រជាជន ៖ ការកាត់ទោស ប៉ុល ពត

នៅថ្ងៃទី២៥ ខែកក្កដា ប៉ុល ពត ត្រូវបាននាំយកមកកាត់ទោស នៅចំពោះមុខ "តុលាការប្រជាជន" ។[២៦១] មេបញ្ជាការកងទ័ពជាន់ខ្ពស់ និងមេដឹកនាំស៊ីវិលចំនួនបួននាក់ ដែលស្មោះត្រង់នឹង តាម៉ុក ត្រូវបានជ្រើសរើសឲ្យធ្វើជាអង្គជំនុំជម្រះ ដែលរួមមាន ខៀវ នៅ (តំណាងឲ្យប្រជាជន), ខឹម ង៉ុន (តំណាងឲ្យកងកម្លាំងប្រដាប់អាវុធ), ម៉ក់ បេន និង ទេព យុនណាល់ (តំណាងឲ្យបញ្ញវន្ត) ។[២៦២] ប្រជាជននៅអន្លង់វែងប្រហែលជាបួនរយទៅប្រាំរយនាក់ ត្រូវបានដឹកឲ្យមកមើលការកាត់ទោសមេដឹកនាំដែលខ្លួនធ្លាប់គោរពបូជាអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ។ អ្នកចូលរួមមិនត្រូវបានអនុញ្ញាតឲ្យយកអាវុធតាមខ្លួនទេ ។ អ្នកចូលរួមភាគច្រើន គឺជាស្ត្រី កុមារ និងកងទ័ពប្រហែលមួយរយនាក់ដែលស្លៀកពាក់ឯកសណ្ឋានពណ៌បៃតងដែលជាជំនួយរបស់ចិន ។ នេះគឺជាលើកទីមួយដែលអ្នកចូលរួមភាគច្រើនបានឃើញមុខ ប៉ុល ពត ដោយផ្ទាល់ បន្ទាប់ពីបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមអស់ជិតបីទសវត្សរ៍ ។

ការកាត់ទោសបានចាប់ផ្តើមជាមួយនឹងស្នូរទះដៃ និងការស្រែកបន្ទរពាក្យស្លោក "ជយោ! លទ្ធិប្រជាធិបតេយ្យដ៏អណ្តែតត្រសែតឡើងហើយ! ជយោ! ជយោ! ជយោ! បរាជ័យ! ពួកក្បត់ ប៉ុល ពត បរាជ័យ! បរាជ័យ! បរាជ័យ!" ។ អ្នកចូលរួមភាគច្រើនធ្វើតាមអ្វីដែលខ្លួនត្រូវបានប្រាប់ឲ្យធ្វើ ។ អ្នកចូលរួមទាំងនោះយល់ដឹងតិចតួច ឬស្ទើរតែមិនដឹងអ្វីទាំងអស់អំពីប្រវត្តិរបស់ ប៉ុល ពត ជម្លោះផ្ទៃក្នុងនាពេលថ្មីៗ ឬដំណើរការនៃការកាត់ទោសនេះ ។

ការកាត់ទោស ដែលមិននានីតិវិធីត្រឹមត្រូវនេះត្រូវបានប្រព្រឹត្តទៅនៅក្នុងរោងឈើមួយ ដែលមានដំបូលប្រក់សង្ក័សី និងពុំមានជញ្ជាំង ។ រោងឈើនេះស្ថិតនៅចម្ងាយ ១៨គីឡូម៉ែត្រពីទីរួមស្រុកអន្លង់វែង ។ តាម៉ុក បានសង់រោងឈើនេះ ឡើងសម្រាប់ធ្វើជាកន្លែងឈប់សម្រាកមុនពេលឆ្លងដែនទៅប្រទេសថៃ ។ ប៉ុល ពត អង្គុយនៅលើកៅអីឈើមួយនៅចំកណ្តាលរោង ។ នៅក្បែរ ប៉ុល ពត គឺជាមេបញ្ជាការកងពលរបស់គាត់បីរូបដែលជាប់ខ្នោះដៃ ។ មេបញ្ជាការកងពលទាំងបីនោះរួមមាន មៀច សាន, សូ សារឿន, និងបុរសម្នាក់ទៀតមិនស្គាល់អត្តសញ្ញាណ ។

ខៀវ នៅ គឺជាប្រធានអង្គជំនុំជម្រះ ដែលមានសមាជិកបួនរូប ។ នៅបានបើក

សវនាការ ដោយបានធ្វើការកត់សម្គាល់ថា ៖

> [ប៉ុល ពត] បានឲ្យពង្រីងស្មារតីពង្រីងគោលជំហរ ។ ដល់តែឲ្យពង្រីងចុះពង្រីងឡើងៗ តាំងមានវិធានការសម្លាប់គ្នាឯងជាបន្តបន្ទាប់ រហូតដល់សម្លាប់អ្នកតស៊ូ ក្នុងជួរ ក្នុងគណៈ ជាមួយគ្នាថែមទៀត ។ ដូច្នេះ យើង ជាប្រជាជន ជាមហាជននៅក្នុងអន្លង់វែងនេះ រកកោះរកត្រើយនៃសន្តិភាពមិនឃើញ ។ រកការដោះស្រាយបញ្ហាជាតិមិនឃើញ ។ រកការរួបរួមសាមគ្គីជាតិក៏មិនឃើញ ។ ប្រជាជាតិចេះ តែបែកបាក់ទៅៗ បែកខ្ញែកទៅៗ ។ ប្រយុទ្ធបកក្រោយវិញកម្ពុជារលាយសូន្យ ។ ចេះតែប្រយុទ្ធកម្ពុជាកាន់តែរលាយ ។[២៦៣]

ខៀវ នៅ មិនទាន់បានបញ្ចប់សុន្ទរកថារបស់គាត់ផង ស្រាប់តែបុរសម្នាក់បានងើបឈរឡើងពីក្នុង ហ្វូងមហាជនហើយបានស្រែកថា ៖ «បរាជ័យ! ប៉ុល ពត ជនក្បត់មួយក្តាប់តូច ។» នៅពេលនោះ អ្នកចូលរួមទាំងអស់បានលើកកណ្តាប់ដៃឡើងលើជាការគាំទ្រ ។

ខឹម ង៉ុន គឺជាអ្នកឡើងថ្លែងការណ៍ទីពីរដោយបាននិយាយថា «របប ប៉ុល ពត បានបញ្ចប់តាំងពី ថ្ងៃទី១៥-១៦ ខែមិថុនា កន្លងទៅនេះ ។» ង៉ុន និយាយសំដៅទៅថ្ងៃដែលកម្លាំងរបស់ ប៉ុល ពត ត្រូវបាន តាម៉ុក វាយបង្ក្រាប ។ ង៉ុន ក៏បានលើកឡើងអំពីការសម្លាប់ សុន សេន ដែរ ។ បុរសម្នាក់ទៀតបានស្រែកចេញពីហ្វូងមហាជនថា «បរាជ័យរបប ប៉ុល ពត! បាតដៃប្រឡាក់ទៅដោយឈាម!» អ្នកចូលរួមទាំងអស់បានស្រែកបន្ទរថា «បរាជ័យ! បរាជ័យ! បរាជ័យ!» ជាមួយនឹងកណ្តាប់ដៃទម្លាក់ចុះក្រោម ។ បន្ទាប់មក ង៉ុន បានចោទជាសំណួរប្រវត្តិសាស្ត្រជាច្រើនក្នុងគោលបំណងធ្វើឲ្យមហាជនមានកំហឹងកាន់តែខ្លាំងឡើង ។

> ក្មេងតូចអាយុ៤-៥ឆ្នាំក៏សម្លាប់គ្នាដែរ តើសម្លាប់ដើម្បីអ្វី? ហើយ ស្ត្រីសម្រាត ចាប់រំលោភ បរឡានកិន បាក់ជើងបាក់ដៃខ្ទេចខ្ទីអស់ យកសាំងដុត ។ ម្តាយយើង ស្រីខ្មែរ ប្អូនស្រីយើងសុទ្ធតែខ្មែរ វាមិនដែលមានទេ វាជាងយួនទៅទៀត អំពើបែបនេះ ។ នេះ សារឿន ដែលជាអ្នកដឹកនាំ

*បញ្ហាផ្ទាល់ ។ យើងបានតស៊ូកន្លងមក ព្រាត់ប្រាសម្តាយឪពុក អស់២០-៣០ឆ្នាំហើយ តស៊ូដើម្បីអ្វី? តស៊ូដើម្បីរំដោះជាតិ តស៊ូដើម្បីការពារទឹកដីឲ្យនៅគង់វង្ស ។ តស៊ូដើម្បីកុំឲ្យកម្ពុជាយើងទៅជាកម្ពុជាក្រោម ។ ម្នាក់ៗស្មោះត្រង់ណាស់ ស្មោះស្ម័គ្រណាស់ជាមួយចលនាតស៊ូ ។ ប៉ុន្តែដល់មកដល់ព្រឹត្តិការណ៍ធ្វើឲ្យម្នាក់ៗរន្ធត់ ។ ថ្នាក់ដឹកនាំប៉ុណ្ណឹងហើយ [សុន សេន] បាញ់កម្ទេចទាំងពូជ ។ ចុះទម្រាំក្រៅពីហ្នឹងតើវាទៅយ៉ាងម៉េច?*[២៦៤]

ម៉ក់ បេន ដែលជាបញ្ញវន្តដែលទទួលបានការសិក្សានៅប្រទេសបារាំង ជាអ្នកឡើងថ្លែងការណ៍ទីបី ។ ម៉ក់ បេន ស្ថិតនៅក្នុងសម្លៀកបំពាក់ឯកសណ្ឋានកងទ័ពពណ៌បៃតងដែលផលិតនៅប្រទេសចិន ។ បេន បានថ្លែងថា ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៥ ខែមិថុនា មកលែងមានរបប ប៉ុល ពត ទៀតហើយ ។ បេន បានប្រកាសថា ខ្មែរបន្ទាត់នយោបាយថ្មីគឺ «ខ្មែរមិនវាយខ្មែរ ខ្មែរមិនបង្ហូរឈាមខ្មែរ ខ្មែររួមគ្នា ខ្មែរគ្រប់គណបក្សកម្លាំងជាតិទាំងអស់រួមគ្នាជាធ្លុងមួយ តស៊ូប្រយុទ្ធប្រឆាំងយួនឈ្លានពានប្រល័យពូជសាសន៍ និងអាយ៉ងកញ្ជះវា ។ បញ្ហានេះបញ្ជាក់ច្បាស់យើងទាំងអស់គ្នាបានឃើញច្បាស់ វាជាមាគ៌ាថ្មីដែលយើងត្រូវអនុវត្តបច្ចុប្បន្ននេះ និងតទៅអនាគត ដើម្បីជាតិយើងរស់ ពូជសាសន៍យើងគង់វង្ស ។ ក្នុងនេះដើម្បីយើងមានកម្លាំងកាន់តែច្រើន តស៊ូសង្គ្រោះជាតិ ដើម្បីសម្រេចទិសដៅយើងបញ្ចប់សង្គ្រាមយួនកុម្មុយនីស្ត សម្រេចការផ្សះផ្សាជាតិពិតប្រាកដ សន្តិភាពពិតប្រាកដ ។»

ទេព យុនណាល់ ដែលជាវិស្វករ ដែលទទួលបានការសិក្សាពីប្រទេសបារាំង ជាអ្នកការទូតរបស់កម្ពុជាប្រជាធិបតេយ្យប្រចាំនៅអង្គការសហប្រជាជាតិ និងជាទីប្រឹក្សារបស់ប៉ុល ពត ជាអ្នកឡើងថ្លែងការណ៍ទីបួន ។ យុនណាល់ បានលើកឡើងថា «អំពើប្រព្រឹត្តរបស់ប៉ុល ពត និងបក្សពួក គឺជាអំពើផ្ទុយនឹងផលប្រយោជន៍ជួរ ផលប្រយោជន៍ប្រជាជន ។ ការសម្រេចតែងតាំងបុគ្គលដែលគ្មានមហាជនឲ្យដឹកនាំ គ្រប់គ្រងអន្លង់វែង ជាការសម្រេចផ្ទុយនឹងសំណូមពររបស់ប្រជាជន កងទ័ព និងកម្មាភិបាលទាំងមូល ។ ការសម្រេចរបស់ប៉ុល ពត បញ្ជាឲ្យប្រមូលកងទ័ព បញ្ឆេះសង្គ្រាមផ្ទៃក្នុងគ្នាឯងជាការសម្រេចក្បត់ជួរក្បត់ប្រជាជន ។»[២៦៥]

ខៀវ សំផន បានអនុញ្ញាតឲ្យកង់ទ័ពពិការពីររូបឡើងបញ្ចេញមតិនៅក្នុងសវនាការនោះ ។ យុទ្ធជនទាំងពីរពិការជើងស្តាំដូចគ្នា ។ យុទ្ធជនទាំងពីរបានអំពាវនាវដល់អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិឲ្យជួយរកយុត្តិធម៌ជូនប្រជាកសិករ ។ យុទ្ធជនម្នាក់បាននិយាយថា ៖

> ខ្ញុំជួបប្រទះជាង២៧ឆ្នាំហើយដែលជីវិតផ្ទាល់ខ្លួន គឺស៊ូរស់នៅក្នុងរបបប៉ុល ពត ។ ខ្ញុំផ្ទាល់ កសាងខ្លួនតាមជំហរនេះ តែក្នុងរយៈកាលបច្ចុប្បន្ននេះ ខ្ញុំផ្ទាល់ជួបការកាប់សម្លាប់គ្នា ដោយសាររបបប៉ុលពត ។ ដូច្នេះឥឡូវក្នុងនាមជាប្រជាជនឡើងសូមមានពាក្យបណ្តឹងដល់អង្គការសហប្រជាជាតិសូមមានពាក្យបណ្តឹងដល់អង្គការក្រៅប្រទេសនានា សូមឲ្យមើលឃើញយុត្តិធម៌របស់កសិករប្រជាជនច្បាស់ណាស់ ។ ដូច្នេះ ខ្ញុំផ្ទាល់ឡើងមកនេះ ឃើញច្បាស់អំពីព្រឹត្តិការណ៍ក្បត់របស់ ប៉ុល ពត ។ ទីមួយ អំពីការអនុវត្តមាគ៌ារបស់ ប៉ុល ពត ។ ក្នុងរយៈ២៧ឆ្នាំនេះ ខ្ញុំរស់នៅផ្ទាល់ឃើញច្បាស់នូវអំពើក្បត់នេះច្បាស់ ។ ទីមួយ ខ្ញុំព្រាត់ប្រាសបងប្អូនសាច់ឈាមដោយសាររបបនេះ ។ ឥឡូវនេះ ខ្ញុំឃើញច្បាស់ហើយថាថ្ងៃទី៩ ខែមិថុនានេះ សុន សេន ត្រូវបានសម្លាប់ ខ្ញុំឃើញច្បាស់ថារបបប៉ុល ពត នេះ ជារបបកាប់សម្លាប់មែនហើយ ។ សូម្បីតែកូនក្មេងតូចមួយក៏មិនទុកផង ។ ដូច្នេះ ចាប់ពីថ្ងៃនេះ តទៅ ខ្ញុំ និងពលទាហានទាំងមូលមិនមែនជាកម្លាំង ប៉ុល ពតអីទៀតទេ ។ ដូច្នេះជាកម្លាំងតស៊ូដ៏ពិតប្រាកដក្រោមការដឹកនាំរបស់គណបក្សមហាសាមគ្គីជាតិជាអ្នកដឹកនាំតស៊ូ ដើម្បីមានទិសដៅកម្ទេចយួនកុម្មុយនីស្ត និងកម្ទេចរបបប្រល័យពូជសាសន៍ទាំងអស់ ។[266]

នៅទីបញ្ចប់ ខៀវ សំផន បានប្រកាសសាលក្រមដោយបានដាក់ទោស ប៉ុល ពត ឲ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋ«សម្លាប់ សុន សេន ការប៉ុនប៉ងសម្លាប់ តាម៉ុក និងការបង្ខិចបំផ្លាញ កិច្ចខិតខំប្រឹងប្រែងផ្សះផ្សាជាតិ ។» បទចោទស្តីពីការបំផ្លិចបំផ្លាញកិច្ច

ប្រឹងប្រែងផ្សះផ្សាជាតិសំដៅទៅលើសកម្មភាពរបស់ ប៉ុល ពត ក្នុងការរារាំងកិច្ចចរចាសន្តិភាពរវាង តាម៉ុក និងហ៊ុនសុិនប៉ិច ។ ប៉ុល ពត ត្រូវបានឃុំឃាំងនៅក្នុងផ្ទះជាមួយប្រពន្ធនិងកូនស្រីរបស់គាត់ ។ ម៉ៅ និង នួន នៅ (ដែលជាប្រធានផ្នែកសេដ្ឋកិច្ចរបស់ តាម៉ុក ដែលទទួលខុសត្រូវលើបញ្ហាហិរញ្ញវត្ថុទាំងអស់ នៅអន្លង់វែង) ត្រូវបានចាត់តាំងឲ្យមើលការខុសត្រូវរាល់បញ្ហាទាំងអស់ ដែលទាក់ទងនឹង ប៉ុល ពត ។ ជាក់ស្តែង អ្នកទាំងពីរត្រូវទទួលខុសត្រូវលើការផ្គត់ផ្គង់ចំណីអាហារ និងថ្នាំពេទ្យដល់ ប៉ុល ពត ។[២៦៧]

តុលាការនេះមិនបានផ្តល់សិទ្ធិអ្វីទាំងអស់ដល់ជនជាប់ចោទ និងមិនមាននីតិវិធី ត្រឹមត្រូវតាមច្បាប់នោះទេ ។ ផ្ទុយទៅវិញសវនាការនោះ មានលក្ខណៈជាពិធីស្តីបន្ទោសជាសាធារណៈ ។ ប៉ុល ពត និងកម្មាភិបាលរបស់ខ្លួនត្រូវបានចោទប្រកាន់ចំពោះទង្វើទាំងឡាយ ដែលប្រឆាំងនឹងប្រជាជនខ្មែរ ។ ជាងនេះទៅទៀត សេចក្តីថ្លែងការណ៍ទាំងឡាយផ្តោតសំខាន់ទៅលើការដាក់ឲ្យ ប៉ុល ពត និងកម្មាភិបាលទទួលខុសត្រូវទាំងស្រុងចំពោះអំពើឃោរឃៅទាំងឡាយ ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាអ្នកឡើងធ្វើសេចក្តីថ្លែងការណ៍ទាំងអស់ ធ្លាប់ដើរតាម ប៉ុល ពត និងចលនាកុម្មុយនីស្តខ្មែរក្រហម អស់រយៈពេលជិតបីទសវត្សរ៍យ៉ាងណាក៏ដោយ ក៏អ្នកទាំងនោះបានពណ៌នាខ្លួនឯងថា ជា“អ្នកប្រជាធិបតេយ្យ” ជាជនកុម្មុយនីស្ត ។ នៅពេលសួរអំពីអត្តសញ្ញាណរបស់ខ្លួន តាម៉ុក បាននិយាយថា “ពួកយើងគឺជាអ្នក ស្នេហាជាតិ ។ ប៉ុល ពត គឺជាមនុស្សតែម្នាក់គត់ដែលទទួលខុសត្រូវចំពោះអ្វីៗទាំងអស់ ។ ខ្ញុំមិនយល់ថាហេតុអ្វីបានជាយើងអនុញ្ញាតឲ្យ ប៉ុល ពត ធ្វើអ្វីតាមចិត្តបែបនេះ ។ ខ្ញុំពិតជាមិនយល់ថា ប៉ុល ពត គិតអ្វី ។ តាមខ្ញុំយល់ ប៉ុល ពត គឺជាជនផ្តាច់ការ ។»[២៦៨]

ការកាត់ទោស ប៉ុល ពត គឺជាដែកគោលចុងក្រោយនៃក្តារមឈូសរបស់ចលនាខ្មែរក្រហម ។ ចលនានេះចាប់ផ្តើមរួមតូចបន្តិចម្តងៗ ដែលជាលទ្ធផលនៃការផ្តាច់ខ្លួននៅក្នុងអំឡុងពេលនៃទសវត្សរ៍ឆ្នាំ១៩៩០ ការតស៊ូផ្ទៃក្នុង និងការសម្តែងការកាត់ទោសនៅឆ្នាំ១៩៩៧ ។ នៅទីបញ្ចប់ ស្មារតីនៃចលនាខ្មែរក្រហមទាំងមូលត្រូវរលាយបាត់បង់ ។



ជំពូក១៤

# សមាហរណកម្មចូលទៅក្នុងរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៨

## គំនិតផ្តួចផ្តើមដំបូងនៃសមាហរណកម្មនៅអន្លង់វែង

ផែនការរបស់ខ្មែរក្រហម ក្នុងការធ្វើសមាហរណកម្មចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានផ្តួចផ្តើមឡើងតាំងពីមុនសមាហរណកម្មចុងក្រោយក្នុងឆ្នាំ១៩៩៨មកម្ល៉េះ ។ គំនិតផ្តួចផ្តើមនៃការធ្វើសមាហរណកម្មដំបូងអាចត្រូវបានពិនិត្យមើលថយក្រោយទៅពេលដែលមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅពេលដែលភាគីជម្លោះទាំងអស់យល់ព្រមរួបរួមគ្នា និងធ្វើការជាមួយគ្នា ដើម្បីកសាងសន្តិភាពក្នុងប្រទេសកម្ពុជា ។ ប្រជាជនដែលរស់នៅក្នុងតំបន់កាន់កាប់របស់ខ្មែរក្រហមមិនចង់បន្តធ្វើសង្គ្រាមជាមួយនឹងគូបដិបក្ខ ដែលជាជនជាតិខ្មែរដូចគ្នាទៀតនោះទេ ។ សេចក្តីប្រាថ្នាក្នុងការស្វែងរកសន្តិភាពបានឈានដល់កម្រិតកំពូលនៅពេលបោះឆ្នោតជាតិឆ្នាំ១៩៩៣ ។

យឹម ផាន់ណា បានអះអាងថា ខ្លួនមានបំណងចូលរួមជាមួយរដ្ឋាភិបាលតាំងពី





ឆ្នាំ១៩៩២ មកម្ល៉េះ ។ នៅពេលនោះកម្មាភិបាលខ្មែរក្រហមមួយក្រុម ដែលរួមទាំង យឹម ផាន់ណា ត្រូវបានបញ្ជូនឲ្យធ្វើជាតំណាងរបស់កម្ពុជាប្រជាធិបតេយ្យឲ្យទៅធ្វើការនៅក្នុងក្របខណ្ឌក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៅទីក្រុងភ្នំពេញ ។ នៅពេលខ្មែរក្រហមធ្វើពហិការមិនចូលរួមនៅក្នុងការបោះឆ្នោត កម្មាភិបាលខ្មែរក្រហមទាំងអស់នោះត្រូវបានកោះហៅឲ្យត្រឡប់មកអន្លង់វែងវិញ ។ អ្នកតំណាងមួយចំនួនត្រូវបានចោទប្រកាន់ថា ជា «អាយ៉ងយួន» ត្រូវបានទីក្រុងភ្នំពេញបញ្ចុះបញ្ចូល និងក្បត់នឹងចលនា ។ ផាន់ណា បានរៀបរាប់អំពីផលលំបាកដែលខ្លួនបានជួបប្រទះថា «នៅពេលដែលខ្ញុំត្រឡប់មកដល់អន្លង់វែងវិញ ខ្ញុំត្រូវបានចោទប្រកាន់ថា បានរួមគំនិតជាមួយ«អាយ៉ងយួននៅភ្នំពេញ» ហើយឃុំខ្ញុំនៅក្នុងទ្រុងដែក ។»

ចាប់តាំងពីពេលនោះមក ផាន់ណា ជឿជាក់ថា «ការបោះឆ្នោតឆ្នាំ១៩៩៣ គឺជាមធ្យោបាយតែមួយគត់ដែលអាចបង្រួបបង្រួមគ្រប់ភាគីទាំងអស់របស់កម្ពុជាឲ្យរួបរួមគ្នានៅក្នុងសន្តិភាពនិងសន្តិសុខ ។»[២៦៩] ប៉ុន្តែ គំនិតសុទិដ្ឋិនិយមរបស់គាត់ត្រូវបានរលាយទៅវិញ នៅពេលមេដឹកនាំខ្មែរក្រហមសម្រេចចិត្តធ្វើពហិការមិនចូលរួមការបោះឆ្នោត និងបន្តការតស៊ូតទៅទៀត ។

ស្ថានភាព និងប្រព័ន្ធគ្រប់គ្រងនៅអន្លង់វែងនាពេលនោះហាក់មានសភាពតានតឹងជាងតំបន់កាន់កាប់ក្បែរខាងដទៃទៀត ដូចជាប៉ៃលិន និងតំបន់ផ្សេងទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ មេបញ្ជាការកងពលនៅតំបន់អន្លង់វែង មិនមានសិទ្ធិស្វ័យភាព ដូចមេបញ្ជាការកងពលនៅតំបន់ប៉ៃលិននោះទេ ។ យឹម ផាន់ណា បានលើកឡើងថា «យើងមិនមានឯករាជភាពផ្នែកសេដ្ឋកិច្ចដូចនៅតំបន់ប៉ៃលិនទេ ។»[២៧០] ជាងនេះទៅទៀត បទបញ្ញត្តិរបស់ខ្មែរក្រហមមិនអនុញ្ញាតឲ្យកងទ័ពបញ្ជូនប្រពន្ធកូនទៅរស់នៅតំបន់ខាងក្នុងនៃប្រទេសទេ ។ ការបញ្ជូនសមាជិកគ្រួសារទៅខាងក្នុងស្មើនឹងអំពើក្បត់ ។

នៅខែតុលា ឆ្នាំ១៩៩៣ ប៉ុល ពត, ខៀវ សំផន និងមេដឹកនាំខ្មែរក្រហម ជាច្រើនទៀត បានធ្វើដំណើរពីភ្នំឆត្រមករស់នៅអន្លង់វែង ។ ដោយសារតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងនោះ បានគ្រប់គ្រងសិទ្ធិកងទ័ព និងសេដ្ឋកិច្ចកាន់តែច្រើន (ដែលលែងស្ថិតនៅក្នុងដៃរបស់ តាម៉ុក តែម្នាក់ទៀតហើយ) វត្តមានរបស់មេដឹកនាំទាំងនោះបានធ្វើឲ្យលទ្ធភាពនៅក្នុងការចុះចូលជាមួយរដ្ឋាភិបាលកាន់តែស្មុចស្មើងឡើងទៅៗ ។ ផាន់ណា បាន

បន្តថា នៅពេលមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកដល់អន្លង់វែង ឱកាសនៃការចុះចូលជាមួយរដ្ឋាភិបាលត្រូវបានបាត់បង់ ។ ស្របពេលជាមួយគ្នានោះ លទ្ធភាពនៃការចុះចូលជាមួយរដ្ឋាភិបាលចាប់ផ្តើមផុសផុលនៅតំបន់ប៉ៃលិន និងម៉ាឡៃ ។[២៧១]

នៅឆ្នាំ១៩៩៦ សមាហរណកម្មរបស់ក្រុមខ្មែរក្រហមនៅតំបន់ប៉ៃលិន និងម៉ាឡៃចូលទៅក្នុងរាជរដ្ឋាភិបាលកម្ពុជាបានក្លាយជាសញ្ញាប្រកាសអាសន្នមួយសម្រាប់មេដឹកនាំខ្មែរក្រហមនៅអន្លង់វែង ។ មេដឹកនាំទាំងនោះបានចាប់ផ្តើមអប់រំប្រជាជននៅអន្លង់វែងកុំឲ្យយកតម្រាប់តាមប្រជាជននៅប៉ៃលិន និងម៉ាឡៃ ។ ប្រជាជនទាំងអស់គ្នាត្រូវតែបន្តការតស៊ូ ទោះបីជាត្រូវលះបង់អ្វីក៏ដោយ ។

ទោះជាយ៉ាងនេះក្តី ប្រជាជនមានការនឿយណាយជាមួយនឹងសង្គ្រាម ដែលនៅតែបន្ត ។ ទោះបីជាមិនមានប្រជាជនណាម្នាក់ ហ៊ានបញ្ចេញអារម្មណ៍នេះជាសាធារណៈក៏ដោយ ក៏មេដឹកនាំខ្មែរក្រហមចាប់ផ្តើមបាត់បង់ការគាំទ្រពីប្រជាជន ។[២៧២] មេបញ្ជាការកងទ័ព និងប្រជាជនភាគច្រើនបានគិតអំពីការផ្តាច់ខ្លួន ប៉ុន្តែមានការភ័យខ្លាចចំពោះគ្រោះថ្នាក់ ។ កងទ័ពម្នាក់ៗអាចរត់គេចខ្លួនបាន ប៉ុន្តែ ប្រពន្ធនិងកូនរបស់ខ្លួននឹងត្រូវបានយកទៅសម្លាប់ចោលជាការដាក់ទោស ។[២៧៣] មិនមានអ្នកណាម្នាក់ហ៊ានបញ្ចេញទស្សនៈអ្វីទាំងអស់ ដោយសារតែការភ័យខ្លាចចំពោះការរាយការណ៍ ។ ការមិនជឿជាក់គ្នានៅក្នុងចំណោមមេបញ្ជាការកងទ័ព គឺជាឧបសគ្គចម្បងមួយដែលរារាំងដល់ផែនការផ្តាច់ខ្លួនចូលជាមួយរាជរដ្ឋាភិបាល ។[២៧៤] ជាងនេះទៅទៀត កងទ័ពខ្មែរក្រហមមិនទាន់ទទួលបានការធានាណាមួយពីរាជរដ្ឋាភិបាលអំពីសន្តិសុខផ្ទាល់ខ្លួន បន្ទាប់ពីការផ្តាច់ខ្លួននៅឡើយទេមកត្រឹមដំណាក់កាលនេះ ។

## ការខិតខំប្រឹងប្រែងដំបូងរបស់ តាម៉ុក ក្នុងការចរចាសន្តិភាព

នៅខែកុម្ភៈ ឆ្នាំ១៩៩៧ តាម៉ុក បានចាប់ផ្តើមការចរចាជាលើកទីមួយជាមួយគណបក្សហ៊ុនស៊ិនប៉ិច ។ តាម៉ុក បានទាក់ទងជាមួយ ហែម ប៊ុនហេង ដែលជាអភិបាលរងទីពីរខេត្តសៀមរាប មកពីគណបក្សហ៊្វុនស៊ិនប៉ិច ។[២៧៥] ប៉ុល ពត មិនបានដឹង អំពីការចរចាដោយសម្ងាត់នេះទេ ។

ការជួបប្រជុំត្រូវបានធ្វើឡើងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ នៅភូមិរមៀត

ដែលមានចម្ងាយ ប្រហែល៣៥គីឡូម៉ែត្រពីទីរួមស្រុកអន្លង់វែង ។ ហែម ប៊ុនហេង បានដឹកនាំក្រុមចរចាដែលមានសមាជិកចំនួន១៥នាក់ ។ ក្រុមអ្នកចរចារបស់ តាម៉ុក រួមមាន ណុប សុជាតិ, ឡុង ទេម និង ខឹម ផុន ។ ឡុង ទេម និង ហែម ប៊ុនហេង ធ្លាប់មានទំនាក់ទំនងជិតស្និទ្ធនឹងគ្នា ។ ប៊ុនហេង គឺជាអតីតមេបញ្ជាការកងទ័ពរបស់ ហ៊ុនស៊ិនប៉ិច នៅក្នុងអំឡុងពេលនៃការតស៊ូប្រឆាំងនឹងវៀតណាម នៅទសវត្សរ៍ឆ្នាំ១៩៨០ ។ ប៊ុនហេង ធ្វើការជិតស្និទ្ធជាមួយខ្មែរក្រហម នៅក្នុងក្របខណ្ឌនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។[២៧៦] សុន សេន បង្ហាញជំហរគាំទ្រចំពោះការចរចានេះ ។

ការចរចានេះមិនត្រូវបានរៀបចំឡើង តែក្នុងគោលបំណងនៃការធ្វើសមាហរណកម្មចូលរួមជាមួយរាជរដ្ឋាភិបាលតែមួយប៉ុណ្ណោះទេ ។ ប៊ុនហេង ត្រូវបានចាត់តាំងឲ្យប្រគល់ឯកសារមួយច្បាប់ស្តីអំពីការបង្កើតរណសិរ្សរួបរួមជាតិ[២៧៧] ដែលផ្តួចផ្តើមឡើង ដោយគណបក្សហ៊ុនស៊ិនប៉ិច ដើម្បីបញ្ចុះបញ្ចូលខ្មែរក្រហមនៅតំបន់អន្លង់វែងឲ្យចូលរួមជាមួយរណសិរ្សនេះ ។[២៧៨]

នៅទីបញ្ចប់ កិច្ចប្រជុំនេះបានបញ្ចប់ទៅនៅក្នុងគ្រោះមហន្តរាយ ។[២៧៩] នៅពេលដែលការជួបប្រជុំ កំពុងតែចាប់ផ្តើម កងទ័ពនៅក្នុងកងពល៨០១ (ជាកងពលដែលស្មោះស្ម័គ្រនឹង ប៉ុល ពត និងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សូ សារឿន) បានបាញ់រះដើម្បីបង្អាក់ដំណើរការប្រជុំ ។ ហែម ប៊ុនហេង ត្រូវរបួសចំជើង និងត្រូវបានចាប់ខ្លួន ហើយបញ្ជូនមកអន្លង់វែង ។ ប៊ុនហេង បានស្លាប់ដោយសារតែរងរបួសធ្ងន់ធ្ងរពេក ។ អ្នកចរចា ១០រូបផ្សេងទៀតរួមមាន ឧត្តមសេនីយ៍ ភួង ប៊ុនភឺន និងឧត្តមសេនីយ៍ ហង្ស សុចាន់ ដែលមកពីក្រសួងការពារជាតិត្រូវបានសម្លាប់នៅនឹងកន្លែង ។ ខ្មាន់កាំភ្លើងចក្រដែលចតនៅក្បែរកន្លែងប្រជុំនោះត្រូវបានដុតកម្ទេចចោល ។ អ្នកបើកយន្តហោះ៤នាក់ ដែលរង់ចាំនៅទីនោះត្រូវបានចាប់ខ្លួន និងបញ្ជូនមកឃុំឃាំងនៅអន្លង់វែង ។

## កិច្ចខិតខំប្រឹងប្រែងលើកទីពីរក្នុងការចរចា

មិនយូរប៉ុន្មានបន្ទាប់ពីបរាជ័យលើកទីមួយ ហ៊ុនស៊ិនប៉ិច និង តាម៉ុក ចាប់ផ្តើមការចរចាជាលើកទីពីរ ។ ញឹក ប៊ុនឆៃ និង ខាន់ សារឿន (មេបញ្ជាការកងទ័ពជាន់ខ្ពស់របស់ហ៊ុនស៊ិនប៉ិច) ទុន ចាយ (អភិបាលខេត្តសៀមរាបរបស់ហ៊ុនស៊ិនប៉ិច) និង ឡុង សារិន

(លេខាធិការទីពីរប្រចាំស្ថានទូតកម្ពុជានៅទីក្រុងបាងកករបស់ហ៊ុនសិុនប៉ិច) គឺជាក្រុមអ្នកចរចាខាងរដ្ឋាភិបាល ។ ភាគីខ្មែរក្រហមរួមមាន តាម៉ុក, ខៀវ សំផន, ទេព ឃុនណាល់ និង ឡុង ទេម ដែលបន្តធ្វើជាផ្លូវទាក់ទងចម្បងសម្រាប់ភាគីទាំងពីរ ។ ការចរចាត្រូវបានប្រព្រឹត្តទៅអស់រយៈពេលជាច្រើនសប្តាហ៍ ។ ហ៊ុនសិុនប៉ិច ទាមទារឲ្យដក ប៉ុល ពត ចេញពីក្នុងក្របខណ្ឌនៃការចរចា ។ ក្រុមអ្នកចរចាខ្មែរក្រហមបានយល់ព្រមចំពោះការទាមទារនោះ ។ តាម៉ុក បានទាមទារសិទ្ធិស្វយ័តសម្រាប់តំបន់អន្លង់វែង ដែលប្រហាក់ប្រហែលទៅនឹងអ្វី ដែលក្រុមខ្មែរក្រហមនៅប៉ៃលិន និងម៉ាឡៃទទួលបានដែរ ។ ជាមួយនឹងលក្ខខណ្ឌទាំងអស់នេះ ខ្មែរក្រហមនៅអន្លង់វែងនឹងយល់ព្រមរំលាយរដ្ឋាភិបាលបណ្តោះអាសន្នរបស់ខ្លួន និងគោរពតាមច្បាប់រដ្ឋធម្មនុញ្ញ ។

ផ្ទុយទៅវិញ ប៉ុល ពត ប្រឆាំងដាច់ខាតចំពោះផែនការធ្វើសមាហរណកម្ម និងព្យាយាមរារាំងការចរចានេះ ។ ក្រៅពីការការពារខ្លួនឯង ប៉ុល ពត ហាក់ដូចជា ជឿជាក់ថា ការខិតខំប្រឹងប្រែងក្នុងការចរចាសន្តិភាពជាមួយរដ្ឋាភិបាលនឹងមិនផ្តល់ជាដំណោះស្រាយផ្លែផ្កានោះទេ ។ នៅក្នុងទស្សនៈរបស់ ប៉ុល ពត មធ្យោបាយទៅមុខតែមួយគត់គឺការបន្តការតស៊ូរហូតដល់ខ្មែរក្រហមដណ្តើមបានប្រទេសទាំងមូលមកវិញ ។

ការចរចាខាងលើបានបរាជ័យ ដោយសារតែការប្រយុទ្ធគ្នារយៈពេល៥ថ្ងៃ រវាងកងទ័ពរបស់ ប៉ុល ពត និង តាម៉ុក ។ កិច្ចប្រជុំបន្ទាប់ត្រូវបានគ្រោងធ្វើនៅថ្ងៃទី១០ ខែមិថុនា ប៉ុន្តែត្រូវបានលុបចោលទៅវិញ ដោយសារតែជម្លោះផ្ទៃក្នុងនៅក្នុងជួរខ្មែរក្រហម ។ តាម៉ុក បានសុំជំនួយពី ញឹក ប៊ុនឆៃ ដើម្បីផ្តួលរំលំ ប៉ុល ពត និងស្តារឡើងវិញនូវអ្វីដែល តាម៉ុក ហៅថាផែនការសម្រាប់ការចរចាសន្តិភាព និងការផ្សះផ្សាជាតិ ។ ញឹក ប៊ុនឆៃ បានយល់ព្រម ហើយបានដឹកជញ្ជូនគ្រឿងសព្វាវុធ តាមខ្ទម្លាគចក្រពីបន្ទាយកងទ័ពនៅអូរស្មាច់ មកឲ្យកម្លាំងរបស់ តាម៉ុក ។[២៨០] តាម៉ុក បានពន្លឿនការចរចាបន្ទាប់ពី ប៉ុល ពត និងមេទ័ពជំនិតរបស់គាត់ត្រូវបានចាប់ខ្លួន ។ កិច្ចព្រមព្រៀងជាមួយហ៊ុនសិុនប៉ិចគ្រោងនឹងសម្រេចនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៩៧ ។

កងទ័ពរបស់ តាម៉ុក យល់ព្រមចុះចូលជាមួយកងទ័ពរដ្ឋាភិបាល និងគោរពច្បាប់រដ្ឋធម្មនុញ្ញរបស់កម្ពុជា និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋាភិបាល ។ ជាការតបស្នង តាម៉ុក បានស្នើសុំការលើកលែងទោសពីព្រះមហាក្សត្រ ដូចគ្នាទៅនឹងការលើកលែង

ទោសឲ្យ អៀង សារី កាលពីឆ្នាំ១៩៩៦ដែរ ។ តាម៉ុក ក៏បានស្នើសុំរក្សាទុករចនាសម្ព័ន្ធរដ្ឋបាល និងយោធានៅអន្លង់វែង ដែលសំណើទាំងអស់នេះត្រូវបានសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ យល់ព្រម ។[២៨១]

ការចរចារវាងហ៊្វុនស៊ិនប៉ិច និង តាម៉ុក បានបញ្ឆេះឲ្យមានជម្លោះកើតឡើងរវាងកម្លាំងដែលស្មោះត្រង់នឹងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ដែលជានាយករដ្ឋមន្ត្រីទីមួយ និងកម្លាំងដែលស្មោះត្រង់ នឹងសម្តេច ហ៊ុន សែន ដែលជានាយករដ្ឋមន្ត្រីទីពីរ ។[២៨២] នៅថ្ងៃទី៥-៦ ខែកក្កដា ការប្រយុទ្ធគ្នាបានផ្ទុះឡើងនៅទីក្រុងភ្នំពេញ ។ នៅទីបំផុតសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវបានទម្លាក់ចេញពីអំណាច ។ មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និងសមាជិកសភាជាច្រើនរបស់ហ៊្វុនស៊ិនប៉ិច បានរត់ភៀសខ្លួនទៅបរទេស ។ មន្ត្រី និងមេទ័ពរបស់ហ៊្វុនស៊ិនប៉ិចជាច្រើន ត្រូវបានសម្លាប់ដោយគ្មានការជំនុំជម្រះ ។ កម្លាំងបរាជ័យរបស់ហ៊្វុនស៊ិនប៉ិចបានរត់គេចខ្លួន និងប្រមូលផ្តុំកងទ័ពឡើងវិញនៅតាមព្រំដែនថៃ ។ ឧត្តមសេនីយ៍ ញ៉ឹក ប៊ុនឆៃ បានរត់ទៅអន្លង់វែង និងស្នើសុំជំនួយពី តាម៉ុក ។

ព្រឹត្តិការណ៍ខែកក្កដា ឆ្នាំ១៩៩៧ បានធ្វើឲ្យ តាម៉ុក ជឿជាក់ថាកម្លាំងសេសសល់របស់ខ្មែរក្រហមមិនអាចធ្វើការជាមួយរដ្ឋាភិបាលរបស់សម្តេច ហ៊ុន សែន បានទៀតទេ ហើយការបន្តការតស៊ូប្រដាប់អាវុធ គឺជាជម្រើសតែមួយគត់ ។ មេបញ្ជាការកងទ័ពរបស់តាម៉ុក មួយចំនួនបានខកចិត្តចំពោះការយល់ឃើញបែបនេះ និងបានចាប់ផ្តើមការចរចាដើម្បីសន្តិភាពជាលើកទីបី និងជាលើកចុងក្រោយ ។

ទោះបីជាការចរចាជាមួយហ៊្វុនស៊ិនប៉ិច ត្រូវបរាជ័យដោយសារតែព្រឹត្តិការណ៍ ខែកក្កដា ឆ្នាំ១៩៩៧យ៉ាងណាក៏ដោយ ក៏ តាម៉ុក បានចាប់ផ្តើមកិច្ចខិតខំប្រឹងប្រែងចុងក្រោយមួយ តាមរយៈការស្វែងរកការគាំទ្រពីអន្តរជាតិដោយបានអញ្ជើញអ្នកសារព័ត៌មានអាមេរិកាំងមួយក្រុម មកជួបសម្ភាសរយៈពេលបីម៉ោងជាមួយគាត់, ខៀវ សំផន, នួន ជា និង ចាន់ យូរ៉ាន់ នៅឯផ្ទះរបស់គាត់ក្បែរមាត់បឹង ។

ក្នុងនាមជាអធិរាជសង្គ្រាមនៅតំបន់អន្លង់វែង តាម៉ុក បានរៀបចំអ្វីៗទាំងអស់ ដែលទាក់ទងទៅនឹងការសម្ភាសនោះ ។ ញ៉ឹក ប៊ុនឆៃ ក៏មានវត្តមាននៅក្នុងអំឡុងពេលសម្ភាសនោះដែរ ។[២៨៣] នៅពេលត្រូវបានចោទសួរថា តើចលនារបស់គាត់អាចបន្តការរស់រានមានជីវិតដោយគ្មានជំនួយបរទេសដោយរបៀបណា តាម៉ុក ឆ្លើយថា ៖

> យើងត្រូវតែបន្តការតស៊ូរបស់យើង និងខិតខំធ្វើការ ។ បើមិនដូច្នោះទេ យើងនឹងស្លាប់ ។ តាមពិតទៅតើយើងអាចធ្វើអ្វីបានទៀត? យើងគ្មានជម្រើសនោះទេ ។[284]

នួន ជា ដែលអង្គុយជាប់នឹង តាម៉ុក បានបន្ថែមថា ៖

> ប្រទេសកម្ពុជាមានគំរូផ្ទាល់ខ្លួន ។ គំរូនោះ គឺចលនារបស់ប្រជាជន ។ ហេតុដូច្នេះហើយ បានជាយើងនៅតែអាចរស់រានមានជីវិតរហូតដល់សព្វថ្ងៃនេះ ទោះបីជាយើងមិនមានជំនួយពីបរទេសក៏ដោយ ។ យើងអាចបន្តបាន ដោយសារតែយើងមានការគាំទ្រពីប្រជាកសិករ និងប្រជាជនកម្ពុជាទូទៅ ។

នួន ជា ក៏បានរំឭកអំពីវគ្គសិក្សានយោបាយដែលខ្លួនធ្លាប់បានបង្រៀនកម្មាភិបាលនៅក្នុងរបបខ្មែរក្រហម ។

នៅចុងបញ្ចប់នៃបទសម្ភាស តាម៉ុក បានអំពាវនាវសុំជំនួយពីសហរដ្ឋអាមេរិក ។

> មុននឹងទៅ សូមផ្តាំផ្ញើប៉ុណ្ណេះ គឺធ្វើម៉េច ស្នើរដ្ឋាភិបាលអាមេរិកជួយជំរុញ និងជួយធ្វើម៉េចឲ្យប្រទេសកម្ពុជាមានសន្តិភាព ហើយមានរដ្ឋាភិបាលជាតិមួយ ដែលមានគ្រប់ភាគីចូលរួមដោយស្មើភាពគ្មានផ្លូវណាដើរក្រៅពីនេះទេ ។[285]

## កិច្ចចរចាសន្តិភាព និងការផ្សះផ្សាចុងក្រោយ

មេបញ្ជាការកងពល៩៨០មួយក្រុម ដែលដឹកនាំដោយ យឹម ផាន់ណា, យឹម សាន, យឹម ពឹម, នួន ជឿន និង លី សុន បានបន្តការចរចាចុងក្រោយដោយសម្ងាត់ ។ ជំនួសឲ្យការចរចាជាមួយហ៊ុនស៊ិនប៉ិច មេបញ្ជាការទាំងនោះបានចរចាជាមួយ សម្តេច ហ៊ុន សែន ដោយមិនឲ្យដំណឹងដល់ តាម៉ុក ។ ផ្នែកមួយនៃការជឿទុកចិត្តទៅលើកងកម្លាំងរបស់សម្តេច

នាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយសារតែមេបញ្ជាការកងពលខ្មែរក្រហមទាំងនោះ ធ្លាប់មានបទពិសោធធ្វើការជាមួយកម្លាំងរបស់សម្តេច ហ៊ុន សែន ។ នៅក្នុងអំឡុងឆ្ពោះទៅការរៀបចំការបោះឆ្នោតឆ្នាំ១៩៩៣ យឹម ផាន់ណា និងកម្លាំងរបស់ខ្លួន ធ្លាប់ធ្វើការជិតស្និទ្ធជាមួយមន្ត្រីរដ្ឋាភិបាលរបស់អតីតរដ្ឋកម្ពុជា ។ មេទ័ពខ្មែរក្រហមទាំងនេះ បានបង្កើតទំនាក់ទំនងល្អជាមួយរដ្ឋាភិបាល ដែលទំនាក់ទំនងនេះបានជួយសម្រួលដល់ការផ្តួចផ្តើមការចរចាសាជាថ្មី ដើម្បីធ្វើសមាហរណកម្មកងកម្លាំងខ្មែរក្រហមទាំងអស់នៅអន្លង់វែង ។

ផាន់ណា ក៏ជាបុគ្គលមួយរូបដែលមានឥទ្ធិពលនៅក្នុងជួរខ្មែរក្រហម ។ គាត់ទទួលបានការគាំទ្រស្ទើរតែទាំងស្រុងពីកម្លាំងនៅក្នុងកងពល៩៨០ ។ នៅពេលរៀបផ្តាច់ខ្លួនចូលរួមជាមួយរាជរដ្ឋាភិបាល គាត់បានអះអាងថា គាត់អាចប្រមូលបានយ៉ាងតិច៦០ភាគរយនៃកម្លាំងកងទ័ព និងប្រជាជននៅអន្លង់វែង ។[២៨៦] អ្នកដែលចូលរួមជាមួយគាត់ដទៃទៀតរួមមាន យឹម ពឹម និង កែ ពក ដែលជាអតីតមេបញ្ជាការកងពល៤១៧ និងមេបញ្ជាការកងទ័ពមួយចំនួនទៀត ។ អ្នកទាំងអស់បានជួបជុំគ្នានៅផ្ទះរបស់ យឹម ពឹម ដើម្បីពិភាក្សាអំពីផែនការលម្អិតចុងក្រោយ ដើម្បីដាក់សំណើទៅរាជរដ្ឋាភិបាលរបស់សម្តេច ហ៊ុន សែន ។

យឹម ផាន់ណា បានដឹកនាំក្រុមចរចាទៅចូលរួមប្រជុំនៅទីក្រុងភ្នំពេញ ។ នៅក្នុងពេលប្រជុំ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា ៖

> *ខ្ញុំខ្លួនឯងក៏ជាអតីតកម្មាភិបាលខ្មែរក្រហមដែរ ប៉ុន្តែ ខ្ញុំបានចូលជាមួយរដ្ឋាភិបាលមុនអ្នកទាំងអស់គ្នា ។ ខ្ញុំមិនមែនជាអ្នកបង្កើតសង្គ្រាមទេ ។ យឹម ផាន់ណា ឯងក៏មិនមានលទ្ធភាពបង្កើតសង្គ្រាមដែរ ។ ពួកគេ [មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម] ជាអ្នកបង្កើតសង្គ្រាម ហើយបានទម្លាក់វាមកលើយើង ។ យើងជាអ្នករងគ្រោះដោយសារតែពួកគេ ។ ដូច្នេះ ខ្ញុំសូមសំណូមពរសូមឈប់វាយគ្នា និងងាកមកធ្វើការជាមួយគ្នា ដើម្បីការផ្សះផ្សាជាតិ និងការបង្រួបបង្រួមជាតិ ។[២៨៧]*

មេបញ្ជាការកងទ័ពខ្មែរក្រហមមានការរំភើបជាមួយនឹងចក្ខុវិស័យរបស់សម្តេច

នាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយបានស្នើសុំលក្ខខណ្ឌបីចំណុច ជាថ្នូរនឹងការផ្ដាច់ខ្លួនៈ (១) សិទ្ធិក្នុងរស់នៅជាប្រជាជនសាមញ្ញ (២) សិទ្ធិក្នុងការកាន់កាប់កម្មសិទ្ធិឯកជន និងសិទ្ធិក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលនៅក្នុងតំបន់ និង (៣) សិទ្ធិក្នុងការទទួលបានតួនាទីក្នុងជួររដ្ឋាភិបាលនៅក្នុងតំបន់ដែលខ្លួនធ្លាប់គ្រប់គ្រង ។ សម្ដេច ហ៊ុន សែន បានយល់ព្រមតាមសំណើទាំងអស់នេះ ។

ក្រោយការចរចាជាមួយសម្ដេច ហ៊ុន សែន យឹម ដាន់ណា និងសហការីរបស់ខ្លួនបានរៀបចំផែនការផ្ដាច់ខ្លួនចេញពី តាម៉ុក នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩៨ ។ ដាន់ណាបានបញ្ជូនក្រុមមួយឲ្យទៅរៀបចំផែនការនេះជាមួយ នៅ សំ អភិបាលរងខេត្តសៀមរាប នៅថ្ងៃទី១៣ ខែមីនា ។ ដើម្បីធានាការទុកចិត្តពីរដ្ឋាភិបាលទៅលើកិច្ចព្រមព្រៀងនេះ ដាន់ណា បានបញ្ជូនប្រពន្ធ និងកូនរបស់ខ្លួនឲ្យទៅរស់នៅខេត្តសៀមរាប ក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលមុនពេលផ្ដាច់ខ្លួន ។ ប៉ុន្តែ ផែនការផ្ដាច់ខ្លួននេះត្រូវបានបែកធ្លាយទៅដល់ តាម៉ុក ដែលបានរៀបចំកម្លាំងរបស់ខ្លួន ដើម្បីវាយបង្រ្កាបក្រុមអ្នកផ្ដាច់ខ្លួន ។

ការប្រយុទ្ធរវាងក្រុមផ្ដាច់ខ្លួន និងកម្លាំងស្មោះត្រង់នឹង តាម៉ុក បានផ្ទុះឡើងនៅថ្ងៃទី២៤ ខែមីនា បីថ្ងៃមុនការអនុវត្តផែនការផ្ដាច់ខ្លួន ។ រដ្ឋាភិបាលបានផ្ដល់គ្រឿងសព្វាវុធដល់កងទ័ពខ្មែរក្រហមផ្ដាច់ខ្លួន ប៉ុន្តែ រដ្ឋាភិបាលមិនបានបញ្ជូនកម្លាំងរបស់ខ្លួនទៅអន្លង់វែងទេ ។ កងកម្លាំងរដ្ឋាភិបាលចូលទៅត្រឹមតំបន់ព្រៃស្អាកតែប៉ុណ្ណោះ ។ កងទ័ពនៅក្នុងកងពល ៩៨០ បានវាយចូលទីប្រជុំជនអន្លង់វែង ដើម្បីផ្ដល់ឱកាសឲ្យប្រជាជនដទៃទៀត អាចចូលរួមនៅក្នុងការផ្ដាច់ខ្លួនបាន ។ ប្រជាជនជាច្រើនបានរត់ភៀសខ្លួនទៅតំបន់អូរបែគាប់ ។ កងពលរបស់ដាន់ណាទទួលបានការគាំទ្រពីកងពល៤១៧ របស់ កែ ពក និងកងពល៨០១ ដែលមេបញ្ជាការកងពល សូ សារឿន ត្រូវបាន តាម៉ុក សម្លាប់កាលពីប៉ុន្មានខែមុន ។ កងពល៩១២ គឺជាកងពលដែល តា ម៉ុក ជឿទុកចិត្ត ។ កងពលនេះដឹកនាំដោយគណៈកងពលចំនួនបីរូប ដែលរួមមាន ហេង, សាន់ គង់ និង ទុយ ប៊ុនរ៉េត ។

នៅពេលដែលស្នូរកាំភ្លើងបានផ្ទុះឡើង ប្រជាជនភាគច្រើននៅក្នុងតំបន់នោះ បាននាំគ្នារត់គេចខ្លួន ។ ដូចដែលប្រជាជនមួយរូបបានពណ៌នា ប្រជាជននៅពេលនោះហាក់ដូចជា "ត្រីកំពុងពុលទឹក" ។ ដោយសារតែការចរចាត្រូវបានធ្វើឡើងដោយសម្ងាត់ ប្រជាជនភាគច្រើនមិនបានដឹងអំពីផែនការផ្ដាច់ខ្លួននោះទេ ។ ក្រោយមក ប្រជាជនបានដឹងអំពី

ផែនការផ្ដាច់ខ្លួននេះតាមរយៈការនិយាយតៗគ្នាពីភូមិមួយទៅភូមិមួយទៀត ដែលចាប់ផ្ដើមពីក្រុមគ្រួសារកងទ័ពផ្ដាច់ខ្លួន ។

ប្រជាជនភាគច្រើនមិនដឹងថាគួររត់ទៅណា ឬចុះចូលជាមួយភាគីណានោះទេ ។[២៨៨] ប្រជាជននាំគ្នារត់ទៅទិសដៅពីរផ្សេងគ្នាអាស្រ័យទៅនឹងទីតាំងដែលខ្លួនរស់នៅ ។ ប្រជាជនមួយចំនួនបានរត់ឡើងលើភ្នំដងរែក ទៅកាន់ជំរំភូណាយនៅក្នុងទឹកដីថៃជាមួយតាម៉ុក ហើយមួយចំនួនទៀតរត់ទៅអូរបៃតាប់ នៅឃុំស្រែណូយ (ប្រហែល៥០គីឡូម៉ែត្រពីស្រុកអន្លង់វែង) ជាមួយកម្លាំងផ្ដាច់ខ្លួន ដែលដឹកនាំដោយមេបញ្ជាការនៅក្នុងកងពល ៩៨០ ។ ដុំ ឈុននី ដែលជាមេបញ្ជាការកងទ័ពមួយរូបទៀតនៅក្នុងកងពល៩៨០ និងដែលកំពុងធ្វើការនៅស្រុកស្ទោង ខេត្តកំពង់ធំ បានដឹកនាំកងទ័ពរបស់ខ្លួន មកចុះចូលជាមួយក្រុមផ្ដាច់ខ្លួននៅអូរបៃតាប់ ។

ប្រជាជនស៊ីវិល និងកងទ័ពប្រហែល៨ពាន់នាក់បានរត់ទៅអូរបៃតាប់ និងបានរស់នៅទីនោះ រហូតដល់ខែកក្កដា ឆ្នាំ១៩៩៨ ។ ក្រោយមក ប្រជាជនមួយចំនួនបានវិលត្រឡប់មកអន្លង់វែងវិញ ។ ប៉ុន្តែ នៅពេលត្រឡប់មកដល់វិញទ្រព្យសម្បត្តិរបស់ខ្លួនជាច្រើនត្រូវ



បានកងទ័ពខ្មែរក្រហមគ្នាឯង ដែលមកដល់មុនរឹបអូសយកទៅអស់ ។

**ជំរំភូណាយ**

នៅក្នុងអំឡុងពេលនៃការវាយប្រហារគ្នាឯង រវាងក្រុមផ្តាច់ខ្លួន និងកម្លាំងរបស់ តាម៉ុក នៅក្នុង ខែមីនា ឆ្នាំ១៩៩៨ តាម៉ុក បានដឹកនាំកងទ័ព និងប្រជាជនរបស់គាត់រត់ភៀសខ្លួនទៅកាន់ជំរំភូណាយនៅក្នុងខេត្តស៊ីសាកេត ប្រទេសថៃ ហើយរស់នៅទីនោះរហូតដល់ខែធ្នូ ឆ្នាំ១៩៩៨ ។ នៅទីនោះ ប្រជាជនរស់នៅក្រោមការឧបត្ថម្ភរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ដែលបានផ្តល់កន្លែងស្នាក់នៅ និងម្ហូបអាហារ ។[២៨៩]

តា ម៉ុក បាននាំមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងអស់ទៅជាមួយគាត់ ។ ប៉ុល ពត, នួន ជា, ខៀវ សំផន, ចាន់ យូរ៉ាន់, ទេព ឃុនណាល់, ម៉ក់ បេន, ពេជ ប៊ុនរ៉េត, អ៊ិន សុភាព និង កោរ ប៊ុនហេង បានធ្វើដំណើរឆ្លងទៅដីថៃជាមួយ តាម៉ុក ។ តាម៉ុក ក៏បានយកឧបករណ៍ផ្សាយវិទ្យុ និងក្រុមវិទ្យុទៅជាមួយខ្លួន ដែលអាចអនុញ្ញាតឲ្យ តាម៉ុក វាយប្រហារក្រុមផ្តាច់ខ្លួនថាជា«ជនក្បត់ជាតិ» ។ តាម៉ុក សច្ចាថានឹងសម្លាប់ ជនផ្តាច់ខ្លួនទាំងអស់នោះចោល ។

ទោះបីជា តាម៉ុក សច្ចាថានឹងតស៊ូប្រឆាំងរាជរដ្ឋាភិបាលរហូតដល់ទីបញ្ចប់ក៏ដោយ ក៏កម្មាភិបាល ដែលគាត់ជឿទុកចិត្តភាគច្រើន មិនបានមើលឃើញសេចក្តីសង្ឃឹមអ្វីទាំងអស់ ។ កម្មាភិបាលរបស់ តាម៉ុក បានស្នើឲ្យគាត់ឈប់សម្រាក និងអនុញ្ញាតឲ្យខ្លួនទៅចរចាជាមួយរាជរដ្ឋាភិបាល ។ តាម៉ុក បានយល់ព្រមហើយបានផ្ទេរការទទួលខុសត្រូវផ្នែកនយោបាយទៅឲ្យ ខៀវ សំផន និងការទទួលខុសត្រូវផ្នែកយោធាទៅឲ្យមេបញ្ជាការជំនិតរបស់គាត់ ឌឹម ឆុន ។

ការប្រយុទ្ធគ្នារវាងកងទ័ពរបស់ តាម៉ុក និងក្រុមផ្តាច់ខ្លួន បានបន្តទៅអស់រយៈពេលជាច្រើនខែ ។ តាម៉ុក មានកងទ័ពនៅក្នុងដៃប្រហែល២ពាន់នាក់តែប៉ុណ្ណោះ ទោះបីជា ឌឹម ឆុន បានអះអាងថាខ្លួនគ្រប់គ្រងកងទ័ពជាង៥ពាន់នាក់ និងប្រជាជនជាង១ម៉ឺន៥ពាន់នាក់ក៏ដោយ ។ នៅថ្ងៃទី២ ខែមេសា កងទ័ពរបស់ តាម៉ុក វាយដណ្តើមកាន់កាប់បានអន្លង់វែងវិញ ប៉ុន្តែមិនយូរប៉ុន្មានកងទ័ពរបស់ តាម៉ុក ត្រូវបានបណ្តេញចេញពីអន្លង់វែងវិញ ដោយកងកម្លាំងរួមរវាងកងទ័ពខ្មែរក្រហមផ្តាច់ខ្លួន និងកងយោធពលខេមរភូមិន្ទ ។ នៅពាក់កណ្តាលខែមេសា កងទ័ពខ្មែរក្រហមផ្តាច់ខ្លួន និងកងយោធពលខេមរភូមិន្ទ វាយកាន់កាប់បានឃុំស្រះឈូកដែលជាមូលដ្ឋានយោធាសំខាន់មួយទៀតរបស់ តាម៉ុក ។ កងទ័ពរបស់

តាម៉ុក បានដកថយទៅភ្នំ២០០ ដែលមានចម្ងាយប្រមាណ២០គីឡូម៉ែត្រខាងជើងទីរួម ស្រុកអន្លង់វែង ។

ជាងនេះទៅទៀត កងទ័ពរបស់ តាម៉ុក មួយចំនួនដែលបដិសេធមិនចុះចូលជាមួយ រាជរដ្ឋាភិបាលតាមរយៈគណបក្សប្រជាជនកម្ពុជាបានចុះចូលជាមួយកម្លាំងរបស់ ញឹក ប៊ុនឆៃ នៅក្បែរប្រកព្រំដែនអូរស្មាច់ ។ នៅពេលនោះហើយដែល ប៉ុល ពត បានស្លាប់ ។ ទោះបីជាការស្លាប់របស់ ប៉ុល ពត នៅមានភាពស្រពេចស្រពិលក្តី ប៉ុល ពត ទំនងជាស្លាប់ ដោយសារជំងឺគាំងបេះដូងក្នុងអំឡុងពេលដែលកងកម្លាំងខ្មែរក្រហមដកថយពីអន្លង់វែង ។ ខណៈពេលដែលកងយោធពលខេមរភូមិន្ទ កាន់តែវាយចូលមកមុខអ្នកមើលថែ ប៉ុល ពត មិនអាចផ្គត់ផ្គង់ខ្យល់អុកស៊ីហ្សែន និងថ្នាំ គ្រប់គ្រាន់ឲ្យ ប៉ុល ពត ។ ប៉ុល ពត បានស្លាប់នៅ លើគ្រែដេករបស់គាត់ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ដោយមានប្រពន្ធវ័យក្មេង និងកូនស្រីនៅក្បែរខ្លួន ។ ពីរថ្ងៃក្រោយមកសាកសពរបស់ ប៉ុល ពត ត្រូវបានដុតជាមួយ នឹងសំបកកង់ឡាន ។

កម្លាំងរបស់ តាម៉ុក កាន់តែចុះខ្សោយទៅ នៅពេលដែលខ្លួនចាញ់ការប្រយុទ្ធ នៅក្នុង សមរភូមិភ្នំ២០០ នៅថ្ងៃទី៤ ខែឧសភា ។ ជាលទ្ធផលកងទ័ពរបស់ តាម៉ុក បានផ្លាស់ទៅ ក្បាលអន្សោង ដែលជាទីបញ្ជាការរបស់ ប៉ុល ពត ។

នៅពេលដែលស្ថានការណ៍កាន់តែតានតឹងឡើង ប្រជាជនដែលនៅក្រោមការគ្រប់ គ្រងរបស់ តាម៉ុក បានឆ្លងដែនទៅខេត្តស៊ីសាកេត ប្រទេសថៃ តាំងពីថ្ងៃទី១ ខែឧសភា ។ ប្រជាជនបានយករថយន្តដឹកទំនិញ រទេះគោ ទោចក្រយាន ត្រាក់ទ័រចូកដី និងរថយន្តតូច ធ្វើជាមធ្យោបាយទៅកាន់ប្រទេសថៃ ។ ប្រជាជនបានយកឧបករណ៍ ផ្ទះបាយ សម្លៀក បំពាក់ និងស្បៀងអាហារ យ៉ាងច្រើនតាមតែអាចយកទៅតាមខ្លួនបាន ។

## ចុងបញ្ចប់នៃចលនាខ្មែរក្រហម

កិច្ចចរចាជាសម្ងាត់រវាងរដ្ឋាភិបាល និងកងទ័ពខ្មែរក្រហមដែលនៅសេសសល់ ត្រូវ បានធ្វើឡើង នៅលើប្រាសាទព្រះវិហារ និងនៅទីក្រុងបាងកក ។ ប្រធានក្រុមចរចារបស់ តាម៉ុក រួមមាន ខឹម ងួន, នួន នៅ និង ទេព ឃុនណាល់ ។ យឹម ផាន់ណា និង យឹម ពឹម រួមទាំង មេបញ្ជាការកងយោធពលខេមរភូមិន្ទមួយចំនួនទៀត ដែលរួមទាំងឯកឧត្តម ទៀ បាញ់



រដ្ឋមន្ត្រីក្រសួងការពារជាតិ និងនាយឧត្តមសេនីយ៍ មាស សុភា តំណាងឲ្យភាគីរាជរដ្ឋាភិបាល ។[២៩០] ការចរចានេះទទួលបរាជ័យជាច្រើនលើកច្រើនសា ដោយសារកម្លាំងរបស់តាម៉ុក ទាមទារស្វ័យភាពលើតំបន់អន្លង់វែង ជាថ្នូរនឹងការចុះចូល ។ ការទាមទារនេះត្រូវបានភាគីរាជរដ្ឋាភិបាលច្រានចោល ។

ចន្លោះពីខែខសភាដល់ខែវិច្ឆិកា ឆ្នាំ១៩៩៨ កម្លាំងរបស់ខ្មែរក្រហមសេស សល់កាន់តែចុះខ្សោយទៅ និងបានបាត់បង់ស្មារតីតស៊ូ ។ កងទ័ពជាច្រើនបានរត់ចូលជាមួយរាជរដ្ឋាភិបាលតាមរយៈគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ។ កងទ័ពមួយចំនួនទៀតដែលមិនចង់ចូលជាមួយរាជរដ្ឋាភិបាលបានរត់ទៅ ប៉ៃលិន និង ម៉ាឡៃ ។ មេដឹកនាំជាន់ខ្ពស់មួយចំនួនដូចជា ចាន់ យូរ៉ាន់, ដួន ជឿន, អ៊ិន សុភាព, កោរ ប៊ុនហេង និង ម៉ក់ បេន បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅ ខែមិថុនា ។ អ្នកទាំងអស់នោះបានទៅរស់នៅប៉ៃលិន ។

នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៨ ភាគីទាំងសងខាងនៃជម្លោះបានឈានដល់ការព្រមព្រៀងគ្នា ដែលជាវគ្គបញ្ចប់នៃការផ្តាច់ខ្លួន និងការរំលាយកងទ័ពខ្មែរក្រហមសេស

សល់ជាស្ពាន ដែលបានតស៊ូប្រឆាំងនឹងរដ្ឋាភិបាលអស់រយៈពេលជិត២៨ឆ្នាំ ។ តាម៉ុក យល់ព្រមចុះចាញ់ និងអនុញ្ញាតឲ្យកងទ័ពនិងប្រជាជនទាំងអស់ចុះពីលើភ្នំ ។ ខឹម ង៉ុន ក៏បាន យល់ព្រមចុះចូលជាមួយរាជរដ្ឋាភិបាល ។[២៩១] តាម៉ុក លែងមានមធ្យោបាយអ្វី ក្នុងការ ផ្គត់ផ្គង់អ្នកនៅក្រោមបង្គាប់របស់ខ្លួនទៀតហើយ ។ តាម៉ុក ក៏បានមើលឃើញអំពីបំណង ប្រាថ្នារបស់ប្រជាជនសម្រាប់សន្តិភាពនិងភាពគ្មានន័យនៃការបន្តធ្វើសង្គ្រាម ។ ជាថ្នូរនឹង ការចុះចូលរាជរដ្ឋាភិបាលសន្យាធានាសន្តិសុខ និងសុខុមាលភាពរបស់ប្រជាជនទាំងអស់ នៅជុំវិញភូណាយ ។

ជាងនេះទៅទៀត អតីតកងទ័ពខ្មែរក្រហម និងប្រជាជនស៊ីវិលទាំងអស់នឹងត្រូវ បានទទួលស្គាល់ជាប្រជាជនកម្ពុជាស្របច្បាប់ និងមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ និងកាន់ មុខតំណែងរដ្ឋបាលទាំងអស់នៅតំបន់អន្លង់វែង ។ អតីតមេបញ្ជាការកងទ័ពខ្មែរក្រហម និងអ្នកដឹកនាំស៊ីវិលជាច្រើន ត្រូវបានតែងតាំងឲ្យទទួលមុខតំណែងដឹកនាំនៅក្នុងរដ្ឋបាល នគរបាល និងយោធានៅក្នុងតំបន់នេះ ។ អ្នកទាំងឡាយណា ដែលមានចំណេះដឹងតិចតួច ឬ សុខភាពខ្សោយ ហើយមិនអាចកាន់មុខតំណែងធំៗ បានត្រូវបានតែងតាំងជាទីប្រឹក្សានៅ តាមក្រសួងនានារបស់រដ្ឋាភិបាល ដូចជាក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។ យឹម ពឹម ត្រូវបានតែងតាំងជាឧត្តមសេនីយ៍ផ្កាយពីរ និងជាមេបញ្ជាការកងពលលេខ៨ ។ យឹម សាន ត្រូវបានតែងតាំងជាអភិបាលទីមួយនៃស្រុកអន្លង់វែង ។ យឹម ដាន់ណា ត្រូវបាន តែងតាំងជាមេបញ្ជាការរងនៃយោធភូមិភាគទី៤ ។

ខៀវ សំផន និង នួន ជា បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៨ និងត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅឯគេហដ្ឋានរបស់សម្តេចនៅក្រុងតាខ្មៅ ។ ខៀវ សំផន និង នួន ជា ត្រូវបានអនុញ្ញាតឲ្យ រស់នៅដោយសេរីនៅ ប៉ៃលិន រហូតដល់ថ្ងៃដែលអ្នកទាំងពីរត្រូវបានចាប់ខ្លួននៅថ្ងៃទី១៩ ខែវិច្ឆិកា និងថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ។

នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ពិធីសមាហរណកម្មផ្លូវការត្រូវបានប្រារព្ធធ្វើឡើង នៅស្រុកអន្លង់វែង ក្រោមអធិបតីភាពរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិឯកឧត្តម ទៀ បាញ់ និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សេរីរ័ត្ន ។ កងទ័ពខ្មែរក្រហមជិត២ពាន់នាក់ បានប្តូរ ឯកសណ្ឋានបែបយោធាចិនមកជាឯកសណ្ឋានរបស់កងយោធពលខេមរភូមិន្ទ នៅក្នុង







ពិធីនោះ ។ ពិធីនេះសម្គាល់ទំព័រចុងក្រោយនៃការផ្តាច់ខ្លួនរបស់ខ្មែរក្រហម ។

នៅចុងបញ្ចប់នៃសង្គ្រាម ប្រជាជននៅអន្លង់វែងសប្បាយរីករាយជាខ្លាំង ។ ប្រជាជនអាចសង់ផ្ទះថ្មីជួបជុំជាមួយក្រុមគ្រួសារ និងចាប់ផ្តើមប្រកបរបររកស៊ីសាជាថ្មី ។[២៩៧] ប្រជាជនបានសម្តែងការដឹងគុណចំពោះរាជរដ្ឋាភិបាល ដែលបានផ្តល់សិទ្ធិឲ្យអតីតកងទ័ពខ្មែរក្រហម និងប្រជាជនស៊ីវិល ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន និងរស់នៅដោយសេរី ។ កែវ ភ័ក្រ បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនបន្ទាប់ពីត្រឡប់ពីអូរបៃតាប់មកអន្លង់វែងវិញថា ៖

> វាមានភាពខុសគ្នាខ្លាំងណាស់ រវាងរបបដឹកនាំរបស់ តាម៉ុក និងរបបបច្ចុប្បន្ន ។ ខ្ញុំមិនដែលមានឱកាសបានទៅសាលារៀនទេ ហើយកូនខ្ញុំ ក៏មិនបានរៀនសូត្រច្រើនដែរ ។ ជំនាន់ តាម៉ុក គឺពោរពេញទៅដោយសង្គ្រាម ។ យើងរត់លូននៅលើដី និងមិនមានការព្យាបាលជំងឺឲ្យបានត្រឹមត្រូវទេ ។ ឥឡូវយើងមិនចាំបាច់រត់លូនទៀតទេហើយ កូនៗរបស់យើងបានចូលរៀន

ទៀងទាត់ ។ ឥឡូវនេះ កូនៗរបស់ខ្ញុំ អាចរៀនដល់ថ្នាក់ទី១១ ។ យើងរស់នៅជាមួយសាច់ញាតិរបស់យើង ។ សេដ្ឋកិច្ចក៏មានការរីកចម្រើនជាងមុន ។ ប្រជាជនអាចប្រកបរបរចិញ្ចឹមជីវិត និងធ្វើការងារដែលខ្លួនពេញចិត្ត ។ យើងអាចធ្វើដំណើរទៅណាក៏បានភ្នំពេញ ឬកំពង់ចាម ឲ្យតែយើងមានលុយ ។ យើងមានសេរីភាពពេញលេញក្នុងការធ្វើដំណើរ ។ យើងមានចម្ការ និងដីស្រែ ដែលផ្តល់ផលគ្រប់គ្រាន់សម្រាប់បរិភោគ ។ ខ្ញុំពេញចិត្តនឹងរបបបច្ចុប្បន្ន និងជីវិតទៅថ្ងៃអនាគតរបស់យើង ។[២៩៣]

## ថ្ងៃចុងក្រោយរបស់ តាម៉ុក

ពីដំបូង តាម៉ុក ត្រូវបានឃុំឃាំងនៅក្នុងផ្ទះនៅពើយតារូន ។ រាជរដ្ឋាភិបាលបានឧបត្ថម្ភការរស់នៅរបស់គាត់នៅអន្លង់វែងអស់ជាច្រើនខែ ។ តាម៉ុក ត្រូវបានឲ្យសារភាពនូវឧក្រិដ្ឋកម្មទាំងឡាយដែលខ្លួនបានប្រព្រឹត្ត ។ ប៉ុន្តែ តាម៉ុក តែងតែឆ្លើយថា «តើឲ្យខ្ញុំសារភាពរបៀបណា? បើមានរឿងរ៉ាវជាច្រើនដែលត្រូវនិយាយ ។ ឲ្យពេលបីឆ្នាំក៏និយាយមិនអស់ដែរ ។ សូមប្រកាសប្រាប់អ្នកទាំងអស់គ្នាថា ខ្ញុំត្រូវបានចាប់ខ្លួនហើយ ។»[២៩៤] តាម៉ុក គឺជាមេដឹកនាំខ្មែរក្រហមចុងក្រោយដែលបដិសេធមិនព្រមចុះចាញ់រដ្ឋាភិបាល ។[២៩៥] នៅទីបញ្ចប់ តាម៉ុក ត្រូវបានប្រកាសជាផ្លូវការថាត្រូវបានចាប់ខ្លួននៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ នៅអន្លង់វែង និងត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងយោធានៅទីក្រុងភ្នំពេញ ។ តាម៉ុក រស់នៅភ្នំពេញអស់រយៈពេល៧ឆ្នាំមុនពេលស្លាប់នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ដោយសារសម្ពាធឈាមឡើងខ្លាំង និងរោគរបេង នៅក្នុងអាយុ៨០ឆ្នាំ ។ សពរបស់ តាម៉ុក ត្រូវបានដឹកត្រឡប់មកស្រុកអន្លង់វែងវិញ ហើយពិធីបុណ្យសពដ៏ធំមួយ ត្រូវបានប្រារព្ធយ៉ាងអធិកអធម ដោយមានការចូលរួមយ៉ាងច្រើនពីអតីតអ្នកដែលស្មោះត្រង់នឹងគាត់ ។ សូម្បីតែពាណិជ្ជករជនជាតិថៃ ក៏មកចូលរួមបុណ្យសពរបស់គាត់ដែរ ។[២៩៦] ចេតិយដ៏ធំមួយរបស់ តាម៉ុក ត្រូវបានកសាងឡើងនៅក្នុងវត្តស្រះឈូក ។

## សេចក្តីបញ្ចប់

សម្រាប់ហេតុផលនយោបាយ និងហេតុផលជាក់ស្តែងជាច្រើនរបបកម្ពុជាប្រជា

ធិបតេយ្យ ជាទូទៅ ត្រូវបានពណ៌នាថា បានចាប់ផ្តើមនៅឆ្នាំ១៩៧៥ និងបញ្ចប់ទៅវិញនៅឆ្នាំ១៩៧៩ ។ នៅក្នុងន័យមួយការពណ៌នាបែបនេះគឺត្រឹមត្រូវ ។ សមត្ថភាពរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការប្រយុទ្ធប្រឆាំងនឹងកងកម្លាំងវៀតណាម បានដួលរលំទាំងស្រុងនៅដើមឆ្នាំ១៩៧៩ ។ ទីក្រុងភ្នំពេញបានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់វៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា លើកលែងតែតំបន់ដាច់ស្រយាលនៅតាមខេត្តមួយចំនួន នៅភាគខាងលិចនៃប្រទេសកម្ពុជា ។ ទោះជាយ៉ាងនេះក្តី របបដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងការបំផ្លិចបំផ្លាញស្ថាប័នសង្គមស្ទើរតែទាំងស្រុងនេះមិនបានបាត់រូបរាងទាំងស្រុងនៅត្រឹមឆ្នាំ១៩៧៩នោះទេ ។ ផ្ទុយទៅវិញ របបនេះបានរៀបចំខ្លួនឡើងវិញ យ៉ាងឆាប់រហ័សទៅជាកម្លាំងទ័ពឈ្លបចល័តដែលបានបន្តធ្វើសង្គ្រាមតទៅទៀត ។

នៅក្រោមស្លាកទាមទារមកវិញនូវអធិបតេយ្យភាពជាតិពីអ្វីដែលខ្មែរក្រហមហៅថា "អាខ្មាំងយួនឈ្លានពាន" និង "អាយ៉ងយួន" ខ្មែរក្រហមបានរៀបចំកម្លាំងរបស់ខ្លួនឡើងវិញ និងធ្វើសង្គ្រាមឈ្លបដ៏វែងមួយទៀត ប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវៀតណាម ។ នៅក្នុងអំឡុងពេលនៃការរៀបចំកម្លាំងទ័ពឡើងវិញ និងការត្រៀមប្រយុទ្ធនៅក្នុងសង្គ្រាមថ្មីនេះ ប្រជាជនកម្ពុជាដែលរស់នៅក្នុងតំបន់គ្រប់គ្រងរបស់ភាគីទាំងពីរនៃគូជម្លោះបន្តរងគ្រោះ ។

ជួរភ្នំដងរែក ដែលជាព្រំដែនធម្មជាតិរវាងប្រទេសកម្ពុជានិងប្រទេសថៃ បានក្លាយទៅជាទីតាំងយុទ្ធសាស្ត្ររបស់ខ្មែរក្រហមសម្រាប់រត់គេចខ្លួន ការប្រមូលផ្តុំកម្លាំងទ័ព និងការតស៊ូឡើងវិញ ។ ជាផ្នែកមួយនៃគម្រោងវាយដណ្តើមកាន់កាប់ប្រទេសកម្ពុជាឡើងវិញខ្មែរក្រហមបានបង្កើតឡើងវិញនូវមូលដ្ឋានសេដ្ឋកិច្ច នយោបាយ និងយោធា ដែលស្ថិតនៅចម្ងាយប្រមាណតែពីរបីគីឡូម៉ែត្រពីព្រំដែន ទាំងនៅក្នុងទឹកដីកម្ពុជា និងទាំងនៅក្នុងដីថៃ ។

ភ្នំ១០០១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន និងភ្នំ១០០៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក បានក្លាយទៅជាមូលដ្ឋានយុទ្ធសាស្ត្រយោធារបស់ចលនាខ្មែរក្រហមទាំងមូល ។ កងពលចំនួន១២របស់ខ្មែរក្រហម បានឈរជើងនៅលើភ្នំ១០០១ និងភ្នំ១០០៣ ។ ពីមូលដ្ឋាននៅភ្នំទាំងពីរនេះ កងទ័ពខ្មែរក្រហម

រាប់ម៉ឺននាក់ត្រូវបានបញ្ជូនឲ្យទៅធ្វើសង្គ្រាមឈ្លប និងសង្គ្រាមប្រជាជននៅខាងក្នុងផ្ទៃប្រទេស ។ ទោះបីជាកងពលផ្សេងទៀត ដែលឈរជើងនៅភាគពាយ័ព្យ និងភាគខាងលិចនៃព្រំដែន មានឯករាជ្យលើផ្នែកសេដ្ឋកិច្ចក៏ដោយ ក៏ទិសដៅយោធាត្រូវបានបញ្ជារចេញពីភ្នំ១០០១ និងភ្នំ១០០៣ដែរ ។

នៅលើភ្នំដងរែក កងទ័ពខ្មែរក្រហមសេសសល់ និងប្រជាជនដែលរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមបន្តរងគ្រោះអស់រយៈពេលមួយទសវត្សរ៍ទៀតពីការផ្លាស់ទីកន្លែង និងការបែកបាក់ពីក្រុមគ្រួសារជាទីស្រឡាញ់របស់ខ្លួន ។ ប្រជាជនទាំងនោះទទួលបានការខបត្ថម្ភផ្នែកស្បៀងអាហារ និងសម្ភារៈចាំបាច់ផ្សេងៗជាច្រើនទៀតពីមេដឹកនាំរបស់ខ្លួន ។ ការសម្លាប់រង្គាលដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យលែងជាការអនុវត្តជាប្រពៃណីទៀតហើយ ។ ទោះជាយ៉ាងនេះក្តី ប្រជាជននៅតែមិនអាចដើរហើរនិយាយស្តី និងរស់នៅដោយសេរីដូចដែលខ្លួនប្រាថ្នាចង់បាននោះទេ ។

នៅក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹង និងការឃោសនារបស់មេដឹកនាំខ្មែរក្រហម កងទ័ពខ្មែរក្រហម និងសមាជិកគ្រួសាររបស់ខ្លួន (ទោះបីជាដោយស្ម័គ្រចិត្តក្តី ឬដោយបង្ខំក្តី) បានលះបង់គ្រប់បែបយ៉ាងសម្រាប់ការតស៊ូយោធារបស់ខ្មែរក្រហម ដោយធ្វើជាអ្នកជំនួយដល់សមរភូមិមុខ ។ ការដឹកជញ្ជូនគ្រឿងសព្វាវុធឆ្លងកាត់ចម្ការមីន ការកាប់ចម្រូង ការដាំចម្រូង និងការដឹកជញ្ជូនស្បៀងអាហារទៅកាន់សមរភូមិមុខ ត្រូវបានចាត់ទុកថា ជាការងារស្នេហាជាតិ ។ ប្រជាជននៅតំបន់អន្លង់វែង បានរស់នៅលើភ្នំដងរែកអស់រយៈពេលជាងដប់ឆ្នាំ ដោយបានធ្វើការងារទាំងអស់នេះ ដែលចាំបាច់សម្រាប់ការការពារសហគមន៍របស់ខ្លួន ។

វាមានរយៈពេលជាងដប់ឆ្នាំបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទើបប្រជាជនអាចធ្វើដំណើរចុះពីភ្នំដងរែក មករស់នៅក្នុងជីវិតជាសហគមន៍ពិតប្រាកដនៅក្នុងតំបន់កាន់កាប់អន្លង់វែង ។ នៅដើមឆ្នាំ១៩៩០ តំបន់អន្លង់វែងបានក្លាយទៅជាសហគមន៍យ៉ាងពិតប្រាកដជាថ្មីម្តងទៀត ។ ប៉ុន្តែការតាំងទីលំនៅនៅអន្លង់វែង គ្រាន់តែជាការតាំងទីបណ្តោះអាសន្នតែប៉ុណ្ណោះ ។ បន្ទាប់ពីការតាំងទីលំនៅរួចរាល់ ហើយប្រជាជនត្រូវចំណាយពេល៨ឆ្នាំទៀត នៅក្នុងការតស៊ូនឹងសង្គ្រាមមុនឈានដល់ការផ្តាច់ខ្លួន និងការផ្សះផ្សាចុងក្រោយ នៅចុងឆ្នាំ១៩៩៨ ។

ការផ្តាច់ជំនួយពីបរទេសបន្ទាប់ពីឆ្នាំ១៩៩១ បានជំរុញឲ្យមានការធ្វើវិមជ្ឈការនៅក្នុងកងកម្លាំងរបស់ខ្មែរក្រហម ។ ខណៈពេលដែលការផ្តាច់ខ្លួនចុះចូលជាមួយរាជរដ្ឋាភិបាលកើនឡើង មេដឹកនាំខ្មែរក្រហមកាន់តែឯកោ និងមានការសង្ស័យពីគ្នាទៅវិញទៅមក ។ នៅទីបំផុត មេដឹកនាំនៃចលនានេះបានប្រយុទ្ធគ្នាឯង ។



នៅក្នុងចំណោមក្រុមខ្មែរក្រហមទាំងអស់ តាម៉ុក គឺជាមេដឹកនាំមួយរូបដែលជោគជ័យជាងគេក្នុងការរៀបចំសេដ្ឋកិច្ចតំបន់អន្លង់វែងឲ្យទៅជាតំបន់មួយ ដែលអាចរស់នៅដោយខ្លួនឯង ដោយមិនបាច់ពឹងពាក់ជំនួយបរទេស ។ តាម៉ុក អាចបង្កើតឥទ្ធិពលផ្ទាល់ខ្លួនយ៉ាងរឹងមាំនៅអន្លង់វែង ដោយសារគាត់បានផ្សារភ្ជាប់ប្រជាប្រិយភាព ទៅនឹងគម្រោងសាងសង់ជាច្រើន ដែលបានបម្រើដល់ផលប្រយោជន៍របស់ប្រជាជន ។ ប៉ុន្តែ ទោះបីជាតាម៉ុក មានភាពវៃឆ្លាតក្នុងការបង្កើតទំនាក់ទំនងប្រកបដោយភាពសុខដុមជាមួយប្រជាជនក៏ដោយ តាម៉ុក មិនមានភាពបត់បែនគ្រប់គ្រាន់ក្នុងការធ្វើដំណើរនៅក្នុងប្រព័ន្ធនយោបាយអន្តរភាគីរបស់កម្ពុជា ។ ការផ្តាច់ខ្លួនរបស់មេបញ្ជាការកងទ័ពរបស់គាត់នៅឆ្នាំ១៩៩៧ បានបន្សល់ទុកឲ្យ តាម៉ុក នូវកម្លាំងស្ទួចស្តើងមួយ ។ នៅទីបញ្ចប់ តាម៉ុក បានចុះចាញ់កម្លាំង



របស់រាជរដ្ឋាភិបាលកម្ពុជា នៅចុងឆ្នាំ១៩៩៨ ។

ជំពូក១៥

# ពិនិត្យមើលតំបន់អន្លង់វែងឡើងវិញ

អន្លង់វែង គឺដូចជាភូមិស្ងប់ស្ងាត់របស់កម្ពុជាដទៃទៀតនៅតំបន់ជនបទដែរ ដែលនៅទីនោះ ជីវិតហាក់មានទំនោរទៅរកលំនាំនៃការរស់នៅបែបសមូហភាព និងឯកភាព្យ ។ ប្រជាជននៅតំបន់នេះឲ្យតម្លៃទៅលើទឹកន្លែងរស់នៅក្នុងទឹកដីកម្ពុជា និងតំបន់ព្រំដែនប្រកបដោយបរិយាកាសល្អ ដោយការប្រកបរបរធ្វើស្រែចម្ការនៅលើទឹកដីរបស់ខ្លួន ។ ប្រជាជន



រស់នៅប្រកបដោយមោទកភាព ដោយសារតែសមត្ថភាពរបស់សហគមន៍ នៅក្នុងការថែរក្សាខ្លួនដោយខ្លួនឯង ដែលបានឆ្លុះបញ្ចាំងអំពីអតីតកាលដែលជាតំបន់គ្មានរដ្ឋ និងការអនុវត្តប្រព័ន្ធចាស់របៀបមេដឹកនាំ និងកូនចៅ ។

ដូចតំបន់ជនបទជាច្រើនក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលនៃរបបអាណានិគមបារាំង អន្លង់វែងស្ថិតនៅក្រៅវង្វង់នៃការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋ ។ នៅពេលនោះភូមិភាគច្រើននៅក្នុងតំបន់នោះ មិនមានសាលារៀនទេ ហើយសេដ្ឋកិច្ចត្រូវបានអនុវត្តតាមប្រព័ន្ធដោះដូរទំនិញ ។[២៩៧] តាមការប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា ស្ថានភាពនៃការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនបានបញ្ជាក់ឲ្យឃើញអំពីការអនុវត្តប្រព័ន្ធគ្រប់គ្រងបែបមេដឹកនាំ និងកូនចៅដែលបានអភិវឌ្ឍតំបន់គ្មានរដ្ឋមួយនេះ ដែលទំនៀមទម្លាប់ត្រូវបានប្រើប្រាស់ជំនួសឲ្យច្បាប់ហើយវប្បធម៌ត្រូវបានបន្តពីជំនាន់មួយទៅជំនាន់មួយទៀតតាមរយៈការនិយាយតៗគ្នា ។ នៅក្នុងបរិបទនេះ វប្បធម៌នៃការរស់នៅបែបសហគមន៍ និងពឹងផ្អែកលើខ្លួនឯង បានរីកចម្រើននៅពេលដែលគ្រួសារនីមួយៗតស៊ូក្នុងការរស់នៅដោយពឹងពាក់គ្នាទៅវិញទៅមកជាមួយនឹងការទ្រទ្រង់ និងការការពារតិចតួចពីរដ្ឋ ។[២៩៨]

ប៉ុន្តែឯករាជភាពធ្វើឲ្យប្រជាជនក្លាយទៅជាជនរងគ្រោះ នៅក្នុងរយៈកាលនៃជម្លោះដោយសារសង្គ្រាម និងការជម្លៀសដោយបង្ខំ បានស្រោចស្រពមកលើតំបន់នេះដំបូងនៅក្រោមរបប លន់ នល់ និងក្រោយមកនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលសង្គ្រាមគ្របដណ្តប់មកលើតំបន់នេះបន្តិចម្តងៗ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ដែលត្រូវបានអនុវត្តជាយូរមកហើយបានរលាយបាត់ ។ កងទ័ព លន់ នល់ បានបណ្តេញប្រជាជនឲ្យទៅនៅក្នុងព្រៃ និងតំបន់ផ្សេងៗទៀត ដែលនៅទីនោះប្រជាជនទាំងនោះ ត្រូវបានជ្រើសរើសឲ្យចូលបម្រើនៅក្នុងចលនាឆ្វេងនិយមខ្មែរក្រហម ។[២៩៩] ប្រជាជនជាច្រើនបានចុះចូលជាមួយខ្មែរក្រហម នៅពេលដែលខ្មែរក្រហមមកដល់អន្លង់វែងជាលើកដំបូង ។ ស្រុកនេះ ត្រូវបានរៀបចំឡើងវិញនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់កុម្មុយនីស្តតាំងពីមុនឆ្នាំ១៩៧៥មកម្ល៉េះ ។ នៅទីបញ្ចប់ប្រជាជននៅក្នុងតំបន់ទាំងអស់ ត្រូវបានបង្ខំឲ្យទៅរស់នៅតាមសហករណ៍ដាច់ស្រយាល ។[៣០០]

នៅតាមសហករណ៍ទាំងនោះ ប្រជាជនបានទទួលរងនូវការអត់ឃ្លាន ការធ្វើការច្រើនម៉ោងនៅតាមវាលស្រែ និងការចូលរួមនៅក្នុងការប្រជុំទិតៀន ដែលនៅក្នុងវេទិកានេះ



រាល់ទិដ្ឋភាពទាំងអស់របស់បុគ្គលម្នាក់ ត្រូវបានរិះគន់ចំពោះភាពខ្សោយ និងភាពមិនស្មោះត្រង់ ។ នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ វប្បធម៌នៃការរស់នៅរួម បានបង្កើតជាទម្រង់ថ្មីចម្លែកមួយដែល“ផលប្រយោជន៍រួម” បានគ្របដណ្តប់ទៅលើគ្រប់ទិដ្ឋភាពទាំងអស់នៃភាពជាមនុស្ស ដោយបានលេបត្របាក់ជីវិតឯកជន នៅក្នុងការទាមទារដោយគ្មានខ្លឹមសារមួយ និងកម្មវិធីកម្មេចបុសគល់ខ្មាំងសម្ងាត់ ។ ស្មារតីឯករាជភាពដែលកើតឡើងនៅក្នុងជីវិតនៃការបង្កបង្កើនផលនៅលើដីស្រែផ្ទាល់ខ្លួននៅក្នុងតំបន់ដែលគ្មានរដ្ឋ ត្រូវបានលុបបំបាត់ដោយកម្មវិធីប្រមូលផ្តុំគ្រប់អ្វីៗទាំងអស់សម្រាប់អង្គការ ។ ទ្រព្យសម្បត្តិ ពេលវេលាទំនាក់ទំនង និងសូម្បីតែទស្សនៈផ្ទាល់ខ្លួនត្រូវបានលេបត្របាក់




ដោយសារតែតម្រូវការមិនចេះឆ្អែតឆ្អន់របស់ខ្មែរក្រហម ក្នុងការគ្រប់គ្រងទៅលើអ្វីៗគ្រប់បែបយ៉ាងរួមទាំងព្រលឹងវិញ្ញាណរបស់មនុស្សម្នាក់ៗផង។ ប៉ុន្តែ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំការអនុវត្តបែបនេះមិនមាននិរន្តរភាពទេ។ នៅក្រោមការរៀបចំរចនាសម្ព័ន្ធឡើងវិញ របស់ចលនាខ្មែរក្រហមវប្បធម៌ឯករាជ្យ និងការរស់នៅបែបប្រមូលផ្តុំបានបង្កើតទម្រង់ដ៏រន្ធត់បែបថ្មីមួយទៀត។

នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ការងារស្រែចម្ការមានលក្ខណៈឯកជន។ កងទ័ព និងគ្រួសារកងទ័ពត្រូវបានលើកទឹកចិត្តឲ្យធ្វើការបង្កបង្កើនផលដោយខ្លួនឯង នៅលើដីស្រែផ្ទាល់ខ្លួន។ ទោះបីជាសេដ្ឋកិច្ចនៅតំបន់អន្លង់វែងភាគច្រើនបន្តស្ថិត នៅក្រោមការ

គ្រប់គ្រងរបស់រដ្ឋក៏ដោយ ការបែងចែកដីឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឯកជន បានបង្កើតជាបរិបទថ្មីមួយក្នុងការរស់នៅដោយឯករាជ្យ ។ ជាងនេះទៅទៀត ដោយសារតែរបបថ្មីនេះ ត្រូវបានហ៊ុមព័ទ្ធដោយកម្លាំងរបស់រដ្ឋាភិបាលថ្មី ដែលគាំទ្រដោយវៀតណាម វប្បធម៌ឯករាជ្យបានផ្លាស់ប្ដូរទម្រង់ថ្មីមួយ ដែលជាផ្នែកមួយដ៏សំខាន់នៃអត្តសញ្ញាណសាធារណៈរបស់ខ្មែរក្រហម ។ ទស្សនៈឯករាជភាព ត្រូវបានដាក់បញ្ចូលនៅក្នុងការឃោសនាដ៏សំខាន់របស់ខ្មែរក្រហមប្រឆាំងនឹងរដ្ឋាភិបាលថ្មី ។[៣០១] នៅក្នុងន័យនេះ របបខ្មែរក្រហមមិនត្រឹមតែដើរតួនាទី នៅក្នុងការពង្រឹងមនោគមន៍វិជ្ជាកុម្មុយនីស្ដប៉ុណ្ណោះទេ ថែមទាំងបង្ហាញខ្លួនថា ជាអ្នកការពារឯករាជ្យរបស់កម្ពុជាពីការឈ្លានពានរបស់វៀតណាមទៀតផង ។ ខ្មែរក្រហមបានជំរុញលើកទឹកចិត្តប្រជាជននៅអន្លង់វែងឲ្យមើលឃើញថា ការងាររបស់ខ្លួនក្នុងការជួយទ្រទ្រង់របបខ្មែរក្រហម មិនមែនត្រឹមតែជា "អ្នកការពារ" ឯករាជភាពរបស់សហគមន៍ខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែដើម្បីការពារអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាទាំងមូលថែមទៀតផង ។

នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និងទសវត្សរ៍ឆ្នាំ១៩៩០ សហគមន៍បានបន្តការតស៊ូនៅក្រោម ការគំរាមកំហែងពីការវាយប្រហារផ្សេងៗ និងការប៉ុនប៉ងធ្វើឲ្យសហគមន៍នេះចុះខ្សោយដោយការបំបែកសហគមន៍នេះចេញពីរដ្ឋាភិបាលកម្ពុជា ។ ជាមួយនឹងការវាយប្រហារម្ដងៗ សហគមន៍នេះបានសម្លឹងមើលខាងក្នុង ហើយកសាងចំណងមិត្តភាពកាន់តែរឹងមាំឡើងនៅក្នុងចំណោមប្រជាជនដែលចែករំលែកផលប្រយោជន៍រួម ក្នុងនាមជាមិត្តរួមអាវុធ និងក្នុងនាមជាប្រជាជន ដែលរស់នៅក្នុងរដ្ឋមួយ ដែលត្រូវបានឡោមព័ទ្ធជិត ។[៣០២] ដោយត្រូវបានបង្កើតឡើងចេញពីវប្បធម៌ផ្ដាច់ការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទុក្ខវេទនារួមនៃជីវិត ដែលគ្មានទីលំនៅច្បាស់លាស់ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ និងផលប្រយោជន៍រួមក្នុងនាមជាសមមិត្ត នៅក្នុងអំឡុងពេលនៃសង្គ្រាមឥតឈប់ឈរ អន្លង់វែងបានក្លាយទៅជារដ្ឋមួយនៅក្នុងរដ្ឋស្រមោលរបស់ខ្មែរក្រហម ។

វប្បធម៌សហគមន៍បែបនេះ បានរួមចំណែកដល់លទ្ធភាពរបស់ តាម៉ុក ក្នុងការរក្សាឯករាជភាពរបស់តំបន់នេះ ខណៈពេលតំបន់គ្រប់គ្រងរបស់ខ្មែរក្រហមផ្សេងទៀត បានធ្លាក់ចូលទៅក្នុងអន្ទាក់នៃគោលនយោបាយ "ឈ្នះឈ្នះ" របស់រដ្ឋាភិបាល ។ យឹម ផាន់ណា ដែលជាអភិបាលស្រុកអន្លង់វែង បានរៀបរាប់ថា "ប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមនៅ







អន្លង់វែងមានលក្ខណៈខុសគ្នាពីប្រព័ន្ធនៅតំបន់ ប៉ៃលិន និងសំឡូត ។ នៅទីនេះ ប្រជាជនពឹងផ្អែកលើយើងសម្រាប់ចំណីអាហារ សម្ភារៈ និងដី ។»[៣០៣] ផ្ទុយទៅវិញ តំបន់ដែលគ្រប់គ្រងដោយ អ៊ី ឈាន បើកឲ្យមានទីផ្សារសេរី ដែលបម្រើដល់ផលប្រយោជន៍បុគ្គលជាជាងផលប្រយោជន៍របស់សហគមន៍ ។ ជាលទ្ធផលវប្បធម៌សហគមន៍ដែលកើតចេញពីសេដ្ឋកិច្ចគ្រប់គ្រង និងអង្គការសង្គមរបស់ថ្នាក់ដឹកនាំខ្មែរក្រហម បានបង្កើតទៅជាស្ថានភាពផ្ទុយមួយ ដែលលទ្ធភាពរបស់ថ្នាក់ដឹកនាំខ្មែរក្រហមក្នុងការរក្សាបានឯករាជភាពពីរដ្ឋា

 

ភិបាល កម្ពុជាកើតចេញពីវប្បធម៌ពឹងផ្អែកពីខាងក្នុងដែលជាការពិតមួយ ដែលប្រជាជននៅ ក្នុងតំបន់បានសង្កេតឃើញ ។ អឿន បាននិយាយថា «និយាយដោយស្មោះត្រង់ទៅ មិនចូលចិត្តរបបរបស់ តាម៉ុក ទេ ។ ប៉ុន្តែ ប្រសិនបើលោកសួរ ថា ហេតុអ្វីបានជា អាចរស់នៅជាមួយ តាម៉ុក អស់រយៈពេលជាច្រើនឆ្នាំ? ចម្លើយរបស់ គឺថា ពីព្រោះ គ្មានជម្រើស ។»[៣០៤] ធួន ក៏បានកត់សម្គាល់ដូចគ្នាដែរ «តាម៉ុក គ្រប់គ្រងរដ្ឋាភិបាលអន្លង់វែង ការដឹកជញ្ជូន និងចំណីអាហារ ។ គាត់គ្រប់គ្រងអ្វីៗទាំងអស់»[៣០៥] វប្បធម៌នៃការពឹងផ្អែកគ្នារវាងអ្នកដឹកនាំ និងកូនចៅ មិនត្រឹមតែពង្រឹងការគ្រប់គ្រងរបស់ តាម៉ុក មកលើប្រជាជននោះទេ ប៉ុន្តែថែមទាំងបានធ្វើឲ្យកេរដំណែលរបស់គាត់ស្ថិតស្ថេរបានយូរអង្វែងទៀតផង ។ តាមពិតទៅកេរដំណែលរបស់ តាម៉ុក ក្នុងនាមជាមេដឹកនាំ ដែលប្រជាជនគោរពស្រលាញ់ដូចជាឪពុក នៅក្នុងសហគមន៍នៅតែបន្តរហូតមកដល់សព្វថ្ងៃ ទោះបីជាមានការនិយាយអំពីរឿងរ៉ាវអតីតកាលដ៏សាហាវរបស់ តាម៉ុក ។ ជាជាងបដិសេធចោលមេដឹកនាំខ្លួន ប្រជាជននៅអន្លង់វែងភាគច្រើនបានធ្វើការបែងចែករវាង តាម៉ុក ដែលជា«ពេជ្ឈឃាត» និង តាម៉ុក ជា«មេដឹកនាំល្អ» ។ នេន បានអះអាងថា «តាម៉ុក គឺជាមនុស្សចិត្តល្អ ។ គាត់ជួយប្រជាជន ។ គាត់បានកសាងផ្លូវ ហើយគាត់ចូលចិត្តជួយសង់ផ្ទះឲ្យប្រជាជន ។»[៣០៦] ចាន់ណា បានបន្ថែមថា «តាម៉ុក បានផ្តល់ម្ហូបអាហារដល់ប្រជាជន ។ គ្រួសារនីមួយៗទទួលបានអង្ករ

*សម្រាប់រយៈពេលដប់ថ្ងៃ ឬកន្លះខែម្តង ។ យើងថែមទាំងទទួលបានគ្រឿងទេសផ្សេងៗ សម្លៀកបំពាក់ និងសាប៊ូកក់សក់ ។»[៣០៧]*

*ការលះបង់របស់សហគមន៍ចំពោះមេដឹកនាំរបស់ខ្លួន និងកេរមរតករបស់ តាម៉ុក បង្កើតឲ្យមានអនុស្សាវរីយ៍នៃសង្គមមួយប្រកបដោយវិន័យ និងការរស់នៅរួមដែលផ្ទុយទៅនឹងការចងចាំទាំងឡាយនៃជីវិតលំបាកវេទនានៃការរស់នៅដោយធ្វើការងារស្រេចម្ការនៅក្នុងរបបខ្មែរក្រហម ។ ជាក់ស្តែងកេរដំណែលរបស់ តាម៉ុក មិនត្រឹមតែស្ថិតនៅក្នុងការចងចាំនូវពេលវេលា ដែលបច្ចុប្បន្នបានក្លាយទៅជាអតីតកាលទៅហើយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាផលវិបាកផ្នែកសីលធម៌ដែលនៅតែបន្ត ក្នុងការពណ៌នាអំពីចលនាខ្មែរក្រហមជាពិសេស សម្រាប់បុគ្គលទាំងឡាយដែលបានបូជាពេញមួយជីវិតរបស់ខ្លួន សម្រាប់ជោគជ័យរបស់ចលនានេះ ។ លី បានរៀបរាប់អំពីជីវិតដែលមានអាហារបរិភោគគ្រប់គ្រាន់ និងជីវិតដែលពោរពេញទៅដោយភាពល្អប្រសើរ នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ។ លី បានរៀបរាប់អំពីភាពមិនខ្វះខាតចំណីអាហារនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក និងជីវិតល្អប្រសើរថា «មានស្រូវ អាហារ និងបន្លែមច្រើនណាស់ ។»[៣០៨] វ៉ែម បានបន្ថែមថា «ទោះបីជា [តាម៉ុក] ធ្លាប់សម្លាប់មនុស្សអស់ជាច្រើនក៏ដោយ តែគាត់នៅតែជាមនុស្សសាមញ្ញ ដូចកសិករធម្មតាដទៃទៀតដែរ ។ គាត់បានសង់សាលារៀន ទំនប់ទឹក និងជួយឧបត្ថម្ភប្រជាជន ។»[៣០៩]*

*ទោះជាយ៉ាងនេះក្តី មិនមែនប្រជាជនអន្លង់វែងទាំងអស់ យល់ឃើញដូចគ្នា ចំពោះអត្តចរិតរបស់ តាម៉ុក នោះទេ ។ គៀក បានអះអាងថា «តាម៉ុក ចាត់ទុកមនុស្សមិនស្មើនឹងឆ្កែរបស់គាត់ផងដែលស៊ីឆ្ងាញ់ជាងមនុស្សទៅទៀត ។»[៣១០] សុខ បានបន្ថែមថា «តាម៉ុក ជាមនុស្សមានអត្តចរិតពីរ ។ គាត់ជាមនុស្សស្លូត ប៉ុន្តែក៏អាចក្លាយជាមនុស្សកាចសាហាវដែរ ។ គាត់ជាមនុស្សកំណាញ់ប៉ុន្តែ គាត់ឲ្យបាយយើងហូប ។ ប្រសិនបើយើងសុំរបស់អ្វីមួយពីគាត់ គាត់នឹងឲ្យយើងភ្លាម ។ អ្នកផ្សេងទៀតមិនដែលឲ្យអ្វីយើងហូបនោះទេ ។»[៣១១] ដោយប្រៀបធៀបរវាងជីវិតក្នុងពេលបច្ចុប្បន្ន និងជីវិតនៅជំនាន់ តាម៉ុក ធួន បានលើកឡើងថា «ប្រជាជនមិនដែលដាច់បាយទេ ។ គាត់តែងតែជួយប្រជាជន ។ ប្រជាជនមិនដែលខ្វះខាតអាហារទេ ។ ប៉ុន្តែ ប្រសិនបើ យើងនិយាយពីការអភិវឌ្ឍបច្ចុប្បន្នគឺល្អប្រសើរជាងជំនាន់នោះ ។»[៣១២]*

នៅក្នុងស្ថានភាពនេះ ប្រជាជននៅអន្លង់វែង បានបង្ហាញអំពីមូលហេតុដែលខ្លួនស្មោះត្រង់ជាមួយ តាម៉ុក ដោយសារតែការឧបត្ថម្ភគាំទ្ររបស់ តាម៉ុក ចំពោះ សហគមន៍ និងសមត្ថភាពរបស់គាត់ក្នុងការដាក់ខ្លួនឲ្យស្មើនឹងកសិករ ។ ចាន់ណា បាននិយាយថា «កាលពីមុន តាម៉ុក គឺជាអ្នកឧបត្ថម្ភដល់យើងទាំងអស់គ្នា ។ ប៉ុន្តែ ការរស់នៅបែបនោះ មិនមែនជាវិធីរស់នៅបានយូរអង្វែងនោះទេ ។»[៣១៣] ទោះជាយ៉ាងនេះក្តីប្រជាជនមួយចំនួនទៀតអាចទទួលយកស្ថានភាពបែបនេះបាន ។ សម្រាប់ ដួង «តាម៉ុក គឺជាកសិករពិតៗ ។ គាត់គឺជាអ្នកដឹកនាំល្អ ពីព្រោះគាត់មិនអនុញ្ញាតឲ្យបុគ្គលណាមួយមានទ្រព្យសម្បត្តិច្រើនហួសហេតុពេកទេ ។ គាត់អនុញ្ញាតឲ្យប្រជាជន និងកងទ័ពមានគ្រប់គ្រាន់ល្មមហូប ។»[៣១៤] សម្រាប់ គៀម «តាម៉ុក គឺជាមេដឹកនាំ ដែលប្រកបដោយការលះបង់ និងស្នេហាជាតិដែលបានប្រយុទ្ធដើម្បីឯករាជភាពរបស់ប្រទេសរយើង ។ លះបង់ខ្លួនដើរតាមការដឹកនាំរបស់គាត់ ពីព្រោះគាត់បានជួយ ដូចជាកូនរបស់គាត់បង្កើត ។»[៣១៥]

សមត្ថភាពរបស់ តាម៉ុក ក្នុងការរួបរួមតំបន់អន្លង់វែងក្រោមរូបភាពចលនា កសិករទាក់ទាញបានការគាំទ្រពីប្រជាជនដែលជីវិតរស់នៅបានផ្សារភ្ជាប់ទៅនឹងជីវិតកសិកម្ម និងដែលទស្សនៈចំពោះពិភពលោករបស់ខ្លួនត្រូវបានបង្កើតឡើង (ក៏ដូចជាត្រូវបានបំផ្លាញទៅវិញ) ដោយសារសង្គ្រាមរាប់ឆ្នាំ និងមនោគមន៍វិជ្ជាកុម្មុយនីស្ត ។

នេះមិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ ដែលប្រជាជននៅអន្លង់វែង ភាគច្រើន ជាពិសេស ប្រជាជនដែលមានវ័យចំណាស់ គឺជាប្រជាជន«មូលដ្ឋាន» ។ «ប្រជាជនមូលដ្ឋាន» គឺជាប្រជាជនដែលមានដើមកំណើត និងវណ្ណៈសង្គមជាកសិករ ។ ជាទូទៅ ប្រជាជនទាំងនេះរស់នៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រជាជនទាំងនេះ ត្រូវបានចាត់ទុកថា ជាកងទ័ពស្រួចនៃមនោគមន៍វិជ្ជា និងចក្ខុវិស័យរបស់របបខ្មែរក្រហម ។ ក្នុងឋានៈជា«ប្រជាជនពេញសិទ្ធិ» ប្រជាជនមូលដ្ឋានទាំងនេះ ទទួលបានការការពារប្រសើរជាងពីយុទ្ធនាការជ្រុលនិយមរបស់របបនេះ ក្នុងការកំណត់សមាសភាពសត្រូវខាងក្នុង ។ នៅក្នុងន័យនេះជីវិតរស់នៅរបស់ប្រជាជនមូលដ្ឋានមានសុវត្ថិភាពជាង និងយ៉ាងហោចប្រសើរជាង«ប្រជាជនថ្មី» ។

ប្រជាជនថ្មី (ឬប្រជាជន១៧មេសា) ជាទូទៅ សំដៅទៅលើប្រជាជនដែលមកពីទីក្រុង ឬទីប្រជុំជន ឬអ្នកទាំងឡាយដែលមានជាប់ពាក់ព័ន្ធនឹងរបបសាធារណរដ្ឋខ្មែរ ។

ប្រជាជនទាំងនោះមិនមានឋានៈអ្វីនៅក្នុងសង្គមទេ ប៉ុន្តែត្រូវបានចាត់ទុកថាជាជំពូកជនសង្ស័យ ។ អ្នកដែលទទួលបានការអប់រំមានទំនាក់ទំនងជាមួយនឹងរបបចាស់ ឬមកពីតំបន់ទីក្រុង ឬទីប្រជុំជននៅក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំត្រូវបានចាត់ទុកថា ជា "ប្រជាជន១៧មេសា" ។

ទោះបីជាប្រជាជនថ្មីទទួលរងការធ្វើទុក្ខបុកម្នេញជាងប្រជាជនមូលដ្ឋានក៏ដោយ ក៏ការធ្វើទុក្ខបុកម្នេញនេះ មានកម្រិតខុសៗគ្នាពីតំបន់មួយទៅតំបន់មួយ ។ ទោះជាយ៉ាងនេះក្តី វាមិនមែនជារឿងចម្លែកនោះទេ ដែលប្រជាជននៅអន្លង់វែងជាច្រើន គឺជា "ប្រជាជនមូលដ្ឋាន" ដែលឋានៈនេះផ្តល់ឲ្យនូវហេតុផលមួយសម្រាប់ការរីកចម្រើនរបស់សហគមន៍អន្លង់វែង ។

ប្រជាជនមូលដ្ឋានមិនត្រឹមតែទទួលបានសុវត្ថិភាពច្រើនជាងប៉ុណ្ណោះទេ ថែមទាំងទទួលបានតួនាទីជាអ្នកដឹកនាំនៅក្នុងរបបខ្មែរក្រហមថែមទៀតផង ។ វាមិនមែនជារឿងភ្ញាក់ផ្អើលនោះទេ ដែលប្រជាជនមូលដ្ឋានទាំងនេះជាច្រើនបានរត់ភៀសខ្លួន ទៅកាន់ទីតាំងកាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម ដែលមិនត្រឹមតែជាជម្រក ក្នុងការការពារខ្លួនពីការគំរាមកំហែងរបស់កងទ័ពវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាតំបន់ជ្រកកោនចុងក្រោយ សម្រាប់ជីវិតដែលបានចាកឆ្ងាយពីភូមិកំណើតអស់ជាច្រើនឆ្នាំ ។ នេន បានលើកឡើងថា "ខ្ញុំបានចេញពីផ្ទះតាំងពីឆ្នាំ១៩៧៣ ហើយមិនដែលបានត្រឡប់ទៅវិញទេរហូតដល់ឆ្នាំ១៩៩៩ ។ ខ្ញុំមិនទាំងចាំថា ផ្ទះរបស់ខ្ញុំនៅម្តុំណាផង នៅពេលខ្ញុំត្រឡប់ទៅដល់ភូមិវិញ ។ ខ្ញុំវង្វេងនៅក្នុងភូមិកំណើតខ្លួនឯង ។"[៣១៦] គៀម ដែលបានចាកចេញពីស្រុកកំណើត ដើម្បីចូលបម្រើក្នុងកងទ័ពខ្មែរក្រហមតាំងពីទសវត្សរ៍ឆ្នាំ១៩៧០ បានរៀបរាប់អំពីបទពិសោធប្រហាក់ប្រហែលគ្នា ។ គៀម បានចាកចោលបងប្អូនបង្កើតចំនួន៦នាក់ (ប្រុសពីរ ស្រីបួន) ។ ប៉ុន្តែ មកដល់បច្ចុប្បន្ននេះមានតែប្អូនប្រុសម្នាក់តែប៉ុណ្ណោះ ដែលនៅរស់រានមានជីវិត ។ បងប្អូនបង្កើតផ្សេងទៀតបានស្លាប់បាត់បង់ជីវិតអស់ជាច្រើនឆ្នាំទៅហើយ ។ ថ្ងៃដែល គៀម ចូលខ្មែរក្រហមគឺជាថ្ងៃចុងក្រោយដែល គៀម បានឃើញមុខឪពុកម្តាយ និងបងប្អូន ។ ទ្រព្យសម្បត្តិរបស់គ្រួសារទាំងអស់ ក៏ត្រូវរលាយបាត់បង់គ្មានសល់ ។ អ្វីដែលនៅសេសសល់ គឺជីវិតរស់នៅអន្លង់វែង ។[៣១៧]

ជាទូទៅ ប្រជាជនភាគច្រើន ដែលបានធ្វើដំណើរទៅលេងភូមិកំណើតរបស់ខ្លួន







ត្រឡប់មកអន្លង់វែងវិញទាំងទឹកភ្នែក ។ ប្រជាជននៅអន្លង់វែងភាគច្រើនដែលមានបំណងចង់ផ្សារភ្ជាប់ទំនាក់ទំនងជាមួយអតីតកាលរបស់ខ្លួន ក្រុមគ្រួសារ និងមិត្តភក្តិឡើងវិញ បានដឹងថា ពេលវេលាដែលបានកន្លងផុតទៅមិនអាចវិលថយក្រោយវិញបានទេ ។ ជាទូទៅផ្ទះសម្បែងរបស់ខ្លួន ដែលត្រូវបានបោះបង់ចោលនៅក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំត្រូវបានអ្នកដទៃកាន់កាប់ ។ សារ៉ាយ បានចាកចេញពីផ្ទះរបស់គាត់នៅខេត្តកំពង់ស្ពឺនៅឆ្នាំ១៩៧៣ ។ សារ៉ាយ បម្រើការនៅក្នុងកងពល៨០១ក្នុងរបបខ្មែរក្រហម និងត្រូវបានបញ្ជូនទៅខេត្តរតនគិរី ។ សារ៉ាយ មិនដែលបានទាក់ទងឪពុកម្តាយបងប្អូន និងសាច់ញាតិរបស់ខ្លួន និងមិនដែលបានត្រឡប់មកភូមិកំណើតរបស់ខ្លួនវិញទេ រហូតដល់ឆ្នាំ១៩៩៩ ។ នៅពេលដែល សារ៉ាយ មកដល់ស្រុកកំណើតចាស់ៗនៅក្នុងភូមិមិនអាចចំណាំមុខរបស់គាត់បានទេ ហើយគាត់ក៏មិនអាចចំណាំដីភូមិរបស់ខ្លួនបានដែរ ។ សារ៉ាយ ចាំបានថា កាលពីខ្លួនអាយុ១៣ឆ្នាំ ខ្លួនធ្លាប់ឃ្វាលគោនៅលើដីរបស់គ្រួសារនោះ ប៉ុន្តែ បច្ចុប្បន្នដីស្រែនោះបានបាត់បង់ទៅហើយ ។ រដ្ឋបានប្រគល់ដីនោះទៅឲ្យគ្រួសារដទៃ ដែលបានសង់ផ្ទះថ្មីរួចទៅហើយ ។ ដោយសារតែចង់បានសន្តិភាព សារ៉ាយ មិនចង់ទាមទារយកដីនោះមកវិញទេ ។[៣១៨] វី បានលើកឡើងថា «ប្រជាជនភាគច្រើនដែលបានចាកចេញពីអន្លង់វែង ត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ តែងតែមកវិញដោយទឹកភ្នែក ។ ប្រជាជនទាំងនោះបានដឹងថា ផ្ទះសម្បែងរបស់ក្រុមគ្រួសាររបស់ខ្លួនត្រូវបានអ្នកដទៃកាន់កាប់ ហើយខ្លួនមិនមានកន្លែងឈរជើងនៅក្នុងសហគមន៍របស់ខ្លួនទៀតទេ ។»[៣១៩]

ប៉ុន្តែ ការបាត់បង់រូម បាននាំឲ្យមនុស្សកាន់តែជិតស្និទ្ធនឹងគ្នា ។ ដោយពុំមានទីកន្លែងរស់នៅច្បាស់លាស់ អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងក្រុមគ្រួសារជាច្រើន បានវិលត្រឡប់មកអន្លង់វែងវិញ ដោយបានដឹងយ៉ាងច្បាស់ថា ផ្ទះសម្បែងតាំងពីកុមារភាព ភូមិកំណើត និងអតីតកាលទាំងអស់របស់ខ្លួន បានបាត់បង់ទៅតាមពេលវេលាទៅហើយ ។ អន្លង់វែងមិនត្រឹមតែក្លាយទៅជាកន្លែងជ្រកកោន នៅចំពោះមុខនៃការបាត់បង់ជីវិតអតីតកាលរបស់ខ្លួនប៉ុណ្ណោះទេប៉ុន្តែ ថែមទាំងជាកន្លែងសម្រាប់កសាងជីវិតថ្មីទៀតផង ។ យ៉ាន មិនអាចរស់នៅក្នុងខេត្តតាកែវបានទេ ពីព្រោះគាត់មិនស្គាល់អ្នកណាម្នាក់នៅទីនោះ ហើយមិនអាចទ្រាំរស់នៅក្នុងភូមិកំណើតរបស់ខ្លួនបាន ។ នៅអន្លង់វែង យ៉ាន ស្គាល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ហើយដីមានតម្លៃថោក ។ យ៉ាន អាចស្វែងរកជំនួយ

ពីមន្ត្រីទាំង អស់នោះបានដូចជា នួន នៅ, យឹម ផាន់ណា, យឹម ពឹម និង ខៀវ វុធ ។ យ៉ាន បានលើកឡើងថា «ការរស់នៅក្បែរផ្សារមានភាពងាយស្រួលជាង ។»[៣២០]

ព្រៃឈើនៅអន្លង់វែង ដែលមិនទាន់ត្រូវបានអភិវឌ្ឍជាមួយនឹងធនធាន និងឱកាសដ៏សម្បូរបែបសម្រាប់ការអភិវឌ្ឍ បានបង្ហាញអំពីព្រំដែនថ្មីមួយសម្រាប់ការកសាងជីវិតសាជាថ្មី ។ ជាងនេះទៅទៀត ដីនៅអន្លង់វែងនៅទំនេរច្រើន ទោះបីជា ជម្លោះដីធ្លីកើតឡើងញឹកញាប់ក៏ដោយ ។ ប្រជាជនមានការគោរពគ្នាទៅវិញទៅមកនៅក្នុងសហគមន៍ ដោយសារប្រជាជនទាំងអស់ចេញមក ពីអតីតកាលប្រហាក់ប្រហែលគ្នាដែលជាជីវិតមួយនៅក្នុងចលនាខ្មែរក្រហមដូចគ្នា ។

ជាការពិតណាស់ ជីវិតមិនអាចចាប់ផ្ដើមឡើងវិញបានដោយងាយស្រួលនោះទេ ។ ជាមួយនឹងរឿងរ៉ាវនៃការចាប់ផ្ដើមជីវិតឡើងវិញ តែងតែបង្កប់នូវរឿងរ៉ាវជូរចត់ និងការបាត់បង់ជីវិតជារៀងរហូត ។ សារ៉ាយ ដែលជាអតីតកងទ័ពខ្មែរក្រហមមួយរូបនិយាយថា ៖

> *ខ្ញុំសោកស្ដាយណាស់ នៅពេលរឿងគ្រប់យ៉ាងបានកន្លងផុតទៅ ខ្ញុំបានបាត់បង់អ្វីៗទាំងអស់ ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់ឲ្យខ្ញុំនូវទឹកប្រាក់ចំនួនបីលានរៀលនៅពេលខ្ញុំចូលនិវត្តន៍ ។ ខ្ញុំបានយកប្រាក់នោះទៅសងបំណុលគេទាំងអស់ ។ ឯប្រាក់ដែលនៅសល់មួយចំនួន ខ្ញុំបានចំណាយទៅលើការព្យាបាលជំងឺ ។ មន្ត្រីផ្នែកសង្គមកិច្ចសន្យាថា រដ្ឋនឹងចែកដីឲ្យខ្ញុំ ។ ប៉ុន្តែតើដីនោះនៅឯណា? ខ្ញុំមិនមានអ្វីទាំងអស់ ។ ខ្ញុំមិនខុសពីលោកសង្ឃដែលទើបតែសឹកនោះទេ ។*[៣២១]

ភាពសោកស្ដាយបានញាំញីជីវិតប្រជាជនអន្លង់វែងច្រើនជាងបញ្ហាសេដ្ឋកិច្ច ទៅទៀត ។ ពេលក្រឡេកក្រោយមើលទៅរយៈពេលជាច្រើនឆ្នាំ នៅក្នុងការបម្រើខ្មែរក្រហម ប្រជាជនជាច្រើនបានមើលឃើញថា ខ្លួនបានចំណាយជីវិតចោលឥតប្រយោជន៍ ហើយក្ដីស្រមៃទាំងឡាយបានរលាយបាត់បង់អស់ ។ គៀម បានបាត់បង់ជើងម្ខាង ហើយគាត់តែងតែឈឺចុកចាប់នៅត្រង់ស្នាជាប្រចាំ ដោយសារតែជីវិតធ្វើជាកងទ័ព ។ គាត់បាន

ចោទសួរថា «តើខ្ញុំទទួលបានអ្វីពីការពលីរបស់ខ្ញុំចំពោះប្រទេសជាតិ? នេះគឺជាសំណួរមួយដែលខ្ញុំចង់សួរទៅកាន់មេដឹកនាំខ្មែរក្រហម ។»[៣២២]

ទោះបីជាអតីតកម្មាភិបាលខ្មែរក្រហម និងប្រជាជនមូលដ្ឋានជាច្រើន អាចចាប់ផ្ដើមជីវិតសាជាថ្មីបានប្រជាជនមួយចំនួនទៀតបានមើលឃើញថា ខ្លួនពុំមានអ្វីសម្រាប់ការចាប់ផ្ដើមជីវិតសាជាថ្មីទេ ដោយសារជីវិតរបស់ខ្លួនទាំងអស់បានបូជា ទៅឲ្យរបបខ្មែរក្រហមអស់ទៅហើយ ។ ជីវិតនៅក្រោយរបបខ្មែរក្រហមពោរពេញទៅដោយភាពសោកស្ដាយដោយគ្មានអ្វីសម្រាប់បង្ហាញប្រកបដោយមោទកភាពទេ ក្រៅពីដៃជើងដែលបាត់បង់ និងក្ដីស្រមៃដែលរលាយបាត់បង់ ដោយសារតែការពលីអស់រយៈពេលជាច្រើនឆ្នាំទៅលើបុព្វហេតុមួយដែលបរាជ័យ ។ ឡុត និយាយថា ៈ

> ប្រសិនបើក្រឡេកទៅមើលរឿងរ៉ាវទាំងឡាយដែលបានកើតឡើង នៅពេលនោះ ខ្ញុំគិតថា ខ្ញុំកំពុងដើរតាមអង្គការ ។ ក្រោយមក ខ្ញុំគិតដល់ការផ្សះផ្សា និងបានភ្ញាក់ខ្លួនថាអ្វីៗ ដែលបានកើតឡើងកន្លងមក គឺជាទង្វើមិនត្រឹមត្រូវ ។ ទីមួយ ខ្ញុំបានដឹងខ្លួនថា យើងបានបំផ្លាញប្រទេសជាតិ ។ ទីពីរ ខ្ញុំបានដឹងថា ខ្ញុំបានបំផ្លាញខ្លួនឯង ។ នៅពេលនោះ យើងគិតថា យើងបានធ្វើរឿងត្រឹមត្រូវ ។ ប៉ុន្តែបន្ទាប់ពីសមាហរណកម្ម ខ្ញុំបានគិតអំពីរឿងនេះម្ដងទៀត ។ ខ្ញុំមានអារម្មណ៍សោកស្ដាយ ។ មនុស្សមួយចំនួនធ្វើអំពើអាក្រក់ ។ ប៉ុន្តែអ្វីដែលយើងនៅមានសង្ឃឹមគឺថា គាត់អាចកែខ្លួន ។ [គាត់អាចក្លាយទៅជាមនុស្សថ្មី ប៉ុន្តែ សម្រាប់ជនពិការដូចជារូបខ្ញុំវិញ ខ្ញុំពុំមានអ្វីនៅសេសសល់ទៀតនោះទេ ។[៣២៣]

ទោះបីជាមិនមានអ្វីនៅសេសសល់ទៀតក៏ដោយ ក៏ប្រជាជនអន្លង់វែងមានបំណងប្រាថ្នាខ្លាំងក្លា ក្នុងការធ្វើដំណើរឆ្ពោះទៅមុខដើម្បីកសាងជីវិតថ្មី ។ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ រ៉ុង មានការសប្បាយរីករាយជាខ្លាំង ។ គាត់បានចាប់ផ្ដើមសង់ផ្ទះថ្មីបង្កើតជីវិតគ្រួសារថ្មីនិងប្រកបរបររកស៊ីនៅអន្លង់វែង ។[៣២៤] សាវើត បានលើកឡើងថា «ពុំមានការរើសអើង ដោយសារតែប្រវត្តិពីអតីតកាល ឬពេលវេលានៃការចាប់ផ្ដើមមករស់នៅ

អន្លង់វែងនោះទេ ។»[៣២៥] ប៉ុន្តែ នៅក្នុងដំណើរនៃការកសាងជីវិតថ្មី ប្រជាជននៅអន្លង់វែង ត្រូវបានតម្រូវឲ្យធ្វើការលះបង់ដែលមិនគួរឲ្យជឿ ទោះបីជាខ្លួនបានលះបង់ជីវិតដើម្បីចលនា ខ្មែរក្រហមពេញមួយជីវិតរួចហើយក៏ដោយ ។ កម្លាំងរបស់រដ្ឋាភិបាលបានវាយប្រហារតំបន់អន្លង់វែងចំនួនពីរលើក ៖ លើកទីមួយនៅឆ្នាំ១៩៩៣ និងលើកទីពីរនៅឆ្នាំ១៩៩៤ ។ នៅក្នុងការវាយប្រហារលើកទីមួយ ខ្មែរក្រហមមិនបានដុតបំផ្លាញផ្ទះសម្បែងរបស់ខ្លួននោះទេ ។ ប៉ុន្តែ នៅពេលកងទ័ពរដ្ឋាភិបាលបានចូលមកជាលើកទីពីរ មេដឹកនាំខ្មែរក្រហម បានបញ្ជាឲ្យប្រជាជន និងកងទ័ពរបស់ខ្លួនដុតផ្ទះខ្លួនឯងចោល ដើម្បីកុំឲ្យកងទ័ពរដ្ឋាភិបាលអាចតាំងទីលំនៅបាន ។[៣២៦] សម្រាប់ប្រជាជនជាច្រើនការលះបង់នេះ គឺពិតជាការសម្រេចចិត្តមួយដ៏ពិបាក ។ គៀម បានលើកឡើងថា ៖

> កងទ័ពបានដុតផ្ទះរបស់ខ្ញុំចោល និងបានបំផ្លាញមធ្យោបាយ ក្នុងការរកទទួលទានចិញ្ចឹមជីវិតរបស់ខ្ញុំចោលទាំងអស់ ។ ទង្វើនេះ បានធ្វើឲ្យស្ថានភាពរស់នៅគ្រួសាររបស់ខ្ញុំធ្លាក់ដុនដាបយ៉ាងខ្លាំង ។ ខ្ញុំមានការសោកស្តាយចំពោះទង្វើ ដែលខ្មែរក្រហមធ្វើមកលើខ្ញុំ បន្ទាប់ពីខ្ញុំបានបូជាជីវិតប្រយុទ្ធដើម្បីការពារប្រទេសជាតិអស់ រយៈពេលជាច្រើនឆ្នាំមក ។ មិនគួរណាទទួលរងទុក្ខវេទនាបែបនេះជាថ្នូរនឹងការលះបង់កន្លងមកទេ ។[៣២៧]

ជាទីបញ្ចប់ ការលំបាកវេទនាបានជះឥទ្ធិពលដល់ឆន្ទៈរបស់ប្រជាជន ហើយចលនាខ្មែរក្រហមនឹងប្រឈមមុខនឹងភាពអន្តរាយពីខាងក្នុង ។ ជាមួយនឹងការផ្តាច់ខ្លួនរបស់មេបញ្ជាការកងទ័ពជាន់ខ្ពស់របស់ តាម៉ុក តំបន់អន្លង់វែងចាប់ផ្តើមធ្វើអន្តរកាលឆ្ពោះទៅសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ប្រជាជននិងមេដឹកនាំខ្មែរក្រហមមួយចំនួនទន្ទឹងចង់បានសន្តិភាព ។[៣២៨] ទោះបីជាសមាហរណកម្មនាំមកនូវយុគសម័យថ្មីនៃសេរីភាពផ្នែកសេដ្ឋកិច្ចនិងសង្គម គោលគំនិតរបស់សហគមន៍ពីអតីតកាល និងវប្បធម៌នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាការអនុវត្តទាំងឡាយក្រោយមកទៀត នៅតែបន្តមានឥទ្ធិពលទៅលើការយល់ឃើញរបស់សហគមន៍អំពីអត្តសញ្ញាណ និងទស្សនវិស័យសម្រាប់អនាគតរបស់ខ្លួន ។

ទោះជាយ៉ាងណា អនុស្សាវរីយ៍ដក់ជាប់យ៉ាងជ្រៅនៅក្នុងចិត្តរបស់ប្រជាជនអន្លង់វែង ទោះបីជាមានការពណ៌នាផ្ទុយអំពីទុក្ខវេទនា និងការបាត់បង់ក៏ដោយ ។ លី បាននិយាយថា "ច្បាប់របស់ខ្មែរក្រហម គឺល្អ ។ ប្រជាជនស្រឡាញ់រាប់អានគ្នាដូចបងប្អូន ។ ប្រជាជនមិនអាចដើរហើរដោយសេរីបានទេ ។ ប្រជាជនត្រូវតែរៀបអត្តចរិតឲ្យបានត្រឹមត្រូវ ។ ប៉ុន្តែបច្ចុប្បន្នគឺខុសពីមុន ។ យុវជនក្មេងៗមួយចំនួនប្រព្រឹត្តអំពើឆ្គាំឆ្គង ។" លី បានបន្ថែមថា "ការអនុវត្តរបស់ខ្មែរក្រហមប្រសើរជាងការអនុវត្តនាពេលបច្ចុប្បន្ន ពីព្រោះមនុស្សចេះជួយគ្នាទៅវិញទៅមក ។"[៣២៩] ឡុត យល់ស្របជាមួយនឹងចំណុចដែលថា សេរីភាពផ្នែក សេដ្ឋកិច្ចនិងសង្គម បានធ្វើឲ្យអន្លង់វែងប្រឈមទៅនឹងបញ្ហា ដែលមិនធ្លាប់កើតមានកាលពីរបបខ្មែរក្រហម ។ "ប្រជាជនឈ្លក់វង្វេងនឹងសង្គមស៊ីវិល័យ ។ ប្រជាជនបានភ្លេចប្រភពដើមរបស់ខ្លួន ដែលនោះគឺការធ្វើស្រែចម្ការ ។"[៣៣០] វ៉ែម បានលើកឡើងថា ៖

> ការធ្វើជំនួញសម័យបច្ចុប្បន្ន ខុសពីសម័យ តាម៉ុក ឆ្ងាយណាស់ ។ នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក យើងរស់នៅជាសហគមន៍ ។ យើងជួយគ្នាទៅវិញទៅមក ទោះបីជាយើងឈឺក៏ដោយ ។ យើងកម្រឈ្លោះប្រកែកគ្នាណាស់ ។ បច្ចុប្បន្ន នៅពេលដែលប្រជាជនធ្វើជំនួញ ពួកគេគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនមុន ។[៣៣១]

ការគោរពយ៉ាងជ្រាលជ្រៅចំពោះសហគមន៍ និងស្មារតីឯករាជភាពពីសហគមន៍ខាងក្រៅហាក់ដូចជានៅតែសមស្របនាពេលបច្ចុប្បន្ននៅក្នុងផ្នែកជាច្រើន ដូចជាការផ្តល់កម្មសិទ្ធិដី ការធ្វើស្រែចម្ការ ជីវិតគ្រួសារ និងរឿងរ៉ាវអាក្រក់អំពីសហគមន៍ ។

ការសុំទានគឺជាអំពើហាមប្រាមមួយនៅក្នុងសហគមន៍ ដែលផ្ទុយទៅនឹងគោលការណ៍ឯករាជ្យ និងប៉ះពាល់ដល់លទ្ធភាពរបស់សហគមន៍ក្នុងការពឹងផ្អែកលើខ្លួនឯង ។ ប្រជាជននៅអន្លង់វែងជឿជាក់ថា តំបន់អន្លង់វែងមានអ្នកសុំទានតិចតួច ឬគ្មានទាល់តែសោះ ពីព្រោះប្រជាជននៅអន្លង់វែងនឹងមិនសុំទានទេ ទោះបីស្ថិតនៅក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយ ។[៣៣២] យោងតាមសម្តីរបស់ សាំង វី "សូម្បីតែជនពិការភ្នែកនៅស្រុកអន្លង់វែង ក៏អាចរស់នៅដោយការធ្វើស្រែចម្ការបានដែរ ។ ជាក់ស្តែង តា សាត គឺជាជន

ពិការភ្នែក ប៉ុន្តែគាត់បានប្រើដៃរបស់គាត់ ដើម្បីស្ទាបរបស់ផ្សេងៗ និងអាចធ្វើចម្ការបាន ។»[៣៣៣] យឹម ផាន់ណា ដែលជាអភិបាលស្រុកអន្លង់វែងបានលើកឡើងថា មេដឹកនាំខ្មែរក្រហមថែរក្សាប្រជាជនទាំងអស់នៅអន្លង់វែង ។ ហេតុដូចនេះហើយបានជាតំបន់នេះមិនមានអ្នកសុំទាន ។ ប្រជាជនទទួលបានការបែងចែកដី ដើម្បីធ្វើស្រែចម្ការ ដែលខុសពីតំបន់របស់កងទ័ពប៉ុល ពត ដែលបានផ្ដល់ដីតិចតួច ឬមិនបានផ្ដល់អ្វីទាំងអស់ដល់សមាជិករបស់ខ្លួន បន្ទាប់ពីសង្គ្រាមបានបញ្ចប់ដែលបានបង្ខំឲ្យពួកគេក្លាយខ្លួនទៅជាអ្នកសុំទាន ។[៣៣៤] ការជឿជាក់ដែលថាមិនមានអ្នកសុំទាន (ហើយការសង្កេតបានបញ្ជាក់យ៉ាងដូច្នេះមែន)ហាក់ដូចជាចេញមកពីវប្បធម៌នៃភាពមិនងាយចុះទ្រុឌទ្រោម ដែលមាននៅក្នុងអត្ត-សញ្ញាណរបស់សមាជិកនៅក្នុងសហគមន៍ ជាពិសេសអ្នកទាំងឡាយដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ដូចគ្នាដែរ ការភ្ជាប់ខ្លួនយ៉ាងរឹងមាំទៅនឹងជីវិតស្រែចម្ការគឺមិនត្រឹមតែជាមធ្យោបាយសម្រាប់ចិញ្ចឹមជីវិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមធ្យោបាយនៃការអនុវត្តតាមប្រពៃណី ដែលបង្ហាញអំពីការគោរពចំពោះជីវិតរស់នៅដោយឯករាជ្យ និងការរស់នៅបែបសមូហភាព ។ សុភាសិតរបស់ខ្មែរក្រហមមួយនិយាយថា «ដើងជាប់ដី គឺជាប្រភពសេដ្ឋកិច្ច» ត្រូវបាននិយាយតៗគ្នា នៅក្នុងសន្ទនាជាច្រើនអំពីសារៈសំខាន់នៃការដាំដុះ ។ សុភាសិតនេះមានន័យថា សេដ្ឋកិច្ចមានប្រភពចេញមកពីដីប្រៀបបានទៅនឹងជើងមនុស្សជាន់លើដីដែរ ។ ដូចដែលអ្នកស្រុកអន្លង់វែងម្នាក់បានលើកឡើង«គ្មានអ្វីក្រៅពីការដាំដុះ និងការធ្វើស្រែចម្ការនោះទេ» ។[៣៣៥] ជីវិតធ្វើស្រែចម្ការដែល តាម៉ុក បានជំរុញ នៅតែបន្តរហូតដល់ពេលបច្ចុប្បន្ន ដែលជាការរំឭកដល់សមត្ថភាពរបស់សហគមន៍ ក្នុងការរកស៊ីចិញ្ចឹមជីវិត និងពឹងពាក់គ្នាទៅវិញទៅមកនៅពេលចាំបាច់ ។

ប៉ុន្តែ នៅពេលសហគមន៍នេះបានផ្លាស់ប្ដូរពីមួយជំនាន់ទៅមួយជំនាន់ ហើយប្រជាជនចំណូលថ្មីបានចូលមករស់នៅយ៉ាងច្រើននៅទីនោះ លក្ខណៈសម្បត្តិទាំងអស់នេះបានចាប់ផ្ដើមសាបរលាបទៅវិញ តាំងពីសមាហរណកម្មមកម្ល៉េះ ។[៣៣៦] ប៉ុន្តែ ទោះបីជានៅចំពោះមុខនៃសហគមន៍ ដែលកាន់តែមានវ័យចំណាស់ និងការផ្លាស់ប្ដូរសង្គម និងសេដ្ឋកិច្ចយ៉ាងណាក៏ដោយ ក៏តម្លៃរបស់សហគមន៍នៅតែអាចរក្សាបានតាមមធ្យោបាយផ្សេងៗ ។

មិនទាន់មានការបង្ហាញពីការខឹងសម្បារ ទៅលើប្រជាជនដែលមកពីខាងក្រៅ[៣៣៧]

ជាពិសេស អ្នកដែលទើបតែចូលមកតាំងទីលំនៅនៅអន្លង់វែង ។ ទោះជាយ៉ាងនេះក្ដីយើងអាចទទួលអារម្មណ៍ដឹងថា មានការកើនឡើងនូវការមិនជឿទុកចិត្តគ្នារវាងសមាជិកនៅក្នុងសហគមន៍ជាមួយនឹងអ្នកចំណូលថ្មី ជាពិសេស ជុំវិញបញ្ហាដីធ្លី ។ នាពេលថ្មីៗនេះមានរបាយការណ៍ព័ត៌មានជាច្រើន អំពីក្រុមហ៊ុនបរទេស ជាពិសេស ក្រុមហ៊ុនចម្ការកៅស៊ូដែលបានរឹបអូសយកដីពីប្រជាជនអន្លង់វែង ។[៣៣៨] ការពិភាក្សាអំពីបញ្ហាដែលក្រុមហ៊ុនចម្ការកៅស៊ូរឹបអូសយកដីកាន់តែមានសភាពធ្ងន់ឡើងៗ នៅពេលមានដំណឹងថា មនុស្សមកពីក្រៅបានវាស់ដីដោយប្រើប្រាស់ឧបករណ៍កំណត់ទីតាំងភូមិសាស្ត្រពិភពលោក ។[៣៣៩]

នៅក្នុងកំណត់ត្រាស្រដៀងគ្នានេះដែរ ការកាន់កាប់ដីនាពេលថ្មីៗនៅជុំវិញតំបន់ប្រាសាទព្រះវិហារ និងការប្រឈមមុខដាក់គ្នាដែលបានផ្ទុះឡើងនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ បានជំរុញឲ្យមានការសង្ស័យទៅលើចេតនាឈ្លានពាន ដែលគ្មានការខ្មាសអៀនរបស់ថៃ ។[៣៤០] នៅក្នុងឆ្នាំ២០១១ សាលាបឋមសិក្សាហ៊ុនសែន នៅអន្លង់វែងត្រូវបានបង្ខំចិត្តបិទទ្វារ ដោយសារតែបញ្ហាជម្លោះព្រំដែនជាមួយប្រទេសថៃ ។ ប្រជាជនមានការព្រួយបារម្ភថាបញ្ហាព្រំដែននឹងបន្តទៅមុខ ។ ការកើនឡើងនូវតម្រូវការដីថ្មីសម្រាប់ការអភិវឌ្ឍ ដោយសារតែកំណើនប្រជាជនបានបង្ហាញសញ្ញាណមិនល្អដល់ប្រជាជននៅក្នុងសហគមន៍ ។ នៅពេលដែលសហគមន៍កាន់តែរីកធំឡើង ដោយសារវត្តមានរបស់អ្នកចំណូលថ្មី ដែលកំពុងតែស្វែងរកផលប្រយោជន៍ពីធនធាននៅក្នុងសហគមន៍កម្មសិទ្ធិដីធ្លីបានក្លាយទៅជាបញ្ហាដ៏គួរឲ្យព្រួយបារម្ភ ។[៣៤១]

ម្យ៉ាងទៀត ការកើនឡើងនៃការចាប់អារម្មណ៍ទៅលើប្រវត្តិសាស្ត្ររបស់តំបន់នេះជាពិសេសទីតាំងប្រវត្តិសាស្ត្រទាំងឡាយ បានផ្ដល់ឱកាសដល់ការទាក់ទាញទេសចរណ៍ និងការអភិវឌ្ឍនៅក្នុងតំបន់ ។ កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងទេសចរណ៍នៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ក្នុងគោលបំណងជំរុញវិស័យទេសចរណ៍ឲ្យកាន់តែធំឡើងបង្ហាញថាសហគមន៍អន្លង់វែងនឹងទទួលបានផលប្រយោជន៍ពីអតីតកាលដ៏ខ្មៅងងឹតរបស់ខ្លួន ជាពិសេសរឿងរ៉ាវដែលពាក់ព័ន្ធនឹងចលនាចុងក្រោយរបស់ខ្មែរក្រហម ។

ទោះជាយ៉ាងណាក្ដី ទេសចរណ៍ និងការអភិវឌ្ឍគ្រាន់តែជាទិដ្ឋភាពមួយនៃអនាគតរបស់តំបន់នេះតែប៉ុណ្ណោះ ។ អនាគតរបស់តំបន់អន្លង់វែងស្ថិតនៅក្នុងដៃរបស់ប្រជាជននៅក្នុងតំបន់ ។ ប្រជាជននៅក្នុងតំបន់អន្លង់វែង បានផ្ដល់បទពិសោធផ្សេងៗគ្នាជាច្រើន

ដែលជាបន្ទូចមួយអាចឲ្យយើងមើលឃើញអំពីកេរដំណែលនៃរបបខ្មែរក្រហមភាពឃោរឃៅនៃសង្គ្រាម ព្រមទាំងសម្រស់ដ៏អស្ចារ្យ និងសេចក្ដីក្លាហានរបស់មនុស្សនៅក្នុងស្ថានភាពដ៏លំបាកបំផុត ។

ជំពូក ១៦

# រឿងរ៉ាវនៅអន្លង់វែង

ការសរសេរប្រវត្តិរបស់ប្រជាជននៅអន្លង់វែង ដូចជាការសរសេរប្រវត្តិរឿងរ៉ាវផ្សេងៗទៀតដែរ ទាមទារឲ្យមានដំណើរការសម្រិតសម្រាំងមួយ ដែលបទពិសោធត្រូវបានចម្រាញ់ឲ្យចេញទៅជាការចងចាំពីការចងចាំទៅជាការនិយាយផ្ទាល់មាត់ និងពីការនិយាយផ្ទាល់មាត់ទៅជាព័ត៌មានដែលអាចកត់ត្រាបាន ។ ជាការពិត ការចងចាំបានឆ្លងកាត់នូវតម្រងចម្រោះជាច្រើនដំណាក់ ។ ទស្សនៈ និងជំនឿ មនោគមន៍វិជ្ជានិងវប្បធម៌ជះឥទ្ធិពលទៅលើគ្រប់ដំណាក់កាលទាំងអស់ នៃដំណើរការប្រវត្តិសាស្ត្រ ដែលបានកំណត់ចរិតលក្ខណៈនៃរឿងរ៉ាវពីអតីតកាលប្រៀបបាននឹងវិចិត្រករកំណត់ទម្រង់បែបផែននៃរូបគំរូរបស់ខ្លួនដែរ ។ ទោះជាលទ្ធផលយ៉ាងណាក៏ដោយ ការងារនេះ គឺជាដំណើរការនៃការដកស្រង់នូវគោលរឿងសំខាន់ៗ ដែលបង្កើតបានទៅជាមូលដ្ឋានសម្រាប់កំណត់ប្រវត្តិរឿងរ៉ាវរបស់សហគមន៍មួយ ។ ជាទូទៅ ដំណើរការប្រៀបបានទៅនឹងឈុតឆាកសម្តែងមួយដែលប្រវត្តិវិទូបានបង្កើតឡើងវិញនូវអារម្មណ៍ និងបរិយាកាសនៃបទពិសោធជាក់ស្តែងណាមួយដែលបានធ្វើឲ្យរឿងរ៉ាវក្នុងអតីតកាលមានជីវិតរស់ឡើងវិញ ។ ប្រសិនបើដំណើរការត្រូវបានធ្វើឡើងប្រកបដោយភាពស្មោះត្រង់ការសរសេរប្រវត្តិសាស្ត្របែបនេះនឹងជួយកសាងស្ពានមួយ ដើម្បីតភ្ជាប់មនសិការរបស់ប្រជាជននៅអន្លង់វែងទៅនឹងអ្នកអាន ។

មិនមានប្រវត្តិសាស្ត្រណាមួយ ដែលអាចបង្កើតស្ពានសម្រាប់តភ្ជាប់ដ៏ល្អឥតខ្ចោះដូចផ្ទាំងគំនូរបាននោះទេ ។ ប៉ុន្តែយើងអាចសាកល្បងពិនិត្យមើលអំពីរឿងរ៉ាវនៃជីវិតរបស់មនុស្ស តាមរយៈពាក្យសម្តីផ្ទាល់មាត់របស់អ្នកស្រុកអន្លង់វែង ។ ការធ្វើបែបនេះ យើងសង្ឃឹមថា នឹងបង្កើតឲ្យមានការយល់ដឹងល្អឥតខ្ចោះអំពីបទពិសោធជាក់ស្តែងនោះទេ ប៉ុន្តែ ការយល់ដឹងទូលំទូលាយជាងមុនមួយអំពីភាពជាមនុស្ស ដែលបានកំណត់អត្តសញ្ញាណរបស់ប្រជាជន និងវប្បធម៌របស់ស្រុកអន្លង់វែង ។

## អំពើអាក្រក់

នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានឃើញស្ត្រីម្នាក់ ដែលត្រូវបានចាប់ខ្លួននៅក្នុងកងកុមារ ។ សម្ងំនៅក្នុងកន្លែងស្នាក់នៅរបស់ខ្ញុំ ។ ស្ត្រីម្នាក់នោះនិយាយស្តីបែបគំរាមកំហែង និងមានចរិតលក្ខណៈបែបស្រីពាក់កណ្តាល ប្រុសពាក់កណ្តាល ។ យើងមិនទុកចិត្តគាត់ទេ ។ យប់មួយគាត់បាននិយាយថា គាត់ចង់ហូបអ្វីៗគ្រប់យ៉ាងទាំងអស់ ។ ខ្ញុំមិនដឹងថា គាត់ចង់ហូបអ្វីឲ្យពិតប្រាកដនោះទេ ។ ប៉ុន្តែ នៅពេលខ្ញុំឮគាត់និយាយដូច្នេះ ខ្ញុំបានរាយការណ៍ប្រាប់ថ្នាក់លើ ។ បន្ទាប់មក កងទ័ពបានមកយាមស្ត្រីម្នាក់នោះ ។ នៅព្រឹកថ្ងៃបន្ទាប់ ខ្ញុំត្រូវបានបញ្ជាឲ្យនាំស្ត្រីនោះចេញមកក្រៅ ។ ក្រោយមក ពួកគេនាំគាត់ទៅបាត់ ហើយមិនដែលឃើញគាត់ត្រឡប់មកវិញទេ ។ កម្មាភិបាលខ្មែរក្រហមតែងតែរំឭកដាស់តឿនយើងឲ្យប្រយ័ត្នប្រយែងជាមួយជនដែលមិនស្មោះត្រង់ ។ ពួកគេបានប្រាប់ខ្ញុំឲ្យបន្តតាមដាន និងស្វែងរកជនក្បត់ ឬជនទាំងឡាយណាដែលមិនមានភាពស្មោះត្រង់ ។[៣៤៧]

## អំពើល្អ

ខ្ញុំជាកងទ័ពខ្មែរក្រហមម្នាក់ ដែលទទួលខុសត្រូវយាមល្បាតនៅតាមបណ្តោយព្រំដែនជាមួយវៀតណាម ។ កងទ័ពក៏ទទួលរងការចាប់ខ្លួន និងសម្លាប់ដូចប្រជាជនស៊ីវិលដែរ ។ ខ្ញុំចាំបានថា នៅថ្ងៃមួយប្រធានកងរបស់ខ្ញុំត្រូវបានចាប់ខ្លួន ។ គេឲ្យខ្ញុំយាមគាត់ ។ ប្រធានកងវរសេនាតូចបានចង្អុលមកខ្ញុំហើយនិយាយថា "ចូលមកយាមមាន់របស់អញ ។" មាន់នោះសំដៅទៅលើប្រធានកងរបស់ខ្ញុំ ។ នៅពេលខ្ញុំដើរចូលទៅក្នុងបន្ទប់ ខ្ញុំបានឃើញប្រធានកងរបស់ខ្ញុំឈ្មោះ ភ័ក្រ ត្រូវបានចាប់ចង ។ ខ្ញុំអាណិតគាត់ខ្លាំងណាស់ ។ យើងធ្លាប់រស់នៅជាមួយគ្នា និងជាមិត្តភក្តិជិតស្និទ្ធ ។ ខ្ញុំបានបន្ធូរចំណងដៃរបស់គាត់ និងបានហុចបារីមួយដើមឲ្យគាត់ ។ ខ្ញុំប្រាប់គាត់កុំឲ្យរត់ បើមិនអ៊ីចឹង ខ្ញុំក៏មិនរស់ដែរ ។ យើងបានជជែកគ្នាមួយសន្ទុះ ។ គាត់បាននិយាយថា គាត់មិនចង់ឲ្យខ្ញុំស្លាប់ជាមួយគាត់ទេ ។ គាត់បានត្រៀមខ្លួនស្លាប់រួចហើយ ។ ក្រោយមក ខ្ញុំបានធ្វើអាហារខ្លះឲ្យគាត់ហូប និងបានឲ្យបារីគាត់ប៉ុន្មានដើមបន្ថែមទៀត ។ នៅប្រហែលម៉ោង៦ល្ងាច ពេជ្ឈឃាតបានមកបណ្តើរគាត់ចេញទៅប្រហែលចម្ងាយពីររយម៉ែត្រពីភូមិ ។ ពួកគេបានបាញ់គាត់ពីក្រោយខ្នងបីគ្រាប់ ។ ប្រហែលមួយម៉ោងក្រោយមក ខ្ញុំបានដើរទៅកាន់កន្លែងកើតហេតុ ហើយ

បានឃើញសាកសពរបស់គាត់នៅទីនោះ ។ ខ្មែរក្រហមមិនទាំងស្រាយចំណងគាត់ចេញផង ។ ខ្ញុំបានកាត់ខ្សែចំណងចេញពីកដៃរបស់គាត់ ។ ខ្ញុំអាណិតគាត់ខ្លាំងណាស់ ។[៣៨៣]

## ម្នាក់រត់គេចខ្លួន ម្នាក់ទៀតតាមស្វែងរក

ប្តីរបស់ខ្ញុំ គឺជាអ្នកយាមមួយរូបនៅចម្ការដូង ។ គាត់មាននាទីមើលការខុសត្រូវលើក្មេងៗនៅទីនោះ ។ នៅឆ្នាំ១៩៧៩ យើងបានបែកគ្នានៅក្នុងពេលចលាចលរត់គេចពីការឈ្លានពានរបស់វៀតណាម ។ ក្រោយមកយើងបានជួបគ្នា ហើយបានរត់គេចខ្លួនទៅកន្ទួតត្រពាំងជង ។ នៅពេលទៅដល់ទីនោះ ខ្មែរក្រហមបានបញ្ជូនស្ត្រីទាំងអស់ទៅកាន់ភូមិថ្មី ។ តាម៉ុក បានបញ្ជូនប្តីរបស់ខ្ញុំទៅកាន់តំបន់ផ្សេង ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យខ្ញុំទៅតាមប្តីរបស់ខ្ញុំទេ ។ ចាប់តាំងពីថ្ងៃនោះមកយើងបានបែកគ្នា ហើយ មិនដែលបានឮដំណឹងពីគាត់ម្តងទៀតទេ ។

នៅពេលដែល ជួបសាច់ញាតិរបស់ខ្ញុំ គេបានប្រាប់ថា ប្តីរបស់ខ្ញុំបានមករកខ្ញុំ ។ ប៉ុន្តែ តើយើងអាចរកគ្នាឃើញដោយរបៀបណា បើម្នាក់កំពុងតែរត់គេចខ្លួន ហើយម្នាក់ទៀតកំពុងតែតាមស្វែងរក ជាលទ្ធផលយើងទាំងពីរបានបែកគ្នាជារៀងរហូត ។

ខ្ញុំជឿថា ប្តីរបស់ខ្ញុំប្រហែលជាស្លាប់ដោយសារការអត់ឃ្លានជាយូរមកហើយ ។ គាត់គឺជាមនុស្សពិការជើងម្ខាង ហើយមិនអាចយកម្ហូបអាហារតាមខ្លួនបានទេ ។ ខ្ញុំបានឮប្រជាជនដែលស្គាល់គាត់និយាយថា ប្តីរបស់ខ្ញុំហូបតែផ្លែឈើប៉ុណ្ណោះ ។ នៅក្នុងព្រៃពុំមានអង្ករហូបទេ ។ កូនក្មេងក៏ត្រូវតែស្ពាយអង្ករ និងដាំបាយហូបដែរ ហើយយើងហូបជុំគ្នា ។ ក្រោយមកប្តីរបស់ខ្ញុំត្រូវបានបំបែកចេញពីកុមារទាំងនោះ ។ មិនមានអ្នកណាម្នាក់ជួយស្ពាយ ឬចម្អិនអាហារឲ្យគាត់ទៀតទេ ។ ដូច្នេះ គាត់ប្រហែលជាគ្មានអ្វីហូបទេ ។

ខ្ញុំបានឮប្រជាជនមួយចំនួន ដែលជួបគាត់និយាយថា ពួកគេបានអនុញ្ញាតឲ្យប្តីរបស់ខ្ញុំរស់នៅជាមួយ ប៉ុន្តែ ប្តីរបស់ខ្ញុំមិនព្រមព្រោះគាត់ចង់ស្វែងរកខ្ញុំ ។

នៅពេលនោះ ខ្ញុំមានទម្ងន់កូនរបស់គាត់ ដែលជាកូនដំបូងរបស់យើង ។ ខ្ញុំពុំមានអាហារហូបគ្រប់គ្រាន់ទេប៉ុន្តែ ខ្ញុំនៅតែមានកម្លាំងនៅឡើយ ។ ទោះបីខ្ញុំមិនមានអ្វីហូបក៏ដោយ ខ្ញុំនៅតែអាចបន្តដំណើរទៅព្រំដែនថៃ និងឡើងភ្នំចុះភ្នំ ទោះបីខ្ញុំកំពុងមានទម្ងន់ក៏ដោយ ។ ប៉ុន្តែ នៅពេលទៅដល់គ្រាង នៅខែកក្កដា ឆ្នាំ១៩៧៩ ខ្ញុំបានសម្រាលកូន ដែល

ទើបតែមានអាយុ៦ខែក្នុងផ្ទៃ ។ បន្ទាប់ពីសម្រាលបានពីរម៉ោងកូនរបស់ខ្ញុំបានស្លាប់ ។ កូននោះយំដូចកង្កែប ហើយមិនមានរូបរាងពេញលក្ខណៈទេ ។ ដៃជើងរបស់វាខ្លីៗ ហើយក្មេងខ្ចីពេក ។ ប្រសិនបើកូននោះមានអាយុ៧ខែក្នុងផ្ទៃវាប្រហែលជាមិនស្លាប់ទេ ។

## ជាប់នៅក្នុងចន្លោះពិភពលោកពីរ

តឿក ស្ថិតនៅក្នុងកងចល័តស្រុករហូតដល់ថ្ងៃដែលវៀតណាមវាយចូលមកក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ ។ គាត់បានវិលត្រឡប់មកភូមិកំណើតវិញ ហើយបានជួបជុំជាមួយក្រុមគ្រួសាររបស់គាត់ ។ ជាសំណាងល្អ គាត់អាចមករស់នៅក្នុងផ្ទះរបស់គាត់វិញបាន ។ កងទ័ពវៀតណាមជាច្រើនកំពុងឈរជើងនៅក្នុងឃុំ ។ គាត់បានចូលបម្រើការជាឈ្លបឃុំរហូតដល់ឆ្នាំ១៩៨៣ ។ នៅពេលគាត់កំពុងប្រូតស្រូវ ខ្មែរក្រហមបានមកចាប់ខ្លួនគាត់ ។ តាម៉ុន នៅកងពល៩៨០ ជាអ្នកចាប់ខ្លួនគាត់ ដោយបានចោទប្រកាន់គាត់ថាជាមនុស្ស“ក្បាលយួនខ្លួនខ្មែរ” ។ គាត់ត្រូវបានបញ្ជូនទៅភ្នំ១០០៣ ដើម្បីដឹកជញ្ជូនគ្រឿងសព្វាវុធឲ្យកងទ័ពខ្មែរក្រហម ដែលប្រចាំការនៅលើភ្នំគូលែននៅស្រុកសូត្រនិគម ។ គាត់រស់នៅជាមួយខ្មែរក្រហម អស់រយៈពេលកន្លះខែមុនពេលត្រូវបានដោះលែងឲ្យត្រឡប់ទៅផ្ទះវិញ ។ ត្រឡប់មកដល់ផ្ទះវិញ កងទ័ពវៀតណាមបានចាប់គាត់ ដោយចោទគាត់ថាជាភ្នាក់ងារស៊ើបការសម្ងាត់របស់ខ្មែរក្រហម ។ គាត់បានរត់គេចពីការចាប់ខ្លួន និងបានចូលជាមួយខ្មែរក្រហមចាប់ពីពេលនោះមក ។ កងទ័ពវៀតណាមគឺសាហាវឃោរឃៅណាស់ ។ ប្រជាជនមួយចំនួនត្រូវបានកងទ័ពវៀតណាមចាប់ខ្លួន និងត្រូវបានបញ្ជូនទៅឃុំឃាំង នៅក្នុងគុកក្នុងឃុំទឹកវិល ។ តឿក បានចូលបម្រើនៅក្នុងអង្គភាពរបស់ តាថេន ។ ជាក់ស្តែង ខ្មែរក្រហមបានធ្វើឲ្យគាត់ក្លាយទៅជាជនរងគ្រោះ ដោយបានធ្វើឲ្យវៀតណាមសង្ស័យថា គាត់ជាភ្នាក់ងារស៊ើបការណ៍របស់ខ្មែរក្រហម ។ ដោយសារតែពុំមានជម្រើស តឿក ត្រូវតែចូលរួមជាមួយខ្មែរក្រហម ពីព្រោះនៅពេលនោះ កងទ័ពវៀតណាមបានសម្លាប់មនុស្សជាច្រើន ដែលត្រូវបានចោទប្រកាន់ថាជាភ្នាក់ងារស៊ើបការណ៍របស់ខ្មែរក្រហម ។[៣៨៤]

## ព្រំដែនដែលមានតែនៅលើក្រដាស

ក្នុងនាមជាជនជាតិថៃមួយរូប មីន ម្យាម ដែលកាលនោះមានអាយុ១៨ឆ្នាំ មិនចង់ចូលរួមជាមួយ កងយោធពលខេមរភូមិន្ទរបស់កម្ពុជានោះទេ ។ ប៉ុន្តែ នៅឆ្នាំ១៩៦៣ នោះ មីន គ្មានជម្រើសនោះទេ ។

មីន កើតនៅភូមិណូឡូហាន ដែលជាភូមិតូចមួយនៅក្នុងទឹកដីថៃ ។ មីន រស់នៅទីនោះដូចកុមារដទៃនៅទីជនបទក្នុងប្រទេសថៃដែរ ។ មីន ជួយធ្វើស្រែចម្ការ ឪពុកម្ដាយ និងការងារដទៃទៀត ។ ជួនកាល មីន ធ្វើដំណើរជាមួយឪពុកម្ដាយឆ្លងកាត់ព្រំដែនទៅប្រទេសកម្ពុជា ដើម្បីទិញរបស់របរផ្សេងៗ ។

ដូចប្រជាជនផ្សេងទៀតនៅក្នុងភូមិដែរ ឪពុកម្ដាយរបស់ មីន ដែលចេះនិយាយតែភាសាខ្មែរប្រកបរបរធ្វើស្រែចម្ការ ។ ឪពុកម្ដាយរបស់គាត់ទំនងជាផ្លាស់ទីពីតំបន់ខ្ពង់រាបនៃប្រទេសថៃតាំងពីមុនពេល មីន កើតម្ល៉េះ ។ ប៉ុន្តែ មីន មិនដែលសួរនាំឪពុកម្ដាយរបស់ខ្លួនថាតើពួកគាត់មកពីណា ហើយជួបគ្នាដោយរបៀបណានោះទេ ។ ប្រហែលជា មីន គិតថាព័ត៌មានទាំងអស់នេះមិនសូវមានសារៈសំខាន់ទេនៅពេលនោះ ។ កាលពីនៅវ័យកុមារក្រោមបញ្ជារបស់រដ្ឋាភិបាលថៃនាពេលនោះ មីន និងក្រុមគ្រួសារបានផ្លាស់ទីលំនៅពីភូមិណូឡូហាន ទៅភូមិណុនដូរាជ ដែលជាភូមិមួយនៅក្បែរព្រំដែនកម្ពុជា ។

មន្ត្រីរដ្ឋាភិបាលថៃតម្រូវឲ្យក្រុមគ្រួសាររបស់ មីន ផ្លាស់ទីលំនៅក្នុងគោលបំណងដើម្បីអភិរក្សព្រៃឈើ ។ ក្រុមគ្រួសាររបស់ មីន មានជម្រើសពីរ ៖ ផ្លាស់ទីលំនៅទៅរស់នៅក្បែរទីរួមខេត្តស៊ីសាកេត ឬទៅនៅភាគខាងត្បូង ។ ក្រុមគ្រួសាររបស់ មីន បានសម្រេចចិត្តទៅនៅភាគខាងត្បូង ពីព្រោះដីនៅភាគខាងលើខេត្ត ស៊ីសាកេត ជាតំបន់ស្ងួតហួតហែងនិងដីពុំសូវមានជីជាតិ ។ ភូមិណុនដូរាជនេះ អនុញ្ញាតឲ្យ មីន និងក្រុមគ្រួសារអាចធ្វើដំណើរឆ្លងកាត់ព្រំដែនទៅកាន់អន្លង់វែង ដើម្បីទិញរបស់របរផ្សេងៗបាន ។

ដំណើរឆ្លងព្រំដែនដ៏សាមញ្ញ ដើម្បីទៅទិញសម្ភារៈនេះ បានផ្លាស់ប្ដូរជីវិតរបស់ មីន យ៉ាងខ្លាំង ។ មន្ត្រីយោធាកម្ពុជាបានប្រកាសប្រាប់ប្រជាជនទាំងអស់នៅអន្លង់វែងថា គ្រប់ក្រុមគ្រួសារទាំងអស់ត្រូវតែស្ម័គ្រចិត្តបញ្ជូនកូនប្រុសវ័យជំទង់របស់ខ្លួន ម្នាក់ឲ្យចូលបម្រើកងទ័ព ។ មីន បានប្រាប់ឪពុកម្ដាយរបស់ខ្លួនថា គាត់ខ្លាចសង្គ្រាមណាស់ ។ ប៉ុន្តែម្ដាយរបស់ មីន បានបញ្ចុះបញ្ចូល មីន ថា ការចូលបម្រើកងទ័ព គ្រាន់តែមួយរយៈពេលខ្លី

តែប៉ុណ្ណោះ ហើយប្រាក់ខែកងទ័ពនឹងអាចជួយសម្រាលបន្ទុកគ្រួសារបាន ។

មីន ដឹងច្បាស់ថាខ្លួនមិនមានជម្រើសច្រើនទេ ហើយខ្លួនក៏មិនមានលិខិតគតិយុត្តអ្វីដែលអាចបញ្ជាក់ថាខ្លួនជាជនជាតិថៃបានដែរ ។ ទោះបើជា មីន មានក៏ដោយ ក៏អារម្មណ៍បានប្រាប់ មីន ថាមិនអាចនិយាយអ្វីបានទេ ។ នៅពេលនោះ ទោះបីជាសហគមន៍ខ្មែរនិងថៃ មានចំណុចត្រួតស៊ីគ្នាអស់ជាច្រើនជំនាន់ តាមរយៈការរៀបអាពាហ៍ពិពាហ៍ឆ្លងសាសន៍ និងទំនាក់ទំនងឆ្លងដែនក៏ដោយ ក៏បញ្ហាសញ្ជាតិគឺជាប្រធានបទរសើបមួយ ។ ដូចដែល មីន បានលើកឡើង«ប្រសិនបើខ្ញុំ ប្រាប់ពួកគេថា ខ្ញុំជាជនជាតិថៃ ពួកគេនឹងសម្លាប់ខ្ញុំ ។»

ដោយសារតែការរស់នៅចំទីកន្លែង និងពេលវេលាមិនសមស្រប មីន ត្រូវបានកេណ្ឌឲ្យចូលបម្រើក្នុងកងទ័ពកម្ពុជា ។ ជំរំកងទ័ពតូចនេះមានកងទ័ពប្រហែលជា១០០នាក់នៅក្នុងអង្គភាព ។ គោលបំណងសំខាន់របស់អង្គភាព នៅដើមទសវត្សរ៍ ឆ្នាំ១៩៦០ ផ្តោតសំខាន់ទៅលើការថែរក្សាសន្តិសុខនៅក្នុងតំបន់ ដែលជាទីតាំងឆ្លងកាត់របស់ក្រុមចោរប្លន់ ក្រុមកុម្មុយនីស្ត និងក្រុមប្រដាប់អាវុធផ្សេងៗ ។[៣៨៥]

## «ភ្នាក់ងារស៊ើបការណ៍សម្ងាត់»

ខ្ញុំរស់នៅក្នុងភូមិ និងបានរៀនសូត្ររហូតដល់ឆ្នាំ១៩៧២ ។ ខ្ញុំបានធំដឹងក្តីល្មមអាចនឹងចូលបម្រើកងទ័ពខ្មែរក្រហមបាន ប៉ុន្តែ ខ្ញុំធ្វើការនៅក្នុងកងចល័តសហករណ៍រហូតដល់ឆ្នាំ១៩៧៧ ទើបបានក្លាយជាកងទ័ព ។ នៅឆ្នាំ១៩៧៩ ខ្ញុំបានឈប់ធ្វើជាកងទ័ព ហើយបានត្រឡប់មករស់នៅក្នុងភូមិវិញ ក្នុងនាមជាកម្លាំងបម្រុង ។ ខ្ញុំបានរៀបការនៅឆ្នាំ១៩៨៤ និងមានកូន ។ ប៉ុន្តែ នៅឆ្នាំ១៩៨៧ ប្រជាជននៅក្នុងភូមិបានចោទប្រកាន់ខ្ញុំថាជាភ្នាក់ងាររបស់ ប៉ុល ពត ។ ដោយសាររឿងនេះ ខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង ។ ខ្ញុំមានតែម្នាក់ឯង ហើយព្យាយាមបង្ហាញពីភាពស្អាតស្អំរបស់ខ្ញុំ ប៉ុន្តែ ប្រជាជននៅក្នុងភូមិនៅតែមិនជឿខ្ញុំ ។ ខ្ញុំគិតថា ប្រសិនបើខ្ញុំបន្តរស់នៅក្នុងភូមិតទៅទៀត ខ្ញុំមុខជាស្លាប់មិនខាន ។ ដូច្នេះ ខ្ញុំបានសម្រេចចិត្តចាកចេញពីប្រពន្ធ កូន និងសាច់ញាតិ ធ្វើដំណើរទៅព្រំដែនថៃ និងចុះចូលជាមួយ តាម៉ុក នៅឆ្នាំ១៩៨៧ ។ នៅពេលនោះ ខ្ញុំមានកូន៤នាក់ ប៉ុន្តែ ខ្ញុំគ្មានជម្រើសអ្វីក្រៅអំពីការចាកចេញនោះទេ ។ ខ្ញុំមិនដែលបានជួបជុំគ្រួសាររបស់ខ្ញុំ

វិញទេ រហូតដល់ការផ្តាច់ខ្លួនចុះចូលជាមួយរាជរដ្ឋាភិបាល ។[៣៤៦]

## ជនចម្លែកដែលប្រហែលមុខ

ខ្ញុំមិនដែលបានជួបសាច់ញាតិរបស់ខ្ញុំ នៅខេត្តរតនគិរី តាំងពីខ្ញុំមានអាយុ១២ឆ្នាំម៉្លេះ ។ ខ្ញុំជឿថា ឥឡូវនេះ ខ្ញុំមានអាយុ៥៥ឆ្នាំហើយ ។ ខ្ញុំមិនអាចចាំមុខសាច់ញាតិរបស់ខ្ញុំបានទេ នៅពេលខ្ញុំជួបគាត់ក្នុងឆ្នាំ២០១០ ។ ប៉ុន្តែ សាច់ញាតិរបស់ខ្ញុំបានដុតជ្រូកមួយក្បាល ដើម្បីទទួលស្វាគមន៍ការវិលត្រឡប់មកវិញរបស់ខ្ញុំ ។ ពួកគាត់ថែមទាំងបានឲ្យថវិកាខ្ញុំមួយចំនួនសម្រាប់ជាជំនូននៃការវិលត្រឡប់មកវិញរបស់ខ្ញុំទៀតផង ។ ដោយសារខ្ញុំមិនអាចចាំបានថាអ្នកណាជាអ្នកណា យើងបាននិយាយអំពីរឿងរ៉ាវពីកុមារភាពរបស់យើង ដើម្បីជួយឲ្យខ្ញុំនឹកឃើញថា គាត់ត្រូវជាអ្វីនឹងខ្ញុំ ។ ខ្ញុំបានសុំទោសសាច់ញាតិចាស់ទុំរបស់ខ្ញុំ ដែលខ្ញុំមិនអាចចំណាំមុខរបស់គាត់បាន ។ ប៉ុន្តែ ពួកគាត់យល់ថាខ្ញុំចេញពីផ្ទះតាំងពីនៅតូចម៉្លេះ ។ ម្តាយរបស់ខ្ញុំបានជួយខ្ញុំឲ្យចាំពីពូ មីង និងជីដូនជីតារបស់ខ្ញុំ ។ ខ្ញុំបានចំណាយពេលពីរបីថ្ងៃ ស្នាក់នៅផ្ទះរបស់ពួកគាត់ម្នាក់ៗ ។ នៅពេលបាន ជួបមុខពួកគាត់ ខ្ញុំមិនអាចទប់ទឹកភ្នែកបាន ។ ខ្ញុំមានអារម្មណ៍អាឡោះអាល័យផង និងអាណិតខ្លួនឯងផង ។ ខ្ញុំទទួលរងការឈឺចាប់អស់ជាច្រើនឆ្នាំ ដោយមិនទទួលបានភាពកក់ក្តៅពីឪពុកម្តាយ ។[៣៤៧]

## ស្តាយក្រោយ

ក្រឡេកមើលទៅក្រោយវិញ នូវអ្វីដែលបានកើតឡើងនៅពេលនោះ ខ្ញុំគិតថា ខ្ញុំដើរតាមអង្គការ ។ ក្រោយមក ខ្ញុំបានគិតដល់ការផ្សះផ្សា និងបានដឹងថាអ្វីដែលបានកើតឡើងកន្លងមកគឺមិនត្រឹមត្រូវ ។ ទីមួយ វាបានបំផ្លាញប្រទេសជាតិរបស់ខ្ញុំ ហើយទីពីរ វាបានបំផ្លាញខ្លួនខ្ញុំផ្ទាល់ ។ ជាលទ្ធផល ខ្ញុំបានក្លាយជាជនពិការ និងធ្មើស្រែចម្ការ ។ នេះគឺជាការយល់ឃើញរបស់ខ្ញុំ ។ នៅពេលយើងដឹកនាំយើងគិតថា ជាទង្វើត្រឹមត្រូវ ។ ប៉ុន្តែបន្ទាប់ពីសមាហរណកម្ម ខ្ញុំបានគិតអំពីរឿងនេះម្តងទៀត ។ ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំង ។ មនុស្សមួយចំនួនបានប្រព្រឹត្តអំពើមិនល្អ ប៉ុន្តែ ពួកគេអាចកែខ្លួនបាន (ពួកគេអាចក្លាយជាមនុស្សថ្មី) ។ ប៉ុន្តែ សម្រាប់ជនពិការដូចជារូប ខ្ញុំពុំមានអ្វីនៅសេសសល់ទៀតទេ ។ អ្វី

ដែលខ្ញុំបានធ្វើកន្លងមក គឺដើម្បីការពារប្រទេសជាតិរបស់ខ្ញុំ ប៉ុន្តែឥឡូវខ្ញុំបានភ្ញាក់ខ្លួនថា ខ្ញុំគឺជាជនរងគ្រោះ ។[៣៤៨]

## ឡើងភ្នំមួយរយ ចុះភ្នំមួយរយ

ពាក្យចាស់មួយបានពោលថា ដើម្បីធ្វើដំណើរទៅដល់ប្រទេសថៃ មនុស្សម្នាក់ត្រូវ «ឡើងភ្នំមួយរយ ចុះភ្នំមួយរយ» ។ ជាក់ស្តែង ការធ្វើដំណើរពីភ្នំដងរែក ទៅកាន់ប្រទេសថៃបង្ហាញថា ពាក្យចាស់មួយឃ្លានេះពិតជាត្រឹមត្រូវមែន ពីព្រោះយើងត្រូវធ្វើដំណើរឡើងចុះៗជាច្រើនដង ។ ការធ្វើដំណើរត្រូវចំណាយពេលប្រហែលមួយខែ ហើយវាមានការលំបាកខ្លាំងណាស់ ។ នៅពេលយើងចាប់ផ្តើមធ្វើដំណើរទៅប្រទេសថៃ យើងមានគ្នាដែលជាស្ត្រីចំនួនដប់នាក់ ។ ប៉ុន្តែ នៅពេលយើងទៅដល់គោលដៅនៅសល់តែបីនាក់ប៉ុណ្ណោះ ។ នៅពេលយើងចាប់ផ្តើមធ្វើដំណើរក្រុមរបស់យើងមានស្ត្រីវ័យចំណាស់ និងក្មេង ។ នៅតាមផ្លូវសមាជិកក្រុមមួយចំនួន ចាប់ផ្តើមឈឺ និងចង់ឈប់សម្រាក ។ អ្នកដែលអាចបន្តដំណើរទៅមុខបានចេះតែបន្តដំណើរទៅមុខទៀត ។ មុនដំបូង យើងហូបបាយជុំគ្នា ។ ក្រោយមក យើងប្រើឆ្នាំងតែមួយ ហើយហូបអ្វីដែលយើងអាចរកបាន ។ វាគឺជាពេលវេលា ដែលលំបាកវេទនាមួយ ។ សមាជិកគ្រួសារចាប់ផ្តើមបោះបង់គ្នាចោល ។ យើងមិនមានអ្វីនៅសេសសល់សម្រាប់ហូបទេ ។ ប្រសិនបើប្តីឈឺតែប្រពន្ធនៅអាចដើរបាន ប្រពន្ធនឹងបោះបង់ចោលប្តី ហើយបន្តដំណើររបស់ខ្លួន ។ ប្រសិនបើប្រពន្ធឈឺដេកនៅលើកន្ទេលប្តីនឹងបន្តដំណើរទៅមុខ ។ ប្រជាជនចេះតែនាំគ្នាស្រែកថា «យួនជិតមកដល់ហើយ!» ដូច្នេះ យើងប្រឹងដើរទៅមុខ ដោយសារតែឮសូរសំឡេងគ្រាប់កាំភ្លើង នៅពីក្រោយយើង ។ ប្រពន្ធ ឬប្តី អាចត្រូវបានទុកចោលនៅក្បែរដើមឈើ ។ សូម្បីតែកុមារតូចៗក៏ត្រូវម្តាយបោះបង់ចោលដែរ ។ ទារកដែលទើបនឹងកើតបានពីរបីថ្ងៃត្រូវបានបោះបង់ចោល ហើយស្រែកយំយ៉ាងឮនៅក្នុងអង្រឹង ។[៣៤៩]

## ការតស៊ូ

អង្គ កើតនៅភូមិកប ឃុំបឹងចក ក្នុងខេត្តរតនគិរី ។ គាត់គឺជាជនជាតិទំពួន ។ នៅឆ្នាំ ១៩៧៧ អង្គ ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅពេទ្យតំបន់ ។ ពីម ដែលជាប្រធានពេទ្យ

តំបន់ ត្រូវបានហៅទៅទីក្រុងភ្នំពេញ ហើយបាត់ខ្លួនតាំងពីពេលនោះមក ។ នៅក្នុងមន្ទីរពេទ្យ អគ្គ បានបាញ់ថ្នាំកម្ចាត់មូស ។ បាយត្រូវបានដាំលាយជាមួយ ដំឡូង ឬដើមចេក ។ អាហារទាំងនោះមិនគ្រប់គ្រាន់ទេ ។ អគ្គ ធ្វើការនៅក្នុងមន្ទីរពេទ្យបានប្រហែលមួយឆ្នាំ ។ បន្ទាប់មក កងទ័ពវៀតណាមបានចូលមកដល់ ។ អ្នកជំងឺជាច្រើនបានស្លាប់ជារៀងរាល់ថ្ងៃ ។ អគ្គ បញ្ចុះសាកសពអ្នកជំងឺជារៀងរាល់ថ្ងៃ ។ អគ្គ ធ្លាប់បានដឹងអំពីការចាប់ខ្លួនប្រជាជនតែមិនធ្លាប់បានឃើញការសម្លាប់មនុស្សនៅនឹងកន្លែងទេ ។ នៅពេលកងទ័ពវៀតណាមចូលមកដល់ អគ្គ បានរត់គេចទៅទន្លេសេសានជាមួយបុគ្គលិកពេទ្យ និងយោធាដទៃទៀត ។ អ្នកទាំងនោះបានឆ្លងទន្លេទៅប្រទេសឡាវ ។ អ្នកទាំងនោះហូបតែដំឡូងដោយសារតែពុំមានអង្ករតាមខ្លួន ។ អគ្គ បានឃើញហ្វូងដំរីជាច្រើន ។ ប្រជាជននាំគ្នាដុតភ្លើង ដើម្បីកុំឲ្យដំរីចូលមក ។ អគ្គ រស់នៅក្នុងព្រៃប្រហែលមួយឆ្នាំ ។ ដោយសារតែការរស់នៅក្នុងព្រៃលំបាកវេទនាខ្លាំងពេក ស្ត្រីម្នាក់បានសម្លាប់កូនរបស់ខ្លួនពីរនាក់ដោយធ្វើឲ្យកូនទាំងពីរថប់ដង្ហើមស្លាប់ ។[៣៩០]

## មិនមានពិធីបុណ្យសព

នៅឆ្នាំ១៩៧៩ ខ្ញុំបានធ្វើដំណើរទៅដល់ជំរំជនភៀសខ្លួននៅលើទឹកដីថៃ ។ មិនយូរប៉ុន្មាន សក់របស់ខ្ញុំ ចាប់ផ្ដើមជ្រុះ ។ ខ្ញុំជឿជាក់ថា សក់ខ្ញុំជ្រុះអស់ដោយសារ ខ្ញុំឈឺនិងទទួលរងការលំបាកជាច្រើននៅតាមផ្លូវ ។ នៅក្នុងជំរំ បុគ្គលិកជនជាតិបារាំងមិនអនុញ្ញាតឲ្យយើងហូបច្រើនទេ ។ ពីដំបូងគេឲ្យយើងហូបតែត្រីផ្សាធូជាមួយខ្ទឹមបារាំង និងបាយ ។ ដោយសារតែឃ្លានខ្លាំងពេកអ្វីក៏ឆ្ងាញ់ដែរ ។ យើងអាចរកអាហារបន្ថែមបាននៅមន្ទីរពេទ្យ ។ គ្រប់គ្នាមានជំងឺរាកជាទម្ងន់ ។ មនុស្សប្រុសស្រីបាន បន្ទោបង់នៅមុខគ្នាដោយគ្មានការខ្មាសអៀន ។ តាមពិតទៅ ការបរិភោគអាហារទាំងនោះ អាចជួយបញ្ចេញជាតិពុលចេញពីក្នុងរាងកាយមនុស្ស ។ មួយខែក្រោយមក យើងលែងកើតជំងឺរាករូសទៀតហើយ ។ យើងចាប់ផ្ដើមឡើងទម្ងន់ ។ ប្រសិនបើយើងក្រឡេកមើលទៅអតីតកាលវិញ មនុស្សរាប់រយនាក់បានស្លាប់ជារៀងរាល់ថ្ងៃនៅជំរំស្រះកែវ ។ បុគ្គលិកអន្តរជាតិដែលបម្រើការនៅទីនោះបានយំ ដោយសារតែឃើញមនុស្សជាច្រើនបានស្លាប់ជាបន្តបន្ទាប់ ។ ត្រាក់ទ័រដែលប្រើសម្រាប់ដឹករណ្ដៅកប់សាកសព មិនអាចជីកទាន់ចំនួនមនុស្សដែលស្លាប់

ក្នុងមួយថ្ងៃបានទេ ។ យើងមិនបានប្រារព្ធពិធីបុណ្យសពអ្វីទេ ។ នៅពេលមានមនុស្សស្លាប់ យើងជីករណ្ដៅ ហើយប្រើរទេះដឹកសាកសពយកមកទម្លាក់ចូលក្នុងរណ្ដៅ ។[៣៥១]

# អវសានកថា

ការផ្សះផ្សាគឺជាដំណើរជាបុគ្គល និងក៏ជាបាតុភូតសមូហភាពមួយដែរ ។ ជាការពិត ប្រសិនបើយើងទទួលស្គាល់ថា ការផ្សះផ្សាអាចសម្រេចបាន លុះត្រាតែកិច្ចការនេះចេញពីបេះដូង និងគំនិតរបស់បុគ្គលម្នាក់ៗ យើងនឹងដឹងថា វាគឺជាស្មារតីរបស់បុគ្គលហើយគឺមិនមែនឆន្ទៈរួមនោះទេ ដែលជាគន្លឹះនៃសង្គមក្រោយជម្លោះមួយក្នុងការជម្នះបាននូវអតីតកាលរបស់ខ្លួន ។ នៅពេលដែល គិតអំពីរឿងនេះ នឹកឃើញដល់ទំនាក់ទំនងរវាងទន្លេសាប និងទន្លេមេគង្គ ។

ទន្លេសាប និងទន្លេមេគង្គ មានលក្ខណៈពិសេសខុសពីគេ នៅត្រង់ដំណើរនៃចរន្តខ្សែទឹករបស់ទន្លេទាំងពីរ ។ ទន្លេទាំងពីរប្រសព្វគ្នានៅខាងមុខព្រះបរមរាជវាំងនៅក្នុងរាជធានីភ្នំពេញ ។ នៅពេលដែលទន្លេទាំងពីរប្រសព្វគ្នា ទន្លេសាបមិនបានបាត់បង់លក្ខណៈពិសេសរបស់ខ្លួននោះទេ ។ ដោយសារជំនន់ទឹកភ្លៀងដ៏ឆាប់រហ័សពីទន្លេមេគង្គ ទន្លេសាបបានក្លាយទៅជាប្រព័ន្ធធារាសាស្ត្រដ៏អច្ឆរិយមួយដែលប្រឆាំងទៅនឹងទំនាញផែនដី ដោយប្តូរចរន្តទឹកហូរបញ្ច្រាសទៅលើ ចាក់ចូលទៅក្នុងបឹងទន្លេសាប ដែលជាអាងនេសាទទឹកសាបដ៏ធំបំផុតមួយនៅក្នុងពិភពលោក ។

ការផ្សះផ្សា ប្រៀបបានទៅនឹងភាពប្រសព្វគ្នានៃទន្លេទាំងពីរដូច្នេះដែរ គឺមិនបានបំផ្លាញភាពជាបុគ្គលរបស់មនុស្សម្នាក់ៗនោះទេ ។ ផ្ទុយទៅវិញ ដូចជាទន្លេសាបភាពប្រសព្វគ្នាបានក្លាយទៅជាកត្តាមួយ ដែលផ្តល់អំណាចទៅឲ្យបុគ្គលនៅក្នុងទម្រង់ទាំងឡាយដែលមិនអាចព្យាករណ៍បាន ។

ទោះបីជាយើងសម្លឹងមើលមកស្ថានភាពរបស់យើង ក្នុងនាមជាបុគ្គល ឬជាសមូហភាព ការផ្សះផ្សាមានសារៈសំខាន់សម្រាប់ការរស់នៅប្រកបដោយសមភាព និងជីវិតដែលពេញលក្ខណៈ ។ យើងមិនអាចគេចវេះពីប្រវត្តិសាស្ត្ររបស់យើងបានទេ ទោះជាយ៉ាងនេះក្តី ក៏យើងមិនត្រូវក្លាយទៅជាទាសករនៃប្រវត្តិសាស្ត្រនោះដែរ ។ ប្រវត្តិសាស្ត្រមានភាពត្រួតស៊ីគ្នា ។ ជាញឹកញយមនុស្សបានភ្លេចថា យើងមិនត្រូវបានដកចេញពីប្រវត្តិសាស្ត្រនៃសម័យខ្មែរក្រហមនោះទេ នៅពេលដែលមនុស្សជំនាន់មុនរបស់យើងត្រូវបាន

*ដកចេញពីប្រវត្តិសាស្ត្រនៃសម័យអាណានិគម សង្គ្រាម និងភាពចលាចលសង្គម ។ ទោះជាយ៉ាងនេះក្តី ការផ្សះផ្សាផ្តល់ឲ្យយើងនូវផ្លូវមួយ ដែលយើងអាចចូលរួមចំណែកនៅក្នុងជោគជ័យជាសមូហភាពរបស់ប្រទេសកម្ពុជារបស់យើង ដោយមិនចាំបាច់លះបង់នូវផលប្រយោជន៍របស់បុគ្គល ។ ដូចជាទន្លេសាប និងទន្លេមេគង្គ ។ យើងមិនបានបាត់បង់បុគ្គលភាពរបស់យើងទេ នៅពេលដែលយើងរួបរួមគ្នា ។ ផ្ទុយទៅវិញ នៅពេលដែលយើងទទួលស្គាល់គ្នាទៅវិញទៅមក យើងផ្តល់អំណាចទៅឲ្យជីវិតផ្ទាល់ខ្លួនទៅវិញទៅមក ហើយចូលរួមចំណែកទៅដល់ប្រទេសកម្ពុជាទាំងមូល ។*

*ឆាំង យុ*
*ស្ថាបនិកវិទ្យាស្ថានស្លឹករឹត / នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា*

# រូបភាពក្របមុខ
# ពិធីរៀបការនៅអន្លង់វែងកាលពីដើមទសវត្សរ៍ឆ្នាំ១៩៩០

បន្ទាប់ពីកងទ័ពវៀតណាមចូលមកក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ កងទ័ពខ្មែរក្រហមបានរត់គេចខ្លួនទៅក្នុងព្រៃភ្នំ និងតំបន់ព្រំដែន។ ភ្នំ១០០៣ គឺជាមូលដ្ឋានយោធាដ៏សំខាន់របស់ខ្មែរក្រហម ដែលស្ថិតនៅលើភ្នំដងរែក តាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងនៅមិនឆ្ងាយប៉ុន្មានពីអន្លង់វែងទេ។ ពីមូលដ្ឋានយោធាភ្នំ១០០៣ ខ្មែរក្រហមបានរៀបចំកម្លាំងរបស់ខ្លួនឡើងវិញ និងត្រៀមសម្រាប់ការតស៊ូរយៈពេលវែងមួយប្រឆាំងនឹងកងទ័ពវៀតណាម និងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ នៅទីបំផុតចេញពីទីតាំងនេះ កងទ័ពខ្មែរក្រហមបានវាយដណ្តើមកាន់កាប់ និងចុះមកតាំងទីលំនៅនៅអន្លង់វែង នៅដើមឆ្នាំ១៩៩០ (និងទីតាំងផ្សេងៗទៀត)។ ខ្មែរក្រហមបានរស់នៅតំបន់កាន់កាប់នេះ រហូតដល់មានការធ្វើសមាហរណកម្មចូលមកក្នុងសង្គមកម្ពុជានៅចុងឆ្នាំ១៩៩៨។

ជីវិតនៅអន្លង់វែងពិតជាមានការលំបាក និងគ្រោះថ្នាក់ដូចគ្នាទៅនឹងជីវិតនៅលើភ្នំ១០០៣ដែរ។ ក្នុងនាមជាតំបន់កាន់កាប់មួយ អន្លង់វែងត្រូវបានប្រើប្រាស់ជាទីចំណុចចាប់ផ្តើមដ៏សំខាន់នៃប្រតិបត្តិការកងទ័ព ឈ្លបរបស់ខ្មែរក្រហម នៅក្នុងប្រទេសកម្ពុជា និងក៏ជាទីតាំងដែលរងការវាយប្រហារញឹកញាប់ពីសំណាក់ កងទ័ពរបស់រដ្ឋាភិបាលកម្ពុជាដែរ។ ទោះបីជាស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ និងបរិយាកាសមិនអំណោយផលយ៉ាងណាក៏ដោយ ប្រជាជននៅក្នុងតំបន់អន្លង់វែង បានខិតខំប្រឹងប្រែង នៅពេលដែលស្ថានភាពអំណោយផលដើម្បីផ្សារភ្ជាប់ និងថែរក្សាបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបរបស់ខ្លួន។

បន្ទាប់ពីត្រូវបានទម្លាក់ពីអំណាចនៅឆ្នាំ១៩៧៩ ខ្មែរក្រហមមិនអាចរក្សាគោលនយោបាយមនោគមន៍វិជ្ជាដ៏តឹងរ៉ឹងរបស់ខ្លួនបានទៀតទេ ជាពិសេសគោលនយោបាយដែលទាក់ទងទៅនឹងសហគមន៍ និងជីវិតគ្រួសារ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្មែរក្រហមបានហាមឃាត់មិនឲ្យមានពិធីរៀបការតាមប្រពៃណីខ្មែរ។ ការរៀបការត្រូវបានរៀបចំដោយថ្នាក់ដឹកនាំ និងកម្មាភិបាលខ្មែរក្រហម ដែល

តែងតែតម្រូវឲ្យមានការរៀបការជាក្រុម ដោយមិនសួរខ្វល់ខ្វាយអំពីប្រពៃណី ឬភាពខុសគ្នារបស់បុគ្គលម្នាក់ៗទេ។ មួយរយៈពេលក្រោយមក គោលនយោបាយ និងការអនុវត្តដ៏តឹងរ៉ឹង ដែលត្រូវបានអនុវត្តយ៉ាងទូលំទូលាយទៅលើជីវិតរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានជំនួសដោយទំនៀមទម្លាប់ និងវប្បធម៌ ដែលដូនតាខ្មែរបានអនុវត្តកាលពីអតីតកាល ។ រូបភាពនៅក្របខាងមុខ ដែលបង្ហាញពីស្ត្រីមួយរូបនៅក្នុងសម្លៀកបំពាក់រៀបការ គឺជាឧទាហរណ៍មួយនៃនិន្នាការនេះ ។ ពិធីរៀបមង្គលការរបស់ខៀវ រុំ គឺជានិមិត្តរូបមួយ ដែលមិនត្រឹមតែបង្ហាញអំពីជីវិតតស៊ូប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញអំពីការរស់រានឡើងវិញនៃប្រពៃណីខ្មែរទៀតផង ។ នៅខាងឆ្វេងដៃ មីងរបស់គាត់ កែន នឹម បានជួយរៀបចំពិធីមង្គលការរបស់គាត់ ដែលរួមទាំងការរៀបចំសម្លៀកបំពាក់តាមបែបប្រពៃណីខ្មែរទៀតផង ។ កែន នឹម និងប្តីរបស់គាត់ ណុប សុជាតិ ដែលជាអតីតមេបញ្ជាការកងពល៩៨០ នៅអន្លង់វែង នៅតែចងចាំរយៈពេលនោះ ។ ប្តីប្រពន្ធទាំងពីរបានចូលរួមជាមួយខ្មែរក្រហមនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ និងបានបន្តរស់នៅជាមួយចលនានេះ រហូតដល់កងទ័ពខ្មែរក្រហមសេសសល់ទាំងអស់ ធ្វើសមាហរណកម្មចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៨ ។ កែន នឹម បានទទួលមរណភាពនៅឆ្នាំ២០១៣ ។ ទោះជាយ៉ាងនេះក្តីរឿងរ៉ាវរបស់គាត់ និងរូបថតមួយសន្លឹកនេះ នៅតែជាឧបករណ៍បង្រៀនដ៏មានតម្លៃសម្រាប់កូនចៅជំនាន់ក្រោយៗទៀត ។

## ជីវប្រវត្តិអ្នកនិពន្ធ

### ឌី ខាំបូលី

ឌី ខាំបូលី គឺជាអ្នកដឹកនាំគម្រោងស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងជាអ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ លោកកើតនិងធំដឹកក្តីនៅខេត្តក្រចេះ ដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ។

ឌី ខាំបូលី ចាប់ផ្តើមបំពេញការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាតាំងពីឆ្នាំ២០០៣ ។ សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ ២០០៧ ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា អនុម័តិជាឯកសារយោងដ៏សំខាន់មួយសម្រាប់សិស្សមធ្យមសិក្សានៅទូទាំងប្រទេស ។ ពេលបច្ចុប្បន្នលោកគឺជានាយកសាលាបង្រៀនពីអំពើប្រល័យពូជសាសន៍ ជម្លោះ និងសិទ្ធិមនុស្សនៃវិទ្យាស្ថានស្លឹករឹត ។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកភាសាអង់គ្លេសពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងបរិញ្ញាបត្រ ផ្នែកពាណិជ្ជកម្មពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ។ លោកធ្លាប់បានទៅធ្វើកម្មសិក្សានៅសារមន្ទីរប្រល័យពូជសាសន៍ និងវិទ្យុសំឡេងសហរដ្ឋអាមេរិក នៅរដ្ឋធានីវ៉ាស៊ីនតោន ឌីស៊ី សហរដ្ឋអាមេរិក ។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកកិច្ចការសាកល ហើយបច្ចុប្បន្នកំពុងបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យរ៉ាត់ហ្គ័រ សហរដ្ឋអាមេរិក ។

### គ្រីស្តូហ្វ័រ ឌៀរីង

គ្រីស្តូហ្វ័រ ឌៀរីង បានបម្រើការនៅវិទ្យាស្ថានស្លឹករឹត និងមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងនាមជាទីប្រឹក្សាផ្នែកច្បាប់និងអប់រំ និងជាអ្នកស្រាវជ្រាវតាំងពីឆ្នាំ២០០៧ ។ ក្នុងនាមជាទីប្រឹក្សាផ្នែកអប់រំ គ្រីស្តូហ្វ័រ បានបោះពុម្ព (ជាមួយសហអ្នកនិពន្ធ បណ្ឌិត ជា ផល្លា) សៀវភៅណែនាំសម្រាប់គ្រូបង្រៀន ៈ វិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តល់វិធីសាស្ត្របង្រៀនជាច្រើនដល់លោកគ្រូ

អ្នកគ្រូនៅទូទាំងប្រទេស ដើម្បីបង្រៀនពីអំពើប្រល័យពូជសាសន៍ ។ ក្រោមការឧបត្ថម្ភគាំទ្រពីមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានតាក់តែងជិពូកមួយស្តីអំពីឧក្រិដ្ឋកម្មនៃការជម្លៀសដោយបង្ខំ និងព្រឹត្តិការណ៍ ដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ ។ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសាលក្រមកាត់ទោសជនជាប់ចោទនៅក្នុងសំណុំរឿង០០២ដំណាក់កាលទីមួយ ដោយបានយល់ស្របដាក់ជំពូកនេះជាគម្រោងសំណាងមួយ ។

ក្រៅពីបម្រើការងារនៅក្នុងប្រទេសកម្ពុជា លោក គ្រីស្តូហ្វ័រ ក៏បានធ្វើការនៅក្នុងវិស័យជាច្រើនដូចជា រដ្ឋាភិបាល យោធា មនុស្សធម៌ និងការវិនិយោគអន្តរជាតិ ។ លោកសូមឧទ្ទិសសៀវភៅនេះជូនចំពោះម្តាយរបស់លោក គឺអ្នកស្រី អេនគ្រេ ឌៀរីង ។

# ចំណងជើងរូបថត

ទំព័រ៧ ផែនទីតំបន់អន្លង់វែង បោះពុម្ពផ្សាយដោយមានការអនុញ្ញាតពីក្រសួងទេសចរណ៍ ។

ទំព័រ១៣ ផែនទីព្រំដែនកម្ពុជា-ថៃ ផលិតដោយគណៈកម្មការកំណត់ព្រំដែនបារាំងនៅឥណ្ឌូចិន និងសៀម រៀបរៀងដោយ អនុសេនីយ៍ឯក Kerler (កងទ័ពជើងគោកអាណានិគម) និង អ៊ុំ (កងទាហានបារាំង បរទេស) បោះពុម្ពផ្សាយដោយក្រុមហ៊ុននិពន្ធផ្នែកភូមិសាស្ត្រ H. Barrere) បោះពុម្ពឡើងវិញ ដោយមានការអនុញ្ញាតពីក្រសួងទេសចរណ៍ ។

ទំព័រ១៨ ផែនទីព្រំដែនកម្ពុជា-ថៃ (មើលពីខាងលិច) ។ ផលិតឡើងវិញដោយមានការអនុញ្ញាតពីក្រសួងទេសចរណ៍ ។

ទំព័រ៥២ ផែនទីតំបន់រំដោះរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៧៩ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ៥៣ ខ្មែរក្រហមកំពុងធ្វើដំណើរឆ្លងចូលប្រទេសថៃនៅឆ្នាំ១៩៧៩ បន្ទាប់ពីត្រូវបានបណ្ដេញចេញដោយកងទ័ពវៀតណាម (រូបថតដោយ Jack Dunford, បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ៧៨ តំបន់កាន់កាប់ និងប្រតិបត្តិការយោធារបស់ខ្មែរក្រហមពីឆ្នាំ១៩៧៩ ទៅឆ្នាំ១៩៨៩ ។ (រចនាផែនទីដោយ លី កុកឆាយ, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា) ។ ផែនទីនេះបង្ហាញអំពីតំបន់កាន់កាប់ និងទីបញ្ជាការសំខាន់ៗរបស់ចលនាខ្មែរក្រហម ដែលត្រូវបានរៀបចំឡើងទៅតាមកិច្ចការសេដ្ឋកិច្ច យោធា និងនយោបាយ ។ ពីភ្នំ១០០១ ភ្នំ១០០២ និងភ្នំ១០០៣ កម្លាំងទ័ពឈ្លប ភ្នាក់ងារស៊ើបការណ៍ និងអ្នកធ្វើវិទ្ធង្សនា ត្រូវបានបញ្ជូនឲ្យទៅធ្វើប្រតិបត្តិការនៅទូទាំងប្រទេស ។

ទំព័រ៨១ តារាងនេះយកលំនាំតាមតារាងរចនាសម្ព័ន្ធយោធា ដែលរៀបរៀងឡើងដោយខ្មែរក្រហម ដើម្បីរាយការណ៍ទៅឲ្យអ៊ុនគាត់ នៅឆ្នាំ១៩៩១ ។ ខ្មែរ

ក្រហមកែងបន្ទំឈ្មោះកងពល និងឈ្មោះរបស់មេបញ្ជាការកងពល ។ អ្នកនិពន្ធរៀបចំតារាងនេះឡើងវិញ ដោយផ្អែកលើទិន្នន័យពីបទសម្ភាសជាមួយអតីតកងទ័ព និងកម្មាភិបាលខ្មែរក្រហមជាងបីរយនាក់ ។ កងពលពីរ (កងពល៨០១ និងកងពល៩០២) គឺជាអតីតកងពលពីសម័យឆ្នាំ១៩៧៥-១៩៧៩ ។ កងពលមួយចំនួនត្រូវបានបង្កើតឡើងក្រោយឆ្នាំ១៩៧៩ និងមួយចំនួនទៀតត្រូវបានបង្កើតឡើង ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ។

ទំព័រ៨៣ សៀវភៅរៀនលេខរបស់ខ្មែរក្រហម សម្រាប់ថ្នាក់ទីបួន (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ៩៣ ប្រជាជនភូមិខ្ញុំនៅទសវត្សរ៍ឆ្នាំ១៩៨០ ។

ទំព័រ៩៥ កងដឹកជញ្ជូនខ្មែរក្រហមនៅទសវត្សរ៍ឆ្នាំ១៩៨០ ។

ទំព័រ៩៨ សៀវភៅសិក្សាភាសាថ្នាក់ទីពីររបស់ខ្មែរក្រហម, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ទំព័រ១១៥ តំបន់កាន់កាប់យ៉ាងរឹងមាំ និងប្រតិបត្តិការយោធារបស់ខ្មែរក្រហម ពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩៨ ។ រៀបរៀងដោយ លី កុកឆាយ, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផែនទីនេះបង្ហាញពីតំបន់កាន់កាប់ និងទីបញ្ជាការសំខាន់ៗ នៅប៉ុន្មានឆ្នាំមុនពេលចលនាខ្មែរក្រហមដល់ទីបញ្ចប់ ។ នៅពេលដែលចលនាខ្មែរក្រហមចាប់ផ្តើមបែកបាក់សាមគ្គី បាត់បង់តំបន់ និងទឹកដីដែលធ្លាប់កាន់កាប់ ដោយសារតែការចុះចូលជាមួយរដ្ឋាភិបាល ឬការដកកងទ័ព ការដឹកនាំរបស់ខ្មែរក្រហមចាប់ផ្តើមប្រមូលផ្តុំនៅក្នុង និងជុំវិញតំបន់អន្លង់វែង ដែលក្លាយទៅជា តំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម ។

ទំព័រ១១៦ រូបថតទី១ ៖ រូបថតនៃការដកទ័ពវៀតណាមចេញពីប្រទេសកម្ពុជា, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ទំព័រ១១៦ រូបថតទី២ ៖ រូបថតនៃពិធីដកទ័ពវៀតណាមចេញពីប្រទេសកម្ពុជា ។ រូបខាងស្តាំ នាយករដ្ឋមន្ត្រី ហ៊ុន សែន (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១១៩ ទង់ជាតិរដ្ឋកម្ពុជា ។

ទំព័រ១២០ រូបថតខាងឆ្វេងៈ អន សុភាព កាន់ដៃកូនស្រីជាមួយនឹងក្មេងតូចៗដទៃទៀត នៅអន្លង់វែង (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១២០ រូបថតខាងស្តាំ ៈ ទាហានខ្មែរក្រហមពីររូប (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១២០ រូបថតខាងក្រោម ៈ ពិធីរៀបការមួយនៅអន្លង់វែង (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារ កម្ពុជា) ។

ទំព័រ១២៤ រដ្ឋាភិបាលបណ្តោះអាសន្នកម្ពុជាប្រជាធិបតេយ្យ (១៩៩៤-១៩៩៨) (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៣២ វិទ្យាល័យអន្លង់វែងៈ អគារធំមួយខ្នងនៃវិទ្យាល័យនេះ ត្រូវបានកសាងឡើងដោយ តាម៉ុក (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។

ទំព័រ១៣៣ មន្ទីរពេទ្យស្រុកអន្លង់វែងៈ "មន្ទីរពេទ្យ តាម៉ុក" ។ ទីតាំងមន្ទីរពេទ្យអាចមើលឃើញទេសភាពដ៏ស្ងប់ស្ងាត់នៃបឹងអន្លង់វែង (បឹងរបស់ តាម៉ុក) និងផ្ទះរបស់ តាម៉ុក ។ មន្ទីរពេទ្យនេះស្ថិតនៅប្រហែលមួយ គីឡូម៉ែត្រពីវិទ្យាល័យអន្លង់វែង ។ តាម៉ុក បានសាងសង់មន្ទីរពេទ្យនេះ នៅឆ្នាំ១៩៩៤ ជាអំណោយសម្រាប់សហគមន៍អន្លង់វែង ។ មន្ទីរពេទ្យផ្តល់ការព្យាបាលដល់ទាហានខ្មែរក្រហម ដែលឈរជើងនៅក្នុងតំបន់ ។ យោងទៅតាមអ្នកគ្រប់គ្រងមន្ទីរពេទ្យ មន្ទីរពេទ្យពីមុនត្រូវបានសាងសង់ឡើងពីឈើ និងនៅមិនឆ្ងាយប៉ុន្មានពីមន្ទីរពេទ្យ តាម៉ុក ទេ ។ (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។

ទំព័រ១៣៦ ស្ពានរបស់ តាម៉ុក (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។

ទំព័រ១៣៧ ផ្ទះរបស់ តាម៉ុក នៅលើភ្នំដងរែក (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។

ទំព័រ១៣៨ រូបឆ្វេងខាងលើ ៈ ជាន់ទីបីនៃផ្ទះក្បែរមាត់បឹងរបស់ តាម៉ុក (រូបថត ដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។

ទំព័រ១៣៨ រូបស្តាំខាងលើ ៈ រោងស្បៀងនៅលើទីវាល មើលពីផ្ទះក្បែរមាត់បឹង របស់ តាម៉ុក ។ (រូបថត ដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។

ទំព័រ១៣៨ រូបឆ្វេងខាងក្រោម ៈ ទ្រុងដែកដាក់មនុស្សរបស់ តាម៉ុក ។ (រូបថតដោយ

គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។

ទំព័រ១៣៨ រូបស្តាំខាងក្រោម ៖ ទីតាំងប្រយុទ្ធ ដែលត្រូវបានសង់នៅក្នុងបរិវេណផ្ទះក្បែរ មាត់បឹងរបស់ តាម៉ុក (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។

ទំព័រ១៣៩ បរិវេណព្រៃឈើខាងក្រោយផ្ទះក្បែរមាត់បឹងរបស់ តាម៉ុក ជាមួយនឹងរថយន្ត របស់កងវិទ្យុចល័ត (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ ២០១២) ។

ទំព័រ១៤០ រូបខាងលើ ៖ ជំរំសាយប៊ី (ប្រទេសថៃ) ក្នុងឆ្នាំ១៩៨៧ (រូបថតដោយ Jack Dunford បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៤០ រូបខាងក្រោម ៖ ផ្សារតូចមួយនៅជំរំសាយប៊ី (រូបថតដោយ Jack Dunford បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៥៤ ទីកន្លែងកប់សព សុន សេន ៖ ទីតាំងនេះស្ថិតនៅចំពីមុខផ្ទះមួយ ដែលមាន ចម្ងាយប៉ុន្មានម៉ែត្រប៉ុណ្ណោះពីផ្លូវដី ។ មានដើមឈើតូចមួយជាទីសម្គាល់ ហើយទីតាំងនេះ ហាក់ដូចជាបង្ហាញយ៉ាងច្បាស់ថា ជាទីតាំងកប់សព ដោយ សារពំនូកមួយដែលយើងអាចមើលឃើញពីផ្លូវ ។ ប៉ុន្តែមិនមាន កន្លែងចំណាំ ផ្សេងទៀតទេ ។ (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២)

ទំព័រ១៦០ ទីតាំងតុលាការប្រជាជនរបស់ខ្មែរក្រហម (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។

ទំព័រ១៦៧ ការសម្តែងសិល្បៈមួយនៅអន្លង់វែង ក្នុងឆ្នាំ១៩៩៨ (បណ្ណសាររបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៦៨ រូបខាងឆ្វេង ៖ សមាជិករបស់កម្ពុជាប្រជាធិបតេយ្យ ហ៊ុនស៊ិនប៉ិច និង រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ នៅក្នុងពិធីជប់លៀងឯកជនមួយ កាលពីឆ្នាំ១៩៩៣ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៦៨ រូបខាងស្តាំ ៖ យោធាខ្មែរក្រហមជាមួយក្មួយស្រីរបស់គាត់នៅក្នុងជំរំដែល គ្រប់គ្រងដោយខ្មែរក្រហម ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៧៧ កន្លែងបូជាសព ប៉ុល ពត ។ ឡានអាចធ្វើដំណើរចូលទៅទីតាំងនេះបានយ៉ាង ស្រួល តាមផ្លូវដីមួយ ដែលមានចម្ងាយប្រមាណមួយគីឡូម៉ែត្រកន្លះ ពីទីតាំង របស់តុលាការប្រជាជន ។ ទីតាំងនេះ មានផ្លាកសម្គាល់របស់ក្រសួងទេសចរណ៍

(រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។

ទំព័រ១៨០ ពីធីសមាហរណកម្មដូវការនៅអន្លង់វែង ដែលប្រារព្ធឡើងនៅខែកុម្ភៈ ឆ្នាំ១៩៨៩ ។ រូបថតនេះថតដោយ យុន លី ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៨២ រូបខាងលើ ៖ មាស មុត អតីតប្រធានកងទ័ពជើងទឹក កងពល១៦៤ របស់កម្ពុជាប្រជាធិបតេយ្យ កំពុងដឹងនាំក្បួនដង្ហែសព តាម៉ុក ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៨២ រូបខាងក្រោម ៖ ពិធីដង្ហែសព តាម៉ុក នៅអន្លង់វែង នៅឆ្នាំ២០០៦ ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៨៣ រូបថតចេតិយ តាម៉ុក (កន្លែងកប់សព) ។ ចេតិយនេះមានទីតាំងនៅក្នុងបរិវេណវត្តមួយ ។ នៅពីមុខចេតិយមានស្រះទឹកមួយ ដែលជីកដោយដៃមនុស្ស ។ បើយោងតាមសម្ដីការរបស់ចៅអធិការវត្ត ចេតិយដែលនៅម្ខាងទៀត គឺជាចេតិយរបស់ប្រធានស្ថាបត្យកររបស់ តាម៉ុក ដែលត្រូវបានជឿជាក់ថា ជាមនុស្សដែលស្និទ្ធនឹងគ្រួសារ តាម៉ុក (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២)

ទំព័រ១៨៧ បឹងអន្លង់វែង ថតដោយ អែម សុវណ្ណា នៅខែមេសា ឆ្នាំ២០០២ ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៨៨ រូបថតក្រុមគ្រួសារអតីតខ្មែរក្រហម ថតនៅក្នុងជំរំជនភៀសខ្លួនមួយ ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៨៩ រូបគូស្វាមីភរិយាចំណាស់មួយគូ ថតនៅអន្លង់វែង ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៩១ រូបអតីតកងទ័ពខ្មែរក្រហម ថតនៅអន្លង់វែង ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៩២ រូបថតគ្រួសារអតីតខ្មែរក្រហមកំពុងអង្គុយនៅក្នុងផ្ទះខ្ទមនៅក្នុងជំរំមួយ នៅឆ្នាំ១៩៨៤ ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៩៤ រៀងរាល់ព្រឹកវេលាម៉ោងប្រហែល៧ ច្រកទ្វារព្រំដែនដាំសាង៉ុំ បានបើក

ហើយប្រជាជនកម្ពុជានាំគ្នាធ្វើដំណើរទៅកាន់ផ្សារមួយក្នុងទឹកដីថៃដើម្បីទិញ ឥវ៉ាន់ និងសមារៈផ្សេងៗយកត្រលប់មក ផ្ទះវិញ ។ (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។ ច្រកព្រំដែននេះបើករៀងរាល់ថ្ងៃពីម៉ោង៧ព្រឹក ដល់ម៉ោង៧យប់ ។ យើងសង្កេតឃើញថា ប្រជាជនកម្ពុជា និងអ្នករកស៊ីជាច្រើនបានធ្វើដំណើរចេញចូលច្រកព្រំដែននេះ ដើម្បីទិញផលិតផលពីប្រទេសថៃ ។ ទីផ្សារនៅក្បែរច្រកព្រំដែននេះត្រូវបានបង្កើតឡើងអស់រយៈពេលជាច្រើនឆ្នាំមកហើយ ព្រមទាំងបានក្លាយជាទីតាំងនៃការដោះដូរទំនិញតាមច្រកព្រំដែនអស់ជាច្រើនជំនាន់ ។

ទំព័រ១៩៥ លេនដ្ឋាននៅខាងក្រោសាលាបឋមសិក្សាមួយរបស់ថៃ ដែលសាងសង់ឡើងដើម្បីការពារពីការបាញ់ផ្លោងរបស់កម្ពុជា ។ (រូបថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ឆ្នាំ២០១២) ។ កម្ពុជា និងថៃ បន្តជម្លោះនឹងគ្នាអំពីសិទ្ធរបស់កម្ពុជាក្នុងការគ្រប់គ្រងតំបន់ប្រាសាទព្រះវិហារ ។ ជារឿយៗជម្លោះបានកើតឡើងនៅតាមបណ្តោយព្រំដែន ដោយមានការបាញ់ផ្លោងពីភាគីម្ខាងទៅភាគីម្ខាង ។ នៅពេលមានជម្លោះកើតឡើង រាជរដ្ឋាភិបាលថៃ បានសាងសង់ជម្រកតូចៗជាច្រើនសម្រាប់សាលានៅតាមតំបន់ជម្លោះនោះ ។ បើយោងតាមគ្រូអនុវិទ្យាល័យនៅសាលានោះ នៅពេលនោះកូនសិស្ស និងលោកគ្រូអ្នកគ្រូ បានចូលរួមហ្វឹកហាត់ការពារខ្លួនពីការទម្លាក់គ្រាប់បែក ។

ទំព័រ១៩៩ រូបខាងលើ ៖ អ៊ឹម ចែម និងអ្នកស្រុកអន្លង់វែង ចូលរួមពិធីចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅវិទ្យាល័យអន្លង់វែង ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅឆ្នាំ២០១២ ថតដោយ ហេង ស៊ីនិត ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៩៩ រូបកណ្តាល ៖ សិស្ស និងប្រជាជនស្រុកអន្លង់វែង ចូលរួមពិធីចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅវិទ្យាល័យអន្លង់វែង ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅឆ្នាំ២០១២ ថតដោយ ហេង ស៊ីនិត ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទំព័រ១៩៩ រូបខាងក្រោម ៖ លោក ឆាំង យុ ស្ថាបនិកវិទ្យាស្ថានស្ទីករីត កំពុងនិយាយ

ជាមួយ អ៊ឹម ចែម ។ នៅក្នុងពិធីចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅវិទ្យាល័យអន្លង់វែង ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅឆ្នាំ២០១២ ថតដោយ ហេង ស៊ីនិត ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

# កំណត់សម្គាល់

១ ចាន់ បៃ ដែលជាអ្នកភូមិម្នាក់នៅអន្លង់វែង បាននិយាយថា "ប្រជាជនដែលរស់នៅអន្លង់វែង មានប្រភពមកពីតំបន់ភាគខាងលើប្រទេសថៃ ។" សុខ វណ្ណៈ សម្ភាសជាមួយ ចាន់ បៃ នៅភូមិតាដេវ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១២ (ចាប់ពីនេះទៅហៅកាត់ថា "បទសម្ភាសជាមួយ បៃ") ។ ការអះអាងនេះស្របគ្នាទៅនឹងការអះអាងរបស់អ្នកភូមិថៃ និងប្រភពដែល ត្រូវបានបោះពុម្ពផ្សាយរួចហើយ ។ យោងតាមបទសម្ភាសជាមួយចាស់ៗជនជាតិថៃមួយចំនួន ប្រជាជនភាគច្រើនដែលមកតាំងទីលំនៅនៅខាងទឹកដីថៃនៃព្រំដែន គឺជាប្រជាជន ដែលធ្វើចំណាកស្រុកមក ពីភាគលើនៃ ខេត្តស៊ីសាកេត ប្រទេសថៃ ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា ប្រជាជនដែលមកតាំងទីលំនៅនៅតំបន់អន្លង់វែង អាចជាផ្នែកមួយនៃលំហូរ ពីភាគខាងត្បូងនៃប្រជាជនខ្មែរ ដែលមកពីភាគខាងលើនៃប្រទេសថៃ ។ ដូចដែលលោក ចន ធូលី បានលើកឡើងនៅតែមានវត្តមានជនជាតិខ្មែររាប់សែននាក់ នៅភាគខាងជើងនៃភ្នំដងរែក (ទឹកដីថៃនាពេលបច្ចុប្បន្ន) ។ ប្រភព ៖ ចន ធូលី, បារាំងនៅតាមដងទន្លេមេគង្គ ៖ ប្រវត្តិអាណាព្យាបាលនៅក្នុងប្រទេសកម្ពុជា ១៨៦៣–១៩៥៣, (Lanham, MD., បោះពុម្ព ឆ្នាំ២០០២) ។

២ Sara Stephens "ឧត្តរមានជ័យ ៖ ខេត្តមួយដែលកើតឡើងវិញ" កាសែត ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ ។ Erin Moriarty "ពីរដ្ឋប្រហារទៅកាស៊ីណូ ៖ តំបន់ព្រំដែនខេត្តឧត្តរមានជ័យដែលត្រូវបានបំភ្លេច" កាសែតភ្នំពេញប៉ុស្តិ៍, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០១ ។

៣ សូមអានសៀវភៅរបស់ David Chandler ប្រវត្តិសាស្ត្រប្រទេសកម្ពុជា, ទំព័រ ១២៥ (Boulder, CO., ២០០៨) ដែលបានរៀបរាប់អំពីការគ្រប់គ្រងភូមិនៅកម្ពុជានៅសតវត្សរ៍ទី១៩ ។

៤ David Chandler ប្រវត្តិសាស្ត្រប្រទេសកម្ពុជា, ទំព័រ៤០ ។ "សិលាចារឹកមួយដែលមិនមានកាលបរិច្ឆេទបានបង្ហាញថា ព្រំដែនអាណាចក្ររបស់ព្រះបាទជ័យវរ្ម័នទី៧

លាតសន្ធឹងដល់ប្រទេសចិន ចម្ប៉ា មហាសមុទ្រ និងតំបន់ជួរភ្នំក្រវាញ ដែលប្រហែលជាទឹកដីស្ថិតនៅភាគខាងលិច ។»

៥ Penny Edwards, *កម្ពុជា ៖ ការបង្កើតរដ្ឋមួយ, ១៨៦០-១៩៤៥*, ទំព័រ៤២ (Silkworm Books, ឈៀងម៉ៃ ប្រទេសថៃ, ២០០៧) ។ «នៅក្នុងរយៈពេលពីរទសវត្សរ៍ដំបូងនៃការស្ថិតនៅក្រោមអាណាព្យាបាល ព្រះមហាក្សត្រនៅតែបន្តគ្រប់គ្រងទាំងស្រុងទៅលើរតនាគារ ក៏ដូចជាចម្ការអាភៀន ជលផលកសិដ្ឋានចិញ្ចឹមជ្រូក ល្បែងស៊ីសង និងសម្បទានផ្សេងៗទៀត ។ មិនតែប៉ុណ្ណោះ ព្រះមហាក្សត្រគឺជាម្ចាស់កម្មសិទ្ធិលើទឹកដីទាំងអស់ នៅក្នុងព្រះរាជាណាចក្រទាំងមូល ។»

៦ John Tully, *បារាំងនៅតាមដងទន្លេមេគង្គ ៖ ប្រវត្តិអាណាព្យាបាលនៅប្រទេសកម្ពុជា ១៨៦៣-១៩៥៣*, ទំព័រ៣៩ ។

៧ ប្រភពឯកសារដូចខាងលើ ។

៨ សូមមើល Chandler, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, ទំព័រ១២៥-១២៦ ។ «ភូមិដែលពឹងផ្អែកលើរបរកសិកម្ម និងភូមិដែលនៅក្នុងព្រៃមានទីតាំងឆ្ងាយពីគ្នា ដែលត្រូវចំណាយពេលរាប់ថ្ងៃមុននឹងធ្វើដំណើរទៅដល់ និងស្ថិតនៅឆ្ងាយពីការិយាល័យរបស់អាជ្ញាធរដែនដី ។ នៅក្នុងស្ថានភាពឯកោបែបនេះ ប្រជាជនរស់នៅតាមទម្លាប់ ដោយការចែករំលែកគ្នាពីម្នាក់ទៅម្នាក់ ។»

៩ John Atkinson Hobson, *ចក្រពត្តិនិយម ៖ ការសិក្សាមួយ*, ទំព័រ៣១៣ (Ann Arbor Paperbacks/University of Michigan, ១៩៦៥), ដកស្រង់ចេញពីលោក Charles Metcalf ដែលជាអ្នករដ្ឋការមួយរូបរបស់អាណានិគម អង់គ្លេសប្រចាំនៅប្រទេសឥណ្ឌា ។

១០ ជនជាតិសៀមគឺជាពាក្យមួយដែលត្រូវបានហៅសំដៅទៅលើជនជាតិថៃ នាពេលបច្ចុប្បន្ន ។

១១ David Chandler, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, ទំព័រ១៨៣, បានលើកឡើងអំពីមូលហេតុ ដែលថៃមិនបានប្រឹងប្រែងក្នុងការដាក់អាណានិគម (ឬបណ្ដេញ) ប្រជាជនចេញពីតំបន់នេះ ដោយជ្រើសរើសការគ្រប់គ្រងស្ទើរតែគ្រប់ជាន់ថ្នាក់ជាមួយជនជាតិខ្មែរ ។

១២ John Tully, *បារាំងនៅតាមដងទន្លេមេគង្គ : ប្រវត្តិអាណាព្យាបាលនៅប្រទេសកម្ពុជា ១៨៦៣-១៩៥៣*, ទំព័រ១១ ។

១៣ គ្រីស្ទហ្វ័រ ឌៀរីង សម្ភាសជាមួយ មីន ប្រូយ៉ាម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ។

១៤ James C. Scott, *សិល្បៈនៃការមិនត្រូវបានគ្រប់គ្រង : ប្រវត្តិនៃភាពអនាធិបតេយ្យនៃតំបន់ខ្ពស់រាប នៅអាស៊ីអាគ្នេយ៍*, ទំព័រ៧, (New Haven, CT., ២០០៩) ។ "អស់រយៈពេលជាយូរលង់ណាស់មកហើយ ប្រជាជនផ្លាស់ទីចេញចូលក្នុងរដ្ឋ ។ "ភាពជារដ្ឋ" គឺមិនទៀតទាត់ និងអាចវិលត្រឡប់ក្រោយបាន ។" Ian G. Baird, *ការរស់នៅក្នុងស្ថានភាពអន់ថយ : ជនជាតិភាគតិច និងខ្សែបន្ទាត់ព្រំដែននៅប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍* ។ "តំបន់នៃការតស៊ូ : ជនជាតិព្រៅ និងព្រំដែនអន្តរជាតិរវាងប្រទេសកម្ពុជានិងឡាវ," ទំព័រ១៩និង២៩ (ថ្ងៃទី១៤-១៥ ខែមិនា ឆ្នាំ២០០៨) បានពិភាក្សាអំពីមូលហេតុ ដែលភូមិជនជាតិព្រៅ និងជនជាតិកាវ៉ែត នៅស្រុកសៀមប៉ាង ឆ្លងព្រំដែនពីប្រទេសកម្ពុជាទៅកាន់ប្រទេសឡាវ នៅឆ្នាំ ១៩០៦, ១៩០៩ និង ១៩១២ ដោយសារតែការដំឡើងពន្ធដារនៅក្នុងប្រទេសកម្ពុជាខ្ពស់ជាង បើប្រៀបធៀបទៅនឹងប្រទេសឡាវ ។

១៥ John Tully, *បារាំងនៅតាមដងទន្លេមេគង្គ : ប្រវត្តិអាណាព្យាបាលនៅប្រទេសកម្ពុជា ១៨៦៣-១៩៥៣*, ទំព័រ១៦៨ ។

១៦ ឡុង ដានី សម្ភាសជាមួយ ប៉ុក តឿក នៅភូមិកណ្ដាលក្រោម ឃុំអន្លង់វែង ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា "សម្ភាសជាមួយ ប៉ុក តឿក") ។

១៧ James C. Scott, *សិល្បៈនៃការមិនត្រូវបានគ្រប់គ្រង : ប្រវត្តិនៃភាពអនាធិបតេយ្យនៃតំបន់ខ្ពស់រាបនៅអាស៊ីអាគ្នេយ៍*, ទំព័រ៨ ។ "នៅពេលយើងទទួលស្គាល់នូវលទ្ធភាពដែលថា មនុស្សឃោរឃៅទាំងនោះ មិនមែនគ្រាន់តែនៅទីនោះក្នុងនាមជាតំបន់សេសសល់មួយនោះទេ ប៉ុន្តែ ប្រហែលជាបានធ្វើការជ្រើសរើសទីតាំងនោះ ការរស់នៅតាមបែបប្រពលវប្បកម្ម និងរចនាសម្ព័ន្ធសង្គមយ៉ាងល្អដើម្បីរក្សាបាននូវស្វ័យភាពរបស់ខ្លួននោះបទដ្ឋាន រឿងរ៉ាវប្រកបដោយអារ្យធម៌នៃការវិវត្តសង្គម និងដួលរលំទាំងស្រុង ។"

១៨ David Chandler, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, ទំព័រ១៧៨ ។ "តាមពិតទៅនៅ

ទសវត្សរ៍ឆ្នាំ១៨៩០ បារាំងបានធ្វើការប្រមូលផ្តុំអំណាចទាំងអស់ នៅឥណ្ឌូចិន រហូតដល់បានធ្វើការតែងតាំងអគ្គទេសាភិបាលប្រចាំតំបន់ឥណ្ឌូចិន លោក Paul Doumer (១៨៩៧-១៩០២) ។»

១៩ សូមមើល David Chandler, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, ទំព័រ១៨១ ។ «ការផ្លាស់ប្តូរក្នុងរយៈពេលវែង ដែលអាចមើលឃើញដោយស្រួលពីទស្សនៈរបស់យើង មិនអាចត្រូវបានយល់ដឹងភ្លាមៗនៅតាមស្រុកនោះទេ ។ អ្នករដ្ឋការជនជាតិបារាំង បានរកឃើញទម្លាប់គ្រប់គ្រងបែបចាស់ជាច្រើន ដូចជាការពឹងផ្អែកលើមេដឹកនាំ អំពើហិង្សា លទ្ធិជំនឿនិយម និងអំពើពុករលួយ ដែលនៅតែបន្តកើតមានពីមួយឆ្នាំទៅមួយឆ្នាំ ។ ការិយាល័យរបស់រដ្ឋនៅតែត្រូវបានលក់ដូរបញ្ជីពន្ធត្រូវបានក្លែងបន្លំ ការប្រមូលទិន្នផលស្រូវ នៅតែមិនបានតាមការកំណត់ ។ ប្រជាជននៅតែជឿទៅលើគ្រូអាបធ្មប់ និងមន្តអាគមអូមអាម ។ នៅចុងឆ្នាំ១៩២៣ នៅខេត្តស្ទឹងត្រែង អតីតព្រះសង្ឃមួយអង្គ បានប្រមូលអ្នកគាំទ្រ ដោយបានអះអាងថា ខ្លួនមាន «កង្កែបពណ៌មាសមួយ ដែលអាចនិយាយភាសាមនុស្សបាន» ។ អំពើឆក់ប្លន់បានរីករាលដាល និងមានគ្រោះទុរ្ភិក្ស និងជំងឺឆ្លងជាញឹកញាប់ ដូចជាគ្រុនចាញ់ និងអាសន្នរោគ ។ ភាពខុសគ្នារវាងទីក្រុង និងស្រុកបានស្តែងឡើង កាន់តែច្បាស់នៅដើមសតវត្សរ៍ទី២០ ដែលហាក់ដូចជាមិនបានធ្វើឲ្យមានការអាក់អន់ចិត្តដល់ប្រជាជននៅតាមស្រុកទេ ។ ទោះជាយ៉ាងនេះក្តីអ្នកស្រែចម្ការត្រូវបង់ពន្ធ ដោយកម្លាំងពលកម្ម និងស្រូវដើម្បីការរីកចម្រើន នៅភ្នំពេញ និងដើម្បីផ្តល់ប្រាក់ខែខ្ពស់ដល់មន្ត្រីរដ្ឋការបារាំង ដែលបង្កឲ្យមានការខឹងសម្បារ និងជំរុញឲ្យមានកងកម្លាំងព្រៃ ប្រឆាំងទៅនឹងបារាំង នៅដើមទសវត្សរ៍ឆ្នាំ១៩៥០ និងបានបង្កើតចលនាកុម្មុយនីស្តក្រោយមកទៀត ។»

២០ សំបុត្រច្បាប់ពីកុងស៊ុលបារាំងប្រចាំខេត្តខបុន ទៅឲ្យអាជ្ញាធរបារាំងនៅខេត្តស្ទឹងត្រែង ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩០៨, បណ្ណសារដ្ឋានជាតិកម្ពុជា ។

២១ John Tully, *បារាំងនៅតាមដងទន្លេមេគង្គ : ប្រវត្តិអាណាព្យាបាលនៅប្រទេសកម្ពុជា ១៨៦៣-១៩៥៣*, ទំព័រ៦៧, ឆ្នាំ២០០២, ដកស្រង់ចេញពីឯកសារ AOM Indochine AF 13 Dosier A30 (22) Cambodge ១៨៧៤-១៨៧៥ ។

លិខិតរបស់លោកទេសាភិបាល Krantz ទៅរដ្ឋមន្ត្រីអាណានិគម, ប៉ារីស, ថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៨៧៤ ។

២២ សំបុត្ររបស់លោកបាឡាត់តំបន់វ៉ារីសេង ដែលជាប្រធានប៉ុស្តិ៍ ផ្ញើទៅឲ្យទេសាភិបាលខេត្តម្លូព្រៃ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩០៨ ។ បណ្ណសារដ្ឋានជាតិកម្ពុជា ឯកសារលេខ៣៦៤៨២ ប្រអប់លេខ៣៧២៧ ។

២៣ សំបុត្ររបស់លោកបាឡាត់តំបន់វ៉ារីសេង ដែលជាប្រធានប៉ុស្តិ៍ ផ្ញើទៅឲ្យទេសាភិបាលខេត្តម្លូព្រៃ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩០៨ ។ បណ្ណសារដ្ឋាន ជាតិកម្ពុជា ឯកសារលេខ៣៦៤៨២ ប្រអប់លេខ៣៧២៧ ។

២៤ លិខិតរបស់លោក Salabelle អ្នករដ្ឋការបារាំងប្រចាំខេត្តស្ទឹងត្រែង ផ្ញើទៅឲ្យទេសាភិបាលជាន់ខ្ពស់បារាំងប្រចាំនៅទីក្រុងភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩០៨ ។ បណ្ណសារដ្ឋានជាតិកម្ពុជា ឯកសារលេខ៣៦៤៨២ ប្រអប់លេខ៣៧២៧ ។

២៥ សំបុត្ររបស់លោកបាឡាត់តំបន់វ៉ារីសេង ដែលជាប្រធានប៉ុស្តិ៍ ផ្ញើទៅឲ្យទេសាភិបាលខេត្តម្លូព្រៃ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩០៨ ។ បណ្ណសារដ្ឋានជាតិកម្ពុជា ឯកសារលេខ៣៦៤៨២ ប្រអប់លេខ៣៧២៧ ។ លោកបាឡាត់តំបន់វ៉ារីសេងបានបញ្ជាក់ថា «តំបន់វ៉ារីសេងមិនមែនជាតំបន់មួយ ដែលគួរឲ្យទាក់ទាញទេ ។ សូមស្នើឲ្យមានការផ្លាស់ប្តូរវេនសម្រាប់កងជីវពល ។ យើងគួរតែផ្លាស់ប្តូរកម្លាំងនៅរៀងរាល់៣ខែម្តង ។ ក្រុមទីមួយ គឺជាក្រុមស្ម័គ្រចិត្ត ។»

២៦ សំបុត្ររបស់លោកបាឡាត់តំបន់វ៉ារីសេង ដែលជាប្រធានប៉ុស្តិ៍ ផ្ញើទៅឲ្យទេសាភិបាលខេត្តម្លូព្រៃ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩០៨ ។ បណ្ណសារដ្ឋានជាតិកម្ពុជា ឯកសារលេខ៣៦៤៨២ ប្រអប់លេខ៣៧២៧ ។ មន្ត្រីបារាំងមួយរូបបានពន្យល់ថា «តាមពិតទៅការបោសសំអាតប្រជាជនចេញពីភូមិ មានន័យថា ក្រុមចោរដើរផ្ទុយទៅនឹងផលប្រយោជន៍របស់ខ្លួនពីព្រោះថា ភូមិដែលគ្មានមនុស្សរស់នៅមិនអាចមានអ្វីសម្រាប់ឆក់ប្លន់បានទៀតទេ ។ ដូច្នេះ ហេតុអ្វីបានជាក្រុមចោរប្លន់ទាំងនោះបោះបង់ចោលប្រភពធនធានរបស់ខ្លួនទៅវិញ? ទង្វើនេះអាចជាការខ្វះខាតនូវការគិតពីប្រយោជន៍របស់ខ្លួន និងជាអំពើឆោតល្ងង់ ដែលមិនអាចយល់បាន ។»

២៧ សំបុត្រពីទេសាភិបាលខេត្តម្លូព្រៃទៅកាន់ទេសាភិបាលខេត្តស្ទឹងត្រែង ស្តីអំពី «សេចក្តីរាយការណ៍របស់ អាឃួន» ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩០៨ ។

២៨ គ្រីស្តូហ្វ័រ ឌៀរីង សម្ភាសជាមួយ កំសែ សំ ខេត្តស៊ីសាកេត ប្រទេសថៃ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ។

២៩ ជំងឺអាសន្នរោគ គឺជាជំងឺរាករូស ដែលធ្វើឲ្យរាងកាយរបស់មនុស្សបាត់បង់សារធាតុទឹក ដែលបណ្តាលមកពីការបាត់បង់ជាតិទឹកក្នុងខ្លួនយ៉ាងច្រើន ។ បាក់តេរីនៃជំងឺនេះរីកលូតលាស់នៅក្នុងទឹក ហើយបាក់តេរីនេះអាចត្រូវបាន ចម្លងចូលមកក្នុងខ្លួនមនុស្ស តាមរយៈការបរិភោគទឹក ឬបរិភោគអាហារកខ្វក់ ។ បន្ទាប់ពីបរិភោគអាហារ ឬទឹកដែលកខ្វក់ អ្នកជំងឺមិនទាន់ធ្លាក់ខ្លួន ឈឺភ្លាមៗនោះទេ ប៉ុន្តែអ្នកជំងឺនឹងចាប់ផ្តើមរាករូសជាមួយនឹងបាក់តេរីអាសន្នរោគរយៈពេលពី៧ទៅ១២ថ្ងៃ ។ រោគសញ្ញាបឋមនៃជំងឺអាសន្នរោគ រួមមាន រាករូស ក្អួតចង្អោរ និងកង្វះសារធាតុទឹកក្នុងខ្លួន ។ កង្វះសារធាតុទឹកអាចស្រាល ឬធ្ងន់ធ្ងរអាស្រ័យទៅលើបរិមាណសារធាតុទឹកដែលបានបាត់បង់ ។

៣០ សូមមើលបទសម្ភាសជាមួយ ចាន់ បៃ ។ «កាលពីមុន នៅទីនេះពុំមានទឹកទេ ។ ប្រជាជននៅតំបន់អន្លង់វែងបានជីកអណ្តូងទឹកសម្រាប់ប្រើប្រាស់ និងពឹងផ្អែកទៅលើប្រឡាយទឹក ។»

៣១ ចាន់ បៃ ធ្លាប់រស់នៅភូមិខ្នុរ ឈូកគ្រាវ ព្រៃរនាម និងតាដេវ ។ ម៉ែនពិចិត្រ សម្ភាសជាមួយ ធីន ប៊ិន នៅភូមិតាដេវ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២ (ហៅកាត់ថា «បទសម្ភាសជាមួយ ធីន ប៊ិន») ។ សូមមើលបទសម្ភាសជាមួយ ចាន់ បៃ ។

៣២ វ៉ាន់ថាន់ ពៅដារ៉ា សម្ភាសជាមួយ ឈិត ធី នៅភូមិព្រលាន ឃុំអន្លង់វែង ស្រុកអន្លង់វែង ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា «បទសម្ភាសជាមួយ ឈិត ធី») ។

៣៣ បទសម្ភាសជាមួយ ចាន់ បៃ ។

៣៤ ឡុង ដានី សម្ភាសជាមួយ អ៊ុក សុខ នៅភូមិស្លែងពណ៌ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១២ ។

៣៥ បទសម្ភាសជាមួយ ចាន់ បែ ។

៣៦ ឡុង ដានី សម្ភាសជាមួយ អោម គឿម នៅភូមិកណ្តាលក្រោម ឃុំអន្លង់វែង ស្រុកអន្លង់វែង ទំព័រទី៩ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា “បទសម្ភាសជាមួយ អោម គឿម») ។ យោងតាមប្រជាជននៅក្នុងតំបន់ម្នាក់«ប្រជាជនដែលរស់នៅតំបន់នេះមុនរបបខ្មែរក្រហម (មុនឆ្នាំ ១៩៧៥) បាននាំគ្នាដាំដើមស្វាយ ។» មានការជឿជាក់ថា ដើមស្វាយធំៗ ដែលប្រជាជននាពេលបច្ចុប្បន្នបាននាំគ្នាដាំ អាចមានប្រភពមកពីជំនាន់នោះ ។

៣៧ បទសម្ភាសជាមួយ ឈិត ធី ។

៣៨ សុខ វណ្ណៈ សម្ភាសជាមួយ មី ឆេង នៅភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១២ (ហៅកាត់ថា “បទសម្ភាសជាមួយ មី ឆេង”) ។

៣៩ បទសម្ភាសជាមួយ ឈិត ធី ។

៤០ បទសម្ភាសជាមួយ ចាន់ បែ ។

៤១ បទសម្ភាសជាមួយ មី ឆេង ។

៤២ បទសម្ភាសជាមួយ ចាន់ បែ ។

៤៣ សម្ភាសជាមួយ ធីន ប៊ិន ។

៤៤ John, Tully, *បារាំងនៅតាមដងទន្លេមេគង្គៈ ប្រវត្តិអាណាព្យាបាលនៅប្រទេសកម្ពុជា ១៨៦៣-១៩៥៣*, ទំព័រ៦៧, ដកស្រង់ចេញពីឯកសារ ANC RSC E03, ឯកសារលេខ១៨៩៩២ ប្រអប់លេខ១២៨៦, ទេសាភិបាលប្រចាំនៅខេត្តស្ទឹងត្រែង, Rappo politiques et economiques trimestriels, ១៩១៤-១៩១៩ ។

៤៥ បទសម្ភាសជាមួយ មី ឆេង ។

៤៦ បទសម្ភាសជាមួយ ធីន ប៊ិន ។

៤៧ បទសម្ភាសជាមួយ ឈិត ធី ។

៤៨ ប្រភពដូចខាងលើ ។

៤៩ ផ្នែកខ្លះនៃប្រទេសឡាវក៏ត្រូវបានប្រគល់ឲ្យទៅថៃដែរ ។

៥០ John Tully, *បារាំងនៅតាមដងទន្លេមេគង្គៈ ប្រវត្តិអាណាព្យាបាលនៅប្រទេសកម្ពុជា ១៨៦៣-១៩៥៣*, ទំព័រ៤៦០-៤៦១ ។

៥១ Elizabeth Becker, *នៅពេលដែលសង្គ្រាមរលត់ទៅ*, ទំព័រ៦៩-៧០ (១៩៩៨) ។ John Tully *ជារាំងនៅតាមដងទន្លេមេគង្គ ៖ ប្រវត្តិអាណាព្យាបាលនៅប្រទេសកម្ពុជា ១៨៦៣-១៩៥៣* ។

៥២ ឌី ខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)*, ទំព័រ៦, (ភ្នំពេញ, ២០០៧) ។

៥៣ Ben Kiernan, *តើ ប៉ុល ពត ឡើងកាន់អំណាចដោយរបៀបណា ៖ អាណានិគមនិយម ជាតិនិយម និងលទ្ធិកុម្មុយនីស្តនៅប្រទេសកម្ពុជា, ១៩៣០-១៩៧៥*, ទំព័រ៨៦ និងទំព័រ២៥៨ (New Haven, CT.,២០០៤) បានរៀបរាប់ឈ្មោះខ្មែរឥស្សរៈ ដែលក្រោយមក បានកាន់កាប់មុខតំណែង នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ហេង សំរិន បានក្លាយទៅជាមេដឹកនាំមួយរូបរបស់រដ្ឋាភិបាល ដែលប្រឆាំងទៅនឹងរបបខ្មែរក្រហម ។

៥៤ ឌី ខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)*, ទំព័រ៦, (ភ្នំពេញ, ២០០៧) ។

៥៥ ឌី ខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)*, ទំព័រ៨, (ភ្នំពេញ, ២០០៧) ។ Ben Kiernan, *តើ ប៉ុល ពត ឡើងកាន់អំណាចដោយរបៀបណា ៖ អាណានិគមនិយម ជាតិនិយម និងលទ្ធិកុម្មុយនីស្តនៅប្រទេសកម្ពុជា, ១៩៣០-១៩៧៥*, ទំព័រ១៩៣, បានពិភាក្សាអំពី រឿងរ៉ាវសម្ងាត់ដែល ប៉ុល ពត បានឡើងកាន់អំណាច ។

៥៦ សូមមើល Taylor Owens & Ben Kiernan, "ការទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជា," The Walrus, (Yale University Press : ២០០៦) ។ ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជាបានចាប់ផ្ដើមនៅឆ្នាំ១៩៦៥ ។ មកត្រឹមចុងឆ្នាំ១៩៧០ ។ គ្រាប់បែកប្រហែលកន្លះលានតោនត្រូវបានទម្លាក់មកលើប្រទេសកម្ពុជា ។

៥៧ ប្រភពដូចខាងលើ, ទំព័រ៣៤១-៣៤៤, ៣៥៧-៣៦៨, ពិភាក្សាអំពីការបណ្ដេញកងទ័ព និងប្រជាជនស៊ីវិលវៀតណាមចេញពីប្រទេសកម្ពុជា ។

៥៨ ឌី ខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)*, ទំព័រ១១,

(ភ្នំពេញ, ២០០៧) ។ Taylor Owen & Ben Kiernan, "ការទម្លាក់គ្រាប់បែកលើកម្ពុជា," The Walrus, (Yale University Press : ២០០៦) ។ ចំនួនប្រជាជនដែលស្លាប់ដោយសារការទម្លាក់គ្រាប់បែកមានប្រហែលជាង ១សែន ៥ម៉ឺននាក់ ។

៥៩ ឡុង ដានី សម្ភាសជាមួយ យឹម ឡាហឿ ភេទប្រុស អតីតកងទ័ពខ្មែរក្រហម សម្ភាសនៅភូមិតាដេរ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២ (ហៅកាត់ថា "បទសម្ភាសជាមួយ យឹម ឡាហឿ") ។

៦០ ការផលិតស្បៀងអាហារនៅទូទាំងប្រទេស បានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារការទម្លាក់គ្រាប់បែក និងប្រតិបត្តិការយោធាបានបង្ខំប្រជាកសិករឲ្យរត់ចោលដីស្រែរបស់ខ្លួន និងមកប្រមូលផ្តុំគ្នានៅតាមទីក្រុង ។ សូមមើល Eva Mysliwiec, *ការដាក់ទណ្ឌកម្មទៅលើជនក្រីក្រ ៖ ភាពឯកោរបស់កម្ពុជានៅលើឆាកអន្តរជាតិ*, "របបខ្មែរក្រហម," (Oxford, ១៩៨៨) ។

៦១ កម្មាភិបាលខ្មែរក្រហមនៅអន្លង់វែង បានបង្កើតអង្គភាពសិល្បៈ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់ខ្មែរក្រហម ដើម្បីទទួលបានការជឿទុកចិត្តពីប្រជាជន និងដើម្បីប្រមូលផ្តុំកម្លាំងបន្ថែមទៀតសម្រាប់ចលនារបស់ខ្លួន ។ បទចម្រៀងបដិវត្តន៍ដែលមានប្រជាប្រិយមួយចំនួននៅពេលនោះរួមមាន "ឱ! ពូៗកងឈ្លប!" និង "ឱ! នីរសារដ៏អង់អាច" ។

៦២ សូមមើល David Priestland *ទង់ក្រហម ៖ ប្រវត្តិកុម្មុយនីស្ត*, ទំព័រ៤៨៩-៤៩៥, (NY, ២០០៩) ។

៦៣ សូមមើល Eva Mysliwiec, *ការដាក់ទណ្ឌកម្មទៅលើជនក្រីក្រ ៖ ភាពឯកោរបស់កម្ពុជានៅលើឆាកអន្តរជាតិ* "របបខ្មែរក្រហម" (Oxford, ១៩៨៨) ។ Elizabeth Becker, *បុប្ផាណា* ទំព័រ២៤ (ភ្នំពេញ ពេជពុម្ពកម្ពុជាដេលី, ២០១០) ។ "មានសិទ្ធិតែមួយគត់ គឺសិទ្ធិក្នុងការធ្វើការងារ ។ ក្រៅពីនេះ គឺខុសច្បាប់ទាំងអស់ ។ អារ្យធម៌ និងសង្គមបានបាត់បង់ ។ សាលា និងបណ្ណាល័យត្រូវបានបិទទ្វារ ។ សៀវភៅត្រូវបានហាមឃាត់ ។ ផ្សារត្រូវបានលុបបំបាត់ ក៏ដូចជាភោជនីយដ្ឋាន ហាងកាហ្វេ និងជំនួញឯកជន ។ វត្តអារាមត្រូវបានបិទទ្វារ ។ សាសនាត្រូវបានហាមឃាត់តាមនយោបាយរបស់បដិវត្តន៍ ។ របាំ និងតន្ត្រីខ្មែរដ៏ល្បីល្បាញត្រូវបាន

លុបបំបាត់ ។ សិល្បករបានលាក់អត្តសញ្ញាណរបស់ខ្លួន ។ សិប្បករទាំងប្រុសទាំងស្រី ដែលធ្លាប់ត្បាញសូត្រ និងឆ្លាក់គ្រឿងប្រាក់ ត្រូវបានបញ្ជូនឲ្យទៅធ្វើការតាមវាលស្រែ ។»

៦៤ បន្ទាប់ពីទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តំបន់៣៥ ត្រូវបានប្តូរឈ្មោះទៅជាតំបន់១០៦ និងបន្ទាប់ពីឆ្នាំ១៩៧៧ តំបន់នេះត្រូវបានប្តូរឈ្មោះម្តងទៀតជាតំបន់៤៦វិញ (របស់ភូមិភាគឧត្តរថ្មី) ។

៦៥ បទសម្ភាសជាមួយ ឈិត ធី ។

៦៦ បទសម្ភាសជាមួយ យឹម ឡាហឿ ។ ឡុង ដានី សម្ភាសជាមួយ យ៉ុន សារឿន, ភេទប្រុស, អតីតកងកុមារ, ឃុំអន្លង់វែង ស្រុកអន្លង់វែង, ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា «បទសម្ភាសជាមួយ យ៉ុន សារឿន») ។ ឡុង ដានី សម្ភាស ជាមួយ មូល មេន, ភេទប្រុស, អ្នកភូមិលំទងចាស់, សម្ភាសនៅភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង, ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ។

៦៧ សូមមើលអត្ថបទសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

៦៨ កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ចងក្រងដោយ Stephen R. Heder, ប្រអប់លេខ៣៨, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្មែរស គឺជាកងទ័ពសេសសល់របស់លោកសេនាប្រមុខ លន់ នល់ ។ ដោយទទួលបានជំនួយពីប្រទេសថៃ និងប្រជាជនខ្មែរនៅក្រៅប្រទេស កងទ័ពនេះបានបន្តប្រយុទ្ធជាមួយខ្មែរក្រហមនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ។

៦៩ ឡុង ដានី សម្ភាសជាមួយ ស៊ីន ហួង, ភេទប្រុស, អ្នកភូមិ, សម្ភាសនៅភូមិ តាដេវ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង, ថ្ងៃទី១ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា «បទសម្ភាសជាមួយ ហួង») ។

៧០ បទសម្ភាសជាមួយ ប៉ុក គឿក ។

៧១ សូមអានអត្ថបទសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

៧២ សូមអានអត្ថបទសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

៧៣ សូមអានអត្ថបទសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

៧៤ បទសម្ភាសជាមួយ យឹម ឡាហឿ ។

៧៥ “ឡូពិឃាតភ្នំទ្រង់បាត” ។ សូមអានរបាយការណ៍វាលពិឃាត ដែលត្រូវបានបង្រួបបង្រួមឡើងនៅឆ្នាំ១៩៩៨ ដោយ ផេង ពង្សរ៉ាស៊ី, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។ របាយការណ៍នេះមិនទាន់ត្រូវបានបោះពុម្ពនៅឡើយទេ ។

៧៦ របាយការណ៍ស្តីអំពីទីតាំងរណ្តៅសាកសពខ្មែរក្រហម រៀបរៀងដោយ ផេង ពង្សរ៉ាស៊ី ។ សម្រាប់ព័ត៌មានលំអិត សូមមើលគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា http://www.d.dccam.org/Projects/Maps/List_of_Burial_Site_Most_Updated.pdf (ដកស្រង់នៅថ្ងៃទី១៣ ខែវិច្ឆកា ឆ្នាំ២០១៣) ។

៧៧ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.), សំណុំរឿង០០១, កាំង ហ្គេកអ៊ាវ ហៅ ឌុច, “សាលក្រម”, កថាខ័ណ្ឌទី៦២, សំណុំរឿងលេខ : ០០១-១៨-០៧-២០០៧, អ.វ.ត.ក., អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ។

៧៨ Ben Kiernan, *របប ប៉ុល ពត : ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្រោមរបបខ្មែរក្រហម, ១៩៧៥-១៩៧៩*, ទំព័រ ៣៥៧-៥៨ (New Haven, CT., ២០០៨) ។ ឌី ខាំបូលី, *ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*, ទំព័រ៥៩-៦០, (ភ្នំពេញ, ២០០៧) ។

៧៩ Ben Kiernan, *របប ប៉ុល ពត : ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅកម្ពុជានៅក្រោមរបបខ្មែរក្រហម, ១៩៧៥-១៩៧៩*, ទំព័រ៣៧៣ ។

៨០ David Chandler, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, ទំព័រ២៧២ ។

៨១ Ben Kiernan, *របប ប៉ុល ពត : ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅកម្ពុជានៅក្រោមរបបខ្មែរក្រហម, ១៩៧៥-១៩៧៩*, ទំព័រ៣៧៥ ។

៨២ David Chandler, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, ទំព័រ២៧២ ។

៨៣ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.), សំណុំរឿង០០១, កាំង ហ្គេកអ៊ាវ ហៅ ឌុច, “សាលក្រម”, កថាខណ្ឌទី៧៩, សំណុំរឿងលេខ : ០០១-១៨-០៧-២០០៧, អ.វ.ត.ក., អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ។ សូមមើល Merle L. Pribbenow II នៅក្នុង សៀវភៅរបស់លោក ដែលមានចំណងជើងថា “រឿងរ៉ាវរបស់ឧត្តមសេនីយ៍ប្រាំរូប : ការឈ្លានពាន

របស់វៀតណាមមកលើប្រទេសកម្ពុជា," ទិន្នានុប្បវត្តិប្រវត្តិសាស្ត្រយោធា, ៧០:២, ខែមេសា ឆ្នាំ២០០៦ ។

៨៤ Pribbenow II, "រឿងរ៉ាវរបស់ឧត្តមសេនីយ៍ប្រាំរូប ៖ ការឈ្លានពានរបស់វៀតណាមមកលើប្រទេសកម្ពុជា," ៧០:២ ។

៨៥ សុខ វណ្ណៈ សម្ភាសជាមួយ ញ៉យ គីន, ភេទប្រុស, អតីតបុគ្គលិកពេទ្យតំបន់១០៥, សម្ភាសនៅភូមិទំនប់ថ្មី ឃុំត្រពាំងតាវ ស្រុកអន្លង់វែង, ថ្ងៃទី៣ ខែមេសា ឆ្នាំ ២០១២ ។

៨៦ កងទ័ពខ្មែរក្រហម និងប្រជាជនមួយចំនួនបានឆ្លងទន្លេនៅភូមិព្រះរំកិល ដែលនៅចុងនៃស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ទៅកាន់ស្រុកឆែប ខេត្តព្រះវិហារ ។

៨៧ ឡុង ដានី សម្ភាសជាមួយ ម៉ៅ ឈឿន, ភេទប្រុស, អតីតកងទ័ពនៅក្នុងកងពល ៩២០, សម្ភាសនៅស្រុកអន្លង់វែង, ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា "បទសម្ភាសជាមួយ ឈឿន") ។

៨៨ វ៉ាន់ថាន់ ពោដារ៉ា សម្ភាសជាមួយ សាំង ថាញ់, ភេទប្រុស, អតីតកងទ័ពនៅក្នុងកងពល២៨០, សម្ភាសនៅភូមិលំទងថ្មី ឃុំលំទង ស្រុកអន្លង់វែង, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ (ហៅកាត់ថា "បទសម្ភាសជាមួយ សាំង ថាញ់") ។

៨៩ បទសម្ភាសជាមួយ ឈឿន ។

៩០ ឡុង ដានី សម្ភាសជាមួយ យឹម ដាន់ណា, ភេទប្រុស, បច្ចុប្បន្នជាអភិបាលស្រុកអន្លង់វែង និងជាអតីតនីរសារនៅក្នុងតំបន់១០១, សម្ភាសនៅសាលាស្រុកអន្លង់វែង ខែកុម្ភៈ ឆ្នាំ២០១២ ។ សម្ភាសលើកទីពីរ នៅខែមីនា ឆ្នាំ២០១២ ។ (ហៅកាត់ថា "បទសម្ភាសជាមួយ យឹម ដាន់ណា") ។

៩១ ឡុងដានី សម្ភាសជាមួយ គីម ណន, ភេទប្រុស, អតីតកងទ័ព, សម្ភាសភូមិអូរអង្រែ ឃុំត្រពាំងតាវ នៅស្រុក អន្លង់វែង, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ (ហៅកាត់ថា "បទសម្ភាសជាមួយ ណន") ។

៩២ ឌី ខាំបូលី សម្ភាសជាមួយ ឡេង ដេង, ភេទប្រុស, អតីតកងទ័ពនៅក្នុងកងពល ៨០១, សម្ភាសនៅភូមិថ្នល់បំបែក ឃុំអន្លង់វែង ស្រុកអន្លង់វែង, ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១២ ។

៩៣ ឌី ខាំបូលី សម្ភាសជាមួយ ឯម សារិន បច្ចុប្បន្នជាប្រធានក្រុមប្រឹក្សា ស្រុកត្រពាំងប្រាសាទ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងជាអតីតសមាជិកតំបន់ក្រូចះ (៥០៥) ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ។

៩៤ ប្រភពដូចខាងលើ ។

៩៥ ឡុង ដានី សម្ភាសជាមួយ ចាន់ សាង, ភេទស្រី, អតីតនីរសារតំបន់៤៣, សម្ភាសនៅភូមិថ្នល់បំបែក ឃុំអន្លង់វែង ស្រុកអន្លង់វែង ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា "បទសម្ភាសជាមួយ សាង") ។

៩៦ បទសម្ភាសជាមួយ យ៉ុន សាវឿន ។

៩៧ ម៉ម សុវណ្ណ សម្ភាសជាមួយ ម៉ម រឿម, ភេទប្រុស, អតីតកងចល័ត, សម្ភាសនៅភូមិថ្នល់ទទឹង ឃុំអន្លង់វែង ស្រុកអន្លង់វែង, ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២ ។

៩៨ បទសម្ភាសជាមួយ យ៉ុន សាវឿន ។

៩៩ ឡុង ដានី សម្ភាសជាមួយ សំ ស៊ាន, ភេទប្រុស, អតីតកងទ័ពខ្មែរក្រហម, សម្ភាសនៅភូមិតាដេវ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២ (ហៅកាត់ថា "បទសាម្ភាស ជាមួយ សំ ស៊ាន") ។

១០០ ប្រភពដូចខាងលើ ។

១០១ បទសម្ភាសជាមួយ យឹម ឡាហឿ ។

១០២ បទសម្ភាសជាមួយ ធីន ប៊ិន ។

១០៣ សុខ វណ្ណៈ សម្ភាសជាមួយ ព្រះ យ៉ង់, ភេទប្រុស, អតីតកងទ័ពខ្មែរក្រហមនៅតំបន់១០៦, សម្ភាសនៅភូមិតាដេវ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា "បទសម្ភាសជាមួយ ព្រះ យ៉ង់") ។

១០៤ បទសម្ភាសជាមួយ យឹម ឡាហឿ ។

១០៥ ឡុង ដានី សម្ភាសជាមួយ តូច មុនី, ភេទប្រុស, អ្នកភូមិ, សម្ភាសនៅភូមិតាដេវ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង, ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា "បទសម្ភាសជាមួយ តូច មុនី") ។ និងបទសម្ភាសជាមួយ ស៊ីន ហួង ។

១០៦ បទសម្ភាសជាមួយ ស៊ីន ហួង ។

១០៧ ផែនការក-៥ គឺជាផែនការសន្តិសុខជាតិ ដែលត្រូវបានបង្កើតឡើង ដើម្បីពង្រឹង

ការការពារប្រទេសកម្ពុជា ពីការលុកលុយ និងការវាយប្រហារពីសំណាក់ខ្មែរក្រហម ។ ផែនការនេះត្រូវបានអនុវត្តពីឆ្នាំ១៩៨៤ដល់ឆ្នាំ១៩៨៨ និងមានច្រើនដំណាក់កាល ។ ដំណាក់កាលទីមួយ គឺការកាប់ឆ្ការព្រៃ ដែលមានទំហំរាប់រយគីឡូម៉ែត្រនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ។ ផែនការនេះក៏រួមមានការជីកត្រង់សេ និងការសាងសង់របងឫស្សី ជាមួយនឹងបន្ទាលួសនៅតាមបណ្តោយព្រំដែន ។ គ្រាប់មីនប្រឆាំងមនុស្សរាប់លានគ្រាប់ត្រូវបានដាក់នៅតាមព្រំដែន ។ ផែនការនេះមានគោលបំណង បិទព្រំដែនជាមួយនឹងប្រទេសថៃ ដើម្បីបិទផ្លូវកុំឲ្យកម្លាំងខ្មែរក្រហម និងកម្លាំងប្រឆាំងផ្សេងទៀត អាចជ្រៀតចូលបាន ។ នៅក្នុងផែនការក-៥ ប្រជាជនកម្ពុជារាប់សែននាក់នៅទូទាំងប្រទេស ត្រូវបានតម្រូវឲ្យស្ម័គ្រចិត្ត ដើម្បីគោលបំណងរួមនៅក្នុងការការពារប្រទេសជាតិ ។ ប្រជាជនជាច្រើនបានស្លាប់ដោយសារការអត់ឃ្លាន ការអស់កម្លាំង គ្រាប់មីន និងជំងឺ ។ ប្រជាជនមួយចំនួនធំកើតជំងឺគ្រុនចាញ់ ដោយសារតែលក្ខខណ្ឌរស់នៅមិនល្អ និងការរស់នៅក្បែរតំបន់ព្រៃ ។ បើយោងតាមអ្នកស្រាវជ្រាវ Margaret Slocomb អក្សរ“ក” គឺជាព្យញ្ជនៈខ្មែរដំបូង ដែលមានន័យថា “ការពារ” ហើយលេខ “៥” សំដៅទៅលើយុទ្ធសាស្ត្រការពារទី៥របស់វៀតណាម ។

១០៨ បើយោងទៅតាមទីតាំងភូមិសាស្ត្រ មុំបី ឬទន្លេរពៅ មានទីតាំងនៅតាមបណ្តោយព្រំដែនរវាងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ។

១០៩ សូមមើល Tom Fawthrop និង Helen Jarvis, គេចវេះពីបទប្រល័យពូជសាសន៍? យុត្តិធម៌ ដែលពិបាកសម្រេចបាន និងតុលាការកាត់ទោស មេដឹកនាំខ្មែរក្រហម, ទំព័រ៥២-៦៦, (ទីក្រុងឡុង : Pluto Press, ២០០៤) ។

១១០ វ៉ាន់ថាន់ ពៅដារ៉ា សម្ភាសជាមួយ ឯម អឿន, ភេទប្រុស, អតីតនីរសារតំបន់, សម្ភាសនៅភូមិកណ្តាលក្រោម ឃុំអន្លង់វែង ស្រុកអន្លង់វែង ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា “បទសម្ភាសជាមួយ ឯម អឿន”) ។

១១១ ឡុង ដានី សម្ភាសជាមួយ ស វ៉ុន, ភេទប្រុស, អតីតអ្នកបើកបរបម្រុងនៅក្នុងកងពល៩២០, សម្ភាសនៅភូមិទួលសាលា ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ (ហៅកាត់ថា “បទសម្ភាស ជាមួយ ស វ៉ុន”) ។

ប្រពន្ធរបស់មេបញ្ជាការកងទ័ពទទួលខុសត្រូវលើស្ត្រី និងកុមារនៅក្នុងអង្គភាពរបស់ខ្លួន។ កូនៗរបស់មេដឹកនាំ និងកងទ័ពខ្មែរក្រហមត្រូវបានប្រមូលដាក់មួយកន្លែង ក្រោមការគ្រប់គ្រងរបស់ យាយវីន ដែលជាប្រពន្ធរបស់ មៀច សាន និងជាប្អូនស្រីរបស់ ឱម អាន។ នី,រ៉ុន និង ធឿន ជាសមាជិកនៅក្នុងអង្គភាពថែទាំកូនក្មេងដែលគ្រប់គ្រងដោយ យាយវីន។

១១២ ឡុង ដានី សម្ភាសជាមួយ ធៀប ថេន ភេទប្រុស អតីតកងទ័ពនៅក្នុងកងពល៩២០ សម្ភាសនៅភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង, ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា "បទសម្ភាសជាមួយ ថេន")។

១១៣ ខេត្តចំនួន៧របស់ថៃ ដែលមានព្រំប្រទល់ជាប់ភាគខាងជើង និងភាគខាងលិចនៃប្រទេសកម្ពុជា រួមមាន ឧប៊ុនរាជធានី ស៊ីសាកេត សុរិន្ទ្រ បុរីរុំ ស្រះកែវ ចាន់បុរី និង ត្រាត។

១១៤ នៅពេលខ្មែរក្រហមរត់ទៅព្រំដែនថៃ មន្ទីរក-១៨មានឈ្មោះថាមន្ទីរ៨៧ ដែលក្រោយមក ត្រូវបានប្តូរឈ្មោះទៅជាមន្ទីរ១៣១ ដែលតាមទីតាំងនៅកន្លែងមួយដែលមានឈ្មោះថាអូរស្វស្តី។ មន្ទីរនេះត្រូវបានប្តូរទីតាំង ទៅក្នុងដីថៃ និងត្រូវបានប្តូរឈ្មោះទៅជាមន្ទីរក-១៨ នៅចុងឆ្នាំ១៩៨៤ នៅពេលដែលកងទ័ពវៀតណាមបានធ្វើប្រតិបត្តិការបោសសម្អាតទីតាំងខ្មែរក្រហមនៅតាមព្រំដែន។ ប៉ុល ពត បានជ្រើសរើសបញ្ញវន្តជាច្រើនឲ្យធ្វើការនៅក្នុងមន្ទីរនេះ។ មន្ទីរក-១៨មានអង្គភាពចំនួន៦ គឺ: អង្គភាព២១ (យោធាការប្រយុទ្ធ និងស៊ើបការណ៍សម្ងាត់); អង្គភាព៣១ (ស្ថិតិប្រជាជន); អង្គភាព៤១ (សង្គមកិច្ច និងសុខុមាលភាព); អង្គភាព៥១ (សេដ្ឋកិច្ច ពាណិជ្ជកម្ម និងកសិកម្ម); អង្គភាព៦១ (អប់រំ និងផ្សព្វផ្សាយ) និងអង្គភាព ៧១ (ទំនាក់ទំនងការបរទេស)។ ឡុង ដានី និង ឌី ខាំបូលី សម្ភាសជាមួយ ជិន គឹមថុន, បច្ចុប្បន្នជានាយករដ្ឋបាលស្រុកត្រពាំងប្រាសាទ, សម្ភាសនៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៣។

១១៥ ឡុង ដានី សម្ភាសជាមួយ សំ ភិន, ភេទប្រុស, អតីតកងទ័ពកងពល១៦៤ និងអតីតអ្នកគ្រប់គ្រងឃ្លាំងតាម៉ុកនៅជើងភ្នំ, សម្ភាសនៅភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍

ស្រុកអន្លង់វែង ខែកុម្ភៈ ឆ្នាំ២០១២ (ហៅកាត់ថា “បទសម្ភាសជាមួយ សំភិន”) ។

១១៦ ឡុង ដានី សម្ភាសជាមួយ ជុំ ដួង, ភេទប្រុស, អតីតប្រធានមន្ទីរតំបន់១០៦, សម្ភាសនៅភូមិកោះថ្មី ឃុំអន្លង់វែង ស្រុកអន្លង់វែង, ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា “បទសម្ភាសជាមួយ ដួង”) ។

១១៧ ឡុង ដានី សម្ភាសជាមួយ អ៊ឹម ចែម, ភេទស្រី, អតីតប្រធានគណៈស្រុកព្រះនេត្រព្រះ, សម្ភាសនៅភូមិអូរអង្រ្រែ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង, ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា “បទសម្ភាសជាមួយ អ៊ឹម ចែម”) ។ អ៊ឹម ចែម, របឹម ទុន (ហៅ ភី ភួន ឬ ចៀម) និង ជឹម គឺជាមេដឹកនាំរដ្ឋបាលនៅលើភ្នំ១០០៣ ។ អ្នកទាំងបីទទួលមើលការខុសត្រូវលើប្រជាជន និងគ្រួសារកងទ័ព ។ អ៊ឹម ចែម និង ជាវ វ៉ាន់ (យាយវ៉ាន់) ទទួលខុសត្រូវទៅលើស្ត្រីនៅលើភ្នំ១០០៣ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ និងរហូតដល់ពេលខ្មែរក្រហមចុះពីលើភ្នំដងរែកមកអន្លង់វែងនៅឆ្នាំ១៩៩០ ។ អ៊ឹម ចែម បានធ្វើដំរៀនប្រជាជននៅលើភ្នំ១០០៣ ដើម្បីផ្គត់ផ្គង់ អង្ករ អាហារ និងសម្ភារផ្សេងៗទៀត ។

១១៨ ឌី ខាំបូលី សម្ភាសជាមួយ ប៊ុល សាវ៉ាត់, ភេទស្រី, អតីតបុគ្គលិកពេទ្យ, សម្ភាសនៅភូមិយាងខាងជើង ឃុំអន្លង់វែង ស្រុកអន្លង់វែង, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១២ (ហៅកាត់ថា “បទសម្ភាសជាមួយ ប៊ុល សាវ៉ាត់”) ។ ភូមិទាំងនោះរួមមាន ភូមិ៩៨០ , ៥០ , ៧៨៥ , ៦០ , ៦១៦ , ៨០ , ៩១២ , ៩២ , ១២ និងភូមិ១៨ ។ ភូមិដែលត្រូវបានដាក់ឈ្មោះ តាមមេភូមិរួមមាន ភូមិយាយចែម ភូមិយាយវ៉ាន់ ភូមិតាធៀប និងភូមិអណ្ដែងមុត ។

១១៩ ម៉ម សុវណ្ណ សម្ភាសជាមួយ អ៊ឹម ឃុត, ភេទស្រី, អតីតកម្មកររោងម៉ាស៊ីនកិនស្រូវ, សម្ភាសនៅភូមិព្រលាន ឃុំអន្លង់វែង ស្រុកអន្លង់វែង, ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ (ហៅកាត់ថា “បទសម្ភាសជាមួយ ឃុត”) ។ បទសម្ភាសជាមួយ ធឿន ។

១២០ ឌី ខាំបូលី សម្ភាសជាមួយ កែវ ភ័ក្រ, ភេទស្រី, អតីតអ្នកបម្រើការផ្នែក កសិកម្ម, សម្ភាសនៅស្រុកអន្លង់វែង ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ (ហៅកាត់ថា “បទសម្ភាសជាមួយ ភ័ក្រ”) ។ ឡុង ដានី សម្ភាសជាមួយ យស់ ផាត់, ភេទប្រុស,

អតីតកងទ័ពនៅក្នុងកងពល១១៧, សម្ភាសនៅភូមិ ត្រពាំងតាវ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ (ហៅកាត់ថា "បទសម្ភាសជាមួយផាត់") ។

១២១ នៅក្នុងចំណោមជំរំជនភៀសខ្លួនជាង៥០ ជំរំចំនួន២០ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ជំរំខ្មែរក្រហមចំនួន ៥ (ជំរំបឹងបេង ប្ញុងវ៉ា, ខាវដិន, ណងព្រូ, អូរស្រឡៅ និង តាប់ព្រីក) ត្រូវបានបញ្ចូលទៅក្នុងជំរំលេខ៨ នៅឆ្នាំ១៩៨៥ ។ ជំរំរបស់ខ្មែរក្រហមដែលត្រូវបានស្គាល់ ភាគច្រើនចាប់ពីឆ្នាំ១៩៨៥មក រួមមាន អន្លង់វែង ក្នុងដីខ្មែរ, បូរ៉ៃ ក្នុង ខេត្តត្រាត, ជំរំ៨៥ ក្នុងដីខ្មែរ, ចុងបុក និង ហួយដើង ក្នុងខេត្តស៊ីសាកេត, ណាំយឺន ក្នុងខេត្តឧប៊ុនរាជថានី ជាប់ព្រំដែនខេត្តព្រះវិហារ, អូរត្រាវ ក្នុងខេត្តស៊ីសាកេត, ភ្នំម៉ាឡៃ ក្នុងដីខ្មែរ, ស្រះកែវ និងជំរំលេខ៨ ក្នុងខេត្តស្រះកែវ, ជំរំលេខ៨ខាងជើង ជំរំលេខ៨ខាងលិច និងជំរំ Site K ក្នុងខេត្តត្រាត ជាប់ព្រំដែនខេត្តពោធិ៍សាត់ ។ ជំរំជនភៀសខ្លួនរបស់ខ្មែរក្រហម ដែលនៅមានវត្តមានរហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០ រួមមាន ជំរំលេខ៨ ជំរំ Site K និងជំរំអូរត្រាវ ។

១២២ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១ នៅក្នុងអំឡុងពេលនៃសង្គ្រាមស៊ីវិល នៅក្នុងប្រទេសកម្ពុជា ជំរំជនភៀសខ្លួនជាង៥០ត្រូវបានបង្កើតឡើងនៅក្នុងទឹកដីថៃ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ភាគខាងលិច ពាយ័ព្យ និងភាគខាងជើង នៃប្រទេសកម្ពុជា ដើម្បីផ្តល់ជម្រកដល់ជនភៀសខ្លួនកម្ពុជា និងជនគ្មានទីលំនៅរាប់សែននាក់ ។ អង្គការដែលបានផ្តល់ជំនួយដល់ជំរំជនភៀសខ្លួនទាំងនោះរួមមាន អគ្គស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) អង្គការកាកបាទក្រហមអន្តរជាតិ (ICRC) និងអង្គការសហប្រជាជាតិសម្រាប់ទ្រទ្រង់តាមព្រំដែន (UNBRO) ។ ជាងនេះទៅទៀត មានអង្គការក្រៅរដ្ឋាភិបាល និងអង្គការរបស់រដ្ឋាភិបាលជាច្រើនផ្សេងទៀត ដែលបានផ្តល់ជំនួយដល់ជំរំជនភៀសខ្លួនទាំងនោះ ។ អង្គការទាំងនោះរួមមាន គណៈកម្មាធិការអាមេរិកសម្រាប់ជនភៀសខ្លួន (ARC) សម្ព័ន្ធអ្នកផ្សាយសាសនា និងគ្រិស្តសាសនា (CAMA) ការិយាល័យកាតូលិកសម្រាប់សង្គ្រោះបន្ទាន់ និងជួយជនភៀសខ្លួន (COERR) ក្រុមផ្សព្វផ្សាយគ្រិស្ត

សាសនា (COR) សេវាកាតូលិកសម្រាប់ការជួយសង្គ្រោះ (CRS) អង្គការជនពិការអន្តរជាតិ ជន បូស្កូ (HI) គណៈកម្មាធិការអន្តរជាតិសម្រាប់ការជួយសង្គ្រោះ (IRC) សេវាព្រះយេស៊ូសម្រាប់ជនភៀសខ្លួន (JRS) គណៈកម្មាធិការជួយសង្គ្រោះជប៉ុនសូតូ (JSRC) ក្រុមគ្រូពេទ្យគ្មានព្រំដែន (MSF) អង្គការ CONCERN អង្គការជនភៀសខ្លួនអន្តរជាតិ (RI) សេវាពិភពលោកគ្រិស្តសាសនាប្រាំពីរថ្ងៃ (SAWS) អង្គការ ស៊ីប៉ារ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) និងអង្គការបេសកកម្មយុវជន (YWAM) ។ អង្គការទាំងអស់នេះផ្តល់ជំនួយជាច្រើនប្រភេទ ដែលរួមមានការអប់រំ សេវាថែទាំសុខភាព សេវាជួសជុលជំរំ និងទឹកស្អាត ។ ជំរំជនភៀសខ្លួន ខាវអ៊ីដាង គឺជាជំរំជនភៀសខ្លួនតែមួយគត់ ដែលទទួលខុសត្រូវក្នុងការបញ្ជូនជនភៀសខ្លួនទៅកាន់ប្រទេសទីបី ។ ជំរំជនភៀសខ្លួនមួយចំនួនត្រូវបានបំផ្លាញ ដោយការវាយប្រហាររបស់កងទ័ពវៀតណាមពីឆ្នាំ ១៩៨២ ទៅឆ្នាំ១៩៨៤ ។ ជំរំមួយចំនួនត្រូវបានបិទតាំងពីឆ្នាំ១៩៨៥ និងត្រូវបានបញ្ចូលទៅក្នុងជំរំដែលទើបត្រូវបានបង្កើតថ្មី ។ ជំរំមួយចំនួនផ្សេងទៀត នៅបន្តសកម្មភាពរហូតដល់មានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១ ។ ជំរំមួយចំនួនតូចបានបន្តគាំទ្រជនភៀស ខ្លួនដល់ឆ្នាំ១៩៩៩ ។ ជំរំភូណយ ត្រូវបានបិទនៅដើមឆ្នាំ១៩៩៩ នៅពេលដែលកងទ័ព និងប្រជាជន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តា ម៉ុក ធ្វើសមាហរណកម្មចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

១២៣ ម៉ម សុវណ្ណ សម្ភាសជាមួយ ញឹប ម៉ៅ, ភេទស្រី, អតីតអ្នកបម្រើការនៅក្នុងកងចល័ត, សម្ភាសនៅភូមិយាងខាងជើង ឃុំអន្លង់វែង ស្រុកអន្លង់វែង, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១២ (ហៅកាត់ថា "បទសម្ភាសជាមួយ ម៉ៅ") ។

